លោកអភិបាល អូលីវីយេ ឆ្មីតអឺស្លែរ
Bishop Olivier SCHMITTHAEUSLER



# ព្រះជាម្ចាស់ជាសេចក្ដីស្រលាញ់

# God is Merciful

# មាតិកា
CONTENT

**ចំណងជើងអត្ថបទ - Title** **ទំព័រ-Page**


០១. ចូរមានចិត្តមេត្តាករុណាដូចព្រះបិតា

Merciful like the Father....01

០២. ខ្ញុំហ្នឹងហើយជាទ្វារ អ្នកណាចូលតាមខ្ញុំព្រះជាម្ចាស់នឹងសង្គ្រោះអ្នកនោះ

I am the gate. Whoever enters through me will be saved....04

០៣. យើងបានស្រឡាញ់អ្នកដោយចិត្តស្រឡាញ់ដែលស្ថិតស្ថេរអស់កល្បជានិច្ច

We love you with hearts that love forever....10

០៤. យ៉ូហាន មានន័យថាព្រះជាម្ចាស់មានព្រះហឫទ័យប្រណីសន្ដោស

The martyrs, signs of a forgiving God....15

០៥. ព្រះយេស៊ូជាព្រះសង្គ្រោះ

Jesus is the savior....20

០៦. ចូរនាំគ្នាទៅគ្រប់ទីកន្លែងក្នុងពិភពលោកទាំងមូល

Go into all the world....23

០៧. ព្រះជាម្ចាស់ណែនាំឲ្យយើងឆ្លងទ្វារនៃជំនឿ

God invites us to pass through the door of Faith, Hope, and Love....27

០៨. យើងមើលឃើញព្រះជាម្ចាស់តាមរបៀបព្រះនាងម៉ារី

Mary, the mirror of God's love....34

០៩. ស្វែងរកពន្លឺ និងចេញទៅប្រកាសដំណឹងល្អដូចពួកហោរាចារ្យ

The Three Kings, seeking and revealing the Light....39

១០. ព្រះវិញ្ញាណដ៏វិសុទ្ធជ្រើសរើសយើងឲ្យទៅប្រកាសដំណឹងល្អ

The Holy Spirit has chosen us to proclaim the Good News....44

១១. យើងទទួលជីវិតថ្មីក្នុងព្រះនាមព្រះជាម្ចាស់

We receive New Life in God's Name....50

១២. យើងយកព្រះគ្រីស្ត ព្រះបន្ទូល ព្រះសហគមន៍ជាទីពឹង
Christ the Word and the Church are our refuge.........................................54
១៣. យើងចេញទៅប្រកាសដំណឹងល្អតាមរបៀបដែលព្រះយេស៊ូបង្កើតព្រះសហគមន៍ដើមដំបូង
We proclaim the Gospel as in the Early Church...........................................60
១៤. យើងទទួលស្គាល់ចំណុចខ្សោយរបស់ខ្លួន និងទទួលការលើកលែងទោសពីព្រះជាម្ចាស់
We embrace our weakness and God's forgiveness.......................................64
១៥. ព្រះជាម្ចាស់បានជ្រើសរើសយើងធ្វើជាប្រជារាស្ត្រដ៏វិសុទ្ធ
God chose us to be a Holy People...............................................................69
១៦. ចូរកែប្រែចិត្តគំនិតដោយធ្វើទាន អធិដ្ឋាន និងតមអាហារ ព្រមទាំងបំពេញកិច្ចការមេត្តាករុណាទាំងផ្លូវកាយ និងផ្លូវវិញ្ញាណ
Repent, with prayer, fasting, and practicing the Corporal and Spiritual Works of Mercy.............................................................................73
១៧. ជ្រើសរើសជីវិតគឺទុកចិត្តលើឧបការគុណព្រះជាម្ចាស់
To choose life is to trust Divine Providence.................................................77
១៨. រដូវ៤០ថ្ងៃកែប្រែចិត្តគំនិតថ្មី ដើម្បីរួមដំណើរជាមួយព្រះជាម្ចាស់
Change your life and walk with God.............................................................83
១៩.ព្រះជាម្ចាស់ត្រាស់ហៅយើងឲ្យមើលឃើញ ស្តាប់លឺ យល់ចិត្តគេ និងសម្តែងមេត្តាករុណា
God calls us to see, hear, and understand others, loving them in truth and in deed.............................................................88
២០. សូមឲ្យយើងយកតម្រាប់តាមសន្តយ៉ូហានបូស្កូដោយមានចិត្តស្រឡាញ់មេត្តាករុណា និងយកចិត្តទុកដាក់
With St. John Bosco, let us love and care for our brothers and sisters.............................................................................91
២១. កុំឲ្យយើងធ្វើជាមនុស្សខ្មាស់អៀនមិនហ៊ានទទួលស្គាល់ព្រះយេស៊ូ
Let us not be ashamed to proclaim our God...............................................96

២២. យើងត្រូវលើកលែងទោសឲ្យអ្នកដែលបានធ្វើខុសដល់យើង

Forgive those who trespass against us........................................................100

២៣. យើងជាអ្នកមានបាបដែលបានទទួលការលើកលែងទោសពីព្រះជាម្ចាស់

We are forgiven sinners...........................................................................103

២៤. សន្តយ៉ូសែបជាគំរូសម្រាប់ព្រះសហគមន៍

Joseph, model for the Church.....................................................................109

២៥. ព្រះយេស៊ូបង្ហាញអំពីធម៌មេត្តាករុណារបស់ព្រះបិតា

Jesus, the face of the Father's Love...........................................................114

២៦. នេះជារូបកាយរបស់ខ្ញុំដែលត្រូវបូជាសម្រាប់អ្នករាល់គ្នា

This is my Body given up for you...............................................................118

២៧. ព្រះជាម្ចាស់ទៅជាធ្លុងតែមួយជាមួយទុក្ខលំបាករបស់មនុស្សលោក

God is One with the suffering of the world..................................................122

២៨. យើងជាព្រះដែលមានព្រះជន្មគង់នៅ

I am the God of Life!.................................................................................126

២៩. ពិតមែនសេចក្ដីស្លាប់មិនឈ្នះ ភាពងងឹតមិនឈ្នះ គឺជីវិតនិងពន្លឺដែលឈ្នះ

Really, death and darkness did not win. Life and light have won!.............132

៣០. ទុកចិត្តលើព្រះជាម្ចាស់ ដោយយកគំរូតាមសន្តយ៉ូហានប៉ូលទីពីរ និងសន្តីហ្វូស្ទីណា

We trust God with Saint John Paul II and St. Faustina................................136

៣១. សូមឲ្យយើងធ្វើជាសាក្សីជាក់ស្តែងអំពីវត្តមានព្រះជាម្ចាស់

Let us be true witnesses of God's presence. .............................................142

៣២. ជាអ្នកដឹកនាំត្រូវមើលឃើញ និងយល់អំពីសេចក្តីត្រូវការរបស់គេ

As a leader you have to see and understand the needs................................146

៣៣. យើងមានតួនាទីប្រកាសអំពីវត្តមានព្រះយេស៊ូនៅក្នុងពិភពលោកទាំងមូល

Proclaim the presence of Jesus in the world...............................................149

៣៤. ផ្លូវនៃសុភមង្គល

The way to happiness...............................................................................156

៣៥. យើងទៅជាសញ្ញាជាក់ស្តែង ដើម្បីឲ្យមនុស្សលោកឃើញព្រះយេស៊ូ

We are signs of the presence of Christ......................................................161

៣៦. ព្រះវិញ្ញាណដ៏វិសុទ្ធជាកម្លាំងដើម្បីបំពេញបេសកកម្មអំពីព្រះជាម្ចាស់

The Holy Spirit, our strength!.....................................................................168

៣៧. ចូរក្លាហានក្នុងការផ្តល់សក្ខីភាពអំពីព្រះយេស៊ូ

Be a brave witness of Christ.......................................................................172

៣៨. ព្រះវិញ្ញាណដ៏វិសុទ្ធយាងមក ដើម្បីឲ្យយើងទៅប្រកាសអំពីព្រះរាជ្យព្រះជាម្ចាស់

The Holy Spirit has sent us to announce the Kingdom of God....................176

៣៩. យើងរៀបចំខ្លួនដើម្បីធ្វើជាសាក្សីនៃសេចក្តីពិត

Let us be witnesses of the Truth..................................................................181

៤០. របៀបបម្រើរបស់សន្តយ៉ូហានបាទីស្តដឺឡាសា គឺអប់រំចំណេះដឹង វិញ្ញាណ រូបកាយ និងចិត្ត

St. John the Baptist de la Salle: Knowledge,heart, mind,

and body in the service of God...................................................................187

៤១. ព្រះវិញ្ញាណដ៏វិសុទ្ធនាំឲ្យយើងមានសេចក្តីក្លាហាន ដើម្បីផ្តល់សក្ខីភាព
អំពីព្រះបិតា ដោយយកចិត្តទុកដាក់ និងបម្រើអ្នកដទៃ

In the Spirit, serve God and our brothers and sisters..............................190

៤២. គ្មានកិច្ចការណាដែលព្រះជាម្ចាស់ធ្វើមិនបាននោះទេ

Nothing is impossible for God.....................................................................193

៤៣. ព្រះយេស៊ូនិងព្រះនាងម៉ារីណែនាំអោយយើងស្គាល់ព្រះហឫទ័យស្រឡាញ់របស់ព្រះបិតា

Jesus and Mary, lead us to know the will of God.......................................198

៤៤. ព្រះនាងម៉ារីជាគំរូសម្រាប់ឧបដ្ឋាក

Mary, our model of service.........................................................................202

៤៥. យើងបានទទួលដោយឥតគិតថ្លៃ យើងធ្វើដូចម្តេចដើម្បីឲ្យដោយឥតគិតថ្លៃដែរ

Freely you have received.  Freely give.......................................................207

៤៦. មិនមែនខ្ញុំទេដែលរស់នៅគឺព្រះគ្រីស្តទេតើដែលរស់នៅក្នុងខ្ញុំ

It is no longer I who live but Christ lives in me...........................................211

៤៧. នៅលើផ្ទាំងសិលានេះ ខ្ញុំនឹងសង់ព្រះសហគមន៍របស់ខ្ញុំ

And on this rock I will build my church........................................................214

៤៨. ចុះអ្នករាល់គ្នាវិញថាខ្ញុំជានរណា?

And you, who do you say I am?.....................................................................221

៤៩. យើងត្រូវតែប្រញាប់ប្រញាល់គ្រប់ពេលវេលាដើម្បីប្រកាសដំណឹងល្អ

Proclaiming the Gospel: a permanent emergency.......................................224

៥០. ចូរប្រយ័ត្ននឹងពួកព្យាការីក្លែងក្លាយ

Beware of false prophets! Be Holy Apostles!............................................228

៥១. ខ្ញុំជាយ៉ូហានបាទីស្ទ

I am John the Baptist!.......................................................................................232

៥២. តើខ្ញុំទៅជាមនុស្សយ៉ាងណា?

Who will I Become?...........................................................................................235

៥៣. ព្រះសហគមន៍ត្រូវការអ្នកបម្រើចេញពីទឹកដីយើង

The Church needs servants here on earth..................................................239

៥៤. ព្រះយេស៊ូជ្រើសរើសយើងឲ្យធ្វើជាមិត្តសម្លាញ់របស់ព្រះអង្គ

Christ has chosen us to be his friends.......................................................243

៥៥. មានតែអ្នកជំងឺប៉ុណ្ណោះដែលត្រូវការគ្រូពេទ្យ

It is not the healthy who need a doctor but sick..........................................247

៥៦. ព្រះជាម្ចាស់មានព្រះហឫទ័យប្រណីសន្ដោសចំពោះយើងខ្ញុំ

God forgives us.................................................................................................252

៥៧. តើយើងត្រូវធ្វើយ៉ាងណា ដើម្បីជាប់ជាមួយព្រះយេស៊ូថែមទៀត?

How to be more close to Christ?.....................................................................260

៥៨. ធ្វើឲ្យព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះគ្រីស្ដប៉ះបេះដូងខ្ញុំ

The mercy of Christ touches my heart...........................................................263

៥៩. ទ្រព្យសម្បត្តិដែលយើងបានទទួលពីព្រះជាម្ចាស់ គឺសេចក្ដីស្រឡាញ់១០០%

The treasure we have received from God is love 100%..............................273

៦០. សូមព្រះអង្គប្រោសប្រណីឲ្យខ្ញុំមានចិត្តមេត្តាករុណាដូចព្រះអង្គ

Be merciful, just as your Father is merciful............................................276

៦១. យើងជាទូតដ៏វិសុទ្ធរបស់ព្រះគ្រីស្ត

Let us be saints!..........................................................................................284

៦២. អ្នកម្តាយតេរេសាជាគំរូនៃមេត្តាករុណា

Mother Teresa, model of Charity....................................................................289

៦៣. សូមព្រះជាម្ចាស់ប្រទានពរឲ្យយើងជាអ្នកកសាងសន្តិភាព

Blessed are the peacemakers........................................................................295

៦៤. ត្រូវប្រែចិត្តគំនិត, លើកលែងទោស, និងធ្វើជាសាក្សី

CONVERSION, FORGIVENESS, WITNESS........................................................300

# "ចូរមានចិត្តមេត្តាករុណា ដូចព្រះបិតា"

Merciful like the Father

*"សូមបងប្អូនមានចិត្តមេត្តាករុណា ដូចព្រះបិតាមានព្រះហឫទ័យមេត្តាករុណាដែរ" ពិតជាបាវចនាសម្រាប់ឆ្នាំនៃមហាករុណាទិគុណ។ យើងមានភស្តុតាងអំពីព្រះហឫទ័យអាណិតមេត្តារបស់ព្រះបិតា គឺព្រះអង្គសព្វព្រះហឫទ័យអាណិតមេត្តាដល់យើងជានិច្ច ទ្រង់មិនសូមឲ្យយើងសងគុណឡើយ។ ពេលណាយើងអង្វរព្រះអង្គទ្រង់យាងមកជួយយើង...ព្រះបិតាយាងមកសង្គ្រោះយើងឲ្យរួចពីភាពទន់ខ្សោយរបស់ខ្លួន។ ព្រះអង្គជួយយើងឲ្យទទួលស្គាល់ថាព្រះអង្គគង់នៅជាមួយយើង គឺទ្រង់គង់នៅក្បែរយើង។ ប្រសិនបើយើងចាប់អារម្មណ៍ នឹងព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គជារៀងរាល់ថ្ងៃ នោះយើងក៏មុខជានឹងមានចិត្តមេត្តាករុណាចំពោះមនុស្សទាំងអស់ដែរ។ "*

***(ហ្វ្រង់ស៊ីស្កូ អភិបាលព្រះសហគមន៍ក្រុងរ៉ូម)***

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ អញ្ជើញព្រះសហគមន៍ទាំងមូលឲ្យចាត់ទុកឆ្នាំខាងមុខនេះជាឆ្នាំមហាករុណាទិគុណ គឺឆ្នាំមហាករុណាទិគុណនេះចាប់ផ្តើមថ្ងៃទី០៨ ធ្នូ ត្រូវនឹងបុណ្យគោរពនាងម៉ារី ដែលមិន ជំពាក់បាប ហើយចប់នៅថ្ងៃ២០វិច្ឆិកា ឆ្នាំ២០១៦ ត្រូវនឹងថ្ងៃអាទិត្យគោរពព្រះគ្រីស្ត ជាព្រះមហាក្សត្រ នៃពិភពលោក។

---

សារលិខិតរបស់លោកអភិបាល អូលីវីយេ
"ឆ្នាំមហាករុណាទិគុណសម្តែងព្រះហឫទ័យប្រណីសន្តោស"

ពិភពលោកយើងនេះ តែងតែរងទុក្ខដោយកើតសង្គ្រាម ដោយមានហិង្សា និងដោយមនុស្សស្អប់គ្នា។ ព្រះបិតាប្រទានធម៌មេត្តាករុណាទុកជាមាគ៌ាតែមួយគត់ដើម្បីឲ្យមនុស្សជាតិយើងអាចស្រុះស្រួលគ្នា និងអាចរស់នៅដូចបងប្អូនបាន ប្រកបដោយសេចក្តីសុខសាន្តនិងដោយសុខដុមរមនា។ ភូមិភាគយើងត្រូវតែសប្បាយរីករាយដោយទទួលឆ្នាំមហាករុណាទិគុណនេះទុកជាពេលដែលព្រះជាម្ចាស់ប្រណីសន្តោសមកយើង យើងក៏ត្រូវយកចិត្តទុកដាក់ប្រែចិត្តគំនិតឲ្យបានជាថ្មីដោយសម្រុះសម្រួលខ្លួនជាមួយព្រះបិតា ហើយសម្រុះសម្រួលជាមួយបងប្អូន។

ចាប់តាំងពីឆ្នាំ២០១៤មក យើងរស់នៅតាមឆ្នាំបង្ហាញមេត្តាករុណា គឺនៅឆ្នាំដើមដំបូងយើង បានយកអ្នកស្រុកសាម៉ារីដែលមានចិត្តសប្បុរស មកធ្វើជាគំរូណែនាំយើងឲ្យយកចិត្តទុកដាក់ទទួល អ្នកដទៃ ទុកជាបងប្អូនរបស់ខ្លួន ដោយចិត្តមេត្តាករុណា។ នៅឆ្នាំបន្ទាប់(២០១៥) យើងបានសម្លឹងមើលព្រះយេស៊ូដែលបានលាងជើងក្រុមសាវ័ក គឺព្រះអង្គបានណែនាំយើងឲ្យបម្រើដោយសេចក្តីស្រឡាញ់តាមសមត្ថភាព។ ក្នុងឆ្នាំទីបីនេះ(២០១៦) យើងនឹងសម្លឹងមើលព្រះបិតាទទួលកូនដែលវង្វេង និងត្រឡប់មកវិញ ហើយទទួលស្គាល់កំពូលនៃសេចក្តីស្រឡាញ់ គឺស្គាល់ព្រះហឫទ័យមេត្តាករុណារបស់ព្រះបិតា។

នៅថ្ងៃទី ១០ខែធ្នូ យើងនឹងបើកទ្វារដ៏វិសុទ្ធសម្រាប់ភូមិភាគយើងជាផ្លូវការ នៅមណ្ឌលសកម្មភាពភ្នំពេញថ្មី។ បន្ទាប់មកគឺនៅថ្ងៃ១៣ធ្នូ យើងនឹងបើកទ្វារដ៏វិសុទ្ធនៅព្រះវិហារសន្តៈយ៉ូសែបរួមជាមួយមរណសាក្សីរបស់យើង។ ក្រោយមកទៀត គឺនៅថ្ងៃ០១មករា ២០១៦ យើងនឹងបើកទ្វារដ៏វិសុទ្ធនេះនៅភូមិអរិយក្សត្ររួមជាមួយព្រះនាងម៉ារីជាមហាក្សត្រីនៃទន្លេមេគង្គ។

ខ្ញុំសូមអញ្ជើញព្រះសហគមន៍នីមួយៗក្នុងភូមិភាគ ឲ្យធ្វើបូជានីយចរនៅកន្លែងទាំងបីក្នុងឆ្នាំដ៏វិសុទ្ធនេះ។ ខ្ញុំសូមអញ្ជើញបងប្អូនឲ្យចូលរួមក្នុងពិធី និងកិច្ចការផ្សេងៗក្នុងឆ្នាំខាងមុខនេះជាពិធី និងជាកិច្ចការដែលអាចជួយណែនាំយើងឲ្យប្រែចិត្តគំនិតយ៉ាងពិតប្រាកដ។

តាំងពីពេលនេះតទៅ តាមសម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ ខ្ញុំសូមអញ្ជើញបងប្អូនម្នាក់ៗឲ្យរៀបចំ

ខ្លួននឹង **"រស់នៅស្របតាមស្នាព្រះហស្តនៃមេត្តាករុណា ទាំងខាងវិញ្ញាណ ទាំងខាងរូបកាយ"** ដើម្បីឲ្យបងប្អូនធ្វើជាសញ្ញាសម្គាល់ សម្តែងព្រះហឫទ័យអាណិតមេត្តាដ៏ធំទូលំទូលាយរបស់ព្រះបិតាចំពោះមនុស្សម្នាក់ៗ ជាពិសេសចំពោះអ្នកតូចតាចដែលមានគ្នាជាច្រើនក្នុងសង្គមយើង។ សូមឲ្យបងប្អូនស្រុះស្រួលគ្នាក្នុងចិត្ត និងស្រុះស្រួលគ្នាក្នុងក្រុមគ្រួសារ ហើយស្រុះស្រួលគ្នាក្នុងសហគមន៍គ្រីស្តបរិស័ទយើង និងក្នុងប្រទេសយើង ដែលហៀបនឹងចូលក្នុងទីផ្សាររួមដ៏ធំទូលំទូលាយនៃសមាគមអាស៊ាន។ ព្រះជាម្ចាស់ជាតួនៃធម៌មេត្តាដូច្នេះយើងត្រូវតែធ្វើជាសញ្ញាសម្គាល់អំពីព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គ។

សូមបងប្អូនបានប្រកបដោយសេចក្តីសុខសាន្តនិងដោយអំណរសប្បាយ។

អូលីវីយេ ជ្មីតអីស្លែរ
អភិបាលភូមិភាគភ្នំពេញ

# ខ្ញុំហ្នឹងហើយជាទ្វារ
# អ្នកណាចូលតាមខ្ញុំព្រះជាម្ចាស់នឹងសង្គ្រោះអ្នកនោះ

I am the gate. Whoever enters through me will be saved

---

អត្ថបទទី១ ៖ អ.ស ២,១-១០
ដំណឹងល្អ ៖ យហ ១០,៧-១០

ថ្ងៃនេះ យើងរំភើបចិត្តយ៉ាងខ្លាំង ដោយយើងបានចូលរួមក្នុងពិធីបុណ្យនៃ **"ឆ្នាំព្រះមហាករុណាទិគុណ"** ដែលព្រះសហគមន៍ណែនាំឲ្យយើងប្រារព្ធ។ យើងមកពីមណ្ឌលសកម្មភាពទាំងអស់នៃភូមិភាគភ្នំពេញ យើងមានអំណរសប្បាយដោយសារព្រះជាម្ចាស់បង្ហាញព្រះហឫទ័យប្រណីសន្ដោសដល់យើងម្នាក់ៗ ក្នុងឆ្នាំមហាករុណាទិគុណនេះ ហើយឆ្នាំនេះ ក៏ជាឆ្នាំទីបីនៃឆ្នាំ "មេត្តាករុណា" របស់ភូមិភាគភ្នំពេញ ក្នុងការចូលរួមជាមួយព្រះសហគមន៍ទូទាំងពិភពលោក។ ឆ្នាំនេះសម្ដេចប៉ាបអញ្ជើញយើងឲ្យមានចិត្តដូចមានសរសេរលើ Logo ថា **"ចូរមានចិត្តមេត្តាករុណាដូចព្រះបិតាមានព្រះហឫទ័យមេត្តាករុណា"**។

ឆ្នាំនេះខ្ញុំសូមអញ្ជើញបងប្អូនឲ្យសម្លឹងមើលព្រះយេស៊ូ ដើម្បីមានបទពិសោធន៍ជាក់ស្ដែងអំពីព្រះហឫទ័យស្រឡាញ់របស់ព្រះបិតាចំពោះយើងម្នាក់ៗ។ ក្នុងអត្ថបទទីមួយយើងបានស្ដាប់ឮថា **"...ព្រះជាម្ចាស់ប្រកបដោយព្រះហឫទ័យមេត្តាករុណា ដ៏ច្រើនពន់ប្រមាណនោះព្រះអង្គមានព្រះហឫទ័យស្រឡាញ់យើងខ្លាំងបំផុត..."** នេះជាអ្វីដែលចាប់ពីថ្ងៃនេះរហូតដល់ថ្ងៃទី២០ ខែវិច្ឆិកាឆ្នាំ២០១៦ ព្រះសហគមន៍សូមឲ្យយើងចូលនៅក្នុងឆ្នាំព្រះមហាករុណាទិគុណដែលបន្តិចម្ដងៗនឹងធ្វើឲ្យជីវិតរបស់យើងជាគ្រីស្ដបរិស័ទ មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយព្រះបិតាដែលស្រឡាញ់យើង ដែលលើកលែងទោសឲ្យយើង ថែមទាំងប្រោសប្រណីឲ្យយើងមានជីវិតថ្មីផង។

---

ពិធីឆ្លងទ្វារដ៏វិសុទ្ធនៅមជ្ឈមណ្ឌលភ្នំពេញថ្មី
ថ្ងៃទី ១០ ធ្នូ ២០១៥

ដូច្នេះចាប់ពីពេលនេះតទៅ ចូរយើងទាំងអស់គ្នាភ្ញាក់ស្មារតីចូលយ៉ាងជ្រៅក្នុងជីវិតជាគ្រីស្តបរិស័ទរួមគ្នាជាមួយព្រះសហគមន៍ទាំងមូល ជាមួយពិភពលោកទាំងមូល ទទួលជីវិតថ្មីពីព្រះបិតា។ ដូច្នេះ តើយើងត្រូវធ្វើអ្វីខ្លះ?

១) ក្នុងអត្ថបទព្រះគម្ពីរដំណឹងល្អបានចែងថា **"ខ្ញុំហ្នឹងហើយជាទ្វារ អ្នកណាចូលតាមខ្ញុំព្រះជាម្ចាស់នឹងសង្គ្រោះអ្នកនោះ"**។ អម្បាញ់មិញយើងបានឆ្លងទ្វារដ៏វិសុទ្ធ ទ្វារនេះមានតុបតែងដូចជាទ្វារនៃវិមានមួយ ប៉ុន្តែត្រូវយល់ថាទ្វារនេះគឺជាព្រះយេស៊ូផ្ទាល់។ យើងបានឆ្លងតាមទ្វារនេះមានន័យថាយើងបានឆ្លងតាមព្រះយេស៊ូ ហើយយើងក៏បានទទួលការសង្គ្រោះពីព្រះអង្គដែរ។ ក្នុងឆ្នាំព្រះមហាករុណាទិគុណនេះ ជាពេលវេលាដែលយើងម្នាក់ៗជួបជាមួយព្រះយេស៊ូសាជាថ្មី និងអធិដ្ឋានច្រើនថែមទៀតទាំងយកចិត្តទុកដាក់ទទួលអគ្គសញ្ញានីមួយៗច្រើនថែមទៀត គឺទទួលព្រះកាយព្រះគ្រីស្ត និងអគ្គសញ្ញាលើកលែងទោស។ ឆ្នាំនេះតើមានប៉ុន្មាននាក់នឹងទទួលអគ្គសញ្ញាលាបថ្ងាស? ទទួលអគ្គសញ្ញាលាបប្រេង? ទទួលអគ្គសញ្ញាអាពាហ៍ពិពាហ៍? ទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យ? ទទួលអគ្គសញ្ញាជ្រមុជទឹក?។ ឆ្នាំនេះចូរឲ្យយើងម្នាក់ៗយកចិត្តទុកដាក់ចូលអភិបូជារាល់អាទិត្យ យ៉ាងតិចក៏ពីរដងក្នុងមួយខែ យកចិត្តទុកដាក់ទទួលអគ្គសញ្ញាលើកលែងទោសម្តងក្នុងមួយខែ ដើម្បីឲ្យយើងចូលនៅក្នុងជីវិតរបស់ព្រះយេស៊ូ។

ទ្វារដែលយើងបានឆ្លងព្រឹកមិញនេះ ជាទ្វារសក្ការៈ យើងឆ្លងទ្វារនេះ ជាសញ្ញាសម្គាល់ថាយើងសុខចិត្តប្រែចិត្តគំនិត។ យើងមិនឆ្លងកាត់ទ្វារនេះដោយគ្រាន់តែដើម្បីដើរកំសាន្ត ឬមើលព្រះនាងម៉ារីស្អាត ឬមើលទឹកបាញ់ស្អាតនោះទេ ប៉ុន្តែយើងឆ្លងកាត់ដើម្បីទៅអធិដ្ឋាននៅមុខព្រះនាងម៉ារីនិងធ្វើដំណើររួមជាមួយព្រះនាងដើម្បីស្គាល់ព្រះយេស៊ូច្បាស់ទៅៗតាមព្រឹត្តិការណ៍អាថ៌កំបាំងនីមួយៗ។ ក្នុងឆ្នាំនេះភូមិភាគភ្នំពេញយើងមានរៀបចំទ្វារដ៏វិសុទ្ធបីកន្លែង គឺនៅទីនេះ នៅផ្សារតូចដែលភ្ជាប់ជាមួយមរណសាក្សី ហើយយើងនឹងបើកនៅថ្ងៃ១៣ខែធ្នូ២០១៥ និងមួយកន្លែងទៀតនៅអារិយក្សត្រ ដែលភ្ជាប់ជាមួយព្រះនាងម៉ារីហើយយើងនឹងបើកនៅថ្ងៃទី១ខែមករាឆ្នាំ២០១៦ខាងមុខ។ ខ្ញុំសូមអញ្ជើញបងប្អូនទាំងអស់ទៅអរិយក្សត្រដើម្បីបើកជាឱឡារិកសម្រាប់បូជនីយ៍ចរនៅក្នុងឆ្នាំនេះ។

ដូច្នេះនៅឆ្នាំក្រោយ បងប្អូនទាំងអស់ ត្រូវធ្វើបូជនីយ៍ចរមួយថ្ងៃ រួមជាមួយព្រះសហគមន៍ ឬការិយាល័យនានា ឬទេវវិទ្យាល័យ ឬសាលានីមួយៗ ទៅកន្លែងទាំងបីដើម្បីអធិដ្ឋាន។ យើងជូនសៀវភៅបងប្អូនមួយក្បាល ដែលប្រៀបដូចជាលិខិតឆ្លងដែនម្យ៉ាង ទៅស្ថានបរមសុខ ដើម្បីបងប្អូនទទួលជីវិតរួមជាមួយព្រះយេស៊ូ។ នៅក្នុងសៀវភៅនោះមានប្រាប់ពីទីកន្លែង ពីរបៀបអធិដ្ឋាន... ដើម្បីឲ្យបងប្អូនភ្ជាប់ចិត្តគំនិតតាមផ្លូវវិញ្ញាណ ទៅជាធ្លុងតែមួយជាមួយព្រះយេស៊ូដែលជាទ្វារ។ ដូច្នេះរាល់ពេលឆ្លងទ្វារនៅទីនេះ ឬទ្វារនៅផ្សារតូច ឬទ្វារនៅអរិយក្សេត្រ នោះចូរដឹងថា យើងមានព្រះយេស៊ូគង់នៅយ៉ាងជិតស្និទ្ធជាមួយយើង ដើម្បីឲ្យយើងទទួលជីវិតថ្មី។

២) ក្នុងអត្ថបទទី១មានចែងថា

> **"...យើងជាស្នាព្រះហស្ត ដែលព្រះជាម្ចាស់បានបង្កើតមកក្នុងអង្គព្រះគ្រីស្ត ដើម្បីឲ្យយើងប្រព្រឹត្តអំពើល្អ ដែលព្រះអង្គបានបម្រុងទុកជាមុនស្រាប់ឲ្យយើងដើរតាម។ យើងទទួលការសង្គ្រោះមិនមែនដោយសារបុណ្យកុសលដែលយើងធ្វើទេតែដោយសារជំនឿលើព្រះជាម្ចាស់ដែលប្រទានការសង្គ្រោះដល់យើង..."។**

ដូច្នេះសម្រាប់យើងមិនមែនបុណ្យកុសលទេដែលនាំឲ្យយើងទទួលការសង្គ្រោះ ការសង្គ្រោះជាព្រះអំណោយទានមកពីព្រះជាម្ចាស់។ ដោយសារការសង្គ្រោះដោយសារយើងទទួលជីវិតថ្មី នោះជំរុញឲ្យយើងធ្វើអំពើល្អ និង បង្ហាញធម៌មេត្តាករុណាតាមគំរូរបស់ព្រះយេស៊ូ។ ឆ្នាំនេះខ្ញុំសូមអញ្ជើញបងប្អូនក្នុងភូមិភាគភ្នំពេញទាំងមូលចូលរួមក្នុងគម្រោងការនៃធម៌មេត្តាករុណាដ៏ធំធេងរបស់ព្រះជាម្ចាស់តាមសកម្មភាពជាក់ស្តែងដូចតទៅ៖

១) ខ្ញុំសូមទាំងលោកឪពុក ទាំងបងប្រុស បងស្រី ទាំងការិយាល័យ ទាំងស្ថាប័នកាតូលិកភូមិភាគភ្នំពេញទាំងអស់ចាប់ពីខែនេះទៅ ក្នុង១ខែត្រូវរើស១ថ្ងៃ ដើម្បីធ្វើកិច្ចការមេត្តាករុណា។ សូម្បីសម្តេចប៉ាបក៏ធ្វើដែរ សម្តេចរើសយករាល់ថ្ងៃសុក្រចុងខែ។ យើងមិនពិបាករកកិច្ចការដែល

ត្រូវធ្វើទេដោយយើងនឹកដល់ព្រះបន្ទូលរបស់ព្រះយេស៊ូថា **"ពេលណាខ្ញុំឃ្លាន ពេលណាខ្ញុំស្រេក ពេលណាខ្ញុំគ្មានសម្លៀកបំពាក់ ពេលណាខ្ញុំជាប់ឃុំឃាំង ពេលណាខ្ញុំជាអ្នកជំងឺ ពេលណាខ្ញុំជាជនបរទេស នោះអ្នករាល់គ្នាយកចិត្តទុកដាក់ចំពោះខ្ញុំ និងពេលណាខ្ញុំស្លាប់អ្នកបានរៀបចំបញ្ចុះសពខ្ញុំ..."**។ ដូច្នេះ១ខែម្តងយើងត្រូវជូនម្ហូប ជូនទឹកដល់អ្នកដែលឃ្លាននិងស្រេក ជូនសម្លៀកបំពាក់ដល់អ្នកអាក្រាត សួរសុខទុក្ខអ្នកជាប់ឃុំឃាំង អ្នកជំងឺ ស្វាគមន៍ជនបរទេស និងរកឱកាសថែអ្នកដែលហៀបនឹងទទួលមរណភាពដែរ។ ទោះបីគ្រីស្តបរិស័ទមានគ្នាតិចមានតែ១ម៉ឺនប្រាំពាន់នាក់ ក្នុងចំណោមប្រជាជន៦លាននាក់នៅក្នុងភូមិភាគភ្នំពេញ ប៉ុន្តែសូមឲ្យយើងទៅជាមេម្សៅ ទៅជាអំបិល និងជាពន្លឺ។

២) ខ្ញុំសូមអញ្ជើញក្រុមគ្រីស្តបរិស័ទនីមួយៗជាពិសេសក្រុមសង្គហៈនៃព្រះសហគមន៍នីមួយៗចូលរួមយ៉ាងសកម្មក្នុងគម្រោងការរបស់ភូមិភាគ ក្នុងឆ្នាំ២០១៦នេះ ដោយសម្តែងធម៌មេត្តាករុណានៅក្នុងវិស័យទាំង៧ គឺ៖



ក្នុងវិស័យទាំង៧នេះសូមរើសយកតែមួយជាអាទិភាពជំរុញឲ្យទៅមុខដើម្បីឲ្យការប្រែចិត្តគំនិតរបស់យើងមានផលផ្លែជាក់ស្តែងគឺ **"ជំនឿមានផលផ្លែ"**។ សម្តេចប៉ាប បេណេឌីកតូទី១៦ បានរំឭកច្រើនដងថា **"ជំនឿមានផ្លែ ហើយផ្លែនោះគឺជាសេចក្តីស្រឡាញ់"**។ យើងដឹងពីជំនឿរបស់យើងដោយពិនិត្យមើលកម្រិតនៃសេចក្តីស្រឡាញ់។

៣) ព្រះយេស៊ូមានព្រះបន្ទូលថា **"...ខ្ញុំមកដើម្បីឲ្យមនុស្សលោកមានជីវិត ហើយជាជីវិតដ៏ពេញបរិបូរណ៍..."**។ ដូច្នេះឆ្នាំព្រះមហាករុណាទិគុណនេះ ជាពេលវេលាដែលព្រះជាម្ចាស់ចែកជីវិតដល់ព្រះសហគមន៍ និងដល់ពិភពលោកទាំងមូលក្នុងនោះគឺដល់ប្រជាជននៅក្នុងប្រទេសកម្ពុជាយើងដែរ។ គ្រីស្តបរិស័ទត្រូវយល់ច្បាស់ថា "ព្រះសហគមន៍គឺជាអគ្គសញ្ញា" គឺជាសញ្ញាដែលអាចមើលឃើញព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់បាននោះមានន័យថាពេលណាបងប្អូនដែលមិនមែនជាគ្រីស្តបរិស័ទមើលមកយើងជាព្រះសហគមន៍គេនឹងអាចឃើញជាក់ស្តែងពិតមែនថាព្រះជាម្ចាស់មានព្រះហឫទ័យប្រណីសន្តោសចំពោះគេ មិនតែប៉ុណ្ណោះព្រះសហគមន៍ក៏ប្រកាសអំពីព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់ តាមរយៈការអធិដ្ឋាននិងដោយធ្វើពិធីដែរដូចជាអភិបូជា និងអគ្គសញ្ញានានា មានអគ្គសញ្ញាលើកលែងទោសជាដើម...។ យើងជាគ្រីស្តបរិស័ទយើងរស់នៅក្នុងធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ គឺរស់នៅជាប់ជាមួយព្រះយេស៊ូដែលយាងមកដើម្បីប្រកាសដំណឹងល្អ អំពីព្រះរាជ្យរបស់ព្រះជាម្ចាស់ ណែនាំឲ្យជនក្រីក្រមានជីវិតថ្មីទាំងធ្វើឲ្យ "ហេតុការណ៍ទាំងនោះបានកើតជារូបរាងហើយនៅថ្ងៃនេះហើយ!"។ ពេលខ្ញុំឃើញព្រះយេស៊ូ ខ្ញុំឃើញដំណឹងល្អ ពេលខ្ញុំឃើញព្រះយេស៊ូខ្ញុំឃើញព្រះរាជ្យព្រះជាម្ចាស់ ពេលខ្ញុំឃើញព្រះយេស៊ូ ខ្ញុំឃើញព្រះបិតាផ្ទាល់។

នៅក្នុងឱកាសបុណ្យព្រះយេស៊ូប្រសូតខាងមុខនេះ យើងនឹងឃើញព្រះយេស៊ូដែលចាប់កំណើតជាមនុស្សជាកូនង៉ែតតូចមួយមកសង្គ្រោះមនុស្សលោក។ ពេលប្រសូតមានគង្វាលមានប្រជាជន មានអ្នកតូចតាចនៅក្នុងសង្គម មានហោរាចារ្យ មកថ្វាយបង្គំព្រះអង្គគេចង់ស្គាល់ព្រះអង្គ ហើយព្រះអង្គសោយទិវង្គតនៅព្រះជន្មប្រមាណជាងសាមសិបវស្សា។ ក្នុងឆ្នាំមហាករុណា

ទិគុណនេះបងប្អូនត្រូវតែមើលឲ្យឃើញរបួសនៅព្រះហស្ត នៅបាទា និងនៅចន្លោះឆ្អឹងជំនីររបស់ព្រះយេស៊ូ តាមសភាពការណ៍ជាក់ស្តែងនៃរបួសរបស់មនុស្សលោកយើងសព្វថ្ងៃដែលជារបួសរបស់បងប្អូន ជាបាបរបស់បងប្អូន និងក៏ជាទុក្ខលំបាករបស់បងប្អូនផ្ទាល់ដែរ។ ក្នុងឆ្នាំនេះយើងត្រូវតែប៉ះរបួសព្រះយេស៊ូដោយផ្ទាល់ដោយហ៊ានប៉ះអ្នកជំងឺ អ្នកតូចតាច អ្នកដែលគ្មានសេចក្តីសង្ឃឹមដើម្បីឲ្យគេបានទទួលជីវិតថ្មី។

តាមបទពិសោធន៍របស់ព្រះសហគមន៍ជាង២០០០ឆ្នាំ បានឲ្យដឹងថា សន្តៈបេណេឌីកតូដែលរស់នៅក្នុងអារាមសម្ងាត់បានប្រៀនប្រដៅអ្នកបួសក្នុងអារាមថា "គ្រប់ពេលដែលមានជនបរទេស ឬមានភ្ញៀវណាម្នាក់មកគោះទ្វារចូរស្វាគមន៍គេទៅ ដ្បិតគេទាំងនោះជាព្រះយេស៊ូផ្ទាល់"។ រីឯសន្តៈហ្វ្រង់ស្វ័រនៃទីក្រុងអាស៊ីស៊ីវិញនៅពេលជួបអ្នកជំងឺឃ្លង់ម្នាក់គាត់បានស្ទុះទៅឱបថើបអ្នកជំងឺនោះទាំងមិនខ្លាចឆ្លងជំងឺទេ ដោយយល់ឃើញថា អ្នកឃ្លង់នោះគឺជាព្រះយេស៊ូផ្ទាល់។ ចំណែកឯអ្នកម្តាយតេរេសាវិញពេលជួបអ្នកជំងឺអនាថាម្នាក់ហៀបនឹងដាច់ខ្យល់ស្លាប់នៅតាមផ្លូវនោះគាត់បាននាំយកមកថែរក្សា និងព្យាបាលដោយយល់ឃើញថាបុរសនោះគឺជាព្រះយេស៊ូ។

នៅក្នុងឆ្នាំមហាករុណាទិគុណនេះ ខ្ញុំសូមឲ្យបងប្អូនប៉ះ គឺប៉ះត្រចៀក ភ្នែក បេះដូង និងដៃរបស់បងប្អូនផ្ទាល់ ដើម្បីបងប្អូនស្តាប់ ដើម្បីមើលឃើញ ដើម្បីស្រឡាញ់ និងដើម្បីបម្រើ។ ខ្ញុំជឿថាឆ្នាំនេះយើងអាចមើលឃើញព្រះរាជ្យរបស់ព្រះជាម្ចាស់តាមព្រឹត្តិការណ៍ផ្សេងៗដែលកើតឡើងដោយដឹងថាព្រះយេស៊ូយាងមកដើម្បីឲ្យយើងមានជីវិតដ៏បរិបូណ៌។ រួមជាមួយមរណសាក្សីរបស់យើងជាមួយព្រះនាងម៉ារីនៃទន្លេមេគង្គ យើងសូមទូលអង្វរព្រះជាម្ចាស់ ឲ្យពេញមួយឆ្នាំនេះយើងទទួលជីវិតថ្មីជាជីវិតផ្ទាល់របស់ព្រះយេស៊ូ។

# យើងបានស្រឡាញ់អ្នកដោយចិត្តស្រឡាញ់ ដែលស្ថិតស្ថេរអស់កល្បជានិច្ច

We love you with hearts that love forever

អត្ថបទទី១ ៖ បសរ ៤៨,១-៤.៩-១១
ដំណឹងល្អ ៖ មថ១១,១០-១៨

ថ្ងៃនេះជាថ្ងៃដ៏ឱឡារិកសម្រាប់ព្រះសហគមន៍របស់យើង ដោយយើងបានទទួលបងស្រីម្នាក់ដែលសុខចិត្តផ្ញើជីវិតទាំងស្រុងលើព្រះជាម្ចាស់។ នៅពេលស្តាប់អត្ថបទនីមួយៗ ខ្ញុំគិតថាគ្រប់អត្ថបទទាំងអស់ជួយយើងឲ្យយល់ថែមទៀត អំពីរបៀបដែលព្រះជាម្ចាស់បង្ហាញធម៌មេត្តាករុណាដល់យើង។ ជាពិសេសក្នុងអត្ថបទទី១មានចែងថា **"ព្រះជាម្ចាស់មានព្រះបន្ទូលមកខ្ញុំថា យើងបានស្រឡាញ់អ្នកដោយចិត្តស្រឡាញ់ដែលស្ថិតស្ថេរអស់កល្បជានិច្ច"** ដែលបង្ហាញថាព្រះជាម្ចាស់មានព្រះហឫទ័យស្រឡាញ់ និងស្មោះត្រង់ចំពោះមនុស្សលោកជានិច្ច ហើយថ្ងៃនេះបងស្រីក៏ឆ្លើយតបចំពោះព្រះជាម្ចាស់ដែលមានព្រះហឫទ័យស្មោះត្រង់ចំពោះបងស្រី និងចំពោះយើងទាំងអស់គ្នាដែរ។

តាមប្រវត្តិសាស្ត្រនៃការសង្គ្រោះគឺតាំងពីព្រះជាម្ចាស់បង្កើតមនុស្សលោករហូតព្រះយេស៊ូយាងមក នោះយើងបានឃើញថាព្រះជាម្ចាស់មានព្រះហឫទ័យស្មោះត្រង់ចំពោះប្រជារាស្ត្ររបស់ព្រះអង្គជានិច្ច ប៉ុន្តែច្រើនលើកច្រើនសា ប្រជារាស្ត្ររបស់ព្រះជាម្ចាស់តែងតែភ្លេចព្រះជាម្ចាស់ និង ឃ្លាតឆ្ងាយពីព្រះអង្គ ទោះបីព្រះអង្គយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះគេយ៉ាងណាក្តី។ តាមប្រវត្តិសាស្ត្រ ពេលជនជាតិហេប្រឺ ចេញពីប្រទេសអេស៊ីបបានតែប៉ុន្មានខែប៉ុណ្ណោះគេក៏បានសិតរូបគោមាសមួយទុកថ្វាយបង្គំ។ ពេលនោះព្រះជាម្ចាស់បានរំឭកគេតាមរយៈព្យាការីថាហេតុអ្វីបាន

ពិធីសច្ចានិរន្តរ៍របស់បងស្រីតេរេសា
នៃក្រុមគ្រួសារឧបការគុណ
ថ្ងៃទី ១២ ធ្នូ ឆ្នាំ ២០១៥

ជាអ្នកលះបង់យើង? ហេតុអ្វីបានជាអ្នកប្រព្រឹត្តកិច្ចការដែលទាស់នឹងហឫទ័យរបស់យើង? ហើយជួនកាលព្រះជាម្ចាស់ក៏មានព្រះពិរោធនឹងគេដែរ ប៉ុន្តែចុងក្រោយបំផុតព្រះជាម្ចាស់មានព្រះបន្ទូលថា **"យើងជាព្រះជាម្ចាស់ដែលមានព្រះហឫទ័យប្រណីសណ្ដោស យើងព្រះជាម្ចាស់ដែលស្មោះត្រង់ចំពោះប្រជារាស្ដ្ររបស់យើងហេតុនេះហើយ យើងមិនអាចបោះបង់ចោលគេបានឡើយ"**។

១) ព្រះជាម្ចាស់មានព្រះហឫទ័យស្មោះត្រង់

ថ្ងៃនេះ នៅពេលបងស្រីប្រកាសពាក្យសច្ចានិវន្ដ៍ សុខចិត្តធ្វើជីវិតទាំងស្រុងលើព្រះជាម្ចាស់ នោះជាឱកាសមួយឲ្យយើងទាំងអស់គ្នាមានពិសោធន៍នៅក្នុងជីវិត ពីរបៀបដែលព្រះជាម្ចាស់ស្រឡាញ់យើង និងពីរបៀបដែលព្រះអង្គមានព្រះហឫទ័យស្មោះត្រង់ចំពោះយើង។ បងស្រីមានពិសោធន៍នេះដែលណែនាំឲ្យបងស្រីមានកម្លាំងដើម្បីធ្វើដំណើរជាមួយព្រះជាម្ចាស់ចាប់ពីពេលនេះរហូតតទៅ ហើយដែលនឹងណែនាំឲ្យបងស្រីមើលឃើញព្រះជាម្ចាស់ដោយផ្ទាល់កាន់តែច្បាស់ទៅៗ។ ក្នុងការរស់នៅមានកាលៈទេសៈ ខ្លះបណ្ដាលឲ្យយើងពិបាកចិត្តដោយសារយើងវង្វេងមិនដឹងថាព្រះជាម្ចាស់គង់នៅឯណា? ក៏ប៉ុន្តែរាល់ថ្ងៃយើងអាចនឹងមើលឃើញព្រះ-ជាម្ចាស់បានតាមរបៀបដែលព្រះអង្គស្រឡាញ់យើង និងមានព្រះហឫទ័យស្មោះត្រង់ចំពោះយើង។

ឆ្នាំនេះយើងចូលក្នុងឆ្នាំព្រះមហាករុណាទិគុណ គឺព្រះជាម្ចាស់សម្ដែងព្រះហឫទ័យមេត្តាករុណាដល់យើង ជាឱកាសម្ដងទៀតឲ្យយើងទាំងអស់គ្នាជាគ្រីស្តបរិស័ទចូលយ៉ាងជ្រៅក្នុងព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គ គឺព្រះបិតាលើកលែងទោសឲ្យយើងជាមនុស្សបាប។ ដូច្នេះអ្វីដែលសំខាន់នោះ គឺយើងជាអ្នកមានបាបដែលបានទទួលព្រះហឫទ័យប្រណីសន្ដោសពីព្រះជាម្ចាស់។ យើងនឹងមិនសូត្រដដែលៗទោសខ្ញុំអើយ ទោសខ្ញុំអើយ ខ្ញុំជាអ្នកមានបាបនោះទេ ប៉ុន្តែយើងសម្លឹងមើលទៅព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះបិតា ទាំងអរព្រះគុណព្រះអង្គវិញ។ នេះជារបៀបដែលនាំឲ្យយើងមានសេចក្ដីសង្ឃឹមជានិច្ច ដោយសារសេចក្ដីស្រឡាញ់របស់ព្រះបិតាចំពោះយើងស្ថិតស្ថេរអស់កល្ប។

២) ទុកចិត្តលើឧបការគុណស្រឡាញ់របស់ព្រះជាម្ចាស់

នៅក្នុងអត្ថបទទី២មានចែងថា "សេចក្ដីស្រឡាញ់របស់ព្រះយេស៊ូ ណែនាំឲ្យយើងមានកម្លាំងកាយនិងកម្លាំងចិត្ត"។ សន្តៈប៉ូលធ្លាប់អធិដ្ឋានថា **"ខ្ញុំទូលអង្វរព្រះជាម្ចាស់ដូចតទៅនេះ គឺខ្ញុំសូមឲ្យបងប្អូនមានសេចក្ដីស្រឡាញ់ដ៏លើសលប់កាន់តែខ្លាំងឡើងៗ សូមឲ្យបងប្អូនចេះដឹងកាន់តែច្បាស់ និងយល់សព្វគ្រប់ទាំងអស់..."។** យើងអាចមានចិត្តស្រឡាញ់ដ៏លើស-លប់កាន់តែខ្លាំងឡើងៗបាន លុះត្រាយើងសុខចិត្តទទួលយកសេចក្ដីស្រឡាញ់របស់ព្រះយេស៊ូទាំងយើងផ្ញើជីវិតទាំងស្រុងលើព្រះអង្គ គឺយើងទុកចិត្តលើឧបការគុណរបស់ព្រះជាម្ចាស់ជាព្រះបិតា។

នៅពេលនេះ បងស្រីតេរេសា សច្ចារស់នៅក្នុងក្រុមគ្រួសារឧបការគុណ។ ក្រុមបងស្រីឧបការគុណនៅទីនេះជួយកិច្ចការព្រះសហគមន៍យ៉ាងច្រើន ឲ្យព្រះសហគមន៍ មានកម្លាំងថែមទៀតក្នុងឧបការគុណរបស់ព្រះជាម្ចាស់។ ពាក្យ **"ឧបការគុណ របស់ព្រះជាម្ចាស់ "** មានន័យថាព្រះជាម្ចាស់មានព្រះហឫទ័យមេត្តាករុណា ការពារ ថែរក្សា និងស្រឡាញ់យើងគ្រប់ពេលវេលា... ដូច្នេះ យើងត្រូវទុកចិត្តលើឧបការគុណរបស់ព្រះជាម្ចាស់ដែលនាំឲ្យយើងអាចទៅមុខបាន។ ក្រុមគ្រួសារបងស្រីឧបការគុណបានបង្កើតឡើងដើម្បីជួយអ្នកក្រីក្រ ដោយលោកបូជាចារ្យយ៉ូហាន ម៉ារតាំងម៉ូយ ជាសាសនទូតនៅប្រទេសចិន នៅពេលដែលលោកត្រឡប់ទៅនៅប្រទេសបារាំងវិញ។ សព្វថ្ងៃក្រុមបងស្រីឧបការគុណមានច្រើនកន្លែងនៅក្នុងពិភពលោកទាំងមូល។ តាមរយៈពាក្យសច្ចាទាំង៣ គឺរស់នៅជាព្រហ្មចារិនី រស់នៅក្នុងភាពក្រីក្រ និងរស់នៅស្ដាប់បង្គាប់ប្រធានទាំងនៅក្នុងប្រទេសកម្ពុជានិងនៅបារាំង នោះសូមឲ្យទៅជាកម្លាំងយ៉ាងពិសេសណែនាំឲ្យសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់រីកចម្រើន កាន់តែខ្លាំងឡើងៗក្នុងជីវិតបងស្រី។ ប៉ុន្តែសូមកុំភ្លេចថាបងស្រីតេរេសាក៏សង្ឃឹមលើការអធិដ្ឋានរបស់យើងទាំងអស់គ្នាដែរ។ ភារកិច្ចរបស់យើងគឺអធិដ្ឋាន យើងអធិដ្ឋានឲ្យបងស្រីតេរេសាមានសេចក្ដីស្រឡាញ់ដ៏ពេញបរិបូរណ៍

ដូចសន្តៈប៉ូលអធិដ្ឋានឲ្យព្រះសហគមន៍នៅក្រុងភីលីព ក្រុងកូរិនថូស ក្រុងថេស្សាឡូនិក និងឲ្យព្រះសហគមន៍របស់យើងសព្វថ្ងៃ បង្ហាញធម៌មេត្តាករុណារបស់ព្រះគ្រីស្តក្នុងព្រះហឫទ័យប្រណីសន្តោសរបស់ព្រះបិតា ភ្លឺត្រចះត្រចង់ឡើងជានិច្ច។

៣) ចូរប្រុងស្មារតី

ក្នុងអត្ថបទគម្ពីរដំណឹងល្អមានចែងថា **"ចូរអ្នករាល់គ្នាប្រុងស្មារតី ដ្បិតអ្នករាល់គ្នាពុំដឹងថាបុត្រមនុស្សនឹងមកដល់នៅពេលណាឬថ្ងៃណាឡើយ!"**។ ការរស់នៅរបស់យើងជាគ្រីស្តបរិស័ទប្រៀបបីដូចជាអ្នកយាមដែលអង្គុយនៅមាត់ទ្វារព្រះសហគមន៍ សម្លឹងមើលខាងក្នុងផង និងមើលខាងក្រៅផង។ យើងយាមពេលវេលាដែលព្រះយេស៊ូនឹងយាងមក ដ្បិតយើងមិនដឹងថាពេលណាព្រះអង្គនឹងយាងមក យើងយាមដោយអធិដ្ឋានជានិច្ច និងយាមដោយទទួលស្វាគមន៍បងប្អូនទាំងអស់ដោយបម្រើ និងបម្រើថែមទៀត ដោយស្រឡាញ់ និងស្រឡាញ់ថែមទៀត ដោយឆ្លើយតបនឹងសេចក្តីត្រូវការរបស់បងប្អូនឯទៀតៗជានិច្ច។ ទាំងនេះក៏ជាតួនាទីរបស់បងស្រីដែរ សូមកុំឲ្យបងស្រីទៅជាស្ត្រីអត់គំនិត ប៉ុន្តែឲ្យទៅជាស្ត្រីដែលមានប្រាជ្ញាឈ្លាសវៃ។ យើងទាំងអស់គ្នាក៏ត្រូវតែជាស្ត្រីដែលមានប្រាជ្ញាឈ្លាសវៃដែរ ដោយយើងមើលឃើញពីរបៀបដែលយើងត្រូវស្រឡាញ់ ពីរបៀបដែលយើងត្រូវបម្រើ ហើយយើងបម្រើដោយអស់ពីកម្លាំងកាយនិងកម្លាំងចិត្ត។

សូមចងចាំថា ព្រះជាម្ចាស់បានស្តាប់ឮ ព្រះជាម្ចាស់បានមើលឃើញ និងព្រះជាម្ចាស់បានចុះមកដើម្បីសង្គ្រោះមនុស្សលោក។ ហេតុដូច្នេះហើយ ទាំងបងស្រី ទាំងយើងទាំងអស់គ្នាត្រូវតែភ្ញាក់ស្មារតីជានិច្ច ដោយស្តាប់ឮ ដោយមើលឃើញ និងដោយបម្រើជានិច្ច ស្រឡាញ់ជានិច្ច ដោយអធិដ្ឋាន និងអធិដ្ឋានជានិច្ចនៅក្នុងបរិយាកាសរបស់ព្រះជាម្ចាស់។ ដូចព្រះនាងម៉ារី ដែលមានតែក្លិនរបស់ព្រះជាម្ចាស់ជាប់នឹងរាងកាយរបស់ព្រះនាង តាំងពីព្រឹករហូតដល់យប់យ៉ាងណានោះខ្ញុំសូមឲ្យ បងស្រីជាប់តែក្លិនរបស់ព្រះជាម្ចាស់គ្រប់ពេលវេលាយ៉ាងនោះដែរ ដើម្បី

បងស្រីចាក់ឫសយ៉ាងជ្រៅក្នុងព្រះសហគមន៍នៅប្រទេសកម្ពុជាដោយស្រឡាញ់ ព្រះសហគមន៍នេះ និងដោយមានការសន្ទនា គឺសន្ទនាក្នុងក្រុមបងស្រីទាំងនៅក្នុងភូមិភាគភ្នំពេញ បាត់ដំបង និងកំពង់ចាម ដើម្បីបម្រើឲ្យអស់ពីកម្លាំងកាយនិងកម្លាំងចិត្ត។

សរុបសេចក្តីមក ថ្ងៃនេះយើងទាំងអស់គ្នាមានកម្លាំងថ្មីដើម្បីធ្វើដំណើរតទៅទៀត ដោយដឹងថាព្រះជាម្ចាស់មានព្រះហឫទ័យស្នេហ៍ចំពោះយើង ដោយដឹងថាយើងអាចទុកចិត្តទាំងស្រុងទៅលើព្រះយេស៊ូដោយសារឧបការគុណរបស់ព្រះអង្គ ហើយយើងក៏ត្រៀមខ្លួនជានិច្ចដើម្បីទទួលព្រះយេស៊ូ គឺព្រះយេស៊ូដែលគង់នៅទីនេះ និងព្រះយេស៊ូដែលគង់នៅទាំងយប់ទាំងថ្ងៃក្នុងចំណោមបងប្អូនទាំងអស់។ យើងសូមអរព្រះគុណព្រះជាម្ចាស់ សូមព្រះអង្គប្រទានព្រះវិញ្ញាណដ៏វិសុទ្ធមកគង់នៅជាមួយយើងខ្ញុំ ដើម្បីឲ្យយើងខ្ញុំអាចបន្តធ្វើដំណើររួមជាមួយព្រះនាងម៉ារី ដែលបង្ហាញឲ្យយើងខ្ញុំស្រឡាញ់ព្រះយេស៊ូកាន់តែខ្លាំងទៅៗ។

**"ព្រះជាម្ចាស់មានព្រះបន្ទូលមកខ្ញុំថា យើងបានស្រឡាញ់អ្នកដោយចិត្តស្រឡាញ់ ដែលស្ថិតស្ថេរអស់កល្បជានិច្ច"**

# យ៉ូហាន មានន័យថា ព្រះជាម្ចាស់មានព្រះហឫទ័យប្រណីសន្ដោស

The martyrs, signs of a forgiving God

---

អត្ថបទទី១ ៖ ផស ៣,១៤-១៨ក;
អត្ថបទទី២ ៖ ភីស ៤, ៤-៧
ដំណឹងល្អ ៖ លក ៣, ១០-១៨

ថ្ងៃនេះតាមប្រក្រតិទិនរបស់ព្រះសហគមន៍ គឺជាអាទិត្យទី៣នៃរដូវរង់ចាំដែលជាអាទិត្យនៃអំណរសប្បាយ។ កាលពីអាទិត្យទី១យើងបានស្ដាប់អត្ថបទគម្ពីរដែលចែងថា **"ប្រជាជននៃក្រុងស៊ីយ៉ូនអើយ! ចូរបន្លឺសម្លេងដោយអំណរ..."** និងនៅអាទិត្យទី២ "បងប្អូនជាទីស្រឡាញ់អើយ! ចូរបងប្អូនអរសប្បាយដោយព្រះអម្ចាស់គង់នៅជាមួយបងប្អូនជានិច្ច!"។ ខ្ញុំសូមជម្រាបមកបងប្អូនម្ដងទៀតថាចូរអរសប្បាយឡើង..."។ ដូច្នេះពេលនេះជាឱកាសមួយដែលយើងទាំងអស់គ្នា រួមគ្នាបង្ហាញអំណរសប្បាយ ដោយសារយើងកំពុងធ្វើដំណើរជាមួយព្រះជាម្ចាស់ ជាមួយព្រះនាងម៉ារី ដើម្បីទទួលស្វាគមន៍ព្រះជាម្ចាស់ដែលចាប់កំណើតជាមនុស្ស។ ក្នុងអត្ថបទថ្ងៃនេះ យើងមានលោកយ៉ូហានបាទីស្ដជាព្យាការីចុងក្រោយ ជាគំរូរបស់យើងបានរៀបចំផ្លូវថ្វាយព្រះយេស៊ូ។ ឈ្មោះ "យ៉ូហាន" មានន័យថា **"ព្រះជាម្ចាស់មានព្រះហឫទ័យប្រណីសន្ដោស"**។

ឆ្នាំនេះ យើងនៅក្នុងឆ្នាំព្រះមហាករុណាទិគុណ ដែលនាំឲ្យយើងនឹកឃើញដល់លោកយ៉ូហាន និងនឹកដល់ព្រះហឫទ័យមេត្តាករុណារបស់ព្រះជាម្ចាស់...។ ពេលនឹកដល់លោកយ៉ូហានបាទីស្ដ ភ្លាមនោះយើងនឹកដល់វាលរហោស្ថានហួតហែងដែលលោករស់នៅ។ ទីនោះ

---

ពិធីឆ្លងទ្វារនៃព្រះហឫទ័យមេត្តាករុណា
នៅព្រះវិហារសន្តយ៉ូសែប (ផ្សារតូច)
ថ្ងៃទី ១៣ ធ្នូ ២០១៥

គ្មានអ្វីគួរចាប់អារម្មណ៍ទេ ប៉ុន្តែលោកមានអំណរសប្បាយក្នុងចិត្ត ដើម្បីប្រកាសអំពីព្រះយេស៊ូដែលកំពុងយាងមក និងព្រះយេស៊ូជាដំណឹងល្អ។ ពេលលោកយ៉ូហានបង្ហាញសាវ័ករបស់លោកឲ្យឃើញព្រះយេស៊ូ ក៏ហាក់បីដូចជាលោកបង្ហាញឲ្យយើងទាំងអស់គ្នាឃើញព្រះបិតាដែរ គឺឃើញធម៌មេត្តាករុណារបស់ព្រះអង្គតាមរយៈអង្គព្រះយេស៊ូគ្រីស្តដែរ។ ព្រះជាម្ចាស់បានធ្វើដំណើរជាមួយជនជាតិអ៊ីស្រាអែល តាំងពីយូរសតវត្សហើយ នៅទីបំផុតព្រះអង្គបង្ហាញព្រះភ័ក្ត្រតាមរយៈព្រះយេស៊ូដែលប្រសូតជាមនុស្សដូចយើង។ ដោយហេតុនេះហើយ បានជាក្នុងឆ្នាំព្រះមហាករុណាទិគុណនេះ យើងមានឡូហ្គូមួយ ដែលមានរូបមនុស្សពីរនាក់ និងមានពាក្យស្លោកមួយ "ចូរមានមេត្តាករុណាដូចព្រះបិតាមានព្រះហឫទ័យមេត្តាករុណាដែរ"។

ឆ្នាំនេះ យើងចូលយ៉ាងជ្រៅនៅក្នុងធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ ហើយថ្ងៃនេះយើងមានអំណរសប្បាយរួមជាមួយមរណសាក្សីរបស់យើង ដែលមានចិត្តស្រឡាញ់ព្រះជាម្ចាស់យ៉ាងខ្លាំង រហូតសុខចិត្តលះបង់ជីវិត។ **គោរពមរណសាក្សីមានន័យថាយើងគោរពដល់ សេចក្តីស្រឡាញ់របស់ពួកគាត់ចំពោះព្រះជាម្ចាស់**។ ពេញមួយឆ្នាំនេះ យើងទាំងអស់គ្នានឹងមកក្នុងបន្ទប់មរណសាក្សីនេះ ដែលយើងបានរៀបចំយ៉ាងសមរម្យ ដើម្បីអធិដ្ឋាន និងដើម្បីឲ្យយើងមានចិត្តគំនិតតែមួយជាមួយពួកគាត់។ នៅក្នុងបន្ទប់នេះយើងមានតាំងគ្រែតំណាងមួយដើម្បីនឹករឭកដល់លោកអភិបាលឆ្នាសាឡាស់ លោកសាឡឹមដែលធ្លាប់អង្គុយអធិដ្ឋាន និងថ្វាយអភិបូជានៅពេលដែលលោកទាំងពីរទំនេរពីការងារ និងក៏ដើម្បីនឹករឭកដល់អស់លោកបូជាចារ្យ ដល់គ្រីស្តបរិស័ទទាំងអស់ដែលបានបូជាជីវិតនៅក្នុងកាលៈទេសៈដ៏លំបាកនោះ។ នៅលើគ្រែនេះ លោកបានថ្វាយសក្ការបូជាដែលជាសក្ការបូជារបស់ព្រះយេស៊ូ ហើយក៏ជាសក្ការបូជារបស់លោកផ្ទាល់នៅមុនពេលដែលលោកទទួលមរណភាពដែរ។ ថ្វាយអភិបូជា គឺថ្វាយជីវិតទៅព្រះជាម្ចាស់ដោយផ្ទាល់។ ដូច្នេះពេលយើងអធិដ្ឋានក្នុងបន្ទប់មរណសាក្សី ពេលយើងស្ថិតនៅខាងមុខគ្រែតំណាង ចូរឲ្យយើងនឹកឃើញជានិច្ចថា "**សក្ការបូជារបស់ព្រះយេស៊ូ ក្លាយជាសក្ការបូជារបស់មរណសាក្សីណែនាំឲ្យយើងមានជីវិតដ៏បរិបូណ៌**"។

នៅម្ខាងនោះមានតាំងសំបុកមាន់ នៅក្នុងសំបុកមាន់នោះយើងដាក់ឈើឆ្កាង ជាឈើឆ្កាងរបស់លោកអភិបាលឆ្នាសាឡាស់ ដែលម្តាយរបស់លោកយកទៅលាក់នៅក្នុងសំបុកមាន់កុំឲ្យខ្មែរក្រហមឃើញ។ ឈើឆ្កាងនោះបង្ហាញយើងពីទុក្ខលំបាករបស់មរណសាក្សីយើងក្នុងភាពងងឹតឆ្ពោះទៅរកពន្លឺ។ ឆ្នាំព្រះមហាករុណាទិគុណនេះក៏ជំរុញយើងឲ្យហាត់ពត់លត់ដំធ្វើដំណើរពីភាពងងឹតទៅរកពន្លឺដែរ។ បុណ្យណូអែលខាងមុខជាពន្លឺធំមួយ ហើយបុណ្យចម្លងជាពន្លឺដ៏ធំមួយទៀតដែលយើងនឹងធ្វើដំណើរឆ្ពោះទៅ ហើយពេញមួយឆ្នាំខាងមុខ យើងនឹងធ្វើបូជនិយចរពីភ្នំពេញថ្មីដែលមានទ្វារដ៏វិសុទ្ធ មកផ្សារតូចជាកន្លែងមរណសាក្សី និងទៅអរិយក្សត្រជាកន្លែងព្រះនាងម៉ារីដើម្បីឲ្យយើងមានអំណរសប្បាយពេញលក្ខណៈ។ ក៏ប៉ុន្តែយើងអាចមានអំណរសប្បាយបានលុះត្រាយើងយកចិត្តទុកដាក់ប្រែចិត្តគំនិត។ តើយើងប្រែចិត្តគំនិតរបៀបណា?

១) ដោយម្នាក់ៗឆ្លើយតបទៅនឹងព្រះហឫទ័យដ៏សប្បុរសរបស់ព្រះជាម្ចាស់ ដូចយើងបានស្តាប់នៅក្នុងអត្ថបទទី១ថា **"...កុំខ្លាចអ្វីឡើយក្រុងស៊ីយ៉ូនអើយ! កុំបាក់ទឹកចិត្តឲ្យសោះ ព្រះអម្ចាស់ជាព្រះរបស់អ្នក ព្រះអង្គគង់នៅជាមួយអ្នក ព្រះអង្គជាវីរបុរសដែលមានជ័យជម្នះ ..."**។ ខ្ញុំគិតថា មរណសាក្សីរបស់យើងក៏បានស្តាប់ព្រះបន្ទូលនេះដែរ ជាអ្វីដែលជំរុញឲ្យពួកគាត់មានកម្លាំងរហូតហ៊ានបូជាជីវិតព្រោះជំនឿ។ ឆ្នាំនេះជារៀងរាល់ថ្ងៃ យើងត្រូវការនឹកដល់ព្រះបន្ទូលនេះជានិច្ច **"កុំខ្លាចឲ្យសោះ កុំបាក់ទឹកចិត្តឲ្យសោះ ព្រះជាម្ចាស់គង់នៅជាមួយខ្ញុំ"** ហើយឲ្យយើងឆ្លើយតបយ៉ាងច្បាស់ ទៅព្រះជាម្ចាស់ដែលស្រឡាញ់យើងថា "ឱ!ព្រះអម្ចាស់អើយ ខ្ញុំធ្វើដំណើរជាមួយព្រះអង្គ ខ្ញុំមិនខ្លាចអ្វីទេ ខ្ញុំមិនបាក់ទឹកចិត្តទេ ដោយសារព្រះអង្គគង់ជាមួយខ្ញុំ"។

២) គួរឲ្យយើងពិចារណាអំពីចម្លើយរបស់លោកយ៉ូហានបាទីស្តចំពោះអ្នកទារពន្ធនិងទាហានដែលសួរលោកថា **"បើដូច្នេះ តើយើងត្រូវធ្វើអ្វីខ្លះ?"**។ ក្នុងឆ្នាំព្រះមហាករុណាទិគុណនេះយើងទាំងអស់គ្នាក៏ត្រូវសួរខ្លួនឯងថា "បើដូច្នេះ តើខ្ញុំត្រូវធ្វើអ្វីខ្លះ?"។ **ទីមួយ**ត្រូវធ្វើជីវិតលើព្រះជាម្ចាស់ដូចមរណសាក្សី និង**ទីពីរ** "អ្នកណាមានអាវ២ ត្រូវចែកឲ្យអ្នកដែលគ្មាន"។ ដូច្នេះ

យើងត្រូវចែករំលែកអ្វីៗដែលយើងមានដល់អ្នកដែលគ្មានដែរ។

ឆ្នាំនេះបូជនីយចររបស់យើង ចាប់ផ្តើមពីភ្នំពេញថ្មីនៅទីនោះម្នាក់ៗនឹងទទួលសៀវភៅមួយដែលប្រៀបដូចជាប៉ាស្ព័រ ដើម្បីទទួលសុភមង្គលដ៏ពេញលក្ខណៈដោយសារយើងប្រែចិត្ត។ ក្នុងសៀវភៅនោះមានចែងអំពីកិច្ចការទាំង៧ ដែលយើងត្រូវធ្វើដល់អ្នកដែលគ្មានទីពឹង គ្មានសេចក្តីសង្ឃឹម...ជាសេចក្តីដែលយើងស្រង់ពីព្រះគម្ពីរ៖ **"ពេលខ្ញុំឃ្លាន ពេលខ្ញុំស្រេក ពេលខ្ញុំគ្មានសម្លៀកបំពាក់ ពេលខ្ញុំជាអ្នកជំងឺ ពេលខ្ញុំជាប់ឃុំឃាំង ពេលខ្ញុំជាជនបរទេស ពេលខ្ញុំស្លាប់" តើយើងអាចធ្វើអីខ្លះដល់ពួកគាត់?។ ព្រះយេស៊ូឆ្លើយទៅអ្នកទារពន្ធដែលមានចិត្តលោភលន់ថា "កុំទារពន្ធលើសពីកម្រិតដែលបានកំណត់ទុកនោះឡើយ..."**។

ដូច្នេះឆ្នាំនេះ ព្រះយេស៊ូអញ្ជើញយើងឲ្យគិតអំពីអំណាចនៃទឹកលុយនិងអំណាចនៃបុណ្យសក្តិនៅក្នុងសង្គមបច្ចុប្បន្នដែរ។ ព្រះអង្គសូមឲ្យយើងមានចិត្តស្មោះត្រង់ឲ្យយើងរស់នៅក្នុងយុត្តិធម៌ ទោះបីយើងមិនមែនជាអ្នកទារពន្ធតែយើងត្រូវពិចារណាខ្លួនឯងថា **"តើខ្ញុំមានចិត្តស្មោះត្រង់ដល់កម្រិតណា? តើខ្ញុំយកចិត្តទុកដាក់អំពីយុត្តិធម៌នៅក្នុងជីវិតរបស់ខ្ញុំ និងជុំវិញខ្ញុំយ៉ាងដូចម្តេច? តើយូរៗម្តងខ្ញុំធ្លាក់នៅក្នុងអំពើពុករលួយដែរឬទេ?"** ដូច្នេះយើងត្រូវប្រុងប្រយ័ត្នដ្បិតថាអំពើពុករលួយមានមុខច្រើនណាស់។ ឆ្នាំនេះយើងត្រូវមានចិត្តស្មោះត្រង់បង្ហាញពីយុត្តិធម៌ជាយុត្តិធម៌មកពីព្រះជាម្ចាស់ដែលនាំឲ្យមនុស្សទាំងអស់មានសេចក្តីសុខ រស់នៅក្នុងតម្លៃដ៏ថ្លៃថ្នូរ។ ដូច្នេះសង្ឃឹមថាយើងជាគ្រីស្តបរិស័ទអាចជួយកសាងសង្គមយើងឲ្យទៅជាសង្គមបរិសុទ្ធដែលរួចផុតពីអំពើពុករលួយ។

៣) ក្នុងអត្ថបទព្រះយេស៊ូបានឆ្លើយទៅទាហានដែលសួរថា **"តើខ្ញុំត្រូវធ្វើអ្វីខ្លះ?"** ដោយមានព្រះបន្ទូលថា **"កុំចោទប្រកាន់ កុំសង្កត់សង្កិន"**។ តាមធម្មតាទាហានមានអំណាចលើសពីអ្នកមានលុយទៅទៀត ដូច្នេះយើងក៏ត្រូវពិចារណាអំពីរបៀបដែលយើងប្រើអំណាចដែរ។ យើងម្នាក់ៗមានអំណាចតាមរបៀបរៀងៗខ្លួន។ ឧទាហរណ៍យើងជាឪពុកជាម្តាយមានអំណាចលើកូន...កុំឲ្យយើងប្រើអំណាចសង្កត់លើកូនៗឡើយ។ ថ្ងៃនេះព្រះយេស៊ូអញ្ជើញយើងឲ្យយក

ចិត្តទុកដាក់គោរពអ្នកដទៃដោយដឹងថា អ្នកដទៃជាបងប្អូនរបស់យើង។ យើងជាបងប្អូនគ្នាដោយសារយើងមានព្រះបិតាតែមួយ។ តើធ្វើដូចម្តេចដើម្បីឲ្យជីវិតរបស់យើងជាសញ្ញាសម្គាល់នៃភាតរភាព?។ ឆ្នាំព្រះមហាករុណាទិគុណសូមឲ្យយើងយកចិត្តទុកដាក់គោរពសិទ្ធ សេរីភាពរបស់បងប្អូនឯទៀតៗ ឲ្យយើងបង្កើតក្រុមគ្រួសារមួយដែលចេះរស់នៅជាមួយគ្នានៅក្នុងសេចក្តីសុខសាន្ត។

ពេលធ្វើពិធីជ្រមុជទឹកឲ្យបណ្តាជនលោកយ៉ូហានបាទីស្តមានប្រសាសន៍ថា **"ខ្ញុំធ្វើពិធីជ្រមុជអ្នករាល់គ្នាក្នុងទឹក ប៉ុន្តែព្រះយេស៊ូនឹងធ្វើពិធីជ្រមុជអ្នករាល់គ្នាក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ និងក្នុងភ្លើងវិញ"**។ ភ្លើងដែលលោកនិយាយ គឺជាភ្លើងនៃសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ដែលជម្រះចិត្តគំនិតរបស់យើងឲ្យស្អាតបរិសុទ្ធ។ ថ្ងៃដែលយើងទទួលពិធីជ្រមុជទឹក គឺជាថ្ងៃដែលយើងបានចូលនៅក្នុងសេចក្តីស្រឡាញ់ដ៏ធំធេងរបស់ព្រះជាម្ចាស់។ ហេតុនេះហើយគ្រប់ពេលទទួលទឹកព្រះពរគឺជាឱកាសរំឭកយើងអំពីអគ្គសញ្ញាជ្រមុជទឹក ដែលយើងចូលក្នុងសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់។

ពេញមួយឆ្នាំនេះជាពេលវេលាឲ្យយើងនឹកឃើញថា ព្រះជាម្ចាស់បានជ្រើសរើសខ្ញុំ ព្រះ-ជាម្ចាស់បានស្រឡាញ់ខ្ញុំ ហើយខ្ញុំបានទទួលពិធីជ្រមុជទឹកនៅក្នុងភ្លើងនៃធម៌មេត្តាករុណារបស់ព្រះអង្គ។ ពេញមួយឆ្នាំនេះជាឱកាសឲ្យយើងប្រែចិត្តគំនិតដើម្បីនឹងទទួលពិធីជ្រមុជទឹកសាជាថ្មី ជាឱកាសឲ្យយើងស្រក់ទឹកភ្នែកដោយរំភើបចិត្តនឹងព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់ចំពោះយើងជាអ្នកបាបដែលទទួលការលើកលែងទោស។ ពេលនេះសូមឲ្យយើងរួមគ្នាបន្តថ្វាយអភិបូជា ទាំងមានអំណរសប្បាយស្របតាមអត្ថបទដែលយើងបានស្តាប់ឮថា ៖ **"បងប្អូនជាទីស្រឡាញ់អើយ! ចូរបងប្អូនអរសប្បាយ ដោយព្រះអម្ចាស់គង់នៅជាមួយបងប្អូនជានិច្ច!"**។

# ព្រះយេស៊ូជាព្រះសង្គ្រោះ

Jesus is the savior

អត្ថបទទី១ ៖ យរ ២៣, ៥-៨;
ដំណឹងល្អ ៖ មថ ១, ១៨-២៤

ព្រះបន្ទូលថ្ងៃនេះ ជំរុញឲ្យយើងបំពេញកិច្ចការរបស់យើងថែមទៀតក្នុងឆ្នាំ ២០១៦ ខាងមុខនេះ។ ព្យាការីយេរេមីបានប្រកាសថា **"ព្រះជាអម្ចាស់មានព្រះបន្ទូលថា នៅគ្រាខាងមុខគេនឹងលែងស្បថក្នុងនាមព្រះជាម្ចាស់ដែលមានព្រះជន្មគង់នៅ ដែលបាននាំជនជាតិអ៊ីស្រាអែលចេញពីស្រុកអេស៊ីបទៀតហើយ ផ្ទុយទៅវិញគេនឹងស្បថក្នុងនាមព្រះអម្ចាស់ដែលមានព្រះជន្មគង់នៅដែលណែនាំជនជាតិអ៊ីស្រាអែលឲ្យចេញទៅស្រុកទាំងប៉ុន្មាន ដែលព្រះអង្គកម្ចាត់កម្ចាយពួកគេឲ្យទៅ..."**។ គួរឲ្យយើងចាប់អារម្មណ៍នឹងពាក្យថា **"នៅគ្រាខាងមុខគេនឹងលែងស្បថ ... ផ្ទុយទៅវិញគេនឹងស្បថក្នុងនាម..."** តាមពិតព្យាការីយេរេមីកំពុងបង្ហាញប្រវត្តិសាស្ត្រនៃការសង្គ្រោះ គឺព្រះជាម្ចាស់បានណែនាំជនជាតិអ៊ីស្រាអែល ឲ្យចេញពីកណ្តាប់ដៃជនជាតិអេស៊ីបឆ្ពោះទៅកាន់សេរីភាព ហើយព្រះអង្គក៏បានណែនាំគេតាមរបៀបថ្មីទៀត ដែលពីមុនមានតែជនជាតិអ៊ីស្រាអែលទេដែលព្រះអង្គណែនាំតែពេលនេះមាន ទាំងជនជាតិអ៊ីស្រាអែលផង និងមានទាំងអ្នកស្រុកទាំងប៉ុន្មានដែលព្រះអង្គបានជ្រើសរើសផង។ ព្រះជាម្ចាស់របស់យើងមានព្រះហឫទ័យមេត្តាករុណាជានិច្ចព្រះអង្គប្រោសយើងឲ្យទៅជាមនុស្សថ្មីគ្រប់ពេលវេលា។ ព្រះអង្គមិនមានសកម្មភាពដដែលៗដែលនាំឲ្យយើងធុញនោះទេ។

---

ក្នុងឱកាសជួបជុំបុគ្គលិកការិយាល័យ
ទាំងអស់ នៅភ្នំពេញថ្មី
ថ្ងៃទី ១៨ ធ្នូ ២០១៥

តាមធម្មតានៅឆ្នាំថ្មីយើងតែងចាប់ផ្តើមការងារថ្មី។ តើឆ្នាំថ្មីនេះយើងនឹងធ្វើអ្វីដើម្បីរីកចម្រើនទៅមុខថែមទៀត? ឆ្នាំថ្មីនេះខ្ញុំសូមឲ្យការិយាល័យនីមួយៗរីកចម្រើនក្នុងរបៀបថ្មីមានកម្លាំងថ្មី តាមគម្រោងការថ្មីដោយដឹងថាមានព្រះជាម្ចាស់ណែនាំយើងហើយគម្រោងការរបស់យើងនឹងចម្រើនឡើងក្នុងសេចក្តីសុខសាន្ត។ យើងអាចទទួលបានជោគជ័យប្រសិនបើការិយាល័យនីមួយៗ ទៅជាកន្លែងសម្តែងព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់ដោយយើងលើកលែងទោសឲ្យគ្នាទៅវិញទៅមក។ យើងមិនអាចទៅមុខបានទេប្រសិនបើយើងមិនចេះលើកលែងទោសឲ្យគ្នា។ ព្រះជាម្ចាស់របស់យើងជាព្រះអម្ចាស់ដែលមានព្រះជន្មគង់នៅព្រះអម្ចាស់របស់មនុស្សដែលមានជីវិតមិនមែន ជាព្រះអម្ចាស់របស់មនុស្សស្លាប់ទេហេតុនេះហើយការិយាល័យនីមួយៗត្រូវតែជាកន្លែង បង្ហាញអំពីព្រះអម្ចាស់ដែលមានព្រះជន្មគង់នៅកន្លែងបង្ហាញពីជីវិតដ៏បរិបូណ៌។ ព្រះជាម្ចាស់របស់យើងណែនាំមនុស្សទាំងអស់ពីស្រុកទាំងប៉ុន្មានព្រះអង្គរំដោះគេហើយព្រះអង្គប្រមែប្រមូលគេឲ្យទទួលជីវិតថ្មី។ ហេតុដូច្នេះការិយាល័យនីមួយៗត្រូវមានសកម្មភាពដើម្បីប្រមូលមនុស្សពីគ្រប់ទីកន្លែង ប្រមូលមនុស្សដែលគ្មានទីពឹងមនុស្សអ្នកដែលគ្មានកម្លាំងកាយចិត្តមនុស្សដែលសង្គមបោះបង់ចោល មកបង្កើតជីវិតឲ្យគេតាមរបៀបព្រះជាម្ចាស់។

ចំពោះអត្ថបទទីពីរ សូមឲ្យយើងចាប់អារម្មណ៍អំពីនាមនីមួយៗមានលោកយ៉ូសែបជាស្វាមីព្រះនាងម៉ារីលោកជា**"មនុស្សសុចរិត"**។ មាននាម"ព្រះយេស៊ូយាងមកសង្គ្រោះមនុស្សលោក" និងមាននាម **"ព្រះអេម៉ាណូអែលប្រែថាព្រះជាម្ចាស់គង់នៅជាមួយយើង"**។ ក្នុងយុទ្ធសាស្រ្ត ឆ្នាំ២០១៦នេះ ខ្ញុំសូមឲ្យយើងរក្សាទុកនាមទាំងបីនេះជាកិច្ចការដ៏សំខាន់ដែលយើងត្រូវធ្វើ។

**"មនុស្សសុចរិត"** ៖ ខ្ញុំសូមបញ្ជាក់ថាដើម្បីទៅជាមនុស្សសុចរិតបាន លុះត្រាយើងបំពេញកិច្ចការទាំងប្រាំពីរ ខាងផ្លូវកាយនិងផ្លូវវិញ្ញាណដើម្បីបង្ហាញថាយើងជាមនុស្សស្មោះត្រង់ពិតមែន យើងស្រឡាញ់ព្រះជាម្ចាស់ពិតមែន ដូចលោកយ៉ូសែបដែលធ្វើតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់។

**"ព្រះយេស៊ូយាងមកសង្គ្រោះមនុស្សលោក"** ៖ សូមឲ្យយើងធ្វើជាសាក្សីផ្ទាល់របស់ព្រះយេស៊ូជាព្រះសង្គ្រោះ ឲ្យយើងបង្ហាញពីជីវិតថ្មីដែលយើងបានទទួលពីព្រះយេស៊ូតាមសកម្មភាពនីមួយដែលយើងបានធ្វើ។ ឧទាហរណ៍ ព្យាការីយេរេមីដែលទទួលជីវិតថ្មីលោកមិននៅស្ងៀមទេ លោកណែនាំមនុស្សឲ្យគេមានគំនិតថ្មីឲ្យគេភ្ញាក់រឭក ចំពោះសភាពការណ៍ថ្មីក្នុងសម័យដែលលោករស់នៅ។ ដូច្នេះសូមឲ្យការិយាល័យនីមួយៗ បង្ហាញអំពីសកម្មភាពអ្វីមួយដែលណែនាំឲ្យអ្នកដទៃទទួលសេចក្ដីសង្ឃឹមពីព្រះយេស៊ូជាព្រះសង្គ្រោះ។

**"ព្រះជាម្ចាស់គង់នៅជាមួយយើង"** ៖ សូមឲ្យសកម្មភាពភាពរបស់ការិយាល័យយើងរបស់ក្រុមការងារយើងបង្ហាញពិតមែនថាមានព្រះជាម្ចាស់គង់នៅជាមួយ។ សូមឲ្យក្រុមការងាររបស់ការិយាល័យនីមួយៗ មានសកម្មភាព ដោយអំណរ ដោយមានសន្តិភាពនៅក្នុងចិត្ត។ ដូច្នេះប្រធានការិយាល័យនីមួយៗ ត្រូវដឹងយ៉ាងច្បាស់ថាមានព្រះជាម្ចាស់គង់នៅជាមួយក្រុមការងាររបស់ខ្លួនពិតមែន។ មិនគ្រាន់តែជាពាក្យសម្ដីប៉ុណ្ណោះទេ ប៉ុន្តែឲ្យយើងអាចទៅមុខបានយ៉ាងជាក់ស្ដែងដូចយើងបានស្ដាប់ព្រះបន្ទូលនៅថ្ងៃនេះថា **"អេម៉ាណូអែល ប្រែថាព្រះជាម្ចាស់គង់នៅជាមួយយើង"** គឺព្រះអង្គគង់នៅគ្រប់សកម្មភាពដែលយើងធ្វើ ណែនាំឲ្យយើងមានកម្លាំងតស៊ូ និងឲ្យយើងទទួលជោគជ័យថែមទៀតផង។

សូមអរព្រះគុណព្រះជាម្ចាស់ សូមព្រះអង្គគង់នៅជាមួយយើងថែមទៀតដើម្បីឲ្យឆ្នាំខាងមុខនេះទៅជាឆ្នាំដ៏សុខសាន្តទៅជាឆ្នាំថ្មីដែលយើងប្រកាសពិតមែនថា **"ព្រះយេស៊ូជាព្រះសង្គ្រោះ"**។

# ចូរនាំគ្នាទៅ
# គ្រប់ទីកន្លែងក្នុងពិភពលោកទាំងមូល

Go into all the world...

---

អត្ថបទទី១ ៖ មីក ៥,១-៤ក;
អត្ថបទទី២ ៖ ហេប ១០,៥-១០
ដំណឹងល្អ ៖ លក ១, ៣៩-៤៥

ជិតដល់ថ្ងៃបុណ្យដែលយើងគោរពព្រះយេស៊ូប្រសូតហើយ។ ក្នុងរដូវរង់ចាំនេះយើងបានធ្វើដំណើរដោយសេចក្តីស្រឡាញ់ចេញពីភាពងងឹតឆ្ពោះទៅរកពន្លឺ  នេះជាដំណើរជីវិតរបស់យើង  គឺយើងខិតខំរៀបចំចិត្តគំនិតចូលទៅក្នុងចិត្តគំនិតរបស់ព្រះនាងម៉ារីដើម្បីទទួលស្វាគមន៍ព្រះយេស៊ូ។

គម្ពីរដំណឹងល្អថ្ងៃនេះ  **ស្តីអំពីព្រះនាងម៉ារីទៅសួរសុខទុក្ខយាយអេលីសាបិត។** នេះជាឱកាសមួយឲ្យយើងរៀបចំចិត្តគំនិតថែមទៀតដើម្បីយល់យ៉ាងច្បាស់អំពីរបៀបដែលព្រះយេស៊ូយាងមកក្នុងលោកនេះ។ យើងដឹងថា ព្រះនាងម៉ារីប្រញាប់ប្រញាល់ធ្វើដំណើរទៅកាន់ ភូមិមួយនៅតំបន់ភ្នំក្នុងស្រុកយូដា ដែលមានចម្ងាយផ្លូវប្រមាណជាង ១៣០គីឡូម៉ែត្រ ដោយកាត់តាមវាលរហោស្ថានក្តៅ។ ព្រះនាងម៉ារីធ្វើដំណើអស់រយៈពេល៧ថ្ងៃទាំងមានផ្ទៃពោះ។ នេះជាដំណើរលើកទីមួយរបស់ព្រះយេស៊ូ  ដែលនៅក្នុងផ្ទៃក្រោយមកព្រះអង្គធ្វើដំណើរហូតគឺធ្វើដំណើរពីផ្ទះយាយ  អេលីសាបិត  ទៅភូមិបេថ្លេហឹមជាកន្លែងដែលព្រះអង្គប្រសូតបន្ទាប់មកទៀតព្រះអង្គធ្វើដំណើរទៅស្រុកអេស៊ីប និងត្រឡប់មកណាសារ៉ែតវិញ។ ពេលព្រះយេស៊ូមានព្រះជន្មប្រមាណជាង៣០វស្សា  ព្រះអង្គបានយាងទៅស្រុក  កាលីឡេដើម្បីប្រកាសដំណឹងល្អ។  ក្រោយមកព្រះ

---

អភិបូជានៅព្រះសហគមន៍ព្រះកុមារយេស៊ូ បឹងទំពុន
ថ្ងៃទី ២០ ធ្នូ ២០១៥

អង្គយាងមកស្រុកសាម៉ារីវិញនិងយាងចូលក្រុងយេរូសាឡឹម។ ដូច្នេះដំណើរជីវិតរបស់ព្រះយេស៊ូពីថ្ងៃដែលព្រះអង្គចាប់កំណើតនៅក្នុងផ្ទៃមាតា រហូតដល់សោយទិវង្គតលើឈើឆ្កាងសុទ្ធតែជាការធ្វើដំណើរ។ នាទីចុងក្រោយព្រះអង្គមានព្រះបន្ទូលទៅកាន់សាវ័កអំពីការធ្វើដំណើរដែរ **"ចូរនាំគ្នាទៅគ្រប់ទីកន្លែងក្នុងពិភពលោកទាំងមូល..."**។

ថ្ងៃនេះយើងយល់ថាជីវិតរបស់យើងក៏ដូចព្រះនាងម៉ារីនិងព្រះយេស៊ូដែរ គឺយើងធ្វើដំណើររហូតដើម្បីសម្តែង ព្រះហឫទ័យប្រណីសណ្តោសរបស់ព្រះជាម្ចាស់ជាព្រះបិតានៃយើង។ នៅថ្ងៃបុណ្យព្រះយេស៊ូប្រសូតខាងមុខនេះ យើងជាគ្រីស្តបរិស័ទមិនអាចស្ថិតនៅក្នុងផ្ទះ បិទទ្វារជិតនិងចាក់សោរបានទេ យើងត្រូវតែធ្វើដំណើរចេញទៅដូចព្រះនាងម៉ារីដូចព្រះយេស៊ូ ដើម្បីជួបជាមួយអ្នកដទៃដើម្បីបង្ហាញព្រះបិតាដល់គេ។ ឆ្នាំព្រះមហាករុណាទិគុណនេះជាពេលវេលាមួយឲ្យយើងជាគ្រីស្តបរិស័ទទាំងអស់ចេញដំណើរពេញមួយឆ្នាំ ឲ្យយើងរៀបចំដួងចិត្តឲ្យយើងរៀបចំគំនិតសាជាថ្មី ឲ្យយើងចេញពីភាពងងឹតចូលនៅក្នុងពន្លឺឲ្យយើងរកឃើញពីរបៀបដែលព្រះបិតាស្រឡាញ់យើងរកឃើញពីរបៀបដែលព្រះបិតាលើកលែងទោសឲ្យយើង។ ពេញមួយឆ្នាំនេះឲ្យយើងធ្វើដំណើរដើម្បីទទួលជីវិតថ្មីពីព្រះបិតា។

**"ពេលខ្ញុំឮពាក្យជម្រាបសួររបស់នាង ស្រាប់តែកូននៅក្នុងផ្ទៃរបស់ខ្ញុំបម្រះឡើងទាំងមានអំណរសប្បាយ"** នេះណែនាំឲ្យយើងយល់ថាឥរិយាបថរបស់ព្រះនាងម៉ារីនៅពេលជួបយាយអេលីសាបិត ណែនាំឲ្យគាត់ និងកូនក្នុងផ្ទៃរបស់គាត់មានអំណរសប្បាយ។ ដូច្នេះវត្តមានព្រះនាងម៉ារីដែលពោរពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ ដែលពោរពេញដោយសេចក្តីស្រឡាញ់ដែលពោរពេញដោយអំណរសប្បាយ និងដែលព្រះជាម្ចាស់បានជ្រើសរើសព្រះនាងធ្វើជាមាតារបស់ព្រះយេស៊ូណែនាំឲ្យយាយអេលីសាបិតឃើញវត្តមានព្រះយេស៊ូនៅក្នុងព្រះនាងហើយ គាត់មានអំណរសប្បាយ និងកូនក្នុងផ្ទៃរបស់គាត់គឺយ៉ូហានបាទីស្តក៏បម្រះឡើងទាំងអំណរសប្បាយដែរ។ តាមពិតតាមរយៈព្រះនាងម៉ារី គឺជាព្រះយេស៊ូផ្ទាល់ដែលទៅសួរសុខទុក្ខយាយអេលីសា-បិត និងលោកយ៉ូហានបាទីស្ត ហើយក៏ជាព្រះយេស៊ូផ្ទាល់ដែលយាយអេលីសាបិត និងលោក

យ៉ូហានបាទីស្ដទទួលស្វាគមន៍។ ដូច្នេះក្នុងឱកាសបុណ្យព្រះយេស៊ូប្រសូតខាងមុខនេះ **តើយើងនឹងមានឥរិយាបថបែបណាដើម្បីណែនាំឲ្យបងប្អូនឯទៀតៗមើលឃើញ និងទទួលអំណរសប្បាយពីព្រះយេស៊ូដែលគង់នៅជាមួយយើង?** ដូច្នេះយើងត្រូវតែគិត យើងត្រូវតែរៀបចំដើម្បីឲ្យរបៀបរស់នៅរបស់យើងពីមួយថ្ងៃទៅមួយថ្ងៃ បង្ហាញអំពីវត្តមានរបស់ព្រះយេស៊ូដែលគង់នៅជាមួយយើង។

ម្សិលមិញនៅភ្នំពេញថ្មី យើងបានទទួលក្មេងៗជាង៤៥០នាក់ទាំងគេមានអំណរ សប្បាយហើយយើងក៏បានទទួលគ្រួសារក្រីក្រ ចាស់ជរា ជាង១០០គ្រួសារដែរ។ ក្នុងឱកាសនោះ សិស្សសាលាដុនបូស្កូក៏បានសម្ដែងរឿង និងបានបង្កើតកម្មវិធីច្រៀង រាំ និងជប់លៀងជាមួយគ្នាក្នុងបរិយាកាសសប្បាយរីករាយ។ កម្មវិធីនេះណែនាំឲ្យគេទាំងអស់គ្នាមានអារម្មណ៍ថាយើង ជាគ្រួសារតែមួយ ហើយគេអាចមើលឃើញព្រះហឫទ័យមេត្តាករុណារបស់ព្រះយេស៊ូដែលគង់នៅជាមួយយើង។ ថ្ងៃនេះយើងមានកម្មវិធីជាមួយក្មេងៗរាប់រយនាក់ ជាឱកាសមួយបង្កើតបរិយាកាសនៃសេចក្ដីស្រឡាញ់បរិយាកាសជាក្រុមគ្រួសារតែមួយដោយយើងចេះស្វាគមន៍គ្នាទៅវិញទៅមក និងបង្ហាញថាព្រះយេស៊ូគង់នៅជាមួយយើង ណែនាំឲ្យយើងចេះស្រឡាញ់គ្នា។ នៅពេលយើងអង្គុយសម្លឹងមើល ព្រះឱរសយេស៊ូនៅក្នុងរោងព្រះយេស៊ូប្រសូត នោះយើងត្រូវសួរខ្លួនយើងថា តើយើងបានឃើញព្រះហឫទ័យស្រឡាញ់របស់ព្រះបិតាក្នុងព្រះឱរសយេស៊ូដែរឬទេ? ហើយយើងក៏ត្រូវសួរខ្លួនឯងថានៅពេលបងប្អូនឯទៀត សម្លឹងមើលមកយើង តើគេបានឃើញព្រះបិតាដែលស្រឡាញ់គេនៅក្នុងយើងដែរឬទេ?

...ពេលយាយអេលីសាបិតពោរពេញដោយព្រះវិញ្ញាណ ភ្លាមនោះគាត់ក៏បន្លឺសំឡេងឡើងថា៖ **"នាងពិតជាមានសុភមង្គលមែន ព្រោះនាងបានជឿព្រះបន្ទូលដែលព្រះជាម្ចាស់ប្រាប់នាងមុខជាបានសម្រេចមិនខាន"**។ ... នៅពេលលោកសាការីទទួលដំណឹងថាបន្តិចទៀតគាត់នឹងទៅជាឪពុករបស់លោកយ៉ូហានបាទីស្ដ ភ្លាមនោះគាត់ទៅជាមនុស្សគលែងនិយាយបាន។ ...នៅពេលព្រះនាងម៉ារីទទួលដំណឹងថា បន្តិចទៀតព្រះនាងនឹងទៅជាមាតារបស់

ព្រះយេស៊ូ ភ្លាមនោះព្រះនាងក៏ពោរពេញដោយអំណរសប្បាយហើយសូត្រទំនុកតម្កើងកោត-សរសើរព្រះជាម្ចាស់ថា...។ ចំពោះយើងវិញនៅពេលណាយើងសុខចិត្តធ្វើតាមព្រះហឫទ័យព្រះជាម្ចាស់ នៅពេលណាយើងរៀបចំខ្លួនទទួលព្រះយេស៊ូពិតមែន ពេលនោះព្រះជាម្ចាស់ក៏នឹងប្រោសឲ្យយើងមានសមត្ថភាព ដើម្បីប្រកាសអំណរ សប្បាយនិងការអស្ចារ្យរបស់ព្រះអង្គតាមរយៈជីវិតរបស់យើងបានយ៉ាងពិតប្រាកដដែរ។

ដូច្នេះយើងដែលកំពុងត្រៀមខ្លួនទទួល ព្រះយេស៊ូប្រសូតនៅប៉ុន្មានថ្ងៃទៀតខាងមុខនេះចូរយើងយកចិត្តទុកដាក់បើកចិត្តគំនិតថែមទៀត រៀបចំខ្លួនថែមទៀតទុកសម្រាប់រាត្រីបុណ្យព្រះយេស៊ូប្រសូត។ នៅរាត្រីនោះយើងនឹង ច្រៀងកោតសរសើរសេរីរុងរឿងរបស់ព្រះជាម្ចាស់រួមជាមួយក្រុមគ្រីស្តទូត។ រាត្រីនោះយើងនឹងប្រកាសដំណឹងល្អអំពីព្រះយេស៊ូយាងមកដើម្បីរំដោះយើង។ ដូច្នេះក្នុងឆ្នាំព្រះមហាករុណាទិគុណនេះកុំឲ្យយើងទៅជាមនុស្សដែលគ្មានសំឡេងតែឲ្យយើងទៅជាសាវ័ករបស់ព្រះយេស៊ូដែលមានសំឡេងក្នុងការប្រកាសដំណឹងល្អ ឲ្យយើងបំពេញកិច្ចការមេត្តាករុណាទាំងខាងផ្លូវកាយនិងទាំងខាងផ្លូវវិញ្ញាណដែរ។

ថ្ងៃនេះយើងខ្ញុំសូមអរព្រះគុណព្រះជាម្ចាស់ដោយរួមជាមួយព្រះនាងម៉ារី យើងខ្ញុំសូមរួមជាមួយព្រះនាងម៉ារីដែលបានធ្វើដំណើរទៅសួរសុខទុក្ខយាយអេលីសាបិត យើងខ្ញុំសូមរួមជាមួយព្រះនាងម៉ារីដែលពោរពេញដោយ សុភមង្គល ដើម្បីបន្តរៀបចំខ្លួនធ្វើជាសាវ័ករបស់ព្រះយេស៊ូយ៉ាងល្អជានិច្ច។

# ព្រះជាម្ចាស់ណែនាំឲ្យយើងឆ្លងទ្វារនៃជំនឿ

God invites us to pass through the door
of Faith, Hope, and Love

ថ្ងៃទី ១០ ធ្នូ ២០១៥ កន្លងមក យើងបានរួមគ្នាឆ្លងទ្វារនៃឆ្នាំដ៏វិសុទ្ធសង់ឡើងក្នុងបរិវេណនៃមណ្ឌលណែនាំនៅភ្នំពេញថ្មី។ ទ្វារនោះជានិមិត្តរូបអំពីទ្វាររបស់អាសនៈវិហារ ដែលយើងមិនទាន់សាងសង់នៅឡើយ។ ឥឡូវទ្វារនោះបានបើកឲ្យយើងអាចទៅកាន់ព្រះនាងព្រហ្ម-ចារិនីម៉ារីដែលពរបុត្ររបស់ព្រះនាង ហើយព្រះនាងអញ្ជើញយើងឲ្យសម្លឹងមើលបុត្រដែលជាព្រះភក្ត្ររបស់ព្រះបិតាប្រកបដោយព្រះហឫទ័យមេត្តាករុណា។

ថ្ងៃទី ១៣ ធ្នូ ២០១៥ កន្លងមក យើងបានបាចទឹកព្រះពរនូវកន្លែងអធិដ្ឋានថ្មីដ៏តូចមួយនៅព្រះសហគមន៍សន្តៈយ៉ូសែប ឧទ្ទិសជូនដល់មរណសាក្សី។ កន្លែងអធិដ្ឋានថ្មីដ៏តូចនោះនឹងជួយយើងឲ្យអធិដ្ឋានរួមជាមួយមរណសាក្សីរបស់យើង។ មរណសាក្សីទាំងនោះ សុខចិត្តបូជាជីវិតថ្វាយព្រះជាម្ចាស់ គឺបានសម្ដែងអំពីព្រះហឫទ័យមេត្តា ករុណាដែលគ្មានព្រំដែនរបស់ព្រះអង្គ។

ថ្ងៃទី ០១ មករា ២០១៦ កន្លងមក យើងបានលើកតម្កើងព្រះនាងម៉ារីជាព្រះមាតារបស់ព្រះអម្ចាស់នៅព្រះសហគមន៍អរិយក្សត្រ ទាំងទូលអង្វរព្រះអម្ចាស់ប្រោសប្រទានសុខសន្តិភាពសម្រាប់មនុស្សលោក និងសម្រាប់ប្រទេសកម្ពុជាយើង ព្រមទាំងសម្រាប់ក្រុមគ្រួសារនីមួយៗរបស់យើង ដោយមានព្រះមហាក្សត្រីនៃទន្លេមេគង្គជួយឧបត្ថម្ភផង។

---

សារលិខិតលោកអភិបាល អូលីវីយេ
បុណ្យព្រះយេស៊ូសម្ដែងឋានៈព្រះអង្គ ថ្ងៃទី០១ មករា ២០១៦

ឆ្នាំនៃមហាករុណាទិគុណនេះ បញ្ចប់ឆ្នាំទាំងបីសម្រាប់សម្ដែងព្រះហឫទ័យមេត្ដាករុណាទាំងអញ្ជើញយើងឲ្យរស់នៅយ៉ាងខ្លាំងបំផុត តាមព្រះហឫទ័យមេត្ដាករុណាដ៏គ្មានព្រំដែនរបស់ព្រះបិតាសម្រាប់យើងម្នាក់ៗ គឺឲ្យយើងប្រែចិត្តដើម្បីបើកភ្នែកនិងត្រចៀករបស់ខ្លួន ទៅរកអស់អ្នកដែលកំពុងរងទុក្ខ និងដែលស្រេកឃ្លានយុត្តិធម៌និងសន្តិភាព។

ពេលយើងកំពុង នឹកសញ្ជឹងគិតដល់គម្រោងការដ៏អស្ចារ្យអំពីព្រះជាម្ចាស់ប្រសូតជាមនុស្ស ដែលជាសញ្ញាសម្គាល់សម្ដែងអំពីព្រះហឫទ័យមេត្ដាករុណារបស់ព្រះបិតាចំពោះមនុស្សលោក នោះខ្ញុំសូមអញ្ជើញបងប្អូនឲ្យឆ្លងកាត់តាមទ្វារបី ក្នុងឆ្នាំខាងមុខនេះ គឺ ៖

## ១- ទ្វារនៃជំនឿ

**"កុំខ្លាចអ្វីឡើយ ខ្ញុំនាំដំណឹងល្អមួយមកប្រាប់អ្នករាល់គ្នាគឺព្រះសង្គ្រោះរបស់អ្នករាល់គ្នាប្រសូតហើយ...នេះជាសញ្ញាសម្គាល់ឲ្យអ្នករាល់គ្នាដឹងគឺអ្នករាល់គ្នានឹងឃើញទារកមួយទើបនឹងប្រសូត រុំដោយសំពត់ដាក់ផ្ដេកនៅក្នុងស្នូកសត្វ"** (លូកា ២: ១២-១៣)

យប់បុណ្យព្រះយេស៊ូប្រសូត មានសេចក្ដីជាច្រើនខុសប្លែកៗពីគ្នាកើតឡើង គឺព្រះអង្គសង្គ្រោះដែលអស់លោកព្យាការីបានជូនដំណឹងតាំងពីដើមរៀងមក បង្ហាញព្រះអង្គជាទារករុំដោយសំពត់ ដាក់ផ្ដេកនៅក្នុងស្នូកសត្វ ដោយសេចក្ដីស្រឡាញ់។

ព្រឹត្តិការណ៍នេះនាំឲ្យខ្ញុំនឹកដល់ព្រះវិហារព្រះយេស៊ូប្រសូតនៅភូមិបេថ្លេហឹម ដែលយើងបានទស្សនារួមជាមួយនិស្សិតនៃសាលាសន្ដះយូស្ដាំងនាឆ្នាំ ២០១៣ នោះ គឺមានទ្វារដ៏ប្រសើរសម្រាប់ឲ្យលោកធំៗជិះសេះអាចចូលបាន។ តែអ្នកចង់ចូលទៅកាន់រូងដែលជាកន្លែងព្រះយេស៊ូប្រសូត ត្រូវតែឆ្លងកាត់ទ្វារដ៏តូចទាបមួយដែលបង្ខំអស់លោកកាន់អំណាចចុះពីសេះ និងឱនខ្លួនដើម្បីទៅគោរពនមស្សការកន្លែងព្រះសង្គ្រោះប្រសូត។

ពេលយប់ព្រះយេស៊ូប្រសូត ព្រះអង្គបានអញ្ជើញយើងឲ្យបន្ទាបខ្លួន ដើម្បីទទួលសេចក្ដីដែលប្រាជ្ញារបស់មនុស្សលោកមិនអាចយល់បាន គឺព្រះជាម្ចាស់មានព្រះហឫទ័យសុភាពរាបសា។

តាំងពីកំណើតពិភពលោកមក មនុស្សយើងមានបំណងចង់បានប្រសើរជាងព្រះជាម្ចាស់ គឺលោកអាដាំនិងនាងអេវ៉ា បានពិសាផ្លែដែលព្រះជាម្ចាស់ហាមមិនឲ្យពិសា និងក្នុងរឿងប្រាសាទនៅស្រុកបាបែលមនុស្សចង់សង់ប៉មទៅកាន់មេឃ។ល។ សង្គមយើងលូតលាស់យ៉ាងសម្បើមនៅភ្នំពេញ និងជំរុញយើងឲ្យមានកម្លាំងដោយមិនបាច់គិតដល់ព្រះជាម្ចាស់។ ក្នុងយប់បុណ្យព្រះយេស៊ូប្រសូត គឺព្រះជាម្ចាស់ប្រសូតជាមនុស្ស ព្រះអង្គមករកយើង ព្រះអង្គអញ្ជើញយើងឲ្យឆ្លងទ្វារនៃជំនឿ ដើម្បីទទួលព្រះយេស៊ូក្នុងការរស់នៅរបស់យើងក្នុងពិភពលោកយើង។ នៅពេលយើងឆ្លងកាត់ទ្វារនៃជំនឿ តើយើងរកឃើញអ្វីខ្លះ?

## ២- ទ្វារនៃព្រះហឫទ័យមេត្តាករុណា

**"ព្រះជាម្ចាស់បានសម្តែងព្រះហឫទ័យប្រោសប្រណីមកដើម្បីសង្គ្រោះមនុស្សទាំងអស់"**

(ទីតុស ២: ១១)

ក្នុងឆ្នាំមេត្តាករុណាយើងនាំគ្នាធ្វើបុណ្យខួបទី៥០នៃធម្មនុញ្ញ"អំណរនឹងសេចក្តីសង្ឃឹម" ដែលដាស់តឿនយើងឲ្យតបឆ្លើយជាបន្ទាន់ គឺថា "អំណរសប្បាយនិងសេចក្តីសង្ឃឹម ទុក្ខព្រួយនិងកង្វល់របស់មនុស្សលោកនាសម័យឥឡូវ ជាពិសេសរបស់ជនក្រីក្រ និងអ្នករងទុក្ខវេទនាជាដើមក៏ជាអំណរសប្បាយ ជាសេចក្តីសង្ឃឹម ជាទុក្ខព្រួយនិងជាកង្វល់របស់សាវ័កព្រះគ្រីស្តដែរ ។ អ្វីៗដែលពាក់ព័ន្ធនឹងលក្ខណៈដ៏ពិតប្រាកដរបស់មនុស្ស ក៏ពាក់ព័ន្ធនឹងសាវ័ករបស់ព្រះអង្គដែរ។ សហគមន៍របស់គ្រីស្តបរិស័ទសាងសង់ឡើង ដោយសារមនុស្សរួមគ្នាក្នុងអង្គព្រះគ្រីស្ត ហើយមានព្រះវិញ្ញាណដ៏ វិសុទ្ធណែនាំពេលធ្វើដំណើរឆ្ពោះទៅកាន់ព្រះរាជ្យរបស់ព្រះបិតា។ គ្រីស្តបរិស័ទទទួលសារមួយស្តីអំពី "ការសង្គ្រោះ" ដែលត្រូវជម្រាបជូនដល់មនុស្សទាំងអស់។ សហគមន៍របស់គ្រីស្តបរិស័ទទទួលស្គាល់ថា ខ្លួនរួមសាមគ្គីយ៉ាងជិតស្និទ្ធនិងយ៉ាងពិតប្រាកដជាមួយមនុស្សជាតិទាំងមូល និងតាមប្រវត្តិសាស្ត្ររបស់មនុស្សជាតិ" (GS 1.1)។

នេះពិតជាកម្មវិធីសម្រាប់ឆ្នាំដ៏វិសុទ្ធយើងនេះ គឺនៅពេលយើងឆ្លងកាត់ទ្វារនៃព្រះហឫទ័យមេត្តាករុណា ចិត្តគំនិត យើងលាតត្រដាងសេចក្តីស្រឡាញ់ដល់មនុស្សទាំងអស់ យើងប្រែចិត្តគំនិតនិងបំពេញសកម្មភាពយ៉ាងពិតមែន ចំពោះមនុស្សដូចគ្នា តាមរបៀបព្រះយេស៊ូ។ ចូរបណ្តោយឲ្យជនជាតិសាម៉ារីប្រកបដោយចិត្តសប្បុរស និងព្រះយេស៊ូដែលលាងជើងក្រុមសាវ័កណែនាំយើងតទៅទៀតក្នុងឆ្នាំ ២០១៦ ខាងមុខនេះ។

ដោយសម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ ជាអភិបាលព្រះសហគមន៍ក្រុងរ៉ូមដាស់តឿន ខ្ញុំសូមអញ្ជើញបងប្អូន ឲ្យរស់នៅតាមលំដាប់នៃកិច្ចការសម្តែងព្រះហឫទ័យមេត្តាករុណា ស្របតាមរូបកាយនិងតាមវិញ្ញាណ (សូមមើលភាគទី ២ ខាងក្រោមនេះ)

ដោយមហាសន្និបាតនៃគណៈកម្មការសង្គហៈ នៅខែកញ្ញាកន្លងផុតទៅដាស់តឿនយើងខ្ញុំក៏សូមអញ្ជើញព្រះសហគមន៍នីមួយៗ ក្នុងភូមិភាគយើងឲ្យអនុវត្តតាមធម្មនុញ្ញថ្មី ហើយជាពិសេសឲ្យជ្រើសរើសអាទិភាពក្នុងអាទិភាពទាំង៦ ដែលយើងបានបញ្ជាក់រួមគ្នានៅពេលនោះដើម្បីឲ្យស្តាប់សូរសម្រែកនៃប្រជាជនរបស់យើងគឺ៖

១- ការអប់រំ

២- សុខភាព

៣- ក្រុមកម្មករ កម្មការិនី

៤- ជនពិការ

៥- កិច្ចការពារបរិដ្ឋាន

៦- ការបញ្ចូលអ្នកក្រីក្រក្នុងសង្គម

ខ្ញុំសូមបន្ថែមមួយទៀត គឺ

៧- ការសន្ទនាជាមួយសាសនាឯទៀតៗ នៅពេលធ្វើបុណ្យខួបទី ៥០ នៃសេចក្តីប្រកាស "សម័យយើង" ។

ព្រះសហគមន៍ដាស់តឿនបុត្រធីតារបស់ខ្លួន ឲ្យទទួលស្គាល់និងថែរក្សានូវសេចក្ដីដ៏ថ្លៃថ្នូរទាំងខាងផ្លូវវិញ្ញាណ ខាងសីលធម៌ និងខាងសង្គម និងវប្បធម៌ដែលមានកប់ទុកក្នុងសាសនាទាំងនោះ។ ព្រះសហគមន៍ក៏ត្រូវធ្វើឲ្យសេចក្ដីដ៏ថ្លៃថ្នូរទាំងនោះចម្រើនឡើងទៀតផង(NA 2)។

បងប្អូនជាទីស្រឡាញ់ តាមបាវចនារបស់ឆ្នាំមហាករុណាទិគុណដាស់តឿនយើងយ៉ាងពិសេស យើងត្រូវសញ្ជឹងគិត ព្រះយេស៊ូជាព្រះបុត្រា សូមឲ្យព្រះហឫទ័យមេត្តាករុណារបស់ព្រះ-បិតាសម្លឹងមើលយើងដែរ។ ដោយព្រះហឫទ័យ ប្រោសប្រណីរបស់ព្រះអង្គ យើងអាចរួមគ្នាឆ្លងកាត់ទ្វារទី៣ គឺជាទ្វារនៃសេចក្ដីសង្ឃឹម។

## ៣- ទ្វារនៃសេចក្ដីសង្ឃឹម

**"គេនឹងថ្វាយព្រះនាមបុត្រនោះថា ព្រះប្រកបដោយព្រះប្រាជ្ញាញាណព្រះដ៏មានឫទ្ធិចេស្ដា ព្រះបិតាដ៏មានព្រះជន្មគង់នៅអស់កល្បជានិច្ច ព្រះអង្គម្ចាស់នៃសេចក្ដីសុចក្ដីសាន្ដ"**

(អេសាយ ៩: ៥)

ក្នុងយប់ដ៏វិសុទ្ធនៃព្រះយេស៊ូប្រសូត យើងបានឮព្រះនាមរបស់ព្រះយេស៊ូទាំងស្ញើចសរសើរ។ ព្រះអង្គជាទ្វារ។ នេះជាសេចក្ដីសង្ឃឹមដ៏ល្អប្រសើរបំផុតសម្រាប់មនុស្សលោកយើងដែលជ្រួលច្របល់នៅឆ្នាំ ២០១៥ កន្លងមកដោយមានមនុស្សស្អប់គ្នា ប្រើហឹង្សា មានភាពក្រីក្រនិងអំពើពុករលួយដែលបង្ខូចមុខមាត់សង្គម។

សេចក្ដីសង្ឃឹមដើម្បីប្រឈមមុខនឹងហិង្សាក្នុងពិភពលោក និងក្នុងក្រុមគ្រួសាររបស់យើងមានឈ្មោះ គឺព្រះអម្ចាស់នៃសេចក្ដីសុខសាន្ដ។

សេចក្ដីសង្ឃឹមដើម្បីប្រឈមមុខនឹងការមើលងាយ និងមើលថោកក្នុងសង្គមយើងមានឈ្មោះ គឺព្រះបិតាដ៏មានព្រះជន្មគង់នៅអស់កល្បជានិច្ច។

សេចក្ដីសង្ឃឹមដើម្បីប្រឈមមុខនឹងភាពទន់ខ្សោយនិងភាពក្រីក្រ មានឈ្មោះ គឺព្រះដ៏មានឫទ្ធិចេស្ដា។

សេចក្ដីសង្ឃឹមដើម្បីប្រឈមមុខនឹងយុវជនដែលបាត់ទិសដៅក្នុងជីវិត ប្រឈមមុខនឹងក្រុមគ្រួសារដែលបាក់បែកគ្នាមានឈ្មោះ គឺព្រះប្រកបដោយព្រះប្រាជ្ញាញាណ។

សេចក្ដីសង្ឃឹមរបស់យើងមានឈ្មោះនិងមានមុខ គឺព្រះយេស៊ូ ។ សូមនឹងសញ្ជឹងគិតអំពីព្រះអង្គ។ សូមឲ្យពន្លឺរបស់ព្រះគ្រីស្ដបំភ្លឺយើង ដើម្បីឲ្យយើងបានកាន់តែដូចព្រះអង្គក្នុងឆ្នាំនៃមេត្តាករុណានេះ។

យើងត្រូវឆ្លងកាត់ទ្វារទាំងបីនោះក្នុងចិត្តយើងជាមុនសិន រួចយើងត្រូវបើកទ្វារទាំងនោះដោយផ្ទាល់ដៃ ដើម្បីឲ្យគ្រប់កិច្ចការដែលសម្ដែងអំពីព្រះហឫទ័យមេត្តាករុណា និងអំពីការថ្នាក់ថ្នមដែលយើងបានបង្ហាញ ក្នុងរដូវបុណ្យព្រះយេស៊ូប្រសូតនោះ នៅកន្លែងមន្ទីរឃុំឃាំង ដោយទៅសួរសុខទុក្ខក្រុមគ្រួសារក្រីក្រ ទៅសួរសុខទុក្ខចាស់ជរាដែលគ្មាននរណារាប់រក ជាមួយកុមារកុមារីពោរពេញដោយសេចក្ដីសង្ឃឹម ដែលបានលេងរឿងព្រះយេស៊ូប្រសូត។ល។ សូមបន្តកិច្ចការទាំងនោះក្នុងឆ្នាំ ២០១៦ ខាងមុខនេះ។

ខ្ញុំសូមជូនពរអោយបងប្អូនទាំងអស់ក្នុងឆ្នាំមហាករុណាទិគុណនេះមាន

សេចក្ដីសុខសាន្តនិងអំណរសប្បាយ

សេចក្ដីសង្ឃឹមនិងសេចក្ដីស្រឡាញ់

សុខភាពល្អនិងសេចក្ដីក្លាហាន

សូមអរព្រះគុណចំពោះបងប្អូនទាំងអស់ដែលមានអំណរក្នុងការប្រកាសដំណឹងល្អ

យើងត្រូវអង្វរព្រះបិតាសម្រាប់គ្នាទៅវិញទៅមក

យើងត្រូវមានចិត្តមេត្តាករុណា ដូចព្រះបិតាមានព្រះហឫទ័យមេត្តាករុណា

"ព្រះជាម្ចាស់មិនមានព្រះហឫទ័យមិនអើពើទេ ព្រះអង្គប្រោសប្រទានឲ្យមនុស្សមាន
សារៈសំខាន់ ព្រះអង្គមិនលះបង់ចោលមនុស្សលោកទេ"
សារលិខិតសម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ ក្នុងឱកាសប្រារព្ធទិវាសន្តិភាពពិភពលោកលើកទី៤៩
"ជម្នះលើភាពពុំអើពើ និងនាំមកនូវសន្តិភាព"។

បុណ្យគោរពព្រះនាងម៉ារីជាព្រះមាតារបស់ព្រះជាម្ចាស់
០១ មករា ២០១៦

APOSTOLIC VICARIATE PHNOM PENH

លោកអូលីវីយេ ដ្មឹតអឺស្លែរ
ជាអភិបាលរបស់បងប្អូន

# យើងមើលឃើញព្រះជាម្ចាស់តាមរបៀបព្រះនាងម៉ារី

Mary, the mirror of God's love

---

អត្ថបទទី១ ៖ ជរ ៦, ២២-២៧
អត្ថបទទី២ ៖ កាឡ ៤,៤-៧
ដំណឹងល្អ ៖ លក ២, ១៦-២១

ថ្ងៃនេះយើងរួមជាមួយព្រះសហគមន៍ យើងគោរពព្រះនាងម៉ារីដែលជាព្រះមាតារបស់ព្រះជាម្ចាស់។ នេះជាការអស្ចារ្យ ដែលព្រះយេស៊ូចាប់កំណើតជាមនុស្សជាមួយព្រះនាងម៉ារី។ ពេលយើងស្តាប់ពាក្យនេះ ប្រហែលណែនាំឲ្យយើងឆ្ងល់ថា ធ្វើដូចម្តេចដើម្បីឲ្យព្រះនាងម៉ារីជាម្តាយរបស់ព្រះជាម្ចាស់?។ ប៉ុន្តែពិតមែនតាំងពីដើមរៀងមកព្រះសហគមន៍ជឿថា ព្រះជាម្ចាស់បានជ្រើសរើសព្រះនាងម៉ារីជាស្ត្រីព្រហ្មចារី ឲ្យព្រះយេស៊ូចាប់កំណើតជាមនុស្សដើម្បីណែនាំឲ្យយើងទទួលជីវិតថ្មី តាមរយៈព្រះយេស៊ូគ្រីស្ត និងជាពិសេសដើម្បីឲ្យយើងបានមើលឃើញព្រះភ័ក្ត្ររបស់ព្រះជាម្ចាស់ដោយផ្ទាល់ផង។

ថ្ងៃនេះយើងមានអំណរសប្បាយខ្លាំងណាស់ យើងមកពីគ្រប់ទីកន្លែងក្នុងភូមិភាគភ្នំពេញដើម្បីបន្តចូលនៅក្នុងឆ្នាំព្រះមហាករុណាទិគុណ។  តាមពិតមុននេះយើងបានចូលតាមទ្វារដ៏វិសុទ្ធនៅភ្នំពេញថ្មីរួចហើយ បន្ទាប់មកបានចូលតាមទ្វារដ៏វិសុទ្ធនៅផ្សារតូច ដើម្បីឲ្យមរណសាក្សីស្ថិតនៅជាមួយយើងតាមរបៀបមួយយ៉ាងពិសេស ក្នុងឆ្នាំព្រះមហាករុណាទិគុណនេះហើយនៅថ្ងៃនេះ  យើងចូលតាមទ្វារដ៏វិសុទ្ធនៅអារិយក្សត្រដើម្បីរួមជាមួយព្រះនាងម៉ារីដែលស្រឡាញ់

---

ពិធីបើកទ្វារនៃសេចក្តីសង្ឃឹម
នៅព្រះវិហារមាតានៃសន្តិភាពអរិយក្សត្រ
ថ្ងៃទី ០១ មករា ២០១៦

យើងដែលណែនាំឲ្យយើងយល់អំពីរបៀបដែលព្រះនាងធ្វើដំណើរជាមួយយើង និងដែលណែនាំឲ្យយើងស្រឡាញ់ព្រះយេស៊ូ ថែមទៀតនៅពេលដែលយើងឃើញព្រះនាងកំពុងពរព្រះកុមារយេស៊ូនៅនឹងដៃ។ ដូច្នេះឆ្នាំនេះយើងមានទ្វារដ៏វិសុទ្ធចំនួនបីដែលត្រូវឆ្លងកាត់យ៉ាងពិតប្រាកដមែនដើម្បីទទួលជីវិតថ្មីរួមជាមួយព្រះជាម្ចាស់។ ចាប់ពីថ្ងៃស្អែកទៅសូមលោកឪពុកបងប្រុសបងស្រី និងបងប្អូនទាំងអស់មកចុះឈ្មោះដើម្បីធ្វើដំណើរដ៏វិសុទ្ធមួយថ្ងៃនៅក្នុងឆ្នាំនេះពីពេលនេះរហូតដល់ខែវិច្ឆិកា។

អម្បាញ់មិញ យើងបានស្ដាប់ឮថា **"សូមព្រះអម្ចាស់ សម្ដែងព្រះហឫទ័យសប្បុរសចំពោះអ្នក និងប្រទានឲ្យអ្នកបានប្រកបដោយសេចក្ដីសុខសាន្ត!"** នេះជាពាក្យជូនពរដែលយើងទទួលនៅថ្ងៃនេះពីព្រះជាម្ចាស់ និងពីព្រះសហគមន៍របស់យើង នៅពេលដែលយើងជួបជុំគ្នាគោរពព្រះនាងម៉ារីជាព្រះមហាក្សត្រីនៃសន្តិភាព និងសូមឲ្យយើងដឹងយ៉ាងច្បាស់ថាកន្លែងនេះ ជាកន្លែងមួយដែលយើងត្រូវអធិដ្ឋានសម្រាប់សុខសន្តិភាព នៅក្នុងជីវិតរបស់យើងផ្ទាល់នៅក្នុងក្រុមគ្រួសារយើងនៅក្នុងព្រះសហគមន៍យើង និងជាពិសេសសម្រាប់ប្រទេសកម្ពុជាយើងទាំងមូល ហើយក៏ឲ្យយើងបើកចិត្តទូលាយអធិដ្ឋានសម្រាប់ពិភពលោកទាំងមូលទៀតផង។ ដូចនេះគ្រប់ពេលវេលាដែលយើងមកទីនេះ មិនមែនមកដើម្បីដើរលេង ដើម្បីមើលរូបព្រះនាងម៉ារីតាមរបៀបធម្មតា ប៉ុន្តែឲ្យយើងមកដើម្បីទទួលសុខសន្តិភាពដែលមកពីព្រះជាម្ចាស់ផ្ទាល់ពីព្រះយេស៊ូផ្ទាល់ ដូចយើងបានស្ដាប់ឮព្រះបន្ទូលនៅក្នុងរាត្រីបុណ្យព្រះយេស៊ូប្រសូតថា "ព្រះយេស៊ូជាព្រះមហាក្សត្រនៃសុខសន្តិភាព"។

ថ្ងៃនេះ ជាថ្ងៃទី១ ខែមករា ឆ្នាំ២០១៦ ជាថ្ងៃដែលសម្ដេចប៉ាប ហ្វ្រង់ស៊ីស្កូ ចេញសារលិខិតជូនពរដល់ពិភពលោកទាំងមូលឲ្យបញ្ឈប់ការមិនអើពើ និងឲ្យកសាងសុខសន្តិភាពគ្រប់ពេលវេលា និងគ្រប់ទីកន្លែង។ នៅក្នុងសារលិខិតសម្ដេចប៉ាបបានអញ្ជើញមនុស្សទាំងអស់ជាពិសេសយើងជាគ្រីស្តបរិស័ទ ឲ្យប្រព្រឹត្តកិច្ចការដ៏សំខាន់បំផុតចំនួនពីរ ទីមួយ គឺឲ្យយើងមានសាមគ្គីភាពរវាងគ្នានិងគ្នា និងទីពីរ ឲ្យយើងមានចិត្តមេត្តាករុណា។ ប៉ុន្មានថ្ងៃកន្លងទៅនេះ

ជាបុណ្យព្រះយេស៊ូប្រសូត នៅគ្រប់ព្រះសហគមន៍របស់យើងមានបណ្ដាជនច្រើនកុះករចូលរួមជាមួយយើង។ មានព្រះសហគមន៍យើងមួយនោះ មានកុមារចូលរួមជាងពីពាន់បីរយហា-សិបនាក់។ តាមព្រះសហគមន៍នីមួយមានអ្នកចូលរួមក្នុងពិធីជប់លៀងរបស់យើង និងមានមហាជនរាប់ពាន់នាក់ ចូលរួមមើលការសម្តែងរឿងព្រះយេស៊ូប្រសូតរបស់យើងដែរ។ យើងក៏បានធ្វើកិច្ចការសប្បុរសធម៌រួមជាមួយគ្នាមានដូចជា ទៅសួរសុខទុក្ខចាស់ជរា អ្នកជាប់ឃុំឃាំង ក្មេងគ្មានទីពឹងដែលរស់នៅតាមមណ្ឌលនានា...។ ជាក់ស្តែងនៅតាខ្មៅ ជាកន្លែងថ្មីក្នុងយប់បុណ្យព្រះយេស៊ូប្រសូត មានមនុស្សរាប់ពាន់នាក់បានមកចូលរួមជាមួយយើងដោយសារគេចង់ដឹងចង់ឃើញអ្វីដែលគ្រីស្តបរិស័ទធ្វើក្នុងឱកាសបុណ្យព្រះយេស៊ូប្រសូត។ គេឃើញព្រះឱរសយេស៊ូផ្ទំក្នុងស្នូក គេឃើញគ្រីស្តបរិស័ទអធិដ្ឋានគេឃើញគ្រីស្តបរិស័ទចែកអំណរសប្បាយគ្នាហើយគេក៏មានអំណរសប្បាយរួមជាមួយយើងដែរ ដែលជាអំណរសប្បាយចេញមកពីសាមគ្គីភាពនិងមេត្តាករុណា។

ដូច្នេះ ឆ្នាំនេះ **សម្រាប់ការបង្កើតសុខសន្តិភាពជូនពិភពលោកនោះតម្រូវឲ្យយើងមានចិត្តសាមគ្គីយ៉ាងពិតប្រាកដ ឲ្យយើងចេះជួយគ្នាទៅវិញទៅមក** ឲ្យយើងបើកកន្លែងរបស់យើងឲ្យទូលំទូលាយដើម្បីទទួលគ្នា និងជួយគ្នា និងឲ្យយើងបង្ហាញធម៌មេត្តាករុណារបស់ព្រះជាម្ចាស់រួមជាមួយគ្នា និងតាមបុគ្គលយើងម្នាក់ៗដែរ។

សន្តៈប៉ូលមានប្រសាសន៍ថា "អ្នកមិនមែនជាទាសករទៀតទេ អ្នកជាបុត្រធីតារបស់ព្រះបិតាហើយអ្នកមានសិទ្ធិហៅព្រះជាម្ចាស់ថា "អប្បា ឱព្រះបិតាអើយ"។ បើអ្នកជាបុត្រធីតាមែន អ្នកក៏ត្រូវទទួលមរតកដែលព្រះបិតាបានប្រទានឲ្យអ្នកដែរ"។ ក្នុងឆ្នាំព្រះមហាករុណាទិគុណនេះ ខ្ញុំសូមអញ្ជើញបងប្អូនឲ្យឆ្លងទ្វារបីទាំងបើកដួងចិត្តរបស់ខ្លួនផង។ **ទ្វារទីមួយ** គឺទ្វារនៃជំនឿឲ្យជំនឿរបស់យើងរឹងមាំទទួលស្គាល់ ពិតមែនថាព្រះយេស៊ូជាព្រះសង្គ្រោះនិងជាជីវិតរបស់យើង ព្រះអង្គជាព្រះជាម្ចាស់ដែលបានចាប់កំណើតជាមនុស្ស ព្រះអង្គជាទ្វារដែលប្រោសប្រទានឲ្យយើងមានជំនឿ។ **ទ្វារទីពីរ** ជាទ្វារនៃមេត្តាករុណាឲ្យយើងសម្តែងព្រះហឫទ័យ

ប្រណីសន្តោសរបស់ព្រះបិតាពេញមួយឆ្នាំ តាមផ្លូវវិញ្ញាណផង និងតាមតាមផ្លូវកាយផងឲ្យព្រះសហគមន៍របស់យើងគឺយ៉ាងត្រចះត្រចង់អំពី ធម៌មេត្តាករុណារបស់ព្រះបិតា ដែលបងប្អូនទាំងអស់អាចមើលឃើញបាន និង**ទ្វារទីបី** ជាទ្វារនៃសេចក្តីសង្ឃឹមឲ្យជំនឿរបស់យើងណែនាំឲ្យយើងមានចិត្តមេត្តាករុណា ហើយចិត្តមេត្តាករុណានោះណែនាំឲ្យយើងមានសេចក្តីសង្ឃឹមជានិច្ច។ ក្នុងពិភពលោករបស់យើងខ្វះសេចក្តីសង្ឃឹមច្រើនណាស់ គ្មានសេចក្តីសង្ឃឹមដោយសារខ្វះចិត្តមេត្តាករុណា ខ្វះចិត្តមេត្តាករុណាដោយសារគ្មានជំនឿលើព្រះជាម្ចាស់។ ពេលយើងមានជំនឿលើព្រះជាម្ចាស់នោះណែនាំឲ្យយើងមានចិត្តមេត្តាករុណា ដែលណែនាំឲ្យពិភពលោករបស់យើងមានសេចក្តីសង្ឃឹម។

យប់បុណ្យព្រះយេស៊ូប្រសូត ជាយប់ដែលយើងបានចូលយ៉ាងជ្រៅ នៅក្នុងអាថ៌កំបាំងនៃជីវិតរបស់យើង គឺព្រះជាម្ចាស់ស្រឡាញ់យើង។ ចាប់ពីពេលនេះទៅយើងនឹងបន្តដំណើរហូតដល់ព្រះយេស៊ូសោយទិវង្គត ដើម្បីបង្ហាញសេចក្តីស្រឡាញ់របស់ព្រះបិតាចំពោះយើង តែបន្ទាប់មក ព្រះអង្គមានព្រះជន្មរស់ឡើងវិញ ដែលណែនាំឲ្យយើងមានសេចក្តីសង្ឃឹម។ ក្នុងឆ្នាំព្រះមហាករុណាទិគុណនេះ ព្រះជាម្ចាស់អញ្ជើញយើងឲ្យចេះស្រឡាញ់ ចេះលើកលែងទោសឲ្យគ្នាទៅវិញទៅមកដោយព្រះអង្គប្រទានសេចក្តីស្រឡាញ់ និងការលើកលែងទោសរបស់ព្រះអង្គឲ្យស្ថិតនៅក្នុងជីវិតរបស់យើងម្នាក់ៗ។ ពេលព្រះយេស៊ូប្រសូត ព្រះនាងម៉ារីចងចាំហេតុការណ៍ទាំងអស់ទុកក្នុងចិត្ត ព្រមទាំងរិះគិតពិចារណា ដោយអរព្រះគុណព្រះជាម្ចាស់ផង។ ដូច្នេះក្នុងឆ្នាំនេះ **តាមរបៀបរបស់ព្រះនាងខ្ញុំសូមអញ្ជើញបងប្អូនទាំងអស់ ឲ្យសម្លឹងមើលពិភពលោក ឲ្យសម្លឹងមើលសង្គមរបស់យើង សម្លឹងមើលជីវិតរបស់យើង រកឲ្យឃើញវត្តមានរបស់ព្រះជាម្ចាស់នៅក្នុងពិភពលោកយើង ក្នុងសង្គមរបស់យើង និងក្នុងជីវិតរបស់យើងជាប្រចាំថ្ងៃ ជឿថាព្រះជាម្ចាស់គង់នៅជាមួយយើងពិតមែន**។ ជារៀងរាល់ថ្ងៃមុនចូលដំណេកឲ្យយើងគិតថា តើថ្ងៃនេះខ្ញុំបានឃើញព្រះជាម្ចាស់ដែរឬទេ? ឃើញព្រះអង្គតាមរយៈអ្វី?។ ព្រះជាម្ចាស់មានគ្រប់ទាំងអំណាច ដូច្នេះនៅក្នុងឆ្នាំនេះឲ្យយើងចេះសម្លឹងមើលអំពីការអស្ចារ្យ ដែលព្រះ

អង្គបានបង្កើតនៅក្នុងជីវិតរបស់យើងឲ្យជីវិតរបស់យើង និងរបស់បងប្អូនយើងទៅជាជីវិតថ្មី ជារៀងរាល់ថ្ងៃ។

យើងសូមអរព្រះគុណព្រះជាម្ចាស់ យើងមានព្រះនាងម៉ារីដែលធ្វើដំណើរជាមួយយើង ដែលបង្ហាញផ្លូវយើងឲ្យស្គាល់ព្រះយេស៊ូថែមទៀត។ ក្នុងឆ្នាំព្រះមហាករុណាទិគុណនេះ យើងជឿថានឹងទៅជាឆ្នាំដ៏អស្ចារ្យ ដើម្បីកសាងជីវិតរបស់យើង ដើម្បីកសាងព្រះសហគមន៍របស់យើងដើម្បីកសាងសង្គមថ្មីរបស់យើងតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់។ សូមព្រះជាម្ចាស់ប្រទានពរ ដល់យើងទាំងអស់គ្នា។ សូមព្រះអង្គប្រទានសេចក្តីសុខសាន្តតាមរយៈព្រះនាងម៉ារីដែលជាព្រះមហាក្សត្រីនៃសេចក្តីសង្ឃឹម។

**"សូមព្រះអម្ចាស់ សម្តែងព្រះហឫទ័យសប្បុរសចំពោះ អ្នក និងប្រទានឲ្យអ្នកបានប្រកប ដោយសេចក្តីសុខសាន្ត!"**

# ស្វែងរកពន្លឺ និងចេញទៅ ប្រកាសដំណឹងល្អដូចពួកហោរាចារ្យ

The Three Kings, seeking and revealing the Light

អត្ថបទទី១ ៖ អស ៦០,១-៦;
អត្ថបទទី២ ៖ អភ ៣,២-៣ក.៥-៦
ដំណឹងល្អ ៖ មថ ២,១-១២

ថ្ងៃនេះយើងគោរពព្រះយេស៊ូសម្តែងឋានៈព្រះអង្គ ដែលមានហោរាចារ្យពីស្រុកឆ្ងាយមកថ្វាយបង្គំ។ ថ្ងៃនេះហាក់បីដូចជាបុណ្យព្រះយេស៊ូប្រសូតមួយទៀត ដោយសារកាលពីអាទិត្យមុន យើងបានប្រារព្ធបុណ្យព្រះយេស៊ូប្រសូតរួចទៅហើយ ដែលមានតែពួកគង្វាលជាអ្នកដែលនៅជិតៗមកថ្វាយបង្គំព្រះអង្គ តែពេលនេះមានអ្នកមកពីចម្ងាយថ្វាយបង្គំព្រះអង្គវិញ។

យើងយល់ថា បុណ្យថ្ងៃនេះ ដូចជាបុណ្យព្រះយេស៊ូប្រសូតសម្រាប់បព្វជិតបព្វជិតាទាំងឡាយ ក្នុងពិភពលោកទាំងមូល។ ថ្ងៃនេះ យើងមានអំណរសប្បាយម្តងទៀត ដោយបានស្តាប់អត្ថបទទីពីរដែលចែងថា "ដំណឹងល្អ" គឺ ព្រះយេស៊ូប្រសូត ហើយដែលសាសន៍ដទៃមានសិទ្ធិចូលរួមទទួលមរត៌កចូលរួមក្នុងព្រះកាយតែមួយ មានសិទ្ធទទួលព្រះពរតាមព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់។ ដូច្នេះនៅពេលនេះ សម្រាប់គ្រីស្តបរិស័ទទាំងអស់ ជាពិសេសគ្រីស្តបរិស័ទនៅប្រទេសកម្ពុជា យើងចូលរួមម្តងទៀតនៅក្នុងអំណរសប្បាយយ៉ាងខ្លាំង ក្នុងសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ចំពោះមនុស្សលោក រហូតដល់ព្រះអង្គបានចាត់ព្រះបុត្រាឲ្យយាងមកដើម្បីឲ្យយើងទទួលជីវិតថ្មី។ ឆ្នាំនេះដែរ ក៏ជាឆ្នាំព្រះមហាករុណាទិគុណ យើងរួមគ្នារិះគិត

---

អភិបូជានៅព្រះវិហារសន្ត មីកាអែល (កំពង់សោម)
ថ្ងៃទី ០៣ មករា ២០១៦

ថាតើយើងធ្វើអ្វី ដើម្បីយើងរួមដំណើរជាមួយព្រះយេស៊ូ? ដូច្នេះ យើងត្រូវមើលថាតើហោរាចារ្យគេបានធ្វើអ្វី?

១) ដូចហោរាចារ្យដែរ "យើងត្រូវតែស្វែងរកព្រះបន្ទូលរបស់ព្រះជាម្ចាស់"។ ថ្ងៃនេះ ព្រះជាម្ចាស់សម្តែងឲ្យយើងមើលឃើញថា ព្រះឱរសយេស៊ូ គឺជាព្រះបន្ទូលដែលកើតជាមនុស្ស ហើយយើងទាំងអស់គ្នា គឺជាអ្នកធ្វើដំណើរដែលស្វែងរកព្រះបន្ទូលនោះ។ នៅពេលនេះ ក្នុងចំណោមយើង គឺមានបងប្អូនខ្លះមិនមែនជាគ្រីស្តបរិស័ទ ប៉ុន្តែបងប្អូនជាអ្នកស្វែងរកព្រះបន្ទូលរបស់ព្រះជាម្ចាស់។ យើងខិតខំធ្វើដំណើរ ដើម្បីស្វែងរកឃើញផ្លូវ ដែលរកឃើញព្រះជា-ម្ចាស់នៅក្នុងជីវិតរបស់យើង។ យើងមើលឃើញថា ហោរាចារ្យដែលមកពីចម្ងាយ គេមើលផ្កាយមួយទាំងដឹងថាមានការអស្ចារ្យកំពុងកើតឡើង ដូច្នេះគេធ្វើដំណើរទៅមុខ រហូតជួបស្តេចហេរ៉ូដ ហើយគេទូលសួរព្រះអង្គអំពីកន្លែងព្រះគ្រីស្តប្រសូត។ ស្តេចហេរ៉ូដត្រាស់ហៅនាយកបូជាចារ្យមកសួរពីទីកន្លែងដែលព្រះគ្រីស្តប្រសូត ហើយប្រាប់ដំណឹងនោះទៅពួកហោរាចារ្យ ទាំងសូមឲ្យគេវិលមកថ្វាយដំណឹងពីកន្លែងដែលព្រះគ្រីស្តប្រសូត ដើម្បីព្រះអង្គទៅថ្វាយបង្គំព្រះគ្រីស្ត។ តាមពិតស្តេចមានបំណងចង់សម្លាប់ព្រះឱរស ដោយភ័យខ្លាចព្រះឱរសគ្រងរាជ្យលើបល្ល័ង្ករបស់ព្រះអង្គនៅថ្ងៃអនាគត។

ពួកហោរាចារ្យ គេធ្វើដំណើរឈ្វេងយល់សេចក្តីពិត គេស្វែងរកព្រះបន្ទូលដែលប្រសូតជាមនុស្ស ដើម្បីបំភ្លឺជីវិតរបស់ពួកគេ។ ចំពោះយើងវិញ តើយើងកំពុងស្វែងរកព្រះបន្ទូលយ៉ាងណាក្នុងជីវិតរបស់យើង? មូលហេតុអីយើងចូលព្រះវិហារជារៀងរាល់ថ្ងៃអាទិត្យ? មូលហេតុអីបានជាយើងសុខចិត្តលះបង់ពេលវេលាយូរខែ មកហាត់របាំ ហាត់សម្តែងរឿងព្រះយេស៊ូប្រសូតឲ្យប្រជាជនទាំងឡាយបានសប្បាយ? ពេលនេះ មានបងប្អូនប្រុសស្រីមកច្រើនណាស់ ដោយសារបងប្អូនចង់មើល ចង់សប្បាយ ចង់ចាប់ឆ្នោតដែលមានរង្វាន់...ប៉ុន្តែពិសេស គឺដោយសារបងប្អូនបានឃើញពន្លឺមួយនៅទីនេះ ដែលណែនាំឲ្យបងប្អូនទាំងអស់ជួបជុំគ្នាសប្បាយជាមួយគ្នា ជាក្រុមគ្រួសារតែមួយ។ កន្លងមក នៅយប់នៅថ្ងៃបុណ្យព្រះយេស៊ូប្រសូត ពេលនោះ

មានទាំងក្មេងៗ មានទាំងលោកពូ អ្នកមីង លោកតា លោកយាយ បានជួបជុំគ្នា ហើយបានរកឃើញបទពិសោធន៍នៃអំណរសប្បាយជាមួយគ្នាម្តងរួចទៅហើយ។

ដូច្នេះថ្ងៃនេះ សូមឲ្យយើងមានបំណងប្រាថ្នាពិតប្រាកដថា ពេញមួយឆ្នាំខាងមុខ យើងត្រូវតែស្វែងរកពន្លឺសម្រាប់ជីវិតរបស់យើង ស្វែងរកសេចក្តីសង្ឃឹមសម្រាប់ជីវិតរបស់យើង ស្វែរកសេចក្តីស្រឡាញ់សម្រាប់ជីវិតរបស់យើងដូចពួកហោរាចារ្យដែរ។ **"ពន្លឺ សេចក្តីសង្ឃឹម សេចក្តីស្រឡាញ់ដែលយើងស្វែងរកនោះ គឺជាព្រះយេស៊ូផ្ទាល់តែម្តង"**។

២) កាលហោរាចារ្យទាំងនោះឃើញផ្កាយ គេក៏ធ្វើដំណើរទៅតាមផ្កាយ ពេលផ្កាយឈប់ គេក៏ចូលទៅក្នុងផ្ទះហើយបានឃើញព្រះឱរស គង់នៅជាមួយនាងម៉ារីជាមាតា។ ពេលនោះគេមានអំណរសប្បាយយ៉ាងខ្លាំង ដោយសារគេមានឱកាស **"សម្លឹងមើល"** ព្រះឱរសដោយផ្ទាល់។ ដូច្នេះ នៅក្នុងឆ្នាំនេះតើយើងអង្គុយសម្លឹងមើលព្រះយេស៊ូយ៉ាងដូចម្តេច? តើយើងសម្លឹងមើលពិភពលោកយើងយ៉ាងដូចម្តេច? ជាទូទៅប្រសិនបើយើងសម្លឹងមើលទៅសង្គមនោះយើងឃើញមានផ្លូវជាច្រើនដែលនាំឲ្យយើងបែកចេញពីព្រះយេស៊ូ។ ហេតុដូច្នោះហើយបានជាក្រុមបងស្រីសម្មាត់ដែលមានមុខងារក្នុងការអធិដ្ឋាន ពួកគាត់ស្វែងរកកន្លែងដែលស្ងាត់ដើម្បីអធិដ្ឋាន។ នៅឆ្នាំ១៩៩៤ ពេលមកដល់ស្រុកខ្មែរក្រុមបងស្រីសម្រេចថាមិននៅក្នុងក្រុងភ្នំពេញទេ ដោយសារមានសម្លេងអ៊ូអរពេក បងស្រីទៅទិញដីមួយកន្លែងនៅទីដាច់ស្រយាលជិតដល់ទីរួមខេត្តកំពង់ស្ពឺ សាងសង់អារាម ដើម្បីមានបរិយាកាសល្អក្នុងការអធិដ្ឋាន។ ប៉ុន្តែទីនោះឥឡូវមិនស្ងាត់ទៀតទេ...។

ដូច្នេះ សម្រាប់យើងក្នុងឆ្នាំនេះ យើងត្រូវរកឲ្យឃើញភាពស្ងៀមស្ងាត់នៅក្នុងដួងចិត្តរបស់យើង ដើម្បីយើងឃើញព្រះជាម្ចាស់ និងដើម្បីអង្គុយ **"សម្លឹងមើល"** ព្រះអង្គ។ ប្រសិនបើយើងអត់ដែលស្ងៀមស្ងាត់ ប្រសិនបើយើងចេះតែគិតពីសម្លេងនៅជុំវិញខ្លួន ពីសង្គមបច្ចុប្បន្នពីអ្វីៗដែលនាំឲ្យអារម្មណ៍យើងមិនមូល តើធ្វើដូចម្តេចយើងមានឱកាសដើម្បីថ្វាយបង្គំព្រះយេស៊ូបាន? ដូច្នេះឆ្នាំព្រះមហាករុណាទិគុណនេះ គឺជាឱកាសមួយយើងអានព្រះគម្ពីរ យើងស្តាប់

ព្រះបន្ទូលដើម្បីយើង**"រកឃើញ"** ព្រះយេស៊ូ **"សម្លឹងមើល"** ព្រះអង្គដូចពួកហោរាចារ្យដែរ។

៣) ក្រោយពីសម្លឹងមើលព្រះឱរសទាំងអំណរសប្បាយមក ពួកហោរាចារ្យបាន **"ថ្វាយទ្រព្យសម្បត្តិ"** ទាំងប៉ុន្មានដែលខ្លួនបានរៀបចំទុកទៅព្រះឱរស។ សម្រាប់យើងឆ្នាំនេះ តើយើងយកអ្វីខ្លះទៅថ្វាយព្រះយេស៊ូ? យើងអត់មានមាស អត់មានប្រេងក្រអូបពីបុរាណដូចពួកហោរាចារ្យ ប៉ុន្តែយើងត្រូវរៀបចំជីវិតរបស់យើងថ្វាយទៅព្រះអង្គ។ ព្រះយេស៊ូដែលបានទទួលទ្រព្យសម្បត្តិពីហោរាចារ្យ ក្រោយមកអស់មួយជីវិតព្រះអង្គបានប្រទានឲ្យគេវិញ គឺព្រះអង្គប្រទានហើយប្រទានទៀត មិនដែលឈប់ឈរទេនាំឲ្យមហាជនដែលដើរតាមព្រះអង្គមានសេចក្តីសង្ឃឹម មានអំណរសប្បាយគ្រប់ៗគ្នា។ ព្រះអង្គបានព្យាបាលអ្នកឈឺឲ្យជា ព្រះអង្គប្រោសអ្នកពិការឲ្យដើរបាន ប្រោសអ្នកខ្វាក់ឲ្យមើលឃើញវិញ... នេះជាអ្វីដែលព្រះយេស៊ូបានប្រទានរហូតដល់ព្រះអង្គបូជាជីវិតនៅលើឈើឆ្កាង។

តាមរបៀបរបស់សម្តេចប៉ាប ក្នុងឆ្នាំព្រះមហាករុណាទិគុណនេះ គឺលោកសូមឲ្យយើងជាយុវជនយុវនារី និងគ្រីស្តបរិស័ទទាំងអស់ត្រូវតែសម្តែងកិច្ចការមេត្តាករុណា **គឺកិច្ចការមេត្តាករុណាខាងផ្លូវកាយ**ដែលមានន័យថាយើងត្រូវយកចិត្តទុកដាក់ នឹងអ្នកជំងឺ អ្នកដែលគ្មានអាហារបរិភោគ យកចិត្តទុកដាក់នឹងជនបរទេស អ្នកជាប់ឃុំឃាំង ដោយសូមឲ្យយើងនៅជាប់ជាមួយគេដើម្បីលើកទឹកចិត្តគេ និងកិច្ចការមេត្តាករុណាខាងផ្លូវវិញ្ញាណ ដោយសូមឲ្យយើងលើកលែងទោសឲ្យយើងស្វាគមន៍អ្នកឯទៀតៗទុកជាបងប្អូនរបស់យើងជានិច្ច និងផ្តល់សេចក្តីសង្ឃឹមដែលចេញពីកម្លាំងកាយ និងកម្លាំងចិត្តរបស់យើង។

កាលថ្ងៃទី ១០ ខែធ្នូ ឆ្នាំ២០១៥ ក្នុងឱកាសជួបជាមួយបងប្អូនខ្លះៗនៅភ្នំពេញថ្មី ខ្ញុំបានរៀបចំសារលិខិតមួយច្បាប់ជូនដល់គ្រីស្តបរិស័ទម្នាក់ៗតាមរយៈលោកឪពុក។ ក្នុងសារលិខិតនោះខ្ញុំបានរៀបចំពាក្យសន្យារបស់យើងចំពោះព្រះជាម្ចាស់ ដែលថានៅក្នុងឆ្នាំនេះជារៀងរាល់ខែយើងនឹងយកចិត្តទុកដាក់សម្តែងធម៌មេត្តាករុណាជាក់ស្តែង ខាងផ្លូវកាយ និងខាងផ្លូវវិញ្ញាណដល់អស់បងប្អូនដែលយើងបានជួប។ លោកឪពុកនឹងពន្យល់បងប្អូនពីសារលិខិតនោះ ដើម្បី

ឲ្យបងប្អូនមានឱកាសបានចែករំលែកអ្វីៗដែលបងប្អូនមាន ដូចហោរាចារ្យបានថ្វាយទ្រព្យសម្បត្តិទៅព្រះយេស៊ូ និងដូចព្រះយេស៊ូបានប្រទានព្រះជន្មព្រះអង្គសម្រាប់យើងដែរ។

នេះជាផ្លូវរបស់យើងនៅក្នុងឆ្នាំនេះ គឺយើងស្វែងរកព្រះពន្លឺ បន្ទាប់មកយើងថ្វាយបង្គំព្រះពន្លឺនៅក្នុងអំណរសប្បាយ និងសម្លឹងមើលព្រះពន្លឺដោយស្ងៀមស្ងាត់ក្នុងដួងចិត្ត ហើយយើងមិនទុកអំណរសប្បាយនេះសម្រាប់តែខ្លួនឯងទេ តែយើងចែកជាមួយបងប្អូនឯទៀតៗវិញ ដើម្បីឲ្យព្រះបន្ទូលរបស់ព្រះជាម្ចាស់ កើតជារូបរាងនៅលើទឹកដីរបស់យើងនៅក្នុងឆ្នាំ ២០១៦ នេះ ដូចហោរាចារ្យ ដែលពោរពេញដោយអំណរសប្បាយ គេមិនត្រឡប់ទៅជួបស្តេចហេរ៉ូដដែលមានបំណងសម្លាប់ព្រះឱរសទេ តែគេចេញទៅតាមផ្លូវផ្សេង ដើម្បីប្រកាសដំណឹងល្អ ឲ្យមនុស្សទាំងអស់បានទទួលអំណរសប្បាយដែរ។ នេះជាគម្រោងការរបស់ព្រះជាម្ចាស់ដូចមានចែងក្នុងអត្ថបទគម្ពីរនៅថ្ងៃនេះ ដែលសូមឲ្យយើងងើបមុខឡើង សម្លឹងមើលជុំវិញខ្លួន ហើយដើរតម្រង់ទៅរកព្រះយេស៊ូ...។

សូមអរព្រះគុណព្រះជាម្ចាស់ និងសូមព្រះអង្គប្រោសឲ្យយើងខ្ញុំ ទៅជាហោរាចារ្យដ៏ពិសេស ដើម្បីឲ្យមនុស្សលោកទទួលស្គាល់ព្រះពន្លឺទទួលស្គាល់សេចក្តីសុខសាន្តគឺជាព្រះយេស៊ូផ្ទាល់ដែលជាសេចក្តីសុខសាន្ត។

# ព្រះវិញ្ញាណដ៏វិសុទ្ធ
# ជ្រើសរើសយើងឲ្យទៅប្រកាសដំណឹងល្អ

The Holy Spirit has chosen us to proclaim the Good News

អត្ថបទទី១ ៖ ១ យហ ៤, ១៩ ដល់ ៥,៤
ដំណឹងល្អ ៖ លក ៤, ១៤-២២ក

អំបាញ់មិញយើងបានស្តាប់ព្រះគម្ពីរ ដែលចែងអំពីព្រះយេស៊ូសម្តែងធម្មទេសនាលើកដំបូងនៅក្នុងធម្មសាលាថា **"ព្រះវិញ្ញាណរបស់ព្រះអម្ចាស់សណ្ឋិតលើខ្ញុំ ព្រះអង្គចាក់ប្រេងអភិសេកខ្ញុំ..."** នោះណែនាំឱ្យយើងនឹកឃើញថា ព្រះជាម្ចាស់ក៏បានជ្រើសរើសយើង ព្រះអង្គបានចាក់ប្រេងអភិសេកយើង និងចាត់យើងឲ្យទៅរកបងប្អូនឯទៀតៗ និងព្រះអង្គក៏តែងតាំងយើងជាឧបករណ៍ផ្ទាល់របស់ព្រះអង្គដែរ។ ជីវិតរបស់យើងជាបព្វជិត បព្វជិតា ជាអ្នកបួសយើងដឹងថា គឺព្រះវិញ្ញាណដ៏វិសុទ្ធនេះហើយដែលបានជ្រើសរើសយើង តែងតាំងយើង និងដែលបានណែនាំយើងក្នុងការប្រកាសដំណឹងល្អ។

១) ពេលនេះចូរយើងនឹកឃើញជាថ្មីម្តងទៀតថា ពិតមែន យើងនៅក្នុងព្រះហស្តរបស់ព្រះជាម្ចាស់យើងជាឧបករណ៍នាំការសង្គ្រោះរបស់ព្រះអង្គទៅមនុស្សលោក ដូចសម្តេចប៉ាបរំឭកយើងនៅក្នុងសារលិខិត ស្តីពី **"អំណរសប្បាយនៃដំណឹងល្អ"** ថាព្រះជាម្ចាស់បានជ្រើសរើសយើងទាំងអស់គ្នាបានតែងតាំងយើងជាឧបករណ៍មួយ និងបានចាត់យើងឲ្យចេញទៅប្រកាសដំណឹងល្អ។ ដូច្នេះយើងទទួលការត្រាស់ហៅយ៉ាងពិសេស គឺឲ្យយើងណែនាំយុវជនយុវនារីកាន់តែច្រើនឡើងៗ ស្តាប់ឮ និងឆ្លើយតបនឹងការត្រាស់ហៅរបស់ព្រះជាម្ចាស់ចំពោះគេ។

---

ពិធីអភិបូជាជាមួយបព្វជិត បព្វជិតា ទាំងអស់
នៅភ្នំពេញថ្មី ថ្ងៃទី០៧ ខែមករា ឆ្នាំ២០១៦

ថ្ងៃនេះម៉ោង ៦កន្លះល្ងាច នៅព្រះសហគមន៍បឹងទំពុន នឹងមានអធិដ្ឋានពេញមួយយប់សម្រាប់ការត្រាស់ហៅលើកទី ៤៥។ ដូច្នេះខ្ញុំសូមអញ្ជើញបងប្អូនទាំងអស់គ្នាចូលរួម។

ការជំរុញការត្រាស់ហៅ គឺជាបេសកកម្មទីមួយរបស់យើងជាបព្វជិតបព្វជិតាដែលបានទទួលការត្រាស់ហៅដែលបានទទួលប្រេងអភិសេក ដែលមានព្រះវិញ្ញាណព្រះជាម្ចាស់គង់នៅជាមួយ។ ខ្ញុំជឿជាក់ថាសក្ខីភាពដែលបងប្អូនផ្តល់ដល់គេអំណរសប្បាយដែលយើងមានហើយដែលយើងបានចែកទៅគេ នឹងទៅជាការជំរុញមួយយ៉ាងពិសេសឲ្យយុវជនយុវនារីយើងភ្ញាក់ស្មារតីស្តាប់ឮសូរសៀងរបស់ព្រះជាម្ចាស់តាមរយៈយើងមិនគ្រាន់ទេ តែគេស្តាប់ឮតាមព្រះគម្ពីរដំណឹងល្អប៉ុណ្ណោះទេ។ នេះគឺជាអំណរសប្បាយដ៏ពេញលក្ខណៈដែលយើងបានទទួលពីព្រះជាម្ចាស់ ។

២) អត្ថបទដែលយើងស្តាប់នៅថ្ងៃនេះរំឭកយើងថាខ្ញុំក៏មានបេសកកម្ម **"នាំដំណឹងល្អទៅប្រាប់ជនក្រីក្រ"** និងជាពិសេសក្នុងឆ្នាំព្រះមហាករុណាទិគុណនេះខ្ញុំក៏មានបេសកកម្ម **" ប្រកាសអំពីឆ្នាំដែលព្រះអម្ចាស់សម្តែងព្រះហឫទ័យមេត្តាករុណា "** ដូចព្រះយេស៊ូដែរ។ តាមពិតឆ្នាំ **"ព្រះមហាករុណាទិគុណ"** នេះមានចែងក្នុងព្រះគម្ពីរសម្ព័ន្ធមេត្រីចាស់គឺ៥០ឆ្នាំម្តងប្រជារាស្ត្ររបស់ព្រះជាម្ចាស់ដែល ជាម្ចាស់បំណុលត្រូវលុបបំណុលម្តងដើម្បីបង្ហាញពីរបៀបដែល ព្រះជាម្ចាស់ស្រឡាញ់ប្រជារាស្ត្រព្រះអង្គ។ សម័យនេះធនាគារមិនអាចលុបបំណុលបានទេហើយយើងក៏មិនអាចមិនសងបំណុលទៅគេវិញបានដែរ ប៉ុន្តែក្នុងការរស់នៅយើងអាចចូលរួមក្នុងឆ្នាំ ព្រះមហាករុណាទិគុណបានតាមរបៀបផ្សេងៗជាច្រើនដូចជាយើងត្រូវចេះលើកលែងទោសឲ្យគ្នាទៅវិញទៅមកដើម្បីយើងអាចចាប់ផ្តើមធ្វើដំណើរសាជាថ្មីរួមជាមួយគ្នាក្នុងសេចក្តីស្រឡាញ់។

ដូច្នេះឆ្នាំ **"ព្រះមហាករុណាទិគុណ"** នេះយើងជាអ្នកបម្រើដែលព្រះជាម្ចាស់បានត្រាស់ហៅយ៉ាងពិសេស និងដោយបានស្តាប់ព្រះបន្ទូលរបស់ព្រះយេស៊ូថា **"ខ្ញុំនាំដំណឹងល្អទៅប្រាប់**

**ជនក្រីក្រ..."** នោះជាឱកាសមួយឲ្យយើងម្នាក់ៗសួរខ្លួនឯងថា តើនរណាជាអ្នកក្រីក្រដែលខ្ញុំត្រូវជូនដំណឹងល្អដល់គេ? និងជាឱកាសដើម្បីដាស់តឿនយើងសាជាថ្មី អំពីបេសកកម្មដែលយើងបានទទួលតាមក្រុមនីមួយៗ និងដើម្បីយើងអាចបំពេញបេសកកម្មនោះបាន តាមវិស័យផ្សេងៗគ្នា មានខ្លះតាមវិស័យអប់រំ មានខ្លះតាមវិស័យសុខភាព មានខ្លះតាមវិស័យអភិវឌ្ឍន៍ជនបទ មានខ្លះតាមវិស័យបម្រើទូទៅ តាមព្រះអំណោយទានពិសេសដែលយើងបានទទួល...។ ខ្ញុំជឿថាឆ្នាំនេះជាឱកាសមួយឲ្យយើងបើកភ្នែកជាថ្មី រកឃើញអ្វីដែលយើងអាចធ្វើថែមទៀតដើម្បីឲ្យព្រះសហគមន៍របស់យើងនិង ដើម្បីឲ្យដំណឹងល្អបានទៅដល់ជនក្រីក្រក្នុងសម័យនេះជា ពិសេសនៅក្នុងសតវត្សទី២១ នៅក្នុងប្រទេសកម្ពុជារបស់យើង។

ក្នុងឆ្នាំនេះដែរ យើងក៏ត្រូវតែចាប់អារម្មណ៍អំពីក្មេងៗដែលមិនបានចូលរៀននៅសាលា។ សព្វថ្ងៃជាពិសេសនៅភ្នំពេញ មានក្មេងៗជាច្រើនមិនបានចូលរៀនទេដោយសារឪពុកម្តាយរបស់គេមកពីជនបទធ្វើជា កម្មករសំណង់នៅទីក្រុង ហើយក្មេងៗទាំងនោះខ្លួនឯងក៏មិនចង់ចូលសាលាដែរ។ នៅជិតផ្ទះខ្ញុំយើងបានទៅប្រមូលគេដើម្បីរៀនក្បួរមួយម៉ោងៗប៉ុន្តែគេមិនព្រមចូលរៀនទេហើយឪពុកម្តាយរបស់គេក៏មិនយល់ព្រមដែរ។ ខ្ញុំជឿថាជាពិសេស សាលាដុនបូស្កូដែលមានសកម្មភាពខាងការអប់រំច្រើនមកហើយនោះ នឹងចូលជ្រៅថែមទៀតជាមួយក្មេងៗដែលមិនបានចូលរៀននៅសាលានៅឡើយ។

យើងមានបេសកកម្មច្រើនទៀតដែលត្រូវធ្វើ ដូចជាទៅសួរសុខទុក្ខអ្នកជាប់ក្នុងមន្ទីរឃុំឃាំងជាដើម។ នៅភ្នំពេញយើងមានកម្មវិធីនេះខ្លះៗ ប៉ុន្តែនៅតាមខេត្តយើងមិនទាន់មានសកម្មភាពនេះប៉ុន្មានទេ។ នៅកំពង់សោម ខ្ញុំបានចូលរួមសួរសុខទុក្ខពិរុទ្ធជនក្នុងមន្ទីរឃុំឃាំងជាមួយបងស្រី ជាមួយគ្រូគង្វាល និងអ៊ីម៉ាំខាង អ៊ីស្លាមដែរ។ នៅតាកែវ នៅកំពត យើងចុះសួរសុខទុក្ខគេមួយឆ្នាំម្តងជាមួយនឹងក្រុមអន្តរសាសនា។ ខ្ញុំជឿថាយើងអាចធ្វើសកម្មភាពនេះបានច្រើនតទៅទៀត។ កាលពីអាទិត្យមុនពេលខ្ញុំទៅកំពតខ្ញុំភ្ញាក់ដោយសារមន្ទីរ ឃុំឃាំងដែលប្តូរទៅនៅជើងភ្នំបូកគោនោះ មានទីធ្លាទូលាយល្អម។ តែក្រុមជំនំកូរ៉េគេសកម្មណាស់គេបាន

សូមកន្លែងមួយក្នុងបរិវេណនោះ សាងសង់អាគារមួយរួចតាំងពីមួយខែមុន ដើម្បីរាល់ថ្ងៃច័ន្ទគេមានកម្មវិធីអប់រំ ជំនឿ សូត្រធម៌ និងថ្ងៃអង្គារ ពុធ ព្រហស្បតិ៍គេមានកម្មវិធីអក្ខរកម្ម មានបង្រៀនកុំព្យូទ័រ មានបង្រៀនភាសាអង់គ្លេស គឺមានមួយកំប្លេរសម្រាប់ទណ្ឌិត។

ខ្ញុំជឿថាក្នុងឆ្នាំព្រះមហាករុណាទិគុណនេះជាពេលវេលាមួយឲ្យយើងមើលគ្រប់ជ្រុងជ្រោយជាថ្មីដើម្បីយើងទៅមុខទៀត ដូចជាក្នុងវិស័យអន្តរសាសនាជាដើម ដែលយើងត្រូវតែខិតខំថែមទៀត។ ឆ្នាំនេះ ខ្ញុំបានចូលក្នុងកម្មវិធីអន្តរសាសនាច្រើនដងនិងខ្ញុំបានស្តាប់ឮនៅគ្រប់ទីកន្លែងទាំងនៅកំពត កំពង់សោម តាកែវ កោះពេជ្រ គឺទាំងព្រះសង្ឃពុទ្ធសាសនា ទាំងអ៊ីម៉ាំឥស្លាមសាសនា ទាំងគង្វាលនៃក្រុមជំនុំប្រូតេស្តង់ ទាំងអស់គ្នាគេសប្បាយចិត្តដោយសារគេមានឱកាសស្វែងយល់ពីគ្នា។ ព្រះសង្ឃមួយអង្គមានសង្ឃដិកាថា **"យើងត្រូវការអានគម្ពីរប៊ីប្លី គម្ពីរកូរ៉ាន និងគម្ពីរព្រះត្រៃបិដកដើម្បីយើងយល់ចិត្តគ្នាទៅវិញទៅមក"**។ អ៊ីម៉ាំខេត្តកំពតបានសំណូមពរដែរថា **"សិក្ខាសាលាឆ្នាំក្រោយសូមឲ្យមានកម្មវិធីពេញមួយថ្ងៃសម្រាប់វិស័យសាសនា ហើយសូមឲ្យមានអ្នកចូលរួមទាំងឥស្លាមបរិស័ទ ពុទ្ធបរិស័ទ គ្រីស្តបរិស័ទ កើនឡើងចំនួន ៣០០នាក់ ដើម្បីកុំឲ្យយើងនៅឆ្ងាយពីគ្នាកុំឲ្យយើងច្រឡំពីគ្នា"**។

ដូច្នេះខ្ញុំជឿថា ហេតុការណ៍ផ្សេងៗដែលកើតនៅលើពិភពលោកសព្វថ្ងៃជាពិសេសសកម្មភាពភេរវកម្ម បានបណ្តាលឲ្យសាសនានីមួយៗភ្ញាក់ស្មារតីដើម្បីយល់ចិត្តគ្នា ដើម្បីធ្វើដំណើរជាមួយគ្នាដើម្បីកសាងសន្តិភាព និងសុខដុមរមនាយ៉ាងពិតប្រាកដជាមួយគ្នាកាន់តែខ្លាំងឡើងៗ។ សូមបងប្អូននឹកចាំថាប្រទេសកម្ពុជាយើង បានចូលក្នុងទីផ្សារអាស៊ានហើយដូច្នេះយើងទាំងអស់គ្នាក៏មានតួនាទីនៅក្នុងសភាពការណ៍ថ្មីនេះដែរ គឺយើងត្រូវខិតខំជួយអប់រំយុវជនយុវនារី ឲ្យគេចេះចូលនៅក្នុងវប្បធម៌ក្នុងសាសនាក្នុងរបៀបរស់នៅនៃ ប្រទេសទាំង១០ ដែលជាសមាជិកអាស៊ាន។ ប្រសិនបើយើងជាសាសនាមិនខ្វល់ខ្វាយក្នុងរឿងនេះទេតើនឹងមាននរណាមកខ្វល់ខ្វាយដ្បិតរាជរដ្ឋាភិបាលខ្វល់ខ្វាយតែនឹងបញ្ហាសេដ្ឋកិច្ច និងបញ្ហានយោបាយប៉ុណ្ណោះ។ នេះគឺជាបេសកកម្មរបស់យើងក្នុងការប្រកាសដំណឹងល្អដល់ជនក្រីក្រ

ក្នុងសភាពការណ៍ថ្មីនេះ។

ជាមួយគ្នានេះដែរក្នុងភូមិភាគភ្នំពេញយើង ខ្ញុំបានលើកទឹកចិត្តដល់និស្សិតសាលាសន្តៈយ៉ូស្វីន ដោយអញ្ជើញសិស្សទាំង២ជំនាន់មកជួបជុំគ្នាប្រហែល ១ខែកន្លះម្តង និងខ្ញុំបានឲ្យគម្រោងការបេសកកម្មពិសេសដល់គេគឺខ្ញុំឲ្យគេចែកគ្នាជាក្រុមដែលមានគ្នា២ ឬ ៣ នាក់ បង្កើតគម្រោងការបេសកកម្មមួយដើម្បីអនុវត្តន៍នៅក្នុងឆ្នាំនេះ។ គម្រោងការបេសកកម្មទាំងនោះគឺទាក់ទងនឹងអ្នកក្រីក្រ និងការអប់រំឲ្យគេធ្វើស្របតាមសមត្ថភាពរបស់ពួកគេហើយគេអាចបន្ថែមសមាជិកពីខាងក្រៅថែមទៀតក៏បាន ដើម្បីឲ្យគេទៅជាសាសនទូតជាក់ស្តែងក្នុងការ ប្រកាសដំណឹងល្អ។ គម្រោងការបេសកកម្មនេះ មានប្រយោជន៍សម្រាប់គេ និងព្រះសហគមន៍។

៣) យើងបានស្តាប់ព្រះយេស៊ូមានព្រះបន្ទូលថា **"ហេតុការណ៍ដែលមានចែងក្នុងគម្ពីរដូចអ្នករាល់គ្នាទើបនឹងស្តាប់បានកើតជារូបរាងនៅថ្ងៃនេះហើយ"**។ នេះជាឱកាសមួយដើម្បីយើងអរព្រះគុណព្រះជាម្ចាស់អស់ពីដួងចិត្ត ដោយសារក្នុងការរស់នៅរបស់យើង ក្នុងគម្រោងការផ្សេងៗរបស់យើង ក្នុងបេសកកម្មរបស់យើង យើងមានបទពិសោធន៍ ច្រើនដងមានការរីកលូតលាស់ប្រសើរឡើង ជារៀងរាល់ថ្ងៃដែលយើងអាចនិយាយបានថា **"អ្វីៗបានកើតជារូបរាងនៅថ្ងៃនេះ"**។ សូមអរព្រះគុណព្រះជាម្ចាស់។

យប់មិញយើងមានកម្មវិធីនៅភូមិសុខសាន្ត យើងធ្វើពិធីជប់លៀងកសាងសន្តិភាព។ ខ្ញុំបានអរព្រះគុណព្រះជាម្ចាស់ ដោយសារខ្ញុំបានឃើញព្រះរាជ្យរបស់ព្រះជាម្ចាស់ជាក់ស្តែងក្នុងរយៈពេលបីម៉ោង ជាមួយមនុស្ស ៣៥០នាក់ ដែលមានកូនពិការធ្ងន់ជាមួយនឹងអាណាព្យាបាលរបស់គេ មានអ្នកពិការល្មម មានគ្រួសារដែលផ្ទុកមេរោគអេដស៍ មានកូនមត្តេយ្យមានប្រជាជនក្នុងភូមិ មានភ្ញៀវជាតិ និងអន្តរជាតិ។ យើងទាំងអស់គ្នាបានបរិភោគអាហារជាមួយគ្នាដោយគ្មានការរើសអើង គេអង្គុយជាមួយគ្នាដោយសេចក្តីសុខសាន្ត មានសម្តែងរឿងមានសិល្បៈ មានកម្មវិធីជាច្រើនរួមគ្នានៅក្នុងយប់ដ៏សុខសាន្តនោះ ដែលធ្វើឲ្យយើងយល់ថា

ពិតមែនព្រះរាជ្យរបស់ព្រះជាម្ចាស់កំពុងយាងមកជាក់ស្តែង។ ខ្ញុំជឿថាបងប្អូនទាំងអស់គ្នាក៏មាន បទពិសោធន៍ដូចនេះជាច្រើនដងដែរក្នុងការរស់នៅផ្ទាល់ខ្លួន។

យើងរួមគ្នាអរព្រះគុណព្រះជាម្ចាស់ សូមព្រះជាម្ចាស់គង់នៅជាមួយយើងដើម្បីជាកម្លាំងមួយឲ្យយើង អាចទៅមុខទៀតបាន។

សូមព្រះវិញ្ញាណដ៏វិសុទ្ធជំរុញយើង ឲ្យទៅប្រកាសដំណឹងល្អដល់ជនក្រីក្រ។

**"ព្រះវិញ្ញាណរបស់ព្រះអម្ចាស់សណ្ឋិតលើខ្ញុំ ព្រះអង្គចាក់ប្រេង អភិសេកខ្ញុំ..."**

# យើងទទួលជីវិតថ្មីក្នុងព្រះនាមព្រះជាម្ចាស់

We receive New Life in God's Name

---

អត្ថបទទី១៖ អស ៤០, ១-៥, ៩-១១
អត្ថបទទី១៖ ទត ២, ១១-១៤; និង ៣, ៤-៧
ដំណឹងល្អ៖ លក ៣, ១៥-១៦. ២១-២២

ថ្ងៃនេះជាអាទិត្យចុងក្រោយនៃ **"រដូវបុណ្យព្រះយេស៊ូប្រសូត"**។ តាមរយៈពិធីជ្រមុជទឹករបស់ព្រះយេស៊ូ ជាឱកាសមួយឲ្យយើងទាំងអស់គ្នាទទួលពន្លឺសម្រាប់ **" ឆ្នាំព្រះមហាករុណាទិគុណ"** ខាងមុខនេះ។ តាមអត្ថបទគម្ពីរលោកយ៉ូហានបាទីស្ត បានធ្វើពិធីជ្រមុជទឹកជូនប្រជាជនឲ្យគេប្រែចិត្តគំនិត និងឲ្យគេទទួលជីវិតថ្មី។ ហេតុដូច្នេះហើយបណ្ដាជនជាច្រើនដែលយល់ឃើញថាជីវិតរបស់ខ្លួនមានជាប់បាប និងអំពើអាក្រក់ជាច្រើននោះ បានមករកលោក មកទទួលពិធីជ្រមុជទឹកពីលោក ដើម្បីទទួលជីវិតថ្មី និងគេអាចបន្តដំណើររួមជាមួយព្រះជាម្ចាស់តទៅទៀត។

តើមូលហេតុអ្វី ព្រះយេស៊ូទទួលពិធីជ្រមុជទឹកពីលោកយ៉ូហាន?។ ពិតមែនព្រះយេស៊ូបានទទួលពិធីជ្រមុជទឹកពីលោកយ៉ូហាន នៅក្នុងទន្លេយ័រដាន់។ ទឹកទន្លេយ័រដាន់ រាល់ឆ្នាំហូរចាក់ទៅសមុទ្រមរណៈ ជាសមុទ្រពិសេសមួយដែលទាបជាងគេក្នុងពិភពលោក មានកម្ពស់ក្រោមនីវ៉ូទឹកសមុទ្រ ៤០០ ម៉ែត្រ។ ពេលចាប់ផ្ដើមបេសកកម្ម ព្រះយេស៊ូបានទទួលពិធីជ្រមុជទឹកនៅក្នុងទន្លេយ័រដាន់នេះជានិមិត្តរូបថាព្រះអង្គចូលរួមក្នុងទុក្ខលំបាករបស់មនុស្សលោកដែលមានបាប និងព្រះអង្គសង្គ្រោះអ្នកបាបទាំងអស់ នៅក្នុងបេសកកម្មរបស់ព្រះអង្គ។

អត្ថបទទីមួយបានបង្ហាញប្រាប់យើងថា ព្រះយេស៊ូសង្គ្រោះយើងតាមព្រះហឫទ័យមេត្តាករុណារបស់ព្រះបិតា មិនមែនមកពីយើងជាមនុស្សសុចរិតនោះទេ។ នេះមានអត្ថន័យណាស់

---

អភិបូជា នៅព្រះវិហារសន្តយ៉ូសែប(ផ្សារតូច)
ថ្ងៃទី ១០ មករា ២០១៦

សម្រាប់យើងនៅក្នុងឆ្នាំព្រះមហាករុណាទិគុណនេះ។ ក្នុងពិធីជ្រមុជទឹក ព្រះយេស៊ូបានទទួលបាបរបស់យើង ណែនាំឲ្យយើងទទួលជីវិតថ្មី។ **យើងទទួលជីវិតថ្មីដោយសារព្រះជាម្ចាស់ស្រឡាញ់យើង លើកលែងទោសឲ្យយើង** មិនមែនមកពីយើងមានបុណ្យកុសលនោះទេ។ សម្រាប់យើងជាគ្រីស្តបរិស័ទ យើងចូលនៅក្នុងព្រះហឫទ័យមេត្តាករុណាដ៏កំពូលរបស់ព្រះជាម្ចាស់។

ពេញមួយឆ្នាំខាងមុខនេះ យើងទាំងអស់គ្នានឹងមានការពិសោធន៍ពីការរស់នៅរបស់យើងជាមនុស្សបាប ប៉ុន្តែព្រះជាម្ចាស់លើកលែងទោសរំដោះបាបយើង ហើយយើងក៏នឹងមានពិសោធន៍ពីជីវិតថ្មីដែលព្រះជាម្ចាស់ស្រឡាញ់យើងដែរ។ យើងទាំងអស់គ្នាដែលបានទទួលពិធីជ្រមុជទឹក ឈ្មោះរបស់យើងចូលនៅក្នុងព្រះនាមរបស់ព្រះជាម្ចាស់រួចហើយ ដូចដែលលោកបូជាចារ្យមានប្រសាសន៍នៅថ្ងៃដែលយើងទទួលអគ្គសញ្ញាជ្រមុជទឹកថា **"ខ្ញុំជ្រមុជទឹក (ដារ៉ា សារឿន សុផល វណ្ណា") ដោយនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ"**។ ដូច្នេះឈ្មោះយើងបានភ្ជាប់នៅក្នុងព្រះនាមព្រះជាម្ចាស់ហើយ យើងទៅជាធ្លុងមួយជាមួយព្រះអង្គ។

ថ្ងៃនេះពេលយើងនឹកដល់ **"ពិធីជ្រមុជទឹករបស់ព្រះយេស៊ូ"** សូមឲ្យយើងនឹកដល់ពិធីជ្រមុជទឹករបស់ខ្លួនយើងផង ដោយដឹងថាឈ្មោះរបស់យើងចូលនៅក្នុងព្រះនាមរបស់ព្រះជាម្ចាស់ ហើយព្រះនាមរបស់ព្រះជាម្ចាស់គឺ **"សេចក្តីស្រឡាញ់"** ដូច្នេះយើងត្រូវរស់នៅក្នុងសេចក្តីស្រឡាញ់។ ក្នុងគម្ពីរមានរបៀបបីដែលជួយឲ្យយើងអាចរស់នៅក្នុងសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់៖

១) **"ចូរជួយសម្រាលទុក្ខប្រជារាស្ត្ររបស់យើង..."** ជារបៀបរបស់ព្រះជាម្ចាស់ សម្រាប់ឆ្នាំព្រះមហាករុណាទិគុណនេះ។ ជួយសម្រាលទុក្ខរបស់ប្រជាជនជាតួនាទីរបស់យើងជាគ្រីស្តបរិស័ទ។ នៅជុំវិញយើង មានមនុស្សជាច្រើនដែលរងទុក្ខលំបាកខាងផ្លូវកាយ ផ្លូវចិត្ត និងផ្លូវវិញ្ញាណ។ តើយើងជាគ្រីស្តបរិស័ទដែលមានឈ្មោះនៅក្នុងព្រះនាមព្រះជាម្ចាស់ដែលជាសេចក្តីស្រឡាញ់ដ៏ធំធេងត្រូវជួយសម្រាលទុក្ខព្រួយរបស់គេយ៉ាងដូចម្តេច?

២) **"ព្រះអង្គថែរក្សាប្រជារាស្ត្ររបស់ព្រះអង្គ ដូចគង្វាលថែរក្សាហ្វូងចៀមរបស់ខ្លួន ព្រះអង្គបីកូនតូចៗជាប់នឹងព្រះឱរា..."**។ ព្រះបន្ទូលនេះនាំឲ្យយើងនឹកឃើញម្ដាយដែលបីកូន ជាប់នឹងដើមទ្រូងផ្ដល់ភាពកក់ក្ដៅនិងកម្លាំងដល់កូន។ នេះជារបៀបដែលយើងត្រូវធ្វើក្នុងឆ្នាំព្រះមហាករុណាទិគុណនេះ ក្នុងនាមយើងជាអ្នកមានឈ្មោះនៅក្នុងព្រះនាមរបស់ព្រះជាម្ចាស់។ ឆ្នាំនេះយើងត្រូវបីមនុស្សទាំងអស់នៅជាប់និងដើមទ្រូងរបស់យើង ដើម្បីឲ្យបងប្អូនយើងទទួលភាពកក់ក្ដៅ និងកម្លាំងពីយើង។ ទីក្រុងយើងសប្បាយណាស់ ប៉ុន្តែមានមនុស្សជាច្រើនខ្វះភាពកក់ក្ដៅ ខ្វះកម្លាំងកាយចិត្ត ដើម្បីរស់នៅក្នុងសង្គមដែលកំពុងតែរីកចម្រើនយ៉ាងលឿននេះ។ សូមឲ្យយើងជាគ្រីស្តបរិស័ទយកចិត្តទុកដាក់ជាពិសេស ជួយអ្នកក្រីក្រឲ្យគេអាចចូលនៅក្នុងសង្គមបាន។ សូមផ្ដល់សេចក្ដីស្រឡាញ់ដល់អ្នកតូចតាច ឲ្យទទួលបានភាពកក់ក្ដៅ និងទទួលបានកម្លាំងកាយចិត្ត អាចរស់នៅក្នុងសង្គមសម័យបច្ចុប្បន្ននេះ។

៣) **"ព្រះអង្គជាបុត្រដ៏ជាទីស្រឡាញ់របស់យើង..."** ព្រះបន្ទូលនេះណែនាំឲ្យយើងមានអំណរសប្បាយពេញលក្ខណៈ ហើយឲ្យយើងធ្វើជាសាក្សីនៃអំណរសប្បាយនោះ។ព្រះ-យេស៊ូមានព្រះបន្ទូលច្រើនដងថាព្រះអង្គមានអំណរសប្បាយដ៏ពេញលក្ខណៈ តែអំណរសប្បាយរបស់ព្រះអង្គមិនមែនតាមលោកីយ៍ទេដូចព្រះអង្គមានព្រះបន្ទូលថា **"អ្នកណាសោកសៅអ្នកនោះមានសុភមង្គលហើយ។ អ្នកដែលស្រេកឃ្លានសេចក្ដីសុចរិតអ្នកនោះមានសុភមង្គលហើយ"**។ អ្នកដែលកសាងសន្តិភាពអ្នកនោះមានសុភមង្គលហើយ"។ នេះជាអំណរសប្បាយដែលព្រះជាម្ចាស់ប្រទានមក ជាអំណរសប្បាយដែលមកពីព្រះយេស៊ូ ជាអំណរសប្បាយអស់កល្បជានិច្ច។

យើងគ្រីស្តបរិស័ទទទួលជីវិតថ្មីតាមអគ្គសញ្ញាជ្រមុជទឹក តាមអគ្គសញ្ញាលើកលែងទោស ដើម្បីរៀបចំខ្លួនបណ្ដើរៗទទួលពន្លឺយ៉ាងពិសេសនៅស្ថានបរមសុខ។ នេះជាអំណរសប្បាយដែលស្ថិតស្ថេរប្លែកពីអំណរសប្បាយក្នុងលោកនេះ ដែលជាអំណរសប្បាយតែមួយភ្លែត។

ពេលយើងមើលប្រវត្តិសាស្ត្រប្រទេសកម្ពុជា យើងដឹងថាសមិទ្ធិផលទាំងអស់របស់ព្រះសហគមន៍នៅកម្ពុជាបានបាត់បង់អស់។ ប៉ុន្តែសព្វថ្ងៃព្រះសហគមន៍របស់យើងនៅតែមានជីវិតនៅតែមានអំណរសប្បាយដដែល ព្រោះអំណរសប្បាយរបស់យើងជាអំណរសប្បាយដែលមកពីព្រះយេស៊ូជំរុញឲ្យយើងទៅមុខ ឲ្យយើងកសាងអនាគតនៅស្ថានបរមសុខ។ អំណរសប្បាយរបស់យើងជារបៀបពិសេសដោយជាប់ជាមួយនឹងសេចក្ដីសង្ឃឹម។ ពេលជួបទុក្ខលំបាកបើយើងមិនជាប់ជាមួយសេចក្ដីសង្ឃឹមទេ ទុក្ខលំបាកនោះ នឹងនាំឲ្យយើងធ្លាក់ទឹកចិត្តដែលធ្វើឲ្យយើងពិបាកធ្វើដំណើរទៅមុខ។ ថ្ងៃនេះសូមឲ្យយើងបន្តធ្វើដំណើរទៅមុខជាមួយកិច្ចការរបស់យើង ទីមួយ ឲ្យយើងជួយសម្រាលទុក្ខរបស់បងប្អូនឯទៀតៗ។ ទីពីរឲ្យយើងបីបងប្អូនទាំងអស់ជាប់នឹងទ្រូងរបស់យើងដើម្បីផ្ដល់ភាពកក់ក្ដៅដល់គេ។ ទីបី ឲ្យយើងធ្វើជាសាក្សីនៃអំណរសប្បាយដែលស្ថិតស្ថេរជានិច្ចជាអំណរសប្បាយមកពីព្រះយេស៊ូ។

សូមអរព្រះគុណព្រះជាម្ចាស់ ដែលប្រោសប្រទាន **"ឆ្នាំព្រះមហាករុណាទិគុណ"** នេះដើម្បីឲ្យយើងខ្ញុំរួមគ្នាកសាងព្រះសហគមន៍ ដែលជាព្រះសហគមន៍របស់ព្រះយេស៊ូគ្រីស្ដ។

# យើងយកព្រះគ្រីស្ត ព្រះបន្ទូល ព្រះសហគមន៍ជាទីពឹង

Christ the Word and the Church are our refuge

---

អត្ថបទទី១៖ នហ ៨, ២-៤ក. ៥-៦.៨-១០
អត្ថបទទី២៖ ១ករ ១២, ១២-៣០
ដំណឹងល្អ៖ លក ១, ១-៤ និង ៤, ១៤-២១

ថ្ងៃនេះយើងជួបជុំគ្នា យើងទទួលបេក្ខជន១០នាក់ឲ្យចូលព្រះសហគមន៍។ ជាឱកាសមួយដ៏ល្អឲ្យយើងទាំងអស់គ្នាជាគ្រីស្តបរិស័ទ និងដែលមិនទាន់ជាគ្រីស្តបរិស័ទគិតពីដំណាក់កាលនៃជីវិតរបស់យើង ដែលធ្វើដំណើរជាមួយព្រះសហគមន៍ ជាមួយព្រះគ្រីស្តជាព្រះអម្ចាស់នៃយើង។

ក្នុងពិធីដែលយើងធ្វើអំបាញ់មិុញមានសញ្ញាមួយដ៏សំខាន់ គឺបេក្ខជនទាំង១០នាក់បានក្រាបថ្វាយបង្គំហើយប្រកាសថា **"ខ្ញុំសូមយកព្រះគ្រីស្តជាទីពឹង"** ជាផ្លូវថ្មីនៃជីវិតរបស់គេពីថ្ងៃនេះតទៅ។ អំបាញ់មិុញយើងក៏បានស្តាប់ធម្មទេសនាដំបូងរបស់ព្រះយេស៊ូ នៅក្នុងធម្មសាលាដែរ។ ព្រះអង្គមានព្រះបន្ទូថា **"ហេតុការណ៍ដែលមានចែងទុកក្នុងគម្ពីរដូចអ្នករាល់គ្នាទើបបានស្តាប់បានកើតជារូបរាងនៅថ្ងៃនេះហើយ "** នោះនាំឲ្យយើងគិតថាហេតុការណ៍ទាំងឡាយនៃជីវិតរបស់បងប្អូនទាំង១០នាក់ ក៏បានកើតជារូបរាងនៅថ្ងៃនេះដែរ គឺថ្ងៃនេះបងប្អូនសុខចិត្តយកព្រះគ្រីស្តជាទីពឹង។ កន្លងមកយើងមិនប្រញាប់ធ្វើពិធីទទួលបងប្អូនចូលក្នុងព្រះសហគមន៍ភ្លាមៗទេ ដោយទុកពេលឲ្យបងប្អូនមានឱកាសស្គាល់ព្រះសហគមន៍ ស្តាប់ព្រះបន្ទូលដើម្បីស្គាល់ព្រះយេស៊ូខ្លះៗមុនពេលបងប្អូនចូលក្នុងព្រះសហគមន៍។

---

ពិធីចូលព្រះសហគមន៍
នៅព្រះវិហារសន្តីតេរេសា (ព្រែកឬស្ស)
ថ្ងៃទី ២៤ មករា ២០១៦

១) **"ខ្ញុំសូមយកព្រះគ្រីស្ទជាទីពឹង"** គឺបងប្អូនមានជីវិតថ្មីដោយសារបងប្អូនបានពឹងលើព្រះយេស៊ូ។ ពីពេលនេះទៅព្រះយេស៊ូផ្ដើមធ្វើដំណើរយ៉ាងពិសេសជាមួយបងប្អូន ព្រះអង្គគង់នៅមិនឆ្ងាយពីបងប្អូនទេ ព្រះអង្គជាប់ជាមួយបងប្អូនក្នុងរបៀបថ្មី ដូចព្រះអង្គមានព្រះបន្ទូលថា **"ថ្ងៃនេះព្រះបន្ទូលរបស់ព្រះជាម្ចាស់បានកើតជារូបរាងហើយ..."** គឺកើតជារូបរាងជាមួយបងប្អូនទាំង១០នាក់យ៉ាងពិតប្រាកដ។ ដូច្នេះចាប់ពីឥឡូវរហូតដល់ពេលទទួលអគ្គសញ្ញាជ្រមុជទឹកដែលមានរយៈពេល១ឆ្នាំ ឬ២ឆ្នាំ ឬ៣ឆ្នាំទៀត នោះសូមឲ្យបងប្អូនខិតខំស្គាល់ព្រះយេស៊ូបន្ថែមទៀតដ្បិតថាព្រះយេស៊ូមិនសោយទីវង្គតរហូតទេ ព្រះអង្គមានព្រះជន្មរស់ឡើងវិញ ដែលពេលនេះគង់នៅក្នុងព្រះពន្លានេះ និងជាមួយយើងដែរ នេះជាហេតុដែលបងប្អូនត្រូវតែបង្កើតទំនាក់ទំនងជាមួយព្រះអង្គ។

ជំនឿរបស់យើងប្លែកគ្នាពីពុទ្ធបរិស័ទ ត្រង់ពុទ្ធបរិស័ទដើរតាមមាគ៌ាដែលព្រះពុទ្ធបានត្រាស់ដឹងទុកឲ្យ ប៉ុន្តែយើងជាគ្រីស្តបរិស័ទមាគ៌ារបស់យើង គឺជាព្រះយេស៊ូផ្ទាល់ដូចព្រះយេស៊ូមានព្រះបន្ទូលថា **"ខ្ញុំនេះហើយជាមាគ៌ា..."** ដូច្នេះយើងមិនបានដើរតាមមាគ៌ាដែលព្រះយេស៊ូបានត្រួសត្រាយទុកឲ្យយើងទេ ប៉ុន្តែយើងដើរជាមួយព្រះយេស៊ូផ្ទាល់ដែលជាមាគ៌ា។ ដូច្នេះចាប់ពីពេលនេះ សូមបងប្អូនបង្កើតទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយព្រះយេស៊ូ ដ្បិតព្រះយេស៊ូមិនមែនជាយោបល់មួយ ជាទស្សនៈមួយ ឬជាវីរបុរសម្នាក់ដែលបានបូជាជីវិតកាល ២០០០ ឆ្នាំមុននោះទេ តែព្រះអង្គជាមាគ៌ាជាព្រះជាម្ចាស់ផ្ទាល់ដែលមានព្រះជន្មគង់នៅសព្វថ្ងៃ ទោះបីបងប្អូនមើលព្រះអង្គមិនឃើញក៏ដោយ។ នៅថ្ងៃដែលបងប្អូនទទួលពិធីជ្រមុជទឹក នោះបងប្អូននឹងទទួលអាវសជាសញ្ញាថាព្រះយេស៊ូគង់នៅជាមួយបងប្អូនពិតមែន។ អាវសនោះមិនមែនជាក្រមាមួយ តែគឺជាព្រះយេស៊ូដែលជាផ្លូវតែមួយជាមួយបងប្អូន ហើយបងប្អូនក៏ជាប់ជាមួយនឹងព្រះអង្គដែរ។ តើ៣ឆ្នាំទៀតបងប្អូនធ្វើអ្វីដើម្បីមានទំនាក់ទំនងជិតស្និទ្ធជាមួយព្រះយេស៊ូ?

ចំពោះបងប្អូនដែលជាគ្រីស្តបរិស័ទហើយ ដោយសារព្រះយេស៊ូជាជីវិត និងជាពន្លឺនោះព្រះអង្គក៏ទៅជាផ្លូវដែលណែនាំជីវិតរបស់យើង។ យើងមិនដើរតាមព្រះយេស៊ូទេ ហើយព្រះយេស៊ូ

ក៏មិនដើរពីមុខឲ្យយើងរត់តាមព្រះអង្គដែរ ប៉ុន្តែព្រះយេស៊ូចាប់ដៃយើងព្រះអង្គធ្វើដំណើរជាមួយយើងតាមសមត្ថភាពយើងម្នាក់ៗដែលដើរលឿនឬយឺត តាមអ្វីដែលយើងអាចទៅបាន។ ដូច្នេះ ថ្ងៃនេះពិសេសណាស់ចំពោះបងប្អូនដែលបានយកព្រះគ្រីស្តជាទីពឹង។ បងប្អូនឈប់គិតពីទីពឹងលើខ្លួនឯង។ យើងទីពឹងលើព្រះយេស៊ូជ្បិតព្រះអង្គមានព្រះជន្មគង់នៅសព្វថ្ងៃគង់នៅជាមួយយើងជាពិសេសនៅពេលយើងអធិដ្ឋាន។

ពេលនេះខ្ញុំសូមរំឮកដល់លោកឪពុកទាំងអស់ សូមយកពេលល្ងាចដើម្បីអធិដ្ឋាន។ យើងមានបទពិសោធន៍ ពីការកសាងព្រះសហគមន៍នៅចម្ការទៀងនិងនៅគិរីវង់។ កាលនោះយើងតែងអធិដ្ឋាននៅរាល់ល្ងាចថ្ងៃសៅរ៍ជាពេលមួយពិសេស មិនមែនជាពេលអប់រំជំនឿ ឬយើងពិនិត្យបញ្ជីវត្តមានទេ តែជាពេលដែលបងប្អូនអាចមកអង្គុយនៅជាមួយព្រះយេស៊ូដែលនៅលើអាសនៈមានតាំងព្រះកាយព្រះគ្រីស្ត។ នៅចំពោះមុខព្រះកាយព្រះគ្រីស្តនិងក្នុងបរិយាកាសស្ងប់ស្ងាត់នៅពេលល្ងាច ពេលព្រះអាទិត្យលិចបងប្អូនអង្គុយអធិដ្ឋានផង និងច្រៀងផងទាំងបង្កើតទំនាក់ទំនងផ្ទាល់ខ្លួនជាមួយព្រះយេស៊ូដែលមានព្រះជន្មគង់នៅ។ នេះជាផ្លូវមួយដ៏សំខាន់ដើម្បីបង្កើតព្រះសហគមន៍ដែលចេះអធិដ្ឋាន ចេះសន្ទនាជាមួយព្រះយេស៊ូដែលកំពុងមានព្រះបន្ទូលមកយើងស្របតាមសេចក្តីដែលបងប្អូនបានប្រកាសថា **"ខ្ញុំសូមយកព្រះបន្ទូលជាទីពឹង"**។

២) **"ខ្ញុំសូមយកព្រះបន្ទូលជាទីពឹង"** ព្រះយេស៊ូជាព្រះបន្ទូលដែលបានកើតជារូបរាង។ ព្រះយេស៊ូយាងមកដើម្បីប្រកាសដំណឹងល្អដល់ជនក្រីក្រ ណែនាំឲ្យជីវិតរបស់យើងភ្លឺស្វាងនៅក្នុងរបៀបថ្មី ឲ្យយើងមានកម្លាំងកាយចិត្តដើម្បីរស់នៅក្នុងសង្គមបច្ចុប្បន្ន។ ខ្ញុំជឿថាបងប្អូនដែលបានចូលព្រះសហគមន៍ រួចហើយរាល់ដងពេលបងប្អូនស្តាប់ព្រះបន្ទូលបងប្អូនពិតជាបានទទួលកម្លាំងពីព្រះបន្ទូលពិតមែន ដូច្នេះបន្តិចទៀតក្រោយពេលទេសនាហើយខ្ញុំនឹងចែកព្រះគម្ពីរជូនបេក្ខជន។ សូមបងប្អូនយកចិត្តទុកដាក់អានព្រះគម្ពីរដំណឹងល្អដែលជាព្រះបន្ទូលរបស់ព្រះជាម្ចាស់ មានដំណឹងល្អតាមលោកម៉ាថាយ ម៉ាកូស លូកា និងយ៉ូហាន និងសូមអានកណ្ឌផ្សេងៗទៀតផង។ កណ្ឌគម្ពីរនីមួយៗប្រៀបដូចជាសៀវភៅមួយដែលមាន

និទានរឿងដ៏ពិរោះ និទានពីសេចក្តីពិតដើម្បីឲ្យស្គាល់ព្រះយេស៊ូច្បាស់ឡើងៗ។

ខ្ញុំមានពិសោធន៍ថា រាល់ដងដែលខ្ញុំបានសួរទៅបេក្ខជនតើព្រះបន្ទូលណាដែលបងប្អូនពេញចិត្តជាងគេ? នោះគេពិបាកឆ្លើយ។ ដូច្នេះខ្ញុំសង្ឃឹមថានៅក្នុងរយៈពេល ១ឆ្នាំ ២ឆ្នាំ ខាងមុខនេះបងប្អូននឹងខិតខំអានព្រះគម្ពីរ និងខិតខំស្តាប់ព្រះបន្ទូលក្នុងអភិបូជាដែរ។ ប្រសិនបើបងប្អូនគ្មានព្រះបន្ទូលនៅក្នុងចិត្តទេ តើបងប្អូនអាចប្រកាសថា **"ខ្ញុំសូមយកព្រះបន្ទូលជាទីពឹង"** ម្តេចបាន។ ប្រសិនបើបងប្អូនគ្មានព្រះបន្ទូលក្នុងចិត្តទេតើបងប្អូនអាចស្គាល់ព្រះយេស៊ូម្តេចបាន? ប្រសិនបើបងប្អូនមិនស្គាល់ព្រះយេស៊ូទេតើបងប្អូនអាចប្រកាសថា **"ខ្ញុំសូមយកព្រះគ្រីស្តជាទីពឹង"** ម្តេចបាន? ដ្បិតថាព្រះយេស៊ូនេះហើយជាព្រះគ្រីស្ត។

ដូច្នេះបងប្អូនត្រូវតែអានព្រះព្រះគម្ពីរ ស្តាប់ព្រះបន្ទូលដើម្បីឲ្យព្រះបន្ទូលយាងចូលយ៉ាងជ្រៅក្នុងដួងចិត្តរបស់បងប្អូន។ សន្តៈប៉ូលធ្លាប់មានប្រសាសន៍ថាព្រះបន្ទូលប្រៀបបីដូចដាវដែលមុតចូលក្នុងបេះដូងធ្វើឲ្យយើងឈឺចាប់។ ពិតមែនពេលយើងស្តាប់ឮ ព្រះបន្ទូលថា **"ចូរស្រឡាញ់សត្រូវរបស់អ្នក"** នោះយើងពិបាកនឹងទទួលណាស់។ **"ចូរលើកលែងទោសឲ្យគេ៧០ដងគុណនិង៧"** យើងក៏ពិបាកនឹងទទួលដែរ មិនតែប៉ុណ្ណោះធ្វើឲ្យយើងឈឺចិត្តទៀត។ ប៉ុន្តែទោះបីយ៉ាងនេះក៏ដោយក៏យើងមិនអាចមិនទទួលព្រះបន្ទូលបានដែរដ្បិតព្រះបន្ទូលនេះហើយដែលផ្តល់កម្លាំងឲ្យយើងនៅពេលយើងទន់ខ្សោយ។

**"ចូរស្រឡាញ់ខ្មាំងសត្រូវរបស់អ្នក"** ពិតមែនយើងពិបាកទទួល ប៉ុន្តែពេលយើងអធិដ្ឋាននោះព្រះជាម្ចាស់នឹងប្រទានកម្លាំងឲ្យយើង អាចស្រឡាញ់អស់អ្នកដែលស្អប់យើង។ **"ចូរលើកលែងទោសឲ្យគេ៧០ដងគុណនិង៧"** ពិតមែនយើងពិបាកទទួល ប៉ុន្តែដោយសារការអធិដ្ឋានយើងនឹងមានកម្លាំងដើម្បីលើកលែងទោស ដល់មនុស្សទាំងអស់ដែលធ្លាប់ធ្វើបាបយើង។ **"ចូរធ្វើជាអំបិល និងជាពន្លឺក្នុងលោក"** នោះព្រះជាម្ចាស់នឹងប្រទានកម្លាំងឲ្យយើងអាចរស់នៅក្នុងសង្គមបច្ចុប្បន្នបាន។ យើងមានកម្លាំងគឺមកពីព្រះយេស៊ូមានព្រះបន្ទូលថា **"អ្នកនឹងត្រូវគេបៀតបៀនដូចខ្ញុំ"** ពិតមែនគ្រប់ទុក្ខលំបាកគ្រប់ការបៀតបៀនទាំងអស់ គឺយើងដូច

ព្រះយេស៊ូ ហើយព្រះអង្គគង់នៅជាមួយយើងធ្វើឲ្យយើងអាចស៊ូទ្រាំបាន។

ពេលយើងស្តាប់ធម្មទេសនារបស់ព្រះយេស៊ូនៅលើភ្នំ **"អ្នកណាកសាងសន្តិភាព អ្នកណាមានចិត្តបរិសុទ្ធ អ្នកណាដាក់ចិត្តជាអ្នកក្រខ្សត់...អ្នកនោះមានសុភមង្គលហើយ..."** ពេលនោះព្រះបន្ទូលនេះបានផ្តល់កម្លាំងឲ្យយើងទៅមុខដោយចិត្តស៊ូទ្រាំ។ ពេលយើងស្តាប់ព្រះបន្ទូលដែលថា **"នៅពេលខ្ញុំឃ្លាន នៅពេលខ្ញុំគ្មានសម្លៀកបំពាក់ នៅពេលខ្ញុំគ្មានផ្ទះស្នាក់នៅ នៅពេលខ្ញុំស្រេកទឹក នៅពេលខ្ញុំជាអ្នកជំងឺ នៅពេលខ្ញុំជាប់ឃុំឃាំង...អ្នករាល់គ្នាបានមកសួរសុខទុក្ខខ្ញុំ។ ចូរចាំថារាល់ពេលដែលអ្នករាល់គ្នាបានប្រព្រឹត្តអ្វីចំពោះអ្នកតូចតាចណាម្នាក់ ហាក់បីដូចជាអ្នកបានប្រព្រឹត្តដល់ខ្ញុំដែរ..."** ពេលនោះយើងពិតជាមានកម្លាំងដើម្បីបំពេញកិច្ចការមេត្តាករុណាថ្វាយទៅព្រះជាម្ចាស់។ ហេតុដូច្នោះហើយសូមបងប្អូនយកចិត្តទុកដាក់អាន និងស្តាប់ព្រះបន្ទូលដើម្បីជាកម្លាំង និងជាពន្លឺអស់កល្បជានិច្ច។

៣) **"ខ្ញុំសូមយកព្រះសហគមន៍ជាទីពឹង"** ជាពាក្យប្រកាសទី៣របស់បងប្អូន។ ព្រះ-សហគមន៍ គឺជាបងប្អូនទាំងអស់គ្នាដែលនៅទីនេះយើងជាមហាគ្រួសារតែមួយ។ អំបាញ់មិញយើងបានស្តាប់ឮពីអត្ថបទទី២ថា **"បងប្អូនជាព្រះកាយរបស់ព្រះគ្រីស្តហើយម្នាក់ៗជាសរីរាង្គនៃព្រះកាយតាមចំណែករៀងៗខ្លួន"** តើសរីរាង្គនៃរូបកាយមានអ្វីខ្លះ ? មានភ្នែក មានមាត់ មានអណ្តាត មានច្រមុះ មានត្រចៀក មានដៃ មានជើង មានបេះដូង...។ ថ្ងៃនេះទាំងលោកឪពុក ទាំងបងប្អូនទាំងខ្ញុំដែរ មានអំណរសប្បាយខ្លាំងណាស់ដោយមើលឃើញថាយើងម្នាក់ៗជាសរីរាង្គមួយនៃព្រះកាយព្រះគ្រីស្ត គឺព្រះសហគមន៍របស់យើងជា **"ព្រះគ្រីស្ត"** តែម្តង។ ប៉ុន្តែយើងមានបទពិសោធដែរថាប្រសិនបើសរីរាង្គណាមួយ នៃរូបកាយពិការនោះរូបកាយទាំងមូលដំណើរការទៅមិនបានល្អទេ។ ដូច្នេះព្រះសហគន៍មានជីវិតបាន លុះត្រាណាយើងជួយគ្នាទៅវិញទៅមក។ ការជួយគ្នាទៅវិញទៅមក ជាតួនាទីមួយដ៏ពិសេសរបស់យើងដើម្បីបង្កើតព្រះកាយព្រះគ្រីស្ត និងបង្កើតព្រះសហគមន៍។ ចាប់ពីពេលនេះតទៅ ទោះបីជាសរីរាង្គណាមួយមានរបួសមិនអាចធ្វើការបានច្រើនតែយើងដឹងថាសរីរាង្គឯទៀតៗ នឹងជួយគ្នាទៅវិញទៅមកក្នុងព្រះកាយតែមួយ

គឺជាព្រះសហគមន៍។

**"ខ្ញុំសូមយកព្រះសហគមន៍ជាទីពឹង"** មានន័យជាក់ស្តែង ដូចជាពេលនេះដែលមានគ្រីស្តបរិស័ទចាស់ យុវជនដែលជាគ្រីស្តបរិស័ទហើយជាបងៗ ដូចជាសុផល សារឿន សុភ័ណ្ឌ ស្រ៊ីជា... ជាដើម បានមកស្វាគមន៍បេក្ខជនទាំងអស់ដែលចូលព្រះសហគមន៍នៅថ្ងៃនេះទទួលបងប្អូនចូលក្នុងមហាគ្រួសារតែមួយ ហើយយើងបន្តធ្វើដំណើរជាមួយគ្នាដោយដឹងថា ទាំងអស់គ្នាមិនស្មើគ្នាទេ មានខ្លះពិបាកនេះ ខ្លះពិបាកនោះ ក៏ប៉ុន្តែនៅក្នុងមហាគ្រួសារនេះយើងជួយគ្នាទៅវិញទៅមក។ ប្រសិនបើលោកបូជាចារ្យអត់មានសហការីទេ លោកមិនអាចធ្វើអ្វីមិនបានទេ ដូច្នេះព្រះយេស៊ូក៏ត្រូវការបងប្អូនដែលជាសរីរាង្គរបស់ព្រះអង្គដែរ។

ថ្ងៃនេះយើងសប្បាយចិត្តណាស់ ដោយយើងដឹងថាមិនមែនតែនៅទីនេះទេ តែយើងមានព្រះសហគមន៍ទូទាំងពិភពលោកទាំងមូល ដែលមានគ្រីស្តបរិស័ទប្រមាណជាង ១.២០០ លាននាក់ជាទីពឹងរបស់យើង។ ថ្ងៃនេះយើងពោរពេញដោយកម្លាំងថ្មីដើម្បីបង្កើតព្រះសហគមន៍របស់យើងនៅទីនេះដោយមានជំនួយពីគ្រីស្តបរិស័ទនៅក្រៅប្រទេស។ ព្រះវិហារនេះសាងសង់ឡើងដោយប្រាក់អំណោយចំនួនមួយម៉ឺនដុល្លាពីលោកតាម្នាក់នៅប្រទេសបារាំង។ គាត់ចង់សាងសង់វិហារមួយដែលមានឈ្មោះថា **"សន្តីតេរេសា"**។ សាលាមត្តេយ្យនេះជាជំនួយមកពីគ្រីស្តបរិស័ទនៅប្រទេសហូឡង់។ មណ្ឌលនេះ ជាជំនួយមកពីព្រះសហគមន៍នៅប្រទេសថៃ និងអូស្ត្រាលី។នេះជារបៀបរស់នៅរបស់ព្រះសហគមន៍យើងដែលជាមហាគ្រួសារតែមួយដែលជួយគ្នាទៅវិញទៅមក និងដែលស្រឡាញ់គ្នាទៅវិញទៅមក។

យើងសូមអរព្រះគុណព្រះជាម្ចាស់ ដែលប្រោសឲ្យយើងយកព្រះគ្រីស្តជាទីពឹង យកព្រះបន្ទូលជាទីពឹង និងយកព្រះសហគមន៍ជាទីពឹង។

# យើងចេញទៅប្រកាសដំណឹងល្អតាមរបៀបដែល ព្រះយេស៊ូបង្កើតព្រះសហគមន៍ដើមដំបូង

We proclaim the Gospel as in the Early Church

អត្ថបទទី១៖ ពង្ស ២, ១-៤. ១០-១២
អត្ថបទទី២៖ របា ២៩
ដំណឹងល្អ៖ មក ៦, ៧-១៣

ថ្ងៃនេះព្រះសហគមន៍បានសូមឲ្យយើងស្តាប់ព្រះបន្ទូល អំពីព្រះយេស៊ូចាត់ក្រុមគ្រីស្តទូតឲ្យចេញទៅប្រកាសដំណឹងល្អជាលើកដំបូង ដែលណែនាំឲ្យយើងនឹកឃើញពីគម្រោងការដ៏អស្ចារ្យរបស់ព្រះអង្គសម្រាប់ព្រះសហគមន៍។ ដំណឹងល្អតាមសន្តៈម៉ាកូសបានបង្ហាញថាមុននឹងព្រះយេស៊ូចាត់ក្រុមគ្រីស្តទូតឲ្យចេញទៅ៖ ទី១ ព្រះយេស៊ូបានជ្រើសរើសក្រុមគ្រីស្តទូត១២នាក់ ពីក្នុងចំណោមសាវ័កដែលដើរតាមព្រះអង្គ។ ទី២ ព្រះយេស៊ូគង់នៅជាមួយគេ ព្រះអង្គបង្រៀនគេតាមរយៈធម្មទេសនារបស់ព្រះអង្គ ទៅកាន់បណ្តាជនតាមរយៈធម្មទេសនា និងការអធិដ្ឋានរបស់ព្រះអង្គនៅក្នុងធម្មសាលា និងតាមរយៈការបណ្តេញមារ និងការប្រោសអ្នកជំងឺឲ្យបានជាសះស្បើយ។ ទី៣ ព្រះយេស៊ូចាត់គេឲ្យទៅប្រកាសដំណឹងល្អ នៅពេលពួកគេមានគំនិតចាស់ទុំល្មមខាងជំនឿ គឺក្នុងចំណោម១២នាក់ ព្រះអង្គចាត់គេពីរនាក់ឲ្យចេញទៅ។ របៀបទាំងនេះសំខាន់ណាស់សម្រាប់ព្រះសហគមន៍យើងសព្វថ្ងៃ។ តើសព្វថ្ងៃយើងអាចប្រកាសដំណឹងល្អតែម្នាក់ឯងដូចម្តេចបាន? ប៉ុន្តែបើយើងទៅពីរនាក់ ពីរនាក់នោះយើង នឹងមានឱកាសផ្តល់សក្ខីភាពអំពីការរស់របស់យើងជាបងប្អូនគ្នាក្នុងអង្គព្រះគ្រីស្ត។

---

ពិធីអធិដ្ឋានពេញមួយយប់នៅទេវវិទ្យាល័យ
ថ្ងៃទី ០៤ កុម្ភៈ ២០១៦

អត្ថបទថ្ងៃនេះសំខាន់ណាស់ គឺហាក់បីដូចជានាំយើងឲ្យចូលនៅក្នុងសុបិន្ត នៃទស្សនៈវិស័យរបស់ព្រះយេស៊ូអំពីព្រះរាជ្យព្រះជាម្ចាស់ និងអំពីរបៀបដែលព្រះអង្គបង្កើតព្រះរាជ្យនៅលើផែនដីដែលមាន ចំណុចខ្លះៗដូចតទៅ៖

១) ក្នុងចំណោមសាវ័កជាច្រើនដែលដើរតាមព្រះយេស៊ូ ព្រះអង្គបានជ្រើសរើសគេ ១២នាក់ធ្វើជាគ្រីស្តទូត គឺជាទូតដែលព្រះអង្គនឹងចាត់ឲ្យចេញ ទៅប្រកាសដំណឹងល្អ។ ក្រុមគ្រីស្តទូតរស់នៅជាមួយគ្នាយ៉ាងស្និទ្ធស្នាល និងទទួលភាពកក់ក្តៅយ៉ាងក្រៃលែងពីព្រះយេស៊ូ។ ក្រុមនេះបានធ្វើដំណើរជាមួយគ្នា អធិដ្ឋានជាមួយគ្នា ញ៉ាំបាយជាមួយគ្នា សម្រាកជាមួយគ្នា នឿយហត់ជាមួយគ្នា ហើយគេមានរបៀបរស់នៅជាក្រុមយ៉ាងស្រួល។ ពេលកំណត់មកដល់ ព្រះយេស៊ូបានចាត់គេឲ្យចេញទៅប្រកាសដំណឹងល្អ។ ព្រះសហគមន៍កាតូលិកយើងបានធ្វើត្រាប់តាមគម្រូរបស់ព្រះយេស៊ូ ក្នុងការប្រកាសដំណឹងល្អសព្វថ្ងៃ។ ក្នុងព្រះសហគមន៍របស់យើង ទោះបីយើងមានក្រុមបព្វជិតបព្វជិតាផ្សេងៗគ្នាជាច្រើនក៏ដោយ ក៏យើងស្គាល់គ្នាទៅវិញទៅមកយ៉ាងច្បាស់ និងយើងមានទំនាក់ទំនងជាមួយគ្នាយ៉ាងស្រួល ហើយបេសកកម្មរបស់យើងមិនចប់ត្រឹមនេះទេ ដ្បិតនេះមិនមែនជារបៀបដែលព្រះយេស៊ូបង្កើតព្រះសហគមន៍នោះឡើយ។ តាមរបៀបរបស់ព្រះយេស៊ូ ព្រះសហគមន៍ត្រូវតែចេញទៅណែនាំឲ្យអ្នកដទៃបានស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ គឺត្រូវធ្វើដំណើរពីស្រុកមួយទៅស្រុកមួយ ប្រសិនបើមានគេស្វាគមន៍យើង នោះយើងសុខចិត្តស្នាក់នៅជាមួយគេ ប្រសិនបើគេមិនស្វាគមន៍ទេនោះយើងត្រូវបន្តដំណើរទៅមុខទៀត។ ក្រុមគ្រីស្តទូតដែលធ្វើដំណើរទៅប្រកាសដំណឹងល្អ គេអត់មានលុយ អត់មានយកម្ហូបអាហារទៅជាមួយគេ អត់មានកន្លែងស្នាក់នៅស្រាប់ទេ គេអត់មានស្បែកជើង ហើយក៏អត់មានយកទឹកជាប់នឹងខ្លួនដែរ នេះជារបៀបចេញទៅប្រកាសដំណឹងល្អ។

២) ព្រះយេស៊ូណែនាំឲ្យយើងប្រកាសដំណឹងល្អ គឺឲ្យយើងបង្ហាញអំណរសប្បាយដែលយើងបានទទួលពីព្រះអង្គ។ មួយរយៈពេលដែលក្រុមគ្រីស្តទូតស្នាក់នៅជាមួយព្រះយេស៊ូ គេមានអំណរសប្បាយណាស់ ដោយសារគេបានឃើញផ្ទាល់ភ្នែកថា មានមនុស្សជាច្រើនបានជា

សះស្បើយពីជំងឺបាន រួចផុតពីអំណាចនៃខ្មោច និងមានខ្លះបានរស់ឡើងវិញ...។ ហេតុដូច្នោះហើយក្រុមគ្រីស្តទូតដែលចេញដំណើរទៅ គឺដើម្បីផ្តល់សក្ខីភាពអំពីអំណរសប្បាយទាំងអស់នោះ ដើម្បីឲ្យអ្នកឯទៀតៗចូលមកទទួលអំណរសប្បាយទាំងនោះដែរ។

ព្រះយេស៊ូមានព្រះបន្ទូលថា **"បើអ្នករាល់គ្នាចូលផ្ទះណាមួយ ហើយមានគេទទួលស្វាគមន៍អ្នករាល់គ្នានោះសូមស្នាក់នៅជាមួយគេហើយផ្តល់សក្ខីភាព ឲ្យគេអំពីអំណរសប្បាយ អំពីសេចក្តីសង្ឃឹម និងអំពីអ្វីៗដែលអ្នករាល់គ្នាបានទទួលពីខ្ញុំ"** នេះមានន័យថា គ្រីស្តទូតពីនាក់ពីនាក់ដែលព្រះយេស៊ូចាត់ឲ្យទៅ នោះគេមានតួនាទីមួយយ៉ាងពិសេស គឺគេសាបព្រោះដំណឹងល្អដោយមិនជ្រើសរើសភូមិនេះ ឬ ភូមិនោះទេ គឺព្រះយេស៊ូសូមឲ្យគេចេញពីភូមិមួយទៅភូមិមួយទៀត ពីស្រុកមួយទៅស្រុកមួយទៀត គឺ ឲ្យទៅគ្រប់ទីកន្លែងដើម្បីសាបព្រោះ ដ្បិតមនុស្សទាំងអស់មានសិទ្ធិស្តាប់ឮព្រះបន្ទូលដំណឹងល្អ មានសិទ្ធិដឹងអំពីគម្រោងការនៃការសង្គ្រោះ។ ប្រសិនបើយើងមិនសាបព្រោះទេ គឺយើងប្រព្រឹត្តខុសនឹងសិទ្ធិដែលមនុស្សទាំងអស់មានដើម្បីទទួលការសង្គ្រោះ និងដើម្បីស្តាប់ព្រះបន្ទូលដំណឹងល្អ។ តើធ្វើដូចម្តេចដើម្បីឲ្យមនុស្សដែលមិនទាន់ទទួលការសង្គ្រោះបានទទួលការសង្គ្រោះ? ហើយអ្វីដែលសំខាន់ គឺសូមឲ្យអស់អ្នកដែលបានទទួលការសង្គ្រោះហើយនោះ នៅតែមានភាពជិតស្និទ្ធដែលជាមួយព្រះអង្គ និងជាមួយគ្នាក្នុងក្រុមពីរនាក់ ពីរនាក់របស់គេដើម្បីជាធ្លុងមួយនៅក្នុងអង្គព្រះគ្រីស្ត។

ខ្ញុំជឿជាក់ថាគ្រីស្តទូតទាំងអស់ ទាំងសន្ត:ម៉ាថាយ ថូម៉ាស់ យូដា ហ្វីលីព បាថូឡូមេសិលា" ទាំងអស់គ្នាមានលក្ខណៈខុសៗគ្នា ចរិតខុសៗគ្នា ដោយសារមានអ្នកខ្លះនៅក្មេង អ្នកខ្លះចាស់ មានអ្នកខ្លះមានចរិតរឹងរូស...តែគេពីរនាក់ ពីរនាក់ធ្វើដំណើរជាមួយគ្នាដោយមានធ្លុងតែមួយនៅក្នុងអង្គព្រះគ្រីស្ត ដោយសារព្រះយេស៊ូ ជាមូលហេតុព្រះយេស៊ូជា គោលព្រះយេស៊ូណែនាំឲ្យគេទៅមុខ។ អ្វីៗទាំងនេះគឺជាមេរៀនសម្រាប់ព្រះសហគមន៍របស់យើង ដែលយើងទាំងអស់គ្នាក៏មានលក្ខណៈខុសៗគ្នាដែរ ប៉ុន្តែនៅក្នុងព្រះគ្រីស្ត យើងមានទស្សនៈតែមួយយើងមានព្រះគ្រីស្តតែមួយ យើងមានជំនឿតែមួយ ដែលណែនាំឲ្យយើងទៅមុខធ្វើឲ្យព្រះរាជ្យ

របស់ព្រះជាម្ចាស់យាងមក។ ដូច្នេះសម្រាប់យើងពីនាក់ ពីរនាក់ក្នុងការប្រកាសដំណឹងល្អ គឺយើងជាក្រុមតូចនីមួយៗ ដែលសហការគ្នានៅក្នុងអង្គព្រះគ្រីស្ទ ទោះបីយើងជាមនុស្សប្លែកពីគ្នា។ នេះជារបៀបដែលព្រះយេស៊ូបានបង្កើតព្រះសហគមន៍ដើមដំបូង ដែលជាព្រះសហគមន៍ប្រកាសដំណឹងល្អ។

ថ្ងៃនេះ ជាពេលវេលាមួយដើម្បីឲ្យយើងនឹកឃើញម្តងទៀតថា ព្រះសហគមន៍នឹងប្រកាសដំណឹងល្អបានលុះត្រាមានកម្មករ ប្រសិនបើអត់មានកម្មករទេមិនអាចទៅមុខបានទេ។ ឆ្លៀតឱកាសនេះដែរ យើងសូមថ្លែងអំណរគុណជូនលោកអភិបាលអេមីល ដែលជាកម្មករគំរូសម្រាប់យើង។ ក្នុងអត្ថបទទី មួយមានចែងថា **"ចូរបុត្រមានចិត្តក្លាហានឲ្យសមជាមនុស្សពេញលក្ខណៈ ចូរមានចិត្តស្មោះត្រង់ចំពោះព្រះជាម្ចាស់ជាព្រះរបស់បុត្រ ចូរបុត្រប្រព្រឹត្តតាមព្រះហឫទ័យរបស់ព្រះអង្គជានិច្ច ហើយកាន់តាមក្រឹត្យវិន័យ តាមបញ្ញាតាមច្បាប់ និងតាមដំបូន្មានដូចមានចែងទុកក្នុងធម្មវិន័យរបស់លោកម៉ូសេ"**។ ពេលស្តាប់អត្ថបទនេះហើយ យើងមានអារម្មណ៍ហាក់បីដូចជាលោកអភិបាលអេមីល មានប្រសាសន៍មកកាន់យើងទាំងអស់គ្នា ដែលជាអ្នកបន្តការប្រកាសដំណឹងល្អពីលោក គឺយើងនេះហើយដែលជាអ្នកមានចិត្តក្លាហាន ជាអ្នកដែលមានចិត្តស្មោះត្រង់ និងជាអ្នកដែលកាន់តាមក្រិត្យវិន័យរបស់ព្រះអង្គ។ ដូច្នេះដើម្បីក្លាយទៅជាសាវ័កពីរនាក់ ពីរនាក់ដែលអាចចេញទៅពីរនាក់ ពីរនាក់បាននោះចូរមានចិត្តក្លាហានចូរមានចិត្តស្មោះត្រង់ ចូរធ្វើតាមព្រះហឫទ័យរបស់ព្រះអង្គជានិច្ច នោះយើងនឹងទៅជាគ្រីស្តទូតពិតៗ ទៅប្រកាសដំណឹងល្អនៅគ្រប់ទីកន្លែង មិនមែនតែកន្លែងដែលយើងរស់នៅនោះទេ។

ថ្ងៃនេះយើងសូមអរព្រះគុណព្រះជាម្ចាស់សម្រាប់ការត្រាស់ហៅ សម្រាប់ការជ្រើសរើសដើម្បីឲ្យយើងទៅជាសាវ័ក និងទៅជាគ្រីស្តទូតរបស់ព្រះគ្រីស្ត ដោយនឹកឃើញថាព្រះអង្គអធិដ្ឋានដើម្បីឲ្យយើងមានចិត្តក្លាហាន ដើម្បីឲ្យយើងមានចិត្តស្មោះត្រង់ និងដើម្បីឲ្យយើងប្រព្រឹត្តតាមព្រះហឫទ័យ របស់ព្រះអង្គជានិច្ច នៅក្នុងអំណរសប្បាយនៃការប្រកាសដំណឹងល្អ។

# យើងទទួលស្គាល់ចំនុចខ្សោយរបស់ខ្លួន និង ទទួលការលើកលែងទោសពីព្រះជាម្ចាស់

We embrace our weakness and God's forgiveness

អត្ថបទទី១៖ អស ៦, ១-២ក. ៣-៦
អត្ថបទទី២៖ ករ ១៥, ១-១១
ដំណឹងល្អ៖ លក ៥, ១-១១

ថ្ងៃនេះមានខ្យល់ត្រជាក់បក់មកជូនពរយើង ប៉ុន្តែអ្វីដែលពិសេសជាងនេះទៀត គឺយើងមានអត្ថបទព្រះគម្ពីរដែលគួរឲ្យចាប់អារម្មណ៍ជាខ្លាំង។ អត្ថបទទី១មានចែង*អំពីលោកអេសាយ* អត្ថបទទី២ចែង*អំពីសន្តៈប៉ូល* និងអត្ថបទទី៣ចែង*អំពីគ្រីស្តទូតផ្សេងៗ* ជាពិសេស*គ្រីស្តទូតសិលា*។ អត្ថបទនីមួយៗដែលយើងបានស្តាប់ នាំឲ្យយើងគិតពីរបៀបដែលព្រះយេស៊ូជ្រើសរើសយើងទៅជាគ្រីស្តបរិស័ទ និងពីរបៀបដែលព្រះអង្គនាំឲ្យយើងចេះចែកទៅបងប្អូនឯទៀតៗ នូវសេចក្តីស្រឡាញ់ នូវអំណរសប្បាយដែលយើងបានទទួលពីព្រះជាម្ចាស់។

លោកអេសាយជាព្យាការីម្នាក់ បានស្តាប់ឮព្រះសូរសៀងព្រះជាម្ចាស់ ដែលលាន់ឡើងកក្រើកទ្វារព្រះវិហារ ហើយថែមទាំងមានផ្សែងផង ពេលនោះលោកលាន់មាត់ថា **"ស្លាប់ខ្ញុំហើយ ខ្ញុំពិតជាត្រូវវិនាស ត្បិតខ្ញុំមានបបូរមាត់មិនបរិសុទ្ធ..."**។ ខណៈនោះសេរ៉ាភីមមួយបានហើរតម្រង់មកលោក ទាំងកាន់តង្កៀបទៅកៀបភ្លើងពីអាសនៈមកប៉ះមាត់លោក ហើយប្រាប់លោកថា **"ដោយសារភ្លើងនេះប៉ះបបូរមាត់លោក ដូច្នេះព្រះអម្ចាស់លើកលែងទោសឲ្យលោក ព្រះអង្គរំដោះបាបចេញពីលោកហើយ..."**។

---

អភិបូជានៅព្រះសហគមន៍ សន្តីម៉ារីម៉ាដាឡា ស្វាយប៉ាក
ថ្ងៃទី ០៧ កុម្ភៈ ២០១៦

តាមអត្ថបទនេះ យើងសង្កេតឃើញថា លោកអេសាយបានទទួលស្គាល់ថា ខ្លួនលោកជាមនុស្សបាប ជាមនុស្សទន់ខ្សោយ លោកមានបបូរមាត់មិនបរិសុទ្ធ ហើយលោកក៏រស់នៅក្នុងចំណោមមនុស្សដែលមិនបរិសុទ្ធដែរ ដូច្នេះលោកមិនអាចទៅជាអ្នកថ្លែងព្រះបន្ទូលព្រះជាម្ចាស់បានទេ។ ប៉ុន្តែសេរ៉ាភីមបានប្រាប់ទៅលោកថា ព្រះជាម្ចាស់បានលើកលែងទោសឲ្យលោកបានរំដោះលោកចេញពីបាប ហើយលោកបានទទួលជីវិតថ្មី លោកជាមនុស្សត្រឹមត្រូវវិញហើយ។ ហេតុនេះហើយ នៅពេលព្រះជាម្ចាស់សួរថា **"តើយើងនឹងចាត់នរណាឲ្យទៅ? តើនរណានឹងនាំពាក្យរបស់យើង?"** ភ្លាមនោះលោកអេសាយឆ្លើយថា **"ទូលបង្គំនៅទីនេះស្រាប់ហើយ សូមព្រះអង្គចាត់ទូលបង្គំចុះ"**។ លោកអេសាយសុខចិត្តទទួលបេសកកម្មនេះ ដោយសារលោកមានពិសោធន៍នៅក្នុងខ្លួនថា ទោះបីរូបលោកជាមនុស្សមានបាប ប៉ុន្តែព្រះជាម្ចាស់បានលើកលែងទោសឲ្យលោក និងព្រះអង្គគង់នៅជាមួយលោក ដូច្នេះពេលព្រះជាម្ចាស់ត្រូវការរូបលោក នោះលោកអាចឆ្លើយតបបាន។ សម្រាប់យើងជាគ្រីស្តបរិស័ទ ជាច្រើនដងបបូរមាត់របស់យើងក៏មិនបរិសុទ្ធដែរ ប៉ុន្តែព្រះជាម្ចាស់លើកលែងទោសរំដោះបាបយើង។

ចំពោះសន្តៈប៉ូលវិញ ដើមឡើយលោកជាសាសនទូតសាសនាយូដា លោកស្អប់អស់អ្នកដែលដើរតាមព្រះយេស៊ូ ជាពិសេសលោកប៉ូលបានសម្លាប់គ្រីស្តបរិស័ទអស់មួយចំនួន។ ថ្ងៃមួយពេលលោកកំពុងតែធ្វើដំណើរតាមសេះទៅក្រុងដាម៉ាស នោះលោកបានជួបនឹងព្រះយេស៊ូនៅតាមផ្លូវ ហើយព្រះយេស៊ូមានព្រះបន្ទូលទៅលោកថា **"សូលអើយ! មូលហេតុអ្វីបានជាអ្នកបៀតបៀនខ្ញុំយ៉ាងដូច្នេះ?"**។ តាំងពីពេលនោះមកលោកបានទទួលជីវិតថ្មី។ លោកទទួលស្គាល់ថានៅក្នុងចំណោមគ្រីស្តទូតទាំងអស់ រូបលោកផ្ទាល់មានឋានៈតូចជាងគេ ហើយមិនសមមានឈ្មោះជាគ្រីស្តទូតទៀតផង ព្រោះលោកបានធ្វើទុក្ខបុកម្នេញព្រះសហគមន៍របស់ព្រះជាម្ចាស់។ លោកទទួលស្គាល់ថា ពីដើមលោកជាមនុស្សដែលធ្វើបាបគ្រីស្តបរិស័ទ និងស្អប់គ្រីស្តបរិស័ទ ហើយលោកក៏ស្អប់ព្រះយេស៊ូដែរ ប៉ុន្តែលោកត្រឡប់ទៅជាគ្រីស្តទូត ដោយសារព្រះហឫទ័យប្រោសប្រណីរបស់ព្រះជាម្ចាស់ ដែលគង់នៅជាមួយលោក និងដែលបានបំប្រែចិត្តគំនិតរបស់

លោកទៅជាមនុស្សថ្មី។

ឯសន្តសិលាវិញ ពេលមួយនោះលោកនេសាទត្រីមិនបានសោះ ប៉ុន្តែព្រះយេស៊ូសូមឲ្យលោកទម្លាក់អួនទៅកន្លែងមួយ តែលោកមិនចង់ធ្វើតាមទេ ដ្បិតលោកគិតថានឹងមិនមានត្រីណាចូលក្នុងអួនរបស់លោកទេ។ ប៉ុន្តែភ្លាមនោះលោកក៏ទូលទៅព្រះយេស៊ូថា លោកយល់ព្រមទម្លាក់អួនតាមព្រះអង្គហើយ។ ពេលសាអួនឡើងមានជាប់ត្រីច្រើនណាស់ ធ្វើឲ្យលោកភ្ញាក់ស្មារតី និងលោកបានទូលទៅព្រះយេស៊ូថា **"សូមព្រះអង្គយាងឆ្ងាយពីទូលបង្គំទៅ ដ្បិតទូលបង្គំជាមនុស្សដែលមានបាប"**។ ព្រះយេស៊ូមានព្រះបន្ទូលតបទៅលោកសិលាថា **"កុំខ្លាចអី! ពីពេលនេះតទៅ អ្នកនឹងនេសាទមនុស្សវិញ"**។ ព្រះយេស៊ូមិនវិនិច្ឆ័យបាបរបស់លោកសិលាទេ ប៉ុន្តែព្រះអង្គបានលើកលែងទោសឲ្យលោក និងចាត់លោកឲ្យទៅប្រកាសដំណឹងល្អទៀតផង។

បន្ទាប់ពីយើងបានស្ដាប់អត្ថបទគម្ពីរដែលមានចែងពីលោកអេសាយ សន្តៈប៉ូល និងសន្តសិលាមកនោះ យើងយល់យ៉ាងច្បាស់ថា នៅក្នុងឆ្នាំព្រះមហាករុណាទិគុណនេះ ដើម្បីសម្ដែងព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់ នោះយើងទាំងអស់គ្នាត្រូវតែដូចលោកទាំងបី គឺឲ្យយើងទទួលស្គាល់អំពីចំណុចខ្សោយរបស់ខ្លួន ឲ្យយើងទទួលស្គាល់អំពីអំពើបាបរបស់យើង ឲ្យយើងទទួលស្គាល់អ្វីដែលមិនល្អនៅក្នុងជីវិតរបស់យើង គឺយើងមិនមែនជាមនុស្សដែលមានសមត្ថភាពគ្រប់សកម្មភាពទេ ដូចលោកអេសាយដែលដឹងខ្លួនថា លោកមិនអាចជាអ្នកប្រកាសព្រះបន្ទូលបាន ដូចសន្តប៉ូលដែលទទួលស្គាល់ថា លោកជាមនុស្សទន់ខ្សោយ ដូចសន្តសិលាដែលដឹងថា ខ្លួនជាអ្នកមានបាបមិនអាចនៅជិតព្រះយេស៊ូបានទេ...។

ក្នុងការរស់នៅ ជួនកាលបបូរមាត់យើងមិនបរិសុទ្ធទេ ជួនកាលយើងមិនបានស្រឡាញ់ព្រះសហគមន៍ យើងភ្លេចព្រះសហគមន៍តែម្ដង ជួនកាលយើងក៏ភ្លេចព្រះយេស៊ូដែរ។ ប៉ុន្តែយើងទទួលស្គាល់ថា យើងជាមនុស្សមានបាបដែលព្រះជាម្ចាស់លើកលែងទោសឲ្យ។ នៅក្នុងឆ្នាំព្រះមហាករុណាទិគុណនេះ ឲ្យយើងមានបទពិសោធន៍អំពីព្រះហឫទ័យសណ្ដោសប្រណីរបស់

ព្រះជាម្ចាស់ ឲ្យយើងយល់ថាឆ្នាំនេះជាឆ្នាំពិសេសដើម្បីទទួលជីវិតថ្មី ជាឆ្នាំពិសេសដើម្បីប្រែចិត្តគំនិត ជាឆ្នាំពិសេសដើម្បីធ្វើបូជនិយចរពីភ្នំពេញថ្មី មកផ្សារតូច និងទៅអរិយក្សត្រ។ អ្វីៗទាំងអស់នេះមកពីព្រះជាម្ចាស់ស្រឡាញ់យើង និងយើងត្រូវតែធ្វើជីវិតលើព្រះអង្គ។ នៅពេលយើងទទួលស្គាល់ចំណុចខ្សោយរបស់ខ្លួន នោះយើងនឹងទទួលការលើកលែងទោសពីព្រះជាម្ចាស់ ហើយព្រះអង្គនឹងជ្រើសរើសយើងព្រះអង្គនឹងចាត់យើងឲ្យចេញទៅប្រកាសដំណឹងល្អ។ ថ្ងៃនេះព្រះជាម្ចាស់មានសំណួរមកយើងម្នាក់ៗថា **"តើខ្ញុំនឹងចាត់នរណាឲ្យទៅ ? តើនរណា នឹងនាំពាក្យរបស់ខ្ញុំ ?"** នោះសូមឲ្យបងប្អូនហ៊ានឆ្លើយថា **"សូមព្រះអង្គចាត់ខ្ញុំមកខ្ញុំជាអ្នកទៅ"**។

ព្រះយេស៊ូមានព្រះបន្ទូលទៅលោកសិលាថា **"ចាប់ពីពេលនេះតទៅ ខ្ញុំជ្រើសរើសអ្នកឲ្យនេសាទមនុស្សវិញ"** មានន័យថាព្រះយេស៊ូសព្វព្រះហឫទ័យឲ្យលោកសិលាដែលបានទទួលជីវិតថ្មីពីព្រះអង្គចេញទៅនេសាទមនុស្ស គឺទៅណែនាំមនុស្សឯទៀតៗមកទទួលជីវិតថ្មីពីព្រះអង្គដូចលោកបានទទួលដែរ។ ចំពោះយើងវិញព្រះយេស៊ូក៏សព្វព្រះហឫទ័យឲ្យយើងឆ្លើយថា **"ជាខ្ញុំដែលនឹងទៅប្រកាសដំណឹល្អ ដើម្បីណែនាំឲ្យមនុស្សឯទៀតៗ បានទទួលជីវិតដូចយើងខ្ញុំបានទទួលពីព្រះអង្គដែរ"**។ តើយើងធ្វើដូចម្ដេចដើម្បីឆ្លើយតបនឹងព្រះអង្គបាន? សូមឲ្យយើងនឹកឃើញដល់លោកអភិបាលអេមីលជាគម្រូរបស់យើង តាមពិតលោកជាមនុស្សទន់ខ្សោយដូចយើងដែរ តែលោកមានបទពិសោធន៍អំពីការលើកលែងទោសរបស់ព្រះជាម្ចាស់ ណែនាំឲ្យលោកមានកម្លាំងក្នុងការលះបង់អ្វីៗទាំងអស់ដើម្បីដើរតាមព្រះយេស៊ូ។ នៅពេលប្រទេសកម្ពុជាកំពុងមានសង្គ្រាមលោកបានសរសេរលិខិតផ្ញើទៅបងប្អូនរបស់លោកថា **"ទោះបីជាមានហេតុការណ៍អ្វីកើតឡើងក៏ដោយ ក៏ខ្ញុំស្ថិតនៅប្រទេសកម្ពុជាជានិច្ច ដោយសារព្រះយេស៊ូបានជ្រើសរើសខ្ញុំឲ្យប្រកាសដំណឹងល្អនៅប្រទេសកម្ពុជា"**។ យើងឃើញហើយ ជីវិតរបស់លោកអភិបាលដែលខ្សោយដូចយើង ប៉ុន្តែព្រះជាម្ចាស់បានជ្រើសរើស និងផ្ដល់សេចក្ដីស្រឡាញ់ដល់លោកណែនាំឲ្យលោកអាចឆ្លើយថា **"ខ្ញុំនឹងហើយជាអ្នកបម្រើរបស់ព្រះជាម្ចាស់"**។

ដូច្នេះក្នុងឆ្នាំនេះ សូមឲ្យយើងយកលោកអភិបាលអេមីលជាគម្រូ ដើម្បីឲ្យយើងឆ្លើយជានិច្ច ដោយយកចិត្តទុកដាក់សម្តែងធម៌មេត្តាករុណាតាមផ្លូវកាយ តាមផ្លូវវិញ្ញាណ ដើម្បីទៅជាមនុស្សថ្មី ដោយសម្លឹងមើលព្រះនាងម៉ារី ដែលបានលះបង់ទាំងអស់ដើម្បីដើរតាមព្រះយេស៊ូ។ នៅថ្ងៃនេះដែរ យើងខ្ញុំសូមអរព្រះគុណព្រះជាម្ចាស់ ដែលប្រោសឲ្យជីវិតរបស់យើងខ្ញុំទៅជាជីវិតដ៏វិសុទ្ធ ដោយសារយើងខ្ញុំបានភ្ជាប់ជាមួយព្រះជាម្ចាស់ ដែលជាព្រះដ៏វិសុទ្ធ។

**"ដោយសារភ្លើងនេះប៉ះបបូរមាត់លោក ដូច្នេះព្រះអម្ចាស់លើកលែងទោសឲ្យលោក ព្រះអង្គរំដោះបាបចេញពីលោកហើយ..."។**

# ព្រះជាម្ចាស់
# បានជ្រើសរើសយើងធ្វើជាប្រជារាស្ត្រដ៏វិសុទ្ធ

God chose us to be a Holy People

---

| |
|---|
| អត្ថបទទី១៖ ពង្ស ៨, ១-៧.៩-១៣<br>ដំណឹងល្អ៖ មក ៦, ៥៣-៥៦ |

ថ្ងៃនេះយើងចូលឆ្នាំថ្មីប្រពៃណីចិន-វៀតណាម ជាឱកាសមួយដែលយើងទទួលព្រះពរពីព្រះជាម្ចាស់ និងជាពិសេសដើម្បីស្តាប់ព្រះបន្ទូល ដែលព្រះអង្គណែនាំយើងក្នុងឆ្នាំថ្មីនេះ។ ដូចយើងបានស្តាប់អត្ថបទទីពីរដែលចែងថា **"ព្រះជាម្ចាស់បានជ្រើសរើសបងប្អូនធ្វើជាប្រជារាស្ត្រដ៏វិសុទ្ធ"** និងដូចយើងបានស្តាប់អត្ថបទគម្ពីរដំណឹងល្អពីម្សិលមិញដែរ ដែលព្រះជាម្ចាស់បានជ្រើសរើសលោកសិលា លោកប៉ូល និងក្រុមគ្រីស្តទូតទាំង១២រូប ប៉ុន្តែថ្ងៃនេះយើងស្តាប់ឮថាព្រះជាម្ចាស់ក៏បានជ្រើសរើសយើងដែរ ដោយមិនគិតថា យើងមិនមានសមត្ថភាពដូចលោកប៉ូល លោកសិលា នឹងដូចក្រុមគ្រីស្តទូតទាំង១២រូបនោះទេ។ ដូច្នេះក្នុងឆ្នាំថ្មីនេះ យើងដឹងថាព្រះជាម្ចាស់បានជ្រើសរើសយើង ធ្វើជាប្រជារាស្ត្រដ៏វិសុទ្ធរបស់ព្រះអង្គ ដែលនេះជាព្រះពរមួយយ៉ាងពិសេស និងជាដំណឹងល្អមួយយ៉ាងពិសេស។

ឆ្នាំថ្មីនេះ ក៏ជាឆ្នាំព្រះមហាករុណាទិគុណដែរ ជាឆ្នាំដែលយើងត្រូវតែខិតខំប្រែចិត្តគំនិត ជាឱកាសមួយឲ្យយើងគិតយ៉ាងពិតប្រាកដថា ទោះបីយើងជាអ្នកមានបាប ប៉ុន្តែព្រះជាម្ចាស់បានជ្រើសរើសយើងធ្វើជាប្រជារាស្ត្រដ៏វិសុទ្ធរបស់ព្រះអង្គ យើងទទួលពន្លឺពីព្រះបន្ទូលសម្រាប់ការរស់នៅរបស់យើង។ ថ្ងៃនេះនៅក្នុងអត្ថបទទីពីរមានចែងដែរថា **"សូមឲ្យសេចក្តីសុខសាន្ត**

---

អភិបូជាចូលឆ្នាំវៀតណាមនៅព្រះសហគមន៍ចំប៉ា
ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៦

**របស់ព្រះគ្រីស្តសោយរាជ្យនៅក្នុងចិត្តបងប្អូន"** នេះជាគន្លឹះដ៏សំខាន់សម្រាប់យើងជាប្រជារាស្ត្រដ៏វិសុទ្ធរបស់ព្រះជាម្ចាស់ គឺសូមឲ្យយើងភ្ជាប់ខ្លួនរបស់យើងជាមួយសេចក្ដីសុខសាន្តដែលមកពីព្រះគ្រីស្ត ដែលណែនាំឲ្យយើងបង្កើតសេចក្ដីសុខសាន្តនៅក្នុងក្រុមគ្រួសាររបស់យើង នៅក្នុងភូមិរបស់យើង និងនៅក្នុងជីវិតរបស់យើង...។ សូមកុំឲ្យឆ្នាំនេះទៅជាឆ្នាំដែលយើងចេះតែឈ្លោះគ្នា ចេះតែអន់ចិត្តគ្នា...។ ក្នុងអភិបូជានេះ សូមឲ្យយើងបានទទួលព្រះពរពីព្រះយេស៊ូ សូមឲ្យសេចក្ដីសុខសាន្តរបស់ព្រះគ្រីស្ត សោយរាជ្យនៅក្នុងចិត្តរបស់បងប្អូន ជាពិសេសក្នុងសង្គមបច្ចុប្បន្នដែលមានអំពើហិង្សាជាច្រើន នៅក្នុងពិភពលោករបស់យើងដែលមានសង្គ្រាម និងអំពើភេរវកម្មជាច្រើន និងសូមឲ្យយើងជាគ្រីស្តបរិស័ទដែលមានបេសកកម្មមួយយ៉ាងពិសេស ចេះផ្តល់សេចក្ដីសុខសាន្តដល់បងប្អូនឯទៀតៗ ដល់សង្គមជាតិរបស់យើង និងដល់ពិភពលោកយើងយ៉ាងពិតប្រាកដមែន។

ឆ្នាំនេះសម្តេចប៉ាបបានសរសេរសារលិខិតមួយសម្រាប់ **"ទិវាសន្តិភាពនៃពិភពលោក"** ដែលមានខ្លឹមសារដ៏សំខាន់ថា **"ប្រសិនបើយើងចង់បង្កើតសេចក្ដីសុខសាន្តនៅក្នុងពិភពលោក នោះសូមឲ្យយើងម្នាក់ៗបង្កើតសាមគ្គីភាព និងមានចិត្តមេត្តាករុណា..."**។ សាមគ្គីភាពជាសកម្មភាពដែលយើងសុខចិត្តជួយគ្នាទៅវិញទៅមក សុខចិត្តជួយបងប្អូនដែលកំពុងរងទុក្ខលំបាកដើម្បីបង្កើតព្រះសហគមន៍របស់យើងដែលជាព្រះសហគមន៍ដ៏វិសុទ្ធ ដែលយើងអធិដ្ឋាន ដែលយើងស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់...។

ជាការពិតណាស់ សេចក្ដីសុខសាន្តនឹងដុះឡើងនៅលើផែនដីនេះដោយសារយើងមានសាមគ្គីភាព។ ក្នុងឆ្នាំព្រះមហាករុណាទិគុណនេះ យើងនឹងទទួលបានសេចក្ដីសុខសាន្តយ៉ាងពិតប្រាកដពីព្រះយេស៊ូ ប៉ុន្តែយើងក៏ត្រូវតែគិតដែរថា ត្រូវធ្វើដូចម្តេចដើម្បីឲ្យគណៈកម្មការនីមួយៗរបស់ព្រះសហគមន៍ ដែលមានក្រុមពិធីបុណ្យ ក្រុមសង្គហៈ និងក្រុមអប់រំជំនឿព្រមទាំងក្រុមផ្សេងៗទៀត មានដូចជាក្រុមយុវជន ក្រុមកាយឫទ្ធិ ក្រុមបេះដូងព្រះយេស៊ូ...មានសាមគ្គីគ្នាដើម្បីបង្កើតសេចក្ដីសុខសាន្តនៅក្នុងភូមិ និងក្នុងព្រះសហគមន៍យើងហើយនឹងទៅ

ជាគម្រូនៅក្នុងសង្គមរបស់យើងគ្រប់ទីកន្លែងផង។ សេចក្តីសុខសាន្តរបស់យើងកើតឡើងដោយសារយើងសាមគ្គីគ្នា ក្នុងធម៌មេត្តាករុណាដែលមកពីព្រះជាម្ចាស់ ដូច្នេះយើងមិនអាចធ្វើអ្វីតែម្នាក់ឯងបានទេ គឺយើងត្រូវធ្វើទាំងអស់គ្នា ក្នុងព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់ ដូចក្រុមគ្រីស្តទូតពីដើមដែរ។ ក្នុងឆ្នាំព្រះមហាករុណាទិគុណនេះ គឺជាពេលវេលាដ៏ពិសេសដើម្បីយើងប្រែចិត្តគំនិត ដើម្បីយើងធ្វើដំណើរក្នុងសេចក្តីស្រឡាញ់របស់ព្រះយេស៊ូ ដូច្នេះសូមឲ្យយើងគិតថា តើធ្វើដូចម្តេចដើម្បីយើងចូលនៅក្នុងសេចក្តីស្រឡាញ់របស់ព្រះយេស៊ូ?។

បន្តិចទៀតយើងចូលក្នុងរដូវអប់រំពិសេស ដែលយើងនឹងទទួលអគ្គសញ្ញាលើកលែងទោសដើម្បីឲ្យយើងប្រែចិត្តគំនិតទៅជាមនុស្សថ្មីតាមព្រះហឫទ័យព្រះជាម្ចាស់។សូមឲ្យសេចក្តីសុខសាន្តរបស់ព្រះគ្រីស្ត សោយរាជ្យនៅក្នុងចិត្តរបស់បងប្អូន។ សូមឲ្យព្រះបន្ទូលរបស់ព្រះគ្រីស្តស្ថិតនៅក្នុងបងប្អូនយ៉ាងបរិបូណ៌។ សូមឲ្យព្រះបន្ទូលរបស់ព្រះគ្រីស្ត ដឹកនាំជីវិតរបស់យើង បំភ្លឺយើង បង្រៀនយើង និងសូមឲ្យយើងដាស់តឿនគ្នាទៅវិញទៅមក ដោយប្រាជ្ញាគ្រប់យ៉ាង។ សាមគ្គីមិនត្រឹមតែជួយលុយជួយធ្វើផ្ទះ ជួយជូនអ្នកជំងឺទៅពេទ្យ ប៉ុន្តែសាមគ្គីគឺឲ្យយើងជួយបំភ្លឺគ្នាទៅវិញទៅមក នៅពេលណាយើងឃើញថា មានបងប្អូនយើងណាម្នាក់ធ្វើខុសដើម្បីឲ្យគេដើរតាមផ្លូវល្អវិញ។

សម្រាប់ឆ្នាំព្រះមហាករុណាទិគុណនេះ សម្តេចប៉ាបបានអញ្ជើញយើង ឲ្យយើងធ្វើកិច្ចការមេត្តាករុណាខាងផ្លូវវិញ្ញាណទាំង៧ មានដូចជា ឲ្យយើងចេះបង្រៀនអ្នកដែលវង្វេង បង្រៀនអ្នកដែលគ្មានចំណេះដឹង បង្រៀនអ្នកដែលមានបាប ទទួលស្វាគមន៍អ្នកដែលរំខានយើង អធិដ្ឋានសម្រាប់អ្នកនៅរស់ និងសម្រាប់អ្នកស្លាប់ដែរ... នេះជារបៀបដែលយើងទទួលព្រះបន្ទូល និង អនុវត្តព្រះបន្ទូលនៅក្នុងជីវិតរបស់យើង។ សូមកុំឲ្យព្រះបន្ទូលទៅជាព្រះបន្ទូលមរណៈ តែឲ្យទៅជាព្រះបន្ទូលឥស្សរៈ ដ៏មានជីវិតដែលដឹកនាំការរស់នៅរបស់យើង ពីមួយថ្ងៃទៅមួយថ្ងៃ។ ថ្ងៃនេះព្រះបន្ទូលសូមឲ្យខ្ញុំស្រឡាញ់ខ្មាំងសត្រូវ ថ្ងៃនេះព្រះបន្ទូលសូមឲ្យខ្ញុំទៅជាពន្លឺសម្រាប់អ្នកដទៃ ថ្ងៃនេះព្រះបន្ទូលសូមឲ្យខ្ញុំស្រឡាញ់គ្នាទៅវិញទៅមក ដូចព្រះអង្គបានស្រឡាញ់

យើងដែរ" នេះជារបៀបដែលព្រះយេស៊ូគង់នៅក្នុងព្រះបន្ទូល។ សូមឲ្យយើងមើលនិងខិតខំអនុវត្តតាមព្រះបន្ទូលទាំងអស់ដែលយើបានទទួល ដើម្បីទទួលសេចក្ដីស្រឡាញ់ដ៏បរិបូណ៌ពីព្រះអង្គនៅក្នុងឆ្នាំថ្មីនេះ ដើម្បីឲ្យយើងទៅជាប្រជារាស្ត្រដ៏វិសុទ្ធ ដ្បិតព្រះជាម្ចាស់បានជ្រើសរើសយើងឲ្យទៅជាប្រជារាស្ត្រដ៏វិសុទ្ធ។ ឆ្នាំថ្មីនេះសូមឲ្យយើងធ្វើខ្លួនទៅជាអ្នកដ៏វិសុទ្ធ ដែលទទួលសេចក្ដីស្រឡាញ់ និងសេចក្ដីសុខសាន្តមកពីព្រះជាម្ចាស់ ជាពិសេសបានទទួលព្រះបន្ទូលព្រះអង្គឲ្យយើងស្រឡាញ់គ្នាទៅវិញទៅមក។

ដូចព្រះយេស៊ូមានព្រះបន្ទូលថា **"អ្នកណាស្រឡាញ់ខ្ញុំ អ្នកនោះនឹងប្រព្រឹត្តតាមពាក្យរបស់ខ្ញុំ"** តើយើងបានស្រឡាញ់ព្រះយេស៊ូដែរឬទេ? ប្រសិនបើយើងស្រឡាញ់ព្រះយេស៊ូ នោះយើងត្រូវតែប្រព្រឹត្តតាមព្រះបន្ទូលរបស់ព្រះអង្គ ត្រូវតែប្រមូលអារម្មណ៍ ប្រមូលកម្លាំងជាថ្មី នៅក្នុងឆ្នាំព្រះមហាករុណាទិគុណនេះ ឲ្យទៅជាឆ្នាំដ៏វិសុទ្ធសម្រាប់យើងទាំងដឹងថាលោកអភិបាលអេមីល ដែលបានទទួលមរណភាពហើយ លោកនៅតែបន្តធ្វើដំណើរជាមួយយើង ជំរុញយើងឲ្យមានជំនឿ ឲ្យយើងស្រឡាញ់ព្រះយេស៊ូ ឲ្យយើងជួយគ្នាទៅវិញទៅមក...។ ក្នុងធម្មទេសនាចុងក្រោយរបស់លោកអភិបាលអេមីលបានគូសសង្កត់ថា **"ចូរឲ្យយើងមានជំនឿលើព្រះយេស៊ូ...!"**។

ចូរឲ្យយើងទុកពាក្យនេះសម្រាប់ជីវិតរបស់យើងទាំងអស់គ្នា។ យើងខ្ញុំសូមអង្វរព្រះនាងម៉ារី សន្តៈយ៉ូសែប ព្រះយេស៊ូសូមជួយផ្ដល់កម្លាំងឲ្យយើងខ្ញុំ ទៅជាប្រជារាស្ត្រដ៏វិសុទ្ធ ដោយសារព្រះជាម្ចាស់បានជ្រើសរើសយើងខ្ញុំ។

# ចូរកែប្រែចិត្តគំនិតដោយធ្វើទាន អធិដ្ឋាន និងតមអាហារ ព្រមទាំងបំពេញកិច្ចការមេត្តាករុណាទាំងផ្លូវកាយ និងផ្លូវវិញ្ញាណ

Repent, with prayer, fasting, and practicing the Corporal and Spiritual Works of Mercy

---

| |
|---|
| អត្ថបទទី១៖ យអ ២, ១២-១៨<br>អត្ថបទទី២៖ ករ ៥, ២០ ដល់ ៦, ២<br>ដំណឹងល្អ ៖ មថ ៦, ១-៦. ១៦-១៨ |

ឆ្នាំនេះជាឆ្នាំព្រះមហាករុណាទិគុណ ជាឆ្នាំដែលយើងត្រូវសម្ដែងព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះបិតា។ ដូច្នេះក្នុងរដូវ៤០ថ្ងៃនេះ ត្រូវតែជារដូវ៤០ថ្ងៃយ៉ាងពិសេសសម្រាប់ព្រះសហគមន៍ទាំងមូល ដើម្បីឲ្យយើងអាចចូលយ៉ាងជ្រៅនៅក្នុងព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់ សម្រាប់យើងរៀងៗខ្លួន ដូចមានចែងនៅក្នុងអត្ថបទទី១អំបាញ់មិញថា **"ចូរប្រែចិត្តគំនិតទាំងសោកស្ដាយ ដោយបានប្រព្រឹត្តអំពើអាក្រក់។ កុំគ្រាន់តែហែកសម្លៀកបំពាក់នោះឡើយ! ចូរត្រឡប់មករកព្រះអម្ចាស់ជាព្រះរបស់អ្នករាល់គ្នាវិញ..."**។ នៅក្នុងអត្ថបទដើម គេមិនសរសេរត្រឹមតែកុំគ្រាន់តែហែកសម្លៀកបំពាក់នោះឡើយ ប៉ុន្តែសូមហែកដួងចិត្តដើម្បីទទួលជីវិតថ្មីមកពីព្រះជាម្ចាស់។ ដូច្នេះរដូវ៤០ថ្ងៃខាងមុខនេះ គឺជាពេលវេលាមួយឲ្យយើងរួមដំណើរជាមួយព្រះជាម្ចាស់វិញ ដោយឲ្យយើងទទួលស្គាល់ស្ថានភាពនៃជីវិតរបស់ខ្លួន ដូចយើងបានស្ដាប់ព្រះបន្ទូលនៅថ្ងៃអាទិត្យមុន ដែលលោកអេសាយ លោកប៉ូល លោកសិលា ទទួលស្គាល់ភាពទន់ខ្សោយ និងបាបរបស់ខ្លួនហើយវិលទៅរួមជាមួយព្រះជាម្ចាស់វិញ។

---

ពិធីបុណ្យរោយផេះ នៅក្នុង
ព្រះវិហារសន្ដ: យ៉ូសែប(ផ្សារតូច)
ថ្ងៃទី១០ កុម្ភៈ ២០១៦

ដូច្នេះរដូវសែសិបថ្ងៃជាឱកាសមួយ ដែលព្រះសហគមន៍ទុកឱកាសឲ្យយើងដើម្បីទទួលស្គាល់អំពីជីវិតរបស់ខ្លួន និងដើម្បីយើងចាប់ផ្តើមជីវិតជាថ្មី។

បន្តិចទៀតយើងនឹងទទួលផេះ ដើម្បីឲ្យយើងនឹកឃើញថាពិតមែន រូបកាយយើងគឺជាធូលី យើងទន់ខ្សោយ យើងមានសភាវៈខ្មៅ អាក្រក់នៅក្នុងចិត្តយ៉ាងច្រើន...ប៉ុន្តែយើងសូមហែកដួងចិត្ត ដើម្បីឲ្យព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់ យាងចូលយ៉ាងជ្រៅនៅក្នុងដួងចិត្តរបស់យើង និងយើងត្រឡប់រកព្រះជាម្ចាស់វិញ។ ដូច្នេះរដូវ៤០ថ្ងៃនេះរួមជាមួយឆ្នាំព្រះមហាករុណាទិគុណ គឺជាពេលវេលាមួយ ៖

១) សម្រាប់យើងផ្ទាល់ខ្លួនម្នាក់ៗ យល់ដឹងពីរបៀបដែលព្រះជាម្ចាស់ស្រឡាញ់យើង ពីរបៀបដៃព្រះជាម្ចាស់ប្រណីសន្តោស និងប្រទានជីវិតថ្មីឲ្យយើង។ ជាពេលឲ្យយើងរិះគិតពីជីវិតរបស់ខ្លួនយ៉ាងណា? ឲ្យយើងអង្គុយជាមួយព្រះជាម្ចាស់ ឲ្យយើងអង្វរព្រះជាម្ចាស់បំភ្លឺយើង។ គ្រប់ពេលដែលយើងប្រៀបធៀបជីវិតរបស់យើង ជាមួយនឹងព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់នោះ នាំឲ្យយើងដឹងថា ព្រះបិតាស្រឡាញ់មនុស្សយើងខ្លាំងណាស់ ហើយក៏ណែនាំឲ្យយើងមានកម្លាំងថ្មី ដើម្បីបន្តដំណើរជាមួយព្រះអង្គនៅក្នុងលោកយើងនេះដែរ ជាពិសេសនៅក្នុងសង្គមរបស់យើងបច្ចុប្បន្ន។

២) ប៉ុន្តែក្នុងឱកាសនេះ មិនគ្រាន់តែជាពេលវេលាដើម្បីឲ្យយើងប្រែចិត្តគំនិតប៉ុណ្ណោះទេ ដូចយើងបានស្តាប់នៅក្នុងអត្ថបទទី២អំបាញ់មិញថា **"យើងគឺជាទូតរបស់ព្រះគ្រីស្តដែលព្រះជាម្ចាស់មានព្រះបន្ទូលដាស់តឿនទៅបងប្អូនតាមរយៈយើង។ ដូច្នេះសូមយើងអង្វរសម្រាប់បងប្អូននៅក្នុងព្រះនាមព្រះគ្រីស្តថា សូមព្រះជាម្ចាស់សម្រុះសម្រួលបងប្អូនឲ្យជានានឹងព្រះអង្គវិញទៅ"**។ ដូច្នេះក្នុងរដូវ៤០ថ្ងៃ ក្នុងឆ្នាំព្រះមហាករុណាទិគុណនេះ យើងក៏ទទួលបេសកកម្មមួយទៀតដែរគឺ **"យើងជាទូតរបស់ព្រះគ្រីស្ត"** ដែលមានតួនាទីណែនាំឲ្យបងប្អូនឯទៀតៗ មកទទួលព្រះហឫទ័យប្រណីសន្តោសពីព្រះជាម្ចាស់ និងមកទទួលជីវិតថ្មីពីព្រះអង្គ។ សូមឲ្យបងប្អូនយល់ថា មិនមែនតែខ្ញុំទេដែលទទួលជីវិតថ្មី ប៉ុន្តែខ្ញុំគឺជាទូតរបស់ព្រះគ្រីស្ត ដែលចេញទៅណែនាំឲ្យ

អស់អ្នកដែលមិនទាន់ស្គាល់ព្រះគ្រីស្ត មកទទួលជីវិតថ្មី កម្លាំងថ្មី និងទៅជាមនុស្សថ្មីដែរ។ កុំឲ្យយើងគិតតែសម្រាប់ខ្លួនយើងផ្ទាល់ ប៉ុន្តែយើងត្រូវគិតពីព្រះសហគមន៍របស់យើង និងលើសពីព្រះសហគមន៍ទៀត គឺគិតពីសង្គមដែលយើងរស់នៅបច្ចុប្បន្ននេះ។ យើងជាគ្រីស្តបរិស័ទយើងជាទូតរបស់ព្រះគ្រីស្តតែម្តង យើងមានតួនាទីចែកជីវិតដែលយើងបានទទួលនោះ ទៅបងប្អូនឯទៀតៗ ដោយណែនាំឲ្យគេសម្រុះសម្រួលជាមួយព្រះជាម្ចាស់ ដើម្បីទទួលជីវិតថ្មី ឲ្យគេប្រែចិត្តគំនិត ដើម្បីធ្វើដំណើរនៅក្នុងសេចក្តីសុខ និងអំណរសប្បាយដែលយើងបានទទួលពីព្រះយេស៊ូផ្ទាល់។

ដើម្បីអាចទៅមុខបាន យើងដែលជាព្រះសហគមន៍ត្រូវតែប្រព្រឹត្តតាមព្រះបន្ទូលរបស់ព្រះយេស៊ូ ដូចមានចែងក្នុងព្រះគម្ពីរនៅថ្ងៃនេះថា **"ចូរធ្វើទាន អធិដ្ឋាន និងតមអាហារ"**។ **នៅក្នុងរដូវ៤០ថ្ងៃនេះចូរគិតថា "តើយើងធ្វើទានដូចម្តេច? តើយើងអធិដ្ឋានថែមទៀតដូចម្តេច? តើយើងតមអាហារដូចម្តេច?"**។ សូមប្រយ័ត្នដ្បិតព្រះយេស៊ូមិនសព្វព្រះហឫទ័យឲ្យយើងធ្វើទាន ដោយមានបំណងអួតអាងនៅក្នុងចិត្ត អួតអាងចំពោះអ្នកដទៃ ដើម្បីគេសរសើរ ដើម្បីទទួលរង្វាន់នោះទេ។ ព្រះអង្គមិនណែនាំឲ្យយើងអធិដ្ឋានដោយបង្ហាញខ្លួនឲ្យគេឃើញថា យើងជាមនុស្សល្អ ជាមនុស្សយកចិត្តទុកដាក់ក្នុងការអធិដ្ឋានទៅព្រះជាម្ចាស់នោះដែរ ហើយព្រះអង្គក៏មិនសព្វព្រះហឫទ័យថែមទៀត ឲ្យយើងតមអាហារដោយធ្វើមុខក្រៀមដើម្បីបង្ហាញមនុស្សម្នាថា យើងជាមនុស្សល្អអស្ចារ្យ។ ប៉ុន្តែព្រះយេស៊ូណែនាំឲ្យយើងធ្វើទាន អធិដ្ឋាន និងតមអាហារដោយមានអំណរសប្បាយនៅក្នុងខ្លួន ដោយថ្វាយអ្វីៗគ្រប់យ៉ាងទៅលើព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់។

នៅក្នុងរដូវ៤០ថ្ងៃនេះ យើងអាចធ្វើទាននៅគ្រប់ទីកន្លែង ដោយសារសព្វថ្ងៃនេះនៅគ្រប់ទីកន្លែងមានមនុស្សក្រីក្រជាច្រើន ដែលរង់ចាំសប្បុរសធម៌ពីសប្បុរសជន។ យើងក៏ត្រូវរកពេលដើម្បីអធិដ្ឋាននៅក្នុងព្រះវិហារ និងនៅក្នុងដួងចិត្តរបស់យើងដែរ ដោយអានព្រះគម្ពីរខ្លះៗដោយអានអត្ថបទផ្សេងៗ ដើម្បីឲ្យយើងចេះអរព្រះគុណព្រះជាម្ចាស់ ដែលជាព្រះបិតារបស់យើងដែលស្រឡាញ់យើង។ យើងក៏តមអាហារតាមរបៀបដែលយើងបន្ថយមកញ៉ាំតែមួយពេល ដោយ

ទុកពីរពេលសម្រាប់អ្នកក្រីក្រដែលកំពុងខ្វះខាតអាហារទទួលទាន។

នៅក្នុងរដូវ៤០ថ្ងៃនេះ យើងមានកិច្ចការមេត្តាករុណាទាំងផ្លូវកាយផង និងកិច្ចការមេត្តាករុណាទាំងផ្លូវវិញ្ញាណផង។ កិច្ចការមេត្តាករុណាខាងផ្លូវកាយ គឺឲ្យយើងយកចិត្តទុកដាក់សួរសុខទុក្ខអ្នកជំងឺ អ្នកជាប់ឃុំឃាំង លើកទឹកចិត្តអ្នកអស់សង្ឃឹម ជូនអាហារដល់អ្នកខ្វះម្ហូបអាហារ ជូនសម្លៀកបំពាក់ដល់អ្នកគ្មានសម្លៀកបំពាក់ រាប់អានជនបរទេស និងជួយបញ្ចុះសពអ្នកស្លាប់...។ ឯកិច្ចការខាងផ្លូវវិញ្ញាណវិញ គឺឲ្យយើងយកចិត្តទុកដាក់អប់រំអ្នកបាប អ្នកប្រព្រឹត្តកំហុស អ្នកដែលវង្វេង អ្នកដែលខ្វះការអប់រំ ដោយទី១ សូមឲ្យយើងបង្រៀនគេ។ ទី២ សូមឲ្យយើងស្វាគមន៍ជានិច្ចដល់អស់អ្នកដែលរំខានយើង ដោយចិត្តតស៊ូនិងដោយទឹកមុខញញឹមជានិច្ច និង ទី៣ សូមឲ្យយើងអធិដ្ឋានជារៀងរាល់ថ្ងៃសម្រាប់អ្នកដែលនៅរស់ មានអ្នកដែលយើងស្គាល់ និងអ្នកដែលយើងមិនស្គាល់ដែរឲ្យគេរកឃើញសេចក្តីសុខសាន្តរបស់ព្រះជាម្ចាស់ ដែលជាព្រះបិតារបស់យើង និងឲ្យយើងអធិដ្ឋានសម្រាប់អស់អ្នកដែលទទួលមរណភាពទៅហើយដែរ។

ព្រះជាម្ចាស់ជាព្រះដ៏វិសុទ្ធបានជ្រើសរើសយើងឲ្យធ្វើជាប្រជារាស្ត្រដ៏វិសុទ្ធ។ ក្នុងឋានៈជាប្រជារាស្ត្រដ៏វិសុទ្ធ សូមឲ្យយើងយកចិត្តទុកដាក់ប្រែចិត្តគំនិត ដោយធ្វើទាន ដោយអធិដ្ឋាន និងដោយតមអាហារ ទាំងបំពេញកិច្ចការមេត្តាករុណាខាងរូបកាយ និងខាងវិញ្ញាណ ដោយដឹងថាក្នុងរាត្រីបុណ្យចម្លងនេះ យើងបានរួមជាមួយព្រះយេស៊ូ ដែលមានព្រះជន្មថ្មីរស់ឡើងវិញ ហើយយើងក៏ធ្វើដំណើរជាមួយបងប្អូនទាំងអស់ កសាងសង្គមរបស់យើងឲ្យមានសេចក្តីសុខសាន្តថែមទៀត។

**"ចូរប្រែចិត្តគំនិត នឹងជឿលើដំណឹងល្អចុះ!"** សូមឲ្យយើងខិតខំអស់ពីសមត្ថភាព អស់ពីសេចក្តីស្រឡាញ់របស់យើង ផ្ញើជីវិតលើព្រះយេស៊ូដែលជាផ្លូវ ជាសេចក្តីពិត និងជាជីវិត ដែលនាំយើងចូលនៅក្នុងព្រះហឫទ័យស្រឡាញ់ អស់កល្បជានិច្ចរបស់ព្រះបិតា។

# ជ្រើសរើសជីវិត
# គឺទុកចិត្តលើឧបការគុណព្រះជាម្ចាស់

To choose life is to trust Divine Providence

---

អត្ថបទទី១៖ ទក ២៦, ៤-១០
អត្ថបទទី២៖ រម ១០, ៨-១៣
ដំណឹងល្អ ៖ លក ៤, ១-១៣

ថ្ងៃនេះពិសេសណាស់សម្រាប់ព្រះសហគមន៍យើង ដោយសារមានលោកឪពុក មានបងប្អូន ជាតំណាងមកពីគ្រប់មណ្ឌលសកម្មភាពជួបជុំគ្នា។ ប៉ុន្តែមណ្ឌលសកម្មភាពទន្លេបាសាក់បានសុំការអនុគ្រោះពិសេស ដោយសារបានធ្វើពិធីត្រាស់ហៅបេក្ខជនចំនួន ៨នាក់រួចហើយកាលពីថ្ងៃអង្គារកន្លងទៅ។ ដូច្នេះពេលនេះយើងមានបេក្ខជន ១០៣នាក់ ប៉ុន្តែនៅរាត្រីបុណ្យចម្លងខាងមុខយើង នឹងមានបេក្ខជន១១១នាក់ដែលនឹងទទួលពិធីជ្រមុជទឹកទៅជាសមាជិកថ្មីនៃក្រុមគ្រួសាររបស់យើង គឺព្រះសហគមន៍។ ដូច្នេះក្នុងរយៈពេល៤០ថ្ងៃខាងមុខ ខ្ញុំសូមបងប្អូនបេក្ខជនទាំងអស់រៀបចំខ្លួន ដើម្បីទទួលជីវិតថ្មីពីព្រះយេស៊ូគ្រីស្តដែលជាជីវិតរបស់យើង។

ថ្ងៃនេះយើងចូលនៅក្នុងរដូវ៤០ថ្ងៃ យើងបានស្តាប់អត្ថបទព្រះគម្ពីរដែលចែងអំពីព្រះយេស៊ូទទួលពិធីជ្រមុជទឹក ហើយព្រះវិញ្ញាណបាននាំព្រះអង្គទៅវាលរហោស្ថាន។ ក្នុងព្រះគម្ពីរសម្ព័ន្ធមេត្រីចាស់បានបង្ហាញថា វាលរហោស្ថានជាកន្លែងមួយពិសេសដែលមនុស្សជួបជាមួយនឹងព្រះជាម្ចាស់។ នៅវាលរហោស្ថានអត់មានអ្វីច្រើនយ៉ាងសម្រាប់បរិភោគទេ ប្រភពទឹកក៏មិនសូវមាន ម្ហូបអាហារក៏អត់សូវមាន កន្លែងសប្បាយ កន្លែងដើរលេងក៏អត់មានដែរ មាន

---

ពិធីត្រាស់ហៅយ៉ាំងឱឡារិក នៅព្រះសហគមន៍
សន្ទះយ៉ូសែប (ផ្សារតូច)
ថ្ងៃទី១៤ កុម្ភៈ ២០១៦

តែវាលខ្សាច់ មានតែសត្វសាហាវខ្លះៗ ជាតំបន់ក្តៅ និងស្ងប់ស្ងាត់។ ដូច្នេះទីនោះអត់មានអ្វីមករំខានអារម្មណ៍ដល់អស់អ្នក ដែលមានបំណងធ្វើបទពិសោធន៍អំពីព្រះជាម្ចាស់នោះទេ។

ចំពោះយើងវិញរដូវ៤០ថ្ងៃ គឺជាឱកាសមួយឲ្យយើងចេញពីជីវិតប្រចាំថ្ងៃ ចេញពីបរិយាកាសទ្បូឡា ដើម្បីយើងចូលយ៉ាងជ្រៅនៅក្នុងដួងចិត្តរបស់យើង ដើម្បីធ្វើបទពិសោធន៍អំពីព្រះជាម្ចាស់ដោយយល់ថាព្រះជាម្ចាស់ណែនាំ ឲ្យយើងប្រែចិត្តគំនិតដោយសួរសំណួរមកយើងម្នាក់ៗថា **"តើយើងជ្រើសរើសជីវិត ឬយើងជ្រើសរើសសេចក្តីស្លាប់?" ដែលមានន័យថា "តើយើងជ្រើសរើសព្រះជាម្ចាស់ ឬជ្រើសរើសមារសាតាំង?" ឬ "តើយើងជ្រើសរើសអំពើល្អ ឬយើងជ្រើសរើសអំពើអាក្រក់?"**។ ពេលព្រះយេស៊ូចូលគង់នៅក្នុងវាលរហោស្ថាន ដើម្បីមានបទពិសោធន៍ជាមួយព្រះបិតាព្រះអង្គ នោះព្រះអង្គបានជួបនឹងការល្បួង។ ការល្បួងដ៏ធំដែលមារល្បួងព្រះអង្គគឺ **"សូមធ្វើដុំថ្មនេះឲ្យទៅជានំប៉័ង នោះខ្ញុំនឹងប្រគល់អំណាចព្រមទាំងភោគទ្រព្យរបស់នគរនេះទាំងប៉ុន្មានឲ្យលោក"**។ ពេលស្តាប់ទៅគួរឲ្យចាប់អារម្មណ៍នឹងមារសាតាំងណាស់ ដែលនឹងថ្វាយអំណាច ថ្វាយកិត្តិយសទៅព្រះយេស៊ូ ប្រសិនបើព្រះអង្គព្រមធ្វើដុំថ្មឲ្យទៅជានំប៉័ងទៅជាម្ហូបអាហារ។ សព្វថ្ងៃនេះប្រសិនបើមាននរណាម្នាក់អាចដូរដុំថ្មទាំងអស់ នៅក្នុងប្រទេសកម្ពុជាឲ្យទៅជាម្ហូបអាហារបាន អ្នកនោះនឹងក្លាយទៅជាអ្នកមានពិតប្រាកដ ហើយគេក៏នឹងមានអំណាចនៅទូទាំងប្រទេស និងជាពិសេសនៅទីក្រុងភ្នំពេញដែលពីមួយថ្ងៃទៅមួយថ្ងៃមានអគារធំៗ មានផ្សារទំនើប មានផ្លូវ មានឡានទំនើបៗ និងមានអ្នកមកវិយោគក៏ច្រើនដែរ។ ការល្បួងដែលព្រះយេស៊ូជួប ក៏ជាការល្បួងរបស់យើងរាល់គ្នាដែរ ដោយសារពេលខ្លះ យើងនឹកចង់បានសិរីរុងរឿង ក្នុងជីវិតតាមរបៀបជាអ្នកមានអំណាច និងជាអ្នកមានទ្រព្យសម្បត្តិដែរ ព្រោះយើងគិតថាយើងជាអ្នកក្រ ជាអ្នកអត់មានអាហារបរិភោគគ្រប់គ្រាន់ទេ។

ប៉ុន្តែសូមយើងមើលចម្លើយរបស់ព្រះយេស៊ូ តើចម្លើយរបស់ព្រះអង្គនឹងទៅជាចម្លើយរបស់យើងដែរឬទេ?។ ព្រះយេស៊ូឆ្លើយទៅមារសារតាំងថា **"ក្នុងគម្ពីរបានចែងថាមនុស្សមិនមែនរស់ដោយសារតែអាហារប៉ុណ្ណោះទេ ដូច្នេះអ្នកត្រូវតែថ្វាយបង្គំព្រះជាម្ចាស់ជាព្រះរបស់**

**អ្នក និងគោរពបម្រើព្រះអង្គតែមួយប៉ុណ្ណោះ**"។ ចម្លើយរបស់ព្រះយេស៊ូណែនាំឲ្យយើងភ្ញាក់ស្មារតី។ ម្ហូបអាហារមិនមែនអ្វីដែលសំខាន់ជាងគេនៅក្នុងជីវិតរបស់យើង។ យើងត្រូវការម្ហូបអាហារបរិភោគដើម្បីកុំឲ្យយើងអស់កម្លាំង ឲ្យយើងអាចរស់នៅបាន ប៉ុន្តែមនុស្សមិនរស់ដោយសារតែម្ហូបអាហារប៉ុណ្ណោះទេ គឺត្រូវតែរស់ដោយសារព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដែលជាអាហារដ៏ពិសេស។ ព្រះយេស៊ូបញ្ជាក់ថា "**គ្រប់អំណាចដែលយើងបានទទួលពីលោកិយ៍ ទ្រព្យសម្បត្តិដែលយើងបានពីលោកិយ៍ មិនសំខាន់ទេ សំខាន់គឺយើងចេះថ្វាយបង្គំ និងបម្រើព្រះជាម្ចាស់តែមួយព្រះអង្គគត់**"។

ដូច្នេះក្នុងរដូវ៤០ថ្ងៃនេះ គឺជាពេលវេលាដែលយើងចូលក្នុងវាលរហោស្ថានរួមជាមួយព្រះយេស៊ូ ដែលយើងចូលនៅក្នុងដួងចិត្តរបស់យើងដើម្បីជួបព្រះជាម្ចាស់ នោះសូមឲ្យយើងដឹងយ៉ាងច្បាស់ថានៅជុំវិញយើងមានការល្បួងជាច្រើន...។ ប៉ុន្តែព្រះបន្ទូលក៏ដាស់តឿនឲ្យយើងសួរខ្លួនឯងដែរថា "**តើយើងជ្រើសរើសជីវិត ឬជ្រើសរើសសេចក្តីស្លាប់? តើយើងជ្រើសរើសព្រះបន្ទូលរបស់ព្រះជាម្ចាស់ ឬជ្រើសរើសការល្បួងមកពីមារសាតាំង?**"។

ថ្ងៃនេះយើងមានបេក្ខជន១០៣នាក់ ដែលព្រះសហគមន៍ត្រាស់ហៅឲ្យទទួលអគ្គសញ្ញាជ្រមុជទឹក នៅរាត្រីបុណ្យចម្លងខាងមុខ។ បងប្អូនទាំង១០៣នាក់នេះ នឹងទៅជាកម្លាំងថ្មីរបស់ព្រះសហគមន៍ ហើយដែលធ្វើឲ្យយើងជាគ្រីស្តបរិស័ទពីយូរឆ្នាំហើយ ភ្ញាក់ស្មារតីដោយឃើញបងប្អូនបានជ្រើសរើសជីវិត ហើយបងប្អូនបានលះបង់អ្វីៗទាំងអស់ដែលមាននៅក្នុងជីវិតរបស់ខ្លួន ដើម្បីទទួលជីវិតថ្មីរួមជាមួយព្រះយេស៊ូ នៅក្នុងរាត្រីបុណ្យចម្លងខាងមុខនេះ ដើម្បីទៅជាមនុស្សថ្មីដែលភ្ជាប់ជាមួយព្រះយេស៊ូ ដែលជាធ្លុងតែមួយជាមួយព្រះអង្គ។

ដោយសារបងប្អូនបាន "**ជ្រើសរើសជីវិត**" នោះប៉ុន្មានឆ្នាំកន្លងមក យើងបានឃើញបងប្អូនខិតខំរៀបចំខ្លួន ដោយបានធ្វើដំណើរក្នុងព្រះសហគមន៍ ដោយបានស្តាប់ព្រះបន្ទូល ដោយបានបម្រើព្រះសហគមន៍ នោះណែនាំឲ្យយើងនឹកឃើញថា ពិតមែនគឺបងប្អូនបានជ្រើសរើសយកជីវិត គឺយកព្រះយេស៊ូទុកជាទីពឹង ហើយព្រះអង្គណែនាំឲ្យយើងជាប់ជាមួយព្រះជាម្ចាស់

និងឲ្យយើងទៅជាអ្នកបម្រើព្រះជាម្ចាស់ ដោយបម្រើបងប្អូនឯទៀតៗ ដូចព្រះយេស៊ូមានព្រះបន្ទូលថា "**យើងគោរពបម្រើព្រះអង្គតែមួយប៉ុណ្ណោះ**"។

សព្វថ្ងៃការល្បួងមានច្រើនណាស់។ ព្រះយេស៊ូបានឆ្លងការល្បួងដ៏សំខាន់មួយទៀតគឺមារល្បួងព្រះអង្គថា "**សូមលោកលោតទម្លាក់ខ្លួនចុះទៅក្រោមមើល! នឹងមិនមានគ្រោះថ្នាក់អ្វីទេ ដោយសារមានទេវទូតចាំទ្រលោក**" ដើម្បីល្បងមើលថា តើព្រះយេស៊ូទុកចិត្តលើព្រះជាម្ចាស់ឬអត់? តើព្រះយេស៊ូបានផ្ញើជីវិតលើព្រះជាម្ចាស់ឬអត់?។ សម្រាប់យើងសព្វថ្ងៃ ច្រើនដងច្រើនសាយើងក៏មានការល្បួងដែរដោយយើងសង្ស័យថា "**ប្រហែលព្រះជាម្ចាស់ភ្លេចខ្ញុំហើយ!**" ណែនាំឲ្យយើងមិនផ្ញើជីវិតទាំងស្រុងលើព្រះអង្គទេ គឺយើងផ្ញើខ្លះៗមិនមែនទាំងអស់។ យើងមិនទុកចិត្តលើព្រះឧបការគុណ ដែលព្រះអង្គបានប្រទានអ្វីៗទាំងអស់តាមសេចក្តីត្រូវការដ៏ពិតប្រាកដរបស់យើង។ យើងដូចជាចង់ទុកចិត្តលើខ្លួនឯងជាងទុកចិត្តលើព្រះអង្គ។ ក្នុងព្រះគម្ពីរព្រះយេស៊ូបានឆ្លើយទៅមារថា "**កុំល្បងលព្រះអម្ចាស់ជា ព្រះរបស់អ្នក**" ដោយបញ្ជាក់ច្បាស់ថាព្រះជាម្ចាស់ស្រឡាញ់យើង។

ថ្ងៃនេះបងប្អូនដែលទទួលការត្រាស់ហៅ បានសុខចិត្តផ្ញើជីវិតទាំងស្រុងលើព្រះជាម្ចាស់ បងប្អូនបានជ្រើសរើសយកជីវិត ដោយដឹងថាព្រះជាម្ចាស់ប្រទានអ្វីៗទាំងអស់ដែលបងប្អូនត្រូវការ ជាពិសេសគឺជំនឿ សេចក្តីសង្ឃឹម និងសេចក្តីស្រឡាញ់ ទុកជាព្រះអំណោយទានពិសេសរបស់ព្រះអង្គចំពោះបងប្អូន។ ដោយហេតុនេះហើយបានជាយើងសូត្រធម៌ "**ឱព្រះបិតាយើងខ្ញុំ**" ដោយអង្វរព្រះអង្គថា "**សូមប្រទានអាហារដែលយើងខ្ញុំត្រូវការនៅថ្ងៃនេះ**" ដោយយើងទុកចិត្តលើព្រះជាម្ចាស់ថា ព្រះអង្គនឹងប្រទានអ្វីៗទាំងអស់ដែលយើងត្រូវការពិតមែននៅក្នុងជីវិតរបស់យើង។

ដប់ថ្ងៃមុន នៅទីនេះពេលយើងធ្វើបុណ្យសពលោកអភិបាលអេមីល ពេលនោះខ្ញុំបានប្រាប់បងប្អូនថា របៀបដែលលោកអភិបាលអេមីលទទួលមរណភាព ណែនាំឲ្យយើងយើងអាចទុកចិត្តលើព្រះជាម្ចាស់បាន។ ប៉ុន្មានអាទិត្យចុងក្រោយមុនលោកអភិបាលទទួលមរណភាព

លោកនៅតែអធិដ្ឋាន នៅតែថ្វាយអភិបូជា ហើយព្រះជាម្ចាស់បានជ្រើសរើសឲ្យលោកទទួលមរណភាព ចំថ្ងៃដែលលោកទទួលព្រះកាយព្រះគ្រីស្តលើកដំបូង។ លោកអភិបាលអេមីលមិនបានជ្រើសរើសថ្ងៃដើម្បីទទួលមរណភាពទេ តែជាព្រះជាម្ចាស់ជ្រើសរើសពេលវេលាសម្រាប់លោក ដើម្បីបង្ហាញអំពីវត្តមានរបស់ព្រះអង្គដល់យើងទាំងអស់គ្នា។ យើងមិនអាចសង្ស័យពីវត្តមានរបស់ព្រះអង្គតទៅទៀតទេ ដ្បិតយើងបានឃើញវត្តមានរបស់ព្រះអង្គយ៉ាងជាក់ស្តែងតាមរយៈលោកភិបាលរបស់យើង។ នេះណែនាំឲ្យយើងមានកម្លាំងណាស់ ដោយយល់ថាពិតមែនព្រះជាម្ចាស់មានព្រះជន្មគង់នៅ គឺព្រះអង្គហើយដែលបានជ្រើសរើសយើងជាមុនធ្វើជាបុត្រធីតារបស់ព្រះអង្គ ដោយឲ្យយើងជ្រើសរើសព្រះអង្គទុកជាទីពឹង។

ក្នុងរាត្រីបុណ្យចម្លងខាងមុខ ក្នុងពិធីជ្រមុជទឹក បងប្អូននឹងឮលោកបូជាចារ្យមានប្រសាសន៍យ៉ាងឱឡារិកថា **"ខ្ញុំសូមជ្រមុជកូនក្នុងទឹក ក្នុងព្រះនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ..."** ទាំងលោកមានអំណរសប្បាយយ៉ាងខ្លាំង ដ្បិតលោកផ្ទាល់ហាក់បានចូលរួមជាមួយព្រះជាម្ចាស់ប្រទានជីវិតមកបងប្អូន និងជាពេលដែលលោកបានបំពេញបេសកកម្មយ៉ាងពិតប្រាកដជាបូជាចារ្យ។ នេះជាអំណរសប្បាយសម្រាប់ព្រះសហគមន៍ទាំងមូល បងប្អូនទៅជាកម្លាំងថ្មីទាំងដឹងថាពិតមែនយើងមិនអាចល្បួងលព្រះជាម្ចាស់បានទេ គឺយើងត្រូវតែគោរពនិងស្រឡាញ់ព្រះជាម្ចាស់រហូតដល់ជីវិតចុងក្រោយ។

បងប្អូនជាទីស្រឡាញ់! ថ្ងៃនេះយើងទាំងអស់គ្នាបានជ្រើសរើសព្រះជាម្ចាស់ និងក្នុងរដូវ៤០ថ្ងៃនេះជាឱកាសមួយដើម្បីឲ្យយើងជម្រះចិត្តគំនិត ដើម្បីឲ្យយើងអរព្រះគុណព្រះជាម្ចាស់ដែលប្រោសឲ្យព្រះសហគមន៍របស់យើងមានឱកាស៤០ថ្ងៃ ឲ្យយើងចូលនៅក្នុងជីវិតថ្មីម្តងទៀត ឲ្យយើងចូលក្នុងដួងចិត្តរបស់យើងយ៉ាងជ្រៅម្តងទៀត ជាពិសេសនៅក្នុងឆ្នាំព្រះមហាករុណាទិគុណនេះដើម្បីឲ្យយើងមានការពិសោធន៍ជាក់ស្តែង អំពីព្រះហឫទ័យសន្តោសប្រណីរបស់ព្រះជាម្ចាស់ និងឲ្យបងប្អូនជាគ្រីស្តបរិស័ទយូរហើយ ទទួលអគ្គសញ្ញាលើកលែងទោស និងឲ្យបងប្អូនដែលទទួលការត្រាស់ហៅទទួលជីវិតថ្មីដោយទទួលអគ្គសញ្ញាជ្រមុជទឹក និង

ទទួលព្រះកាយព្រះគ្រីស្ដជាលើកដំបូងនៅក្នុងរាត្រីបុណ្យចម្លងខាងមុខ។

យើងអធិដ្ឋាន ដើម្បីឲ្យឆ្នាំព្រះមហាករុណាទិគុណនេះ និងរដូវ៤០ថ្ងៃនេះ ទៅជាពេលវេលាដើម្បីជម្រះចិត្តគំនិត ទៅជាព្រះសហគមន៍ដែលមានបងប្អូនទទួលការត្រាស់ហៅទាំងចូលរួមក្នុងពិធីជម្រះចិត្តគំនិតលើកទី១ លើកទី២ និងលើកទី៣ ជាមួយបងប្អូនទាំងអស់នៅក្នុងសេចក្ដីស្រឡាញ់របស់ព្រះបិតា និងព្រះបុត្រាដែលស្រឡាញ់យើងយ៉ាងខ្លាំង។ ដូចខ្ញុំបានជម្រាបជូនបងប្អូនរួចហើយ គឺខ្ញុំសូមឲ្យបងប្អូនយើងឆ្លាក់ពាក្យថា **"អធិដ្ឋាន ស្រឡាញ់ និងបម្រើ"** នៅក្នុងដួងចិត្តរបស់យើង និងក៏សូមឲ្យបងប្អូនអនុវត្តកិច្ចការមេត្តាករុណាខាងរូបកាយ និងខាងវិញ្ញាណដែរ ដើម្បីនៅក្នុងរាត្រីនៃបុណ្យចម្លងខាងមុខ បងប្អូនយល់យ៉ាងច្បាស់ថា **"ព្រះជាម្ចាស់ស្រឡាញ់ខ្ញុំខ្លាំងណាស់"**។ ក្នុងរាត្រីនោះ ចំពោះយើងជាគ្រីស្ដបរិស័ទយូរហើយ នៅពេលយើងឃើញបងប្អូនជាបេក្ខជនទទួលជីវិតថ្មី នោះណែនាំឲ្យយើងទាំងអស់គ្នា ក៏ទទួលជីវិតថ្មី ជាថ្មីទៀតដែរ ដើម្បីយើងបន្តធ្វើដំណើរដោយអធិដ្ឋានដោយស្រឡាញ់ និងដោយបម្រើព្រះជាម្ចាស់ និងបម្រើបងប្អូនឯទៀតៗ។

យើងសូមអរព្រះគុណព្រះជាម្ចាស់ និងសូមព្រះអង្គប្រទានពរឲ្យយើងខ្ញុំ និងដោយសារពិធីបុណ្យរោយផេះនៅពេលបន្តិចទៀតនេះ សូមឲ្យយើងខ្ញុំទទួលស្គាល់ពិតមែនថាយើងខ្ញុំជាអ្នកមានបាប ប៉ុន្តែយើងដឹងថាព្រះជាម្ចាស់ស្រឡាញ់យើង និងព្រះជាម្ចាស់លើកលែងទោសឲ្យយើងគ្រប់ពេលវេលា។

# រដូវ៤០ថ្ងៃកែប្រែចិត្តគំនិតថ្មី
# ដើម្បីរួមដំណើរជាមួយព្រះជាម្ចាស់

Change your life and walk with God

អត្ថបទទី១៖ កណ ១៥, ៥-១២. ១៧-១៨
អត្ថបទទី២៖ ភីល ៣, ១៧ ដល់ ៤,១
ដំណឹងល្អ ៖ លក ៩, ២៨ខ-៣៦

ថ្ងៃនេះជាអាទិត្យទីពីរនៃរដូវ៤០ថ្ងៃ ដែលព្រះសហគមន៍យើងបន្តធ្វើដំណើររួមជាមួយព្រះយេស៊ូតទៅទៀត។ ពីថ្ងៃអាទិត្យមុនព្រះយេស៊ូបានយាងទៅវាលរហោស្ថាន ជាកន្លែងមួយយ៉ាងពិសេស ជាកន្លែងស្ងៀមស្ងាត់ អស់ពេល៤០ថ្ងៃ ដើម្បីជួបព្រះជាម្ចាស់ផ្ទាល់។ សម្រាប់យើងអាទិត្យមុន ជាពេលវេលាមួយដើម្បីយល់ថា ៤០ថ្ងៃខាងមុខនេះ យើងនឹងចូលនៅក្នុងវាលរហោស្ថាននៃដួងចិត្តរបស់យើង ដោយយើងនៅស្ងៀមស្ងាត់ជាមួយព្រះជាម្ចាស់ ដោយដឹងថា យើងនឹងមានការល្បួងជាច្រើនទាក់ទាញឲ្យយើងភ្លេចសម្លឹងមើលព្រះជាម្ចាស់។

ប៉ុន្តែនៅសប្តាហ៍នេះ ព្រះយេស៊ូណែនាំឲ្យយើងឡើងលើភ្នំនៃជីវិតរបស់យើងដើម្បីអធិដ្ឋាន។ អំបាញ់មិញយើងបានស្តាប់អត្ថបទគម្ពីរដែលថែងអំពីព្រះយេស៊ូយាងឡើងលើភ្នំដើម្បីអធិដ្ឋាន។ ភ្នំជាកន្លែងមួយដែលមនុស្សជួបនឹងព្រះជាម្ចាស់ ដូចលោកអេលីបានជួបព្រះជាម្ចាស់នៅលើភ្នំ ដូចលោកម៉ូសេបានឡើងលើភ្នំ ហើយបានទទួលវិន័យទាំងដប់ប្រការពីព្រះជាម្ចាស់...។ ដូច្នេះក្នុងសប្តាហ៍នេះ យើងត្រូវតែឡើងលើភ្នំនៃជីវិតរបស់យើងដើម្បីអធិដ្ឋាន ដើម្បីជួបព្រះជាម្ចាស់ និងដើម្បីមានបទពិសោធន៍មួយយ៉ាងពិសេសជាមួយព្រះអង្គ។

---

អភិបូជាសំណាក់រដូវ៤០ថ្ងៃ មណ្ឌលសកម្មភាព
តាខ្មៅនិងភ្នំពេញថ្មី
ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៦

ក្នុងសប្ដាហ៍មុន យើងបានខិតខំឈ្នះអំពើអាក្រក់នៃជីវិតរបស់យើង ហើយក្នុងសប្ដាហ៍នេះ ព្រះយេស៊ូសូមឲ្យយើងមានបទពិសោធន៍មួយយ៉ាងអស្ចារ្យថែមទៀត គឺឲ្យយើងដូចលោកសិលា ដែលបានសម្លឹងមើលព្រះភ័ក្ត្រព្រះអង្គ ដែលពោរពេញដោយរស្មីពណ្ណរាយ។ ពេលណាយើង សម្លឹងមើលព្រះភ័ក្ត្ររបស់ព្រះយេស៊ូ នោះក៏ដូចជាយើងសម្លឹងមើលព្រះភ័ក្ត្រព្រះបិតាដែរ គឺ យើងឃើញព្រះភ័ក្ត្រព្រះបិតាតាមរយៈព្រះយេស៊ូ ហើយនៅជុំវិញព្រះយេស៊ូមានលោកម៉ូសេ លោកអេលី និងលោកសិលា។

ជាធម្មតាពេលណាយើងនឹកដល់លោកម៉ូសេ នោះយើងនឹកដល់វិន័យ ១០ប្រការដែល លោកបានទទួលពីព្រះជាម្ចាស់មកណែនាំជីវិតរបស់យើង។ ដូច្នេះយើងជាអ្នកដែលចង់ជួប ព្រះយេស៊ូត្រូវតែសួរខ្លួនឯងថា **"តើខ្ញុំបានគោរពព្រះជាម្ចាស់ ស្របតាមវិន័យរបស់លោកម៉ូសេ ដែរឬទេ? តើខ្ញុំបានគោរពអ្នកដទៃ ស្របតាមវិន័យរបស់លោកម៉ូសេដែរឬទេ? តើខ្ញុំបានគោរព មាតាបិតា ស្របតាមវិន័យរបស់លោកម៉ូសេដែរឬទេ?"** ដ្បិតលោកម៉ូសេបានណែនាំឲ្យយើង គោរពវិន័យទាំងនេះ ដែលមិនអនុញ្ញាតឲ្យយើងធ្វើតាមតែចិត្តនោះទេ។ យើងមានសេរីភាពតែ នៅក្នុងវិន័យដែលយើងបានទទួលពីព្រះជាម្ចាស់ប៉ុណ្ណោះ គឺឲ្យយើងស្រឡាញ់គ្នាទៅវិញទៅ មក ឲ្យយើងស្រឡាញ់បងប្អូនឯទៀតៗ...។ ព្រះជាម្ចាស់ជាធម្មវិន័យរបស់យើង ណែនាំឲ្យយើង ស្គាល់និងឲ្យយើងមានបទពិសោធន៍ជាមួយព្រះយេស៊ូ។

ចំណែកលោកអេលីវិញ លោកជាព្យាការីដែលបានថ្លែងព្រះបន្ទូលរបស់ព្រះជាម្ចាស់ និង លោកបានប្រកាសដំណឹងល្អអំពីព្រះជាម្ចាស់យាងមក។ ដូច្នេះប្រសិនបើយើងចង់សម្លឹង មើលព្រះយេស៊ូ យើងត្រូវតែដូចលោកអេលី គឺត្រូវគិតអំពីខ្លួនយើងផ្ទាល់ថា **"តើយើងត្រូវថ្លែង ព្រះបន្ទូលរបស់ព្រះជាម្ចាស់ នៅក្នុងជីវិតរបស់យើងជាក់ស្ដែងយ៉ាងដូចម្ដេច?"**។ យើងមិនថ្លែង ព្រះបន្ទូលតែនៅលើបបូរមាត់នោះទេ តែត្រូវធ្វើឲ្យជីវិតរបស់យើងទាំងស្រុង ទៅជាគម្រូដល់ បងប្អូនឯទៀតៗ គឺឲ្យគេមើលឃើញការរស់នៅរបស់យើង ដូចជាគេបានស្ដាប់ឮព្រះបន្ទូល របស់ព្រះជាម្ចាស់ទៅវិញ។ នៅសម័យព្រះយេស៊ូមានបណ្ដាជនជាច្រើនដើរតាមព្រះអង្គ ពួក

គេមានអំណរសប្បាយខ្លាំងណាស់ ដោយសារជាឱកាសមួយដែលពួកគេបានស្តាប់ព្រះអង្គមានព្រះបន្ទូល និងបានឃើញជាក់ស្តែងថា ព្រះបន្ទូលរបស់ព្រះអង្គបានកើតរូបរាងពិតមែន គឺអ្នកជំងឺបានជាសះស្បើយ អ្នកខ្វាក់មើលឃើញវិញ អ្នកថ្លង់ស្តាប់ឮ... ពេលនោះគេយល់ឃើញថាព្រះយេស៊ូណែនាំឲ្យមនុស្សបាបមានជីវិតថ្មី។

ដូច្នេះក្នុងរដូវ៤០ថ្ងៃនេះសម្រាប់យើង គឺយើងត្រូវតែធ្វើកិច្ចការមេត្តាករុណាតាមរូបកាយ និងតាមវិញ្ញាណដែរ ហើយកិច្ចការជាក់ស្តែងទាំងនោះ នឹងទៅជាព្រះបន្ទូលរបស់ព្រះជាម្ចាស់សម្រាប់អ្នកដទៃ នឹងទៅជាសាក្សីរបស់ព្រះយេស៊ូតែម្តង។ ម្សិលមិញយើងបានសម្ពោធបណ្ណាល័យតូចមួយក្នុងភូមិមួយ នៅខាងលិចព្រះវិហារផ្សារតូច ដែលមានកម្មកររាប់ពាន់គ្រួសាររស់នៅ។ កម្មវិធីនេះបានរៀបចំដោយគណៈកម្មការពលករភូមិភាគភ្នំពេញ។ ក្នុងពិធីនោះមានបងប្អូនជាច្រើនមកចូលរួម មានក្មេងៗជាច្រើនមកអានសៀវភៅ ហើយពេលខ្ញុំនិយាយប្រាប់អំពីឆ្នាំព្រះមហាករុណាទិគុណ អំពីធម៌មេត្តាករុណា...គេមិនយល់ទេ។ ប៉ុន្តែនៅទីនោះគេបានឃើញផ្ទាល់ភ្នែក ថាមានក្រុមមួយដែលបានយកចិត្តទុកដាក់រៀបចំកន្លែងនេះ ឲ្យគេទាំងមានសៀវភៅផ្សេងៗជាច្រើនមុខសម្រាប់ឲ្យកូនៗរបស់គេអាន ដើម្បីទទួលនូវចំណេះដឹងបន្ថែមទាំងអក្សរ ទាំងសុជីវធម៌...។ តាមពិតអ្វីៗដែលគេបានទទួល អ្វីដែលគេបានឃើញនោះ គឺជារបៀបមួយដែលគេមើលឃើញធម៌មេត្តាករុណាជាក់ស្តែងរបស់ព្រះជាម្ចាស់ ជារបៀបមួយដែលគេមានបទពិសោធន៍អំពីព្រះជាម្ចាស់ស្រឡាញ់គេ។ ដូច្នេះសូមឲ្យយើងទៅជាអ្នកថ្លែងព្រះបន្ទូលរបស់ព្រះជាម្ចាស់នៅក្នុងជីវិតរបស់យើង ដូចលោកអេលីដែរ។

ដើម្បីយើងមើលឃើញព្រះយេស៊ូ នោះសូមឲ្យយើងសម្លឹងមើលទៅលោកសិលា។ លោកសិលាជាមនុស្សពិសេសម្នាក់ ដែលបានប្រកាសមុនគេបង្អស់ថា **"ព្រះយេស៊ូជាព្រះគ្រីស្ត" "ព្រះយេស៊ូជាព្រះបុត្រារបស់ព្រះជាម្ចាស់"**។ លោកបានប្រកាសថាលោកស្រឡាញ់ព្រះយេស៊ូខ្លាំងណាស់ ហើយលោកមិនអាចទៅណាឆ្ងាយពីព្រះយេស៊ូបានទេ។ ប៉ុន្តែលោកសិលាក៏ជាអ្នកដែលបានក្បត់ព្រះយេស៊ូដែរ ដោយលោកបានឆ្លើយបដិសេធបីដងថាមិនស្គាល់ព្រះអង្គ។

លោកបានជួបព្រះយេស៊ូមុនគេនៅពេលព្រះអង្គមានព្រះជន្មថ្មីដ៏រុងរឿង ហើយលោកបានទូលសូមព្រះយេស៊ូលើកលែងទោស។ លោកសិលាជាតំណាងយើងទាំងអស់គ្នាដែលជាព្រះសហគមន៍ដ៏វិសុទ្ធ គឺយើងទាំងអស់គ្នាជាអ្នកដែលមានបាប ប៉ុន្តែយើងបានទទួលបទពិសោធន៍មួយយ៉ាងអស្ចារ្យ គឺព្រះជាម្ចាស់លើកលែងទោសឲ្យយើង។

ក្នុងឱកាសនេះ ពេលយើងសម្លឹងមើលលោកទាំងបី គឺលោកម៉ូសេ នោះយើងនឹកឃើញដល់វិន័យដែលណែនាំឲ្យយើងស្រឡាញ់ព្រះជាម្ចាស់ ដោយស្រឡាញ់បងប្អូនឯទៀត...។ ពេលយើងសម្លឹងមើលលោកអេលី នោះយើងនឹកឃើញថា យើងគឺជាអ្នកថ្លែងព្រះបន្ទូលរបស់ព្រះជាម្ចាស់ តាមជីវិតរបស់យើងប្រចាំថ្ងៃ និងនៅពេលយើងសម្លឹងមើលទៅលោកសិលា នោះយើងនឹកឃើញថា ពិតមែនយើងជាមនុស្សមានបាប ប៉ុន្តែព្រះជាម្ចាស់លើកលែងទោសឲ្យ យើងដើម្បីឲ្យយើងទទួលជីវិតថ្មី។ ទាំងនេះណែនាំឲ្យយើងចូលយ៉ាងជ្រៅនៅក្នុងរដូវ៤០ថ្ងៃ ដើម្បីសម្លឹងមើលព្រះភ័ក្ត្រព្រះយេស៊ូនៅលើឈើឆ្កាង និងបន្តិចម្តងៗ យើងចូលនៅក្នុងជីវិតរបស់ព្រះយេស៊ូដែលកំពុងថែរក្សាអ្នកដែលមានរបួស អ្នកដែលកំពុងបម្រើបងប្អូន...។ ព្រះយេស៊ូក៏ណែនាំឲ្យយើងទទួលការលើកលែងទោសដែរ។ យើងសង្ឃឹមថាយើងបន្តជួបព្រះយេស៊ូនៅក្នុងរដូវ៤០ថ្ងៃនេះ រហូតដល់ថ្ងៃសុក្រដែលព្រះអង្គសោយទិវង្គត ប៉ុន្តែនៅរាត្រីបុណ្យចម្លងរួមជាមួយបងប្អូន ដែលទទួលអគ្គសញ្ញាជ្រមុជទឹក រួមជាមួយព្រះយេស៊ូយើងនឹងទទួលជីវិតថ្មីថែមទៀត ដើម្បីណែនាំឲ្យយើងទៅជាជីវិតសម្រាប់បងប្អូនឯទៀតៗ។

ថ្ងៃនេះយើងទទួលបេសកកម្មមួយយ៉ាងពិសេស ដូចព្រះយេស៊ូដែលបានទទួលបេសកកម្មមួយយ៉ាងពិសេស ទាំងមានព្រះភ័ក្ត្រភ្លឺថ្លាពណ្ណរាយដែរ។ ដូច្នេះក្នុងរដូវ៤០ថ្ងៃនេះសូមឲ្យយើងមានឱកាសប្រែចិត្តចូលនៅក្នុងវាលរហោស្ថាន ឲ្យយើងមានរស្មីពណ្ណរាយនៅលើមុខក្នុងការរស់នៅ ឲ្យយើងដើរជាមួយព្រះយេស៊ូគ្រប់កាលៈទេសៈ។ សូមឲ្យយើងញញឹមដាក់បងប្អូនឯទៀត ដូចព្រះជាម្ចាស់ញញឹមដាក់យើង សូមឲ្យយើងលាងរបួសបងប្អូនឯទៀតៗ ដូចព្រះជាម្ចាស់លាងរបួសរបស់យើងដែរ...។

យើងខ្ញុំសូមអរព្រះគុណព្រះជាម្ចាស់ ដែលបានណែនាំឲ្យយើងខ្ញុំធ្វើដំណើររួមជាមួយព្រះអង្គ និងឲ្យយើងខ្ញុំបានស្តាប់ព្រះសូរសៀងព្រះអង្គដែលបន្លឺពីក្នុងពពកមកថា **"នេះជាបុត្រដ៏ជាទីស្រឡាញ់របស់យើង ដែលយើងបានជ្រើសរើសចូរស្តាប់ព្រះអង្គចុះ"**។

**"តើខ្ញុំបានគោរពព្រះជាម្ចាស់ ស្របតាមវិន័យរបស់លោកម៉ូសេ ដែរឬទេ? តើខ្ញុំបានគោរពអ្នកដទៃ ស្របតាមវិន័យរបស់លោកម៉ូសេដែរឬទេ? តើខ្ញុំបានគោរពមាតាបិតា ស្របតាមវិន័យរបស់លោកម៉ូសេដែរឬទេ?"**

# ព្រះជាម្ចាស់ត្រាស់ហៅយើងឲ្យមើលឃើញ ស្តាប់លឺ យល់ចិត្តគេនិងសម្តែងមេត្តាករុណា

God calls us to see, hear, and understand others, loving them in truth and in deed

---

អត្ថបទទី១៖ សរ ៣, ១-៨ក.១០.១៣-១៥
អត្ថបទទី២៖ ករ ១០, ១-៦. ១០-១២
ដំណឹងល្អ ៖ លក ១៣, ១-៩

នៅពេលស្តាប់ឮពីស្ត្រីសាសន៍សាម៉ារី នោះខ្ញុំចង់ឲ្យបងប្អូនចាប់អារម្មណ៍អំពីរបៀបដែលព្រះជាម្ចាស់ស្រឡាញ់យើង ព្រះអង្គធ្វើដំណើរជាមួយយើង និងជាពិសេសក្នុងឆ្នាំព្រះមហាករុណាទិគុណ នេះសូមឲ្យបងប្អូនសម្តែងព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់ចំពោះមនុស្សទាំងអស់។ ថ្ងៃនេះក្នុងអត្ថបទទី១ ព្រះជាម្ចាស់មានព្រះបន្ទូលមួយយ៉ាងពិសេស គឺព្រះអង្គបង្ហាញព្រះនាមផ្ទាល់របស់ព្រះអង្គទៅលោកម៉ូសេ។ ព្រះជាម្ចាស់មានព្រះបន្ទូលថា **"យើងជាព្រះអម្ចាស់ដែលមានព្រះជន្មគង់នៅ"** ដែលមានន័យថា **"ព្រះជាម្ចាស់គង់នៅជាមួយយើងគ្រប់ពេលវេលា"**។ កន្លែងណាដែលយើងទៅ កន្លែងនោះមានព្រះជាម្ចាស់គង់នៅជាមួយយើង ពេលយើងទៅព្រះវិហារក្តី ទៅផ្សារក្តី ទៅសាលារៀនក្តី ពេលយើងងូតទឹក ពេលដើរលេង ពេលធ្វើចម្ការ ពេលធ្វើស្រែ...ត្រូវដឹងថាមានព្រះជាម្ចាស់គង់នៅជាមួយយើង។ ព្រះអង្គមិនគង់នៅតែក្នុងទូព្រះកាយប៉ុណ្ណោះទេ។

ពេលនេះ សូមឲ្យយើងសម្លឹងមើលព្រះជាម្ចាស់ម្តងទៀត គឺមើលពីរបៀបដែលព្រះអង្គមានព្រះបន្ទូលទៅកាន់លោកម៉ូសេ **"សូមប្រាប់គេថា យើងបានឃើញទុក្ខលំបាករបស់ប្រជារាស្ត្ររបស់យើង យើងបានឮសម្រែករបស់គេ យើងដឹងអំពីទុក្ខវេទនារបស់ពួកគេហើយ។**

---

អភិបូជាសំណាកធម៌រដូវ៤០ថ្ងៃនៅព្រះសហគមន៍សន្តយ៉ូសែបជុំគីរី
ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៦

**ដូច្នេះយើងចុះមករំដោះគេ"** ក៏ដូចគ្នាដែរ ព្រះយេស៊ូដែលមានព្រះហឫទ័យមេត្តាករុណានៅពេលដែលព្រះអង្គទតឃើញស្ត្រីមេម៉ាយម្នាក់យំដោយសារកូនគាត់ស្លាប់ ពេលនោះព្រះអង្គបានទៅជិត ហើយពាល់កូននោះក៏មានជីវិតវិញ។ ដូចគ្នាដែរអំពីបុរសសាសន៍សាម៉ារីដែលមានចិត្តមេត្តាករុណា នៅពេលគាត់ឃើញបុរសម្នាក់ត្រូវរបួសដេកស្តូកស្តឹងនៅកណ្តាលផ្លូវ គាត់ក៏ចុះពីរទេះទៅពាល់ និងលាងរបួសរបស់បុរសនោះផង។ ក្នុងព្រះគម្ពីរក៏មានចែងដែរ អំពីស្ត្រីសាសន៍សាម៉ារីម្នាក់មកដងទឹកអណ្តូងនៅម៉ោង១២ថ្ងៃត្រង់ ជាពេលក្តៅ ហើយជាពេលស្ងាត់ដោយសង្ឃឹមថានាងនឹងមិនជួបនរណាឡើយ។ នាងគេចមុខពីគេដោយសារនាងមានប្តី៥នាក់ហើយ ឯបុរសដែលនាងរស់នៅជាមួយសព្វថ្ងៃ មិនមែនជាប្តីរបស់នាងទេ។ អ្នកភូមិអត់មាននរណាចង់និយាយជាមួយនាង ប៉ុន្តែថ្ងៃនេះ នាងបានជួបព្រះយេស៊ូ ហើយព្រះអង្គយល់ចិត្តនាងដឹងពីទុក្ខលំបាករបស់នាង។ ព្រះយេស៊ូយាងចូលទៅជិតហើយព្រះអង្គទុកពេល ដើម្បីស្តាប់នាងនិយាយ ព្រះអង្គទតមុខនាងហើយមានព្រះបន្ទូលឆ្លងឆ្លើយជាមួយនាង យ៉ាងជិតស្និទ្ធរហូតធ្វើឲ្យនាងភ្ញាក់ស្មារតីថា ហេតុអ្វីបានជាព្រះយេស៊ូ ដឹងថានាងមានប្តីច្រើនដូច្នេះ? និងបន្តិចម្តងៗ ព្រះយេស៊ូបង្ហាញឲ្យនាងដឹងថា ព្រះអង្គជាទឹកដែលផ្តល់ជីវិតអស់កល្បជានិច្ច។ ពេលនោះនាងសាសន៍សាម៉ារីភ្ញាក់ស្មារតី នាងសប្បាយចិត្តណាស់ ហើយរត់ទៅភូមិវិញទាំងលែងខ្មាសគេ លែងខ្លាចគេដូចមុនទៀតហើយ ដើម្បីប្រាប់ពីអំណរសប្បាយរបស់នាងទៅអ្នកភូមិថានាងបានជួបព្រះមេស្ស៊ីហើយ គឺជាព្រះយេស៊ូ ព្រះអង្គជាទឹកដែលផ្តល់ជីវិតអស់កល្បជានិច្ច...។

នៅថ្ងៃនោះ មានមនុស្សម្នាជាច្រើនបានស្តាប់ស្ត្រីនោះ នាងជាស្ត្រីដែលគេធ្លាប់ស្អប់គេធ្លាប់មើលងាយ ប៉ុន្តែពេលនេះនាងជាមនុស្សថ្មី ដោយសារនាងបានជួបនឹងព្រះយេស៊ូ ហើយព្រះជាម្ចាស់បានលើកលែងទោសឲ្យនាងមានជីវិតថ្មី។ នាងមិននៅស្ងៀមបានចេញទៅភូមិចែកអំណរសប្បាយ ដែលនាងបានទទួលទៅអ្នកភូមិ។ នៅពេនោះមានមនុស្សជាច្រើនគេសប្បាយចិត្ត និងគេដើរតាមព្រះយេស៊ូ។ យើងក៏ដូចគ្នាដែរ ព្រះជាម្ចាស់បានអញ្ជើញយើងឲ្យស្តាប់ឲ្យឮ ឲ្យមើលឃើញ ឲ្យយើងយល់ចិត្តគេ ឲ្យយើងចុះទៅរកគេ ដើម្បីឲ្យគេមានជីវិតថ្មី

និងដើម្បីចែកអំណរសប្បាយរបស់យើង។ ពេលនេះមានបេក្ខជន បីនាក់ដែលនឹងទទួលពិធីជម្រះចិត្តគំនិតលើកទីមួយ ហើយប្អូនក៏នឹងទទួលជីវិតថ្មីក្នុងរាត្រីបុណ្យចម្លងនៅពេលខាងមុខនេះដែរ ដូច្នេះជាឱកាសមួយឲ្យប្អូនប្រកាសដំណឹងល្អបន្តទៀត ដើម្បីមានមនុស្សច្រើនថែមទៀតចូលក្នុងព្រះសហគមន៍ជាព្រះកាយព្រះគ្រីស្ត។ នេះជារបៀបរបស់អស់អ្នក ដែលបានជួបព្រះយេស៊ូមានដូចជាលោកម៉ូសេដែលបានជួបព្រះជាម្ចាស់ដែលមានព្រះជន្មគង់នៅ និងដូចស្ត្រីសាសន៍សាម៉ារីដែលបានជួបជាមួយព្រះយេស៊ូ ជាជីវិតអស់កល្បជានិច្ចដូច្នោះដែរ។

នៅថ្ងៃនេះយើងអរព្រះគុណព្រះជាម្ចាស់ ដើម្បីឲ្យយើងមើលឃើញ ស្តាប់ឮ យល់ចិត្តគេ និងចុះទៅពាល់គេ ដើម្បីបង្ហាញធម៌មេត្តាករុណា តាមកិច្ចការមេត្តាករុណាទាំង៧ខាងរូបកាយ និងខាងវិញ្ញាណ ដោយរាល់ថ្ងៃទៅជួបគេ ស្វាគមន៍គេ អរគុណគេ ណែនាំគេ។ យើងសូមព្រះជាម្ចាស់ជួយយើងឲ្យបានជួបព្រះយេស៊ូ ដើម្បីឲ្យយើងមានបទពិសោធពិតមែនថា ព្រះយេស៊ូជាទឹកដែលផ្តល់ជីវិតអស់កល្បជានិច្ច។

# សូមឲ្យយើងយកតម្រាប់តាមសន្តយ៉ូហានបូស្កូដោយមានចិត្តស្រឡាញ់ មេត្តាករុណា និងយកចិត្តទុកដាក់

With St. John Bosco, let us love and care for our brothers and sisters

---

អត្ថបទទី១៖ សរ ៣, ១-៨ក.១០.១៣-១៥
អត្ថបទទី២៖ ករ ១០, ១-៦. ១០-១២
ដំណឹងល្អ ៖ លក ១៣, ១-៩

ថ្ងៃនេះយើងទាំងអស់គ្នាមានអំណរសប្បាយយ៉ាងខ្លាំង យើងនឹកចាំថាឆ្នាំមុនយើងបានធ្វើខួប២០០ឆ្នាំនៃថ្ងៃកំណើតសន្តៈយ៉ូហានបូស្កូនៅទីនេះ។ សព្វថ្ងៃដុនបូស្កូមានវត្តមាននៅជាង១៣២ប្រទេស ដែលមានលោកបូជាចារ្យប្រហែល១៥.០០០នាក់ បងស្រីជាង១០.០០០នាក់ និងមានសហការីរាប់ម៉ឺននាក់ ណែនាំឲ្យយើងយល់ថា ពិតមែនការអស្ចារ្យរបស់សន្តៈយ៉ូហានបូស្កូ មានផ្លែនៅគ្រប់ទីកន្លែង។ តាមអត្ថបទថ្ងៃនេះមានចែងថា **"ឲ្យយើងចាំបីឆ្នាំសិនប្រសិនបើឥតផ្លែយើងនឹងកាប់ដើមចោល"** ប៉ុន្តែយើងដឹងថាយ៉ូហានបូស្កូ បានបង្កើតផលផ្លែយ៉ាងច្រើន។ ថ្ងៃនេះយើងបានប្រារព្ធខួប២៥ឆ្នាំ នៃវត្តមានរបស់ដុនបូស្កូនៅក្នុងប្រទេសកម្ពុជា។ យើងមានអំណរសប្បាយជាមួយអ្នកដែលបានចាប់ផ្តើមដំបូង មានដូចជាបងប្រុស រ៉ូប៊ែតូ លោកបូជាចារ្យចនវីសសែជាដើម ហើយថ្ងៃនេះដែរ មានវត្តមានយ៉ាងពិសេសរបស់អ្នកបន្តវេនសន្តៈបូស្កូ គឺលោកអគ្គមហាធិការ **អនជែនហ្វេរណាង់ដែសប៉ាទីមេ**។ នេះជាពេលវេលាមួយដើម្បីយើងអរព្រះគុណព្រះជាម្ចាស់។

---

ពិធីខួប២៥ឆ្នាំនៃវត្តមានរបស់ដុនបូស្កូនៅកម្ពុជា
ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៦

ពេលខ្ញុំមកដល់ប្រទេសកម្ពុជានៅឆ្នាំ១៩៩៨ នៅទីនេះគ្មានអ្វីផ្សេងទៀត ក្រៅតែពីសាលាដុនបូស្កូដែលនៅកណ្តាលវាលស្រែតែឯង ប៉ុន្តែសព្វថ្ងៃ ហាក់ដូចជានៅកណ្តាលទីក្រុងវិញ។ យើងបានដឹងថា មាននិស្សិតចំនួន២៥.០០០នាក់ ដែលបានចេញពីសាលាដុនបូស្កូទៅទូទាំងប្រទេសកម្ពុជាពួកគេកំពុងជួយអភិវឌ្ឍន៍ប្រទេសយើងយ៉ាងខ្លាំង។ យើងមានសាលាដុន-បូស្កូនៅកែបដែលកំពុងតែរីកចម្រើន។ ពីមុននៅទីនោះមានអាគារទុកចោលនៅមាត់សមុទ្រ តែឥឡូវលោកបូជាចារ្យសំណាងបានរៀបចំទៅជាកន្លែងមួយដ៏អស្ចារ្យ។ សាលាដុនបូស្កូនៅកំពង់សោមស្ថិតនៅលើដីមួយកន្លែង ដែលកាលពីមុនគ្មានអ្វីទេ តែឥឡូវនេះយើងបានសាងសង់សណ្ឋាគារគម្រូមួយ និងយើងមានសាលារៀនគ្រប់កម្រិត។ កាលពីឆ្នាំ២០០០ ខ្ញុំរស់នៅបាត់ដំបង កាលនោះមានជនជាតិបារាំងពីរនាក់ បានរៀបចំកម្មវិធីអក្ខរកម្មសម្រាប់ក្មេងដែលធ្វើការនៅក្នុងរោងចក្រឡឥដ្ឋ តែពេលនេះនៅបាត់ដំបង យើងមានគ្រប់កម្រិតសិក្សា ហើយមានកន្លែងមួយចំនួនទៀតកំពុងមានសកម្មភាពដោយក្រុមដុនបូស្កូ។

យើងសប្បាយចិត្តដោយបានធ្វើការជាមួយដុនបូស្កូ និងជាពិសេសនៅក្នុងឆ្នាំព្រះមហាករុណាទិគុណនេះ ជាពេលវេលាមួយយ៉ាងល្អឲ្យយើងនឹកដល់គរុកោសល្យយ៉ាងពិសេសរបស់សន្តៈបូស្កូ ដែលអនុវត្តតាមរបៀបព្រះយេស៊ូ គឺណែនាំឲ្យបងប្អូនយើងចូលក្នុងសង្គមបច្ចុប្បន្នយ៉ាងសកម្ម ជាមួយនឹងគុណធម៌ដ៏ពិសេសទៀតផង។ សាលាបានណែនាំឲ្យបងប្អូនយើងមានចិត្តស្រឡាញ់ចិត្តមេត្តាករុណានិងយកចិត្តទុកដាក់ជានិច្ច។សាលាដុនបូស្កូតាមកន្លែងនីមួយៗខិតខំអប់រំសិស្សនិស្សិតឲ្យមានចិត្តស្រឡាញ់ ចិត្តមេត្តាករុណា និងយកចិត្តទុកដាក់ជានិច្ច ទាំងសាលាបានផ្តល់អំណរសប្បាយដល់បងប្អូនយើង ហើយឲ្យបងប្អូនយើងចែកអំណរសប្បាយនោះ ដល់បងប្អូនឯទៀតៗ ឲ្យគេមានអំណរសប្បាយ និងមានសេចក្តីសង្ឃឹមដែរ និងឲ្យបងប្អូនយើងចេះស្វាគមន៍ជានិច្ច គ្រប់បងប្អូនទាំងអស់នេះជារបៀបដែលមកពីព្រះយេស៊ូតែម្តង។

អត្ថបទទីមួយ មានចែងអំពីលោកម៉ូសេ ដែលមានឱកាសយ៉ាងអស្ចារ្យជួបព្រះជាម្ចាស់។ អ្នកណាក៏ចង់ជួបព្រះជាម្ចាស់ដែរ ពេលមានសំណាក់ធម៌នៅភ្នំពេញថ្មីខ្ញុំបាន

សួរក្មួយៗថា**"តើធ្លាប់ឃើញព្រះបិតាឬទេ?"** គេឆ្លើយថាធ្លាប់ឃើញព្រះបិតាដែរ ព្រះអង្គខ្ពស់ណាស់ មានពុកមាត់ពណ៌ខ្មៅ សក់វែង ភ្នែកខ្មៅ...នៅជុំគីរីគេប្រាប់ខ្ញុំថាធ្លាប់ឃើញដែរ។ លោកម៉ូសេមានសំណាងបានជួបជាមួយព្រះជាម្ចាស់ ហើយព្រះអង្គបានប្រាប់ព្រះនាមរបស់ព្រះអង្គថា "យើងជាព្រះអម្ចាស់ ដែលមានព្រះជន្មគង់នៅ"។ ពេលស្តាប់ឮសេចក្តីនេះ ណែនាំឲ្យយើងមានអំណរសប្បាយយ៉ាងខ្លាំង ដោយសារយើងដឹងថា ព្រះជាម្ចាស់មានព្រះជន្មគង់នៅសព្វថ្ងៃ ដែលមានន័យថា **"ព្រះអង្គគង់នៅជាមួយយើង"**។

សន្តៈយ៉ូហានបូស្កូ បានចាប់ផ្តើមកិច្ចការរបស់លោក ជាមួយនឹងយុវជនក្រីក្រខ្លះៗនៅប្រទេសអ៊ីតាលី ក្នុងស.វទី១៩ ជាសម័យដែលចាប់ផ្តើមមានឧស្សាហកម្ម។ នៅពេលនោះលោកយល់ថាពួកគេក្រីក្រមែន តែព្រះជាម្ចាស់ដែលមានព្រះជន្មគង់នៅ ព្រះអង្គស្រឡាញ់គេ ព្រះអង្គសព្វព្រះហឫទ័យឲ្យគេមានជីវិតដ៏បរិបូណ៌។ ជំនឿបែបនេះបានផ្តល់សន្ទុះចិត្តឲ្យលោកចាប់ផ្តើមកិច្ចការ ដែលរហូតដល់សព្វថ្ងៃ មានលោកបូជាចារ្យ បងស្រីដុនបូស្កូជាច្រើនបន្តផ្តល់សក្ខីភាពដល់យុវជនយុវនារី អំពីព្រះជាម្ចាស់ដែលមានព្រះជន្មគង់នៅសព្វថ្ងៃជាមួយយើង។ ព្រះជាម្ចាស់មានព្រះបន្ទូលថា **"យើងបានឃើញទុក្ខលំបាករបស់ប្រជារាស្ត្ររបស់យើង យើងបានឮសម្រែករបស់គេយើងដឹងអំពីទុក្ខវេទនារបស់គេ ដូច្នេះយើងចុះមករំដោះគេឲ្យគេមានសេរីភាព"**។ នេះជារបៀបរបស់ព្រះជាម្ចាស់ គឺព្រះអង្គទតឃើញបញ្ហារបស់យើង ព្រះអង្គស្តាប់ឮពីទុក្ខលំបាករបស់យើង ព្រះអង្គដឹងនិងយល់ចិត្តរបស់យើង ហើយព្រះអង្គយាងចុះមកផ្តល់ជីវិតឲ្យយើង។

នេះជារបៀបដែលព្រះជាម្ចាស់បានធ្វើជាមួយសន្តៈយ៉ូហានបូស្កូ តាមរយៈសាលាដុនបូស្កូដែលបានមកដល់ប្រទេសកម្ពុជានៅជំរុំ ក្នុងឆ្នាំ១៩៨៩ និងតាមរយៈលោកបូជាចារ្យបងប្រុស បងស្រីជាច្រើននាក់។ ដូចគ្នានេះដែរព្រះយេស៊ូបានឃើញទុក្ខលំបាករបស់ប្រជាជននៃប្រទេសកម្ពុជា បានឮសម្រែករបស់ប្រជាជនយើង ដែលគ្មានសាលា គ្មានមន្ទីរពេទ្យ ហើយតាមរយៈព្រះសហគមន៍ យើងក៏បានចុះមក និងចាប់ផ្តើមបំពេញកិច្ចការរហូតដល់បច្ចុប្បន្ន

នេះ ដើម្បីជួយឲ្យយុវជនយុនារីបានទទួលការសិក្សា ឲ្យប្រជាជនក្រីក្រយើងបានទទួលព្យាបាលជំងឺ...។ នេះជារបៀបដែលបងប្អូនទាំងអស់គ្នាក្នុងពេលឥឡូវនេះ ជាសិស្សរបស់សាលាដុនបូស្កូ ដែលនឹងទៅជាអតីតសិស្សនៅពេលអនាគត ត្រូវតែប្រព្រឹត្តតាមគំរូរបស់ព្រះយេស៊ូ កុំធ្វើខ្លួនឲ្យទៅជាមនុស្សបិទភ្នែក តែត្រូវតែបើកភ្នែកដើម្បីមើលឃើញទុក្ខលំបាករបស់ប្រជារាស្ត្ររបស់ព្រះជាម្ចាស់ កុំឲ្យភ្នែកយើងភ្លេច ដោយសារបានឃើញតំបន់មួយចំនួនមានការរីកចម្រើនហើយ។ ឲ្យយើងស្តាប់ឮ គឺឮពីបញ្ហាជាច្រើនដែលមាននៅក្នុងសង្គមរបស់យើង ដូចជាអ្នកគ្មានទីលំនៅ អ្នកគ្មានការងារធ្វើ កុមារដែលមិនបានទទួលការអប់រំ" នេះជារឿងពិតនៃការរស់នៅសព្វថ្ងៃរបស់ប្រជាជនយើង។ ឲ្យយើងដឹងនិងយល់ចិត្តគេដើម្បីមានចិត្តតែមួយជាមួយគេ និងក្រោយមកយើងធ្វើសកម្មភាព។ ប្អូនៗបានទទួលអ្វីៗដ៏ច្រើនពីសាលាដុនបូស្កូ និងនៅពេលប្អូនៗចូលនៅក្នុងសង្គម នោះកុំឲ្យយើងភ្លេចសាលាដុនបូស្កូ សាលាមិនចង់បានការសងគុណពីប្អូនៗទេ តែសាលាចង់ឲ្យប្អូនៗដែលបានទទួលផ្នត់គំនិតថ្មីហើយនោះយកទៅកសាងសង្គមជាសង្គមប្រកបដោយយុត្តិធម៌សេចក្ដីសង្ឃឹម និងសិទ្ធិសេរីភាព។

ពេលយើងនិយាយអំពីសាលាដុនបូស្កូដែលបានមកនៅទីនេះ២៥ឆ្នាំហើយ នោះណែនាំឲ្យយើងនឹកឃើញកាល២០០ឆ្នាំមុន ពេលសាលាដុនបូស្កូកើតដំបូងនៅប្រទេសអ៊ីតាលី។ កាលនោះជាសម័យបដិវត្តឧស្សាហកម្ម ដែលចាប់ផ្តើមមានរោងចក្រយ៉ាងច្រើនសន្ធឹកសន្ធាប់នៅប្រទេសអ៊ីតាលី។ សព្វថ្ងៃរោងចក្រនៅប្រទេសកម្ពុជាយើងដុះដូចផ្សិត មានកម្មករកម្មការិនីរោងចក្រនៅក្នុងប្រទេសប្រមាណ៥% នៃប្រជាជនខ្មែរ និងប្រមាណ៥%ទៀត ធ្វើជាកម្មករនៅក្រៅប្រទេសដែលស្រដៀងគ្នាទៅនឹងសម័យ២០០ឆ្នាំមុននៅប្រទេសអ៊ីតាលី។ហេតុដូច្នេះហើយខ្ញុំសូមឲ្យសាលាដុនបូស្កូទាំងអស់គិតថែមទៀត ជាពិសេសអំពីកម្មករកម្មការិនីដែលបានចោលការសិក្សា តើធ្វើដូចម្តេចដើម្បីជួយឲ្យពួកគេបានទទួលការអប់រំផ្លូវចិត្ត អប់រំអនាម័យ អប់រំអំពីថ្ងៃអនាគតដែលនឹងទៅជាម្តាយ ជាឪពុករបស់គេ។ សូមឲ្យចាប់អារម្មណ៍អំពីក្មេងដែលឪពុកម្តាយគេជាកម្មករសំណង់ ដែលគេគ្មានឱកាសនឹងចូលសាលា និងជួនកាលដោយសារគេមិន

ចង់ទៅសាលាដែរ។ ឲ្យយើងគិតថែមទៀត តើយើងធ្វើដូចម្ដេចដើម្បីឲ្យគេមានវិជ្ជាជីវៈខាងបច្ចេកទេស ដែលសព្វថ្ងៃមានការគាំទ្រពីឯកឧត្តមរដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡាផងដែរ...។

ឆ្នាំនេះជាឆ្នាំមួយឲ្យយើងភ្ញាក់ស្មារតី ឲ្យយើងមានចិត្តសាមគ្គី ចិត្តមេត្តាករុណាដើម្បីបន្តមើលឃើញអ្វីៗទាំងអស់ដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា។ សូមឲ្យយើងទាំងអស់គ្នាសហការគ្នាកាន់តែជិតស្និទ្ធថែមទៀតរវាងសាលាដុនបូស្កូ និងការិយាល័យអប់រំកាតូលិកភូមិភាគភ្នំពេញ។ យើងសហការគ្នាដើម្បីបន្ថែមបច្ចេកទេស ចំណេះដឹង តាមរយៈជួយឲ្យលោកគ្រូអ្នកគ្រូមានសិក្ខាសាលា ពិនិត្យមើលកម្មវិធីសិក្សាក្នុងភូមិភាគរបស់យើង ឲ្យទៅជាគំរូដ៏អស្ចារ្យនៅក្នុងប្រទេសកម្ពុជាយើង។ ភូមិភាគភ្នំពេញយើងក៏មានគណៈកម្មការពលករដែរ តែយើងមានកម្មវិធីតិចតួចនៅឡើយជាមួយកម្មករកម្មការិនីរោងចក្រ ដូច្នេះសូមឲ្យយើងសហការគ្នាតាមឧត្តមគតិរបស់សន្តៈបូស្កូ ដើម្បីយើងបង្កើតជីវិតថ្មីទាំងនៅក្នុងភូមិភាគ ទាំងនៅក្នុងសង្គមខ្មែរទាំងមូល។

ថ្ងៃនេះយើងខ្ញុំទាំងអស់គ្នា សូមអរព្រះគុណព្រះជាម្ចាស់ចំពោះសន្តៈបូស្កូ និងចំពោះលោកអគ្គមហាធិការ **អនជែនហ្វេរណង់ដែស ប៉ាទីមេ** ដែលបានអញ្ជើញមកលើកទឹកចិត្តសាលាដុនបូស្កូ។ សូមអរព្រះគុណព្រះជាម្ចាស់ ដែលពិតមែនយើងជាព្រះសហគមន៍តែមួយរបស់ព្រះយេស៊ូគ្រីស្ត សូមឲ្យយើងអធិដ្ឋានសម្រាប់គ្នាទៅវិញទៅមក ឲ្យយើងមានអំណរសប្បាយគ្រប់ពេលវេលា ឲ្យយើងចេះស្វាគមន៍គ្នាទៅវិញទៅមក ដោយមើលឃើញ ស្ដាប់ឮ និងយល់ដឹងពីគ្នាដោយមានចិត្តតែមួយ និងឲ្យយើងចេញទៅណែនាំឲ្យអ្នកដែលអស់សង្ឃឹម រកឃើញសេចក្ដីសង្ឃឹមវិញ។ សូមព្រះជាម្ចាស់ប្រទានពរឲ្យបងប្អូនទាំងអស់ ឲ្យយើងបន្តអរព្រះគុណព្រះអង្គសម្រាប់អ្វីៗទាំងអស់ដែលយើងបានសាបព្រោះ និងដែលបានបង្កើតផលផ្លែជាក់ស្ដែង ពិតមែនយើងសូមអរព្រះគុណព្រះជាម្ចាស់។

# កុំឲ្យយើងធ្វើជាមនុស្សខ្មាស់អៀនមិនហ៊ាន ទទួលស្គាល់ព្រះយេស៊ូ

Let us not be ashamed to proclaim our God

អត្ថបទទី១៖ យរ ១១, ១៨-២០
ដំណឹងល្អ ៖ យហ ៧, ៤០-៥៣

ថ្ងៃនេះយើងមានគ្នាយ៉ាងច្រើនកុះករ មកដើម្បីអរព្រះគុណព្រះជាម្ចាស់ក្នុងរដូវ ៤០ថ្ងៃ ដែលជាឱកាសមួយយ៉ាងអស្ចារ្យដើម្បីនឹករឭកដល់ធម៌មេត្តាករុណារបស់ព្រះអង្គចំពោះយើង។ ថ្ងៃនេះយើងមានកូនៗ ៤០នាក់ទទួលព្រះកាយព្រះគ្រីស្តលើកដំបូង ជាពេលវេលាមួយយ៉ាងពិសេសដែលកូនៗទទួលព្រះយេស៊ូយាងចូលនៅក្នុងខ្លួនរបស់គេ។ ថ្ងៃនេះដែរយើងបានស្ដាប់ព្រះបន្ទូលមួយដែលបានណែនាំឲ្យយើងភ្ញាក់ស្មារតីទាំងអស់គ្នាគឺ **"នៅទីនេះមានមនុស្សខ្លះគេនឹងស្លាប់ និងមានមនុស្សខ្លះទៀតគេមិនស្លាប់ទេមុនបានឃើញព្រះរាជ្យរបស់ព្រះជាម្ចាស់"**។ ដូច្នេះតើយើងចង់មើលឃើញព្រះរាជ្យរបស់ព្រះជាម្ចាស់ឬទេ? តើធ្វើដូចម្ដេចដើម្បីយើងមើលឃើញព្រះរាជ្យរបស់ព្រះជាម្ចាស់លើផែនដីនេះ?

ថ្ងៃនេះ ព្រះយេស៊ូបានពន្យល់យើងពីរបៀបដើម្បីមើលឃើញព្រះរាជ្យរបស់ព្រះជាម្ចាស់នៅលើផែនដីនេះ។ ព្រះរាជ្យរបស់ព្រះជាម្ចាស់គឺស្ថិតនៅលើយើងម្នាក់ៗដែលជាតំណាងរបស់ព្រះជាម្ចាស់ គឺយើងម្នាក់ៗដែលកំពុងកសាងព្រះរាជ្យរបស់ព្រះអង្គបន្តិចម្ដងៗជារៀងរាល់ថ្ងៃ គឺចាប់ពីថ្ងៃដែលយើងបានទទួលអគ្គសញ្ញាជ្រមុជទឹក ជាពេលដែលយើងមានសមត្ថភាពក្នុងការកសាងព្រះរាជ្យរបស់ព្រះអង្គគឺ៖

---

ពិធីសម្ពោធចេតិយ លោកបូជាចារ្យ ប៊ួយៀប នៅផ្លូវត្រី
ថ្ងៃទី ១២ មិនា ២០១៦

១/ យើងមិនត្រូវធ្វើខ្លួនជាមនុស្សដែលខ្មាសអៀនមិនហ៊ានទទួលស្គាល់ព្រះយេស៊ូនោះទេ។ ព្រះយេស៊ូមានព្រះបន្ទូលថា **"ប្រសិនបើអ្នកណាខ្មាស់មិនហ៊ានទទួលស្គាល់ខ្ញុំ នៅពេលក្រោយខ្ញុំក៏មិនទទួលស្គាល់វិញដែរ"**។ ដូច្នេះតើយើងត្រូវធ្វើដូចម្ដេចដើម្បីធ្វើជាសាក្សីជាក់ស្ដែងអំពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ នៅលើទឹកដីដែលយើងកំពុងរស់នៅនេះ?។ ជិតដល់ថ្ងៃដែលព្រះយេស៊ូរងទុក្ខលំបាក គ្រីស្ដទូតដែលនៅជិតស្និទ្ធជាមួយព្រះអង្គ ក៏បានលះបង់ចោលព្រះអង្គ។ ជាពិសេសលោកសិលាបានបដិសេធមិនស្គាល់ព្រះយេស៊ូបីដង មុនមាន់រងាវ។

ថ្ងៃនេះសូមព្រះជាម្ចាស់ជួយយើងខ្ញុំឲ្យមានចិត្តក្លាហាន មិនអៀនខ្មាស់នឹងរស់នៅក្នុងរបៀបជាគ្រីស្ដបរិស័ទដែលចេះស្រឡាញ់ ចេះលើកលែងទោស និងចេះបង្កើតទំនាក់ទំនងជាមួយមនុស្សទាំងឡាយ ។ ចំពោះកូនៗដែលនឹងទទួលព្រះកាយព្រះគ្រីស្ដលើកទីមួយនៅថ្ងៃនេះ សូមឲ្យកូនៗមានចិត្តក្លាហានមួយយ៉ាងពិសេស ដោយសារព្រះយេស៊ូយាងមកគង់នៅក្នុងខ្លួនកូនៗ។ ចំពោះយើងជាគ្រីស្ដបរិស័ទ ទាំងអស់គ្នានៅពេលយើងទទួលព្រះកាយព្រះគ្រីស្ដ នោះសូមឲ្យយើងទទួលនូវចិត្តក្លាហានមួយ ហ៊ានប្រកាសយ៉ាងពិសេសនៅក្នុងទឹកដីរបស់យើងដែលមានពុទ្ធបរិស័ទជាច្រើន ដែលគេមិនស្គាល់ព្រះយេស៊ូសោះថា **"ខ្ញុំជាសាវ័ករបស់ព្រះយេស៊ូ"**។ ដូច្នេះនៅក្នុងភូមិនីមួយៗយើងត្រូវមានចិត្តក្លាហានបង្ហាញថា យើងជាគ្រីស្ដបរិស័ទដែលចេះស្រឡាញ់ដែលចេះលើកលែងទោស និងដែលចេះបង្កើតទំនាក់ទំនងជាមួយមនុស្សទាំងអស់។

ថ្ងៃនេះយើងមានគំរូមួយ គឺលោកបូជាចារ្យប៊ួយៀប ហើយយើងក៏នឹកឃើញដល់មរណសាក្សីទាំងអស់នៅក្នុងប្រទេសកម្ពុជា និងនៅប្រទេសវៀតណាមដែរ ដែលអស់លោកសុខចិត្តថ្វាយជីវិតដោយចិត្តក្លាហាន បង្ហាញថាពិតមែនខ្ញុំជាគ្រីស្ដបរិស័ទ ខ្ញុំស្រឡាញ់ព្រះយេស៊ូខ្លាំងណាស់ ខ្ញុំមិនខ្លាចនឹងលះបង់ជីវិតដោយនាមព្រះយេស៊ូនោះទេ។

២/ ព្រះយេស៊ូណែនាំឲ្យយើងលះបង់ខ្លួនដើម្បីទទួលជីវិត **"ប្រសិនបើអ្នកបានទ្រព្យសម្បត្តិទាំងអស់ក្នុងពិភពលោកទាំងមូលហើយត្រូវបាត់ជីវិតតើមានប្រយោជន៍អ្វី?"**។ ទស្សនៈ

នេះផ្ទុយនឹងទស្សនៈរបស់មនុស្សយើងដែលចេះតែចង់បានគ្មានទីបញ្ចប់ ដូចជាថ្ងៃនេះជាដើម ដែលយើងជឿថាលោកឪពុកប៊ូយៀប នឹងជួយឲ្យយើងរកស៊ីមានបាន។ សេចក្តីនេះមិនសំខាន់ជាងព្រះបន្ទូលរបស់ព្រះយេស៊ូដែលសូមឲ្យយើងលះបង់និងបន្ទាបខ្លួននោះទេ។ ពេលយើងទទួលបានច្រើននោះយើងក៏ត្រូវការលះបង់ច្រើនវិញដែរ ដើម្បីជួយដល់បងប្អូនឯទៀតៗដែលកំពុងរងទុក្ខលំបាក។ យើងរកស៊ីបាននោះយើងគឺជាមនុស្សដែលទទួលជោគជ័យ ប៉ុន្តែយើងក៏ជាអ្នកដែលត្រូវតែបើកភ្នែកឲ្យធំៗ ដើម្បីមើលឃើញទុក្ខលំបាករបស់បងប្អូនឯទៀតៗដែលរស់នៅជុំវិញយើង។

ព្រះយេស៊ូសូមឲ្យយើងបើកចិត្តឲ្យទូលាយ មានសេចក្តីស្រឡាញ់យ៉ាងបរិបូណ៌មកពីព្រះជាម្ចាស់ ដែលយើងត្រូវអនុវត្តតាមរូបកាយ និងតាមវិញ្ញាណដើម្បីឲ្យព្រះរាជ្យរបស់ព្រះជា-ម្ចាស់យាងមកយ៉ាងពិតប្រាកដដោយ ទីមួយសូមឲ្យយើងមានចិត្តក្លាហានប្រកាសដំណឹងល្អតាមការរស់នៅរបស់យើង និង ទីពីរ សូមឲ្យយើងដែលជាអ្នកមានទ្រព្យសម្បត្តិគ្រប់គ្រាន់យកចិត្តទុកដាក់ចែករំលែកជាមួយបងប្អូនឯទៀតៗ ដើម្បីឲ្យធម៌មេត្តាករុណារបស់ព្រះជាម្ចាស់បានទៅដល់គ្រប់ទីកន្លែង ដើម្បីបង្ហាញថាពិតមែនព្រះរាជ្យរបស់ព្រះជាម្ចាស់កំពុងយាងមក។

សរុបសេចក្តីមក ជីវិតរបស់យើងជាគ្រីស្តបរិស័ទក្នុងឆ្នាំព្រះមហាករុណាទិគុណនេះ គឺយើងរួមគ្នាបំផ្លាញការស្អប់ខ្ពើមគ្នា បំផ្លាញអ្វីៗដែលរាំងផ្លូវរបស់យើងដើម្បីយើងទទួលស្គាល់វត្តមានរបស់ព្រះជាម្ចាស់នៅក្នុងជីវិតរបស់យើង ដើម្បីយើងទៅជាប្រជារាស្ត្ររបស់ព្រះជាម្ចាស់ ដើម្បីយើងប្រកាសថាពិតមែនព្រះជាម្ចាស់ជាសេចក្តីស្រឡាញ់ ហើយយើងក៏ស្រឡាញ់គ្នាទៅវិញទៅមកដោយបង្កើតព្រះសហគមន៍ថ្មី និងដោយបង្កើតពិភពលោកថ្មី។

ក្នុងភូមិភាគភ្នំពេញយើងមានពីរកន្លែងដែលពិសេសណាស់ គឺផ្លូវត្រីដែលមានលោកឪពុកប៊ូយៀប និងនៅអរិយក្សត្រដែលមានព្រះនាងម៉ារីជាកន្លែងដែលយើងទទួលព្រះអំណោយទានដ៏ថ្លៃថ្លាពីព្រះជាម្ចាស់។ ដូច្នេះសូមបងប្អូនគ្រីស្តបរិស័ទដែលរស់នៅទាំងពីរកន្លែងនេះ

យកចិត្តទុកដាក់ថែរក្សាព្រះអំណោយទាននេះកុំបីធ្វេសប្រហែសឡើយ ដោយសូមបងប្អូនយកចិត្តទុកដាក់ទទួលស្វាគមន៍គ្រប់ពេលវេលាដល់បងប្អូនទាំងអស់ ដល់ភ្ញៀវទាំងឡាយដែលមកទីនេះ។

សូមបងប្អូនដែលអញ្ជើញមកពីគ្រប់ទីកន្លែងទាំងអស់ កុំខ្លាចនឹងចេញចូលនៅផ្លូវត្រីនេះក៏ដូចជានៅអរិយក្សត្រដែរ ដើម្បីទទួលជំនឿថ្មី ជីវិតថ្មី សេចក្តីស្រឡាញ់ថ្មី តាមរយៈលោកប៊ួយៀប និងតាមរយៈព្រះនាងម៉ារីគ្រប់ពេលវេលា។

**"ប្រសិនបើអ្នកណាខ្មាស់មិនហ៊ានទទួលស្គាល់ខ្ញុំ នៅពេលក្រោយខ្ញុំក៏មិនទទួលស្គាល់វិញដែរ"។**

# យើងត្រូវលើកលែងទោសឲ្យអ្នក
# ដែលបានធ្វើខុសដល់យើង

Forgive those who trespass against us

---

អត្ថបទទី១៖ អស ៤៣, ១៦-២១
អត្ថបទទី២៖ ភីល ៣, ៨-១៤
ដំណឹងល្អ៖ យហ ៧, ៤០-៥៣

ថ្ងៃនេះព្រះសហគមន៍ឲ្យយើងសម្លឹងមើលម្ដងទៀត អំពីរបៀបដែលព្រះជាម្ចាស់ដែលជាព្រះបិតាស្រឡាញ់យើង។ យើងនឹកដល់ព្រះបន្ទូលដែលយើងស្ដាប់អំបាញ់មិញ គឺព្រះយេស៊ូយាងទៅភ្នំដើមអូលីវ ដែលមានន័យថាព្រះអង្គយាងទៅរៀបចំព្រះកាយដើម្បីសោយទិវង្គត។ នៅទីនោះព្រះអង្គអធិដ្ឋានចុងក្រោយដើម្បីជិតស្និទ្ធជាមួយព្រះបិតារបស់ព្រះអង្គថែមទៀត ដើម្បីទទួលព្រះហឫទ័យប្រណីសន្ដោសពីបិតារបស់ព្រះអង្គឲ្យបានពោរពេញថែមទៀតដែរ។ ក្រោយមកព្រះអង្គយាងទៅក្នុងវិហារម្ដងទៀត ដែលពេលនោះពួកផារីស៊ីរកចាប់កំហុសព្រះអង្គ ក្នុងករណីដែលស្ត្រីម្នាក់បានប្រព្រឹត្តខុសនឹងធម្មវិន័យ ជាពិសេសគេចង់ដាក់កំហុសថាព្រះយេស៊ូមិនគោរពតាមធម្មវិន័យរបស់លោកម៉ូសេ។

ថ្ងៃនេះឲ្យយើងចាប់អារម្មណ៍ពីរបៀបដែលព្រះយេស៊ូប្រឈមនឹងអ្នកដែលគេរករឿងចាប់កំហុសព្រះអង្គដែលគេចង់បង្កើតសង្គ្រាមជាមួយព្រះអង្គ គឺជាដំបូងព្រះអង្គស្ដាប់គេដោយស្ងៀមស្ងាត់ ព្រះអង្គមិនឆ្លើយតបនឹងគេភ្លាមទេ ដែលនាំឲ្យមានជម្លោះរវាងគ្នាទៅវិញទៅមក។ បន្ទាប់មកព្រះយេស៊ូឱនព្រះកាយចុះហើយយកព្រះអង្គុលីគូសលើដីរួចហើយ ព្រះយេស៊ូសួរទៅគេថា **"ក្នុងចំណោមអ្នករាល់គ្នា សូមឲ្យអ្នកដែលគ្មានបាបសោះយកដុំថ្មគប់នាងមុនគេទៅ!"** និងព្រះ

---

អភិបូជានៅព្រះសហគមន៍បឹងឈូក
ថ្ងៃទី១៣ មិនា ២០១៦

អង្គបន្តគូសលើដីតទៅទៀតដោយស្ងៀមស្ងាត់ដែលធ្វើឲ្យគេធូល់គ្រប់គ្នា និងចុងក្រោយបង្អស់នៅសល់តែព្រះយេស៊ូនិងស្ត្រីមានបាបនោះប៉ុណ្ណោះ ហើយពេលនោះព្រះយេស៊ូមានព្រះបន្ទូលទៅនាងថា **"ខ្ញុំក៏មិនដាក់ទោសនាងដែរ សូមអញ្ជើញទៅចុះ តែចាប់ពីពេលនេះតទៅកុំប្រព្រឹត្តអំពើបាបទៀតឡើយ"**។

អត្ថបទថ្ងៃនេះ ណែនាំឲ្យយើងឃើញព្រះបិតា ដោយយើងសម្លឹងមើលព្រះយេស៊ូ ទីមួយ **ព្រះយេស៊ូអធិដ្ឋានដើម្បីទៅជាធ្លុងមួយជាមួយព្រះបិតា** ដើម្បីបង្កើតទំនាក់ទំនងជាមួយព្រះបិតាយ៉ាងជិតស្និទ្ធ។ ទីពីរ **ព្រះយេស៊ូមានព្រះហឫទ័យស្លូតបូត** ទោះបីគេបង្កើតទំនាស់ជាមួយព្រះអង្គ ក៏ព្រះអង្គមិនឆ្លើយតបភ្លាមៗ ដោយព្រះអង្គឈ្វេងយល់ថាអ្វីដែលគេនិយាយគ្មានប្រយោជន៍។ ទីបី **ព្រះយេស៊ូមិនវិនិច្ឆ័យ** ស្ត្រីនោះទេថែមទាំងដោះលែងនាងដោយសូមអញ្ជើញនាងឲ្យទៅចុះ ហើយព្រះអង្គអប់រំនាងឲ្យឈប់ប្រព្រឹត្តអំពើបាបតទៅទៀត។ ព្រឹត្តិការណ៍នេះណែនាំឲ្យយើងនឹកឃើញដល់ការរស់នៅរបស់យើងគឺ ទីមួយ ឲ្យយើងជិតស្និទ្ធជាមួយព្រះជាម្ចាស់ជាមួយព្រះយេស៊ូដោយយើងចូលរួមថ្វាយអភិបូជាដោយយើងស្តាប់ព្រះបន្ទូលដោយយើងទទួលព្រះកាយព្រះគ្រីស្តយើងទៅជាធ្លុងតែមួយជាមួយព្រះជាម្ចាស់ ។ ចំពោះកូនៗដែលនឹងទទួលព្រះកាយព្រះគ្រីស្តលើកទីមួយនៅថ្ងៃនេះ ទៅជាធ្លុងតែមួយជាមួយព្រះយេស៊ូពិតមែនដោយកូនៗទទួលព្រះកាយព្រះគ្រីស្ត គឺព្រះយេស៊ូផ្ទាល់យាងចូលនៅក្នុងខ្លួនកូនៗ។ ទីពីរ ឲ្យយើងបង្កើតទំនាក់ទំនងជាមួយអ្នកដែលមកឈ្លោះជាមួយយើង ដែលនិយាយមិនល្អអំពីយើង គឺឲ្យយើងធ្វើដូចព្រះយេស៊ូដែលមិនតបហើយនៅស្ងៀមស្ងាត់។ យើងដឹងថា ពួកបូជាចារ្យ និងគណៈផារីស៊ីស្អប់ព្រះយេស៊ូខ្លាំងណាស់ ប៉ុន្តែនៅពេលព្រះយេស៊ូនៅស្ងៀមស្ងាត់ នោះណែនាំឲ្យពួកគេថយកំហឹង និងថយការស្អប់ខ្ពើមដែរ។ ព្រះយេស៊ូនៅស្ងៀមស្ងាត់បាន ដោយសារព្រះអង្គមានព្រះហឫទ័យមេត្តាករុណាដែលមកពីព្រះបិតា។ ទីបី ព្រះយេស៊ូមិនវិនិច្ឆ័យស្ត្រីដែលប្រព្រឹត្តអំពើបាបនោះទេ ព្រះអង្គចាប់អារម្មណ៍នឹងនាង ព្រះអង្គបន្តនៅជាមួយនាងស្វាគមន៍នាង ហើយព្រះអង្គលើកលែងទោសនាងទាំងមានព្រះបន្ទូលបន្ថែមថា **"កុំប្រព្រឹត្តអំពើ**

**បាបទៀតឡើយ"**។ ពេលស្ត្រីនោះបានឃើញរបៀបដែលព្រះយេស៊ូធ្វើចំពោះខ្លួន នោះខ្ញុំជឿថា ពេលនោះ ព្រះបន្ទូលទាំងប៉ុន្មានដែលព្រះយេស៊ូមានចំពោះនាង បានចូលជ្រួតជ្រាបពេញខ្លួនប្រាណរបស់នាង ផ្លាស់ប្រែចិត្តគំនិតនាងទៅជាមនុស្សថ្មី។ ដូចព្រះយេស៊ូដែរ ក្នុងការរស់នៅរបស់យើង គឺតាមកិច្ចការខាងវិញ្ញាណនោះយើងត្រូវមានស្មារតីលើកលែងទោស និង ចែករំលែកជីវិតដែលយើងបានទទួលពីព្រះជាម្ចាស់ ដល់អស់អ្នកដែលបានប្រព្រឹត្តខុសដែរដើម្បីឲ្យគេភ្ញាក់ស្មារតីជាថ្មីឲ្យគេ ទទួលជីវិតថ្មីតាមព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់ដូចអ្វីដែលយើងបានស្តាប់ក្នុងអត្ថបទទីពីរ **"ខ្ញុំមិនមែនសុចរិតដោយសារធម្មវិន័យ តែដោយសារជំនឿលើព្រះយេស៊ូ"**។

យើងជាគ្រីស្តបរិស័ទដែលមានជំនឿលើព្រះយេស៊ូ នោះណែនាំឲ្យយើងទៅជាមនុស្សសុចរិតដូចព្រះយេស៊ូដែរ។ មនុស្សសុចរិត មានន័យថាជាមនុស្សដែលមានចិត្តទៀងត្រង់ដែលចេះស្រឡាញ់ ដែលចេះលើកលែងទោសឲ្យគេ ដូចព្រះយេស៊ូដែលជាមនុស្សសុចរិតដល់កំពូល។ ហេតុដូច្នោះហើយ សម្រាប់យើងជាគ្រីស្តបរិស័ទ ដែលកំពុងធ្វើដំណើរក្នុងរដូវ៤០ថ្ងៃនៃឆ្នាំព្រះមហាករុណាទិគុណនេះ សូមឲ្យយើងប្រព្រឹត្តដូចព្រះបន្ទូលរបស់ព្រះយេស៊ូថា **"ខ្ញុំមិនដាក់ទោសអ្នកទេ សូមអ្នកអញ្ជើញទៅចុះតែចាប់ពីពេលនេះតទៅសូមអ្នកកុំប្រព្រឹត្តអំពើបាបទៀតឡើយ"**។

សូមអរព្រះគុណព្រះជាម្ចាស់ ដែលណែនាំបន្តិចម្តងៗឲ្យយើងខ្ញុំស្គាល់របៀបដែលព្រះបិតាស្រឡាញ់យើង របៀបដែលព្រះបិតាលើកលែងទោសឲ្យយើង របៀបដែលព្រះបិតាណែនាំឲ្យយើងមានជីវិតសាជាថ្មី កម្លាំងសាជាថ្មី ដើម្បីឲ្យយើងខ្ញុំយកទៅចែករំលែកជាមួយបងប្អូនឯទៀតៗ។ សម្រាប់កូនៗដែលទើបទទួលព្រះកាយព្រះគ្រីស្តលើកទីមួយនៅថ្ងៃនេះ ឲ្យដឹងដាក់ក្នុងចិត្តថារាល់ថ្ងៃអាទិត្យកូនៗត្រូវមកព្រះវិហារ ស្តាប់ព្រះបន្ទូល ទទួលព្រះកាយ ដើម្បីឲ្យកូនៗពោរពេញដោយសេចក្តីស្រឡាញ់របស់ព្រះយេស៊ូ និងឲ្យកូនៗចែករំលែកសេចក្តីស្រឡាញ់នោះជាមួយបងប្អូនឯទៀតៗផង។

# យើងជាអ្នកមានបាប ដែលបានទទួលការលើកលែងទោសពីព្រះជាម្ចាស់

We are forgiven sinners

---

អត្ថបទទី១៖ ដន ៣, ១៤-២០. ៩១-៩២.៩៥
អត្ថបទទី២៖ ដន ៣
ដំណឹងល្អ៖ យហ ៨, ៣១-៤២

ថ្ងៃនេះ ជាថ្ងៃពិសេសសម្រាប់លោកបូជាចារ្យទាំងអស់ ដោយសារជារៀងរាល់ឆ្នាំក្នុងអភិបូជាធ្វើព្រះពរលើប្រេង គឺជាឱកាសមួយឲ្យយើងជាបូជាចារ្យអរព្រះគុណព្រះជាម្ចាស់។ ឆ្នាំនេះជាឆ្នាំព្រះមហាករុណាទិគុណ ក្នុងឱកាសនេះខ្ញុំចង់បន្តសន្ទនារិះគិតពីជីវិតរបស់យើងជាបូជា-ចារ្យដែលបម្រើបងប្អូន ហើយថ្ងៃនេះមានបងប្អូនអញ្ជើញមកជាច្រើន ដើម្បីបង្ហាញសេចក្ដីស្រឡាញ់របស់បងប្អូនចំពោះព្រះជាម្ចាស់ និងចំពោះយើងដែលជាគង្វាលរបស់ពួកគាត់។ ឆ្នាំនេះ យើងមានពាក្យស្លោក "**ចូរមានចិត្ត មេត្តាករុណាដូចព្រះបិតាមានព្រះហឫទ័យមេត្តាករុណា**" សម្រាប់ណែនាំយើង។ សម្រាប់យើងជាបូជាចារ្យ រាល់ពេលភ្ញាក់ពីដំណេក ប្រសិនបើយើងអធិដ្ឋានសូមព្រះជាម្ចាស់ប្រោសឲ្យថ្ងៃនេះយើងមានចិត្តមេត្តាករុណាដូចព្រះបិតា នោះពិតជាយើងនឹងមានកម្លាំងពេញមួយថ្ងៃ។

សម្ដេចប៉ាបយ៉ូហានប៉ូលទីពីរ ធ្លាប់សរសេរសារលិខិតសម្រាប់បូជាចារ្យទាំងអស់នៅឆ្នាំ ២០០១ ថា បូជាចារ្យជាឧបករណ៍យ៉ាងពិសេសដើម្បីសម្ដែងព្រះហឫទ័យមេត្តាករុណារបស់ព្រះជាម្ចាស់។ ព្រះជាម្ចាស់បានជ្រើសរើសយើងជាមនុស្សបាប ឲ្យធ្វើជាព្រះភ័ក្ត្រនៃព្រះហឫទ័យស្រឡាញ់របស់ព្រះអង្គចំពោះមនុស្សលោក។ ដូច្នេះថ្ងៃនេះ មុនដំបូងបង្អស់ខ្ញុំសូមឲ្យយើងច្រៀង

---

អភិបូជាប្រសិទ្ធិពរលើប្រេងនៅភ្នំពេញថ្មី
ថ្ងៃទី១៦ មិនា ២០១៦

តាមទំនុកតម្កើងលេខ៥១ថា៖ **"ឱព្រះអម្ចាស់អើយ! សូមប្រណីសន្ដោសទូលបង្គំផង ដ្បិតព្រះ-អង្គមានព្រះហឫទ័យមេត្តាករុណាដ៏លើសលុប សូមលើកលែងទោសឲ្យទូលបង្គំផង ដ្បិតព្រះអង្គមានព្រះហឫទ័យអាណិតមេត្តាដ៏ទូលំទូលាយ សូមលុបលាងកំហុសទូលបង្គំឲ្យបានស្អាតទាំងស្រុង សូមជម្រះទូលបង្គំឲ្យបានបរិសុទ្ធផង!"។**

ពិតមែនយើងម្នាក់ៗ យើងមានបទពិសោធជាក់ស្ដែងអំពីព្រះហឫទ័យមេត្តាករុណារបស់ព្រះជាម្ចាស់ចំពោះយើង ដែលព្រះអង្គបានត្រាស់ហៅយើងទៅជាបូជាចារ្យ ដែលបានចាត់ឲ្យយើងទៅប្រកាសដំណឹងល្អ។ ពិតមែនយើងមានបាប ប៉ុន្តែជាអ្នកមានបាបដែលបានទទួលការលើកលែងទោសពីព្រះជាម្ចាស់ហើយ។ ហេតុនេះហើយរួមជាមួយព្រះនាងម៉ារី យើងសូមកោត-សរសើរព្រះជាម្ចាស់ទាំងមានចិត្តអំណរសប្បាយ ដោយយើងដឹងថាព្រះជាម្ចាស់បានជ្រើសរើសយើងព្រះអង្គស្រឡាញ់យើង និងព្រះអង្គណែនាំឲ្យយើងទៅជាសាក្សីជាក់ស្ដែងអំពីព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះអង្គ។ ដោយសារព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់ នោះអ្នកមានបាបដែលបានទទួលការលើកលែងទោស នឹងទៅជាសញ្ញាសម្គាល់នៃព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះអង្គនៅលើផែនដីនេះ និងជាពិសេសនៅលើទឹកដីនៃប្រទេសកម្ពុជាយើង។

ឆ្នាំនេះជាឆ្នាំព្រះមហាករុណាទិគុណ យើងជាបូជាចារ្យត្រូវតែសម្លឹងមើលព្រះយេស៊ូគ្រីស្ដដែលជាព្រះភ័ក្ត្ររបស់ព្រះបិតាលើផែនដីនេះ។ ពេលយើងសម្លឹងមើលព្រះយេស៊ូបន្តិចម្ដងៗ យើងនឹងជាប់ចិត្តជាមួយព្រះយេស៊ូថែមទៀត ហើយយើងនឹងដូចព្រះយេស៊ូ ហើយយើងនឹងចេញទៅរកបងប្អូនឯទៀតៗទាំងអស់ដើម្បីសម្ដែងព្រះហឫទ័យមេត្តាករុណារបស់ព្រះបិតាដូចព្រះយេស៊ូដែរ។ ពេលយើងមើលក្នុងឡូហ្គូឆ្នាំព្រះមហាករុណាទិគុណ នោះយើងបានឃើញព្រះយេស៊ូកំពុងលីមនុស្សម្នាក់ដែលហាក់បីដូចជាព្រះបិតា សូមឲ្យយើងទាំងអស់គ្នាលីទុក្ខលំបាករបស់មនុស្សទាំងអស់ ឲ្យយើងទៅជាផ្លូងតែមួយជាមួយអ្នកឯទៀតៗដែលមានរបួស គឺឲ្យយើងដូចព្រះគ្រីស្ដដែលស្រឡាញ់យើង ដែលមិនវិនិច្ឆ័យយើង ប៉ុន្តែព្រះអង្គណែនាំឲ្យមនុស្សយើងងើបឈរឡើងជាថ្មី ដោយមានព្រះបន្ទូលលើកទឹកចិត្តថា **"ចូរទៅចុះជំនឿរបស់អ្នកបានសង្គ្រោះ**

**អ្នកហើយ! ចូរទៅចុះ ហើយឈប់ប្រព្រឹត្តអំពើបាបទៀត ខ្ញុំលើកលែងទោសឲ្យកូនដោយនាមព្រះបិតាព្រះបុត្រានិងព្រះវិញ្ញាណដ៏វិសុទ្ធ"**។ ដែលសូមឲ្យកែវភ្នែករបស់យើងទៅជាសញ្ញាសម្គាល់នៃព្រះហឫទ័យស្រឡាញ់របស់ព្រះបិតាដល់បងប្អូនឯទៀត ដែលកំពុងជួបទុក្ខលំបាក ដែលកំពុងតែវង្វេង និងអស់សង្ឃឹមនៅក្នុងជីវិត ហើយមករកជួបយើង និងដើម្បីទទួលការលើកលែងទោសពីយើងដោយនាមព្រះបិតា។

តាមគម្ពីរដំណឹងល្អរបស់សន្តៈលូកាយើងឃើញថា ព្រះយេស៊ូបានយាងទៅសួរសុខទុក្ខអ្នកភូមិ និងព្រះអង្គបានអប់រំគេអធិដ្ឋានជាមួយគេ និងព្រះអង្គបានបង្ហាញព្រះភក្រ្តរបស់ព្រះ-បិតាដល់ប្រជាជន ដែលរស់នៅស្រុកប៉ាឡេស្ទីននៅសម័យនោះ។ សព្វថ្ងៃព្រះយេស៊ូក៏សូមឲ្យយើងធ្វើដំណើរចេញទៅសួរសុខទុក្ខបងប្អូនឯទៀតៗដែរ ដើម្បីយកពេលបង្ហាញព្រះភ័ក្រ្តព្រះបិតាដល់អស់បងប្អូនឯទៀតៗដែលមិនទាន់ស្គាល់ព្រះយេស៊ូ។ អ្វីៗទាំងអស់បានចាប់ផ្តើមនៅពេលដែលព្រះយេស៊ូយាងចេញពីភូមិណាសារ៉ែតទៅប្រកាសថា **"ចូរប្រែចិត្តគំនិតហើយជឿលើដំណឹងល្អចុះ ដ្បិតព្រះរាជ្យព្រះជាម្ចាស់យាងមកជិតបង្កើយហើយ"** និងនៅពេលដែលព្រះ-អង្គប្រកាសនៅធម្មសាលាថា **"ព្រះវិញ្ញាណរបស់ព្រះអម្ចាស់បានសណ្ឋិតលើខ្ញុំ ព្រះអង្គបានចាក់ប្រេងអភិសេកខ្ញុំឲ្យនាំដំណឹងល្អ ទៅប្រាប់ជនក្រីក្រ និងឲ្យខ្ញុំប្រកាសប្រាប់ជនជាប់ជាឈ្លើយថាគេនឹងមានសេរីភាព ព្រមទាំងប្រកាសអំពីឆ្នាំដែលព្រះអម្ចាស់សម្តែងព្រះហឫទ័យមេត្តាករុណា..."**។

ព្រះយេស៊ូបានយាងពីភូមិមួយ ទៅភូមិមួយទៀត។ ថ្ងៃមួយព្រះយេស៊ូបានជួបស្រ្តីមេម៉ាយម្នាក់ដែលប្តីស្លាប់ពីប៉ុន្មានឆ្នាំមុន កំពុងយំសោកដោយសារកូនប្រុសរបស់គាត់ស្លាប់។ ព្រះយេស៊ូអាណិតគាត់ខ្លាំងណាស់ហើយព្រះអង្គមានព្រះបន្ទូលទៅគាត់ថា **"កុំយំធ្វើអ្វីនាងអើយ"** បន្ទាប់មកព្រះអង្គយាងទៅជិតមឈូសហើយមានព្រះបន្ទូលថា **"ក្រោកឡើងអ្នកកំឡោះអើយ"** ភ្លាមនោះកូនប្រុសរបស់គាត់បានរស់ឡើងវិញ...និងពេលបន្ទាប់ ព្រះយេស៊ូបានយាងទៅរួមតុអាហារជាមួយគណៈផារីស៊ី។...មានថ្ងៃមួយនោះ មានស្រ្តីមានបាបម្នាក់បានមកជួបព្រះយេស៊ូ នាងយំខ្លាំងណាស់ដោយសារនាងនឹកឃើញពីអំពើបាបរបស់ខ្លួន និងដោយសារនាងបានឃើញថាព្រះ

យេស៊ូមានព្រះហឫទ័យប្រណីសន្ដោសខ្លាំងណាស់ចំពោះនាង ព្រះអង្គមិនរើសអើងនាងដូចមនុស្សឯទៀតៗទេ។ នាងបានសម្រក់ទឹកភ្នែកលើព្រះបាទារបស់ព្រះអង្គហើយយកសក់របស់នាងមកជូតសម្អាត ទាំងលាបប្រេងក្រអូបលើព្រះបាទាផង។ នេះបញ្ជាក់ថា នាងបានទទួលបទពិសោធន៍នៃសេចក្ដីស្រឡាញ់ដោយផ្ទាល់ពីព្រះយេស៊ូ។ ព្រះយេស៊ូស្វាគមន៍នាងហើយមានព្រះបន្ទូលទៅនាងថា **"សូមទៅចុះ ជំនឿរបស់នាងបានសង្គ្រោះនាងហើយ"**។ ព្រះយេស៊ូក៏ធ្លាប់មានព្រះបន្ទូលជាប្រស្នា អំពីបុរសសាសន៍សាម៉ារីដែលបានជួយថែទាំអ្នករបួសម្នាក់នៅតាមផ្លូវទៅបុរសម្នាក់ថា **"សូមលោកអញ្ជើញទៅចុះហើយប្រព្រឹត្តឲ្យបានដូចបុរសម្នាក់នោះទៅ"**។

ព្រះបន្ទូលរបស់ព្រះយេស៊ូពេលនោះ ក៏សម្រាប់យើងនៅថ្ងៃនេះដែរ គឺសូមឲ្យយើងធ្វើដំណើរទៅសួរសុខទុក្ខបងប្អូនឯទៀតៗ ដើម្បីមើលថែគេ ដើម្បីលាងរបួសឲ្យគេដោយសូមឲ្យមានចិត្តមេត្តាករុណាតាមរូបកាយ និងតាមវិញ្ញាណដូចព្រះយេស៊ូផង។ ក្នុងឆ្នាំព្រះមហាករុណាទិគុណនេះ យើងមានចក្ខុវិស័យប្រាំពីរដើម្បីបង្ហាញធម៌មេត្តាករុណាតាមរូបកាយ និងប្រាំពីរទៀតតាមវិញ្ញាណ ដែលយើងនឹងចាប់ផ្ដើមអនុវត្ត។ តាមវិញ្ញាណឲ្យយើងធ្វើមួយថ្ងៃមួយតាមរូបកាយយ៉ាងតិចមួយខែមួយ។ បន្ទាប់មកយើងធ្វើដំណើរទៅដល់ទីក្រុងយេរីខូ ដែលមានលោកសាខេនៅលើដើមឈើមួយយ៉ាងខ្ពស់ និងព្រះយេស៊ូដែលបានសម្លឹងមើលទៅគាត់ ហើយក្រោយមកព្រះអង្គយាងទៅសោយអាហារនៅផ្ទះរបស់គាត់។ ចំពោះយើង ជាញយដងយើងតែងតែភ្លេចសម្លឹងមើលអ្នកនៅជុំវិញយើង។ ព្រះយេស៊ូបានសម្លឹងមើលលោកសាខេដោយមានព្រះបន្ទូលថា **"ថ្ងៃនេះ ខ្ញុំចង់ស្នាក់នៅផ្ទះរបស់លោក"** ដែលណែនាំឲ្យលោកសាខេមានជីវិតថ្មីសមដូចព្រះអង្គមានព្រះបន្ទូលថា **"បុត្រមនុស្សបានមកដើម្បីស្វែងរកមនុស្សដែលវិនាសបាត់បង់"**។

ព្រះបន្ទូលប្រស្នារបស់ព្រះយេស៊ូអំពីកូនពៅវង្វេង មានអត្ថន័យណាស់សម្រាប់យើងដែលជាបូជាចារ្យដែលប្រៀបដូចជាឪពុក។ ទីមួយ ជាឪពុកដែលបានចែកកេរឲ្យកូនដោយគ្មានចិត្តចង្អៀតចង្អល់ ដូចព្រះបិតាប្រទានជីវិតនិងសេចក្ដីស្រឡាញ់ឲ្យយើងដោយព្រះហឫទ័យទូលំទូលាយ។ ទីពីរ ជាឪពុកដែលទន្ទឹងរង់ចាំកូនជានិច្ច និងពេលឃើញកូន ពីចម្ងាយរត់ទៅ

ឱបកូន។ ទីបី ជាឪពុកដែលទទួលស្វាគមន៍កូនដោយបើបដោយរៀបចំពិធីជប់លៀងទទួលកូនដែលមកវិញ។ ទីបួន ជាឪពុកដែលលើកលែងទោសឲ្យកូន។ នេះជាអំណរសប្បាយដ៏កំពូលសម្រាប់យើងជាបូជាចារ្យ។ ប៉ុន្តែយើងក៏ត្រូវសម្លឹងមើលព្រះយេស៊ូដែលធ្វើពិធីជប់លៀងចុងក្រោយដែរ គឺព្រះអង្គយកនំប៉័ងមកកាន់អរព្រះគុណព្រះបិតា រួចហើយកាច់ប្រទានឲ្យគេទាំងមានព្រះបន្ទូលថា **"នេះជារូបកាយរបស់ខ្ញុំដែលត្រូវបូជាសម្រាប់អ្នករាល់គ្នា។ សូមអ្នករាល់គ្នាធ្វើដូច្នេះដើម្បីនឹករឭកដល់ខ្ញុំ"**។

តាមពិត យើងដែលទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យ គឺយើងនឹករឭកព្រះយេស៊ូគ្រប់ពេលដោយយើងថ្វាយអភិបូជារាល់ថ្ងៃ ដែលបន្តិចម្តងៗយើងទៅជាយញ្ញបូជាដែលថ្វាយជីវិតទៅលើព្រះជាម្ចាស់យើងទៅជា ឧបករណ៍ពិសេសដែលសម្តែងធម៌មេត្តាករុណារបស់ព្រះបិតា។ ព្រះយេស៊ូមានព្រះបន្ទូលចុងក្រោយក្នុងពិធីជប់លៀងថា **"អ្នកដែលអង្គុយតុនិងអ្នកបម្រើតើអ្នកណាធំជាងគេ?។ តាមធម្មតាអ្នកដែលអង្គុយតុធំជាងគេ រីឯខ្ញុំវិញ ខ្ញុំនៅកណ្តាលអ្នករាល់គ្នាខ្ញុំធ្វើជាអ្នកបម្រើទៅវិញ"**។ ព្រះយេស៊ូក៏អញ្ជើញយើងឲ្យឈរនៅក្បែរឈើឆ្កាងរបស់ព្រះអង្គរួមជាមួយព្រះនាងម៉ារី និងជាមួយសន្តៈយ៉ូហានដែរ ដើម្បីស្តាប់ព្រះអង្គមានព្រះបន្ទូលថា **"ឱព្រះបិតាអើយ សូមព្រះអង្គលើកលែងទោសឲ្យអ្នកទាំងនេះផង ដ្បិតគេមិនដឹងថាគេកំពុងធ្វើអ្វីឡើយ"**។ ព្រះយេស៊ូបានលើកលែងទោសអ្នកបាបដែលទទួលស្គាល់បាបរបស់ខ្លួន ដោយមានព្រះបន្ទូលថា **"ខ្ញុំសូមប្រាប់ឲ្យដឹងច្បាស់ថា ថ្ងៃនេះអ្នកបានទៅនៅស្ថានរមសុខជាមួយខ្ញុំហើយ"** បន្ទាប់មកព្រះអង្គបន្លឺព្រះសូរសៀងខ្លាំងៗថា **"ឱព្រះបិតាអើយ! ទូលបង្គំសូមប្រគល់វិញ្ញាណរបស់ទូលបង្គំទៅក្នុងព្រះហស្តព្រះអង្គវិញ"** ក្រោយមកព្រះអង្គសោយទិវង្គត។

តាំងពីថ្ងៃប្រសូតនៅភូមិបេថ្លេហឹម រហូតដល់ថ្ងៃសោយទិវង្គតនៅលើឈើឆ្កាងព្រះយេស៊ូបានប្រព្រឹត្តគ្រប់កិច្ចការ ដើម្បីបង្ហាញព្រះហឫទ័យមេត្តាករុណារបស់ព្រះបិតាដល់មនុស្សលោក។ ព្រះយេស៊ូមានព្រះបន្ទូលជាញឹកញាប់ថា **"កូនអើយ! ខ្ញុំស្រឡាញ់កូនខ្លាំងណាស់ ខ្ញុំបានជ្រើសរើសកូន ខ្ញុំលើកលែងទោសឲ្យកូន ខ្ញុំធ្វើពិធីជ្រមុជទឹកឲ្យកូន ដើម្បីឲ្យកូនដឹងថា**

**ព្រះបិតាស្រឡាញ់កូនហួសពីការស្មាន**"។ មុនយាងឡើងស្ថានបរមសុខ ព្រះយេស៊ូមានព្រះបន្ទូលផ្ដែផ្ដាំថា "**អ្នករាល់គ្នាត្រូវប្រកាសក្នុងព្រះនាមព្រះបិតា ឲ្យមនុស្សគ្រប់ជាតិសាសន៍ប្រែចិត្តគំនិតដើម្បីឲ្យគេបានរួចពីបាប គឺត្រូវប្រកាសចាប់តាំងពីក្រុងយេរូសាឡឹមតទៅ**"។ ២០០០ឆ្នាំហើយដែលព្រះសហគមន៍ប្រកាសដំណឹងល្អបន្តពីក្រុមគ្រីស្តទូតមក ដើម្បីធ្វើពិធីជ្រមុជទឹកដើម្បីឲ្យបងប្អូនប្រែចិត្តគំនិត ដើម្បីចែកជីវិតដែលព្រះយេស៊ូបានប្រទានមកឲ្យយើង រហូតសព្វថ្ងៃដែលមានវត្តមានព្រះសហគមន៍នៅប្រទេសកម្ពុជាយើង។

ពិតមែនយើងជាឧបករណ៍ពិសេស ដើម្បីសម្ដែងធម៌មេត្តាករុណារបស់ព្រះជាម្ចាស់នៅលើទឹកដីនៃប្រទេសកម្ពុជា។ ចូរមានចិត្តមេត្តាករុណាដូចព្រះបិតាមានព្រះហឫទ័យមេត្តាករុណា។

**"ចូរទៅចុះជំនឿរបស់អ្នកបានសង្គ្រោះអ្នកហើយ! ចូរទៅចុះ ហើយឈប់ប្រព្រឹត្តអំពើបាបទៀត ខ្ញុំលើកលែងទោសឲ្យកូនដោយនាម ព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ"។**

# សន្តយ៉ូសែបជាគំរូសម្រាប់ព្រះសហគមន៍

Joseph, model for the Church

| |
|---|
| អត្ថបទទី១៖ យរ ២០, ១០-១៣<br>ដំណឹងល្អ៖ យហ ១០, ៣១-៤២ |

លោកអភិបាលអេមីល បានផ្ទេរសិទ្ធិឲ្យខ្ញុំនៅខែតុលាឆ្នាំ២០១០។ ថ្ងៃនេះខ្ញុំពាក់អាវដែលខ្ញុំបានពាក់នៅថ្ងៃដែលខ្ញុំទទួលសិទ្ធិ ដើម្បីនឹករឭកដល់ថ្ងៃដែលលោកអភិបាលអេមីលបានប្រគល់ឈើឆ្កាងរបស់លោកអភិបាលឆ្នារសាឡាស់មកឲ្យខ្ញុំ។ ពេលប្រគល់ឈើឆ្កាងនេះមកខ្ញុំ លោកយំដោយសារឈើឆ្កាងនេះបានភ្ជាប់ជីវិតរបស់លោកជាមួយនឹងប្រជាជនកម្ពុជា រហូតលោកបានទទួលអគ្គសញ្ញាតែងតាំងជាលោកអភិបាល និងលោកបានទទួលឈើឆ្កាងនេះពីម្តាយរបស់លោកអភិបាលឆ្នារសាឡាស់។ អ្វីៗទាំងអស់នេះ ណែនាំឲ្យយើងអរព្រះគុណព្រះជាម្ចាស់សម្រាប់លោកអភិបាលអេមីល ដែលជាគង្វាលដ៏សប្បុរសដ៏សុចរិតដូចសន្តៈយ៉ូសែបដែរ។ ថ្ងៃនេះយើងនឹករឭកដល់សន្តៈយ៉ូសែប ជាពិសេសពីរបៀបផ្សេងៗដែលលោកទៅជាគំរូរបស់ព្រះសហគមន៍យើងទាំងមូល គឺ៖

១/ លោកជាមនុស្សចូលចិត្តភាពស្ងៀមស្ងាត់ដើម្បីស្តាប់ឮព្រះសូរសៀងរបស់ព្រះជាម្ចាស់ និងដើម្បីទទួលការអស្ចារ្យក្នុងការរស់នៅតាមព្រះហឫទ័យរបស់ព្រះអង្គ។ ក្នុងសុបិនមួយ លោកបានឃើញព្រះជាម្ចាស់ណែនាំ ឲ្យលោកយល់ព្រមទទួលនាងម៉ារីធ្វើជាភរិយានិក្នុងសុបិនមួយទៀតនោះ លោកបានឃើញព្រះជាម្ចាស់ណែនាំឲ្យលោករត់គេចពីព្រះពិរោធរបស់ស្តេច ធ្វើដំណើរទៅស្រុកអេហ្ស៊ីបមុនលោកត្រឡប់មកណាសារ៉ែតវិញ។ លោកជាមនុស្សដែលពូកែរក

---

អភិបូជាបុណ្យរំឭកសន្តៈយ៉ូសែបនៅផ្សារតូច
ថ្ងៃទី១៨ មិនា ២០១៦

ស៊ីចិញ្ចឹមគ្រួសារតាមរបៀបដ៏សុចរិត និងស្មោះត្រង់។ លោកក៏ជាអ្នកដែលបាន ថែរក្សាការពារព្រះដំណាក់របស់ព្រះជាម្ចាស់ ដោយលោកបានចិញ្ចឹមបីបាច់ថែរក្សាព្រះយេស៊ូ អប់រំទូន្មានព្រះកុមារបន្តិចម្តងៗឲ្យទៅជាមនុស្សពេញវ័យ។ ពេលព្រះយេស៊ូនៅវ័យកុមារ ព្រះអង្គយាងទៅព្រះវិហារនៅយេរូសាឡឹម ពេលនោះព្រះអង្គមានព្រះបន្ទូលថា **"ខ្ញុំនៅក្នុងដំណាក់ព្រះបិតារបស់ខ្ញុំ"។** យើងគោរពសន្តៈយ៉ូសែប ទុកជាគំរូរបស់យើងក្នុងការការពារថែរក្សាព្រះសហគមន៍ទាំងមូល។

ថ្ងៃនេះជាខួប៦ឆ្នាំ ដែលខ្ញុំបានទទួលការតែងតាំងជាលោកអភិបាល។ ខ្ញុំសូមអធិដ្ឋានសម្រាប់ព្រះសហគមន៍នៅប្រទេសកម្ពុជាជាពិសេសព្រះសហគមន៍ភូមិភាគភ្នំពេញ។ ខ្ញុំសូមអធិដ្ឋានសម្រាប់លោកបូជាចារ្យ បព្វជិតបព្វជិតា សម្រាប់គ្រីស្តបរិស័ទទាំងអស់នៅក្នុងភូមិភាគ ដោយសូមឲ្យបងប្អូនយកចិត្តទុកដាក់បម្រើ យកចិត្តទុកដាក់អធិដ្ឋានសម្រាប់បងប្អូនទាំងអស់ដែលកំពុងស្វែងយល់ព្រះបន្ទូលរបស់ព្រះយេស៊ូ។ សព្វថ្ងៃតាមព្រះសហគមន៍នីមួយៗ មានបងប្អូនជាច្រើនដែលកំពុងស្វែងយល់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដោយមានបងប្អូនខ្លះទើបមកទទួលការអប់រំ ខ្លះទៀតបានចូលព្រះសហគមន៍ហើយ និងខ្លះទៀតត្រៀមខ្លួនដើម្បីទទួលអគ្គសញ្ញាជ្រមុជទឹកនៅឆ្នាំនេះ។

ពិតមែនថ្ងៃនេះ ខ្ញុំសូមអធិដ្ឋានសម្រាប់ព្រះសហគមន៍របស់យើង ឲ្យរីកចម្រើនក្នុងសេចក្តីសុខសាន្ត និងក្នុងអំណរសប្បាយដើម្បីឲ្យមនុស្សទាំងអស់អាចយល់បានថាព្រះសហគមន៍គឺជាក្រុមគ្រួសារមួយ និងខ្ញុំសូមសន្តៈយ៉ូសែបដែលបានថែរក្សាក្រុមគ្រួសាររបស់លោកយ៉ាងណាក៏សូមឲ្យលោកបន្តការពារថែរក្សាព្រះសហគមន៍ ដែលជាក្រុមគ្រួសារមួយដ៏ធំរបស់ព្រះជាម្ចាស់យ៉ាងនោះដែរ។ កាលយើងថ្វាយអភិបូជាប្រសិទ្ធិពរលើប្រេងគ្រីស្តស្នាស់ នោះយើងឃើញមានបូជាចារ្យ៦១រូប មានបព្វជិតបព្វជិតា និងគ្រីស្តបរិស័ទជាច្រើនរូប អញ្ជើញមកពីគ្រប់ទីកន្លែងចូលរួមដែលណែនាំឲ្យយើងមានអារម្មណ៍ថា ពិតមែនព្រះសហគមន៍របស់យើងជាក្រុមគ្រួសារមួយដែលចេះជួយគ្នាទៅវិញទៅមកនៅក្នុងសេចក្តីស្រឡាញ់របស់ព្រះគ្រីស្ត។

២/ សន្តៈយ៉ូសែប ជាអ្នកថែរក្សាមនុស្សលោកយើងនៅលើផែនដីនេះ។ លោកជាមនុស្សសុចរិត ជាពន្លឺមួយយ៉ាងពិសេសបង្ហាញផ្លូវដល់មនុស្សទាំងអស់ ជាពិសេសនៅប្រទេសកម្ពុជា យើងដែលជួនកាលយើងវង្វេង យើងភ្លេចខ្លួន យើងចាប់អារម្មណ៍នឹងពន្លឺផ្សេងៗដែលនៅជុំវិញយើង ហើយយើងភ្លេចពន្លឺមួយយ៉ាងពិសេស គឺពន្លឺរបស់ព្រះជាម្ចាស់ផ្ទាល់ដែលបានណែនាំហោរាចារ្យឲ្យទៅថ្វាយបង្គំព្រះឱរសយេស៊ូ។ សន្តៈយ៉ូសែប ជាពន្លឺមួយយ៉ាងពិសេសបំភ្លឺមនុស្សទាំងអស់ឲ្យទៅជាមនុស្សរឹងមាំក្នុងការរស់នៅដោយចាក់គ្រឹះលើផ្ទាំងថ្ម គឺសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់។

ដូច្នេះ នៅថ្ងៃខួប៦ឆ្នាំរបស់ខ្ញុំជាអភិបាល នោះខ្ញុំសូមអធិដ្ឋានសម្រាប់សង្គមយើងបច្ចុប្បន្ននេះឲ្យរកឃើញសេចក្តីសុខសាន្ត។ សម្រាប់យើងជាគ្រីស្តបរិស័ទឲ្យទៅជាអំបិល ជាពន្លឺ និងទៅជាមេម្សៅនៅក្នុងសង្គមរបស់យើង។ ឲ្យយើងមានចិត្តមេត្តាករុណាឲ្យយើងចេះណែនាំមនុស្សទាំងអស់នៅក្នុងសង្គមបច្ចុប្បន្ន អាចរកឃើញសេចក្តីក្លាហាននៅក្នុងសេចក្តីស្រឡាញ់ និងធម៌មេត្តាករុណារបស់ព្រះជាម្ចាស់។ ឲ្យយើងជាគ្រីស្តបរិស័ទទៅជាពន្លឺក្នុងការរស់នៅរបស់បងប្អូនទាំងអស់។ សម្រាប់ឆ្នាំព្រះមហាករុណាទិគុណនេះសូមឲ្យព្រះសហគមន៍នៅភូមិភាគភ្នំពេញយើងដែលកំពុងអនុវត្តលើវិស័យទាំងប្រាំពីរ មានដូចជា៖ ការសិក្សា សុខភាព ពលករ ជនពិការ ការការពារធម្មជាតិ ណែនាំឲ្យអ្នកក្រីក្រចូលនៅក្នុងសង្គម និងការសន្ទនាអន្តរសាសនា បានទៅដល់គោលដៅ។ សន្តៈយ៉ូសែបជាគំរូមួយយ៉ាងអស្ចារ្យជួយឲ្យយើងមានចិត្តនឹងននៅក្នុងការអនុវត្តកិច្ចការដ៏ថ្លៃថ្លានេះ។

៣/ សន្តៈយ៉ូសែប ជាអ្នកការពារថែរក្សាក្រុមគ្រួសារ។ លោកប្រកបរបររកស៊ីចិញ្ចឹមព្រះយេស៊ូ ចិញ្ចឹមព្រះនាងម៉ារី។ លោកជាស្វាមីដ៏ស្មោះត្រង់ ដែលមានភក្តីភាពចំពោះភរិយា និងកូន។ លោកជាឧបការីក្នុងការអធិដ្ឋាន ក្នុងការទាក់ទងគ្នាជាមួយអ្នកជិតខាងក្នុងការតស៊ូចំពោះការងារជាជាងឈើ ក្នុងឋានៈជាឪពុកដែលថែរក្សាកូន។ សន្តៈយ៉ូសែបជាឧបការីយ៉ាងពិសេសសម្រាប់ក្រុមគ្រួសារទាំងឡាយ។ ថ្ងៃនេះជាគម្រប់ខួប៦ឆ្នាំរបស់ខ្ញុំជាអភិបាលនោះ ខ្ញុំ

សូមអធិដ្ឋានសម្រាប់ក្រុមគ្រួសារទាំងអស់ ជាពិសេសក្រុមគ្រួសារគ្រីស្តបរិស័ទ សូមឲ្យរកឃើញអំណរសប្បាយនៅក្នុងការលើកលែងទោសដែលមកពីព្រះជាម្ចាស់ ដើម្បីឲ្យក្រុមគ្រួសាររបស់យើងនីមួយៗមានទាំងកូន ទាំងចៅផងនោះ ចម្រើនឡើងក្នុងភាពសុខដុមរមនាក្នុងសេចក្តីស្រឡាញ់ ដែលចេញមកពីទឹកចិត្តស្រឡាញ់របស់យើងជាឪពុកម្តាយ។ ខ្ញុំក៏សូមអធិដ្ឋានយ៉ាងពិសេសដែរសម្រាប់ក្រុមគ្រួសារទាំងឡាយដែលបាក់បែកគ្នាដែលកំពុងជួបទុក្ខលំបាក។ ខ្ញុំសូមអង្វរសន្តៈយ៉ូសែប សូមលោកការពារថែរក្សាក្រុមគ្រួសារទាំងអស់ទាំងនៅក្នុងព្រះសហគមន៍ និងទាំងនៅក្រៅព្រះសហគមន៍ដេប្ម ក្នុងប្រទេសកម្ពុជាទាំងមូល។

៤/ សន្តៈយ៉ូសែប ជាអ្នកការពារថែរក្សាជីវិតរបស់យើងម្នាក់ៗ។ លោកបានថែរក្សាព្រះនាងម៉ារី លោកបានតស៊ូក្នុងការងារ លោកបានយកចិត្តទុកដាក់ស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់។ សន្តៈយ៉ូសែបបានលើកទឹកចិត្តយើងម្នាក់ៗ ឲ្យមានកម្លាំងថែមទៀត មានសេចក្តីស្រឡាញ់ថែមទៀត និងមានអំណរសប្បាយថែមទៀត ក្នុងតួនាទីរបស់ខ្លួនជាគ្រីស្តបរិស័ទដែលដើរតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់។ ថ្ងៃនេះជាខួប៦ឆ្នាំរបស់ខ្ញុំជាអភិបាល នោះខ្ញុំសូមអធិដ្ឋានសម្រាប់បងប្អូនម្នាក់ៗក្នុងឆ្នាំព្រះមហាករុណាទិគុណនេះ ឲ្យរកឃើញបទពិសោធនៃការលើកលែងទោសដែលមកពីព្រះជាម្ចាស់ និងឲ្យបងប្អូនចែកបទពិសោធនោះជាមួយមនុស្សទាំងអស់ដែលបងប្អូនបានជួបប្រាស្រ័យទាក់ទងរាល់ថ្ងៃ។

មានតែសេចក្តីស្រឡាញ់ មានតែធម៌មេត្តាករុណា មានតែការលើកលែងទោសទេ ដែលអាចសង្គ្រោះមនុស្សលោក។ យើងបានទទួលតួនាទីជាអ្នកបន្តការសង្គ្រោះនេះពីព្រះជាម្ចាស់។ តាមរយៈអគ្គសញ្ញាជ្រមុជទឹកយើងទាំងអស់គ្នាបានទទួលសេចក្តីស្រឡាញ់ ទទួលការលើកលែងទោស ទទួលអំណរសប្បាយយ៉ាងពិសេសពីព្រះយេស៊ូផ្ទាល់។ យើងក៏ចូលរួមនៅក្នុងគម្រោងការនៃការសង្គ្រោះដ៏អស្ចារ្យរបស់ព្រះជាម្ចាស់នោះដែរ ដោយយើងម្នាក់ៗទៅជាឧបករណ៍ដ៏តូចមួយរបស់ព្រះអង្គ ជួយឲ្យការសង្គ្រោះរបស់ព្រះអង្គបានទៅដល់គ្រប់ទីកន្លែងនៅក្នុងពិភពលោកយើងទាំងមូល។

តាមរយៈសន្តៈយ៉ូសែប យើងខ្ញុំសូមអរព្រះគុណព្រះជាម្ចាស់ និងសូមព្រះអង្គការពារថែរក្សាព្រះសហគមន៍មនុស្សលោក ក្រុមគ្រួសារនីមួយៗ និងយើងខ្ញុំម្នាក់ៗ ឲ្យយើងខ្ញុំរស់នៅក្នុងសេចក្តីសុខសាន្តដែលមកពីព្រះជាម្ចាស់ផ្ទាល់។

**"ខ្ញុំបានបង្ហាញអោយអ្នករាល់គ្នាឃើញកិច្ចការដ៏ល្អប្រសើរជាច្រើន ដែលព្រះបិតាប្រទានអោយខ្ញុំធ្វើ។ ក្នុងបណ្តាកិច្ចការទាំងនោះ តើកិច្ចការណាមួយ ដែលនាំអោយអ្នករាល់គ្នាយកដុំថ្មបំរុងនឹងគប់សម្លាប់ខ្ញុំ?"**

# ព្រះយេស៊ូបង្ហាញអំពីធម៌មេត្តាករុណារបស់ព្រះបិតា

Jesus, the face of the Father's Love

---

អត្ថបទទី១៖ អស ៥០, ៤-៧
អត្ថបទទី២៖ ភីល ២, ៦-១១
ដំណឹងល្អ៖ លក ២២, ១៤ ដល់ ២៣, ៥៦;

ថ្ងៃនេះជិតប្រាំសប្ដាហ៍ហើយ ដែលយើងបានចូលនៅក្នុងទុក្ខលំបាករបស់ព្រះយេស៊ូ ដែលយើងបានធ្វើដំណើរជាមួយព្រះគ្រីស្ត និងចូលនៅក្នុងការរស់នៅរបស់ព្រះអង្គ ហើយថ្ងៃនេះជាថ្ងៃកំពូល ព្រោះជាថ្ងៃដែលព្រះយេស៊ូសោយទិវង្គត ជាពេលដែលយើងគិតថែមទៀតទាំងសម្លឹងមើលអំពីព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះបិតា។

ឆ្នាំព្រះមហាករុណាទិគុណ ជាឱកាសមួយឲ្យយើងមើលឃើញព្រះយេស៊ូ និងពេលយើងមើលឃើញព្រះយេស៊ូនោះគឺយើងមើលឃើញព្រះបិតា។ គ្រីស្តទូតលូកាដែលបាននិពន្ធគម្ពីរដំណឹងល្អ បានយកចិត្តទុកដាក់បង្ហាញអំពីព្រះបិតាលើកលែងទោសឲ្យមនុស្សលោក តាមរបៀបដែលព្រះបិតាស្រឡាញ់យើងតាមរបៀប ដែលព្រះបិតាសម្ដែងព្រះហឫទ័យប្រណីសន្ដោសដល់យើងម្នាក់ៗ។ ដូច្នេះសូមអញ្ជើញបងប្អូនមើលដើម្បីយល់ថែមទៀតអំពីព្រះបិតាដែលស្រឡាញ់យើង។

ក្នុងកណ្ឌគម្ពីរសន្តៈលូកាដដែល ដើម្បីបង្ហាញអំពីរបៀបដែលព្រះយេស៊ូស្រឡាញ់យើង មុនគេបង្អស់ព្រះយេស៊ូបានយកនំប៉័ងមកកាន់ និងកាច់ហើយមានព្រះបន្ទូលថា **"នេះជារូបកាយរបស់ខ្ញុំដែលត្រូវបូជាសម្រាប់អ្នករាល់គ្នា"** និងបន្ទាប់មកព្រះអង្គលើកពែងឡើងហើយមាន

---

អភិបូជាសំណាក់ធម៌រដូវ ៤០ ថ្ងៃនៅកំពង់សោម
ថ្ងៃទី ២០ មិនា ២០១៦

ព្រះបន្ទូលថា **"នេះជាពែងនៃសម្ព័ន្ធមេត្រីថ្មីដែលចងឡើងដោយសារលោហិតរបស់ខ្ញុំដែលត្រូវបង្ហូរសម្រាប់អ្នករាល់គ្នា"**។ ដូច្នេះព្រះយេស៊ូបានបូជាព្រះជន្មតាមរយៈនំប៉័ងដែលជារូបកាយរបស់ព្រះអង្គផ្ទាល់ និងតាមរយៈស្រាទំពាំងបាយជូរដែលជាលោហិតរបស់របស់ព្រះអង្គផ្ទាល់។ ក្នុងការរស់នៅកិច្ចការដ៏កំពូលរបស់ព្រះយេស៊ូ គឺនៅត្រង់កាយវិការកាច់នំប៉័ង និងលើកពែងស្រាឡើង ទាំងមានព្រះបន្ទូលថាព្រះអង្គសព្វព្រះហឫទ័យ លះបង់ព្រះជន្ម ដើម្បីបូជា ដើម្បីស្រឡាញ់ និងដើម្បីលើកលែងទោស...។ នៅពេលព្រះយេស៊ូលើកនំប៉័ងនិងស្រាទំពាំងបាយជូឡើងពេលនោះលែងជាសញ្ញាសម្គាល់ លែងជានិមិត្តរូបទៀតហើយ តែជារូបកាយផ្ទាល់របស់ព្រះអង្គដែលត្រូវបូជាដែលត្រូវលះបង់ចោលសម្រាប់យើង។ នេះជារបៀបដែលព្រះជាម្ចាស់ជាព្រះបិតាស្រឡាញ់យើង។

ឥឡូវយើងបន្តដំណើរតាមរយៈអត្ថបទដែលយើងបានស្ដាប់នៅថ្ងៃនេះគឺព្រះយេស៊ូយាងទៅសួនកេតសេម៉ានី ហើយព្រះអង្គអធិដ្ឋាន។ ព្រះយេស៊ូមានព្រះបន្ទូលថា **"ឱព្រះបិតាអើយ! ប្រសិនបើព្រះអង្គសព្វព្រះហឫទ័យ សូមព្រះអង្គដកយកពែងនៃទុក្ខលំបាកនេះចេញឲ្យឆ្ងាយពីទូលបង្គំទៅ ប៉ុន្តែសូមកុំឲ្យសម្រេចតាមចិត្តទូលបង្គំឡើយ គឺសូមឲ្យបានសម្រេចតាមព្រះហឫទ័យរបស់ព្រះអង្គវិញ"**។ នេះជារបៀបដែលព្រះយេស៊ូបង្ហាញអំពីធម៌មេត្តាករុណារបស់ព្រះបិតា និងអំពីសេចក្ដីស្រឡាញ់របស់ព្រះអង្គផ្ទាល់ដែលធ្វើតាមព្រះហឫទ័យរបស់ព្រះបិតាជានិច្ច គឺព្រះអង្គបូជារូបកាយនិងបូជាលោហិត តាមព្រះហឫទ័យព្រះបិតាដោយមិនគិតដល់សេចក្ដីសុខផ្ទាល់ខ្លួនព្រះអង្គឡើយ។

នៅពេលពួកទាហានមកចាប់ព្រះយេស៊ូ មានសាវ័កម្នាក់ចេញតតាំងនឹងពួកទាហាននោះដើម្បីការពារព្រះអង្គ រហូតកាប់ដាច់ស្លឹកត្រចៀកខាងស្ដាំរបស់ទាហានម្នាក់។ ពេលនោះព្រះយេស៊ូមានព្រះបន្ទូលឃាត់គាត់ថា **"ប៉ុណ្ណឹងបានហើយ"** រួចហើយព្រះអង្គពាល់ស្លឹកត្រចៀកទាហាននោះ និងប្រោសឲ្យបានជាដូចដើមវិញ។ ក្រោយមកសាវ័កនោះបានប្រព្រឹត្តកំហុសធ្វើឲ្យព្រះយេស៊ូដូចជាអស់សង្ឃឹម ប៉ុន្តែព្រះអង្គបានធ្វើឲ្យគេរកឃើញសេចក្ដីសុខនៅក្នុងខ្លួនរបស់

គេវិញ។ លោកសិលាបានបដិសេធបីដងថាមិនស្គាល់ព្រះយេស៊ូ ប៉ុន្តែនៅពេលមាន់រងាវបីដង ព្រះអម្ចាស់ដែលពោរពេញដោយសេចក្តីស្រឡាញ់ បានបែរព្រះភ័ក្ត្រទតមើលទៅលោក ហើយលោកក៏យំយ៉ាងខ្លាំង ដោយបានឃើញថា ព្រះយេស៊ូស្រឡាញ់លោកខ្លាំងណាស់។

ពេលទាហានបណ្តើរព្រះយេស៊ូទៅ ពេលនោះមានស្ត្រីៗដែលយំនឹកអាណិតព្រះអង្គ។ ពេលទតឃើញពួកនាងយំទោះបីព្រះអង្គកំពុងរងទុក្ខលំបាកយ៉ាងខ្លាំងដូចនេះក៏ដោយក៏ព្រះ-អង្គមិនចង់ឲ្យគេយំអាណិតព្រះអង្គដែរ ផ្ទុយទៅវិញព្រះអង្គអាណិតអាសូរគេយ៉ាងខ្លាំងវិញ ទាំងឆ្លៀតមានព្រះបន្ទូលលើកទឹកចិត្តទៅពួកនាងៗថា **"ស្ត្រីក្រុងយេរូសាឡឹមអើយ! កុំយំសោកអាណិតខ្ញុំធ្វើអ្វី ចូរយំសោកអាណិតខ្លួននាង និងកូននាងវិញ ដ្បិតនឹងមានគេពោលថាស្ត្រីណាឥតកូន ស្ត្រីណាមិនដែលបង្កើតកូន ស្ត្រីណាមិនដែលបំបៅកូន ស្ត្រីនោះពិតជាមានសុភមង្គលមែន"**។ នេះជារបៀបដែលព្រះយេស៊ូបង្ហាញពី សេចក្តីស្រឡាញ់របស់ព្រះបិតាដល់យើង គឺទោះបីព្រះអង្គរងទុក្ខលំបាកយ៉ាងណាក៏ដោយ ក៏ព្រះអង្គនៅតែលើកលែងទោស និងផ្តល់កម្លាំងដល់ស្ត្រីៗដើម្បីឲ្យគេយល់ថាជីវិតគេមានតម្លៃសម្រាប់ព្រះជាម្ចាស់។

នៅលើឈើឆ្កាង ព្រះយេស៊ូបានមានព្រះបន្ទូលលើកលែងទោស។ ទីមួយព្រះអង្គបានលើកលែងទោសឲ្យមនុស្សទាំងអស់ ដោយមានព្រះបន្ទូលថា **"ឱព្រះបិតាអើយ! សូមព្រះអង្គលើកលែងទោសឲ្យអ្នកទាំងនោះផង ដ្បិតគេមិនដឹងថាគេកំពុងធ្វើអ្វីឡើយ"**។ ទីពីរព្រះអង្គបានលើកលែងទោសឲ្យចោរដែលជាប់ឆ្កាងជាមួយព្រះអង្គ ដ្បិតចោរនោះទទួលស្គាល់អំពើបាបរបស់ខ្លួនដោយព្រះអង្គមានព្រះបន្ទូលថា **"ខ្ញុំសូមប្រាប់ឲ្យអ្នកដឹងច្បាស់ថា ថ្ងៃនេះអ្នកបានចូលទៅស្ថានបរមសុខជាមួយខ្ញុំ"** ។ ព្រះបន្ទូលចុងក្រោយបំផុតរបស់ព្រះយេស៊ូគឺ **"ឱព្រះបិតាអើយ! ទូលបង្គំសូមប្រគល់វិញ្ញាណរបស់ទូលបង្គំទៅក្នុងព្រះហស្តព្រះអង្គវិញ"** ដែលណែនាំឲ្យយើងយល់ថាព្រះយេស៊ូនិងព្រះបិតាគឺជាអង្គតែមួយ។

ដូច្នេះគ្រប់កិច្ចការដែលព្រះយេស៊ូបានធ្វើ គឺព្រះយេស៊ូដែលបូជាព្រះជន្មតាមព្រះហឫទ័យព្រះបិតាព្រះយេស៊ូដែលព្យាបាលត្រចៀករបស់ទាហានម្នាក់ព្រះយេស៊ូដែលទតមើលលោក

សិលា ដោយសេចក្តីស្រឡាញ់ ព្រះយេស៊ូដែលលើកទឹកចិត្តស្រ្តីៗ ព្រះយេស៊ូដែលលើកលែងទោសឲ្យមនុស្សទាំងអស់ ព្រះយេស៊ូដែលទទួលស្វាគមន៍ចោរទៅស្ថានបរមសុខនោះណែនាំឲ្យយើងរកឃើញថា ព្រះយេស៊ូនិងព្រះបិតាជាអង្គតែមួយ ដែលប្រោសប្រទានសេចក្តីសុខសាន្តនិងការលើកលែងទោសឲ្យយើងម្នាក់ៗ។

គ្រប់ស្នាព្រះហស្តរបស់ព្រះយេស៊ូក្នុងពេលព្រះអង្គរងទុក្ខលំបាក ណែនាំឲ្យអ្នកដែលសម្លឹងមើលព្រះអង្គបានប្រែចិត្តគំនិត។ លោកសិលាយំទាំងដឹងថាព្រះយេស៊ូស្រឡាញ់លោកខ្លាំងណាស់ នៅពេលលោកសម្លឹងទៅព្រះយេស៊ូដែលទតមកគាត់ដោយសេចក្តីស្រឡាញ់។ លោកពីឡាត បានបានប្រែចិត្តគំនិតដោយ ខិតខំនិយាយបីដងបង្ហាញថាព្រះយេស៊ូជាមនុស្សសុចរិតដើម្បីដោះលែងព្រះអង្គតែពុំបានសម្រេចទេ នៅពេលលោកបានសម្លឹងមើលព្រះយេស៊ូ។ ចោរដែលជាប់ឆ្កាងជាមួយព្រះយេស៊ូ បានប្រែចិត្តទាំងនិយាយថា **"គេកាត់ទោសខ្ញុំត្រូវហើយ ព្រោះខ្ញុំបានប្រព្រឹត្តអំពើបាបច្រើនណាស់ រីឯលោកវិញ លោកមិនបានធ្វើអំពើអាក្រក់សោះ"** ចោរនោះបាននិយាយបន្ថែមថា **"ឱព្រះយេស៊ូអើយពេលព្រះអង្គយាងមកគ្រងរាជ្យ សូមកុំភ្លេចទូលបង្គំ"** នៅពេលចោរនោះបានសម្លឹងមើលទៅព្រះយេស៊ូ។ ដូច្នេះចូរយើងសម្លឹងមើលព្រះយេស៊ូសម្លឹងមើលពីរបៀដែលព្រះអង្គប្រព្រឹត្តដែល នឹងនាំឲ្យយើងម្នាក់ៗទៅជាមនុស្សថ្មីដែលទទួលជីវិតថ្មី និងដែលទទួលការស្វាគមន៍ ទទួលសេចក្តីស្រឡាញ់ពីព្រះជាម្ចាស់ជាព្រះបិតារបស់យើង។

# នេះជារូបកាយរបស់ខ្ញុំដែលត្រូវបូជា សម្រាប់អ្នករាល់គ្នា

This is my Body given up for you

អត្ថបទទី១៖ សរ ១២, ១-៨.១១-១៤
អត្ថបទទី២៖ ១ ករ, ២៣-២៦
ដំណឹងល្អ៖ យហ ១៣, ១-១៥

ថ្ងៃនេះ យើងចូលរួមនៅថ្ងៃចុងក្រោយរបស់ព្រះយេស៊ូជាមួយក្រុមគ្រីស្តទូត។ ពេលនោះព្រះយេស៊ូកំពុងជប់លៀងនៅថ្ងៃបុណ្យចម្លងជាមួយក្រុមសាវ័ក ដែលបានធ្វើដំណើរជាមួយព្រះអង្គដែលបានរស់នៅយ៉ាងជិតស្និទ្ធជាមួយព្រះអង្គតាំងពីប៉ុន្មានឆ្នាំមកហើយ។ ថ្ងៃនេះ ជាថ្ងៃដែលយើងគោរពព្រះយេស៊ូលាងជើងសាវ័កក្នុងឆ្នាំព្រះមហាករុណាទិគុណ គឺជាឱកាសមួយដើម្បីយើងនឹកឃើញដល់ព្រះយេស៊ូ។ យើងរួមគ្នាអង្គុយជាមួយព្រះយេស៊ូដែលព្រះអង្គគង់នៅជាមួយក្រុមគ្រីស្តទូត ដែលព្រះអង្គយកនំប៉័ងមកកាន់ហើយមានព្រះបន្ទូលថា "នេះជារូបកាយរបស់ខ្ញុំ ដែលត្រូវបូជាសម្រាប់អ្នករាល់គ្នា"។

យប់នេះព្រះយេស៊ូគង់នៅជាមួយយើង យើងជាសាវ័ករបស់ព្រះអង្គ យើងធ្វើដំណើរជាមួយព្រះអង្គ យើងដឹងថាពេលនេះ ព្រះយេស៊ូអញ្ជើញយើងឲ្យយើងជប់លៀងជាមួយព្រះអង្គដែលជាជប់លៀងយ៉ាងប្លែក ដ្បិតជាពេលដែលព្រះអង្គបង្ហាញអំពីអត្ថន័យដ៏ពេញលក្ខណៈនៃជីវិតរបស់ព្រះអង្គ។ **"នេះជារូបកាយរបស់ខ្ញុំដែលត្រូវបូជាសម្រាប់អ្នករាល់គ្នា នេះជាពែងនៃសម្ព័ន្ធមេត្រីថ្មីដែលត្រូវបង្ហូរសម្រាប់អ្នករាល់គ្នា"** គឺព្រះយេស៊ូកំពុងបូជាព្រះជន្មបូជារូបកាយ បូជាព្រះលោហិតរបស់ព្រះអង្គ ទៅជាអាហារដើម្បីចិញ្ចឹមជីវិតរបស់ក្រុមគ្រីស្តទូតរបស់

---

អភិបូជាថ្ងៃព្រហស្បត្តិ៍ពិសិដ្ឋនៅព្រះសហគមន៍ចម្ការទៀង
ថ្ងៃទី ២៤ មិនា ២០១៦

ព្រះសហគមន៍ និងរបស់យើងម្នាក់ៗដែរ។

ឆ្នាំព្រះមហាករុណាទិគុណនេះ ជាឆ្នាំដែលព្រះអម្ចាស់សម្តែងព្រះហឫទ័យប្រណីសន្តោសដល់យើងម្នាក់ៗ ជាពេលវេលាឲ្យយើងសម្លឹងមើលព្រះយេស៊ូ។ បន្តិចទៀតទាំងលោកអភិបាលទាំងលោកបូជាចារ្យ នឹងនឹករឭកដល់ពិធីជប់លៀងលើកដំបូងរបស់ព្រះយេស៊ូដែលជាពិធីអភិបូជារបស់យើងសព្វថ្ងៃ ជាពេលវេលាមួយដើម្បីយើងសម្លឹងមើលរបៀបដែលព្រះជាម្ចាស់ជាព្រះបិតាស្រឡាញ់យើង ដោយសុខចិត្តប្រទានព្រះបុត្រារបស់ព្រះអង្គមកសម្រាប់យើង។ គ្រប់អភិបូជា គឺជាសក្ការបូជារបស់ព្រះអម្ចាស់ ជាសក្ការបូជានៃសេចក្តីស្រឡាញ់ ដែលរូបកាយរបស់ព្រះអង្គមិនមែនសម្រាប់ព្រះអង្គផ្ទាល់ លោហិតរបស់ព្រះអង្គមិនមែនសម្រាប់ព្រះអង្គផ្ទាល់ ប៉ុន្តែទាំងរូបកាយ និងទាំងព្រះលោហិតរបស់ព្រះយេស៊ូទៅរូបកាយ និងទៅជាលោហិតសម្រាប់យើងម្នាក់ៗវិញ។

ព្រះយេស៊ូយាងមក ដើម្បីសម្តែងព្រះភ័ក្ត្ររបស់ព្រះបិតា។ យប់នេះពេលលោកបូជាចារ្យយកនំប៉័ងមកកាន់ហើយនិយាយថា **"នេះជារូបកាយរបស់ខ្ញុំ"** លើកស្រាឡើងហើយនិយាយថា **"នេះជាលោហិតរបស់ខ្ញុំ"** នោះគឺជាពេលវេលាមួយដែលយើងចូលរួមនៅក្នុងជីវិតព្រះយេស៊ូ និងដើម្បីយើងនឹកឃើញដល់សេចក្តីស្រឡាញ់របស់ព្រះអង្គសម្រាប់យើងម្នាក់ៗ។ ពិតមែនព្រះបិតាបានស្រឡាញ់មនុស្សលោកខ្លាំងណាស់ ហេតុនេះហើយបានជាព្រះអង្គចាត់ព្រះបុត្រាឲ្យយាងមកដើម្បីសង្គ្រោះមនុស្សលោក។ យប់នេះជាយប់នៃការសង្គ្រោះសម្រាប់យើងម្នាក់ៗ ដោយយើងដឹងថាព្រះអង្គស្រឡាញ់យើងម្នាក់ៗ។ អំបាញ់មិញនៅពេលផ្តើមពិធីខ្ញុំបានគូសសញ្ញាឈើឆ្កាង គឺជាសញ្ញាឈើឆ្កាងដែលយើងបើកពិធីនៅថ្ងៃនេះរហូតដល់យើងបិទនៅថ្ងៃសៅរ៍ពេលយប់ដោយយើងទទួលព្រះពរនៅពេលព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ។ ដូច្នេះពីពេលនេះរហូតដល់យប់ថ្ងៃសៅរ៍ពេលយើងទទួលព្រះពរ គឺជាអភិបូជាតែមួយជាសក្ការបូជាតែមួយរបស់ព្រះយេស៊ូដែលថ្ងៃនេះតាមរយៈព្រះកាយ និងព្រះលោហិតរបស់ព្រះយេស៊ូថ្ងៃស្អែកតាមរយៈព្រះយេស៊ូនៅលើឈើឆ្កាង និងថ្ងៃសៅរ៍ពេលយប់ជារាត្រីបុណ្យចម្លងតាមរយៈ

ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញសម្រាប់យើង។

នៅពេលនេះយើងអរព្រះគុណព្រះជាម្ចាស់ សម្រាប់ជីវិតដែលយើងបានទទួលពីព្រះយេស៊ូដែលយើងបានដើរជាមួយព្រះយេស៊ូ ដែលយើងបានអធិដ្ឋាន ដែលយើងបានស្តាប់ព្រះបន្ទូលរបស់ព្រះយេស៊ូដូចក្រុមគ្រីស្តទូតពីដើម។ ព្រះយេស៊ូដែលបូជាព្រះជន្មសម្រាប់យើងម្នាក់ៗ ព្រះអង្គក៏អញ្ជើញយើងឲ្យសុខចិត្តបូជាជីវិតរួមជាមួយព្រះអង្គដែរ។ សម្រាប់យើងជាបូជាចារ្យសូមឲ្យយើងយល់យ៉ាងច្បាស់ថា នៅពេលយើងថ្វាយអភិបូជា គឺយើងថ្វាយជីវិតរបស់យើងផ្ទាល់រួមជាមួយព្រះយេស៊ូ។ ចូរយើងបន្តស្តាប់ព្រះបន្ទូល និងមើលកាយវិការរបស់ព្រះយេស៊ូ។ សូមឲ្យយើងនឹកដល់ព្រះយេស៊ូដែលងើបឈរឡើង ព្រះយេស៊ូដែលក្រវ៉ាត់ក្រមា នៅនឹងចង្កេះ ហើយឱនព្រះកាយទៅលាងជើងសន្តៈសិលា លាងជើងក្រុមគ្រីស្តទូត និងលាងជើងយើងម្នាក់ៗដែរ។ ចូរយើងស្តាប់សម្លេងទឹកដែលហូរលើជើងរបស់យើង ដែលណែនាំឲ្យយើងម្នាក់ៗភ្ញាក់ស្មារតីដូចសន្តៈសិលាដែរថា **"តើព្រះយេស៊ូកំពុងធ្វើអ្វីដល់យើង?"** ។ លាងរួចហើយព្រះយេស៊ូទតទៅសាវ័ក និងទតមកយើងម្នាក់ៗដោយព្រះហឫទ័យស្រឡាញ់ទាំងមានព្រះបន្ទូលថា **"ខ្ញុំបានលាងជើងអ្នករាល់គ្នាដើម្បីឲ្យអ្នករាល់គ្នាលាងជើងដល់បងប្អូនឯទៀតៗតៗគ្នា"**។ ដែលមានន័យថាឲ្យយើងធ្វើជាអ្នកបម្រើតាមគំរូរបស់ព្រះអង្គ។

យប់នេះ ព្រះយេស៊ូដែលកំពុងឱនព្រះកាយនៅក្បែរយើងម្នាក់ៗអញ្ជើញយើងឲ្យយើងធ្វើតាមគំរូរបស់ព្រះអង្គ។ ព្រះហឫទ័យស្រឡាញ់របស់ព្រះយេស៊ូ គឺបម្រើគ្នាទៅវិញទៅមកដើម្បីបង្កើតពិភពថ្មី សង្គមថ្មី ដោយគ្មានមេដែលមើលងាយកូនចៅ គ្មានអ្នកមានអំណាចដែលជិះជាន់អ្នកតូចតាច។ យប់នេះជាយប់ដែលណែនាំឲ្យរបៀបរស់នៅក្នុងសង្គមបច្ចុប្បន្ននេះទៅជារបៀបថ្មី គឺមេដែលត្រូវលាងជើងដល់កូនចៅ គឺយើងម្នាក់ៗទៅជាអ្នកបម្រើគ្នាទៅវិញទៅមករស់នៅតាមព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់ចំពោះមនុស្សលោក រស់នៅជាក្រុមគ្រួសារតែមួយដែលនេះជួយគ្នាទៅវិញទៅមក ជាពិសេសក្នុងឆ្នាំព្រះមហាករុណាទិគុណនេះឲ្យយើងមើលឃើញរបៀបព្រះយេស៊ូ និងឲ្យយើងស្តាប់ព្រះបន្ទូលរបស់ព្រះអង្គថា **"ពេលខ្ញុំនៅខ្លួនទទេ**

**ពេលខ្ញុំគ្មានម្ហូបអាហារពេលខ្ញុំស្រេកទឹក ពេលខ្ញុំជាអ្នកជំងឺ ពេលខ្ញុំជាជនបរទេស ពេលខ្ញុំជាប់ឃុំឃាំង តើអ្នកបានចែកសម្លៀកបំពាក់ ជូនម្ហូបអាហារ ជូនទឹក ជូនថ្នាំព្យាបាលទទួលស្វាគមន៍ខ្ញុំ និងមកសួរសុខទុក្ខខ្ញុំដែរឬទេ?"**។

យប់នេះ ព្រះយេស៊ូផ្ទាល់កំពុងសួរមកយើងតាមរយៈអ្នកក្រីក្រ អ្នកតូចតាច អ្នកគ្មានម្ហូបអាហារ អ្នកគ្មានទឹកស្អាតបរិភោគ អ្នកគ្មានកន្លែងស្នាក់នៅ អ្នកជំងឺដែលគ្មានថវិការសម្រាប់ព្យាបាល...គឺពួកគាត់ ជាព្រះយេស៊ូផ្ទាល់ ដែលកំពុងសម្លឹងមកយើង ដែលកំពុងរង់ចាំទទួលសេចក្តីស្រឡាញ់ពីយើង ជាសេចក្តីស្រឡាញ់ដែលយើងបានទទួលពីព្រះជាម្ចាស់ យកទៅចែកបន្តទៀតដល់ពួកគាត់។

រាត្រីនេះជារាត្រីអគ្គសញ្ញានៃព្រះហឫទ័យ ប្រណីសន្តោសរបស់ព្រះបិតាសម្រាប់យើងម្នាក់ៗជារាត្រីនៃសេចក្តីស្រឡាញ់ ជារាត្រីដែលយើងមើលឃើញជាក់ស្តែងពីសេចក្តីស្រឡាញ់ដែលព្រះជាម្ចាស់ប្រទានឲ្យយើងដោយមានព្រះបន្ទូលថា **"នេះជារូបកាយរបស់ខ្ញុំ នេះជាលោហិតរបស់ខ្ញុំ។ ចូរលាងជើងគ្នាទៅវិញទៅមក ចូរបម្រើគ្នាទៅវិញទៅមក"** ដើម្បីឲ្យសេចក្តីស្រឡាញ់របស់ព្រះបិតាយាងចូលនៅគ្រប់ទីកន្លែង ក្នុងភូមិ ក្នុងស្រុក ក្នុងប្រទេសរបស់យើង។

ចូរយើងនៅស្ងៀមស្ងាត់បន្តិចដោយអរព្រះគុណព្រះជាម្ចាស់ដែលបានប្រទានជីវិតថ្មីឲ្យយើងតាមរយៈព្រះកាយ តាមរយៈព្រះលោហិត។ ចូរយើងអរព្រះគុណព្រះជាម្ចាស់ដែលណែនាំឲ្យយើងទៅជាអ្នកបម្រើនៅក្នុងសេចក្តីស្រឡាញ់។

# ព្រះជាម្ចាស់នៅជាធ្លុងតែមួយជាមួយទុក្ខលំបាករបស់មនុស្សលោក

God is One with the suffering of the world

---

អត្ថបទទី១៖ អស ៥២, ១៣ ដល់ ៥៣,១២
អត្ថបទទី២៖ ហប ៤, ១៤-១៦ និង ៥, ៧-៩
ដំណឹងល្អ៖ យហ ១៨, ១ ដល់ ១៨, ៤២

នៅពេលនេះ ចូរឲ្យយើងនៅស្ងៀមស្ងាត់ ព្រះយេស៊ូបានសោយទិវង្គតហើយ ព្រះអង្គបានបូជាព្រះជន្មដើម្បីរំដោះបាបឲ្យយើងម្នាក់ៗ។ ក្នុងឆ្នាំមហាករុណាទិគុណនេះជាពេលវេលាមួយយ៉ាងពិសេស ថ្ងៃនេះយើងសម្លឹងមើលព្រះយេស៊ូ ដែលសោយទិវង្គតនៅលើឈើឆ្កាង ព្រះអង្គជាព្រះភ័ក្ត្រព្រះបិតាដែលយាងមកណែនាំឲ្យមនុស្សលោកមានជីវិតថ្មី។ យើងកំពុងសម្លឹងមើលព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះបិតា កាលគ្រានោះពេលមហាជនឃើញលោក គេក៏គ្រប់គ្នាព្រឺខ្លាចយ៉ាងខ្លាំង ព្រោះគេមើលមុខលោកលែងស្គាល់ លោកលែងមានទ្រង់ទ្រាយជាមនុស្សទៀតហើយលោកជាមនុស្សដែលត្រូវគេមើលងាយ គ្មាននរណារាប់រក លោកជាមនុស្សដែលស្គាល់តែការឈឺចាប់ស្គាល់តែភាពវេទនា។ យើងបានមើលងាយលោក ហើយមិនរាប់រកលោកទេ។

នៅពេលនឹកគិតដល់ទុក្ខលំបាកនេះ ណែនាំឲ្យយើងនឹកឃើញយ៉ាងពិសេសដល់ព្រះវិហារលើភ្នំបូកគោនេះ ដែលជាសាក្សីនៃប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជាជាសាក្សីនៃទុក្ខលំបាករបស់ប្រជារាស្ត្រយើង ដែលមានមនុស្សរាប់លាននាក់ បានទទួលមរណភាពក្នុងសម័យប៉ុលពត។ យើងក៏នឹកឃើញដល់ទុក្ខលំបាករបស់មនុស្សនៅក្នុងពិភពលោកទាំងមូល។

---

អភិបូជាថ្ងៃសុក្រពិសិដ្ឋ នៅលើភ្នំបូកគោ
ថ្ងៃទី ២៥ មិនា ២០១៦

នឹកឃើញដល់បងប្អូននៅទ្វីបអឺរ៉ុប និងនៅទ្វីបអាហ្វ្រិកដែលកំពុងទទួលមរណភាពដោយសារភេរវកម្មរបស់ក្រុមអាយស៊ីស។ យើងនឹកឃើញដល់ក្រុមបងស្រីមេត្តាករុណានិងបុគ្គលិកដែលត្រូវគេសម្លាប់។ យើងនឹកឃើញដល់លោកបូជាចារ្យតួនដែលគេបានចាប់និងកំពុងរងទុក្ខលំបាកដូចព្រះយេស៊ូ។ យើងនឹកឃើញដល់មនុស្សទាំងអស់ក្នុងពិភពលោកទាំងមូលដែលត្រូវបានគេសម្លាប់ដោយគ្មានកំហុសដែលត្រូវគេមើលងាយដែលបាត់បង់កិត្តិយសជាមនុស្ស។

តាមពិតលោកបានរងទុក្ខវេទនាជំនួសយើង លោកបានទទួលយកការឈឺចាប់របស់យើងដាក់លើខ្លួនលោក។ តាមពិតថ្ងៃនេះយើងយល់ហើយលោកដែលរងទុក្ខលំបាកយើងនោះគឺជាព្រះយេស៊ូផ្ទាល់ដែលព្រះអង្គទទួលយកគ្រប់ទុក្ខលំបាករបស់មនុស្សលោក។ ថ្ងៃនេះព្រះ-ជាម្ចាស់ទៅជាឆ្លងតែមួយជាមួយទុក្ខលំបាករបស់មនុស្សលោក ហើយទុក្ខលំបាករបស់មនុស្សលោកគឺជាទុក្ខលំបាករបស់យើងម្នាក់ៗ។ នៅលើឈើឆ្កាង ព្រះយេស៊ូបានទទួលគ្រប់ស្នាមរបួសរបស់យើង និងគ្រប់ការឈឺចាប់របស់យើង។ ព្រះភ័ក្ត្ររបស់ព្រះបិតាដែលយើងមើលឃើញទៅជាតែមួយជាមួយនឹងទុក្ខលំបាករបស់យើង។ ថ្ងៃនេះយើងបានយល់អំពីរបៀបដែលព្រះ-ជាម្ចាស់ស្រឡាញ់យើង អំពីរបៀបដែលព្រះជាម្ចាស់សង្គ្រោះយើង អំពីរបៀបដែលព្រះជាម្ចាស់យាងមកដើម្បីឲ្យយើងទទួលជីវិតអស់កល្បជានិច្ច។

លោកត្រូវគេចាក់ទម្លុះព្រោះតែយើងបានលះបង់លោកចោល ព្រោះតែអំពើទុច្ចរិតរបស់យើង។ លោកបានរងទារុណកម្មដើម្បីឲ្យយើងបានសេចក្តីសុខសាន្ត និងដោយសារស្នាមរបួសរបស់លោក យើងក៏បានជាសះស្បើយ។ ថ្ងៃនេះយើងសម្លឹងមើលម្តងទៀតដោយសារស្នាមរបួសរបស់ព្រះយេស៊ូនៅលើព្រះហស្ត នៅលើព្រះឱ៉ា និងនៅលើព្រះបាទាបានធ្វើឲ្យយើងបានជាសះស្បើយ។ ថ្ងៃនេះជាពេលវេលាមួយយ៉ាងពិសេស ឲ្យយើងយល់ថាព្រះយេស៊ូយាងមកដើម្បីពាល់ ដើម្បីទទួល ដើម្បីថើបរបួសរបស់យើង ដើម្បីឲ្យយើងទទួលជីវិតថ្មី។

តើព្រះយេស៊ូជានណា? តើព្រះយេស៊ូជាអ្នកភូមិណាសារ៉ែត? ព្រះយេស៊ូឆ្លើយថា **"គឺខ្ញុំហ្នឹងហើយ"**។ គេសួរព្រះអង្គទៀតថា តើលោកជាស្តេចនៃសាសន៍យូដា? ព្រះយេស៊ូឆ្លើយថា

**"ខ្ញុំបានកើត និងចុះមកក្នុងពិភពលោកនេះដើម្បីផ្តល់សក្ខីភាពនៃសេចក្តីស្រឡាញ់។ អ្នកណាជាប់និងសេចក្តីពិត អ្នកនោះនឹងស្តាប់សម្តីខ្ញុំ"**។ ពិតមែនព្រះយេស៊ូជាអ្នកភូមិណាសារ៉ែត និងព្រះយេស៊ូជាស្តេច ដែលយើងបានសរសេរលើឈើឆ្កាងថា **"យេស៊ូអ្នកភូមិណាសារ៉ែតជាស្តេចនៃជនជាតិយូដា"**។ ព្រះយេស៊ូជាមនុស្ស និងជាព្រះជាម្ចាស់ដែលបានចាប់កំណើតជាមនុស្ស ដើម្បីប្រទានពរដល់យើងម្នាក់ៗ ឲ្យយើងទទួលជីវិត ទទួលការសង្គ្រោះរកឃើញសេចក្តីសង្ឃឹមនៅក្នុងភាពងងឹតនៃជីវិតរបស់យើង។

ថ្ងៃនេះយើងសម្លឹងមើលព្រះយេស៊ូ ហើយយើងដឹងថានៅក្បែរឈើឆ្កាងមានតែព្រះនាងម៉ារីនិងលោកយ៉ូហានប៉ុណ្ណោះ។ ថ្ងៃនេះយើងក៏នៅក្បែរឈើឆ្កាងរបស់ព្រះយេស៊ូដែរ យើងសម្លឹងមើលព្រះអង្គ ដើម្បីបន្តបេសកកម្មនៃសេចក្តីស្រឡាញ់ដែលព្រះអង្គបានប្រទានឲ្យយើង។ នៅពេលនេះយើងស្តាប់ព្រះយេស៊ូដែលកំពុងមានព្រះបន្ទូលមកយើងថា **"ខ្ញុំស្រេកទឹក"** នៅពេលយើងកំពុងសម្លឹងមើលទៅក្មេងៗ មើលទៅយុវជនយុវនារីដែលគ្មានឱកាសដើម្បីទទួលការអប់រំ និងរៀបចំអនាគតរបស់គេ។ ថ្ងៃនេះ**"ខ្ញុំស្រេកទឹក"** នៅពេលយើងឃើញអ្នកជំងឺដែលគ្មានសមត្ថភាពដើម្បីទៅព្យាបាលជំងឺ ដែលគ្មានទីពឹង ដែលរង់ចាំសេចក្តីស្លាប់មកដល់។ ថ្ងៃនេះ **"ខ្ញុំស្រេកទឹក"** នៅពេលខ្ញុំឃើញកម្មករ កម្មការិនី ពលករទៅធ្វើការក្រៅប្រទេសជួបការលំបាកដោយសារគ្មាននរណាដែលគោរពសិទ្ធិរបស់គេ។ នៅពេលខ្ញុំឃើញពលករធ្វើការយ៉ាងធ្ងន់ពីមួយថ្ងៃទៅមួយថ្ងៃដោយគ្មានសេរីភាព និងបាត់បង់សិទ្ធិជាមនុស្សរបស់គេ។

ថ្ងៃនេះ **"ខ្ញុំស្រេកទឹក"** នៅពេលខ្ញុំឃើញជនពិការធ្ងន់ត្រូវគេបោះបង់ចោល ហាក់បីដូចជាជីវិតគេគ្មានតម្លៃ។ ថ្ងៃនេះ **"ខ្ញុំស្រេកទឹក"** នៅពេលខ្ញុំឃើញបរិដ្ឋានធម្មជាតិរបស់យើងដែលកំពុងរងនូវការបំផ្លាញគ្មានការថែរក្សាការពារ និងស្រឡាញ់។ ថ្ងៃនេះ **"ខ្ញុំស្រេកទឹក"** នៅពេលខ្ញុំឃើញគ្រួសារក្រីក្រដែលគ្មានការងារធ្វើ ដែលគ្មានម្ហូបអាហារ ដែលបាត់បង់សេចក្តី សង្ឃឹមដោយសារសង្គមមិនទទួលស្គាល់គេ មិនរកកន្លែងមួយឲ្យគេរស់នៅដោយសមរម្យមិនការពារតម្លៃថ្លៃថ្នូររបស់គេ។ ថ្ងៃនេះ**"ខ្ញុំស្រេកទឹក"** នៅពេលខ្ញុំឃើញបងប្អូនដែលមានសាសនាខុសៗគ្នាមិន

សន្ទនាគ្នា មិនយល់ចិត្តគ្នា មិនទទួលស្គាល់គ្នានៅក្នុងជំនឿសាសនាខុសគ្នា មិនរស់នៅក្នុងសេចក្តីថ្លៃថ្នូរតែមួយគត់គឺយើងជាបងប្អូនគ្នា ដោយសារយើងមានព្រះបិតាតែមួយព្រះអង្គគត់ដែលបានបង្កើតយើងនិងស្រឡាញ់យើង។ **"ខ្ញុំស្រេកទឹក"** ដើម្បីប្រាប់បងប្អូនទាំងអស់ថា កុំភ្លេចក្នុងឆ្នាំព្រះមហាករុណាទិគុណនេះ យើងជាដៃ យើងជាជើង យើងជាភ្នែក យើងជាត្រចៀក របស់ព្រះបិតាយើង។

ព្រះបិតាណែនាំឲ្យយើងម្នាក់ៗយកចិត្តទុកដាក់ថែរក្សាគ្នា លើកទឹកចិត្តគ្នា ដើម្បីឲ្យសង្គមរបស់យើងទៅជាសង្គមមួយថ្មី ដើម្បីឲ្យជីវិតរបស់យើងទៅជាជីវិតថ្មី ដើម្បីឲ្យធម៌មេត្តាករុណារបស់ព្រះអង្គយាងមកយ៉ាងពេញលេញនៅលើពិភពលោកនេះ។ ការអប់រំ សុខភាព ពលករជនពិការ ការពារធម្មជាតិ ណែនាំឲ្យជនក្រីក្រចូលនៅក្នុងសង្គម និងកិច្ចសន្ទនាអន្តរសាសនានេះជាបេសកកម្មរបស់គេ នៅក្នុងអង្គព្រះគ្រីស្ត ដើម្បីឲ្យព្រះសហគមន៍របស់យើងទៅជាព្រះភ័ក្ត្រព្រះបិតាពិតមែន។ ព្រះយេស៊ូមានព្រះបន្ទូលថា "អ្វីៗទាំងអស់បានបង្ហើយសព្វគ្រប់អស់ហើយ" ព្រះយេស៊ូសោយទិវង្គតសម្រាប់ខ្ញុំ ព្រះយេស៊ូសោយទិវង្គតដោយសារបាបរបស់ខ្ញុំ ព្រះយេស៊ូសោយទិវង្គតដើម្បីឲ្យខ្ញុំជាសះស្បើយ។

# យើងជាព្រះដែលមានព្រះជន្មគង់នៅ

I am the God of Life!

អត្ថបទទី១៖ បារ ៣, ៩-១៥. ៣២ ដល់ ៤, ៤
អត្ថបទទី២៖ អគ ៣៦, ១៦-១៧ក.១៨-២៨
ដំណឹងល្អ៖ លក ២៤, ១-១២

ព្រះគ្រីស្ដមានព្រះជន្មរស់ឡើងវិញហើយ អាលេលូយ៉ា! អាលេលូយ៉ា!

នេះគឺជាអំណរសប្បាយរបស់គ្រីស្ដបរិស័ទ ជាពិសេសនៅក្នុងឆ្នាំព្រះមហាករុណាទិគុណនេះ។ គ្រីស្ដបរិស័ទតែងនិយាយថា **"នៅពេលព្រះយេស៊ូប្រសូត គឺជាពេលដែលព្រះជាម្ចាស់បានចាប់កំណើតជាមនុស្ស ដើម្បីព្រះអង្គបង្ហាញសេចក្ដីស្រឡាញ់ចំពោះមនុស្សលោក"**។ តែយប់នេះជាយប់សុខសាន្ដ យ៉ាងពិសេសមួយទៀត ជាយប់ដ៏កំពូលទីពីរក្នុងឆ្នាំព្រះមហាករុណាទិគុណនេះ ដែលព្រះជាម្ចាស់សម្ដែងសេចក្ដីស្រឡាញ់របស់ព្រះអង្គចំពោះមនុស្សលោកដោយប្រោសព្រះយេស៊ូឲ្យមានព្រះជន្មរស់ឡើងវិញ។

យប់នេះ ជាយប់ដែលព្រះជាម្ចាស់សម្ដែងព្រះនាមព្រះអង្គ តាមរយៈប្រវត្តិសាស្ត្ររបស់មនុស្សលោកហើយនឹងព្រះអង្គ។ យើងបានស្ដាប់អត្ថបទតាំងពីកំណើតពិភពលោក រហូតដល់ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ ជាពេលវេលាដែលព្រះជាម្ចាស់សម្ដែងព្រះនាមរបស់ព្រះ-អង្គតាមរយៈសម្ព័ន្ធមេត្រី ដែលព្រះអង្គបានចងជាមួយយើងជាបុរស ជាស្ត្រី ជាមនុស្សលោក។ តើព្រះជាម្ចាស់មានព្រះនាមអ្វី? សូមឲ្យយើងនឹកឃើញនៅពេលព្រះជាម្ចាស់ជួបជាមួយលោកម៉ូសេ ពេលនោះព្រះអង្គមានព្រះបន្ទូលថា៖ **"យើងជាព្រះដែលមានព្រះជន្មគង់នៅ"**។ ប៉ុន្តែយប់នេះតាមរយៈអត្ថបទគម្ពីរដែលយើងបានស្ដាប់ជាបន្តបន្ទាប់ នោះព្រះជាម្ចាស់បានសម្ដែង

អភិបូជារាត្រីបុណ្យចម្លងនៅផ្សារតូច
ថ្ងៃទី២៦ ខែមិនា ឆ្នាំ២០១៦

ព្រះនាមរបស់ព្រះអង្គបន្តិចម្តងៗ ដើម្បីឲ្យយើងជាគ្រីស្តបរិស័ទ ដើម្បីឲ្យបងប្អូនដែលបន្តិចទៀត នឹងទទួលអគ្គសញ្ញាជ្រមុជទឹក អាចចូលយ៉ាងជ្រៅថែមទៀតទៅក្នុងប្រវត្តិសាស្ត្រនៃការសង្គ្រោះដ៏អស្ចារ្យដែលព្រះអង្គបានរៀបចំឲ្យយើងម្នាក់ៗ។

១) ព្រះជាម្ចាស់ជាដង្ហើមនៃជីវិតនិងជាពន្លឺនៃពិភពលោកទាំងមូល។ យើងបានស្តាប់ឮហើយថា កាលដើមដំបូងឡើយព្រះវិញ្ញាណរបស់ព្រះជាម្ចាស់គង់នៅលើផែនដីយើង។ ពេលព្រះជាម្ចាស់មានព្រះបន្ទូលថា៖ **"ចូរមានពន្លឺ"** នោះពន្លឺក៏កើតមានឡើង។ ព្រះជាម្ចាស់ជាដង្ហើមនៃជីវិត និងជាពន្លឺបំភ្លឺមនុស្សលោកយើង។ បន្ទាប់មកព្រះជាម្ចាស់បង្កើតមនុស្សលោក គឺព្រះអង្គបង្កើតយើងជាស្ត្រីនិងជាបុរស។ ព្រះអង្គផ្លុំខ្យល់ដង្ហើមឲ្យយើងនោះយើងក៏មានជីវិតឡើង។ យប់នេះព្រះជាម្ចាស់ណែនាំឲ្យយើងទទួលម្តងទៀត គឺទទួលដង្ហើមនៃជីវិតរបស់ព្រះអង្គចូលទៅក្នុងសួតរបស់យើងទៅក្នុងជីវិតរបស់យើង ដើម្បីឲ្យយើងពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ។ យប់នេះ ព្រះជាម្ចាស់អញ្ជើញយើងឲ្យទៅជាពន្លឺនៅក្នុងទីងងឹតនៃពិភពលោកទាំងមូល ទាំងប្រទានពិភពលោកឲ្យយើង និងណែនាំឲ្យយើងបង្កើតកូនចៅច្រើនឡើងពាសពេញលើផែនដី និងត្រួតត្រាផែនដីទៅ។ នេះជាតួនាទីដែលយើងបានទទួលពីព្រះជាម្ចាស់។ ក្រុមគ្រួសារដែលបានរៀបការហើយ មានប្តី មានប្រពន្ធ មានកូនដែល បានអញ្ជើញមកក្នុងពេលនេះ ជាសញ្ញាសម្គាល់ជាក់ស្តែងនៃព្រះអំណោយទាននេះ។ សព្វថ្ងៃសម្តេចប៉ាបក៏បានរំឭកយើងអំពីសេចក្តីនេះដែរថា **"ផែនដីរបស់យើងជាផ្ទះរបស់យើង ពិភពលោកទាំងមូលជាផ្ទះរួមរបស់យើងពិតមែន"**។ យប់នេះព្រះជាម្ចាស់អញ្ជើញយើងឲ្យទៅជាអ្នកបង្កើតបន្តពីព្រះអង្គទៅជាអ្នកសួនផែនដី ទៅជាអ្នកសួនមនុស្សឲ្យគេមានជីវិតដ៏ពិសេសហើយព្រះអង្គក៏ណែនាំយើងឲ្យទៅជាអ្នកទទួលមរតកពីព្រះអង្គ គឺទទួលផែនដីទាំងមូលទុកសម្រាប់បន្តឲ្យទៅកូនរបស់យើងតទៅទៀត ហើយព្រះអង្គក៏ណែនាំឲ្យយើងទៅជាពន្លឺសម្រាប់ពិភពលោកទាំងមូលដែរ។

2) ព្រះជាម្ចាស់ជាព្រះដែលរំដោះយើងឲ្យឆ្លងពីភាពងងឹត ពីបាប ពីអ្វីៗទាំងអស់ដែល

ណែនាំឲ្យយើងជាប់នៅមួយកន្លែង ទៅរកសិទ្ធិសេរីភាពពេញលេញ។ យើងបានស្តាប់រឿងលោកម៉ូសេនាំប្រជារាស្ត្រអ៊ីស្រាអែលឆ្លងសមុទ្រក្រហម ដែលពេលនោះ សមុទ្របានញែកជាពីរ ឲ្យប្រជារាស្ត្រអ៊ីស្រាអែល អាចដើរចេញពីកណ្តាប់ដៃជនជាតិអេហ្ស៊ីប ឆ្ពោះទៅរកសេរីភាព ទៅរកជីវិតបាន។ ព្រះជាម្ចាស់សូមឲ្យយើងស្តាប់ព្រះបន្ទូលដែលមានជីវិត នោះយើងនឹងមានជីវិតដោយមានព្រះបន្ទូលថា៖ **"ទឹកភ្លៀង ដែលធ្លាក់ពីលើមេឃមកផែនដី ទឹកនោះនឹងត្រឡប់ទៅវិញដរាបណាបានធ្វើឲ្យដំណាំដុះឡើង និង បង្កើតផលយ៉ាងច្រើន រីឯពាក្យរបស់យើងដែលបានធ្លាក់ទៅក្នុងដួងចិត្តរបស់អ្នករាល់គ្នា ក៏ដូច្នោះដែរ គឺនឹងត្រឡប់មកវិញដរាបណាបានបង្កើតផលផ្លែយ៉ាងច្រើន តាមរយៈសេចក្តីស្រឡាញ់របស់យើង"**។ ដូច្នេះក្នុងឆ្នាំមហាករុណាទិគុណនេះ ព្រះជាម្ចាស់អញ្ជើញយើងឲ្យទទួលចិត្តថ្មី គឺ **"យើងនឹងប្រគល់ចិត្តគំនិតថ្មីឲ្យអ្នករាល់គ្នា ហើយយើងដាក់វិញ្ញាណថ្មីឲ្យអ្នករាល់គ្នាដែរ យើងនឹងជម្រះអ្នករាល់គ្នាឲ្យបានស្អាតបរិសុទ្ធ ផុតពីអំពើសៅហ្មងទាំងឡាយ"** នេះជាដំណឹងល្អដែលយើងទទួលយប់នេះ។

ព្រះជាម្ចាស់ជាព្រះដែលរំដោះយើងឲ្យបានទទួលជីវិតថ្មីពីព្រះអង្គ។ យប់នេះព្រះជាម្ចាស់អញ្ជើញយើងឲ្យស្តាប់ព្រះបន្ទូលព្រះអង្គ ដើម្បីឲ្យយើងរស់ឡើងវិញ ឲ្យយើងកើតសាជាថ្មីរួមជាមួយព្រះយេស៊ូជា ព្រះបុត្រាព្រះអង្គ។ ក្នុងរាត្រីបុណ្យចម្លងនេះ ក្នុងភូមិភាគភ្នំពេញទាំងមូលមានបងប្អូនយើង ១១១នាក់ ដែលកំពុងត្រៀមខ្លួនដើម្បីទទួលអគ្គសញ្ញាជ្រមុជទឹក ហើយពួកគាត់ក៏បានស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ដើម្បីបានទទួលជីវិតថ្មីដែរ។ ព្រឹកមិញ ខ្ញុំបានទៅថ្វាយអភិបូជាសម្រាប់អ្នកដែលជាប់ឃុំឃាំង នៅព្រៃស ពេលនោះមានម្នាក់បានអធិដ្ឋានថា **"ឱព្រះយេស៊ូអើយ! សូមប្រទានសេរីភាពមកក្នុងដួង ចិត្តរបស់ខ្ញុំផង គឺសេរីភាពដែលនាំឲ្យខ្ញុំមានចិត្តស្រឡាញ់អ្នកដទៃ មានចិត្តអាណិតមេត្តាអ្នកដទៃឲ្យខ្ញុំអស់នូវចិត្តហិង្សា ស្អប់គ្នា ច្រណែនគ្នា..."**។ តាមពិតសេចក្តីអធិដ្ឋានរបស់គាត់បង្ហាញថាគាត់មានបទពិសោធន៍យ៉ាងជ្រៅអំពីព្រះជាម្ចាស់ ដែលរំដោះមនុស្សយើងឲ្យរួចពីបាប និងរួចពីចំណងនានា និងណែនាំឲ្យយើងអាចទទួលស្វាគមន៍បងប្អូនឯទៀតៗនៅក្នុងសេរីភាព និងសេចក្តីស្រឡាញ់របស់ព្រះអង្គ និងឲ្យយើងបន្តធ្វើ

ដំណើរតាមព្រះគម្ពីរដែលបានណែនាំឲ្យ យើងទទួលព្រះយេស៊ូដែលមានព្រះជន្មរស់ឡើងវិញ។

ព្រះជាម្ចាស់របស់យើងមានព្រះនាមថា ព្រះជាម្ចាស់ដែលមានព្រះហឫទ័យមេត្តាករុណា ព្រះជាម្ចាស់ដែលមានព្រះជន្មគង់នៅ ព្រះជាម្ចាស់ដែលជាពន្លឺសម្រាប់ពិភពលោក ព្រះជាម្ចាស់ដែលរំដោះយើងព្រះជាម្ចាស់ដែលមានព្រះហឫទ័យប្រណីសន្ដោសដោយបានប្រទានព្រះយេស៊ូមកឲ្យយើង។ នៅថ្ងៃបុណ្យដែលព្រះយេស៊ូប្រសូតជាមនុស្ស ថ្ងៃនោះព្រះអង្គបន្តចងសម្ព័ន្ធមេត្រីថ្មីជាមួយយើង ដូចយើងបានស្តាប់នៅក្នុងអត្ថបទគម្ពីររ៉ូមថា **"ហេតុនេះហើយយើងដែលបានរួមស្លាប់ជាមួយព្រះអង្គ យើងក៏ដូចជាបានចូលនៅក្នុងផ្នូររួមជាមួយព្រះអង្គដែរ។ ព្រះគ្រីស្តទទួលព្រះជន្មថ្មីដោយសារសេរីរុងរឿងរបស់ព្រះបិតាយ៉ាងណា យើងក៏រស់នៅតាមរបៀបថ្មីយ៉ាងនោះដែរ"**។ ពួកស្ត្រីៗដែលបានរួមដំណើរជាមួយព្រះយេស៊ូបានឃើញផ្នូរទទេ លោកសិលាក៏បានឃើញផ្នូរទទេដែរតែពួកគេយល់មិនច្បាស់អំពីព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញនោះទេប៉ុន្តែគេយល់បន្តិចម្តងៗ។

ព្រះយេស៊ូគង់នៅជាមួយយើងអស់កាលជានិច្ច ព្រះជន្មថ្មីរបស់ព្រះអង្គណែនាំឲ្យយើងទាំងអស់រួមស្លាប់រួមរស់ជាមួយព្រះអង្គ ហេតុនេះហើយយើងទទួលជីវិតរួមជាមួយគ្នានេះជាដំណឹងល្អដែលយើងបានទទួលក្នុងយប់នេះ។ ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ ព្រះអង្គសម្តែងព្រះនាមរបស់ព្រះជាម្ចាស់ជាមេត្តាករុណាជាសេចក្តីស្រឡាញ់...។ ពន្លឺដែលព្រះ-ជាម្ចាស់បានបង្កើតកាលពីដើមដំបូងក្នុងភាពងងឹត ពន្លឺនោះបានយាងមកបំភ្លឺពិភពលោករបស់យើង និងបំភ្លឺភាពងងឹតក្នុងជីវិតរបស់យើងផ្ទាល់។ យប់នេះព្រះជាម្ចាស់ដែលជាព្រះសង្គ្រោះបានរំដោះយើងតាមរយៈពិធីជ្រមុជទឹក ដោយមានព្រះបន្ទូលមកយើងថា **"ចូរទៅចុះ ជំនឿរបស់អ្នកបានសង្គ្រោះអ្នកហើយ។ ចូរទៅចុះ ហើយឈប់ធ្វើអំពើបាប ចូរក្រោកឡើង ហើយមកទទួលជីវិតថ្មីពីខ្ញុំ..."**។ នេះជាព្រះបន្ទូលដែលយើងស្តាប់នៅយប់ដែលព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ ជាព្រះបន្ទូលដែលផ្តល់ពន្លឺ ផ្តល់ជីវិត ផ្តល់ការណែនាំឲ្យយើងជាសះស្បើយដោយសារព្រះជាម្ចាស់លើកលែងទោសឲ្យយើង។

បន្តិចទៀតបងប្អូននឹងទទួលពិធីជ្រមុជទឹក បន្តិចទៀតបងប្អូននឹងប្រកាសជំនឿសាជាថ្មីទាំងនឹកដល់ពិធីជ្រមុជទឹករបស់ខ្លួនផ្ទាល់ផង។ រាត្រីនេះយើងទាំងអស់គ្នានឹងចូលយ៉ាងជ្រៅទៅក្នុងអាថ៌កំបាំងនៃជីវិតដើម្បីទទួលព្រះពន្លឺដែលយាងមកពីស្ថានបរមសុខ។ យប់នេះមុខរបស់យើងទាំងអស់គ្នាដែលភ្លឺយ៉ាងត្រចះត្រចង់ គឺដោយសារពន្លឺនៃស្ថានបរមសុខដោយសារយើងបានរួមជាមួយព្រះយេស៊ូគ្រីស្ត។ ទឹកព្រះពរដែលហូរចេញពីរបួសរបស់ព្រះយេស៊ូគ្រីស្តណែនាំឲ្យយើងមានជីវិត។ ពន្លឺទៀនព្រះជ័យនឹងបំភ្លឺយើងពេញមួយឆ្នាំខាងមុខនេះ។ ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ ជាពិធីជប់លៀងនៃព្រះពន្លឺ ជប់លៀងនៃជីវិត ជប់លៀងនៃការព្យាបាលដួងចិត្តរបស់យើង ជាពិសេសក្នុងឆ្នាំព្រះមហាករុណាទិគុណនេះ សូមឲ្យយើងម្នាក់ៗដែលបានទទួលទឹកនិងឈាមពីស្នាមរបួសរបស់ព្រះយេស៊ូទៅជាអ្នកដែលសម្តែងធម៌មេត្តាករុណាយ៉ាងសកម្មដើម្បីឲ្យមនុស្សលោកសម្លឹងមើលព្រះគ្រីស្តលើឈើឆ្កាង។

នៅយប់ថ្ងៃព្រហស្បតិ៍យើងបានលាងជើងឲ្យគ្នាទៅវិញទៅមក យប់នោះព្រះយេស៊ូបានអញ្ជើញយើងឲ្យទៅលាងជើងដល់អស់អ្នកដែលកំពុងរងទុក្ខលំបាក ដល់អស់អ្នកដែលត្រូវរបួសពេញខ្លួនដើម្បីគេទទួលជីវិតថ្មីដែរ។ ព្រះជាម្ចាស់ជំរុញយើងឲ្យបង្ហាញព្រះហឫទ័យប្រណីសន្តោសរបស់ព្រះអង្គ ដោយឲ្យលើកលែងទោសយ៉ាងពិតប្រាកដមិនមែនគ្រាន់តែញញឹមតែក្នុងចិត្តនៅតែបន្តស្អប់គ្នា។ ព្រះជាម្ចាស់ប្រទានកម្លាំងថ្មីឲ្យយើងអាចលើកលែងទោសឲ្យគ្នាទៅវិញទៅមកដូចព្រះយេស៊ូបានលើកលែងទោសឲ្យយើងទាំងអស់គ្នាដែរ។ យប់នេះព្រះជាម្ចាស់អញ្ជើញយើងឲ្យសម្តែងជាក់ស្តែងអំពីពន្លឺរបស់ព្រះយេស៊ូគ្រីស្ត ឲ្យយើងម្នាក់ៗទទួលស្វាគមន៍អ្នកក្រីក្រ កុមារកំព្រា អ្នកពិការ...ឲ្យយើងទៅជា អ្នកព្យាបាលដល់អស់អ្នកដែលកំពុងមានរបួសទាំងកាយនិងចិត្ត ដល់អស់អ្នកដែលកំពុងអស់សង្ឃឹម ដល់អស់អ្នកដែលកំពុងវង្វេងក្នុងដំណើរជីវិតរបស់គេ ហើយដែលកំពុងរង់ចាំឲ្យយើងទៅជួយគេ ដើម្បីគេទទួលសេចក្តីសង្ឃឹមឡើងវិញ...។ កុំឲ្យយើងអធិដ្ឋានសម្រាប់គេតាមតែបបូរមាត់ ប៉ុន្តែដោយឲ្យយើងខិតខំធ្វើយ៉ាងជាក់ស្តែងវិញ។

ពិតមែន! ព្រះយេស៊ូគ្រីស្តយាងមករំដោះយើង ព្រះអង្គជាពន្លឺនៅក្នុងភាពងងឹត ក្នុងភាពកម្សត់ទុរគតនៃជីវិតរបស់យើង ក្នុងសង្គមរបស់យើងដែលមានហិង្សា សង្គ្រាម អំពើភេរវកម្ម អយុត្តិធម៌...។ ព្រះជាម្ចាស់ណែនាំឲ្យយើងទទួលព្រះគ្រីស្តទុកជាគ្រូពេទ្យដែលព្យាបាលកាយ វាចា និងចិត្តរបស់យើង។ ព្រះគ្រីស្តជាព្រះភ័ក្ត្ររបស់ព្រះបិតា។ ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញហើយ! ចូរមានចិត្តមេត្តាករុណាដូចព្រះបិតាមានព្រះហឫទ័យមេត្តាករុណា ! អាលេលូយ៉ា! អាលេលូយ៉ា!។

**"យើងនឹងប្រគល់ចិត្តគំនិតថ្មីឲ្យអ្នករាល់គ្នា ហើយយើងដាក់វិញ្ញាណថ្មីឲ្យអ្នករាល់គ្នាដែរ យើងនឹងជម្រះអ្នករាល់គ្នាឲ្យបានស្អាតបរិសុទ្ធផុតពីអំពើសៅហ្មងទាំងឡាយ"**

# ពិតមែនសេចក្តីស្លាប់មិនឈ្នះ ភាពងងឹតមិនឈ្នះ គឺជីវិតនិងពន្លឺដែលឈ្នះ

Really, death and darkness did not win.
Life and light have won

អត្ថបទទី១៖ កក ១០, ៣៤ក.៣៧-៤៣
អត្ថបទទី២៖ កូឡ ៣, ១-៤
ដំណឹងល្អ៖ លក ២៤, ១៣-៣៥

ក្នុងឆ្នាំមហាករុណាទិគុណនេះ យើងរួមគ្នាដើម្បីប្រារព្ធបុណ្យព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ ជាពេលវេលាមួយពិសេស ដែលព្រះសហគមន៍បានរៀបចំខ្លួនពី៤០ថ្ងៃកន្លងមក ដើម្បីទទួលដំណឹងល្អដែលយើងបានស្តាប់យប់មិញ **"ពិតមែនជីវិតនិងពន្លឺដែលមកពីព្រះជាម្ចាស់ឈ្នះលើសេចក្តីស្លាប់និងភាពងងឹត"**។

ទូទាំងពិភពលោកទាំងមូល យប់មិញយើងបានដុតភ្លើងដើម្បីនឹកឃើញដល់ព្រះយេស៊ូដែលមានព្រះជន្មរស់ឡើងវិញ ទាំងយើងបានច្រៀងកោតសរសើរព្រះអង្គផង។ យប់មិញប្រសិនបើយើងជិះយន្តហោះយើងអាចមើលឃើញពិភពលោករបស់យើងដូចជាពន្លឺមួយ ដោយសារគ្រីស្តបរិស័ទទូទាំងពិភពលោកទាំងមូល ម្នាក់ៗកាន់ទៀនតូចមួយ ដើម្បីបង្ហាញថាព្រះយេស៊ូជាព្រះពន្លឺដើម្បីបំភ្លឺភាពងងឹត។ យប់មិញយើងមានបទពិសោធអំពីសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ចំពោះយើង។

បើយើងគិតមួយភ្លែត នោះដឹងថាជីវិតរបស់មនុស្សមានកំណត់ មានពេលកើតនិងមានពេលស្លាប់។ ប៉ុន្តែយប់មិញយើងបានស្តាប់ឮថាព្រះយេស៊ូសោយទិវង្គតហើយព្រះអង្គមាន

---

អភិបូជាថ្ងៃបុណ្យចម្លងនៅស្អាង
ថ្ងៃទី ២៧ មិនា ២០១៦

ព្រះជន្មរស់ឡើងវិញ។ នៅថ្ងៃនេះនេះទៀត យើងស្តាប់ឮថា នៅក្នុងផ្នូរឥតមានព្រះសពរបស់ព្រះយេស៊ូទេ នោះណែនាំឲ្យយើងយល់ថា ពិតមែនព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ។ សូម្បីបីក្រុមគ្រីស្តទូតពីដើមគេមិនយល់សេចក្តីនេះភ្លាមៗទេ តែយើងមានសំណាងដោយសារយើងមានសាក្សីពីក្រុមគ្រីស្តទូតកាល ២.០០០ឆ្នាំមុន និងក្រោយមកមានសាក្សីដែលបំភ្លឺគ្នាទៅវិញទៅមក ដើម្បីបង្ហាញថា ពិតមែនព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ។

ថ្ងៃនេះយើងជួបជុំគ្នានៅទីនេះ ដោយសារយើងជឿថា ព្រះយេស៊ូមានព្រះជន្មថ្មីដ៏រុងរឿង ព្រះអង្គគង់នៅជាមួយយើងជានិច្ច ដូចសន្តៈប៉ូលបានមានប្រសាសន៍ថា **"ប្រសិនបើព្រះយេស៊ូគ្មានព្រះជន្មរស់ឡើងវិញ ជំនឿរបស់យើងគ្មានអត្ថន័យទេ"។** ព្រះយេស៊ូបានសោយទិវង្គតតែព្រះអង្គមានព្រះជន្មរស់ឡើងវិញ នេះជាសេចក្តីសង្ឃឹមសម្រាប់ជីវិតរបស់យើង។ ដូច្នេះដំណើរជីវិតរបស់យើងលែងគិតអំពីសេចក្តីស្លាប់ជាទីបញ្ចប់នៃជីវិត តែយើងយល់ថា ព្រះយេស៊ូបានបើកទ្វារនៃភាពងងឹត ទ្វារនៃសេចក្តីស្លាប់ដើម្បីឲ្យយើងចូលនៅក្នុងពន្លឺ ហើយឲ្យយើងទទួលជីវិតអស់កល្បជានិច្ចជាមួយព្រះយេស៊ូ។

ថ្ងៃនេះយើងមានទារកបីនាក់ដែលទទួលអគ្គសញ្ញាជ្រមុជទឹក ដើម្បីគេចូលរួមជាមួយយើងនៅក្នុងសេចក្តីសង្ឃឹម និងសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់។ ដូច្នេះនៅក្នុងឆ្នាំធម៌មេត្តាករុណានេះជាពេលវេលាម្តងទៀតដើម្បីឲ្យយើងសម្លឹងមើល របៀបដែលព្រះជាម្ចាស់ស្រឡាញ់យើងរបៀបព្រះជាម្ចាស់ចង់ឲ្យយើងចូលរួមជាមួយព្រះអង្គ ដើម្បីទទួលជីវិតអស់កល្បជានិច្ច។ ពេលខ្ញុំធ្វើអគ្គសញ្ញាជ្រមុជទឹកមានន័យថា កូនទាំងបីនាក់ភ្ជាប់ជាមួយព្រះយេស៊ូអស់កល្បជានិច្ច។ សម្រាប់យើងដែលបានទទួលអគ្គសញ្ញាជ្រមុជទឹកហើយ ក៏ដូចគ្នាដែរគឺយើងភ្ជាប់ជាមួយព្រះយេស៊ូអស់មួយជីវិត។ នេះណែនាំឲ្យយើងមានកម្លាំងនិងអំណរសប្បាយ ប៉ុន្តែយើងត្រូវការនឹកឃើញដល់តួនាទីរបស់យើងជាគ្រីស្តបរិស័ទ ជាពិសេសក្នុងឆ្នាំមហាករុណាទិគុណនេះគឺព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញមានន័យថា ព្រះយេស៊ូអញ្ជើញយើងឲ្យយើងទៅជាសាក្សីនៃជីវិតដ៏បរិបូណ៌ដែលយើងបានទទួលពីព្រះជាម្ចាស់ ជាសាក្សីដែលសម្តែងបន្ទាល់អំពីធម៌

មេត្តាករុណារបស់ព្រះអង្គ។

កាលពីយប់ថ្ងៃព្រហស្បតិ៍ យើងបានលាងជើងឲ្យគ្នាទៅវិញទៅមក ពេលនោះព្រះយេស៊ូអញ្ជើញយើងឲ្យលាងជើងមនុស្សដែលមានជើងមិនស្អាត ជើងរបស់អ្នកក្រីក្រ ជើងរបស់អ្នកអស់សង្ឃឹម...។ ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ ព្រះអង្គអញ្ជើញយើងឲ្យមានចិត្តលើកលែងទោសដល់បងប្អូនឯទៀតៗយ៉ាងពិតប្រាកដមែនដ្បិតជួនកាលយើងបានទទួលការលើកលែងទោសពីព្រះយេស៊ូហើយ តែយើងនៅបន្តខឹងគេ ស្អប់គេ។ ដូច្នេះពេលនេះជាឱកាសមួយឲ្យយើងទៅជួបអ្នកដែលយើងស្អប់ ជួបអ្នកដែលយើងខឹងដើម្បីនិយាយថា **"ខ្ញុំសូមទោសនិងខ្ញុំលើកលែងទោសឲ្យអ្នកហើយ"** ដើម្បីកុំឲ្យយើងធ្វើជាមនុស្សដែលលើកលែងទោសតែលើបបូរមាត់។ ក្នុងឆ្នាំព្រះមហាករុណាទិគុណនេះ ព្រះជាម្ចាស់បានអញ្ជើញយើងឲ្យទៅជាពន្លឺមួយយ៉ាងពិសេសដើម្បីបំភ្លឺបងប្អូននៅក្នុងស្រុកស្អាងរបស់យើង។

យប់មិញ យើងបានដុតភ្លើង ហើយម្នាក់ៗបានរក្សាទុកទៀនតូចមួយនោះសម្រាប់ពេញមួយឆ្នាំខាងមុខនេះ។ ដូច្នេះសូមឲ្យយើងជាគ្រីស្តបរិស័ទក្នុងមណ្ឌលសកម្មភាពទន្លេបាសាក់ ទៅជាពន្លឺមួយយ៉ាងធំដើម្បីបំភ្លឺបងប្អូនដែលវង្វេងដែលពិបាកចិត្តដែលគ្មានពន្លឺនៅក្នុងជីវិត និងសូមឲ្យយើងគិតតើត្រូវធ្វើដូចម្តេចដើម្បីទៅជាពន្លឺមួយយ៉ាងស្អាត ជាពិសេសសម្រាប់មនុស្សនៅក្នុងផ្សារស្អាងយើងនេះដែលមានមនុស្សជាច្រើនចេញចូល។ ឆ្នាំព្រះមហាករុណាទិគុណនេះព្រះជាម្ចាស់អញ្ជើញឲ្យយើងធ្វើជាគ្រូពេទ្យដើម្បីព្យាបាលអ្នកជំងឺ ព្រះយេស៊ូមានព្រះបន្ទូលថា **"ខ្ញុំយាងមកដើម្បីណែនាំឲ្យអ្នកបាបមានជីវិតថ្មី រីឯអ្នកដែលមានសុខភាពល្អគេមិនត្រូវការគ្រូពេទ្យទេ"**។ ព្រះយេស៊ូជាគ្រូពេទ្យព្យាបាលរបួសដែលមាននៅក្នុងចិត្តមានដូចជាការពិបាកចិត្ត ភាពអស់សង្ឃឹម និងអ្វីៗទាំងអស់ដែលណែនាំឲ្យយើងពិបាកនៅក្នុងជីវិតរបស់យើង។

ក្នុងឆ្នាំមហាករុណាទិគុណនេះ ព្រះជាម្ចាស់ឲ្យយើងធ្វើជាគ្រូពេទ្យពិសេសដែលអាចព្យាបាលអ្នកដទៃ ដោយឱសថនៃសេចក្តីស្រឡាញ់ នៃសេចក្តីសង្ឃឹមដែលយើងបានទទួលពីព្រះជាម្ចាស់នៅរាត្រីបុណ្យចម្លង។ ឆ្នាំនេះក្រុមសង្គហៈរបស់យើងត្រូវមានទាំងពូ ទាំងមីង

ទាំងលោកយាយ ទាំងលោកតា ទាំងយុវជន ដើម្បីឲ្យទៅជាកម្លាំងមួយដ៏ធំ ដែលអាចទទួលរ៉ាប់រងការងារបានច្រើន។ ចូរឲ្យយើងរួមគ្នាទៅជាគ្រូពេទ្យសម្រាប់ព្យាបាលបងប្អូនឯទៀតៗ ដែលកំពុងរងទុក្ខលំបាក ដែលមានទាំងពុទ្ធបរិស័ទ ទាំងគ្រីស្តបរិស័ទ ទាំងបងប្អូនខ្មែរ ទាំងបងប្អូនវៀតណាម និងមនុស្សទាំងអស់ដែលត្រូវការយើង។ យើងជាព្រះសហគមន៍យើងជាគ្រូពេទ្យតាមរបៀបព្រះយេស៊ូដើម្បីព្យាបាលបងប្អូនឯទៀតៗ ដែលកំពុងមានទុក្ខលំបាក។ ដោយសារហេតុនេះ យើងអាចប្រកាសថាគ្រីស្តបរិស័ទយើងមានសេចក្តីស្រឡាញ់ និងមានកម្លាំងពោរពេញដោយសារព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ។

ថ្ងៃនេះយើងខ្ញុំសូមអរព្រះគុណព្រះជាម្ចាស់ជាព្រះបិតា សូមព្រះអង្គមេត្តាបំភ្លឺជីវិតរបស់យើងខ្ញុំ រំដោះយើងខ្ញុំ ព្យាបាលយើងខ្ញុំ និងប្រោសយើងខ្ញុំឲ្យទទួលជីវិតថ្មីរួមជាមួយព្រះយេស៊ូ ដែលជាព្រះភ័ក្ត្ររបស់ព្រះបិតា ជាមួយព្រះយេស៊ូដែលជាធម៌មេត្តាករុណារបស់ព្រះបិតា និងនៅថ្ងៃនេះសូមឲ្យយើងខ្ញុំទទួលជីវិតថ្មីរួមជាមួយកូនៗទាំងបីនាក់ តាមរយៈព្រះយេស៊ូគ្រីស្ត ដែលមានព្រះជន្មរស់ឡើងវិញ!។

**"ខ្ញុំយាងមកដើម្បីណែនាំឲ្យអ្នកបាបមានជីវិតថ្មី រីឯអ្នកដែលមានសុខភាពល្អគេមិនត្រូវការគ្រូពេទ្យទេ"**

# ទុកចិត្តលើព្រះជាម្ចាស់ដោយយកគំរូតាមសន្តយ៉ូហាន ប៉ូលទីពីរ និងសន្តីហ្វូស្ទីណា

We trust God with Saint John Paul II
and St. Faustina

---

អត្ថបទទី១៖ កក ៤, ១៣-២១
ដំណឹងល្អ៖ មក ១៦, ៩-១៥

ថ្ងៃនេះ យើងនឹកគិតដល់សន្តីហ្វូស្ទីណា ដែលសម្តេចប៉ាបយ៉ូហានប៉ូលទី២ បានតែងតាំងជាសន្តីនៅឆ្នាំ២០០០។ សម្តេចបានមានប្រសាសន៍ថាចាប់ពីពេលនេះតទៅ រៀងរាល់ថ្ងៃអាទិត្យបន្ទាប់បុណ្យចម្លង សូមឲ្យយើងគោរពព្រះហឫទ័យមេត្តាករុណារបស់ព្រះជាម្ចាស់ដោយ មានតាំងរូបព្រះយេស៊ូដែលបងស្រីហ្វូស្ទីណាបានគូរតាមរបៀបដែលព្រះយេស៊ូ បានបំភ្លឺគាត់ និងតាមរយៈការអធិដ្ឋាននោះ ណែនាំឲ្យយើងមានសង្ឃឹមថែមទៀតក្នុងជីវិតថ្មីដែលយើងបានទទួលតាមរយៈព្រះលោហិតរបស់ព្រះយេស៊ូ ដែលហូរស្រោចស្រពក្នុងខ្លួនរបស់យើង និងតាមរយៈទឹកដែលជម្រះចិត្តគំនិតរបស់យើងជាមួយនឹងពាក្យអធិដ្ឋានមួយឃ្លាថា "ឱព្រះយេស៊ូអើយ ទូលបង្គំទុកចិត្តលើព្រះអង្គខ្លាំងណាស់"។

ថ្ងៃនេះជាខួប១៦ឆ្នាំ ដែលសម្តេចប៉ាបយ៉ូហានប៉ូលទី២បានទទួលមរណភាព ជាឱកាសមួយឲ្យយើងចូលនៅក្នុងគំនិតរបស់សម្តេចប៉ាបយ៉ូហានប៉ូលទី២ ដែលទាក់ទងនឹង ព្រះហឫទ័យមេត្តាករុណារបស់ព្រះជាម្ចាស់។ បងស្រីហ្វូស្ទីណាជាលេខានៃព្រះហឫទ័យមេត្តាករុណារបស់ព្រះជាម្ចាស់ ឯសម្តេចប៉ាបយ៉ូហានប៉ូលទី២ ជាគ្រីស្តទូតនៃព្រះហឫទ័យមេត្តាករុណារបស់ព្រះជាម្ចាស់។ អស់មួយជីវិតរបស់សម្តេចប៉ាបយ៉ូហានប៉ូលទី២ លោកបានយកចិត្តទុកដាក់នាំ

---

អភិបូជាទិវានៃការត្រាស់ហៅ
ថ្ងៃទី០២ មេសា ២០១៦

យកសេចក្តីស្រឡាញ់ របស់ព្រះជាម្ចាស់ទៅគ្រប់ទីកន្លែងនៅក្នុងពិភពលោកទាំងមូល។ សញ្ញាមួយដ៏អស្ចារ្យ គឺសម្តេចប៉ាបត្រូវទទួលមរណភាពតាំងពីយូរខែ មុនលោកទទួលមរណភាព ដ្បិតថាលោកមានអាការៈខ្សោយទៅៗយ៉ាងខ្លាំងតាំងពីឆ្នាំ២០០៣ ប៉ុន្តែព្រះជាម្ចាស់បានត្រាស់ហៅឲ្យលោកទទួលមរណភាព នៅថ្ងៃដែលយើងគោរពព្រះហឫទ័យមេត្តាករុណារបស់ព្រះជាម្ចាស់ ដូចលោកអភិបាលអេមីលដែរ ព្រះជាម្ចាស់បានត្រាស់ហៅឲ្យលោកទទួលមរណភាពបន្ទាប់ពីលោកបានទទួលព្រះកាយព្រះគ្រីស្តហើយ។

មុនទទួលមរណភាព សម្តេចប៉ាបយ៉ូហានប៉ូលទី២ បានសរសេរអត្ថបទខ្លីមួយដើម្បីលោកអាននៅថ្ងៃដែលព្រះសហគមន៍យើងគោរពព្រះហឫទ័យមេត្តាករុណារបស់ព្រះជាម្ចាស់ ដែលមានខ្លឹមសារទាំងស្រុងថា**"ព្រះយេស៊ូដែលមានព្រះជន្មរស់ឡើងវិញប្រទានព្រះអំណោយទានមួយយ៉ាងពិសេសដល់មនុស្សលោកយើង ដែលជួនកាលវង្វេងផ្លូវ ជួនកាលនៅក្រោមអំណាចនៃសេចក្តីអាក្រក់ ជួនកាលមានការភ័យខ្លាចក្នុងចិត្ត និងមានចិត្តចង្អៀតចង្អល់អាត្មានិយម។ ព្រះជាម្ចាស់បានប្រទានអំណោយទានមួយយ៉ាងពិសេស គឺសេចក្តីស្រឡាញ់របស់ព្រះអង្គដែលលើកលែងទោស សេចក្តីស្រឡាញ់របស់ព្រះអង្គដែលសម្រុះសម្រួលមនុស្សលោក សម្រុះសម្រួលព្រលឹងរបស់យើង ដើម្បីឲ្យយើងរកឃើញសេចក្តីសង្ឃឹម សេចក្តីស្រឡាញ់របស់ព្រះអង្គដែលណែនាំឲ្យយើងប្រែចិត្តគំនិតទទួលសេចក្តីសុខ។ ពិតមែនពិភពលោករបស់យើងមានសេចក្តីត្រូវការតែមួយ គឺទទួលស្វាគមន៍ព្រះហឫទ័យមេត្តាករុណារបស់ព្រះជាម្ចាស់។ ថ្ងៃនេះព្រះយេស៊ូមានព្រះបន្ទូលដល់ក្រុមគ្រីស្តទូតថា សូមឲ្យអ្នករាល់គ្នាបានប្រកបដោយសេចក្តីសុខសាន្ត សេចក្តីសុខសាន្តនេះយើងរកឃើញនៅក្នុងព្រះហឫទ័យមេត្តាករុណារបស់ព្រះជាម្ចាស់"**។

តាមអត្ថបទនេះ សន្តៈយ៉ូហានប៉ូលទី២ បានប្រាប់ដល់យើងម្នាក់ៗគឺ **"មានតែព្រះហឫទ័យមេត្តាករុណារបស់ព្រះជាម្ចាស់ប៉ុណ្ណោះ ដែលណែនាំឲ្យពិភពលោករកឃើញសេចក្តីសង្ឃឹម និងសេចក្តីសុខសាន្តបាន"**។ នេះជាបទពិសោធន៍របស់សម្តេចប៉ាបផ្ទាល់ ដែលលោកធ្លាប់បានរស់នៅក្នុងភាពងងឹតនៃពិភពលោក ក្នុងសង្គ្រាមលោកលើកទី២។ កាលនោះលោកបាន

ជួបទុក្ខលំបាកនិងការឈឺចាប់យ៉ាងច្រើន។ នៅពេលអាយុប្រាំបួនឆ្នាំ ម្ដាយស្លាប់ចោល នៅអាយុ១២ឆ្នាំ បងតែម្នាក់របស់លោកបានស្លាប់ នៅពេលអាយុ២១ឆ្នាំឪពុកលោកបានស្លាប់ទៀត។

នៅសម័យនោះ ប្រទេសប៉ូឡូញបានជាប់ទាក់ទងនឹងសង្គ្រាមលោកលើកទីពីរ។ សង្គ្រាមនេះបានសម្លាប់ជីវិតមនុស្សរាប់លាននាក់ ជាពិសេសនៅប្រទេសប៉ូឡូញ មានសាសនិកយូដាប្រមាណជាងប្រាំមួយលាននាក់ ត្រូវបានទាហានអាឡឺម៉ង់ប្រមូលយកទៅដាក់នៅក្នុងជំរុំដើម្បីសម្លាប់។ ទីក្រុងក្រាការនេះ ជាកន្លែងដែលសម្ដេចប៉ាបយ៉ូហានប៉ូលទី២ បានក្លាយទៅជាលោកអភិបាល។ យើងជិះរថភ្លើងប្រហែលមួយម៉ោងពីទីក្រុងនោះយើងនឹងទៅដល់ជំរុំមួយរបស់ទាហានអាឡឺម៉ង់ ដែលទីនោះគេបានសម្លាប់មនុស្សរាប់លាននាក់។ ដូច្នេះមានន័យថាសម្ដេចប៉ាបបានឃើញផ្ទាល់ភ្នែកពីអំពើអាក្រក់របស់មនុស្សយើង។

ពេលសង្គ្រាមលោកលើកទីពីរបានបញ្ចប់ប្រទេសប៉ូឡូញ និងប្រទេសសូវៀត បានធ្លាក់ចូលក្នុងប្លុកកុម្មុយនីស្ដ ដែលមានទស្សនៈនយោបាយបិទសិទ្ធិសេរីភាព របស់មនុស្ស គឺមនុស្សគ្មានសិទ្ធិកាន់សាសនា គ្មានសិទ្ធិរីកចម្រើនតាមរបៀបផ្ទាល់ខ្លួនទេ។ សម្ដេចប៉ាប បានចូលនៅក្នុងប្រវត្តិសាស្ត្រដ៏ជូរចត់នេះ។ នៅសម័យនោះទេវវិទ្យាល័យ ដែលសម្ដេចចូលរៀន គឺស្ថិតនៅក្រោមដី ដ្បិតថាយើងមិនអាចបង្ហាញពីកន្លែងដែលអប់រំនិស្សិតឲ្យទៅជាបូជាចារ្យបានទេ។ ដូច្នេះនៅក្នុងជីវិតរបស់សម្ដេចប៉ាបយ៉ូហានប៉ូលទី២ បានជួបទាំងមរណភាពរបស់ក្រុមគ្រួសារ បានជួបទាំងសង្គ្រាមលោក និងបានជួបទាំងរបបកុម្មុយនីស្ដដែរ។ សម្ដេចបានឃើញនូវអំពើអាក្រក់ទាំងឡាយ ដែលហូរចេញពីដួងចិត្តរបស់មនុស្សយើង។

នៅបុរីវ៉ាទីកង់ក្នុងឆ្នាំ១៩៨១ ថ្ងៃទី១៣ ខែឧសភា វេលាម៉ោង៩ព្រឹក ពេលសម្ដេចប៉ាបចេញទៅទទួលស្វាគមន៍បងប្អូនដែលមកសូមជួប ពេលនោះមានគេលួចធ្វើឃាតព្រះអង្គ។ គ្រាប់កាំភ្លើងបានផ្លុះចូលទៅជិតដល់បេះដូង នៅខ្វះតែមួយមីល្លីម៉ែត្រទៀតប៉ុណ្ណោះ ដែលហាក់បីដូចជាព្រះនាងម៉ារីបានជួយសង្គ្រោះជីវិតព្រះអង្គ ដ្បិតថ្ងៃនោះជាថ្ងៃបុណ្យគោរពព្រះ នាងម៉ារីនៅហ្វាទីម៉ា។ ក្នុងរបួសដ៏ឈឺចាប់នោះ សម្ដេចប៉ាបយ៉ូហានប៉ូលទីពីរ បានរកឃើញសេចក្ដី

ក្លាហាននៅក្នុងព្រះហឫទ័យមេត្តាករុណារបស់ព្រះជាម្ចាស់។ ក្នុងការឈឺចាប់ និងទុក្ខលំបាកបែបនេះលោកនៅតែអធិដ្ឋានជានិច្ចថា **"ឱព្រះយេស៊ូអើយ! ទូលបង្គំទុកចិត្តលើព្រះអង្គខ្លាំងណាស់!"**។ ដោយមានរបៀបរស់នៅបែបនេះហើយ ទើបលោកក្លាយទៅជាសម្ដេចប៉ាបមួយអង្គដ៏អស្ចារ្យ។ នៅពេលលោកបង្ហាញខ្លួន និងបន្ទាប់ពីសន្តៈសិលាបាន បដិសេធព្រះអង្គបីដងថា "ខ្ញុំមិនស្គាល់អ្នកនេះទេ"។

ថ្ងៃនេះយើងនឹកដល់តួនាទីជាសម្ដេចប៉ាប ដែលបន្តមុខងារពីព្រះយេស៊ូ។ ដំបូងឡើយព្រះយេស៊ូដែលមានព្រះជន្មរស់ឡើងវិញ ព្រះអង្គបានយាងទៅជួបសាវ័ករបស់អង្គម្ដងទៀតនៅឯមាត់សមុទ្រកាលីឡេ។ ពេលនោះព្រះអង្គបានសួរទៅសន្តៈសិលាបីដងថា **"តើអ្នកស្រឡាញ់ខ្ញុំឬទេ?"**។ សន្តៈសិលាព្រួយចិត្តដោយដឹងថាខ្លួនធ្លាប់ក្បត់នឹងព្រះយេស៊ូតែលោកក៏ដឹងដែរថាព្រះយេស៊ូដែល មានព្រះជន្មរស់ឡើងវិញបានលើកលែងទោសឲ្យលោកដោយបានសួរមកលោកបីដងថា **"តើអ្នកស្រឡាញ់ខ្ញុំឬទេ?"** ទាំងដឹងខ្លួនថែមទៀតថា ព្រះយេស៊ូបានតែងតាំងលោកឲ្យទៅជាមេដឹកនាំព្រះសហគមន៍របស់ព្រះអង្គទៀតផង។ ដោយហេតុនេះហើយ ព្រះសហគមន៍របស់យើងបានចាក់ឫសនៅលើព្រះយេស៊ូ ដែលលើកលែងទោសឲ្យលោកសិលាចាក់ឫសលើព្រះហឫទ័យមេត្តាករុណារបស់ព្រះជាម្ចាស់ ដែលបានប្រោសលោកសិលាឲ្យទៅជាមេដឹកនាំព្រះសហគមន៍ដំបូង គឺជាសម្ដេចប៉ាប ដែលបានបញ្ជូនបន្តមុខងារនេះរហូតមកដល់សម្ដេចប៉ាបយ៉ូហានប៉ូលទី២ ឲ្យណែនាំពិភពលោកទាំងមូលរកឃើញសេចក្តីសុខសាន្ត តាមរយៈព្រះហឫទ័យមេត្តាករុណារបស់ព្រះជាម្ចាស់។

នៅឆ្នាំ១៩៧៨ ជាលើកដំបូងដែលសម្ដេចប៉ាបយ៉ូហានប៉ូលទី២ បានជួបជាមួយថ្នាក់ដឹកនាំពិភពលោកទាំងមូលនៅវិសាលវិហារសន្តៈសិលា ពេលនោះព្រះអង្គគូសសង្កត់យ៉ាងច្បាស់ថា **"កុំខ្លាចអី! សូមបើកទ្វារថ្វាយព្រះយេស៊ូគ្រីស្ត សូមបើកទ្វារដែលចងដៃ ចងជើង និង ដែលបិទផ្លូវសេរីភាពថ្វាយព្រះយេស៊ូ សូមបើកទ្វារនៃនយោបាយ នៃសេដ្ឋកិច្ច នៃវប្បធម៌នីមួយៗថ្វាយព្រះយេស៊ូ និងយាងព្រះអង្គចូលនៅក្នុងគ្រប់វិស័យនៃពិភពលោក..."** ដ្បិតមានតែព្រះយេស៊ូ

គ្រីស្តដែលមានព្រះជន្មគង់នៅទេ ដែលអាចសង្គ្រោះយើងបាន ដែលអាចបង្ហាញព្រះហឫទ័យមេត្តាករុណារបស់ព្រះជាម្ចាស់បាន។ នៅពេលនោះពិភពលោកទាំងមូលភ្ញាក់ផ្អើលយ៉ាងខ្លាំងដោយសារគេដឹងថា សម្តេចប៉ាបមកពីប្រទេសកុម្មុយនីស្ត ដែលគ្មានសិទ្ធិសេរីភាព ដែលគេបិទទ្វារមិនព្រមយាងព្រះយេស៊ូចូលទេ។ ប្រទេសទីមួយដែលសម្តេចប៉ាបយ៉ូហានប៉ូលទី២ បានយាងទៅសួរសុខទុក្ខ គឺម៉ិចស៊ិកកូ ជាប្រទេសដែលមានគ្រីស្តបរិស័ទច្រើន ប៉ុន្តែត្រូវគេបិទសេរីភាព។ សម្តេចប៉ាបបានស្តីបន្ទោសជាខ្លាំងដល់រដ្ឋាភិបាល ដើម្បីឲ្យគេភ្ញាក់ស្មារតី ដោយជាស់តឿនថា មានតែព្រះយេស៊ូដែលមានព្រះជន្មគង់នៅទេ ដែលបំភ្លឺផ្លូវរបស់យើង។

សារលិខិតទីពីរដែលសម្តេចប៉ាបបានសរសេរជាផ្លូវការបង្ហាញថា **"ព្រះបិតាជាធម៌មេត្តាករុណា"**។ សម្តេចបានអនុវត្តនូវធម៌មេត្តាករុណារបស់ព្រះបិតាជាប្រចាំ នៅក្នុងការរស់នៅផ្ទាល់ខ្លួនរបស់ព្រះអង្គ។ ជាក់ស្តែងព្រះអង្គបានយាងទៅមន្ទីរឃុំឃាំងដោយផ្ទាល់ ដើម្បីលើកលែងទោសឲ្យឃាតករដែលបានលួចធ្វើឃាតព្រះអង្គ។ សម្តេចប៉ាបក៏បានយាងទៅក្នុងពិភពលោកទាំងមូល បានណែនាំឲ្យព្រះបន្ទូលរបស់ព្រះជាម្ចាស់ យាងចូលយ៉ាងជិតស្និទជាមួយនឹងគ្រីស្តបរិស័ទ និងជាមួយមនុស្សលោកដែរ។ ព្រះអង្គបានចាប់ផ្តើមបង្កើតទិវាយុវជនពិភពលោក ដើម្បីឲ្យយុវជនបានជួបជុំគ្នា ជាឧទាហរណ៍នៅឆ្នាំ១៩៩៧ ទិវាយុវជនពិភពលោកបានចាប់ផ្តើមនៅប្រទេសបារាំង ដែលមានជនជាតិបារាំងមួយចំនួនធំនឹកគិតថា នឹងមិនមានយុវជនយ៉ាងច្រើនចូលរួមឡើយ។ តែផ្ទុយទៅវិញគេភ្ញាក់ផ្អើលយ៉ាងខ្លាំងដោយសារមានមនុស្សជាច្រើនចូលរួម។ នៅឆ្នាំ១៩៨៨ សម្តេចប៉ាបបានយាងទៅក្រុងគ្រាស់ស្បួរ ពេលនោះមានយុវជនប្រាំមួយម៉ឺននាក់មកជួបជុំគ្នានៅពហុកីឡដ្ឋាន។ សម្តេចប៉ាបបានសួរទៅយុវជនថា **"តើយើងអាចស្រឡាញ់សាកល្បងឬទេ? តើយើងកើតមកសាកល្បងឬទេ? តើយើងស្លាប់សាកល្បងឬទេ?។ គ្មានការសាកល្បងទេពេលយើងស្រឡាញ់គឺឲ្យយើងស្រឡាញ់តែម្តង"**។ សម្តេចប៉ាបយ៉ូហានប៉ូលទី២ បានណែនាំឲ្យយើងចូលយ៉ាងជ្រៅនៅក្នុងព្រះហឫទ័យមេត្តាករុណារបស់ព្រះជាម្ចាស់។

ថ្ងៃនេះយើងបានស្តាប់ព្រះយេស៊ូដែលមានព្រះបន្ទូលមកយើងថា **"អ្នកជឿមកពីអ្នកបានឃើញខ្ញុំ អ្នកណាជឿដោយឥតបានឃើញសោះ អ្នកនោះមានសុភមង្គលហើយ"**។ សម្រាប់យើងដែលជាគ្រីស្តបរិស័ទថ្ងៃនេះព្រះយេស៊ូចាត់ យើងឲ្យយើងទៅប្រកាសអំពីព្រះហឫទ័យមេត្តាករុណារបស់ព្រះជាម្ចាស់ នៅក្នុងសង្គមរបស់យើងដែលនៅឆ្ងាយពីព្រះជាម្ចាស់។ នៅសតវត្សទី២១នេះ ជំងឺធំបំផុតរបស់មនុស្សយើង គឺជំងឺ "មិនអើពើអ្នកដទៃ"។ ថ្ងៃនេះព្រះយេស៊ូមានព្រះបន្ទូលមកយើងម្នាក់ៗថា **"ដូចព្រះបិតាបានចាត់ខ្ញុំឲ្យមកយ៉ាងណា ខ្ញុំក៏ចាត់អ្នករាល់គ្នាឲ្យទៅយ៉ាងនោះដែរ"** គឺព្រះអង្គចាត់យើងឲ្យទៅយកចិត្តទុកដាក់ជាមួយបងប្អូនឯទៀតៗ ដែល កំពុងជួលនៅតាមផ្លូវ ឲ្យយើងទៅយកចិត្តទុកដាក់បម្រើបងប្អូនឯទៀតៗ ដូចព្រះយេស៊ូបានបម្រើដែរ។ សម្រាប់ឆ្នាំព្រះមហាករុណាទិគុណនេះ ព្រះយេស៊ូបានចាត់យើងឲ្យធ្វើជាសាក្សីនៃការលើកលែងទោសឲ្យគ្នាទៅវិញទៅមក។ យើងជាគ្រីស្តបរិស័ទកាតូលិក សូមឲ្យយើងទុកពាក្យ **"ឱព្រះយេស៊ូអើយ! ខ្ញុំទុកចិត្តលើព្រះអង្គហើយ!"** នេះសម្រាប់ណែនាំការរស់នៅប្រចាំថ្ងៃរបស់យើង ដើម្បីយើងមានកម្លាំងក្នុងការរស់នៅ។

ថ្ងៃនេះតាមរយៈសន្តៈយ៉ូហានប៉ូលទី២ តាមរយៈសន្តីហ្វូស្ទីណា យើងខ្ញុំសូមទូលអង្វរព្រះជាម្ចាស់សម្រាប់យុវជនយុវនារី សម្រាប់បងប្អូនដែលកំពុងស្វែងយល់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ឲ្យពួកគេទៅជាលេខា ទៅជាគ្រីស្តទូតនៃព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គសម្រាប់ព្រះសហគមន៍ និងសម្រាប់សង្គមរបស់យើងនៅពេលបច្ចុប្បន្ននេះ។ សូមឲ្យយើងខ្ញុំម្នាក់ៗរកឃើញព្រះហឫទ័យមេត្តាករុណារបស់ព្រះជាម្ចាស់ ដែលឃាងចូលនៅគ្រប់ទីកន្លែង ដូចទឹកភ្លៀងដែលជ្រាបចូលទៅក្នុងដី។ សូមឲ្យយើងខ្ញុំដឹងថាព្រះអង្គគង់នៅជាមួយយើងខ្ញុំជាព្រះសហគមន៍។

# សូមឲ្យយើងធ្វើជាសាក្សីជាក់ស្តែងអំពីវត្តមានព្រះជាម្ចាស់

Let us be true witnesses of God's presence

អត្ថបទទី១៖ កក ៥, ២៧-៣៣
ដំណឹងល្អ៖ យហ ៣, ៣១-៣៦

ថ្ងៃនេះ យើងជួបជុំគ្នាអធិដ្ឋានសម្រាប់ការត្រាស់ហៅ។ យើងរួមគ្នាស្តាប់សន្តៈសិលា ដែលជាបុព្វបុរសខាងជំនឿរបស់យើងមានប្រសាសន៍ថា **"ព្រះជាម្ចាស់ដែលពោរពេញដោយព្រះហឫទ័យប្រណីសន្តោស ព្រះអង្គបានប្រោសលោកយេស៊ូ ដែលអស់លោកបានសម្លាប់នៅលើឈើឆ្កាងឲ្យព្រះអង្គទទួលព្រះជន្មថ្មីដ៏រុងរឿង។ ព្រះជាម្ចាស់បានលើកលោកយេស៊ូឡើងដោយឫទ្ធិបារមីរបស់ព្រះអង្គ ហើយតែងតាំងលោកជាព្រះអម្ចាស់និងជាព្រះសង្គ្រោះ ដើម្បីឲ្យប្រជាជនអ៊ីស្រាអែលប្រែចិត្តគំនិត។ យើងខ្ញុំជាសាក្សីអំពីហេតុការណ៍ទាំងនេះ ហើយព្រះវិញ្ញាណដ៏វិសុទ្ធជាព្រះជាម្ចាស់ ដែលប្រទានដល់អស់អ្នកដែលស្តាប់បង្គាប់ព្រះអង្គទ្រង់ក៏ជាសាក្សីដែរ"**។ សន្តៈសិលាប្រកាសថា យើងជាសាក្សីអំពីហេតុការណ៍ទាំងនេះ គឺអំពីព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ និងព្រះយេស៊ូណែនាំឲ្យមនុស្សលោកទទួលការសង្គ្រោះ។ សព្វថ្ងៃយើងជាគ្រីស្តបរិស័ទ បន្តធ្វើជាសាក្សីអំពីព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ ហើយយើងបន្តមើលសញ្ញាសម្គាល់នៃជីវិត ដែលព្រះយេស៊ូប្រទានឲ្យពិភពលោកទាំងមូលដែរ។

ក្នុងរាត្រីបុណ្យចម្លងកន្លងមក មានសញ្ញាច្រើនដែលណែនាំឲ្យយើងជឿថា ពិតមែនព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញគង់នៅជាមួយយើង ពិតមែនព្រះយេស៊ូជាព្រះសង្គ្រោះរបស់មនុស្សលោក។ នៅថ្ងៃបុណ្យចម្លង ខ្ញុំបានទៅថ្វាយអភិបូជានៅមន្ទីរឃុំឃាំងព្រៃស នៅ

---

ក្នុងអភិបូជាអធិដ្ឋានពេញមួយយប់
នៅអារាមកាម៉ែល
ថ្ងៃទី០៧ មេសា ២០១៦

ទីនោះមានអ្នកទោសម្នាក់បានអធិដ្ឋានថា **"សូមអរព្រះគុណព្រះជាម្ចាស់ ដែលបានប្រទានសិទ្ធិសេរីភាពនៅក្នុងដួងចិត្តខ្ញុំ ណែនាំឲ្យខ្ញុំរកឃើញសេចក្ដីសង្ឃឹមនៅក្នុងជីវិត ដោយសារព្រះយេស៊ូមានព្រះជន្មថ្មី"**។ ពាក្យអធិដ្ឋាននេះបញ្ជាក់ថា ទោះបីគាត់ជាប់ឃុំឃាំង ប៉ុន្តែគាត់មានសេចក្ដីសង្ឃឹមដោយសារមានព្រះយេស៊ូផ្ដល់ជីវិត។ នេះជាសក្ខីភាពមួយដែលផ្ដល់កម្លាំងថែមទៀត ឲ្យយើងនឹកឃើញពីរបៀបដែលព្រះយេស៊ូសង្គ្រោះមនុស្សលោក។

ក្នុងរាត្រីបុណ្យចម្លង នៅទូទាំងភូមិភាគភ្នំពេញ យើងមានបេក្ខជន១១០នាក់ទទួលអគ្គសញ្ញាជ្រមុជទឹក ដោយនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ ហើយបេក្ខជនបានឆ្លើយថា **"អាម៉ែន"** ដែលមានន័យថា **"យើងទទួល" "យើងសប្បាយចិត្តណាស់ ដោយសារយើងបានជាប់ជាមួយព្រះបិតា ព្រះយេស៊ូជាព្រះបុត្រា និងជាមួយព្រះវិញ្ញាណអស់មួយជីវិត"**។ ពិតមែន២០០០ឆ្នាំកន្លងមកហើយ ដែលព្រះយេស៊ូនៅតែណែនាំឲ្យយើងទទួលជីវិតថ្មី និងទទួលការសង្គ្រោះ។ ក្រោយបុណ្យចម្លង នៅព្រះសហគមន៍តាកែវ យើងបានជួបប្រជុំជាមួយគ្រួសារអ្នកជំងឺអេដស៍១០០គ្រួសារ។ ពេលនោះជាឱកាសមួយដើម្បីយើងសួរសុខ-ទុក្ខ សំណេះសំណាល លើកទឹកចិត្តដល់ពួកគាត់ ហើយការណ៍នេះណែនាំឲ្យយើងដឹងថាពិតមែនព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ ពិតមែនព្រះយេស៊ូកំពុងគង់នៅជាមួយគេ ព្រះអង្គកំពុងសួរសុខទុក្ខគេ និងកំពុងលើកទឹកចិត្តគេដែរ សមដូចព្រះអង្គមានព្រះបន្ទូលថា **"អ្វីៗទាំងអស់ដែលអ្នកបានប្រព្រឹត្តដល់អ្នកតូចតាចណាម្នាក់ នោះបីដូចជាអ្នកបានប្រព្រឹត្តដល់ខ្ញុំដែរ"** ។

ក្រោយមក ខ្ញុំបានទៅសួរសុខទុក្ខបងប្អូននៅកន្លែងថ្មីមួយរបស់មណ្ឌលសកម្មភាពតាកែវ គឺភូមិកំពង់អំពិល ដែលមានអ្នកស្វែងយល់ប្រហែល៣០នាក់។ បងប្អូននៅទីនោះបានស្គាល់ព្រះជាម្ចាស់ តាមរយៈកូនស្រីម្នាក់ដែលបានមករៀននៅសាលាសន្តៈហ្វ្រង់ស្វ័រតាំងពីយូរឆ្នាំហើយ។ ពេលកូនស្រីនោះនិយាយអំពីព្រះយេស៊ូប្រាប់ទៅឪពុកម្ដាយ ពួកគាត់ភ្ញាក់ស្មារតីហើយសុំទទួលការអប់រំជំនឿ ដើម្បីស្គាល់ព្រះយេស៊ូ បន្ទាប់មកក៏មានបងប្អូន ឯទៀតៗ

ចូលរួមទទួលការអប់រំដូចពួកគាត់ដែរ។ សកម្មភាពរបស់ក្រុមនេះពោរពេញដោយអំណរសប្បាយ។ ពេលយើងឃើញពួកគាត់នោះ ដូចជាយើងបានឃើញព្រះយេស៊ូដោយផ្ទាល់ដែរ។ នៅសាលាសន្តៈប៉ូល ប៉ុន្មានថ្ងៃកន្លងមក មានបាត់ម៉ូតូបីគ្រឿង ណែនាំឲ្យនិស្សិតធ្លាក់ទឹកចិត្ត ក្រោយមកទាំងនិស្សិត ទាំងគ្រូ គេបានព្រមព្រៀងគ្នាប្រមូលលុយយកទៅជួយដល់អ្នកដែលបាត់ម៉ូតូនោះ។ នេះជារបៀបដែលព្រះយេស៊ូគង់នៅជាមួយគេ ជារបៀបដែលព្រះយេស៊ូផ្តល់កម្លាំងឲ្យយើងចេះបង្កើតសមត្ថភាព ឲ្យយើងចេះជួយគ្នាទៅវិញទៅមក ឲ្យយើងធ្វើជាសាក្សីនៃជីវិតដែលយើងបានទទួលពីព្រះជាម្ចាស់។

សប្តាហ៍មុន មានគ្នាជិត៣០០នាក់មកចូលរួមក្នុង **"ទិវានៃការត្រាស់ហៅ"** នៅភ្នំពេញថ្មី ដើម្បីរិះគិតអំពីព្រះហឫទ័យមេត្តាករុណារបស់ព្រះជាម្ចាស់តាមរយៈសន្តីហ្វូស្ទីណា។ ពេលយើងឃើញមានយុវជនដែលពោរពេញដោយកម្លាំង ដែលពោរពេញដោយអំណរសប្បាយ ចូលរួមក្នុងការរិះគិត ក្នុងការអធិដ្ឋាន ក្នុងអភិបូជា ក្នុងការស្តាប់និងផ្តល់សក្ខីភាព នោះណែនាំឲ្យយើងយល់ថា ពិតមែនព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ ពិតមែនព្រះជាម្ចាស់កំពុងធ្វើការ នៅក្នុងដួងចិត្តរបស់យុវជនទាំងអស់។ បងប្អូនអើយ! សូមធ្វើជាលេខានៃព្រះ-ហឫទ័យមេត្តាករុណារបស់ព្រះជាម្ចាស់ ដូចសន្តីហ្វូស្ទីណា និងធ្វើជាគ្រីស្តទូតនៃព្រះហឫទ័យមេត្តាករុណារបស់ព្រះជាម្ចាស់ ដូចសន្តៈយ៉ូហានប៉ូលទី២។ ពិតមែនព្រះជាម្ចាស់កំពុងមានវត្តមាន នៅក្នុងព្រះសហគមន៍របស់យើង សូមឲ្យយើងធ្វើជាសាក្សីជាក់ស្តែងអំពីព្រះជាម្ចាស់នៃយើង។

សន្តៈយ៉ូហាន ពេលឃើញផ្នូរទទេគាត់ជឿថា ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ។ សព្វថ្ងៃមានសញ្ញាសម្គាល់ជាច្រើនឲ្យយើងអាចប្រកាសថា ពិតមែនព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ។ នៅក្នុងជីវិតរបស់យើង នៅក្នុងព្រះសហគមន៍របស់យើង នៅក្នុងសង្គមរបស់យើង ប្រសិនបើយើងចេះបើកភ្នែកមើល ប្រសិនបើយើងចេះទួលអង្វរព្រះវិញ្ញាណដ៏វិសុទ្ធ នោះយើងពិតជាអាចរកឃើញសញ្ញាសម្គាល់ជាច្រើន ដើម្បីឲ្យយើងប្រកាសថាព្រះយេស៊ូមាន

ព្រះជន្មរស់ឡើងវិញ និងគង់នៅជាមួយយើង ដូចសន្ត្ថសិលាមានប្រសាសន៍ថា **"យើងខ្ញុំជាសាក្សីអំពីហេតុការណ៍ទាំងនេះ"**។ សូមឲ្យយើងបន្តធ្វើជាសាក្សីអំពីហេតុការណ៍ទាំងនេះ គឺពិតមែនព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ ពិតមែនព្រះយេស៊ូសង្គ្រោះមនុស្សលោក ដែលណែនាំឲ្យយើងទទួលជីវិតថ្មី។

យប់នេះពេញមួយយប់ យើងរួមគ្នាអធិដ្ឋាន យើងអរព្រះគុណព្រះជាម្ចាស់ និងសូមព្រះអង្គជួយឲ្យយើងបន្តធ្វើជាសាក្សីជាក់ស្តែង អំពីព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ និងអំពីព្រះយេស៊ូជាព្រះសង្គ្រោះរបស់មនុស្សលោក។

**"អ្វីៗទាំងអស់ដែលអ្នកបានប្រព្រឹត្តដល់អ្នកតូចតាចណាម្នាក់ នោះបីដូចជាអ្នកបានប្រព្រឹត្តដល់ខ្ញុំដែរ"**

# ជាអ្នកដឹកនាំត្រូវមើលឃើញ និងយល់អំពីសេចក្ដីត្រូវការរបស់គេ

As a leader you have to see and understand the needs

អត្ថបទទី១៖ កក ៩, ៣៤-៤២
ដំណឹងល្អ៖ យហ ៦, ១-១៥

ក្នុងឆ្នាំព្រះមហាករុណាទិគុណនេះ ថ្ងៃនេះយើងជួបជុំគ្នាបោះជំរុំ ដើម្បីរិះគិតអំពីរបៀបធ្វើជាមេក្រុមកាយឫទ្ធិ និងជាពិសេស យើងរួមគ្នាសម្លឹងមើលព្រះបិតា ដើម្បីទទួលព្រះហឫទ័យស្រឡាញ់របស់ព្រះអង្គ។ ថ្ងៃនេះសូមឲ្យយើងរិះគិតថា តើយើងជាមេក្រុមកាយឫទ្ធិរបៀបណា?។ សូមមើលតាមរបៀបព្រះយេស៊ូនៅក្នុងអត្ថបទព្រះគម្ពីរថ្ងៃនេះ ដែលនឹងបំភ្លឺយើង អំពីរបៀបដែលយើងត្រូវណែនាំកូនៗកាយឫទ្ធិរបស់យើង។ ជាញយដង ព្រះយេស៊ូតែងយកពេលទៅអង្គុយជាមួយបណ្ដាជន ហើយព្រះអង្គបង្រៀនគេ និងព្រះអង្គព្យាបាលអ្នកជំងឺឲ្យបានជាសះស្បើយដែរ។ ពេលព្រះយេស៊ូទតឃើញបណ្ដាជនច្រើនកុះករធ្វើដំណើរតាមព្រះអង្គអស់កម្លាំងនោះ ព្រះអង្គអាណិតអាសូរគេ ហើយមានព្រះបន្ទូលទៅកាន់ក្រុមគ្រីស្តទូតថា "តើយើងទៅរកទិញអាហារឯណាបាន ដើម្បីយកមកចែកឲ្យបងប្អូនទាំងអស់គ្នាបរិភោគ?"។ ដូច្នេះយើងឃើញរបៀបរបស់ព្រះយេស៊ូដូចតទៅ៖

ទី១/ ព្រះយេស៊ូទតមើលស្ថានការណ៍ដែលបានកើតឡើងនៅពេលនេះ គឺប្រជាជនដែលបានអង្គុយនៅជាមួយព្រះអង្គអស់រយៈពេលយូរម៉ោងហើយនោះ គេកំពុងឃ្លាន នេះមានន័យថា **"ព្រះយេស៊ូទតឃើញបញ្ហារបស់គេ"**។ ដូច្នេះយើងដែលជាអ្នកដឹកនាំក្មេងៗកាយ-

ក្នុងអភិបូជាបោះជំរុំកាយឫទ្ធិ នៅគីរីវង់
ថ្ងៃទី០៨ មេសា ២០១៦

ឫទ្ធិ យើងក៏ត្រូវចេះមើលស្ថានការណ៍ និងបញ្ហារបស់ក្មេងៗដែរ។ បន្ទាប់មកព្រះយេស៊ូសួរយោបល់របស់ក្រុមគ្រីស្តទូតថា **"តើយើងទៅរកទិញអាហារឯណាបាន ដើម្បីយកមកចែកឲ្យបងប្អូនទាំងអស់គ្នាបរិភោគ?"**។ យើងជាអ្នកដឹកនាំក្មេងៗកាយឫទ្ធិ ក៏ត្រូវតែចាប់អារម្មណ៍អំពីស្ថានការណ៍ អំពីបរិយាកាស និងអ្វីៗដែលកំពុងកើតឡើងជាមួយក្មេង។

ទី២/ យើងត្រូវការដឹងអំពីសេចក្តីត្រូវការរបស់គេ និងសួរយោបល់គេ ដូចព្រះយេស៊ូបានសួរយោបល់ក្រុមគ្រីស្តទូតដែរ។ ឧទាហរណ៍ អំពីការជួយអ្នកក្រីក្រនោះ សូមឲ្យយើងសួរយោបល់កូនៗរបស់យើង ថាតើយើងទៅជួយគ្រួសារណាខ្លះ?។ តាមរបៀបព្រះយេស៊ូ ក្រោយពីព្រះអង្គសួរគេហើយនោះ ព្រះអង្គសម្លឹងមើលថា តើជាក់ស្តែងគេមានអ្វីខ្លះ? ក្រោយមកព្រះអង្គប្រមូលអ្វីដែលគេមានពិតប្រាកដនោះ។ ចំពោះយើងក៏ដូចគ្នាដែរ គឺយើងត្រូវរករបៀបណាមួយឲ្យកូនៗរបស់យើង អាចចូលរួមសកម្មភាពជាមួយយើងបាន ដោយយើងបង្កើតគម្រោងការណាមួយ ដែលណែនាំឲ្យយើងអាចប្រមូលកម្លាំងរបស់គេនិងប្រមូលសមត្ថភាពដែលគេមានដែរ។ ក្រោយពេលក្រុមគ្រីស្តទូតប្រមូលបាននំប៉័ងប្រាំដុំ និងត្រីពីរ កន្ទុយហើយនោះ ព្រះអង្គអរព្រះគុណព្រះបិតា ហើយចែកប្រទានឲ្យក្រុមគ្រីស្តទូត និងបណ្តាជនបរិភោគ។ បន្ទាប់មកព្រះយេស៊ូមានព្រះបន្ទូលថា **"ចូរប្រមូលនំប៉័ង និងត្រីដែលនៅសល់"** ពេលនោះក្រុមគ្រីស្តទូតដែលជាអ្នកចែកផង និងជាអ្នកប្រមូលទុកវិញផង ប្រមូល បាន១២ល្អីពេញ។

ពាក្យ Boss មានន័យថាជាអ្នកអង្គុយមើលពីលើ ឯពាក្យ Leader មានន័យថាជាអ្នកដែលនៅពីខាងមុខមើល និងជួយណែនាំឲ្យក្មេងៗបញ្ចេញស្នាដៃរបស់គេផ្ទាល់ រួមជាមួយគ្នា។ បន្ទាប់ពីបានស្តាប់អត្ថបទព្រះគម្ពីរហើយ នោះយើងទទួលបានមេរៀនជាច្រើនដើម្បី ទៅជាមេគេយ៉ាងល្អ គឺទៅជា Leader ជាអ្នកដឹកនាំ ជាអ្នកមានយោបល់ ជាអ្នកណែនាំឲ្យក្មេងៗ ចេះមើលឃើញស្ថានការណ៍ចេះជួយយោបល់គ្នាក្រោយមករួមគ្នាបញ្ចេញកម្លាំង បញ្ចេញសមត្ថភាព និងបង្កើតស្នាដៃរួមជាមួយគ្នា។ នេះណែនាំឲ្យក្រុមកាយឫទ្ធិរបស់យើងរឹងមាំធ្វើឲ្យក្មេងៗសប្បាយចិត្ត និងចូលរួមសកម្មភាពជាមួយយើងពីមួយអាទិត្យ

ទៅមួយអាទិត្យដោយអំណរ ដោយដឹងថាខ្លួនគេមានសមត្ថភាព និងចេះទទួលខុសត្រូវ។ សូមឲ្យយើងបង្កើតទំនាក់ទំនងជាមួយក្មេងៗ តាមរបៀបប្លែកពីនៅសាលាដោយយើងធ្វើតាមរបៀបព្រះយេស៊ូ គឺមើលឃើញស្ថានភាព ជួយយោបល់គ្នា ចេញកម្លាំងជួយគ្នាដើម្បីជោគជ័យក្នុងការរស់នៅ។

សូមអរព្រះគុណព្រះជាម្ចាស់ដែលគង់នៅជាមួយយើងខ្ញុំ ដើម្បីឲ្យយើងខ្ញុំទៅជាមេក្រុមកាយឫទ្ធិដ៏ល្អ ចេះដឹកនាំ ចេះស្រឡាញ់ និងចេះយល់អំពីស្ថានភាពនៅក្នុងក្រុមដែលយើងទទួល។ គោលដៅរបស់យើង គឺណែនាំឲ្យក្មេងៗចេះគោរពគ្នាទៅវិញទៅមក ចេះគោរពចាស់ទុំ ចេះគោរពអ្វីៗទាំងអស់ដែលមាននៅក្នុងសង្គម ចេះគោរពជីវិតផ្ទាល់ខ្លួន ចេះគោរពធម្មជាតិ និងក្លាយទៅជាពលរដ្ឋដ៏ល្អនៅក្នុងសង្គមនាពេលអនាគត។ កាយឫទ្ធិជាកម្មវិធីដែលណែនាំឲ្យយើងអាចបង្កើតសង្គមថ្មី ដែលណែនាំឲ្យមនុស្សម្នាក់ៗយល់ថាជីវិតមានតម្លៃ មានសមត្ថភាព និងពោរពេញដោយសេចក្ដីស្រឡាញ់។

# យើងមានតួនាទីប្រកាសអំពីវត្តមានព្រះយេស៊ូ នៅក្នុងពិភពលោកទាំងមូល

## Proclaim the presence of Jesus in the world

អត្ថបទទី១៖ កក ៥, ២៧ខ-៣២.៤០ខ-៤១
អត្ថបទទី២៖ វវ ៥, ១១-១៤
ដំណឹងល្អ៖ យហ ២១, ១-១៩

ថ្ងៃនេះជាអាទិត្យទី៣នៃបុណ្យចម្លង ជាឱកាសមួយដើម្បីអរព្រះគុណព្រះជាម្ចាស់ ជាពិសេសដើម្បីគិតពីរបៀបដែលព្រះយេស៊ូបង្ហាញព្រះកាយ ដល់ក្រុមគ្រីស្តទូតពីដើម។ អម្បាញ់មិញ យើងបានស្តាប់អត្ថបទទី១ ដែលព្រះវិញ្ញាណដ៏វិសុទ្ធយាងមកលើក្រុមគ្រីស្តទូត។ ថ្ងៃនេះយើងមាន១៦នាក់ដែលទទួលព្រះវិញ្ញាណដ៏វិសុទ្ធ ជាពេលដែលយើងនឹកដល់ព្រះយេស៊ូចាត់ព្រះវិញ្ញាណដ៏វិសុទ្ធ យាងមកគង់នៅជាមួយក្រុមគ្រីស្តទូតពីដើម ណែនាំឲ្យគេប្រែចិត្តគំនិត និងទៅជាមនុស្សថ្មី។

ពេលព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ ពេលនោះក្រុមគ្រីស្តទូតមានពិសោធន៍ឃើញព្រះអង្គដោយផ្ទាល់ភ្នែក ហើយគេមានអំណរសប្បាយ។ ប៉ុន្តែពេលព្រះអង្គយាងឡើងស្ថានបរមសុខ ក្រុមគ្រីស្តទូតដូចជាធ្លាក់ទឹកចិត្ត អស់សង្ឃឹម អស់កម្លាំង ដ្បិតគេបាត់ព្រះអម្ចាស់នៃជីវិតរបស់គេ ទោះបីព្រះយេស៊ូធ្លាប់មានព្រះបន្ទូលច្រើនដងប្រាប់គេថា **"ខ្ញុំទៅឯព្រះបិតា ហើយខ្ញុំនឹងផ្ញើព្រះវិញ្ញាណដ៏វិសុទ្ធមកគង់នៅជាមួយអ្នករាល់គ្នា"** ក៏ដោយ។ ពេលនោះគេមិនហ៊ានជួបជុំគ្នាជាសាធារណៈទេ គេជួបជុំគ្នានៅតែក្នុងបន្ទប់តូចមួយដែលបិទបង្អួច បិទទ្វារយ៉ាងជិត ដ្បិតគេភ័យខ្លាចមានអ្នកមកតាមចាប់គេយកទៅសម្លាប់ ដូច

អភិបូជាអគ្គសញ្ញាលាបថ្ងាសនៅកំពត
ថ្ងៃទី១០ មេសា ២០១៦

លោកគ្រូរបស់ពួកគេដែរ។ នេះជាអារម្មណ៍របស់គ្រីស្ទទូតនៅពេលនោះ។

៥០ថ្ងៃ ក្រោយព្រះយេស៊ូទទួលព្រះជន្មថ្មីដ៏រុងរឿង ពេលពួកសាវ័កកំពុងជួបជុំគ្នា ស្រាប់តែឫទ្ធានុភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធយាងមកសណ្ឋិតលើពួកគេ ប្រទានកម្លាំងថ្មី ទាំងជំរុញពួកគេឲ្យទៅមុខទៀត **"រំពេចនោះស្រាប់តែមានឮស្នូរមួយមកពីលើមេឃ ដូចខ្យល់បក់បោកយ៉ាងខ្លាំងពេញក្នុងផ្ទះដែលគេនៅ។ ពួកសាវ័កបានឃើញអណ្ដាតភ្លើងជះមកលើគេបែកចេញពីគ្នាចូលមកសណ្ឋិតលើពួកគេម្នាក់ៗ។ អ្នកទាំងនោះពោរពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ ហើយចាប់ផ្ដើមនិយាយភាសាផ្សេងៗពីគ្នា តាមព្រះវិញ្ញាណប្រោសប្រទានឲ្យគេក្រោយមកគេទៅតាមផ្លូវ ដើម្បីប្រកាសអំពីព្រះយេស៊ូមានព្រះជន្មថ្មី"**។ ចំពោះបងប្អូនវិញក៏ដូចគ្នាដែរ បន្ដិចទៀតបងប្អូន នឹងទទួលព្រះវិញ្ញាណដ៏វិសុទ្ធជាក់ជាមិនខាន។ ពេលបងប្អូនទទួលអគ្គសញ្ញាជ្រមុជទឹក ពេលនោះបងប្អូនទៅជាមនុស្សថ្មី ដោយសារព្រះវិញ្ញាណរួចទៅហើយ ប៉ុន្តែពេលនេះព្រះវិញ្ញាណដ៏វិសុទ្ធដដែលនោះ នឹងប្រទានកម្លាំងមួយបន្ថែមទៀតឲ្យបងប្អូនទៅជាសាក្សីអំពីព្រះយេស៊ូដែលមានព្រះជ្មនថ្មីដ៏រុងរឿង។

ក្រុមគ្រីស្ដទូតពីដើមមានសំណាងជាងយើង ព្រោះគេបានធ្វើដំណើរជាមួយព្រះយេស៊ូអស់រយៈពេល៣ឆ្នាំ និងក្រោយពេលព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ ព្រះអង្គបានបង្ហាញព្រះកាយនៅមាត់សមុទ្រកាលីឡេឱ្យពួកគេឃើញ។ សព្វថ្ងៃយើងអត់បានឃើញព្រះយេស៊ូដោយផ្ទាល់ភ្នែកទេ យើងក៏អត់ដែលបានរួមតុអាហារជាមួយព្រះអង្គដោយផ្ទាល់ដែរ ប៉ុន្តែយើងបានទទួលបេសកកម្មមួយយ៉ាងពិសេស ដូចក្រុមគ្រីស្ដទូតពីដើមដែរ គឺទៅប្រកាសដំណឹងដល់បងប្អូនឯទៀតៗថា ព្រះយេស៊ូពិតជាមានព្រះជ្មនរស់ឡើងវិញមែនព្រះអង្គមានព្រះជន្មគង់នៅសព្វថ្ងៃនេះជាតួនាទីរបស់យើង។ សព្វថ្ងៃ យើងអាចប្រកាសសេចក្តីទាំងនេះបាន គឺដោយសារតែព្រះវិញ្ញាណដ៏វិសុទ្ធគង់នៅជាមួយយើង និងបំភ្លឺយើង។ យើងអាចមើលឃើញវត្តមានរបស់ព្រះយេស៊ូនៅក្នុងព្រះសហគមន៍របស់យើង និងនៅក្នុងសង្គមរបស់យើងបានគឺដោយសារព្រះវិញ្ញាណដ៏វិសុទ្ធ ដែលបងប្អូននឹងទទួលនៅពេលបន្តិចទៀតនេះ។ព្រះវិញ្ញាណ

ដ៏វិសុទ្ធជាកម្លាំង ជាវត្តមាន និងជាសេចក្តីស្រឡាញ់របស់ព្រះយេស៊ូចំពោះយើង...។ ដូច្នេះ បងប្អូនត្រូវសួរខ្លួនឯងថា តើខ្ញុំដែលបានឃើញវត្តមានរបស់ព្រះយេស៊ូ ដែលមានព្រះជន្មរស់ឡើងវិញក្នុងព្រះសហគមន៍ និងក្នុងសង្គមដែរឬទេ? តើខ្ញុំនឹងទៅជាសាក្សីអំពីវត្តមានរបស់ព្រះយេស៊ូយ៉ាងណាដែរ?

តាំងពីថ្ងៃបុណ្យចម្លងកន្លងមក ខ្ញុំអាចនិយាយថា ខ្ញុំបានមើលឃើញវត្តមានរបស់ព្រះវិញ្ញាណប៉ុន្មានដងរួចទៅហើយ គឺឃើញនៅថ្ងៃបុណ្យចម្លងដែលខ្ញុំបានទៅថ្វាយអភិបូជានៅព្រៃស ជាមន្ទីរឃុំឃាំងនៅក្នុងរាជធានីភ្នំពេញ ដែលមានអ្នកទោស៧.០០០នាក់។ ខ្ញុំទៅថ្វាយអភិបូជានៅទីនោះ ដោយសារមានអ្នកទោសប៉ុន្មាននាក់ជាគ្រីស្តបរិស័ទ។ នៅពេលអង្វរសកល មានអ្នកទោសម្នាក់អធិដ្ឋានថា **"កូនសូមអរព្រះគុណព្រះជាម្ចាស់ ដែលខ្ញុំមានសេរីភាពដោយសារព្រះយេស៊ូ"**។ ពេលស្តាប់ឮភ្លាម ខ្ញុំនឹកគិតថា គាត់ជាអ្នកទោសនៅក្នុងគុកយូរឆ្នាំហើយ តើគាត់មានសេរីភាពយ៉ាងដូចម្តេច? តាមពិតគាត់អរព្រះគុណព្រះ-ជាម្ចាស់ដែលព្រះយេស៊ូបានណែនាំឱ្យគាត់មានសេរីភាព គឺសេរីភាពខាងផ្លូវចិត្ត គឺគាត់បានទទួលពន្លឺមួយពីព្រះយេស៊ូ។ តាមរយៈពាក្យដែលគាត់អធិដ្ឋាននោះ ខ្ញុំយល់ថាពិតមែនព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញគង់នៅជាមួយគាត់ដែរ ទោះបីគាត់ស្ថិតនៅក្នុងមន្ទីរឃុំឃាំងក៏ដោយ។

នៅរាត្រីបុណ្យចម្លង ខ្ញុំបានធ្វើអគ្គសញ្ញាជ្រមុជទឹកឲ្យបេក្ខជនប៉ុន្មានអ្នកនៅផ្សារតូច និងនៅទូទាំងភូមិភាគភ្នំពេញយើងមានបេក្ខជនចំនួន១១០នាក់។ ពេលយើងនឹកដល់ព្រឹត្តិការណ៍នេះយើងយល់ថា ពិតមែនព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញយ៉ាងពិតប្រាកដ។ មូលហេតុអីមនុស្សពេញវ័យ១១០នាក់ សុខចិត្តទទួលជីវិតថ្មីពីព្រះយេស៊ូ សុខចិត្តផ្ញើជីវិតលើព្រះយេស៊ូ នេះគឺដោយសារព្រះយេស៊ូដែលមានព្រះជន្មរស់ឡើងវិញ គង់នៅជាមួយពួកគាត់។ ប៉ុន្មានថ្ងៃមុនខ្ញុំបានទៅមន្ទីរធម្មការនិងសាសនាខេត្តតាកែវ ក្នុងកម្មវិធីជួបជាមួយអ្នកជំងឺអេដស៍១០០នាក់ ដែលមកពីកន្លែងផ្សេងៗនៃខេត្តតាកែវ។ ក្នុងឱកាសនោះខ្ញុំ

បានសួរសុខទុក្ខ បាននិយាយសំណេះសំណាល លើកទឹកចិត្តពួកគាត់ ហើយ ពួកគាត់ក៏បានប្រាប់ខ្ញុំវិញ អំពីសុខទុក្ខដែលពួកគាត់បានជួបប្រទះកន្លងមក គឺខ្លះអត់មានផ្ទះស្នាក់នៅ ខ្លះអត់មានដីភូមិ អត់មានម្ហូបអាហារគ្រប់គ្រាន់ អត់មានលុយទៅមន្ទីរពេទ្យនៅពេលកូនឈឺ..។

ពេលយើងមានឱកាសរៀបរាប់ពីសុខទុក្ខប្រាប់គ្នាទៅវិញទៅមកបែបនេះ នោះយើងយល់ថាព្រះយេស៊ូពិតជាមានវត្តមាននៅកណ្ដាលចំណោមពួកយើង ព្រះអង្គណែនាំឲ្យពួកយើងយល់ពីគ្នាទៅវិញទៅមក ជាពិសេសណែនាំឲ្យបងប្អូនទាំងនោះ អាចមើលឃើញធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ ដែលគង់នៅក្នុងគណៈកម្មការសង្គហៈរបស់ព្រះសហគម៍យើង។ ម្យ៉ាងទៀតរបៀបដែលបងប្អូនបានសួរសុខទុក្ខគ្នាទៅវិញទៅមក លើកទឹកចិត្តគ្នាទៅវិញទៅមកក្នុងចំណោមបងប្អូនដែលមានជំងឺអេដស៍ដូចគ្នា និងដែលមកពីកន្លែងផ្សេងៗគ្នាបែបនេះ ណែនាំឲ្យគេមានកម្លាំងថ្មី ដោយដឹងថាគេមិនលំបាកតែម្នាក់ឯងទេ គឺមានបងប្អូនឯទៀតៗដែលកំពុងតស៊ូនឹងការលំបាកដូចខ្លួនដែរ។ នេះជាសក្ខីភាព ដែលបញ្ជាក់ថាព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញគង់នៅជាមួយយើង។ ខ្ញុំជឿថា បងប្អូនទាំងអស់គ្នាក៏គង់មានពិសោធន៍អំពីព្រះយេស៊ូមានព្រះជន្មគង់នៅជាមួយយើងដែរ។

ម្សិលមិញ ខ្ញុំបានធ្វើពិធីអាពាហ៍ពិពាហ៍សម្រាប់គូស្រករថ្មីនៅចម្ការទៀង និងខ្ញុំបានទេសនាអំពីសេចក្ដីស្រឡាញ់ និងក្រោយមកខ្ញុំទៅហូបបាយ។ ពេលនោះមានមីងម្នាក់មកនិយាយជាមួយខ្ញុំថា **"លោកឪពុក នេះជាលើកទីមួយ ដែលខ្ញុំចូលក្នុងព្រះវិហារយេស៊ូ។ ខ្ញុំបានរៀបការជាមួយប្ដីខ្ញុំជាង២០ឆ្នាំហើយ ពីព្រឹកទល់យប់ ខ្ញុំគិតតែពីជេរគាត់ ដោយសារខ្ញុំគិតពីរឿងរកស៊ី ឯប្ដីខ្ញុំគាត់ជាមនុស្សខ្ជិល។ ខ្ញុំអត់ដែលបាននិយាយប្រាប់គាត់ថា ខ្ញុំស្រឡាញ់គាត់ទេ។ ថ្ងៃនេះពេលខ្ញុំស្ដាប់លោកឪពុកទេសនាអំពីសេចក្ដីស្រឡាញ់ នោះខ្ញុំភ្ញាក់ស្មារតី យប់នេះ ខ្ញុំនឹងនិយាយប្រាប់គាត់ថា ខ្ញុំស្រឡាញ់គាត់ខ្លាំងណាស់"**។ ស្ដាប់ហើយ ខ្ញុំសប្បាយចិត្ត ដោយយល់ថា នេះជាសញ្ញាសម្គាល់នៃវត្តមានរបស់ព្រះយេស៊ូដែលមានព្រះ-ជន្មរស់ឡើងវិញ គង់នៅជាមួយយើង។

ចាប់ពីពេលនេះតទៅ បងប្អូនទាំង១៦នាក់ដែលបានទទួលអគ្គសញ្ញាលាបថ្វាសទទួលព្រះវិញ្ញាណដ៏វិសុទ្ធ ត្រូវតែប្រកាសតាមរបៀបជាក់ស្តែងអំពីព្រះយេស៊ូដែលមានព្រះជន្មរស់ឡើងវិញ។ សូមកុំប្រើពាក្យ **"ព្រះគ្រីស្តមានព្រះជន្មរស់ឡើងវិញ និង ពាក្យអាលេលូយ៉ា"** ដោយគ្រាន់តែនិយាយនឹងមាត់ ប៉ុន្តែត្រូវមើលឃើញពិតប្រាកដថា ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញមែន ព្រះអង្គគង់នៅក្នុងសង្គមរបស់យើងបច្ចុប្បន្ននេះ និងគង់នៅក្នុងជីវិតរបស់យើងផ្ទាល់ដែរ រួចហើយសូមឲ្យយើងចេញទៅប្រកាសតាមរបៀបជាក់ស្តែងដល់បងប្អូនយើងឯទៀត។

ក្នុងគម្ពីរដំណឹងល្អ ព្រះយេស៊ូមានព្រះបន្ទូលសួរទៅលោកសិលាបីដងថា **"តើអ្នកស្រឡាញ់ខ្ញុំឬទេ?"** ។ ប៉ុន្មានអាទិត្យមុននោះ នៅលើភ្នំបូកគោយើងបានអានអត្ថបទព្រះគម្ពីរមួយស្តីពី **"ព្រះយេស៊ូរងទុក្ខលំបាក"** ដែលមានចែងពីលោកសិលាបានក្បត់ព្រះ-យេស៊ូ៣ដង។ ពេលមាន់រងាវបីដង ជាពេលដែលលោកសិលាឆ្លើយបដិសេធព្រះយេស៊ូបីដងដែរ។ ប៉ុន្តែពេលនោះលោកបានក្រឡេកឃើញព្រះយេស៊ូកំពុងទតមើលមកលោក ដោយព្រះហឫទ័យស្រឡាញ់និងប្រោសប្រណី ដែលបណ្តាលឲ្យលោកភ្ញាក់ស្មារតីដឹងថា ខ្លួនបានក្បត់ព្រះយេស៊ូបីដងរួចហើយ លោកសិលាចាប់ផ្តើមយំយ៉ាងខ្លាំង។ នេះជារបៀបដែលព្រះយេស៊ូលើកលែងទោសឲ្យលោកសិលា គឺព្រះអង្គសួរទៅលោកបីដងដូចដែលលោកសិលាបានក្បត់ព្រះអង្គ៣ដងដែរ។ ពេលលោកសិលាប្រកាសបីដងថា **"ខ្ញុំស្រឡាញ់ព្រះអង្គ"** ក៏ជាពេលដែលព្រះយេស៊ូបានជ្រើសលោកធ្វើជាមេដឹកនាំព្រះសហគមន៍ដែរ។ លោកសិលាជាសម្តេចប៉ាបទី១របស់យើង ឥឡូវនេះយើងមានសម្តេចប៉ាបថ្មីគឺសម្តេចហ្វ្រង់ស៊ីស្កូ។ លោកសិលាដែលបានបដិសេធបីដងថា **"ខ្ញុំមិនស្គាល់ព្រះអង្គ"** ត្រូវបានព្រះយេស៊ូលើកលែងទោសឱ្យ និងជ្រើសរើសលោកធ្វើជាមេដឹកនាំព្រះសហគមន៍។ ដូចគ្នាដែរនៅក្នុងជីវិតរបស់យើងប៉ុន្មានដងដែលយើងក្បត់ព្រះយេស៊ូ? ប៉ុន្មានដងដែលយើងបដិសេធព្រះអង្គ? ប៉ុន្មានដងដែលព្រះយេស៊ូបានទតមើលមកយើង ដោយព្រះហឫទ័យស្រឡាញ់ និងព្រះអង្គសួរមក

យើងថា **"តើអ្នកស្រឡាញ់ខ្ញុំឬទេ ?"**។

ថ្ងៃនេះជាឱកាសមួយឲ្យយើងម្នាក់ៗឆ្លើយ នឹងសំណួរដែលព្រះយេស៊ូសួរយើងថា **"តើអ្នកស្រឡាញ់ខ្ញុំឬទេ ?"**។ បន្តិចទៀតនេះ ខ្ញុំនឹងធ្វើអគ្គសញ្ញាលាបថ្វាស ជាសញ្ញាដែលព្រះយេស៊ូស្រឡាញ់យើងយ៉ាងខ្លាំង ហើយពេលនេះដែរ បេក្ខជនទាំង១៦នាក់នឹងឆ្លើយក្នុងនាមយើងទាំងអស់គ្នាថា **"ខ្ញុំស្រឡាញ់ព្រះអង្គខ្លាំងណាស់"**។ ដូច្នេះ ថ្ងៃនេះយើងគឺជាសញ្ញាសម្គាល់អំពីវត្តមានរបស់ព្រះយេស៊ូ ដែលមានព្រះជន្មរស់ឡើងវិញគង់នៅក្នុងជីវិតរបស់យើង គង់នៅតាមព្រឹត្តិការណ៍នានា ដែលកើតឡើងនៅក្នុងពិភពលោកយើង ទោះបីមនុស្សយើងមានបាប ជាអ្នកដែលភ្លេចព្រះអង្គ ប៉ុន្តែព្រះយេស៊ូលើកលែងទោសឱ្យជានិច្ចដើម្បីឲ្យយើងកសាងព្រះសហគមន៍។ លោកសិលាទទួលតួនាទីដឹកនាំព្រះសហគមន៍ ឯយើងម្នាក់ៗ ទទួលតួនាទីកសាងព្រះសហគមន៍។

នៅភ្នំពេញថ្មីកាលពីអាទិត្យមុនមានធ្វើទិវាសម្រាប់ការត្រាស់ហៅ ពេលនោះយើងបាននឹកដល់បងស្រីហ្វូស្ទីណា ដែលបានសម្តែងព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់។ ខ្ញុំបាននិយាយទៅកាន់យុវជន យុវនារីទាំង៣០០នាក់ថា **"យើងម្នាក់ៗ ត្រូវតែទៅជាលេខានៃមេត្តាករុណារបស់ព្រះជាម្ចាស់ ដូចបងស្រីហ្វូស្ទីណា និងទៅជាគ្រីស្តទូតនៃធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ ដូចសម្តេចប៉ាបយ៉ូហានប៉ូលទី២"**។ តើយើងម្នាក់ៗជាលេខាផងជាគ្រីស្តទូតផង ដើម្បីសម្តែងព្រះហឫទ័យមេត្តាករុណារបស់ព្រះជាម្ចាស់ ក្នុងឆ្នាំព្រះមហាករុ-ណាទិគុណនេះឬទេ ?។ សូមឲ្យយើងទាំងអស់គ្នាភ្ញាក់ស្មារតី និងអរព្រះគុណព្រះជាម្ចាស់។ ថ្ងៃនេះខ្ញុំឃើញមានបងស្រីជាច្រើនអញ្ជើញមក នាំឲ្យយើងនឹកឃើញដល់បងស្រីសុជាតិ។ ព្រះសហគមន៍របស់យើងត្រូវការមានបងប្រុសបងស្រី មានលោកបូជាចារ្យថែមទៀត ដើម្បីកសាងព្រះសហគមន៍ឲ្យទៅជាសញ្ញាសម្គាល់ នៃព្រះហឫទ័យមេត្តាករុណារបស់ព្រះជាម្ចាស់។

ថ្ងៃនេះ យើងខ្ញុំសូមអរព្រះគុណព្រះជាម្ចាស់ ដែលណែនាំឲ្យយើងខ្ញុំរួមដំណើរជាមួយព្រះយេស៊ូ និងបង្ហាញពីវត្តមានរបស់ព្រះយេស៊ូក្នុងពិភពលោកនេះ វត្តមានរបស់ព្រះយេស៊ូគឺជាសេចក្តីសង្ឃឹម សេចក្តីស្រឡាញ់ និងការតស៊ូ ដែលណែនាំឱ្យជីវិតរបស់យើងខ្ញុំទៅជាជីវិតថ្មី។

**"រំពេចនោះស្រាប់តែមានឮស្នូរមួយមកពីលើមេឃ ដូចខ្យល់បក់ បោកយ៉ាងខ្លាំងពេញក្នុងផ្ទះដែលគេនៅ។ ពួកសាវ័កបានឃើញអណ្តាតភ្លើងជះមកលើគេបែកចេញពីគ្នាចូលមកសណ្ឋិតលើពួកគេម្នាក់ៗ។ អ្នកទាំងនោះពោរពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ ហើយចាប់ផ្តើមនិយាយភាសាផ្សេងៗពីគ្នាតាមព្រះវិញ្ញាណប្រោសប្រទានឲ្យគេក្រោយមកគេទៅតាមផ្លូវ ដើម្បីប្រកាសអំពីព្រះយេស៊ូមានព្រះជន្មថ្មី"**

# ផ្លូវនៃសុភមង្គល

The way to happiness

អត្ថបទទី១៖ កក ៨, ២៦-៤០
ដំណឹងល្អ៖ យហ ៦, ៤៤-៥១

អម្បាញ់មិញយើងបានស្ដាប់អត្ថបទគម្ពីរដែលចែងថា **"ចូរអរសប្បាយរីករាយឡើង ព្រោះអ្នករាល់គ្នានឹងទទួលរង្វាន់យ៉ាងធំនៅស្ថានបរមសុខ"**។ ដូច្នេះក្នុងឱកាសចូលឆ្នាំថ្មីនេះ សូមឲ្យយើងអរសប្បាយរីករាយឡើង ដោយសារយើងទទួលរង្វាន់មួយយ៉ាងពិសេសនៅស្ថានបរមសុខ។ រង្វាន់ដែលយើងទទួលនៅស្ថានបរមសុខ តម្រូវឲ្យយើងរៀបចំដើម្បីទទួលពីពេលនេះតទៅ។ អភិបូជាសម្រាប់ឆ្នាំថ្មីប្រពៃណីជាតិខ្មែរពេលនេះ ជាឱកាសមួយសូមព្រះជាម្ចាស់ប្រទានពរដល់គ្រួសារយើងនីមួយៗ ប្រទានពរដល់យើងម្នាក់ៗ ប្រទានពរដល់ប្រទេសកម្ពុជាទាំងមូល។ ជាពិសេសប្រទានពរ តាមព្រះបន្ទូលក្នុងអត្ថបទទី១ ដែលបានចូលនៅក្នុងដួងចិត្តរបស់យើងគឺ **"សូមព្រះអម្ចាស់ប្រទានពរនិងថែរក្សាយើង សូមព្រះអម្ចាស់ទតមកយើងដោយព្រះហឫទ័យមេត្តាករុណា សូមព្រះអង្គប្រណីសន្ដោសយើង សូមព្រះអង្គសម្ដែងព្រះហឫទ័យសប្បុរសចំពោះយើង និងប្រទានពរឲ្យយើងបានប្រកបដោយសេចក្ដីសុខសាន្ត"** នេះជាព្រះពរដែលយើងទទួលសម្រាប់ឆ្នាំថ្មីនេះ។

ដូចរាល់ឆ្នាំដែរថ្ងៃនេះយើងបានស្ដាប់ព្រះបន្ទូលស្ដីអំពី"ផ្លូវនៃសុភមង្គល"ដែលធ្វើឲ្យយើងមានអំណរសប្បាយក្នុងចិត្ត។ តាមពិតទៅយើងម្នាក់ៗដែលចូលមកក្នុងព្រះវិហារនេះ និងមនុស្សទាំងអស់ដែលរស់នៅលើផែនដី នរណាក៏ចង់ទទួលសុភមង្គលដ៏ពិតប្រាកដដែរ

ក្នុងអភិបូជាបុណ្យចូលឆ្នាំខ្មែរនៅចម្ការទៀង
ថ្ងៃទី១៤ មេសា ២០១៦

ប៉ុន្តែសុភមង្គលមកពីព្រះជាម្ចាស់ ជាសុភមង្គលដ៏ពិតប្រាកដ មិនដូចសុភមង្គលមកពីលោកីយ៍ទេ។ យើងបានស្តាប់ឮថា **"អ្នកណាសោកសៅ អ្នកនោះមានសុភមង្គលហើយ"** មូលហេតុអ្វីយើងមានសុភមង្គល នៅពេលយើងសោកសៅ? នៅពេលទឹកភ្នែករបស់យើងហូរ?។ នោះគឺដោយសារព្រះជាម្ចាស់សម្រាលទុក្ខរបស់យើង។

យើងនឹកឃើញដល់រឿងស្ត្រីដែលលាងជើងថ្វាយព្រះយេស៊ូ នាងជាស្រីខូចពេញដោយបាប។ នាងលាងជើងថ្វាយព្រះយេស៊ូទាំងយំ ដោយសារនឹកឃើញដល់បាបរបស់ខ្លួន។ នាងយំដោយសារនាងរំភើបចិត្ត ដ្បិតព្រះយេស៊ូស្វាគមន៍នាង ព្រះអង្គមិនបណ្តេញនាងដូចគេទេណែនាំឲ្យនាងទទួលជីវិតថ្មី ទទួលកម្លាំងថ្មីផុតពីទុក្ខកង្វល់ពីមុន។ ប៉ុន្មានថ្ងៃមុនយើងបានទៅតាកែវជួបជាមួយគ្រួសារអ្នកមានជំងឺអេដស៍១០០គ្រួសារ។ យើងបាននិយាយសំណេះសំណាលជាមួយពួកគាត់ ពេលនោះមានមីងម្នាក់យំទាំងរៀបរាប់ប្រាប់យើងថាគាត់គ្មានផ្ទះស្នាក់នៅ គ្មានស្រែ គ្មានដី គ្មានប្តី គ្មានកម្លាំង គ្មានសេចក្តីសុខ គ្មានសុភមង្គល...។ យើងសម្លឹងមើលគាត់កំពុងយំ តាមរបៀបដែល ព្រះយេស៊ូបានសម្លឹងមើលអ្នកជំងឺ អ្នករងទុក្ខលំបាកពីដើមដែរ។ ដូច្នេះពេលចូលឆ្នាំហើយ យើងនឹងទៅសាងសង់ផ្ទះមួយ ជូនគាត់។ នេះជាសញ្ញាសម្គាល់នៃធម៌មេត្តាករុណា ដែលព្រះយេស៊ូទន្ទឹងរង់ចាំឲ្យយើង ធ្វើនៅពេលយើងជួបបងប្អូនឯទៀតកំពុងយំ។ តើយើងធ្វើអ្វីដើម្បីឲ្យបងប្អូនកំពុងយំទទួលកម្លាំងថ្មី?

ដូចគ្នាដែរ មានគ្រួសារមួយទៀតមានកូនពីរនាក់ពិការធ្ងន់ធ្ងរ។ គាត់ជាម្តាយអត់មានពេលប្រកបរបរអ្វីឲ្យពិតប្រាកដទេ ព្រោះជាប់មើលថែកូន។ នៅតំបន់គាត់រស់នៅជួបគ្រោះរាំងស្ងួត អត់មានទឹក សូម្បីទឹកសម្រាប់ហូបក៏ពិបាករកដែរ។ ឥឡូវនេះយើងបានជីកអណ្តូងទឹកមួយជូនគាត់។ សកម្មភាពរបស់យើងណែនាំឲ្យគាត់ទទួលសេចក្តីសុខសាន្តនិង ឲ្យភ្នែករបស់គាត់បានឃើញជាក់ស្តែងនូវធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ក្នុងជីវិតរបស់គាត់។ ថ្ងៃនេះមានបងប្អូនជាច្រើនមកពីវិទ្យាស្ថានសន្តៈប៉ូល ក្នុងចំណោមនេះមានបងប្អូនខ្លះបានស្គាល់ព្រះសហគមន៍ដោយសារលោកតាប៉ូល។ មុនទទួលមរណភាពលោក

តាបានផ្ដាំកូនចៅថា **"សូមដើរតាមព្រះយេស៊ូ សូមទុកចិត្តលើព្រះយេស៊ូ សូមស្រឡាញ់ព្រះយេស៊ូទៅ"** ហើយឥឡូវនេះមានបងប្អូនជាច្រើនក្នុងភូមិ បានមកសូមទទួលការអប់រំជំនឿពីព្រះសហគមន៍យើង។ យើងជាគ្រីស្ដបរិស័ទមានពិសោធន៍ថា ទោះបីយើងមានទុក្ខលំបាកមានឧបសគ្គក្នុងការរស់នៅ ប៉ុន្តែយើងមានព្រះយេស៊ូសម្រាលទុក្ខរបស់យើង យើងមានព្រះ-យេស៊ូណែនាំយើង យើងមានព្រះយេស៊ូប្រទានកម្លាំងថ្មីឲ្យយើងអាចធ្វើដំណើរទៅមុខបាន។

**"អ្នកណាមានចិត្តមេត្តាករុណា អ្នកនោះមានសុភមង្គលហើយ"**។ ចិត្តមេត្តាករុណាជាអំណោយទានមកពីព្រះជាម្ចាស់។ យើងទាំងអស់គ្នា ចង់បានសេចក្ដីស្រឡាញ់ ដើម្បីមានកម្លាំងចិត្តក្នុងការរស់នៅ។ ក្នុងអគ្គសញ្ញាអាពាហ៍ពិពាហ៍ប៉ុន្មានថ្ងៃមុននេះ ខ្ញុំបានទេសនាអំពីសេចក្ដីស្រឡាញ់ ដោយសូមឲ្យគូស្រករថ្មីស្រឡាញ់គ្នារហូត និងគោរពគ្នាអស់មួយជីវិតទោះបីក្នុងគ្រាអាសន្នឬអំណរសប្បាយ។ មីងម្នាក់ដែលចូលរួមក្នុងពិធីនោះបានស្ដាប់ធម្មទេសនានេះរួចហើយ គាត់ចាប់ផ្ដើមនឹកគិតពីជីវិតរបស់គាត់។ ពេលចប់ពិធីគាត់មកប្រាប់ខ្ញុំថា គាត់រៀបការជាង២០ឆ្នាំហើយ ប៉ុន្តែមិនដែលបានគិតពីសេចក្ដីស្រឡាញ់ថាជាអ្វីទេគាត់គិតតែពីរកលុយ។ ដូច្នេះពីមួយថ្ងៃទៅមួយថ្ងៃ គាត់ចេះតែជេរថាប្ដីខ្ជិលមិនខំរកស៊ីឲ្យមានបាន។ នៅក្នុងពិធីពេលឃើញកូនកម្លោះកូនក្រមុំនិយាយសន្យាគ្នាថា **"អូនយកបងជាប្ដី/បងយកអូនជាប្រពន្ធ និងស្រឡាញ់គ្នាអស់មួយជីវិត"** នោះគាត់ភ្ញាក់ស្មារតីថាគាត់មិនទាន់បានស្រឡាញ់ប្ដីគ្រប់គ្រាន់នៅឡើយទេ។ ដូច្នេះយប់នេះគាត់នឹងប្រាប់ប្ដីថា "ខ្ញុំស្រឡាញ់ប៉ាវ៉ា"។ យប់នោះប្រហែលប្ដីគាត់នឹងភ្ញាក់ថា **"ជាង២០ឆ្នាំហើយដែលខ្ញុំទើបបានឮពាក្យថាស្រឡាញ់ពីម៉ាក់វ៉ា"**។ នេះជាអ្វីដែលយើងបានទទួលពីព្រះយេស៊ូ។

ប៉ុន្មានថ្ងៃមុននៅទីនេះ មានបងប្អូនជាង៤០០នាក់មកពីកន្លែងផ្សេងៗ ចូលរួមពិធីប្រកួតកីឡាក្នុងលក្ខណៈជាមិត្តភាពនិងសហការគ្នា។ តាំងពីព្រឹករហូតដល់ល្ងាច ទោះបីថ្ងៃក្ដៅក៏យើងសប្បាយដែរ ដោយសារយើងមានឱកាសនិយាយរាក់ទាក់គ្នា ស្និទ្ធស្នាលគ្នា យើងស្រឡាញ់គ្នាទៅវិញទៅមកដូចបងប្អូន។ អត់មានអ្នកដែលចង់ឈ្នះដើម្បីឲ្យគូប្រកួតឈឺចិត្ត

ឬបាក់មុខ អត់មានអ្នកដែលបង្កើតរឿងឈ្លោះ ផ្ទុយទៅវិញបង្កើតមិត្តភាពនៅក្នុងសេចក្ដីស្រឡាញ់។ នេះជាអ្វីដែលយើងបានទទួលពីព្រះយេស៊ូ ជាអ្វីដែលពិភពលោកកំពុងទន្ទឹងរង់ចាំ។ កាលពីអាទិត្យមុន ខ្ញុំបានទៅសួរសុខទុក្ខបងប្អូននៅកំពង់អំពិល។ នៅទីនោះមានបងប្អូនជាង៤០នាក់ស្វែងយល់ព្រះបន្ទូលព្រះយេស៊ូ ចង់ស្គាល់សេចក្ដីស្រឡាញ់របស់ព្រះអង្គ ចង់ទទួលធម៌មេត្តាករុណាពីព្រះអង្គ។ នេះជាផលផ្លែដែលយើងបានទទួលពីព្រះជាម្ចាស់ស្របតាមព្រះបន្ទូលរបស់ព្រះយេស៊ូថា **"អ្នកណាមានចិត្តមេត្តាករុណា អ្នកនោះមានសុភមង្គល ហើយដ្បិតព្រះជាម្ចាស់នឹងសម្ដែងព្រះហឫទ័យមេត្តាករុណាដល់ពួកគេ"**។

ឆ្នាំនេះសម្រាប់យើងជាគ្រីស្ដបរិស័ទនៅចម្ការទៀង យើងត្រូវគិតអំពីរបៀបសម្ដែងធម៌មេត្តាករុណាឡើងវិញ។ យើងដឹងហើយថា ព្រះសហគមន៍របស់យើងមានគ្រីស្ដបរិស័ទជាច្រើនដែលមិនរស់នៅទីនេះ និងមានគ្រីស្ដបរិស័ទជាច្រើនដែលមិនចូលព្រះវិហារសោះ។ ដូច្នេះយើងត្រូវគិត ត្រូវរកឱកាសយូរៗម្ដងទៅសួរសុខទុក្ខបងប្អូនដែលកំពុងឃ្លាតឆ្ងាយពីព្រះយេស៊ូឲ្យគេមកវិញ ឲ្យមកទទួលធម៌មេត្តាករុណារបស់ព្រះអង្គដែលគេធ្លាប់បានទទួលរួចមកហើយ។ តាមសេចក្ដីពិត គឺមានតែព្រះយេស៊ូទេ ដែលណែនាំឲ្យយើងមានសេចក្ដីសុខ-សាន្ត។ ព្រះសហគមន៍យើងនៅចម្ការទៀង មានបេសកកម្មមួយយ៉ាងពិសេស មិនមែនតែជាគ្រីស្ដទូតទៅដល់ទន្លេបាទី ទៅដល់កំពង់អំពិល ទៅដល់គីរីវង់ ទៅដល់តាកែវឬទៅដល់សន្ទះប៉ូលប៉ុណ្ណោះទេ ប៉ុន្តែយើងជាគ្រីស្ដទូតដែលត្រូវរំឭកដល់គ្រីស្ដបរិស័ទនៅក្នុងព្រះសគមន៍របស់យើងដែរ ដើម្បីឲ្យគេបន្ដពោរពេញដោយសុភមង្គលថែមទៀតនិងថែមទៀតដូចយើងបានស្ដាប់ឮព្រះបន្ទូលថា **"ចូរអរសប្បាយរីករាយឡើង ព្រោះអ្នករាល់គ្នានិងទទួលរង្វាន់យ៉ាងធំនៅស្ថានបរមសុខ"**។

ដូច្នេះសម្រាប់ឆ្នាំថ្មីនេះ ខ្ញុំសូមជូនពរដល់បងប្អូនទាំងអស់ ទី១ សូមឲ្យយើងម្នាក់ៗបន្ដទុកចិត្តទាំងស្រុង លើព្រះយេស៊ូ ដោយហ៊ាននិយាយជារៀងរាល់ថ្ងៃថា **"ទូលបង្គំសូមផ្ញើជីវិតលើព្រះយេស៊ូ ទូលបង្គំទុកចិត្តលើព្រះយេស៊ូខ្លាំងណាស់"**។ ទី២ សូមឲ្យយើងទាំងអស់

គ្នាចេះស្វាគមន៍គ្នាទៅវិញទៅមក ដូចព្រះយេស៊ូបង្ហាញព្រះហឫទ័យស្រឡាញ់របស់ព្រះបិតាដល់យើង។ ទី៣ សូមឲ្យបងប្អូនមានមោទនភាពដោយសារយើងជាគ្រីស្តទូតរបស់ព្រះគ្រីស្តមានកិត្តិយសដោយសារយើងជាសាវ័ករបស់ព្រះគ្រីស្ត មានអំណរសប្បាយដោយសារយើងបានទទួលអគ្គសញ្ញាជ្រមុជទឹក មានកម្លាំងដោយសារយើងបានស្គាល់ព្រះយេស៊ូ។ សូមបងប្អូនចែកមោទនភាព កិត្តិយស អំណរសប្បាយ និងកម្លាំងនោះដល់បងប្អូនឯទៀតៗ ដូចព្រះគ្រីស្តបានប្រទានមកយើងដែរ។

ខ្ញុំសូមជូនពរបងប្អូន សូមឲ្យឆ្នាំថ្មីនេះ ទៅជាឆ្នាំដ៏សុខសាន្ត ទៅជាឆ្នាំដែលយើងបន្តបង្កើតព្រះសហគមន៍របស់យើង គឺព្រះសហគមន៍ដែលចេះរួបរួមគ្នា ដើម្បីសម្តែងព្រះហឫទ័យមេត្តាករុណារបស់ព្រះជាម្ចាស់ ដល់មនុស្សទាំងអស់។

**"ចូរអរសប្បាយរីករាយឡើង ព្រោះអ្នករាល់គ្នានឹងទទួលរង្វាន់យ៉ាងធំនៅស្ថានបរមសុខ"**

# យើងនៅជាសញ្ញាជាក់ស្តែង ដើម្បីឲ្យមនុស្សលោកឃើញព្រះយេស៊ូ

We are signs of the presence of Christ

---

អត្ថបទទី១៖ កក ១៤, ២១ខ-២៧
អត្ថបទទី២៖ វវ ២១, ១-៥ក
ដំណឹងល្អ៖ យហ ១៣, ៣១-៣៣ក, ៣៤-៣៥

ក្នុងការរស់នៅរបស់យើង ព្រះបន្ទូលរបស់ព្រះជាម្ចាស់ជាអ្វីមួយដែលសំខាន់បំផុត។ ព្រះបន្ទូលរបស់ព្រះជាម្ចាស់មានជីវិតដែលបំភ្លឺ និងដែលណែនាំយើង។ ក្នុងភូមិភាគភ្នំពេញទាំងមូលប៉ុន្មានថ្ងៃកន្លងមក មានបេក្ខជនជាង១៣០នាក់ជួបជុំគ្នារិះគិតព្រះបន្ទូលព្រះជាម្ចាស់តាមសំណួរថា តើព្រះបន្ទូលរបស់ព្រះជាម្ចាស់បានបំភ្លឺជីវិតខ្ញុំរបៀបណា? តើព្រះបន្ទូលរបស់ព្រះជាម្ចាស់ចិញ្ចឹមជីវិតខ្ញុំរបៀបណា? តើព្រះបន្ទូលរបស់ព្រះជាម្ចាស់ណែនាំជីវិតរបស់ខ្ញុំជាប្រចាំថ្ងៃរបៀបណា?។ ម្សិលមិញយើងបានស្តាប់ព្រះបន្ទូល ដែលណែនាំយើងឲ្យបង្កើតទំនាក់ទំនងជាមួយព្រះជាម្ចាស់ជាប្រចាំ។ ព្រះបន្ទូលរបស់ព្រះជាម្ចាស់មានចែងទុកក្នុងព្រះ-គម្ពីរ។ ព្រះគម្ពីរមិនមែនតែជាសៀវភៅមួយយ៉ាងក្រាស់ មិនមែនតែជាបណ្ណាល័យយ៉ាងតូចមួយប៉ុន្តែព្រះគម្ពីរគឺ ជាព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែលកំពុងមានព្រះបន្ទូលមកខ្ញុំផ្ទាល់ដែលណែនាំជីវិតរបស់ខ្ញុំជាប្រចាំ។

រាល់ដងយើងបាននិយាយថា ពេលចូលអភិបូជាគឺជាឱកាសមួយពិសេសដើម្បីស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ពីម្សិលមិញខ្ញុំបានសួរបងប្អូនដែលខ្ញុំបានណែនាំថា **"តើ**

---

ក្នុងអភិបូជាបិទសិក្ខាសាលាព្រះគម្ពីរនៅភ្នំពេញថ្មី
ថ្ងៃទី២៤ មេសា ២០១៦

**ថ្ងៃអាទិត្យមុន យើងអានអត្ថបទគម្ពីរដំណឹងល្អអំពីអ្វី?"** គេគ្រប់គ្នាចាប់ផ្តើមមើលមុខគ្នាទៅវិញទៅមក។ ឥឡូវដូចគ្នាដែរបើខ្ញុំសួរថា **"តើអម្បាញ់មិញ យើងបានស្តាប់អត្ថបទគម្ពីរអំពីអ្វី?"** នោះយើងពិបាកចាំណាស់ ជួនកាលយើងស្តាប់មែន ប៉ុន្តែដូចជាមិនបានចូលទៅខាងក្នុងទេ ដូចពាក្យថាចាក់ទឹកលើក្បាលទា។ ថ្ងៃនេះខ្ញុំសង្ឃឹមថា អត្ថបទដែលយើងបានស្តាប់នឹងបំភ្លឺជីវិតរបស់យើងពិតមែន។ តើបំភ្លឺជីវិតរបស់យើងរបៀបណា?

ក្នុងអភិបូជា យើងមានអត្ថបទទាំងអស់ចំនួន៤ គឺមានអត្ថបទទី១ មានទំនុកតម្កើងជាពេលវេលាមួយដើម្បីយើងចូលទៅក្នុង ការអធិដ្ឋានរបស់ជនជាតិហេប្រឺពីដើម មានអត្ថ-បទទី២ និងមានគម្ពីរដំណឹងល្អ។ ថ្ងៃនេះខ្ញុំចង់បង្ហាញពីចំណុចខ្លះៗដើម្បីឲ្យយើយល់ថាព្រះបន្ទូលរបស់ព្រះជាម្ចាស់ពិតមែនចិញ្ចឹម និងណែនាំយើងសម្រាប់មួយអាទិត្យ។ ប៉ុន្តែអត្ថបទនីមួយៗក៏ជាទស្សនៈមួយសម្រាប់យើងអស់មួយជីវិតដែរ។

១/ ក្នុងអត្ថបទទី១ ដែលស្រង់ចេញពីគម្ពីរកិច្ចការគ្រីស្តទូត បានបង្ហាញពីរបៀបដែលក្រុមគ្រីស្តទូតបានបង្កើតព្រះសហគមន៍ពីដើម។ ពីដើមក្រុមគ្រីស្តទូតដើរពីកន្លែងមួយទៅកន្លែងមួយ ជួបជាមួយបងប្អូនដើម្បីប្រកាសអំពីព្រះយេស៊ូដែលមានព្រះជន្មរស់ឡើងវិញណែនាំឲ្យមនុស្សជាច្រើនចង់ទទួលអគ្គសញ្ញាជ្រមុជទឹក។ ជាពិសេសក្រុមគ្រីស្តទូតក៏ខិតខំដាស់តឿនក្រុមសាវ័កថ្មីៗឲ្យតាំងចិត្តមាំមួន និងលើកទឹកចិត្តគេឲ្យមានជំនឿ មានកម្លាំង មានចិត្តក្លាហាន ចិត្តតស៊ូ ដោយបញ្ជាក់យ៉ាងច្បាស់ថា **"យើងត្រូវតែឆ្លងកាត់ទុក្ខវេទនាជាច្រើន ដើម្បីបានចូលទៅក្នុងព្រះរាជ្យព្រះជាម្ចាស់"**។ ក្រោយមកមានការតែងតាំងក្រុមព្រឹទ្ធាចារ្យមានន័យថានៅតាមកន្លែងនីមួយៗ គេរើសចាស់ទុំម្នាក់ឲ្យគាត់ទទួលតួនាទីដឹកនាំក្រុមរបស់គេ។ ក្រុមគ្រីស្តទូតចេញទៅប្រកាសដំណឹងល្អ ដោយសារព្រះសហគមន៍បានចាត់អស់លោកឲ្យចេញទៅ ដោយផ្ញើអស់លោកលើព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់។ ដូច្នេះសម្រាប់យើងសព្វថ្ងៃ តាមរយៈអត្ថបទទី១ គឺយើងបានទទួលកម្លាំងមួយពិសេសដើម្បីទៅជាអ្នកប្រកាសដំណឹងល្អ នៅតាមកន្លែងដែលយើងរស់នៅ ដោយដឹងថា

យើងអាចប្រកាសដំណឹងល្អបានយើងអាចផ្តល់សក្ខីភាពបាន យើងអាចលើកទឹកចិត្តដល់ក្រុមរបស់យើងបាន គឺដោយសារយើងពឹងផ្អែកលើព្រះអំណោយទានរបស់ព្រះជាម្ចាស់។

ថ្ងៃនេះពេលត្រឡប់ទៅវិញ សូមឲ្យបងប្អូននឹកឃើញថាទោះបីបងប្អូនមកពីភូមិតូចមួយក្តី ឬមកពីព្រះសហគមន៍ថ្មីមួយក្តី ឬមកពីទីក្រុងជាព្រះសហគមន៍ធំក្តី ឬមកពីព្រះ-សហគមន៍ចាស់យូរហើយក្តី ឬទោះបីបងប្អូនជាគ្រីស្តបរិស័ទថ្មីពីឆ្នាំ២០១២រហូតមកដល់ពេលនេះក្តី **"តើយើងធ្វើដូចម្តេចដើម្បីលើកទឹកចិត្តគ្នា? យើងធ្វើដូចម្តេចដើម្បីប្រកាសដំណឹងល្អថែមទៀត?"** ដើម្បីឲ្យអ្នកដែលកំពុងស្វែងយល់ព្រះបន្ទូលរបស់ព្រះជាម្ចាស់យល់ថាព្រះបន្ទូលរបស់ព្រះជាម្ចាស់ជាកម្លាំងឲ្យយើងអាចឆ្លងឧបសគ្គទាំងឡាយបាន ឲ្យយើងបង្កើតព្រះរាជ្យរបស់ព្រះជាម្ចាស់បាន។ ថ្ងៃនេះដែរ ក្រោយពីស្តាប់អត្ថបទទី១ហើយខ្ញុំសង្ឃឹមថា យើងទាំងអស់គ្នានឹងមានកម្លាំងថ្មីដើម្បីទៅជាអ្នកប្រកាសដំណឹងល្អ ជាអ្នកលើកទឹកចិត្តក្រុមគ្រីស្តបរិស័ទដែលយើងស្គាល់ និងជាពិសេសទៅជាអ្នកផ្តល់កម្លាំងឲ្យអស់បងប្អូនដែលកំពុងស្វែងយល់ព្រះបន្ទូលរបស់ព្រះជាម្ចាស់។

២/ ទំនុកតម្កើង **"ព្រះជាអម្ចាស់ ប្រកបដោយព្រះហឫទ័យត្រចង់ ប្រណីសន្តោសករុណាមុតមាំ អត់ធ្មត់កន្លង អាណិតមេត្តា។ ព្រះជាអម្ចាស់ ព្រះទ័យសប្បុរសលើមនុស្សលោកាទ្រង់មានព្រះទ័យ សន្តោសករុណា មនុស្សគ្រប់អាត្មា រស់ពេញផែនដី"** នេះយើងកំពុងប្រកាសថាព្រះជាម្ចាស់ មានព្រះហឫទ័យប្រណីសន្តោសព្រះជាម្ចាស់មានព្រះហឫទ័យអត់ធ្មត់ ព្រះជាម្ចាស់មានព្រះហឫទ័យអាណិតមេត្តា ព្រះជាម្ចាស់មានព្រះ-ហឫទ័យសប្បុរសសម្រាប់មនុស្សទាំងអស់។ សេចក្តីប្រកាសនេះជាកម្លាំងមួយដ៏ពិសេសណែនាំឲ្យយើងទទួលស្គាល់ថា ព្រះជាម្ចាស់ស្រឡាញ់ខ្ញុំ។បងប្អូនដែលបានទទួលអគ្គសញ្ញាលើកលែងទោស មានឱកាសទទួលពិសោធន៍អំពីព្រះជាម្ចាស់ស្រឡាញ់គេ។ ថ្ងៃនេះពេលយើងកោតសរសើរព្រះជាម្ចាស់តាមទំនុកតម្កើង ជាឱកាសមួយដើម្បីទទួលស្គាល់ថា ពិតមែនខ្ញុំបានទទួលអំណរសប្បាយយ៉ាងពិសេសដោយសារព្រះជាម្ចាស់ស្រឡាញ់ខ្ញុំ ដោយសារព្រះ-

ជាម្ចាស់លើកលែងទោសឲ្យខ្ញុំ ដោយសារព្រះជាម្ចាស់អាណិតមេត្តាខ្ញុំ ណែនាំឲ្យខ្ញុំមានអំណរសប្បាយពោរពេញ។ តើខ្ញុំជានរណា? ខ្ញុំគឺជាមនុស្សតូចតាច ជាមនុស្សទន់ខ្សោយជាមនុស្សមានបាបដែលព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការទតមើលមកខ្ញុំ ស្រឡាញ់ខ្ញុំ អាណិតខ្ញុំ លើកលែងទោសឲ្យខ្ញុំ និងណែនាំឲ្យខ្ញុំមានជីវិតថ្មី។ ពេលយើងសូត្រទំនុកតម្កើង ជាពេលដែលយើងប្រកាសជំនឿរបស់យើងលើព្រះជាម្ចាស់ ជាពេលយើងអរព្រះគុណព្រះជាម្ចាស់សម្រាប់ជីវិតដែលយើងបានទទួល ជាពេលយើងទទួលស្គាល់ថា ពិតមែនខ្ញុំជាអ្នកមានបាបប៉ុន្តែព្រះជាម្ចាស់លើកលែងទោសឲ្យខ្ញុំ។

៣/ អត្ថបទទី២ ចេញពីព្រះគម្ពីរវិវរណៈដែលសន្តៈយ៉ូហានថែងពីនិមិត្តរបស់លោកផ្ទាល់ **"ខ្ញុំយ៉ូហាន ឃើញផ្ទៃមេឃថ្មី និងផែនដីថ្មី"**។ ផែនដីយើងនេះជាកន្លែងដ៏អស្ចារ្យដែលព្រះជាម្ចាស់គង់នៅជាមួយមនុស្សលោក គង់នៅក្នុងចំណោមពួកយើង ហើយពួកយើងទៅជាប្រជារាស្ត្ររបស់ព្រះអង្គដើម្បីរួមគ្នាកសាងផែនដីថ្មី។ នេះជាដំណឹងល្អសម្រាប់យើងដែលណែនាំឲ្យយើងមានកម្លាំងថែមទៀត ដោយសារយើងដឹងថាព្រះជាម្ចាស់បានជ្រើសរើសលោកីយ៍នេះ ពិភពលោកនេះដើម្បីគង់នៅជាមួយយើង និងព្រះអង្គណែនាំយើងឲ្យបង្កើតពិភពលោកថ្មី។ បងប្អូនដែលបានទទួលអគ្គសញ្ញាជ្រមុជទឹកពីឆ្នាំ២០១២ រហូតដល់ឆ្នាំ២០១៦ មានពិសោធន៍ពីជីវិតថ្មីដែលបងប្អូនបានទទួលពីព្រះជាម្ចាស់។ បងប្អូនបានទទួលជីវិតថ្មីក៏ដោយសារមានរៀមច្បងយើង បានធ្វើជាសាក្សីនៃជីវិតថ្មីនេះចំពោះបងប្អូន។ ខ្ញុំជឿថាអត្ថបទទី២ដែលយើងបានស្តាប់បានចូលទៅក្នុងចិត្តរបស់យើងណែនាំឲ្យយើងចូលទៅក្នុងពិសោធន៍យ៉ាងជ្រៅក្នុងទំនាក់ទំនងរបស់យើងជាមួយព្រះជាម្ចាស់។ សន្តៈយ៉ូហានមានប្រសាសន៍ថា **"ខ្ញុំឃើញផ្ទៃមេឃថ្មី និងផែនដីថ្មី"** នោះណែនាំឲ្យយើងនឹកឃើញភ្លាមដល់ជីវិតថ្មីអំណរសប្បាយថ្មីដែលយើងបានទទួលដោយសារព្រះជាម្ចាស់បានជ្រើសរើសយើងធ្វើជាបុត្រធីតារបស់ព្រះអង្គ ហើយព្រះអង្គប្រទានកម្លាំងឲ្យយើងបន្ត កសាងពិភពលោកថ្មី កសាងផែនដីថ្មី តាមព្រះហឫទ័យរបស់ព្រះអង្គ។

៤/ តាមអត្ថបទគម្ពីរដំណឹងល្អ ព្រះយេស៊ូបានឆ្លើយតបនឹងសំណួររបស់យើងដែលថាតើយើងត្រូវធ្វើអ្វីដើម្បីកសាងផែនដីថ្មី? តើយើងត្រូវធ្វើអ្វីដើម្បីឲ្យការរស់នៅរបស់យើងថ្មីគ្រប់ពេលវេលា?។ ព្រះយេស៊ូមានព្រះបន្ទូលថា **"ខ្ញុំឲ្យវិន័យថ្មីដល់អ្នករាល់គ្នា គឺត្រូវស្រឡាញ់គ្នាទៅវិញទៅមកដូចខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ។ បើអ្នករាល់គ្នាស្រឡាញ់គ្នាទៅវិញទៅមក មនុស្សទាំងអស់មុខជានឹងដឹងថា អ្នករាល់គ្នាពិតជាសាវ័ករបស់ខ្ញុំ"** ដែលមានន័យថា យើងទទួលជីវិតថ្មីតាមវិន័យថ្មីរបស់ព្រះយេស៊ូដែលមិនដូចនឹងវិន័យរបស់ជនជាតិអ៊ីស្រាអែលពីដើមដែល **"ត្រូវស្រឡាញ់បងប្អូនឯទៀតៗដូចស្រឡាញ់ខ្លួនឯងដែរ"**។ វិន័យថ្មី របស់ព្រះយេស៊ូលែង **"ត្រូវស្រឡាញ់គ្នាទៅវិញទៅមកដូចស្រឡាញ់ខ្លួនឯង"** ទៀតហើយប៉ុន្តែ **"ត្រូវស្រឡាញ់គ្នាទៅវិញទៅមកដូចខ្ញុំស្រឡាញ់អ្នករាល់គ្នាដែរ"**។ ដូច្នេះវិន័យថ្មីរបស់ព្រះយេស៊ូណែនាំឲ្យយើងសម្លឹងមើលរបៀបរបស់ព្រះយេស៊ូ ជារបៀបដែលលើកទឹកចិត្តដល់អស់អ្នកកំពុងមានរបួស ជារបៀបដែលលាងជើង ជារបៀបដែលបម្រើ និងជារបៀបដែលលើកលែងទោស។ ដូច្នេះតាមអត្ថបទទី១ គឺនាំឲ្យយើងបង្កើតព្រះសហគមន៍ថ្មី។ តាមអត្ថបទទំនុកតម្កើងនាំឲ្យយើងទទួលស្គាល់ព្រះជាម្ចាស់ជាសេចក្តីស្រឡាញ់ និងយើងស្រឡាញ់ព្រះអង្គយើង។ តាមអត្ថបទទី២នាំឲ្យយើង ជាអ្នកដែលទទួលជីវិតថ្មីពីព្រះជាម្ចាស់ ចេញទៅកសាងពិភពលោកថ្មី និងអត្ថបទគម្ពីរដំណឹងល្អនាំឲ្យយើងស្រឡាញ់គ្នាទៅវិញទៅមកដូចព្រះយេស៊ូស្រឡាញ់យើង។ នេះជាវិន័យថ្មីដែលយើងទទួល។

ថ្ងៃនេះព្រះសហគមន៍ណែនាំឲ្យ យើងទៅជាអគ្គសញ្ញា នៃមេត្តាករុណារបស់ព្រះជាម្ចាស់ដែលមានន័យថា ឲ្យយើងទៅជាសញ្ញាជាក់ស្តែងដែលមនុស្សលោកអាចមើលឃើញព្រះជាម្ចាស់បាន ដូចព្រះយេស៊ូមានព្រះបន្ទូលថា **"បើអ្នករាល់គ្នាស្រឡាញ់គ្នាទៅវិញទៅមក មនុស្សទាំងអស់មុខជានឹងដឹងថា អ្នករាល់គ្នាពិតជាសាវ័ករបស់ខ្ញុំមែន"**។ ប្រសិនបើនៅក្នុងព្រះសហគមន៍យើងឈ្លោះគ្នា យើងបង្កើតរឿងស្អប់គ្នា នោះយើងមិនអាចបង្ហាញសញ្ញាសម្គាល់ថា យើងជាសាវ័ករបស់ព្រះយេស៊ូដល់មនុស្សលោកបានទេ។ ផ្ទុយទៅវិញប្រសិន

បើយើងចេះស្រឡាញ់គ្នាទៅវិញទៅមក នៅក្នុងពិភពមួយដែលអត់សូវមានសេចក្ដីស្រឡាញ់ចំពោះអ្នកតូចតាច អ្នកក្រីក្រ នោះយើងនឹងទៅជាសញ្ញាសម្គាល់វត្តមានរបស់ព្រះជាម្ចាស់។

បងប្អូនជាទីស្រឡាញ់!

ប្រសិនបើយើងយកចិត្តទុកដាក់ស្ដាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ នោះយើងមិនខ្វះកម្លាំង មិនខ្វះយោបល់ និងមិនខ្វះជំនឿដើម្បីរស់នៅជាគ្រីស្ដបរិស័ទយ៉ាងពិតប្រាកដនៅក្នុងសង្គមបច្ចុប្បន្ននេះទេ។ រាល់អាទិត្យពេលដែលយើងចូលក្នុងអភិបូជា យើងត្រូវតែយកចិត្តទុកដាក់ស្ដាប់ដើម្បីឲ្យព្រះបន្ទូលចូលយ៉ាងជ្រៅក្នុងដួងចិត្តរបស់យើង។ ដូចយើងឃើញស្រាប់នៅខាងមុខព្រះវិហារ មានរូបសន្ដៈប៉ូលដែលមានព្រះគម្ពីរនៅក្នុងដៃម្ខាងនិងដៃម្ខាងទៀតមានកាន់ដាវ នេះមានន័យថាព្រះបន្ទូលរបស់ព្រះជាម្ចាស់ប្រៀបបីដូចជាដាវដែលចាក់ទម្លុះទៅក្នុងបេះដូងយើង ណែនាំឲ្យយើងឈឺផងនិងឲ្យយើងភ្ញាក់ស្មារតីផង ដើម្បីចេញទៅប្រកាសដំណឹងល្អ ដើម្បីបង្កើតពិភពលោកថ្មី ព្រះសហគមន៍ថ្មីដែលស្រឡាញ់គ្នាទៅវិញទៅមកដូចព្រះយេស៊ូ។ ដូច្នេះ ព្រះបន្ទូលមិនមែនផ្អែមទេ ប៉ុន្តែជូរអែមដើម្បីឲ្យយើងភ្ញាក់ស្មារតី។

ខ្ញុំសូមអំពាវនាវឲ្យបងប្អូនទាំងអស់គ្នាយកចិត្តទុកដាក់ យកពេលវេលាដើម្បីអានព្រះ-បន្ទូលរបស់ព្រះជាម្ចាស់។ ប្រសិនបើមានសមត្ថភាព តាមព្រះសហគមន៍នីមួយៗត្រូវបង្កើតក្រុមតូចៗមានគ្នាបួនឬប្រាំនាក់ មុនចូលអភិបូជាក៏បាន ឬថ្ងៃសៅរ៍ពេលល្ងាចក៏បានយើងប្រជុំគ្នាដើម្បីអានព្រះគម្ពីរដំណឹងល្អដែលយើងនឹងស្ដាប់នៅក្នុងអភិបូជា។ យើងអានទុកជាមុនយើងអធិដ្ឋានយ៉ាងស្ងៀមស្ងាត់ ហើយយើងចែករំលែក **"តើព្រះបន្ទូលនេះមាន អត្ថន័យយ៉ាងណាសម្រាប់ជីវិតរបស់ខ្ញុំ?"**។ ចែករំលែកព្រះបន្ទូលជារបៀបដែលយើងបង្ហាញពីជីវិតយើងផ្ទាល់ ពីក្រុមគ្រួសាររបស់យើង ពីបញ្ហារបស់យើង ពីការរៀនសូត្ររបស់យើង ពីទុក្ខលំបាករបស់យើងក្នុងជីវិតប្រចាំថ្ងៃ ដើម្បីដឹងថាតើថ្ងៃនេះព្រះបន្ទូលណែនាំការរស់នៅរបស់ខ្ញុំយ៉ាងណា? យើងទាំងអស់គ្នាអង្គុយនៅចំពោះមុខព្រះនាងម៉ារី យើងអានព្រះគម្ពីរដើម្បីឲ្យព្រះ-

បន្ទូលបំភ្លឺជីវិតរបស់យើង ដោយយើងចែករំលែកយោបល់ ដោយយើងស្តាប់គ្នាទៅវិញទៅមកដោយដឹងថានៅពេលនេះព្រះយេស៊ូគង់នៅជាមួយយើង។

នៅពេលបងប្អូនត្រឡប់ទៅតាមព្រះសហគមន៍វិញ សូមបងប្អូនជំរុញលោកបូជាចារ្យ បងប្រុសបងស្រី ជួយបង្កើតក្រុមតូចៗដើម្បីរិះគិតព្រះបន្ទូល ដើម្បីឲ្យព្រះបន្ទូលចិញ្ចឹមជីវិតយើងពិតមែន។ មានបងប្អូនខ្លះសួរថា **"មូលហេតុអ្វីលោកអភិបាលចាំគម្ពីរច្រើនម្ល៉េះ?"** តាមពិតគឺដោយសារព្រះបន្ទូលត្រឡប់ទៅជាជីវិតរបស់ខ្ញុំផ្ទាល់ ដោយសារព្រះបន្ទូលជាព្រះ-បន្ទូលដែលណែនាំខ្ញុំពីមួយថ្ងៃទៅមួយថ្ងៃ។ ខ្ញុំសង្ឃឹមថា បងប្អូនទាំងអស់គ្នាក៏នឹងអាចដូចខ្ញុំដែរ ប្រសិនបើបងប្អូនអានព្រះគម្ពីរជារៀងរាល់ថ្ងៃ នោះបន្តិចម្តងៗព្រះបន្ទូលនឹងត្រឡប់ទៅជាតែមួយនឹងជីវិតរបស់បងប្អូនផ្ទាល់។ ព្រះបន្ទូលមិនដូចជាមេរៀនគណិតវិទ្យា មេរៀនគីមីវិទ្យាដែលក្រោយពេលប្រឡងយើងភ្លេចអស់នោះទេ ព្រះគម្ពីរគឺជាព្រះបន្ទូលរបស់ព្រះយេស៊ូ ដែលយាងចូលទៅក្នុងជីវិតរបស់យើង ដើម្បីដឹកនាំជីវិតយើងពីមួយថ្ងៃទៅមួយថ្ងៃ។

ដូច្នេះថ្ងៃនេះនៅក្នុងឆ្នាំព្រះមហាករុណាទិគុណ យើងខ្ញុំសូមអរព្រះគុណព្រះជាម្ចាស់ម្តងទៀត ដែលព្រះអង្គយាងមកដើម្បីណែនាំជីវិតរបស់យើងខ្ញុំឲ្យទៅជាជីវិតថ្មី និងណែនាំយើងខ្ញុំឲ្យទៅជាសញ្ញាសម្គាល់ជាក់ស្តែងអំពីសេចក្តីស្រឡាញ់របស់ព្រះយេស៊ូ ដូចព្រះអង្គមានព្រះបន្ទូលថា **"សូមស្រឡាញ់គ្នាទៅវិញទៅមក ដូចខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ"**។

# ព្រះវិញ្ញាណដ៏វិសុទ្ធជាកម្លាំងដើម្បីបំពេញបេសកកម្ម អំពីព្រះជាម្ចាស់

The Holy Spirit, our strength!

អត្ថបទទី១៖ កក ១, ១-១១
អត្ថបទទី២៖ ហប ៩, ២៤-២៨ និង ២០
ដំណឹងល្អ៖ លក ២៤, ៤៦-៥៣

ថ្ងៃនេះយើងគោរពព្រះយេស៊ូយាងឡើងស្ថានបរមសុខ គឺជាពេលវេលាមួយដ៏អស្ចារ្យរបស់ព្រះសហគមន៍ ដោយសារព្រះយេស៊ូយាងឡើងស្ថានបរមសុខ ទាំងមានក្រុមគ្រីស្តទូតកំពុងឈរមើល ក្រោយពេលព្រះអង្គបង្ហាញព្រះកាយអស់រយៈពេល៤០ថ្ងៃ។ សម្រាប់យើង ថ្ងៃដែលព្រះយេស៊ូយាងឡើងស្ថានបរមសុខ គឺជាពេលវេលាមួយឲ្យយើងរិះគិតព្រះបន្ទូល ដែលព្រះ-អង្គបានទុកជាមរតកឲ្យក្រុមគ្រីស្តទូត។ ព្រះយេស៊ូបានជ្រើសរើសក្រុមគ្រីស្តទូត១២រូបមុនពេលដែលព្រះអង្គសោយទិវង្គត មកអប់រំណែនាំឲ្យគេរៀបចំខ្លួនទៅជាសាវ័កពិសេស ដើម្បីឲ្យគេបន្តបេសកកម្មរបស់ព្រះអង្គ។

ព្រះយេស៊ូបានប្រគល់ធម្មវិន័យថ្មី គឺ **"ស្រឡាញ់គ្នាទៅវិញទៅមកដូចខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ"**។ ព្រះយេស៊ូបានសម្តែងកិច្ចការមួយយ៉ាងពិសេសដើម្បីឲ្យគេធ្វើតាម គឺព្រះអង្គលាងជើងក្រុមគ្រីស្តទូត ទាំងមានព្រះបន្ទូលថា **"សូមបម្រើគ្នាទៅវិញទៅមកដូចខ្ញុំបានបម្រើអ្នករាល់គ្នាដែរ"**។ ព្រះយេស៊ូបានអធិដ្ឋានឲ្យក្រុមគ្រីស្តទូតដើម្បីឲ្យសាវ័ករបស់ព្រះអង្គទៅជាធ្លុងតែមួយ ចិត្តគំនិតតែមួយ ដូចព្រះបុតា្រនិងព្រះបិតាជាអង្គតែមួយ ដើម្បីឲ្យមនុស្សលោកជឿលើព្រះជាម្ចាស់។ ដើម្បីឲ្យយើងមានកម្លាំងអនុវត្តព្រះបន្ទូលរបស់ព្រះអង្គនោះព្រះយេស៊ូបានមានព្រះបន្ទូលថា **"កុំព្រួយបារម្ភបន្តិចទៀតខ្ញុំនឹងទៅឯព្រះបិតារបស់**

អភិបូជា អគ្គសញ្ញាណបថ្វាស នៅក្តីកណ្តាល
ថ្ងៃទី ០៨ ឧសភា ២០១៦

**ខ្ញុំ ហើយខ្ញុំនឹងផ្ញើព្រះមួយអង្គយ៉ាងពិសេស គឺព្រះវិញ្ញាណដ៏វិសុទ្ធដែលយាងមក ជាព្រះដែលការពារថែរក្សា"** ដូចអត្ថបទថ្ងៃនេះ ព្រះយេស៊ូមានព្រះបន្ទូលថា **"បន្តិចទៀតខ្ញុំនឹងចាត់ព្រះវិញ្ញាណមកសណ្ឋិតលើអ្នករាល់គ្នា"**។ ព្រះវិញ្ញាណដ៏វិសុទ្ធជាព្រះជាម្ចាស់ដែលគង់នៅជាមួយយើង ដើម្បីណែនាំឲ្យយើងអនុវត្តព្រះបន្ទូលរបស់ព្រះយេស៊ូជាក់ស្តែងនៅក្នុងជីវិតរបស់យើង។ ឲ្យយើងស្រឡាញ់គ្នាទៅវិញទៅមកបម្រើគ្នាទៅវិញទៅមក ក្នុងន័យយើងជាក្រុមគ្រួសារ តែមួយ យើងជាបងប្អូនគ្នាដូចព្រះបិតានិងព្រះបុត្រាជាអង្គតែមួយដែរ។

ថ្ងៃនេះ មុនយាងឡើងស្ថានបរមសុខ ព្រះយេស៊ូមានព្រះបន្ទូលចាត់ពួកសាវ័ករបស់ព្រះអង្គឲ្យចេញទៅប្រកាសក្នុងព្រះនាមព្រះអង្គ ឲ្យមនុស្សគ្រប់ជាតិសាសន៍ប្រែចិត្តគំនិត ឲ្យបានរួចពីបាប គឺប្រកាសចាប់ពីក្រុងយេរូសាឡឹមតទៅ។ ដូច្នេះយើងត្រូវប្រកាសក្នុងនាមព្រះយេស៊ូ ក្នុងនាមព្រះជាម្ចាស់ដែលជាព្រះបិតារបស់យើង មិនមែនក្នុងនាមខ្លួនយើងទេ គឺយើងប្រកាសឲ្យមនុស្សគ្រប់ជាតិសាសន៍ប្រែចិត្តគំនិត។ មុនយាងឡើងស្ថានបរមសុខ ព្រះយេស៊ូមានព្រះបន្ទូលដោយនឹកដល់មនុស្សគ្រប់ជាតិសាសន៍ ដល់មនុស្សទូទៅ មិនមែននឹកដល់តែមនុស្សប៉ុន្មាននាក់ប៉ុណ្ណោះទេ។ បងប្អូនដែលបានទទួលអគ្គសញ្ញាជ្រមុជទឹកក្នុងរាត្រីបុណ្យចម្លង គឺបានទទួលជីវិតថ្មីដោយសុខចិត្តប្រែចិត្តគំនិតដោយសុខចិត្តទៅជាមនុស្សថ្មី។

សម្រាប់យើងជាគ្រីស្តបរិស័ទ គ្រប់ពេលវេលាដែលយើងចូលរួមថ្វាយអភិបូជា គ្រប់ពេលដែលយើងស្តាប់ព្រះបន្ទូលជាឱកាសដែលយើងភ្ញាក់ស្មារតីថែមទៀត ដើម្បីប្រែចិត្តគំនិតទៅជាមនុស្សថ្មីតាមព្រះបន្ទូលរបស់ព្រះយេស៊ូ។ ប៉ុន្តែព្រះយេស៊ូមិនគ្រាន់តែសូមឲ្យយើងប្រែចិត្តគំនិតប៉ុណ្ណោះ ប៉ុន្តែព្រះអង្គ សូមឲ្យយើងប្រកាសថែមទៀតអំពីព្រះអង្គ ពីក្រុងយេរូសាឡឹមទៅរហូតទីដាច់ស្រយាលនៃផែនដី។ ដូច្នេះក្រុមគ្រីស្តទូតត្រូវចេញដំណើរទៅគ្រប់ទីកន្លែងក្នុងពិភពលោកទាំងមូល ដើម្បីឲ្យមនុស្សទាំងអស់មានឱកាសស្តាប់អំពីសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ចំពោះមនុស្សលោក។ ២.០០០ ឆ្នាំមុន ក្រុមគ្រីស្តទូតដែលបានស្តាប់ព្រះបន្ទូលរបស់ព្រះយេស៊ូហើយ គេចេញនៅគ្រប់ទីកន្លែងដើម្បីធ្វើជាសាក្សីអំពីជីវិតដែលព្រះយេស៊ូបានប្រទានឲ្យគេ។ សាក្សីជាអ្នកដែលបង្ហាញអំពីអ្វីដែលខ្លួនបានឃើញ បានឮ បានទទួល និងប្រកាសនូវ

អ្វីៗទាំងនោះដល់អ្នកផ្សេងហើយគេប្រកាសតៗគ្នា រហូតមកដល់យើង។

ថ្ងៃនេះ យើងបានទទួលព្រះបន្ទូលដែលគេប្រកាសនោះ ដើម្បីឲ្យយើងប្រែចិត្តគំនិត ឲ្យយើងទៅជាសាក្សីអំពីជីវិតថ្មី ដើម្បីណែនាំឲ្យបងប្អូនឯទៀតៗទៅជាសាក្សីរបស់ព្រះយេស៊ូ ដូចយើងដែរ គឺយើងធ្វើជាសាក្សីនៅក្នុងភូមិរបស់យើង នៅកន្លែងដែលយើងរស់នៅ។ សព្វថ្ងៃ ព្រះសហគមន៍របស់យើង ជាព្រះសហគមន៍ដែលផ្តល់សក្ខីភាពអំពីធម៌មេត្តាករុណា ជាពិសេស ក្នុងឆ្នាំសម្តែងមេត្តាករុណារបស់ព្រះជាម្ចាស់ ដែលយើងហៅថាឆ្នាំព្រះមហាករុណាទិគុណនេះ យើងបង្ហាញថាព្រះជាម្ចាស់ស្រឡាញ់មនុស្សលោក ព្រះជាម្ចាស់ចង់ឲ្យមនុស្សលោកទទួលជីវិតថ្មី។ មនុស្សដែលរងទុក្ខលំបាក ឲ្យគេរកឃើញសេចក្តីសង្ឃឹម ឲ្យគេយល់ថាយើងជាបងប្អូនដែល ស្រឡាញ់គេ។ ឆ្នាំនេះជាឆ្នាំព្រះមហាករុណាទិគុណ យើងទទួលព្រះបន្ទូលរបស់ព្រះយេស៊ូដែល ឲ្យយើងស្រឡាញ់គ្នាទៅវិញទៅមក បម្រើគ្នាទៅវិញទៅមក និងកសាងព្រះសហគមន៍មួយ ដែលយើងជាបងប្អូនគ្នា ព្រមទាំងណែនាំឲ្យបងប្អូនឯទៀតៗ មានឱកាសដើម្បីស្តាប់ព្រះបន្ទូល របស់ព្រះយេស៊ូ និងដើម្បីទទួលជីវិតថ្មីរួមជាមួយព្រះយេស៊ូដែរ។

សម្រាប់បងប្អូនទាំងប្រាំបួននាក់ដែលទទួលអគ្គសញ្ញាលាបថ្វាសនៅថ្ងៃនេះ ព្រះវិញ្ញាណ ដ៏វិសុទ្ធក៏សណ្ឋិតលើបងប្អូន តាមព្រះបន្ទូលសន្យា ដើម្បីឲ្យបងប្អូនទៅជាសាក្សីប្រកាស ដំណឹងល្អ ដើម្បីឲ្យបងប្អូនរស់នៅតាមដំណឹងល្អក្នុងជីវិតប្រចាំថ្ងៃ ជាពិសេសក្នុងឆ្នាំព្រះមហា ករុណាទិគុណនេះ ព្រះសហគមន៍សូមឲ្យយើងយកចិត្តទុកដាក់ បង្កើតស្នាដៃមេត្តាករុណាតាម រូបកាយ ដែលមានន័យថា ឲ្យយើងយកចិត្តទុកដាក់ដល់បងប្អូនដែលគ្មានកន្លែងស្នាក់នៅ គ្មានសម្លៀកបំពាក់ គ្មានទឹកហូប គ្មានម្ហូបអាហារ គ្មានអ្វីជាទីពឹង ឲ្យយើងទៅសួរសុខទុក្ខគេឲ្យ យើងបង្ហាញទំនាក់ទំនងជាមួយគេដើម្បីឲ្យគេបានទទួលជីវិតថ្មី។ យើងត្រូវការគិត តើយើង ម្នាក់ៗត្រូវធ្វើអ្វីខ្លះសម្រាប់ជនក្រីក្រ? តើយើងត្រូវធ្វើអ្វីខ្លះដើម្បីឲ្យអស់អ្នករងទុក្ខលំបាកអាច ទទួលភាពកក់ក្តៅពីយើងដែលជាគ្រីស្តបរិស័ទកាតូលិក?

ម្សិលមិញក្មេងៗកាយបូទ្ធិបានយកពេលវេលាទៅសួរសុខទុក្ខអ្នកជំងឺ និងចាស់ជរា។ សម្រាប់យើងជាគ្រីស្តបរិស័ទកុំគិតថា នេះជាតួនាទីរបស់ក្រុមសង្គហៈ ប៉ុន្តែក៏ជាតួនាទីរបស់

យើងម្នាក់ៗដើម្បីសម្តែងមេត្តាករុណាតាមរបៀបព្រះយេស៊ូ ដែលសូមឲ្យយើងស្រឡាញ់គ្នាទៅវិញទៅមក ឲ្យយើងបម្រើគ្នាទៅវិញទៅមក និងឲ្យយើងទៅជាផ្លូងតែមួយ ដោយសារយើងជាបងប្អូនគ្នា។ ប៉ុន្តែព្រះអង្គក៏សូមឲ្យយើងសម្តែងមេត្តាករុណាតាមផ្លូវវិញ្ញាណដែរ ដោយឲ្យយើងជួយណែនាំ លើកទឹកចិត្តអស់អ្នកដែលអស់សង្ឃឹម អស់អ្នកដែលកំពុងសង្ស័យអំពីជំនឿអស់អ្នកដែលប្រព្រឹត្តិបាបរកឃើញផ្លូវត្រឹមត្រូវវិញ ទាំងស្វាគមន៍បងប្អូនទាំងអស់ដែលមកសួរសុខទុក្ខយើង។

ថ្ងៃនេះ បងប្អូនដែលទទួលអគ្គសញ្ញាលាបថ្វាស បានទទួលអំណោយទានពិសេស គឺចិត្តក្លាហាន ដឹងខុសដឹងត្រូវ មានយោបល់ល្អ និងគោរពកោតខ្លាចព្រះជាម្ចាស់។ នៅថ្ងៃនេះព្រះសហគមន៍យើង គឺយើងទាំងអស់គ្នាបានទទួលនូវអ្វីៗទាំងអស់ ដើម្បីយើងរស់នៅជាសាក្សីរបស់ព្រះយេស៊ូ ដូចព្រះអង្គមានព្រះបន្ទូលថា **"អ្នករាល់គ្នាជាសាក្សីអំពីហេតុការណ៍ទាំងនេះ"**។ ដូច្នេះយើងត្រូវគិត តើខ្ញុំជាគ្រីស្តបរិស័ទត្រូវធ្វើដូចម្តេចដើម្បីទៅជាសាក្សីអំពីសេចក្តីស្រឡាញ់ អំពីធម៌មេត្តាករុណា អំពីជីវិតដ៏បរិបូណ៌ដែលយើងបានទទួលពីព្រះយេស៊ូ។ ព្រះយេស៊ូបានប្រទានព្រះវិញ្ញាណដ៏វិសុទ្ធមកសណ្ឋិតលើយើង ឲ្យយើងទៅជាមនុស្សថ្មី មានចិត្តក្លាហានដើម្បីបម្រើអ្នកដទៃ ស្រឡាញ់អ្នកដទៃ ណែនាំឲ្យព្រះសហគមន៍របស់យើងទៅជាក្រុមគ្រួសារតែមួយជាបងប្អូនបង្កើតនៅក្នុងព្រះគ្រីស្ត ដូចព្រះបុត្រានិងព្រះបិតាជាអង្គតែមួយដែរ។

ថ្ងៃនេះយើងខ្ញុំសូមអរព្រះគុណព្រះជាម្ចាស់ ចំពោះព្រះយេស៊ូយាងឡើងស្ថានបរមសុខ ចំពោះក្រុមគ្រីស្តទូត ដែលវិលត្រឡប់ចូលក្រុងយេរូសាឡឹមវិញប្រកបដោយអំណរដ៏លើសលុប។ ដូចក្រុមគ្រីស្តទូតដែរ សូមព្រះអង្គប្រណីសន្តោសឲ្យយើងខ្ញុំបានពោរពេញដោយអំណរសប្បាយដើម្បីបន្តប្រកាសដំណឹងល្អដល់បងប្អូនឯទៀតៗ។ យើងខ្ញុំសូមអរព្រះគុណព្រះជាម្ចាស់ដែលគង់នៅជាមួយយើងខ្ញុំ ដែលចាត់ព្រះវិញ្ញាដ៏វិសុទ្ធមកសណ្ឋិតលើយើងខ្ញុំ ឲ្យយើងខ្ញុំមានចិត្តក្លាហានទៅជាសាក្សីនៃដំណឹល្អ នៃធម៌មេត្តាករុណា នៃការបម្រើ នៃការឯកភាពគ្នា ជាផ្លូងមួយនៅក្នុងអង្គព្រះគ្រីស្ត។

# ចូរក្លាហានក្នុងការផ្តល់សក្ខីភាពអំពីព្រះយេស៊ូ

Be a brave witness of Christ

អត្ថបទទី១៖ កក ២២, ៣០ និង ២៣, ៦-១១
ដំណឹងល្អ៖ យហ ១៧, ២០-២៦

យប់នេះ ជាយប់ទី៤៩ ដែលយើងបានអធិដ្ឋានសម្រាប់ការត្រាស់ហៅ។ នៅពេលអធិដ្ឋានចូល ខ្ញុំបានអានថា **"សូមទ្រង់ព្រះមេត្តាប្រទានព្រះវិញ្ញាណព្រះអង្គមកប្រែចិត្តគំនិតយើងខ្ញុំ ដើម្បីឲ្យបានគាប់ព្រះហឫទ័យព្រះអង្គ និងស្ម័គ្រចិត្តធ្វើតាមព្រះបំណងរបស់ព្រះអង្គគ្រប់ពេលវេលា"**។ យើងជួបជុំគ្នាយប់នេះ ដើម្បីអធិដ្ឋាន គឺដើម្បីគិតអំពីព្រះហឫទ័យរបស់ព្រះជាម្ចាស់ចំពោះយើងសព្វថ្ងៃ មានន័យថាព្រះជាម្ចាស់មានព្រះបំណងអ្វីខ្លះសម្រាប់យើង ដើម្បីឲ្យយើងស្ម័គ្រចិត្តធ្វើតាមព្រះបំណងព្រះអង្គគ្រប់ពេលវេលា។ ក្នុងភូមិភាគភ្នំពេញកាលពីឆ្នាំ២០១២ យើងបានសម្រេចចិត្តដើម្បីជួយឲ្យគ្រីស្តបរិស័ទទាំងអស់ ជួយឲ្យយុវជនយុវនារីទាំងអស់មានឱកាសរិះគិតអំពីជីវិតផ្ទាល់ខ្លួន ថាតើព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យខ្ញុំធ្វើអ្វីខ្លះ? ដោយចាត់ចែងក្នុងមួយខែម្តងនៅតាមមណ្ឌលសកម្មភាពនីមួយៗ យើងជួបជុំគ្នាដើម្បីអធិដ្ឋាន ដែលចាប់ផ្តើមពីម៉ោង៦កន្លះល្ងាច រហូតដល់ម៉ោង៦កន្លះព្រឹក ដែលមានរយៈពេល១២ម៉ោង។

យើងជឿលើព្រះយេស៊ូដែលគង់នៅជាមួយយើង និងដឹកនាំជីវិតរបស់យើង។ ដើម្បីទទួលកម្លាំង និងទទួលគំនិតពីព្រះយេស៊ូ យើងត្រូវការពេលដើម្បីអធិដ្ឋានដោយយើងនៅស្ងៀមស្ងាត់ និងដោយមានចិត្តតស៊ូ។ ពេលយើងអធិដ្ឋានពេញមួយយប់មានន័យថាយើងតស៊ូ យើងខិតខំហើយការតស៊ូនេះជួយឲ្យយើង ចូលនៅក្នុងព្រះបន្ទូលរបស់ព្រះយេស៊ូដែលយើង

---

អភិបូជាអធិដ្ឋានពេញមួយយប់ នៅព្រៃកប្បាស់
ថ្ងៃទី ១២ ឧសភា ២០១៦

បានស្តាប់ជារៀងរាល់ថ្ងៃ។ អត្ថបទទី១ចែងអំពីសន្តៈប៉ូលមុនពេលលោកធ្វើដំណើរចុងក្រោយ នោះលោកត្រូវបានគេចាប់បញ្ជូនទៅតុលាការដើម្បីកាត់ក្តី។ សន្តៈប៉ូលស្តាប់ឮព្រះបន្ទូលលើកទឹកចិត្តថា **"ចូរក្លាហានឡើង អ្នកត្រូវផ្តល់សក្ខីភាពអំពីយើងនៅក្រុងរ៉ូម ដូចអ្នកបានផ្តល់សក្ខីភាពអំពីយើងនៅក្រុងយេរូសាឡឹមនេះដែរ"**។ ព្រះយេស៊ូបានជ្រើសរើសសន្តៈប៉ូលដែលពីមុនលោកធ្លាប់ជាអ្នកដែលស្អប់គ្រីស្តបរិស័ទយ៉ាងខ្លាំង ប៉ុន្តែចាប់តាំងពីលោកបានទទួលពន្លឺមួយនៅតាមផ្លូវទៅក្រុងដាម៉ាស ទាំងលោកបានឮព្រះសូរសៀងរបស់ព្រះអម្ចាស់យេស៊ូថា **"ប៉ូលអើយ! ប៉ូលអើយ! មូលហេតុអ្វីអ្នកបៀតបៀនខ្ញុំ?"** នោះណែនាំឲ្យលោកភ្ញាក់ស្មារតី ហើយលោកត្រឡប់ទៅជាមិត្តសម្លាញ់របស់ព្រះយេស៊ូវិញ ទាំងលោកធ្វើដំណើរទៅកន្លែងនានាដើម្បីប្រមូលប្រជាជនដូចយើងសព្វថ្ងៃ ដើម្បីប្រាប់គេអំពីជីវិតរបស់ព្រះយេស៊ូ ក្រោយមកមានមនុស្សជាច្រើនជឿ និងគេបានទទួលអគ្គសញ្ញាជ្រមុជទឹក និងគេដើរតាមព្រះយេស៊ូ។

ចំនុចទី១ សព្វថ្ងៃនេះ ព្រះជាម្ចាស់ក៏មានព្រះបន្ទូលមកយើង ដូចព្រះអង្គមានព្រះបន្ទូលទៅកាន់សន្តៈប៉ូលដែរថា **"ចូរក្លាហានឡើង អ្នកត្រូវផ្តល់សក្ខីភាពអំពីយើង..."**។ យើងបានចាប់ផ្តើមផ្តល់សក្ខីភាពអំពីព្រះយេស៊ូនៅចម្ការទៀង ដូចសន្តៈប៉ូលចាប់ផ្តើមពីទីក្រុងយេរូសាឡឹម។ ក្រោយមកយើងចេញដំណើរទៅកន្លែងផ្សេង ដូចសន្តៈប៉ូលចេញពីក្រុងយេរូសាឡឹមទៅកន្លែងផ្សេងៗដែរ។ សព្វថ្ងៃទីក្រុងរ៉ូមរបស់យើង គឺនៅគិរីវង្ស នៅព្រៃកប្បាស នៅកំពង់អំពិល នៅទីរួមខេត្តតាកែវ នៅទន្លេបាទី នៅត្រពាំងក្រញូង។ ដូច្នេះយើងបានចេញដំណើរទៅកន្លែងផ្សេងតាមប្រសាសន៍របស់សន្តៈប៉ូល ទាំងយើងកសាងព្រះសហគមន៍នៅកន្លែងនីមួយៗនោះ ឲ្យរឹងមាំឲ្យអ្នកដទៃបានស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់។

ថ្ងៃនេះព្រះយេស៊ូមានព្រះបន្ទូលពិសេស ណែនាំឲ្យយើងទៅជាអង្គតែមួយ ដូចព្រះបិតា និងព្រះបុត្រាជាអង្គតែមួយ។ ឲ្យយើងជាសាវ័ករបស់ព្រះអង្គ ជាមិត្តសម្លាញ់របស់ព្រះអង្គធ្វើដំណើរជាមួយគ្នាជាបងប្អូនបង្កើត ជាក្រុមមួយដែលចេះសហការគ្នា ចេះលើកទឹកចិត្តគ្នា ចេះយល់ចិត្តគ្នាដើម្បីកសាងព្រះសហគមន៍ពិតៗ។ ដោយសារព្រះសហគមន៍របស់យើងជា

ព្រះសហគមន៍របស់បងប្អូនបង្កើត ដោយសារយើងមានព្រះបិតាតែមួយ ដោយសារយើងមើលឃើញព្រះបិតាដែលស្រឡាញ់ព្រះយេស៊ូដែលជាព្រះបុត្រា ដោយសារព្រះអង្គស្រឡាញ់គ្នាទៅវិញទៅមកជាធ្លុងតែមួយនោះណែនាំឲ្យយើងជាព្រះសហគមន៍ទៅជាគ្រួសារតែមួយដែរ។យប់នេះមានបងប្អូនដែលអញ្ជើញមកពីកន្លែងផ្សេងពីគ្នាចូលរួម នេះបង្ហាញថា យើងជាក្រុមតែមួយនៅក្នុងព្រះសហគមន៍។ អ្នកដទៃនឹងចូលព្រះវិហាររបស់យើងនៅពេលគេឃើញរបៀបដែលគ្រីស្តបរិស័ទស្រឡាញ់គ្នាទៅវិញទៅមក នៅពេលគេឃើញរបៀបដែលយើងស្រឡាញ់ព្រះយេស៊ូ និងរបៀបដែលយើងស្រឡាញ់អ្នកដទៃដែរ។ ដូច្នេះប្រសិនបើក្នុងព្រះសហគមន៍យើងចេះស្រឡាញ់គ្នាពិតមែន យើងចេះជួយគ្នាពិតមែន យើងចេះយល់ចិត្តគ្នាពិតមែន នោះមានន័យថា យើងបានផ្តល់សក្ខីភាពអំពីព្រះយេស៊ូពិតមែន។ នេះជាកម្លាំងមួយយ៉ាងពិសេស សម្រាប់យើងនៅក្នុងខេត្តតាកែវនេះ។

លោកបូជាចារ្យ មានតួនាទីណែនាំឲ្យប្រជារាស្ត្ររបស់ព្រះជាម្ចាស់នៅតាមកន្លែងនីមួយៗ ឲ្យទៅជាគ្រួសារតែមួយ និងក្រោយមកលោកអភិបាលណែនាំឲ្យព្រះសហគមន៍ទាំងអស់ឲ្យទៅជាភូមិភាគតែមួយ នៅក្នុងអង្គព្រះគ្រីស្តនេះជាជីវិតរបស់យើងជាគ្រីស្តបរិស័ទ។ ថ្ងៃនេះយើងបានស្តាប់ព្រះបន្ទូលរបស់ព្រះយេស៊ូដែលជំរុញឲ្យយើងមាន សេចក្តីស្រឡាញ់របស់ព្រះអង្គអស់កល្បជានិច្ច។ បើគ្មានសេចក្តីស្រឡាញ់របស់ព្រះអង្គ យើងមិនអាចទៅជាគ្រួសារតែមួយជាបងប្អូនគ្នាបានទេ។ យប់នេះសូមឲ្យយើងយកព្រះបន្ទូលរបស់ព្រះយេស៊ូដែលយើងបានស្តាប់ និងពាក្យអធិដ្ឋាននៅពេលយើងហែរចូលមកទុកក្នុងចិត្ត ទាំងទូលអង្វរថា ឱព្រះជាម្ចាស់អើយ តើខ្ញុំធ្វើដូចម្តេចដើម្បីស្របតាមព្រះបំណងរបស់ព្រះអង្គ? ខ្ញុំធ្វើដូចម្តេចដើម្បីកសាងព្រះសហគមន៍ដោយផ្តល់សក្ខីភាពដូចសន្តៈប៉ូលពីដើម? តើខ្ញុំធ្វើដូចម្តេចដើម្បីឲ្យព្រះសហគមន៍របស់យើងខ្ញុំ ទៅជាក្រុមគ្រួសារតែមួយដែលចេះទទួលស្វាគមន៍មនុស្សគ្រប់គ្នានៅក្នុងសេចក្តីស្រឡាញ់។ តើខ្ញុំធ្វើដូចម្តេចដើម្បីបើកទ្វារជានិច្ចទទួលស្វាគមន៍ថែមទៀតឲ្យអ្នកដទៃគេសប្បាយចិត្ត? ខ្ញុំធ្វើដូចម្តេចដើម្បីឲ្យគេឃើញថាយើងខ្ញុំចេះស្រឡាញ់គ្នាទៅវិញ

ទៅមក ចេះជួយគ្នាទៅវិញទៅមក ចេះបម្រើគ្នាទៅវិញទៅមក ទោះបីយើងមកពីក្រុមគ្រួសារខុសគ្នាតែក្នុងព្រះយេស៊ូ យើងជាក្រុមគ្រួសារតែមួយដោយសារសេចក្ដីស្រឡាញ់របស់ព្រះយេស៊ូស្ថិតនៅក្នុងយើង និងដូចសេចក្ដីស្រឡាញ់របស់ព្រះយេស៊ូ ស្ថិតនៅក្នុងព្រះបិតាដែរ។ ដូច្នេះពាក្យអធិដ្ឋាននៅក្នុងឆ្នាំព្រះមហាករុណាទិគុណនេះ គឺដើម្បីធ្វើចិត្តគំនិតយើងឲ្យតែមួយជាមួយព្រះយេស៊ូ និងជាពិសេសឲ្យយុវជនយុវនារីដែលអង្គុយនៅទីនេះដឹងថាទៅថ្ងៃមុខ **"តើខ្ញុំត្រូវធ្វើអ្វីដើម្បីបម្រើសង្គម? ដើម្បីបម្រើព្រះសហគមន៍? ដើម្បីឲ្យសេចក្ដីស្រឡាញ់ដែលខ្ញុំបានទទួលនៅថ្ងៃនេះទៅជាសេចក្ដីស្រឡាញ់សម្រាប់មនុស្សជាច្រើនទៀត?"**។ យប់នេះជាឱកាសមួយសម្រាប់យើងដើម្បីស្ដាប់ព្រះបន្ទូលរបស់ព្រះយេស៊ូ ដោយសារព្រះយេស៊ូមានព្រះបន្ទូលសម្រាប់យើងម្នាក់ៗ។

យើងខ្ញុំសូមអរព្រះគុណព្រះជាម្ចាស់ និងសូមព្រះអង្គគង់នៅជាមួយយើងខ្ញុំដើម្បីឲ្យយើងខ្ញុំធ្វើដំណើរទៅមុខដើម្បីឲ្យព្រះសហគមន៍ក្នុងខេត្តតាកែវយើងខ្ញុំ ទៅជាព្រះសហគមន៍ របស់ព្រះគ្រីស្តដែលមកពីទីក្រុងយេរូសាឡឹមដល់ទីក្រុងរ៉ូម និងពីភូមិចម្ការទៀងដល់គ្រប់ទីកន្លែងនៅក្នុងខេត្តតាកែវ។ យើងខ្ញុំសូមអរព្រះគុណព្រះជាម្ចាស់ដែលជាអម្ចាស់យើងខ្ញុំ។

# ព្រះវិញ្ញាណដ៏វិសុទ្ធយាងមក ដើម្បីឲ្យយើងទៅប្រកាសអំពីព្រះរាជ្យព្រះជាម្ចាស់

The Holy Spirit has sent us to announce the Kingdom of God

---

| |
|---|
| អត្ថបទទី១៖ កក ២, ១-១១<br>អត្ថបទទី២៖ រម ៨, ៨-១៧<br>ដំណឹងល្អ៖ យហ ១៤, ១៥-១៦.២៣ខ-២៦ |

ពេលនេះជាពេលគោរពព្រះវិញ្ញាណដ៏វិសុទ្ធយាងមក នៅក្នុងឆ្នាំព្រះមហាករុណាទិគុណ ជាពេលវេលាមួយពិសេសសម្រាប់យើងជាព្រះសហគមន៍។ ពីប៉ុន្មានខែហើយយើងរួមគ្នារិះគិតពាក្យស្លោក **"ចូរមានចិត្តមេត្តាករុណាដូចព្រះបិតាមានព្រះហឫទ័យមេត្តាករុណា"** នៅថ្ងៃនេះព្រះវិញ្ញាណដ៏វិសុទ្ធកំពុងយាងមក អ្វីដែលយើងបានស្តាប់នៅក្នុងអត្ថបទទី២គឺ បងប្អូនបានទទួលព្រះវិញ្ញាណដ៏វិសុទ្ធ ដែលធ្វើឲ្យបងប្អូនទៅជាបុត្រធីតារបស់ព្រះជាម្ចាស់។ ដោយសារព្រះ-វិញ្ញាណនេះយើងបន្លឺសម្លេងឡើងថា **"អប្បា"** គឺ **"ឱព្រះបិតា"**។ ជាព្រះវិញ្ញាណផ្ទាល់ដែលផ្តល់សក្ខីភាពឲ្យវិញ្ញាណយើងដឹងថា យើងពិតជាបុត្រធីតារបស់ព្រះជាម្ចាស់ ហើយយើងនឹងទទួលមរតកពីព្រះជាម្ចាស់។ មរតកដែលយើងទទួលពី ព្រះបិតាគឺ ព្រះអង្គប្រោសឲ្យយើងមានចិត្តមេត្តាករុណាដូចព្រះបិតាមានព្រះហឫទ័យមេត្តាករុណា។

យើងធ្លាប់និយាយថា ឪពុកយ៉ាងណាកូនយ៉ាងហ្នឹង បើយើងមើលឃើញឪពុក យើងដឹងថាកូនជាមនុស្សយ៉ាងម៉េច។ ដូច្នេះយើងមានព្រះជាម្ចាស់ជាឪពុករបស់យើងបើយើងសម្លឹងមើលឪពុករបស់យើងជាព្រះបិតា នោះយើងអាចដឹងថា ព្រះអង្គសព្វហឫទ័យឲ្យយើងជាបុត្រធីតារស់នៅតាមរបៀបយ៉ាងណាមិនខាន។ នៅថ្ងៃនេះយើងពោរពេញដោយព្រះវិញ្ញាណ

---

អភិបូជាលាបថ្ងាស
នៅផ្សារតូច ថ្ងៃទី ១៥ ឧសភា ២០១៦

ដ៏វិសុទ្ធដែលណែនាំឲ្យយើងយល់ថា ពិតមែនព្រះជាម្ចាស់ណែនាំឲ្យយើងមា ចិត្តមេត្តាករុណា ឲ្យយើងមានចិត្តស្រឡាញ់ ដូចព្រះបិតាមានព្រះហឫទ័យមេត្តាករុណា និង ព្រះហឫទ័យស្រឡាញ់យើងដែរ។ អំបាញ់មិញយើងបានសូត្រ **"ឱព្រះវិញ្ញាណព្រះបវរសូមយាងកុះករក្នុងដួងចិត្តសូមចាត់ពន្លឺរស្មីពិតឲ្យមកតាំងស្ថិតលើអស់យើង"** នោះគឺយើងកំពុងទន្ទឹងរង់ចាំព្រះវិញ្ញាណដែលថ្ងៃនេះព្រះវិញ្ញាណដ៏វិសុទ្ធទ្រង់យាងមកទាំងប្រទានឱកាស ឲ្យយើងជាព្រះ-សហគមន៍ជួបជុំគ្នាទូលអង្វរព្រះអង្គ ដើម្បីឲ្យយើងធ្វើកិច្ចការមេត្តាករុណា ដើម្បីបំភ្លឺ និងដើម្បីប្រទានសេចក្តីពិតដល់ព្រះសហគមន៍។

មុនពេលព្រះយេស៊ូយាងឡើងស្ថានបរមសុខព្រះសហគមន៍បានទទួលបេសកកម្មមួយគឺ "សូមទៅណែនាំឲ្យគេប្រែចិត្តគំនិតធ្វើពិធីជ្រមុជទឹកឲ្យគេក្នុងព្រះនាមព្រះបិតា ព្រះបុត្រានិងព្រះវិញ្ញាណដ៏វិសុទ្ធ និងសូមទៅដល់ទីដាច់ស្រយាលនៃផែនដីដើម្បីប្រកាសអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់"។ សម្រាប់យើងជាគ្រីស្តបរិស័ទ កិច្ចការមេត្តាករុណាគឺជាចំណុចកំពូលដ៏មានសារៈសំខាន់បំផុត ដូចសម្តេចប៉ាប បេណេឌិកតូទី១៦ បានមានប្រសាសន៍ថា **"ចូរឲ្យយើងប្រកាសដំណឹងល្អ ជាពិសេសចំពោះអ្នកតូចតាច។ ចូរធ្វើដូចក្រុមគ្រីស្តទូត ពេលព្រះវិញ្ញាណដ៏វិសុទ្ធសណ្ឋិតលើគេ គេលែងភ័យខ្លាច គេទៅប្រកាសដំណឹងល្អអំពីព្រះយេស៊ូសោយទិវង្គតអំពីព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ អំពីព្រះយេស៊ូដែលណែនាំឲ្យបងប្អូនទាំងអស់មានសេចក្តីសង្ឃឹមដោយសារសេចក្តីស្លាប់លែងឈ្នះទៀតហើយ"**។ យើងបានទទួលព្រះអំណោយទានយ៉ាងពិសេសពីព្រះយេស៊ូគឺជំនឿ ដែលយើងត្រូវតែចែកដល់បងប្អូនឯទៀតៗ ជាពិសេសក្នុងសង្គមរបស់យើងសព្វថ្ងៃដែលកំពុងអភិវឌ្ឍយ៉ាងលឿន និងដែលពិបាកទុកកន្លែង ឬពេលវេលាសម្រាប់ទទួលស្វាគមន៍ព្រះជាម្ចាស់។ ជាក់ស្តែងនៅក្នុងដួងចិត្តរបស់យើង ជាច្រើនដងយើងពិបាកនឹងទុកកន្លែងសម្រាប់ព្រះជាម្ចាស់ ដែលចិញ្ចឹមជីវិតផ្លូវវិញ្ញាណរបស់យើង។ ថ្ងៃនេះក្នុងនាមយើងជាគ្រីស្តបរិស័ទត្រូវសួរខ្លួនឯងថា **"តើខ្ញុំត្រូវធ្វើដូចម្តេច ដើម្បីចែកទ្រព្យសម្បត្តិដែលខ្ញុំបាន ទទួលពីព្រះយេស៊ូដល់បងប្អូនឯទៀត ដើម្បីឲ្យបងប្អូនបានរកឃើញសេចក្តីពិត និងពន្លឺដែលខ្ញុំ ទទួលពីព្រះវិញ្ញាណដ៏វិសុទ្ធ"**។

**"ឱព្រះវិញ្ញាណដ៏វិសុទ្ធអើយសូមយាងមក!"** ដើម្បីប្រទានយុត្តិធម៌ និងសេចក្ដីសុខសាន្ត ដល់ពិភពលោកទាំងមូល និងជាពិសេសដល់សង្គមកម្ពុជារបស់យើងបច្ចុប្បន្ននេះ។ សព្វថ្ងៃយើង ឃើញប៉ុន្មានកន្លែងនៅក្នុងសង្គម និងក្នុងពិភពលោករបស់យើងគឺខ្វះយុត្តិធម៌។ មនុស្សដែលចង់ ប្រកាសអំពីយុត្តិធម៌អំពីសិទ្ធិមនុស្សត្រូវប្រឈមនឹងបញ្ហាយ៉ាងច្រើន ឬរហូតប៉ះពាល់ជីវិត។ តើយើងជាគ្រីស្តបរិស័ទដែលជាសាក្សីអំពីយុត្តិធម៌ត្រូវធ្វើដូចម្ដេច? យើងត្រូវនឹកចាំព្រះបន្ទូល របស់ព្រះយេស៊ូដែលថា **"អ្នកណាស្រេកឃ្លានយុត្តិធម៌ អ្នកនោះមានសុភមង្គលហើយ។ អ្នកណាកសាងសុខសន្តិភាព អ្នកនោះមានសុភមង្គលហើយ"** នេះជាតួនាទីរបស់យើងដែល បានទទួលពីព្រះគ្រីស្ត។ ខ្ញុំជឿថាសម្រាប់យើងជាគ្រីស្តបរិស័ទ ពីមួយថ្ងៃទៅមួយថ្ងៃនៅពេល យើងស្ដាប់វិទ្យុ ទូរទស្សន៍អំពីព័ត៌មានផ្សេងៗក្នុងប្រទេស និងក្រៅប្រទេស ក្នុងពិភពលោក ទាំងមូល នោះជំរុញឲ្យដួងចិត្តរបស់យើងចង់ស្រែកថា **"ឱសេចក្ដីសុខសាន្ត សូមយាងមកដើម្បី បំភ្លឺពិភពលោក!"** ដើម្បីកុំឲ្យយើងបន្តមានសង្គ្រាម មានការមើលងាយ មានការបាក់បែកគ្នា មាន អំពើអយុត្តិធម៌ដែលណែនាំឲ្យយើងរស់នៅក្នុងភាពងងឹត។

ពិតមែនយើងមិនមែនជា ម៉ាតាំងលូទែឃីង ជាអ្នកម្ដាយតេរេសា ប៉ុន្តែយើងមានគ្រប់ សមត្ថភាពដែលយើងបានទទួលពីព្រះជាម្ចាស់ផ្ទាល់នៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ ដើម្បីទៅជាអ្នក សាបព្រោះយុត្តិធម៌និងសេចក្ដីសុខសាន្ត នៅគ្រប់ទីកន្លែងនៅក្នុងពិភពលោក និងជាពិសេសក្នុង ក្រុមគ្រួសាររបស់យើង នៅក្នុងសង្គមដែលយើងរស់នៅ និងក្នុងព្រះសហគមន៍របស់យើង។ យើងមានគ្រប់សមត្ថភាពនៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ ដើម្បីកសាងផែនដីថ្មីដែលជាផ្ទះរួមរបស់ យើងដើម្បីឲ្យផែនដីនេះទៅជាទីលំនៅនៃសេចក្ដីសុខសាន្ត និងអំណរសប្បាយ ដូចព្រះយេស៊ូ មានព្រះបន្ទូលថា **"ខ្ញុំយាងមកដើម្បីឲ្យបងប្អូនមានអំណរសប្បាយពេញលក្ខណៈ"**។

**"ឱព្រះវិញ្ញាណសូមយាងមក!"** ដើម្បីប្រទានធម៌មេត្តាករុណាសេចក្ដីប្រណីសន្ដោសដល់ អ្នកតូចតាចដល់អ្នកកំសត់ទុគ៌ត។ តើយើងត្រូវប្រកាសដំណឹងល្អតាមរបៀបណា? នេះជា សំណួរដែលត្រូវរិះគិត។ ប៉ុន្តែយើងត្រូវនឹកដល់របៀបរបស់ព្រះយេស៊ូ ពីដើមព្រះអង្គប្រកាស ដំណឹងល្អជូនដល់អ្នកក្រីក្រ អ្នកខ្វាក់ អ្នកជាប់ឃុំឃាំង ហើយនេះជាអ្វីដែលយើងត្រូវធ្វើដែរ។

ដំណឹងល្អយាងមក ណែនាំឲ្យយើងដឹងថាយើងជាអ្នកមានបាបដែលបានទទួលការលើកលែងទោសពីព្រះជាម្ចាស់។ សេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ ណែនាំឲ្យយើងនឹកឃើញដល់ម្តាយដែលកំពុងបំបៅកូន និងថែទាំកូនង៉ែតរបស់គាត់ និងឲ្យយើងនឹកឃើញដល់ឪពុកនៅក្នុងគម្ពីរដំណឹងល្អ ដែលកំពុងទទួលកូនពៅវង្វេងរបស់គាត់ដែលត្រឡប់មកផ្ទះវិញ។ នេះជារបៀបរបស់ព្រះជាម្ចាស់ជាព្រះបិតា ស្រឡាញ់យើងនៅថ្ងៃនេះ។

នៅក្នុងឆ្នាំព្រះមហាករុណាទិគុណនេះ ខ្ញុំសូមឲ្យយើងបន្តអនុវត្តកិច្ចការដែលជាអាទិភាពរបស់ភូមិភាគភ្នំពេញយើង គឺមេត្តាករុណាខាងរូបកាយមួយខែម្តង និងខាងវិញ្ញាណមួយថ្ងៃម្តងៗ ដើម្បីឲ្យជីវិតរបស់យើងអាចបង្កើតផលផ្លែនៅក្នុងសង្គមបាន។ លោកអភិបាលរំឭកហើយរំឭកទៀតអំពីការសិក្សា សុខភាព អ្នកក្រីក្រ ពលករ ជនពិការ ការថែរក្សាធម្មជាតិ និងសន្ទនាអន្តរសាសនាដែលយើងចែកគ្នា អនុវត្តដើម្បីមានបទពិសោធន៍។ ប្រសិនបើយើងគ្មានបទពិសោធន៍អំពីធម៌មេត្តាករុណា នោះយើងនឹងពិបាកចែករំលែកបទពិសោធន៍។ ជាមួយគ្នានេះដែរនៅពេលព្រះសហគមន៍នីមួយៗធ្វើបូជនិយចរពីភ្នំពេញថ្មីទៅកាន់ផ្សារតូច និងអរិយក្សត្រនោះយើងនឹងទទួលព្រះកាយព្រះគ្រីស្ត ទទួលអគ្គសញ្ញាលើកលែងទោសដែលជាឱកាសមួយយើង នឹងមានពិសោធន៍ជាក់ស្តែងថា ពិតមែនព្រះបិតាស្រឡាញ់ខ្ញុំ ហើយខ្ញុំក៏ត្រូវចែកដល់បងប្អូនឯទៀតៗដែរ។

**"ឱព្រះវិញ្ញាណសូមយាងមក!"** ដើម្បីឲ្យព្រះសហគមន៍របស់យើង ក្រុមគ្រួសាររបស់យើង និងយើងទាំងអស់គ្នាដែលជួបជុំគ្នានៅទីនេះទៅជាអង្គតែមួយ នៅក្នុងអង្គព្រះគ្រីស្តដើម្បីណែនាំឲ្យមនុស្សក្នុងពិភពលោកទាំងមូលជឿលើព្រះជាម្ចាស់ជាព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ។ មុនព្រះយេស៊ូសោយទិវង្គតមុនព្រះយេស៊ូយាងឡើងស្ថានបរមសុខមុនព្រះយេស៊ូចាត់ព្រះវិញ្ញាណដ៏វិសុទ្ធ ព្រះយេស៊ូមានព្រះបន្ទូលថា **"ឱព្រះបិតាអើយ! ខ្ញុំទូលអង្វរព្រះអង្គសូមឲ្យគេទៅជាធ្លុងតែមួយ ដូចព្រះបិតានិងទូលបង្គំជាធ្លុងតែមួយដែរ"**។ ពាក្យអធិដ្ឋាននេះត្រូវតែជាពាក្យអធិដ្ឋានរបស់យើងពេញមួយជីវិត។ យើងក៏មានពិសោធខ្លះៗអំពីអង្គតែមួយដែរ ដោយសារយើងធ្លាប់បានរួមគ្នាអធិដ្ឋានជាមួយបងប្អូនមកពីក្រុមផ្សេងៗដែលប្លែកពីយើង ហើយបន្តិចទៀតនេះ យើងនឹងទទួលព្រះកាយព្រះគ្រីស្ត ដែលយើងនឹងរួមគ្នាជាអង្គតែមួយ។

មិនត្រូវគិតថាយើងរួមគ្នាតែ២ម៉ោង ឬ៣ម៉ោងប៉ុណ្ណោះទ នេះគឺជាមហាទស្សនៈសម្រាប់យើងជាគ្រីស្តបរិស័ទ។ ដូច្នេះយើងត្រូវខិតខំធ្វើឲ្យព្រះសហគមន៍កាតូលិកនៅលើទឹក ដីកម្ពុជាយើងទៅជាសញ្ញាសម្គាល់នៃអង្គតែមួយ នៃផ្លូវតែមួយដោយយើងទាំងអស់ជាគ្រីស្តបរិស័ទ ត្រូវស្ថិតនៅហួសពីកម្រិតជាតិសាសន៍ ប្រទេស ដោយយល់ថាពិតមែនយើងជាគ្រួសារតែមួយ ដែលមានចិត្តថ្លើមតែមួយជាមួយ មិត្តសម្លាញ់របស់យើងជាមួយក្រុមគ្រួសាររបស់យើង ជាមួយបងប្អូនជា មួយលោកបូជាចារ្យ ជាមួយលោកអភិបាល ជាមួយសម្តេចប៉ាប ជាមួយបងប្អូននៅកន្លែងធ្វើការនៅក្នុងសង្គម នៅក្នុងសហគមន៍អាស៊ានដើម្បីបំពេញតួនាទីដែលយើងបានទទួលពីព្រះយេស៊ូគឺកសាងពិភពលោកថ្មីដែលចេះសហការគ្នា ចេះស្រឡាញ់គ្នា ចេះគោរពគ្នា ដោយសារយើងមានព្រះបិតាតែមួយដែលស្រឡាញ់យើង។

ទាំងអស់នេះជាផលផ្លែនៃព្រះវិញ្ញាណដ៏វិសុទ្ធ ដែលយើងត្រូវអធិដ្ឋានហើយអធិដ្ឋានទៀត ដើម្បីឲ្យបងប្អូនទាំងអស់ ជាពិសេសបងប្អូនដែលទទួលអគ្គសញ្ញាលាបថ្វាសនៅថ្ងៃនេះ យកចិត្តទុកដាក់កសាងព្រះសហគមន៍ ជាព្រះសហគមន៍ដែលគាប់ព្រះហឫទ័យព្រះយេស៊ូ ដែលយើងត្រូវធ្វើពិសោធន៍ដោយផ្ទាល់បន្តិចម្តងៗ។ ដូច្នេះប្រសិនបើបងប្អូន មិនទាន់យល់ច្បាស់ សូមអានគម្ពីរសន្តៈយ៉ូហានជំពូក១៤ ដល់១៧។ នៅពេលយូដាចេញពីពិធីជប់លៀង ព្រះយេស៊ូចាប់ផ្តើមមានព្រះបន្ទូលយ៉ាងជិតស្និទ្ធបំផុតជាមួយក្រុមគ្រីស្តទូត បង្ហាញពីអ្វីដែលមានសារៈសំខាន់បំផុត ក្នុងការកសាងព្រះសហគមន៍របស់ព្រះជាម្ចាស់ មុនពេលព្រះអង្គយាងទៅសួនច្បារកេសេម៉ានី។

**"ព្រះអង្គជាបិតាអ្នកខ្សត់ ត្រីក្រទុរគតបិតាថ្កើង<br>យាងមកប្រទានកុំបីភ្លេង អំណោយក្រាស់ស្ដើងកូនទទួល"**

# យើងរៀបចំខ្លួនដើម្បីធ្វើជាសាក្សីនៃសេចក្តីពិត

Let us be witnesses of the Truth

អត្ថបទទី១៖ យក ៥, ៩-១២;
ដំណឹងល្អ៖ មក ១០,១-១២

ថ្ងៃនេះពិតមែន "ចូរយើងមានអំណរសប្បាយឡើង" ដោយសារព្រះហគមន៍កាតូលិកកម្ពុជាយើងទាំងមូលមកជួបជុំគ្នាលើទឹកដីមរណសាក្សីរបស់យើងនៅតាំងគោក។ យើងមានអំណរសប្បាយដោយសារយើងបានអធិដ្ឋានរួមជាមួយគ្នានៅក្នុងឆ្នាំព្រះមហាករុណាទិគុណដើម្បីទូលអង្វរព្រះបិតាប្រទានព្រះហឫទ័យប្រណីសន្តោសលើយើងម្នាក់ៗ។ យើងមានអំណរសប្បាយដោយសារយើងបានរួមគ្នាអរព្រះគុណព្រះជាម្ចាស់ សម្រាប់ជីវិតមរណសាក្សីរបស់យើងនិងជីវិតរបស់លោកអភិបាលអេមីលដែរ។ បុណ្យ១០០ថ្ងៃរបស់លោកអភិបាលអេមីលចំលើថ្ងៃដែលព្រះយេស៊ូយាងឡើងស្ថានបរមសុខ នេះជាសញ្ញាសម្គាល់ឲ្យយើងដឹងថា ពិតមែនលោកអភិបាលអេមីលបានចូលក្នុងស្ថានបរមសុខហើយដោយលោកកំពុងសម្លឹងមើលព្រះយេស៊ូដ៏ជាទីស្រឡាញ់របស់លោក និងកំពុងសម្លឹងមើលមកយើងទាំងអស់គ្នាដែលនៅទីនេះដោយមានប្រសាសន៍មកយើងម្នាក់ៗថា **"សូមទៅជាផ្លុងតែមួយនៅក្នុងនាមព្រះបិតាដែលជាព្រះជាម្ចាស់របស់យើង"។**

ព្រឹកនេះ យើងជួបជុំគ្នាដើម្បីនឹករឭកដល់មរណសាក្សីរបស់យើងដែលបានបូជាជីវិតដល់អស់បងប្អូនគ្រីស្តបរិស័ទ និងបងប្អូនខ្មែរដែលបានស្លាប់ក្នុងសម័យប៉ុលពត។ ឆ្នាំមុនយើងបានបើកការស៊ើបអង្កេតមរណសាក្សីដើម្បីឲ្យព្រះសហគមន៍ទទួលស្គាល់។ រាល់ខែគណៈកម្មការ

ក្នុងអភិបូជាខួប១០០ថ្ងៃ លោកអភិបាលអេមីល
និង ពិធីគោរពមរណសាក្សីកម្ពុជា នៅតាំងគោក
ថ្ងៃទី២០ ឧសភា ២០១៦

កាត់ក្តីមរណសាក្សីរបស់យើងដែលមានខ្ញុំ មានលោកធ័ត្រសេរី លោកម៉ារីយ៉ូ លោកចនលូកា បងស្រីស៊ីណា និងសារ៉ែនផងបានធ្វើការកាត់ក្តីដោយយើងបានអញ្ជើញសាក្សីផ្ទាល់មកផ្តល់សក្ខីភាព។

ថ្ងៃនេះយើងចូលយ៉ាងជ្រៅនៅក្នុងជំនឿរបស់យើងជាគ្រីស្តបរិស័ទ តាមរយៈប្រសាសន៍ចុងក្រោយរបស់សន្តៈប៉ូល និងព្រះបណ្តាំរបស់ព្រះយេស៊ូមុនពេលព្រះអង្គសោយទីវង្គតដែលណែនាំឲ្យយើងយល់ថា ជីវិតរបស់យើងមកពីព្រះជាម្ចាស់និងវិលទៅឯព្រះជាម្ចាស់វិញ។ សន្តៈប៉ូលមានប្រសាសន៍ថា "សូមបងប្អូនថែរក្សាខ្លួនឯង និងថែរក្សាក្រុមដែលមានជំនឿទាំងមូលផង ព្រោះព្រះវិញ្ញាណដ៏វិសុទ្ធបានផ្ទុកផ្តាក់ឲ្យបងប្អូនធ្វើជាអ្នកទទួលខុសត្រូវធ្វើជាគង្វាលថែរក្សាព្រះសហគមន៍របស់ព្រះជាម្ចាស់ ដែលព្រះអង្គបានលោះមកដោយសារព្រះលោហិតរបស់ព្រះអម្ចាស់យេស៊ូផ្ទាល់"។ សេចក្តីនេះ នាំឲ្យយើងនឹកឃើញដល់លោកអភិបាលអ៊ីវ៉ាំមូស្ស ក្នុងឱកាសដែលលោកតែងតាំងលោកឆ្មារសាឡាស់ទៅជាលោកអភិបាល នៅថ្ងៃទី១៤ ខែមេសា ឆ្នាំ១៩៧៥។ នៅចំពោះមុខលោកបូជាចារ្យខ្មែរប៉ុន្មាននាក់ និងចំពោះមុខបងប្អូនគ្រីស្តបរិស័ទខ្មែរ ដែលពេលនោះ ប្រហែលលោកអភិបាលអ៊ីវ បានមានប្រសាសន៍ដូចសន្តៈប៉ូលដែរថា **"សូមបងប្អូនថែរក្សាខ្លួនឯង សូមបងប្អូនថែរក្សាក្រុមដែលជឿលើព្រះជាម្ចាស់ សូមបងប្អូនថែរក្សាក្រុមដែលត្រូវចាកចេញពីទីក្រុង ឲ្យគេទទួលជីវិតយ៉ាងបរិបូណ៌ពីព្រះជាម្ចាស់"**។

ពេលយើងស្តាប់ប្រសាសន៍សន្តៈប៉ូល **"ឥឡូវនេះ ខ្ញុំសូមផ្ញើបងប្អូននឹងព្រះជាម្ចាស់ សូមផ្ញើបងប្អូននឹងព្រះបន្ទូលស្តីអំពីព្រះហឫទ័យប្រណីសន្តោសរបស់ព្រះអង្គ"** នាំឲ្យយើងនឹកដល់លោកអភិបាលឆ្មារសាឡាស់ដែលបានចេញដំណើរពីភ្នំពេញមកដល់ទីនេះ និងពីទីនេះទៅជួបគ្រីស្តបរិស័ទខ្លះៗ នៅកន្លែងផ្សេងៗទៀត ដើម្បីប្រាប់ទៅបងប្អូនដូចសន្តៈប៉ូលថា "ខ្ញុំសូមផ្ញើបងប្អូននឹងព្រះជាម្ចាស់ ខ្ញុំសូមផ្ញើបងប្អូននឹងព្រះបន្ទូលស្តីអំពីព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់"។ សន្តៈប៉ូលបាន មានប្រសាសន៍ដែរថា **"គ្រប់ពេលទាំងអស់ ខ្ញុំតែងតែប្រាប់ទៅបងប្អូនឲ្យដឹងថា យើងត្រូវធ្វើការនឿយហត់បែបនេះឯង ដើម្បីជួយអ្នកក្រខ្សត់ ដែលស្របតាម**

**ព្រះបន្ទូលព្រះអម្ចាស់យេស៊ូថាអ្នកឲ្យ នឹងបានសុភមង្គលច្រើនជាងអ្នកទទួល"**។

លោកអភិបាលអេមីល អស់មួយជីវិតលោក បានខិតខំយកចិត្តទុកដាក់ជាមួយអ្នកតូចតាច ជាមួយអ្នកក្រីក្រដោយដឹងថា **"អ្នកឲ្យមានសុភមង្គលច្រើនជាងអ្នកទទួល"** នេះជាមូលហេតុនៅឆ្នាំ ១៩៧០ លោកបានបង្កើតអង្គការការីតាស់កម្ពុជា និងក្រុមសង្គហៈដើម្បីជួយបងប្អូនដែលកំពុងរងទុក្ខលំបាកដោយសារសង្គ្រាម។ ព្រះបន្ទូលទាំងអស់ សុទ្ធតែត្រាស់ហៅយើងជាលោកអភិបាលជាលោកបូជាចារ្យឲ្យថែរក្សាប្រជារាស្ត្ររបស់ព្រះអង្គដែលព្រះអង្គប្រទានឲ្យយើងដោយចិត្តស្រឡាញ់។ ថ្ងៃនេះព្រះបន្ទូលបានត្រាស់ហៅយើងទាំងអស់គ្នាជាគ្រីស្តបរិស័ទឲ្យយើងជិតស្និទ្ធនិងទុកចិត្តលើព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដោយសង្ឃឹមថាយើងនឹងទទួលព្រះអំណោយទាន ទទួលកម្លាំងពីព្រះបិតា ទោះបីយើងជួបទុក្ខលំបាកយ៉ាងណាដើម្បីឲ្យយើងអាចរស់នៅស្របតាមព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះអង្គជាពិសេស គឺឲ្យយើងសម្ដែងមេត្តាករុណាដែលយើងត្រូវតែបំពេញនៅក្នុងឆ្នាំព្រះមហាករុណាទិគុណនេះ។

ខ្ញុំសូមទូលអង្វរព្រះជាម្ចាស់ សូមឲ្យព្រះបន្ទូលដែលយើងបានស្ដាប់នៅថ្ងៃនេះយាងចូលយ៉ាងជ្រៅក្នុងដួងចិត្តរបស់យើង។ ថ្ងៃនេះយើងនៅក្បែរឈើឆ្កាងដែលដាំយ៉ាងជ្រៅនៅកណ្ដាលវាលស្រែ។ យើងទាំងអស់គ្នាជាផលផ្លែនៃឈើឆ្កាងនេះដែលជាឈើឆ្កាងរបស់មរណសាក្សីដើម្បីឲ្យព្រះសហគមន៍របស់យើងមានជីវិតដ៏បរិបូរណ៍ ជាឈើឆ្កាងរបស់បងប្អូនប្រជាជនកម្ពុជាយើងដែលបានលះបង់ជីវិត និងជាពិសេសជាឈើឆ្កាងរបស់ព្រះយេស៊ូដែលបានបូជាព្រះជន្មដើម្បីប្រទានជីវិតអស់កល្បជានិច្ចឲ្យមនុស្សយើង។ សូមឲ្យយើងខិតខំស្ដាប់ព្រះបន្ទូលសម្រាប់យើងនៅថ្ងៃនេះម្ដងហើយម្ដងទៀត ដើម្បីណែនាំឲ្យព្រះសហគមន៍របស់យើងទៅជាព្រះសហគមន៍ស្របតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ និងជាព្រះសហគមន៍របស់ព្រះយេស៊ូពិតមែន។

ព្រះយេស៊ូមានព្រះបន្ទូលថា **"សូមថែរក្សាអ្នកទាំងនោះដោយព្រះនាមព្រះអង្គ គឺព្រះនាមនេះហើយដែលព្រះអង្គបានប្រទានមកទូលបង្គំ ដើម្បីឲ្យគេរួមគ្នាជាអង្គតែមួយដូចយើង**

**ជាអង្គតែមួយដែរ**"។ ព្រះសហគមន៍យើងនៅប្រទេសកម្ពុជា ទៅជាអង្គតែមួយ ទៅជាផ្លូងតែមួយពិតមែនដូចយើងឃើញនៅពេលនេះស្រាប់ ដែលយើងមកអង្គុយជាមួយគ្នាជាក្រុមគ្រួសារតែមួយ។ សូមឲ្យយើងបន្តអង្គតែមួយនេះនៅក្នុងជីវិតរបស់យើង នៅក្នុងក្រុមគ្រួសាររបស់យើង នៅក្នុងព្រះសហគមន៍របស់យើង និងនៅក្នុងសង្គមរបស់យើង ដោយសារយើងចេះស្រឡាញ់គ្នាដូចបងប្អូនបង្កើត។ ព្រះយេស៊ូសព្វព្រះហឫទ័យឲ្យយើងជាផ្លូងតែមួយ ដូចព្រះបិតានិងព្រះបុត្រាជាអង្គតែមួយនៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធដូច្នេះដែរ។ ព្រះយេស៊ូមានព្រះបន្ទូលទៀតថា **"សូមឲ្យគេមានអំណររបស់ទូលបង្គំ ដែលជាអំណរដ៏ពេញលក្ខណៈ"** ដូច្នេះថ្ងៃនេះសូមឲ្យយើងរិះគិតថា **"តើខ្ញុំបានភ្ជាប់ជីវិតរបស់ខ្ញុំជាមួយនឹងអំណរដ៏ពេញលក្ខណៈរបស់ព្រះយេស៊ូហើយឬនៅ?"** ។ ពេលនេះខ្ញុំជឿថាយើងទាំងអស់គ្នាពិតជាមានអំណរសប្បាយ គឺជាអំណរសប្បាយដែលមកពីព្រះជាម្ចាស់ដែលជាសញ្ញាសម្គាល់របស់យើងជាគ្រីស្តបរិស័ទ។ ពេលមានអំណរសប្បាយណែនាំឲ្យយើងនឹកឃើញពីអំណរសប្បាយរបស់ព្រះនាងម៉ារីនៅពេលព្រះនាងទទួលដំណឹងថាធ្វើជាមាតារបស់ព្រះយេស៊ូ។ ថ្ងៃនេះព្រះយេស៊ូទូលអង្វរព្រះបិតាដើម្បីឲ្យយើងម្នាក់ៗមានអំណរសប្បាយដ៏ពេញលក្ខណៈដូចព្រះនាងម៉ារីដែរ។

ក្នុងអង្គតុលាការមរណសាក្សី ពីម្សិលមិញមានសាក្សីម្នាក់បាននិយាយពីបងស្រីលីវី ជាបងស្រីខ្មែរក្នុងក្រុមឧបការគុណ។ ពេលចេញពីភ្នំពេញមកដល់ផ្សារបារាយណ៍ ខ្មែរក្រហមបានសុំឲ្យបងស្រីមើលថែរក្សាក្មេងពេលឪពុកម្តាយគេទៅធ្វើការ។ តាមអ្វីដែលសាក្សីបាននិយាយបងស្រីសប្បាយរហូត រាល់ថ្ងៃគាត់ច្រៀងកោតសរសើរព្រះជាម្ចាស់ជាភាសាឡាតាំង រហូតដល់ខ្មែរក្រហមស្តាប់ឮហើយគេសម្លាប់គាត់។ នេះជាអំណរសប្បាយដែលបងស្រីបានទទួលពីព្រះជាម្ចាស់។ ព្រះយេស៊ូទូលអង្វរព្រះបិតាថា **"សូមព្រះអង្គប្រោសគេឲ្យបានវិសុទ្ធដោយសារសេចក្តីពិត"**។ សាក្សីនៃសេចក្តីពិតមានន័យថា ជាសាក្សីអំពីព្រះយេស៊ូ ដ្បិតព្រះយេស៊ូជាសេចក្តីពិត។ ព្រះអង្គមានព្រះជន្មគង់នៅ និងណែនាំការរស់នៅរបស់យើងជាពិសេសព្រះអង្គណែនាំព្រះសហគមន៍របស់ព្រះអង្គ។ សេចក្តីពិតគឺជាចិត្តបម្រើ ចិត្តស្រឡាញ់ ចិត្តអធិដ្ឋាន

ចិត្តលើកលែងទោសដូចព្រះយេស៊ូ និងដូចលោកអភិបាលអេមីលដែលបានបង្ហាញយើង។ ក្នុងសង្គមយើងសព្វថ្ងៃសេចក្ដីពិតដែលយើងកំពុងស្វែងរក គឺជាចិត្តស្មោះត្រង់ជាយុត្តិធម៌ដែលមិនស្វែងរកប្រយោជន៍ខ្លួនឯង។

ព្រះយេស៊ូបានទូលអង្វរព្រះបិតាឲ្យយើងទៅជាអ្នកដ៏វិសុទ្ធតាមសេចក្ដីពិតថា "**ទូលបង្គំចាត់គេឲ្យទៅដូចព្រះអង្គចាត់ទូលបង្គំឲ្យមកនៅក្នុងលោកនេះដែរ**"។ ថ្ងៃនេះនៅមុខឈើឆ្កាងមរណសាក្សី យើងបានទទួលបេសកកម្ម ដើម្បីប្រកាសដំណឹងល្អពីព្រះរាជ្យព្រះជាម្ចាស់ដែលកំពុងយាងមក ដើម្បីបង្ហាញសញ្ញាសម្គាល់ជាក់ស្ដែងនៃធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ ដោយយើងចេះស្រឡាញ់គ្នាទៅវិញទៅមក ដោយយើងទៅជាធ្លុងតែមួយ ដោយយើងកំពុងស្វែងរកសេចក្ដីពិត ដោយយើងមានអំណរសប្បាយមកពីព្រះយេស៊ូ នោះខ្ញុំសូមអញ្ជើញយើងទាំងអស់គ្នាទាំងលោកអភិបាល ទាំងលោកបូជាចារ្យ ទាំងបងប្រុស បងស្រី ទាំងបងប្អូនគ្រីស្ដបរិស័ទទាំងអស់សម្លឹងមើលព្រះឈើឆ្កាងរបស់ព្រះគ្រីស្ដ ដែលឈរត្រង់ចាក់ឫសទៅក្នុងទឹកដីរបស់យើង ដើម្បីទូលអង្វរព្រះជាម្ចាស់ដែលចាត់យើងឲ្យទៅប្រកាសដំណឹងល្អ សូមឲ្យយើងចូលនៅក្នុងមហាគម្រោងការរបស់ព្រះយេស៊ូ ដើម្បីឲ្យពិភពលោករបស់យើងទៅជាធ្លុងតែមួយនៅក្នុងសេចក្ដីពិត ដើម្បីឲ្យយើងទៅជាព្រះសហគមន៍របស់ព្រះគ្រីស្ដក្នុងភាពដ៏វិសុទ្ធ នៅក្នុងប្រទេសកម្ពុជាយើង។

ខ្ញុំសូមអញ្ជើញបងប្អូនបន្តប្រកាស ឲ្យមនុស្សជាច្រើនបានស្ដាប់ព្រះបន្ទូលដ៏អស្ចារ្យឲ្យគេបានទទួលជីវិតអស់កល្បជានិច្ចដែរ។ មុនចេញទៅវិញ សូមកុំភ្លេចទៅថ្វាយបង្គំព្រះឈើឆ្កាងថ្វាយបង្គំគ្រែដ៏មានជីវិត ដោយសារគ្រែនេះជាតុសក្ការៈដែលលោកឆ្មារសោឡាស់ លោកឆ្មារសោឡឹម លោកចម្រើន និងបងប្អូនគ្រីស្ដបរិស័ទខ្មែរយើងឯទៀតបានថ្វាយសក្ការបូជាគឺជីវិតរបស់គេរហូតដល់ថ្ងៃចុងក្រោយ។ ក្រោយសម័យប៉ុលពតរហូតដល់ឆ្នាំ២០០០ យើងបានរកឃើញគ្រែនេះ ហើយគ្រួសារដែលថែរក្សាគ្រែនេះបានប្រាប់យើងថា គាត់មិនហ៊ានរុះរើគ្រែនេះទេដោយសារគាត់មានអារម្មណ៍ថាគ្រែនេះប្លែក។ ពិតមែនគ្រែនេះប្លែក ដោយសារលើ

គ្រែនេះលោកបូជាចារ្យខ្មែរបានថ្វាយសក្ការបូជារបស់ព្រះគ្រីស្ត ដែលណែនាំឲ្យព្រះសហគមន៍របស់យើងមានជីវិតជាង២០០០ឆ្នាំមកហើយ។

លោកអភិបាលអេមីល លោកអភិបាលឆ្មារសាឡាស់ និងមរណសាក្សីទាំងឡាយអើយ ថ្ងៃនេះយើងខ្ញុំទាំងអស់គ្នាដែលជាប្រជារាស្ត្ររបស់ព្រះជាម្ចាស់ បានខិតខំធ្វើដំណើរមកជួបជុំជាមួយអស់លោក។ ថ្ងៃនេះយើងខ្ញុំទាំងអស់គ្នាសូមប្រកាសយ៉ាងឱឡារិកថាយើងខ្ញុំបានរៀបចំខ្លួនដើម្បីរស់នៅរួមជាមួយព្រះគ្រីស្តដូច លោកអភិបាលអេមីល ដូចលោកអភិបាល ឆ្មារសាឡាស់ និង ដូចមរណសាក្សីទាំងអស់ដែលបានរួមស្លាប់និងរួមរស់ជាមួយព្រះគ្រីស្តដែរ។ យើងខ្ញុំសូមប្រកាសយ៉ាងឱឡារិកថាយើងខ្ញុំ នឹងធ្វើខ្លួនទៅជាអ្នកដ៏វិសុទ្ធនៅក្នុងសេចក្តីពិតដើម្បីទទួលអំណរសប្បាយដ៏ពេញលក្ខណៈដែលមកពីព្រះអម្ចាស់នៃយើងដែលមានព្រះជន្មរស់ឡើងវិញមែន។

**"សូមទៅជាធ្លុងតែមួយនៅក្នុងនាមព្រះបិតាដែលជាព្រះជាម្ចាស់របស់យើង"។**

# របៀបបម្រើរបស់សន្ដយ៉ូហានបាទីស្ដដឺឡាសាល គឺអប់រំចំណេះដឹង វិញ្ញាណ រូបកាយ និងចិត្ត

St. John the Baptist de la Salle: Knowledge, heart, mind, and body in the service of God

---

អត្ថបទទី១៖ យក ៥, ១៣-២០
ដំណឹងល្អ៖ មក ១០, ១-១២

ថ្ងៃនេះយើងជួបជុំគ្នាដើម្បីគោរពខួប១១០ឆ្នាំ នៃវត្តមានរបស់ក្រុមគ្រួសារបងប្រុស ដឺឡាសាល នៅលើទឹកដីកម្ពុជា។ នេះជាឱកាសមួយដើម្បីយើងនឹកឃើញដល់សន្តៈយ៉ូហាន បាទីស្ដដឺឡាសាល ដែលបានបង្កើតក្រុមគ្រួសារបងប្រុស នៅឆ្នាំ១៦៨០ នៅប្រទេសបារាំង។ ក្នុងសតវត្សរ៍ទី១៧ នៅប្រទេសបារាំងជាសតវត្សរ៍ដែលមានក្រុមគ្រួសារថ្មីៗជាច្រើនកើតឡើងមានដូចជាក្រុមសាសនទូតMEP ក្រុមបងស្រីអាម៉ុងដឺឡាហ្គរ ក្រុមវ៉ាំងសង់ដឺប៉ូល ក្រុមដឺឡាសាល និងមានក្រុមច្រើនទៀត។ នៅសតវត្សនោះជាពេលមួយដែលព្រះវិញ្ញាណដ៏វិសុទ្ធណែនាំឲ្យយើងភ្ញាក់ស្មារតី ណែនាំឲ្យមានមនុស្សជាច្រើនទៅប្រកាសដំណឹងល្អ ទៅបម្រើសង្គម និងព្រះសហគមន៍ដែរ។

ពេលមកដល់ប្រទេសកម្ពុជា ក្រុមដឺឡាសាលបានតាំងនៅបាត់ដំបងមួយរយៈខ្លី និងក្រោយមកបានបង្កើតសាលាមីស្សនៅភ្នំពេញ។ **"មីស្ស"** ជាឈ្មោះរបស់លោកអភិបាលដែលទទួលខុសត្រូវព្រះសហគមន៍ភ្នំពេញ សាយហ្គន និងឡាវនៅឆ្នាំ១៨៥០។ ក្រោយមកបុរីវ៉ាទីកង់បានចែកភូមិភាគជាថ្មី ហើយលោកទទួលខុសត្រូវតែភូមិភាគភ្នំពេញវិញ។ លោកអភិបាលមីស្សល្បីល្បាញដោយសារលោកបានជួយនាំរាជសារពីព្រះមហាក្សត្រកម្ពុជា ទៅថ្វាយព្រះចៅអធិរាជ

---

អភិបូជាខួប១១០ឆ្នាំ
នៃវត្តមានក្រុមគ្រួសារបងប្រុសដឺឡាសាលនៅកម្ពុជា
ថ្ងៃទី២១ ឧសភា ២០១៦

បារាំងដើម្បីសុំឲ្យប្រទេសបារាំងមកជួយការពារប្រទេសកម្ពុជា និ ងលោកជាអ្នកដែលនាំយកពូជទៀបបារាំងចូលមកប្រទេសកម្ពុជាមុនគេ។ ថ្ងៃនេះក្នុងអត្ថបទគម្ពីរមានសំណួរមួយថា **"តើអ្នកណាមានឋានៈធំជាងគេ?"**។ សន្តៈយ៉ូហានបាទីស្តដឺឡាសាល បានឆ្លើយហើយ នៅពេលដែលគាត់បង្កើតក្រុមគ្រួសារដឺឡាសាល ដែលបងប្រុសត្រូវបម្រើគ្នាទៅវិញទៅមក។ ដូច្នេះអ្នកធំជាងគេគឺជាអ្នកដែលបម្រើគេ។ ក្រុមគ្រួសារដឺឡាសាលមាពិសោធន៍ឆ្លងសតវត្សក្នុងគំនិតដើមថា "យើងជាក្រុមគ្រួសារដែលបម្រើគ្នាទៅវិញទៅមក"។

ពេលនេះជាឱកាសមួយដើម្បីអរព្រះគុណព្រះជាម្ចាស់ សម្រាប់ក្រុមគ្រួសារដឺឡាសាលដែលបានចាប់ផ្តើមនៅប្រទេសកម្ពុជា ជួយណែនាំឲ្យយើងទៅជាក្រុមគ្រួសារមួយចេះជួយគ្នាទៅវិញទៅមក និងជាពិសេសគឺយកចិត្តទុកដាក់អប់រំកូនក្មេងនិងយុវជនយុវនារី។ សន្តៈយ៉ូហានបាទីស្តដឺឡាសាល មានទស្សនវិស័យអំពីការសិក្សាតាំងពី៣៥០ឆ្នាំមុន។ លោកគិតពីការអប់រំទាំងមូលគឺគិតអំពីការអប់រំជំនឿការអប់រំចំណេះទូទៅការអប់រំដួងចិត្ត វិញ្ញាណ និងរូបកាយ។ នេះជាអ្វីដែលយើងសង្ឃឹមថាក្រុមបងប្រុសដឺឡាសាលនៅកម្ពុជា នឹងបន្តអនុវត្តតាមគោលគំនិតរបស់សន្តៈដឺឡាសាលដែលនឹងណែនាំឲ្យក្មេងៗរបស់យើងយុវជនយុវនារីយើងបានទទួលការអប់រំខាងចំណេះដឹងទូទៅខាងវិញ្ញាណខាងរូបកាយ និងខាងដួងចិត្តដែរ។ ខ្ញុំបានអានគំនិតខ្លះៗដែលសន្តៈយ៉ូហានបាទីស្តដឺឡាសាលបានទុកជាគោលការណ៍ក្នុងការណែនាំក្រុមរបស់លោក គឺ៖

១. បងប្រុសបានទទួលការត្រាស់ហៅពីព្រះជាម្ចាស់ និងទទួលកម្លាំងពីព្រះជាម្ចាស់ ហេតុនេះហើយអ្វីៗទាំងអស់ដែលបងប្រុសធ្វើសព្វថ្ងៃនៅទីនេះ គឺដើម្បីព្រះជាម្ចាស់។

២.បងប្រុសធ្វើការដោយសហការជាមួយព្រះជាម្ចាស់និងខ្ញុំសូមបន្ថែមថាក៏ត្រូវសហការជាមួយព្រះសហគមន៍ដែរមានន័យថាសាលានេះដែលស្ថិតនៅក្នុងភូមិភាគភ្នំពេញត្រូវតែសហការយ៉ាងជិតស្និទ្ធជាមួយព្រះសហគមន៍ភូមិភាគភ្នំពេញ ហើយនៅតំបន់នេះ យើងមានលោកបូជាចារ្យហ្គូស្តាវ៉ូទទួលខុសត្រូវ ទាំងយើងមានគ្រីស្តបរិស័ទនៅពោធិ៍ធំ និងនៅក្តីកណ្តាលដែល

ជាសញ្ញាសម្គាល់ពីព្រះសហគមន៍របស់យើងនៅទីនេះ។ ព្រះសហគមន៍មិនមែនតែពោធិ៍ធំ និងក្តីកណ្តាលនេះទេ ប៉ុន្តែក៏ជាលោកអភិបាលដែរ។ ហេតុនេះហើយការសហការជាមួយព្រះជាម្ចាស់ គឺជាការសហការយ៉ាងជិតស្និទ្ធជាមួយភូមិភាគរបស់ព្រះសហគមន៍ដែលបងប្រុសស្ថិតនៅដើម្បីឲ្យកម្មវិធីសិក្សារបស់យើងចម្រើនឡើង និងចម្រើនឡើងថែមទៀត។

៣.បងប្រុសត្រូវធ្វើការសម្រាប់អ្នកក្រីក្រ។ ពីសម័យសន្តៈយ៉ូហានបាទីស្តដឺឡាសាលរស់នៅ លោកបានបង្កើតសាលារៀនដោយមិនបង់លុយសម្រាប់កូនអ្នកក្រីក្រ។ បងប្រុសគួរតែបន្តរបៀបនេះ ដោយផ្តល់អាទិភាពឲ្យកូនអ្នកក្រីក្របានចូលរៀន និងគួរបង្កើតសាលាបង់ថ្លៃនៅថ្ងៃអនាគត។ សម្រាប់ដុនបូស្កូក៏ដូចគ្នាដែរ គេបានចាប់ផ្តើមជាដំបូងនៅប្រទេសថៃ និងប្រទេសជប៉ុន ដោយគិតដល់អ្នកក្រីក្រជាអាទិភាព ប៉ុន្តែសព្វថ្ងៃ សុទ្ធតែកូនអ្នកមានដែលចូលរៀនដោយបង់លុយ ហើយគេយកលុយនោះមកជួយព្រះសហគមន៍វិញ។ ដូច្នេះសូមឲ្យបងប្រុសបន្តថែរក្សាគំនិតដើមដដែល គឺយើងជាព្រះសហគមន៍ត្រូវតែគិតគូរដល់អ្នកតូចតាចអ្នកដែលគ្មានសមត្ថភាព ដើម្បីគេមានឱកាសរៀបចំអនាគតរបស់គេ។

៤. តាំងពីសតវត្សទី១៧រៀងមក ក្រុមគ្រួសារបងប្រុសយ៉ូហានបាទីស្តដឺឡាសាល បានធ្វើការក្រោមការដឹកនាំរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ។ ព្រះវិញ្ញាណដ៏វិសុទ្ធដែលបំភ្លឺ ដែលជំរុញ និងដែលណែនាំឲ្យយើងទៅជាអង្គតែមួយមានន័យថាយើងជាក្រុមគ្រួសារមួយដែលចេះសហការគ្នា។ គម្រោងការរបស់សាលាដឺឡាសាលគឺណែនាំទាំងលោកគ្រូ អ្នកគ្រូ ទាំងអាណាព្យាបាលទាំងសិស្សទាំងបងប្រុសឲ្យទៅជាក្រុមគ្រួសារតែមួយ ដើម្បីលើកស្ទួយការអប់រំ។ នៅទីនេះយើងទទួលទាំងកូនក្មេងខ្មែរ និងកូនក្មេងវៀតណាមជាឱកាសមួយដើម្បីបង្ហាញថាយើងជាក្រុមគ្រួសារតែមួយនៅក្នុងព្រះយេស៊ូ និងក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ។

ដូច្នេះសូមឲ្យយើងបន្តអធិដ្ឋានថែមទៀត ដើម្បីឲ្យកម្មវិធីសិក្សារបស់យើងចម្រើនឡើងថែមទៀតហើយយើងសង្ឃឹមថា ថ្ងៃអនាគតយើងនឹងមានសាលាបឋមសិក្សា អនុវិទ្យាល័យ វិទ្យា-ល័យ ដើម្បីផ្តល់ឱកាសដល់បងប្អូនជាអ្នកក្រីក្រ ដែលនៅជុំវិញយើង អាចសាងអនាគតបាន។

# ព្រះវិញ្ញាណដ៏វិសុទ្ធនាំឲ្យយើងមានសេចក្ដីក្លាហាន ដើម្បីផ្ដល់សក្ខីភាពអំពីព្រះបិតា ដោយ យកចិត្តទុកដាក់ និងបម្រើអ្នកដទៃ

In the Spirit, serve God and our brothers and sisters

អត្ថបទទី១៖ សុភ ៨, ២២-៣១
អត្ថបទទី២៖ រម ៥, ១-៥
ដំណឹងល្អ៖យហ ១៦, ១២-១៥

ថ្ងៃនេះយើងគោរពព្រះជាម្ចាស់ដែលជាព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ ជាព្រះត្រៃឯក។ រៀងរាល់ថ្ងៃនៅពេលយើងអធិដ្ឋាន យើងគូសសញ្ញាឈើឆ្កាងដោយព្រះនាម ព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ គឺយើងចូលនៅក្នុងជីវិតរបស់ព្រះជាម្ចាស់យ៉ាង ជ្រៅ។ សម្រាប់យើងជាគ្រីស្ដបរិស័ទ យើងមិននិយាយដោយព្រះនាមព្រះជាម្ចាស់នោះទេ គឺយើងនិយាយដោយព្រះនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធវិញ ដែលមានន័យថា យើងនឹកដល់ ៖

១. ព្រះបិតា គឺយើងនឹកដល់ព្រះបិតាដែលស្រឡាញ់និងដែលថែរក្សាយើង។ នៅពេល យើងសូត្រធម៌ឱព្រះបិតាជាឱកាសមួយឲ្យយើងនឹកដល់ព្រះបិតាដែលបង្កើតយើងហើយរំឭក ឲ្យយើងមានទំនាក់ទំនងជាមួយព្រះបិតាវិញ។ ព្រះបិតារបស់យើងជាព្រះជាម្ចាស់ដែលគង់ នៅជាមួយយើងដែលស្រឡាញ់ថែរក្សា និងការពារយើង។ ឆ្នាំនេះជាឆ្នាំព្រះហាកុរុណាទិគុណ ជាឆ្នាំដែលយើងសម្ដែងព្រះហឫទ័យមេត្តាករុណារបស់ព្រះបិតា។ យើងជាគ្រីស្ដបរិស័ទបាន ទទួលមេត្តាករុណាពីព្រះបិតា ដូច្នេះយើងក៏ត្រូវតែមានចិត្តស្រឡាញ់មេត្តាករុណាដូចព្រះបិតា

ក្នុងអភិបូជាអគ្គសញ្ញាលាបថ្ងាសនៅសំណោងធំ
ថ្ងៃទី២២ ឧសភា ២០១៦

ដែរ។ ថ្ងៃនេះយើងនឹកឃើញពីរបៀបដែលព្រះបិតាស្រឡាញ់យើង លើកលែងទោសឲ្យយើង ការពារនិងថែរក្សាយើង គឺព្រះអង្គប្រៀបដូចជាឪពុកដែលបានចេញមកទទួលកូនពៅវង្វេងដែរ។

២. ព្រះបុត្រា គឺយើងនឹកដល់ព្រះយេស៊ូដែលបានយាងមកក្នុងលោកនេះ និងព្រះអង្គស្រឡាញ់យើងយ៉ាងខ្លាំង។ ព្រះអង្គជួយយើងឲ្យមានជីវិតជាប់ជាមួយព្រះបិតា និងជាប់ជាមួយព្រះវិញ្ញាណដ៏វិសុទ្ធ។ ព្រះអង្គបានសោយទិវង្គតនៅលើឈើឆ្កាង និងព្រះអង្គមានព្រះជន្មរស់ឡើងវិញសម្រាប់យើង។ នៅក្នុងព្រះវិហារយើងឃើញមានទូដាក់ព្រះកាយ គឺជាសញ្ញាសម្គាល់ថាព្រះយេស៊ូស្រឡាញ់យើងនិងគង់នៅជាមួយយើង។ យើងឃើញរូបមួយទៀតគឺព្រះយេស៊ូកំពុងលាងរបួស ជាសញ្ញាសម្គាល់ថា ព្រះយេស៊ូព្យាបាលជំងឺរបស់យើង និងព្រះអង្គជាអ្នកបម្រើហើយព្រះអង្គសូមឲ្យយើងទៅជាអ្នកបម្រើដូចព្រះអង្គដែរ។

រាល់ថ្ងៃពេលអធិដ្ឋាន សូមបងប្អូននឹកជានិច្ចថាព្រះបិតាស្រឡាញ់ខ្ញុំព្រះអង្គណែនាំខ្ញុំឲ្យទទួលជីវិតដ៏ពេញលក្ខណៈ និងឲ្យខ្ញុំស្រឡាញ់អ្នកដទៃដូចព្រះអង្គដែរ។ សូមបងប្អូននឹកជានិច្ចថាព្រះយេស៊ូប្រទានជីវិតផ្ទាល់របស់ព្រះអង្គឲ្យខ្ញុំ និងណែនាំខ្ញុំឲ្យយកចិត្តទុកដាក់បម្រើអ្នកដទៃដូចព្រះអង្គដែរ។ សូមបងប្អូននឹកបែបនេះជានិច្ចនៅរាល់ពេលបងប្អូនគូសសញ្ញាឈើឆ្កាងដោយព្រះនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ។

៣. ព្រះវិញ្ញាណដ៏វិសុទ្ធ គឺយើងនឹកដល់ព្រះវិញ្ញាណ ដែលណែនាំឲ្យក្រុមគ្រីស្តទូតមានចិត្តក្លាហានប្រកាសជំនឿ។ យើងស្គាល់ព្រះយេស៊ូ ដោយសារព្រះវិញ្ញាណដ៏វិសុទ្ធបានសណ្ឋិតលើក្រុមគ្រីស្តទូតហើយគេចេញពីក្រុងយេរូសាឡឹមក្រុងរ៉ូមមករហូតដល់ប្រទេសកម្ពុជាយើង។ សព្វថ្ងៃយើងអង្គុយនៅទីនេះ គឺដោយសារកាល២០០០ឆ្នាំមុន ព្រះវិញ្ញាណដ៏វិសុទ្ធបានយាងមកគង់នៅជាមួយក្រុមគ្រីស្តទូត។ ថ្ងៃនេះសូមកូនៗទាំងអស់ដែលទទួលអគ្គសញ្ញាលាបថ្វាសមានសេចក្តីក្លាហាន ហ៊ានផ្តល់សក្ខីភាពអំពីព្រះបិតាដែលស្រឡាញ់យើង អំពីព្រះយេស៊ូដែលណែនាំឲ្យយើងយកចិត្តទុកដាក់បម្រើអ្នកដទៃ។ សូមព្រះវិញ្ញាណដ៏វិសុទ្ធណែនាំឲ្យកូនៗចេះទទួលខុសត្រូវឲ្យមានយោបល់ល្អ ឲ្យមានប្រាជ្ញាឈ្លៀសវៃ ឲ្យកោតខ្លាចព្រះបិតា ឲ្យធ្វើតាម

ព្រះវិញ្ញាណដ៏វិសុទ្ធ។ នេះជាការអស្ចារ្យដែលកូនៗបានទទួលពីព្រះវិញ្ញាណដ៏វិសុទ្ធដើម្បីឲ្យកូនៗទៅជាមនុស្សថ្មី។

រាល់ថ្ងៃពេលយើងអធិដ្ឋានដោយនាមព្រះបិតា មានន័យថាព្រះបិតាស្រឡាញ់ខ្ញុំណាស់។ ដោយនាមព្រះបុត្រាមានន័យថាព្រះយេស៊ូណែនាំខ្ញុំឲ្យចេះស្រឡាញ់ ចេះបម្រើ ចេះយកចិត្តទុកដាក់អ្នកដទៃ។ ដោយនាមព្រះវិញ្ញាណដ៏វិសុទ្ធ មានន័យថាព្រះវិញ្ញាណណែនាំឲ្យខ្ញុំមានចិត្តក្លាហាន ដើម្បីទៅជាគ្រីស្តបរិស័ទប្រកាសដំណឹងល្អនៅក្នុងជីវិតប្រចាំថ្ងៃនៅកន្លែងដែលខ្ញុំរស់នៅ នៅសាលា នៅទីផ្សារ...ឲ្យខ្ញុំមានទំនាក់ទំនង ឲ្យខ្ញុំចេះស្រឡាញ់ ឲ្យខ្ញុំលើកលែងទោសឲ្យខ្ញុំ លើកទឹកចិត្តគេឲ្យខ្ញុំចេះសម្រុះសម្រួលគ្នាឲ្យខ្ញុំរស់នៅជាអង្គតែមួយ ជាគ្រួសារតែមួយនៅក្នុងព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ។

សរុបសេចក្តីមក សម្រាប់យើងជាគ្រីស្តបរិស័ទ គ្រប់ពេលដែលយើងគូសសញ្ញាឈើឆ្កាង គឺយើងជាគ្រួសារតែមួយ យើងជាក្រុមតែមួយដូចក្រុមគ្រីស្តទូតពីដើម។ ក្រុមគ្រីស្តទូតពីដើមអាចចេញទៅប្រកាសដំណឹងល្អបានដោយសារគេសហការគ្នាដោយសារគេជួយគ្នាទៅវិញទៅមក។ ក្នុងឆ្នាំព្រះមហាករុណាទិគុណនេះ ឲ្យយើងធ្វើដូចព្រះជាម្ចាស់គឺ ១+១+១=១។ ព្រះ-ជាម្ចាស់គង់នៅជាមួយយើងដើម្បីឲ្យយើងទៅជាគ្រីស្តបរិស័ទពិតប្រាកដដែលចេះស្រឡាញ់គ្នាដូចព្រះបិតាស្រឡាញ់យើង ដូចព្រះយេស៊ូជាអ្នកបម្រើដូចព្រះវិញ្ញាណដ៏វិសុទ្ធដែលបំភ្លឺយើង។

សូមព្រះជាម្ចាស់ជាព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ ប្រទានពរឲ្យយើងខ្ញុំទាំងអស់គ្នា គូសសញ្ញាឈើឆ្កាងដោយភ្ជាប់ខ្លួនជាមួយព្រះជាម្ចាស់។ ឲ្យយើងខ្ញុំនឹកឃើញជានិច្ចថាសញ្ញាឈើឆ្កាងគឺជាទុក្ខលំបាករបស់យើងខ្ញុំផង និងក៏ជាសេចក្តីសង្ឃឹមរបស់យើងខ្ញុំផងដែរ ដោយសារព្រះជាម្ចាស់ជាព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធគង់នៅជាមួយយើងខ្ញុំ និងណែនាំឲ្យយើងខ្ញុំមានសេចក្តីសង្ឃឹមជានិច្ច។ យើងខ្ញុំសូមអរព្រះគុណព្រះជាម្ចាស់ ជាព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ។

# គ្មានកិច្ចការណាដែលព្រះជាម្ចាស់ធ្វើមិនបាននោះទេ

Nothing is impossible for God

---

អត្ថបទទី១៖ កណ ១៤,១៨-២០
អត្ថបទទី២៖ ករ ១១, ២៣-២៦
ដំណឹងល្អ៖ លក ៩, ១១ខ-១៧

ថ្ងៃនេះយើងមានកូនៗប្រាំនាក់ដែលទទួលព្រះកាយព្រះគ្រីស្ត។ សន្ដីតេរេសានៃព្រះកុមារយេស៊ូនៅពេលទទួលព្រះកាយព្រះគ្រីស្ដលើកទីមួយ គាត់បាននិយាយថា "ថ្ងៃនេះជាថ្ងៃដ៏អស្ចារ្យសម្រាប់ខ្ញុំដែលហាក់បីដូចជាព្រះយេស៊ូមកថើបខ្ញុំ"។ គ្រប់ពេលអភិបូជាយើងត្រូវតែនឹកឃើញថាគឺជាពេលដ៏អស្ចារ្យសម្រាប់យើងដែលយើងមានពិសោធន៍ជាអង្គតែមួយជាមួយព្រះយេស៊ូ។ ក្នុងព្រះគម្ពីរដែលយើងបានស្ដាប់អំបាញ់មិញ មានចែងពីហេតុការណ៍ដែលបានកើតឡើងនៅពេលព្រះអាទិត្យជិតលិច។ ពេលព្រះអាទិត្យជិតលិច ជាពេលដែលកម្ដៅព្រះអាទិត្យមិនក្ដៅប៉ុន្មានទេ ជាពេលដែលផ្ទៃមេឃឡើងពណ៌ក្រហម ជាពេលដែលយើងមានអារម្មណ៍ថាជិតស្និទ្ធនឹងគ្នា ពេលនោះព្រះយេស៊ូកំពុងគង់នៅយ៉ាងស្និទ្ធស្នាលជាមួយបណ្ដាជនប្រមាណជាង៥.០០០នាក់ ព្រះអង្គកំពុងអប់រំគេ ព្យាបាលអ្នកជំងឺទាំងមានព្រះបន្ទូលអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់ប្រាប់គេផង។

ក្នុងពិធីជប់លៀងចុងក្រោយ ព្រះយេស៊ូបានចែកនំប៉័ងដែលជារូបកាយរបស់ព្រះអង្គផ្ទាល់ទៅក្រុមគ្រីស្ដទូតកាលនោះក៏ជាពេលល្ងាចដែរ។ នៅពេលព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ ព្រះអង្គបានធ្វើដំណើរជាមួយសាវ័កពីរនាក់ទៅភូមិអេម៉ាអូស កាលនោះក៏ជាពេលល្ងាចដែរ។ ពេលនេះព្រះយេស៊ូដែលកំពុងទតមើលទៅបណ្ដាជនដែលដើរតាមព្រះអង្គកំពុង

---

អភិបូជាកុមារប្រាំនាក់ទទួលអគ្គសញ្ញាព្រះកាយព្រះគ្រីស្ដនៅភ្នំពេញថ្មី
ថ្ងៃទី២៩ ឧសភា ២០១៦

ឃ្លាន។ ដោយចាប់ផ្តើមពីនំប៉័ងប្រាំដុំនិងត្រីពីរកន្ទុយព្រះអង្គមានព្រះបន្ទូលទៅក្រុមគ្រីស្តទូតថា **"ចូរអ្នករាល់គ្នាយកម្ហូបអាហារឲ្យគេបរិភោគទៅ"**។ ក្រុមគ្រីស្តទូតគិតថាអ្វីដែលកំពុងមានមិនគ្រប់គ្រាន់ទេ ដោយសារមានបណ្តាជនប្រមាណជាង៥.០០០នាក់ឯណោះ។ ប៉ុន្តែ **"គ្មានការអ្វីអស្ចារ្យពេកដែលព្រះជាម្ចាស់ធ្វើមិនបាននោះទេ"** ព្រះយេស៊ូក៏បញ្ជាទៅសាវ័កថា **"ចូរអ្នករាល់គ្នាយកម្ហូបអាហារឲ្យគេបរិភោគទៅ"**។ នេះជាព្រះបញ្ជារបស់ព្រះយេស៊ូដែលយើងសព្វថ្ងៃត្រូវតែអនុវត្តជានិច្ចនៅពេលយើងបានឃើញបងប្អូនដែលរស់នៅជុំវិញយើងកំពុងជួបទុក្ខលំបាក និងកំពុងជួបបញ្ហា។

ក្នុងអង្គប្រជុំក្រុមលោកអភិបាលទូទាំងពិភពលោកទាំងមូល ដែលជួបជុំគ្នាជាមួយសម្តេចប៉ាបនៅទីក្រុងរ៉ូមកាលពី៥០ឆ្នាំមុន កាលនោះក៏បានយកព្រះបន្ទូល "ចូរអ្នករាល់គ្នាយកម្ហូបអាហារឲ្យគេបរិភោគ" ធ្វើជាប្រធានបទដែរដោយគូសសង្កត់ថា **"ប្រសិនបើយើងមិនបានយកម្ហូបអាហារចែកដល់មនុស្សដែលគ្មានទីពឹង មនុស្សដែលគ្មានម្ហូបអាហារ មនុស្សដែលខ្វះខាតបានបរិភោគទេ នោះយើងហាក់ដូចជាឃាតករដែរ"**។ ដូច្នេះសូមឲ្យយើងគិតគូរចាប់អារម្មណ៍ដល់បងប្អូនយើងឯទៀតៗដែលគ្មានម្ហូបអាហារ។ សូមឲ្យយើងផ្តល់អាហារដល់គេដូចព្រះយេស៊ូមានព្រះបន្ទូលថា **"ចូរអ្នករាល់គ្នាយកម្ហូបអាហារឲ្យគេបរិភោគទៅ"**។

ក្នុងឆ្នាំព្រះមហាករុណាទិគុណនេះ ព្រះយេស៊ូបានបង្ហាញពីរបៀបដែលព្រះបិតាស្រឡាញ់យើង។ ព្រះយេស៊ូសព្វព្រះហឫទ័យឲ្យយើងចែកអាហារដល់បងប្អូនឯទៀតៗដែលខ្វះអាហារ ដើម្បីឲ្យគេមានកម្លាំងអាចងើបឈរឡើង ដើម្បីឲ្យគេមានឱកាសស្តាប់ព្រះបន្ទូល ដើម្បីឲ្យគេមានសេចក្តីសង្ឃឹម ដើម្បីឲ្យគេមានជីវិតថ្មីនិងដើម្បីឲ្យគេអាចទៅមុខបានដើម្បីឲ្យគេមានជំនឿ និងដើម្បីឲ្យគេបានទទួលការសង្គ្រោះ។ ក្នុងអង្គប្រជុំជាមួយប្រធានយុវជនកាតូលិកយើងបានឲ្យគេរិះគិតថាតើយើងជាយុវជន ត្រូវធ្វើដូចម្តេចដើម្បីបម្រើបងប្អូននៅក្នុងសេចក្តីស្រឡាញ់ និងក្នុងការលើកលែងទោសឲ្យគ្នាទៅវិញទៅមក?។

ព្រះបន្ទូលរបស់ព្រះយេស៊ូនៅថ្ងៃនេះ ណែនាំឲ្យយើងយល់ពីតួនាទីរបស់យើង ពីរបៀប

ដែលយើងបម្រើគេពីរបៀបដែលយើងស្រឡាញ់គេ ពីរបៀបដែលយើងលើកលែងទោសឲ្យគេ និងពីរបៀបដែលយើងណែនាំគេឲ្យបានទទួលជីវិតថ្មី។ សកម្មភាពទាំងអស់របស់ព្រះយេស៊ូ គឺជារបៀបដែលយើងត្រូវប្រព្រឹត្តនៅក្នុងការរស់នៅរបស់យើង។ មានសកម្មភាពបួនយ៉ាង ដែលយើងត្រូវប្រព្រឹត្តគឺ ទីមួយព្រះយេស៊ូយកនំបុ័ងមកកាន់ ទីពីរព្រះយេស៊ូសរសើរតម្កើង ព្រះជាម្ចាស់ ទីបីព្រះយេស៊ូកាច់នំបុ័ងនិងប្រទានឲ្យសាវ័ក និងទីបួនព្រះយេស៊ូចាត់ក្រុមសាវ័ក ឲ្យចែកអាហារទៅបណ្ដាជន រួចហើយព្រះយេស៊ូឲ្យគេប្រមូលអ្វីដែលសល់មកទុកវិញ ដែល មានន័យថាប្រមូលសេចក្ដីសង្ឃឹម ជំនឿ សេចក្ដីស្រឡាញ់ ទេពកោសល្យ សមត្ថភាពមករួមគ្នា អធិដ្ឋានសរសើរតម្កើងព្រះជាម្ចាស់។ មនុស្សយើងមិនអាចធ្វើអ្វីដោយកម្លាំងផ្ទាល់ខ្លួនបានទេ តែយើងទទួលកម្លាំងពីព្រះជាម្ចាស់វិញ។ ព្រះយេស៊ូមាននំបុ័ងប្រាំដុំនិងត្រីពីរកន្ទុយ ប៉ុន្តែព្រះ-អង្គអាចចិញ្ចឹមមនុស្សជាង៥.០០០នាក់បានគឺដោយ សារព្រះអង្គបានសរសើរតម្កើងព្រះជាម្ចាស់ ដោយសារព្រះអង្គបានអធិដ្ឋាន។ ដូចគ្នាដែរយើងត្រូវតែអធិដ្ឋាន យើងត្រូវផ្ញើអ្វីដ៏តិចតួចដែល យើងមានទៅព្រះជាម្ចាស់ឲ្យព្រះអង្គបំពេញ ឲ្យព្រះអង្គគង់នៅជាមួយយើង ឲ្យព្រះអង្គផ្ដល់ សមត្ថភាពឲ្យយើងម្នាក់ៗ ដើម្បីយើងមានជំនឿ ដើម្បីយើងមានកម្លាំងមកពីព្រះយេស៊ូ ដើម្បី យើងប្រព្រឹត្តគ្រប់កិច្ចការតទៅមុខទៀត។

បន្ទាប់មកព្រះយេស៊ូបានកាច់នំបុ័ងចែកទៅក្រុមគ្រីស្តទូតនិងបណ្ដាជន។ ដូចគ្នាដែរ ក្នុងការរស់នៅ យើងត្រូវតែចែករំលែកអ្វីដែលយើងមានឲ្យទៅបងប្អូនឯទៀតៗ ដើម្បីឲ្យគេបាន សេចក្ដីសុខដើម្បីឲ្យគេមានកម្លាំងថ្មី...។ ក្រោយពីបរិភោគឆ្អែតគ្រប់ៗគ្នាហើយ បណ្ដាជនប្រមូល នំបុ័ងដែលនៅសល់បាន១២ល្អីទុកចែកដល់អ្នកផ្សេងៗទៀត។ ដូច្នេះក្រុមគ្រីស្តទូតរួមជាមួយ ព្រះយេស៊ូ មិនត្រឹមតែចែកឲ្យបណ្ដាជនបានឆ្អែត ប៉ុន្តែបានបង្រៀនបណ្ដាជនឲ្យចេះប្រមូលអ្វីៗ ដែលគេមាន ទុកសម្រាប់ចែកឲ្យអ្នកឯទៀតៗដែរ គឺចែកឲ្យគ្នាទៅវិញទៅមក។ ដូច្នេះគ្រប់ពេល ដែលយើងធ្វើសកម្មភាព នោះត្រូវមានគោលដៅជានិច្ចថា ឲ្យគេទទួលកម្លាំងដើម្បីឲ្យគេអាច ងើបឈរបាន និងឲ្យគេមានសមត្ថភាពដើម្បីចែកដល់បងប្អូនឯទៀតៗដែរ។ យើងទាំងអស់

គ្នានឹងទៅជាក្រុមគ្រួសារមួយ ដែលចេះចែករំលែកគ្នាទៅវិញទៅមក ដោយសារយើងមានព្រះយេស៊ូគង់នៅជាមួយយើង។

អគ្គសញ្ញាអរព្រះគុណព្រះជាម្ចាស់នៅពេលនេះ គឺជាឱកាសមួយឲ្យយើងទាំងអស់គ្នារួមជាមួយកូនៗទាំងប្រាំនាក់ អរព្រះគុណព្រះជាម្ចាស់ដែលប្រមូលយើងធ្វើជាក្រុមគ្រួសារតែមួយ។ ពេលយើងទទួលព្រះកាយព្រះគ្រីស្តពិតមែន គឺយើងទទួលព្រះយេស៊ូ គឺយើងទទួលជីវិតពីព្រះអង្គ។ ក្នុងអភិបូជាមុនចែកព្រះកាយព្រះគ្រីស្តលោកបូជាចារ្យបានកាច់នំបុ័ងជាពីរហើយចែកឲ្យយើងមានន័យថាយើងគ្រប់គ្នាទទួលព្រះកាយព្រះគ្រីស្តតែមួយដូចគ្នា ដូច្នេះយើងគឺយើងជាក្រុមគ្រួសារតែមួយយើងជាព្រះកាយតែមួយរបស់ព្រះយេស៊ូយើងជាព្រះដំណាក់របស់ព្រះគ្រីស្ត។ពេលបញ្ចប់អភិបូជាលោកបូជាចារ្យមានប្រសាសន៍ថា **"សូមអញ្ជើញឲ្យបានសុខសាន្ត"** មានន័យថាលោកចាត់ឲ្យយើងចេញទៅក្នុងនាមព្រះគ្រីស្តដើម្បីចែករំលែកសេចក្តីសុខសាន្ត សេចក្តីស្រឡាញ់ អំណរសប្បាយ ដែលយើងបានទទួលពីព្រះយេស៊ូក្នុងអភិបូជានេះទៅដល់អ្នកឯទៀតៗ។

ថ្ងៃនេះជាថ្ងៃពិសេសសម្រាប់កូនៗទាំងប្រាំនាក់ និងសម្រាប់យើងទាំងអស់គ្នា ដោយសារយើងបានរួមគ្នាថ្វាយអភិបូជា ដែលគ្រប់អភិបូជាគឺជាឱកាសដែលព្រះយេស៊ូយាងមកគង់នៅជាមួយយើង ហើយយើងទៅជាគ្រួសារតែមួយដែលទទួលកម្លាំងពីព្រះអង្គ។ យើងបានទទួលព្រះកាយព្រះគ្រីស្តតូចមួយ ប៉ុន្តែតាមរយៈសកម្មភាពរបស់យើង ព្រះកាយនេះមានឥទ្ធិពលដល់មនុស្សជាច្រើននាក់ទៀត នេះជាអត្ថន័យនៃជីវិតរបស់យើង។ នាយប់ចុងក្រោយក្នុងទិវាយុវជនពិភពលោកនៅប្រទេសអេស្ប៉ាញ ជាមួយសម្តេចប៉ាបបេណេឌិកតូទី១៦ យើងនៅជាមួយគ្នាជាង២លាននាក់ជាមួយនឹងអាកាសធាតុដ៏លំបាក ដែលមានខ្យល់និងភ្លៀង។ កាលនោះសម្តេចប៉ាបបានតាំងព្រះកាយយ៉ាងធំលើអាសនៈហើយលុតជង្គង់ចុះយ៉ាងស្ងប់ស្ងាត់ចំនួន១៥នាទី។ យើងទាំងអស់គ្នាជាង២លាននាក់ យើងបានលុតជង្គង់ដោយសម្លឹងមើលព្រះកាយព្រះគ្រីស្តដោយគ្មានសម្លេងណាមួយសោះ។ ពេលនោះទាំងយុវជន ទាំងបងប្រុស

បងស្រី ទាំងបូជាចារ្យ ទាំងលោកអភិបាល រួមជាមួយសម្ដេចប៉ាបដែលនៅមុខព្រះកាយព្រះគ្រីស្ដ យើងមានពិសោធន៍អំពីអង្គតែមួយ គ្រួសារតែមួយជាមួយព្រះយេស៊ូ។ យើងមកពីគ្រប់ប្រទេសទូទាំងពិភពលោកទាំងមូល សម្លឹងមើលព្រះកាយព្រះគ្រីស្ដទាំងយល់ថាព្រះយេស៊ូគង់នៅជាមួយយើង និងណែនាំឲ្យយើងទាំងអស់គ្នារួបរួមគ្នាជាអង្គតែមួយ ជាព្រះកាយព្រះគ្រីស្ដនៅក្នុងសេចក្ដីសុខសាន្តរបស់របស់ព្រះជាម្ចាស់។

**"ចូរអ្នករាល់គ្នាយកម្ហូបអាហារឲ្យគេបរិភោគទៅ"**

# ព្រះយេស៊ូ និងព្រះនាងម៉ារីណែនាំឲ្យយើងស្គាល់ព្រះហឫទ័យស្រឡាញ់របស់ព្រះបិតា

Jesus and Mary, lead us to know the will of God

---

| |
|---|
| អត្ថបទទី១៖ កណ ១៤,១៨-២០ |
| អត្ថបទទី២៖ ករ ១១, ២៣-២៦ |
| ដំណឹងល្អ៖ លក ៩, ១១ខ-១៧ |

សូមអរព្រះគុណព្រះជាម្ចាស់សម្រាប់ព្រះសហគមន៍នៅប្រទេសកម្ពុជា សម្រាប់យុវជនយុវនារី សម្រាប់បងប្រុសឆាល ដែលនឹងទទួលអគ្គសញ្ញាតែងតាំងជាឧបដ្ឋាកនៅថ្ងៃស្អែក។ ពេលនេះជាឱកាសមួយសម្រាប់យើងចូលយ៉ាងជ្រៅនៅក្នុងជីវិត ដែលយើងបានទទួលពីព្រះជាម្ចាស់ជាពិសេសក្នុងឆ្នាំព្រះមហាករុណាទិគុណនេះ។

ថ្ងៃនេះយើងគោរពព្រះបេះដូងរបស់ព្រះយេស៊ូ និងព្រះហឫទ័យមេត្តាករុណារបស់ព្រះយេស៊ូ និងថ្ងៃស្អែកយើងគោរពព្រះបេះដូងរបស់ព្រះនាងម៉ារី។ ព្រះយេស៊ូនិងព្រះនាងម៉ារីណែនាំឲ្យយើងស្គាល់ព្រះហឫទ័យស្រឡាញ់របស់ព្រះបិតា។ ព្រះយេស៊ូបានធ្វើដំណើរពីភូមិមួយទៅភូមិមួយទៀតដើម្បីប្រកាសអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់ និងជាពិសេសដើម្បីណែនាំឲ្យមនុស្សទាំងអស់ស្គាល់ព្រះបិតា និងប្រែចិត្តគំនិតមកផ្ញើជីវិតលើព្រះអង្គ ដោយបានស្តាប់ព្រះបន្ទូលដំណឹងល្អរបស់ព្រះជាម្ចាស់។ ព្រះយេស៊ូក៏អញ្ជើញយើងទាំងអស់គ្នាឲ្យហៅព្រះជាម្ចាស់ថាជាព្រះបិតាថាជាអប្បាដែរ ដោយសារព្រះបិតាគង់នៅជាមួយយើង និងណែនាំឲ្យយើងទទួលជីវិតថ្មី។

ជីវិតថ្មីដែលព្រះបិតាប្រទានឲ្យយើង គឺសេចក្តីស្រឡាញ់ ដែលប្រៀបដូចជាឪពុកមានកូនពៅបានឃ្លាតឆ្ងាយទៅ។ នៅពេលបាត់បង់អ្វីៗទាំងអស់ កូនពៅនោះក៏នឹកឃើញដល់ឪពុក

---

អភិបូជាអធិដ្ឋានពេញមួយយប់នៅកំពង់សោម
ថ្ងៃទី០៣ មិថុនា ២០១៦

របស់ខ្លួនហើយសុខចិត្តត្រឡប់មករកឪពុកវិញ។ មកមិនទាន់ដល់ផ្ទះផង ឪពុកដែលបានឃើញកូនពីចម្ងាយក៏រត់ទៅទទួលស្វាគមន៍កូនទាំងចិត្តស្រឡាញ់ នឹករឭកកូន និងមានអំណរសប្បាយដោយសារបានឃើញកូនដែលបាត់បង់ទៅវិលត្រឡប់មកវិញ។ នេះជាពិសោធន៍សម្រាប់ណែនាំយើងនៅក្នុងឆ្នាំព្រះមហាករុណាទិគុណនេះ។ចំពោះយើងថ្វីដ្បិតតែយើងជាមនុស្សមានបាប បានធ្វើខុសពីព្រះហឫទ័យរបស់ព្រះជាម្ចាស់ យើងបានរស់នៅឆ្ងាយពីដំណឹងល្អពីធម្មវិន័យដែលព្រះយេស៊ូបានប្រៀនប្រដៅឲ្យយើងស្រឡាញ់គ្នាទៅវិញទៅមកដូចព្រះអង្គបានស្រឡាញ់យើង ឲ្យយើងស្រឡាញ់ខ្មាំងសត្រូវ ឲ្យយើងលើកលែងទោសឲ្យគេ៧០គុណនឹង៧ដង... ប៉ុន្តែព្រះជាម្ចាស់នៅតែទទួលស្វាគមន៍យើងជានិច្ច ព្រះអង្គលើកលែងទោសឲ្យយើង ព្រះអង្គប្រណីសន្ដោសយើងដើម្បីឲ្យយើងបានទទួលជីវិតថ្មី និងជាពិសេសឲ្យយើងទទួលកិត្តិយសជាបុត្រធីតាដ៏ពេញលក្ខណៈរបស់ព្រះអង្គ នៅពេលយើងទទួលស្គាល់ពីភាពទន់ខ្សោយរបស់ខ្លួន។

ពិតមែន យើងជាអ្នកបាបដែលបានទទួលការលើកលែងទោស និងកិត្តិយសដ៏ពេញលក្ខណៈសាជាថ្មីពីព្រះជាម្ចាស់។ នេះជាអំណរសប្បាយរបស់យើងក្នុងឆ្នាំព្រះមហាករុណាទិគុណនេះ និងជាពិសេសក្នុងយប់នេះជាយប់ទី៥០ ដែលយើងរួមគ្នាអធិដ្ឋាន រួមគ្នាអង្គុយនៅក្បែរឈើឆ្កាងរបស់ព្រះយេស៊ូ ដូចព្រះនាងម៉ារីដែលនៅក្បែរព្រះយេស៊ូតាំងពីព្រះអង្គចាប់ផ្ទៃរហូតព្រះអង្គសោយទិវង្គត។ ព្រះនាងម៉ារីតែងយល់ពីព្រះបំណងរបស់ព្រះយេស៊ូ ដោយសារព្រះនាងបានសម្លឹងមើលព្រះយេស៊ូ។ ពេលនេះយើងសម្លឹងមើលព្រះយេស៊ូដូចព្រះនាងដែរដើម្បីយើងយល់ពីព្រះហឫទ័យរបស់ព្រះអង្គ។

យប់នេះនៅក្បែរឈើឆ្កាង យើងនឹកដល់ព្រះយេស៊ូដែលបង្ហាញព្រះហឫទ័យមេត្តាករុណារបស់ព្រះបិតាចំពោះយើង ដោយព្រះអង្គលើកលែងទោសឲ្យអ្នកដែលបានធ្វើគតព្រះអង្គដោយមានព្រះបន្ទូលថា **"ឱព្រះបិតាអើយ! កុំដាក់ទោសគេធ្វើអ្វី ដោយសារគេមិនដឹងថាគេកំពុងធ្វើអ្វីឡើយ"**។ យើងនឹកដល់ព្រះយេស៊ូដែលបានលើកលែងទោសឲ្យអ្នកទោសដែលជាប់ឆ្កាងក្បែរព្រះអង្គដោយមានព្រះបន្ទូលថា "ថ្ងៃនេះពិតមែនអ្នកនឹងបានទៅស្ថានបរមសុខជាមួយខ្ញុំ"។

ចុងក្រោយព្រះយេស៊ូបានទតសម្លឹងទៅមាតា និងលោកយ៉ូហានដោយមានព្រះបន្ទូលថា **"អ្នកអើយសូមទទួលគាត់ទុកជាកូនផងចុះ"** និងថា **"យ៉ូហានអើយ សូមទទួលមាតាទុកជាមាតារបស់អ្នកផងចុះ"**។ ពិតមែនព្រះនាងម៉ារីជាព្រះមាតានៃព្រះសហគមន៍ ដែលណែនាំឲ្យយើងចូលនៅក្នុងព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់ ឲ្យយើងមានពិសោធន៍នៅក្នុងដួងចិត្ត នៅក្នុងជីវិតពីរបៀបដែលព្រះជាម្ចាស់ស្រឡាញ់យើងដោយគ្មានព្រំដែន។

យប់នេះយើងអង្គុយសម្លឹងមើលទឹក ដែលកំពុងហូរចេញពីព្រះបេះដូងព្រះយេស៊ូ មកលាងជម្រះចិត្តគំនិតរបស់យើងឲ្យបរិសុទ្ធ។ យើងសម្លឹងមើលព្រះលោហិតដែលកំពុងហូរចេញពីព្រះបេះដូងព្រះគ្រីស្តចូលនៅក្នុងសរសៃឈាមរបស់យើង ដើម្បីឲ្យយើងទទួលជីវិតដ៏បរិបូរណ៍ពីព្រះអង្គ និងឲ្យយើងចេះស្រឡាញ់គ្នាទៅវិញទៅមកដូចព្រះយេស៊ូបានស្រឡាញ់យើងដែរ។ ថ្ងៃនេះព្រះនាងម៉ារីដែលជាព្រះមាតានៃព្រះហឫទ័យប្រណីសន្ដោស ជាមាតារបស់ព្រះបុត្រាដែលជាព្រះភក្ត្ររបស់ព្រះបិតា ព្រះនាងអញ្ជើញយើងម្នាក់ៗ ដែលជាគ្រីស្តបរិស័ទឲ្យទទួលបេសកកម្មថ្មី ចេញទៅគ្រប់ទីកន្លែង ដើម្បីសម្ដែងព្រះហឫទ័យមេត្តាករុណារបស់ព្រះជាម្ចាស់ចំពោះមនុស្សទាំងឡាយ។

ក្នុងសង្គមរបស់យើងបច្ចុប្បន្ននេះ មិនខ្វះទេអ្នកដែលគ្មានទីពឹង មិនខ្វះទេអ្នកដែលគ្មានសេចក្តីសង្ឃឹម។ ថ្ងៃនេះយើងដែលបានទទួលបេសកកម្មថ្មី គឺយើងនេះហើយដែលត្រូវទៅណែនាំពួកគេឲ្យអាចងើបឈរឡើង ដូចព្រះយេស៊ូមានព្រះបន្ទូលថា **"នាងអើយឈរឡើងជ្បិតជំនឿរបស់នាងបានសង្គ្រោះនាងហើយ"**។ ថ្ងៃនេះព្រះយេស៊ូក៏មានព្រះបន្ទូលមកយើងដែរថា "ចូរចេញទៅ ជំនឿរបស់អ្នកបានសង្គ្រោះអ្នកហើយ" គឺព្រះអង្គចាត់យើងឲ្យចេញទៅធ្វើជាសញ្ញាសម្គាល់នៃព្រះហឫទ័យស្រឡាញ់របស់ព្រះបិតាដើម្បីឲ្យសង្គមរបស់យើងបច្ចុប្បន្នទៅជាសង្គមថ្មីដោយសារសេចក្តីស្រឡាញ់របស់យើង។ កន្លែងណាមានសេចក្តីស្រឡាញ់ កន្លែងនោះនឹងមានសកម្មភាពសង្គ្រោះដែលណែនាំឲ្យអ្នកដទៃមានជីវិតដ៏បរិបូណ៌។

យប់នេះយើងខ្ញុំសូមអរព្រះគុណព្រះជាម្ចាស់អស់ពីដួងចិត្ត រួមជាមួយព្រះនាងម៉ារី

ដែលឆ្លើយថា **"នាងខ្ញុំជាអ្នកបម្រើ សូមព្រះអង្គធ្វើតាមព្រះហឫទ័យរបស់ព្រះអង្គចុះ"**។ យប់នេះព្រះជាម្ចាស់បានជ្រើសរើសយើងខ្ញុំ ឲ្យធ្វើជាសាវ័កនៃធម៌មេត្តាករុណា ឲ្យធ្វើជាអ្នកបម្រើ ដើម្បីបន្តបេសកកម្មរបស់ព្រះអង្គ គឺបេសកកម្មប្រកាសដំណឹងល្អ ដែលព្រះយេស៊ូបានប្រទានឲ្យក្រុមគ្រីស្តទូតដើមដំបូង ដែលពេលនេះយើងត្រូវប្រកាសនៅលើទឹកដីរបស់យើង ដោយអស់ពីកម្លាំងកាយចិត្ត អស់ពីសេចក្តីស្រឡាញ់នៅក្នុងអំណរសប្បាយដែលមកពីព្រះវិញ្ញាណដ៏វិសុទ្ធ។

**"ចូរចេញទៅ ជំនឿរបស់អ្នកបានសង្គ្រោះអ្នកហើយ"**

# ព្រះនាងម៉ារីជាគំរូសម្រាប់ឧបដ្ឋាក

Mary, our model of service

អត្ថបទទី១៖ ធម ៤, ១-៨
ដំណឹងល្អ៖ លក ២, ៤១-៥១

អស់រយៈពេល៥០ឆ្នាំហើយ ដែលព្រះសហគមន៍សន្តៈមីកាអែលនៅកំពង់សោម នេះបានកើតឡើង និងជាលើកទីមួយដែរ ដែលមានអគ្គសញ្ញាតែងតាំងជាឧបដ្ឋាកនៅទីនេះ។ សូមអរគុណដល់ក្រុមយេរ៉ូម៉ាល់ ដែលអនុញ្ញាតឲ្យបងប្រុសធាល បានទទួលអគ្គសញ្ញាតែង តាំងជាឧបដ្ឋាកនៅកម្ពុជា។ ឧបដ្ឋាកមានន័យថា ជាអ្នកបម្រើរបស់ព្រះយេស៊ូ និងបម្រើ ព្រះសហគមន៍។ ថ្ងៃនេះយើងគោរពព្រះនាងម៉ារី។ ពេលព្រះនាងម៉ារីបានទទួលដំណឹងថា ព្រះនាងនឹងទៅជាមាតារបស់ព្រះជាម្ចាស់ នោះព្រះនាងបានឆ្លើយទៅទេវទូតកាព្រីអែលភ្លាម ថា **"នាងខ្ញុំជាអ្នកបម្រើរបស់ព្រះជាម្ចាស់ សូមធ្វើតាមព្រះហឫទ័យរបស់ព្រះអង្គចុះ"**។

នៅពេលយើងនិយាយអំពីតួនាទីជាឧបដ្ឋាក នោះសូមឲ្យយើងមើលរបៀបរបស់ព្រះ នាងម៉ារី ដែលយើងអាចនិយាយបានថា ព្រះនាងជាឧបដ្ឋាកមុនគេបង្អស់ក្នុងព្រះសហគមន៍។ នៅពេលទទួលដំណឹងភ្លាមព្រះនាងសប្បាយចិត្តណាស់ ដោយបានធ្វើជាអ្នកបម្រើរបស់ ព្រះជាម្ចាស់ **"នាងខ្ញុំមានអំណរយ៉ាងខ្លាំងព្រោះតែព្រះអម្ចាស់។ នាងខ្ញុំរីករាយអស់ពីចិត្ត ព្រោះតែព្រះរបស់នាងខ្ញុំ ដ្បិតព្រះអង្គបានសង្គ្រោះនាងខ្ញុំ"**។ ខ្ញុំសង្ឃឹមថាបងប្រុសធាលនៅពេល ព្រះសហគមន៍ត្រាស់ហៅឲ្យគាត់ធ្វើជាឧបដ្ឋាក គាត់ក៏មានអំណរសប្បាយយ៉ាងខ្លាំងដែរហើយ គាត់បានចែកអំណរសប្បាយនោះជាមួយបងប្អូនរបស់គាត់នៅប្រទេសកេនយ៉ា និងជាមួយ

---

អភិបូជាតែងតាំងបងប្រុសធាលជាឧបដ្ឋាក នៅកំពង់សោម
ថ្ងៃទី ០៤ មិថុនា ២០១៦

ក្រុមគ្រួសារយ៉ូសែបម៉ាល់។ គាត់មានអំណរសប្បាយ ដូចព្រះនាងម៉ារីដែលមានអំណរសប្បាយ ដោយបានត្រាស់ហៅទៅជាមាតារបស់ព្រះយេស៊ូ។

ថ្ងៃនេះព្រះនាងម៉ារីនិងលោកយ៉ូសែប ដែលធ្វើដំណើរត្រឡប់ពីក្រុងយេរូសាឡឹមវិញបាត់ព្រះកុមារយេស៊ូ។ ព្រឹត្តិការណ៍នេះនាំឲ្យយើងគិតខ្លះៗអំពីជីវិតជាឧបដ្ឋាក។ ខ្ញុំសូមអញ្ជើញបងប្អូន ជាពិសេសបងប្រុសឆាល ពិនិត្យមើលរបៀបរបស់ព្រះនាងម៉ារី។ ជារៀងរាល់ឆ្នាំក្នុងឱកាសបុណ្យចម្លង អ្នកកាន់សាសនាយូដាតែងតែធ្វើដំណើរទៅទីក្រុងយេរូសាឡឹមជានិច្ច។ ពេលព្រះយេស៊ូមានព្រះជន្ម១២ព្រះវស្សា ព្រះនាងម៉ារីនិងលោកយ៉ូសែបជាមាតាបិតា ក៏បាននាំព្រះកុមារយេស៊ូចូលរួមក្នុងពិធីបុណ្យនោះតាមទំនៀមទម្លាប់ដែរ។ ព្រះនាងម៉ារីនិងលោកយ៉ូសែបគោរពពិធីបុណ្យតាមសាសនារបស់គាត់ខ្លាំងណាស់ ដោយរាល់ឆ្នាំពួកគាត់តែងធ្វើដំណើរទៅក្រុងយេរូសាឡឹមដើម្បីគោរពព្រះជាម្ចាស់តាមពិធីដ៏សក្ការៈ ដែលអ្នកកាន់សាសនាយូដាត្រូវតែគោរព។

ដូចគ្នាដែរតួនាទីទី១របស់ឧបដ្ឋាក គឺគោរពពិធីបុណ្យនីមួយៗក្នុងសាសនាយើង មានដូចជាពិធីបុណ្យអធិដ្ឋានតាមកំណត់ ពិធីបុណ្យអភិបូជា និងពិធីបុណ្យដោយធ្វើអគ្គសញ្ញាខ្លះៗ ដូចជាអគ្គសញ្ញាជ្រមុជទឹក និងអគ្គសញ្ញាអាពាហ៍ពិពាហ៍ និងជួយបម្រើអាសនៈជាដើម។ ជារៀងរាល់ថ្ងៃ ឧបដ្ឋាកត្រូវយកពេលចូលរួមក្នុងអភិបូជា ត្រូវបម្រើអាសនៈ ត្រូវអធិដ្ឋានតាមកំណត់ គឺអធិដ្ឋានពេលព្រឹក ពេលថ្ងៃ និងពេលល្ងាចឲ្យព្រះសហគមន៍ទាំងមូលទទួលកម្លាំងកាយ កម្លាំងចិត្តតាមរយៈការអធិដ្ឋានរបស់ខ្លួន។

ព្រះនាងម៉ារីនិងលោកយ៉ូសែបជាមាតាបិតា បាននាំព្រះកុមារជាបុត្រ ទៅចូលរួមក្នុងពិធីបុណ្យសាសនាតាមទំនៀមទម្លាប់ សេចក្តីនេះមានន័យថា យើងជាសាសនទូតដែលបម្រើព្រះសហគមន៍នៅប្រទេសកម្ពុជា ក៏ត្រូវតែកើតសាជាថ្មីក្នុងវប្បធម៌នៅទីនេះដែរ ដោយយើងត្រូវចូលយ៉ាងជ្រៅនៅក្នុងជីវិតថ្មីដែលយើងបានទទួល យើងត្រូវចូលយ៉ាងជ្រៅនៅក្នុងទឹកដី

ដែលយើងបានទទួលដោយមុនដំបូងបង្អស់ គឺយើងត្រូវយល់ចិត្តគំនិតរបស់បងប្អូនដែលយើងនឹងបម្រើ។សម្រាប់បងប្រុសឆាលដែលបានទទួលអគ្គសញ្ញាតែងតាំងនៅលើទឹកដីកម្ពុជាដែលបានរស់នៅក្នុងប្រទេសកម្ពុជាមួយឆ្នាំកន្លះហើយ នោះបងប្រុសនឹងមានពេលច្រើនទៀតដើម្បីចូលជ្រៅទៅៗ និងទៅជាផ្លុងមួយជាមួយទឹកដីខ្មែរ ដូចប្រសាសន៍របស់លោកអភិបាលអេមីលដែលយើងបានចារនៅលើផ្នូររបស់លោកថា **"ខ្ញុំបានមកបម្រើព្រះសហគមន៍នៅកម្ពុជាខ្ញុំបានរស់នៅប្រទេសកម្ពុជា ខ្ញុំសូមស្លាប់នៅប្រទេសកម្ពុជា ដើម្បីទៅជាតែមួយនឹងទឹកដីកម្ពុជា"** និងដូចព្រះនាងម៉ារីដែលបានចូលយ៉ាងជ្រៅនៅក្នុងប្រពៃណី និងទំនៀមទម្លាប់របស់អ្នកកាន់សាសនាយូដាដែរ។ ទាំងអស់នេះជាសេចក្ដីសង្ឃឹមរបស់យើងដែលជាសាសនាទូត បម្រើព្រះសហគមន៍នៅទីនេះ។

បីថ្ងៃក្រោយមក មាតាបិតារកឃើញព្រះកុមារយេស៊ូនៅក្នុងព្រះវិហារ។ ក្នុងរយៈពេលបីថ្ងៃនេះ មាតាបិតាបានខិតខំស្វែងរកកូនខ្លាំងណាស់ គាត់បានចូលពីផ្ទះមួយទៅផ្ទះមួយទៀត រហូតទៅដល់វិសាលវិហារ ដែលជាឱកាសឲ្យព្រះនាងម៉ារីបានសួរសុខទុក្ខប្រជាជនតាមផ្ទះនីមួយៗជាហូរហែ រហូតទៅដល់ក្រុងយេរូសាឡឹម។ នេះក៏ជាតួនាទីរបស់បងប្រុសឆាលដែរ។ យើងជាសាសនាទូត ត្រូវតែទៅជួប និងទៅសួរសុខទុក្ខបងប្អូនឯទៀតៗដែរ ដែលជាឱកាសមួយដើម្បីយើងផ្ដល់សក្ខីភាព ដើម្បីរកឃើញព្រះយេស៊ូតាមកន្លែងនីមួយៗដែលយើងទៅដល់។

បងប្រុសឆាលនឹងទៅជាឧបដ្ឋាក និងជាបូជាចារ្យនៅពេលខាងមុខ ត្រូវដឹងថា យើងជាអ្នកបម្រើត្រូវតែដើរពីភូមិមួយទៅភូមិមួយទៀត ត្រូវចូលតាមផ្ទះនីមួយៗដើម្បីសួរសុខទុក្ខបងប្អូន។ ដូច្នេះត្រូវគិតថាតើត្រូវធ្វើដូចម្ដេចដើម្បីបានជួប បានស្រឡាញ់ បានបម្រើ បានស្វាគមន៍ បានបង្កើតទំនាក់ទំនងជាមួយបងប្អូន ដូចព្រះនាងម៉ារី ក្នុងរយៈពេលបីថ្ងៃដើររកព្រះកុមារយេស៊ូតាមផ្ទះប្រជាជន ហើយក្រោយមកបានរកឃើញព្រះកុមារយេស៊ូក្នុងព្រះវិហា។ ពេលយើងធ្វើតាមគំរូដូចនេះ ណែនាំឲ្យយើងរកឃើញព្រះយេស៊ូ និងក៏ណែនាំឲ្យអ្នកដទៃរកឃើញព្រះយេស៊ូដែរ។

ពេលជួបព្រះយេស៊ូហើយ នៅចំពោះមុខធម្មាចារ្យ ព្រឹទ្ធាចារ្យដែលកំពុងស្តាប់ព្រះកុមារមានព្រះបន្ទូលនោះ ព្រះនាងម៉ារីក៏សួរទៅព្រះកុមារជាបុត្រថា **"កូនអើយ! ហេតុអ្វីបានជាកូនធ្វើដូច្នេះ?"**។ ព្រះនាងម៉ារីហ៊ានចូលទៅជិត និងហ៊ានសួរដូចនេះនៅចំពោះមុខអស់លោកធម្មាចារ្យ និងព្រឹទ្ធាចារ្យ ដោយសារតែព្រះនាងមានព្រះវិញ្ញាណដ៏វិសុទ្ធគង់ជាមួយ និងដោយសារតែព្រះនាងជាមាតារបស់ព្រះជាម្ចាស់។ សម្រាប់បងប្រុសឆាលក៏ត្រូវធ្វើដូចនេះដែរ គឺត្រូវតែជាអ្នកមានសមត្ថភាពខ្ពស់ក្នុងការស្ទង់ចិត្តគំនិតរបស់មនុស្ស និងទៅជាអ្នកមានសមត្ថភាពខ្ពស់ក្នុងការបំពេញកិច្ចការរបស់ព្រះជាម្ចាស់ ដោយបើកដួងចិត្តបន្តិចម្តងៗដើម្បីទទួលបងប្អូនឯទៀតៗដូចព្រះនាងម៉ារី។ ពេលរកឃើញព្រះកុមារយេស៊ូហើយ ព្រះនាងម៉ារីបានសួរថា **"ហេតុអ្វី?"** ជាសំណួរដែលបង្កើតចម្លើយ គឺបង្កើតទំនាក់ទំនង។ ដូចគ្នាដែរ ពេលចុះទៅតាមភូមិ បងប្រុសឆាលត្រូវបង្កើតការសន្ទនាជាមួយបងប្អូនទាំងអស់។ ខ្ញុំក៏សូមអញ្ជើញបងប្អូនទាំងអស់បង្កើតទំនាក់ទំនងជាមួយអ្នកដទៃ ដោយសួរសុខទុក្ខ ដោយចាប់អារម្មណ៍ ដើម្បីយល់ថាពិតមែនយើងជាបងប្អូនបង្កើតនៅក្នុងព្រះជាម្ចាស់។

មាតារបស់ព្រះកុមារយេស៊ូចងចាំហេតុការណ៍ទាំងអស់នោះទុកក្នុងចិត្ត គឺព្រះនាងបណ្តោយតាមព្រះហឫទ័យព្រះជាម្ចាស់។ ក្នុងការរស់នៅយើងជួបបញ្ហាជាច្រើន ដែលបានកើតឡើង ហើយណែនាំឲ្យយើងវង្វេង ឲ្យយើងបាក់ទឹកចិត្ត ប៉ុន្តែសូមឲ្យយើងធ្វើដូចព្រះនាងម៉ារីដែរ គឺអ្វីៗដែលកំពុងកើតឡើងឲ្យយើងទុកនៅក្នុងចិត្ត ហើយឲ្យយើងថ្វាយកិច្ចការនោះទៅព្រះជាម្ចាស់ ដើម្បីយើងបន្តដំណើរទៅមុខទៀត។ លោកអភិបាលអេមីល បានមានប្រសាសន៍ជាញឹកញាប់ថា **"រឿងនេះខ្ញុំមិនចង់ទទួលទេ ប៉ុន្តែខ្ញុំថ្វាយទៅព្រះជាម្ចាស់"**។ដូចព្រះនាងម៉ារីដែរ លោកបានថ្វាយទៅព្រះជាម្ចាស់ ដោយធ្វើតាមព្រះហឫទ័យរបស់ព្រះអង្គ។ សរុបមកសូមឲ្យយើងទាំងអស់គ្នាជាពិសេសបងប្រុសឆាល ត្រូវធ្វើជាអ្នកបម្រើដែលដើរតាមសួរសុខទុក្ខបងប្អូន ដើម្បីគេរកឃើញព្រះយេស៊ូ ដោយបង្កើតទំនាក់ទំនង បង្កើតការសន្ទនាជាមួយបងប្អូនឯទៀតៗជានិច្ច។

ឆ្នាំនេះជាឆ្នាំព្រះមហាករុណាទិគុណ ជាឆ្នាំដែលយើងសម្តែងព្រះហឫទ័យមេត្តាករុណារបស់ព្រះជាម្ចាស់ គឺជាឱកាសមួយដើម្បីអស់មួយជីវិតឲ្យយើងធ្វើជាសញ្ញាសម្គាល់នៃព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គ ដូចយើងស្តាប់ឮព្យាការីអេសាយមានប្រសាសន៍ថា **"ព្រះជាអម្ចាស់នឹងធ្វើឲ្យសេចក្តីសុចរិត និងការសរសើរតម្កើងផុសចេញពីទឹកដីនេះនៅចំពោះប្រជាជាតិទាំងប៉ុន្មាន"** និងសូមឲ្យយើងអាចនិយាយបានថា **"ព្រះជាអម្ចាស់នឹងធ្វើឲ្យសេចក្តីសុចរិត និងការសរសើរតម្កើងផុសចេញពីទឹកដីកម្ពុជានៅចំពោះប្រជារាស្ត្រកម្ពុជាទាំងឡាយ"** ដើម្បីទទួលសេចក្តីសុខសាន្ត។

សូមសេចក្តីសុខសាន្ត និងអំណរសប្បាយរបស់ព្រះជាម្ចាស់គង់នៅជាមួយយើងទាំងអស់គ្នា ជាពិសេសជាមួយបងប្រុសធាល។ សូមឲ្យបងប្រុសធ្វើជាអ្នកបម្រើដែលពោរពេញដោយអំណរសប្បាយដ៏ពេញលក្ខណៈ។

**"នាងខ្ញុំជាអ្នកបម្រើរបស់ព្រះជាម្ចាស់ សូមធ្វើតាមព្រះហឫទ័យរបស់ព្រះអង្គចុះ"**

# យើងបានទទួលដោយឥតគិតថ្លៃយើងធ្វើដូចម្ដេចដើម្បីឲ្យដោយឥតគិតថ្លៃដែរ...

Freely you have received. Freely give

---

អត្ថបទទី១៖ កក ១១, ២១ខ-២៦ និង ១៣, ១-៣
ដំណឹងល្អ៖ មថ ៩, ៣៣-៣៧

ថ្ងៃនេះយើងមាននិស្សិតសាលាអប់រំជំនឿសន្តៈយ៉ូស្វីនជំនាន់ទី១ និងទី២រួមគ្នាដែលជំនាន់ទី១រៀនពីឆ្នាំ២០១១ ដល់ឆ្នាំ២០១៣ និងជំនាន់ទី២រៀនពីឆ្នាំ២០១៣ ដល់ឆ្នាំ២០១៥។ ក្រោយមកយើងមិនបានទទួលជំនាន់ទី៣ទេ ដើម្បីគ្រូៗមានឱកាសរៀបចំមេរៀនសម្រាប់ជំនាន់ទី៣ និងក៏ដើម្បីឲ្យនិស្សិតជំនាន់ទី១និងទី២ទទួលការអប់រំបន្ថែមដែរ។ យើងបានជួបជុំគ្នា៦ដងក្នុងឆ្នាំនេះដោយជួបជាមួយលោកបប់ម្ដង លោកម៉ារីយូម្ដង លោកវ៉ាំងសង់ម្ដង និងលោកអភិបាលបីដង ដើម្បីមកទទួលការអប់រំបន្ថែមអំពីឆ្នាំព្រះមហាករុណាទិគុណ អំពីគម្ពីរ អំពីប្រវត្តិសាស្ត្រនៃព្រះសហគមន៍ អំពីសីលធម៌ អំពីទេវវិទ្យា និងចុងក្រោយអំពីលទ្ធិព្រះសហគមន៍នៅក្នុងសង្គម និងជាពិសេសក្នុងឆ្នាំនេះ និស្សិតបានរៀបចំគម្រោងការធ្វើឲ្យយើងដែលជានិស្សិតសាលាអប់រំសន្តៈជំនឿយូស្វីន ទៅជាគ្រីស្តទូតប្រកាសដំណឹងល្អ។ យើងមាន១២ក្រុមដែលបានរៀបចំគម្រោងការប្រកាសដំណឹងល្អនៅក្នុងភូមិភាគភ្នំពេញ។

ថ្ងៃនេះជាបុណ្យរបស់សន្តៈបាណាបាស់ ស្របនឹងគម្រោងការរបស់យើងមែនទែន ដែលព្រះយេស៊ូមានព្រះបន្ទូលថា **"សូមទៅប្រកាសថាព្រះរាជ្យនៃស្ថានបរមសុខមកជិតបង្កើយហើយ"**។ យើងនៅសល់ពេលវេលាសម្រាប់ចូលរួមក្នុងគម្រោងការប្រកាសដំណឹងល្អ។ ព្រះ-

---

ក្នុងអភិបូជាចាត់ក្រុមនិស្សិតនៃសាលាសន្តៈយ៉ូស្វីន
ចេញទៅប្រកាសដំណឹងល្អ
ថ្ងៃទី ១១ មិថុនា ២០១៦

យេស៊ូមានព្រះបន្ទូលតាំងពី២.០០០ឆ្នាំមុន រហូតដល់ ឥឡូវនេះឆ្នាំ២០១៦ ប៉ុន្តែព្រះរាជ្យរបស់ព្រះជាម្ចាស់នៅតែមិនទាន់មកដល់យ៉ាងពេញលក្ខណៈទេ គឺកំពុងយាងមក។ ដូច្នេះយើងត្រូវខិតខំសាបព្រោះថែមទៀត ដើម្បីឲ្យព្រះរាជ្យរបស់ព្រះជាម្ចាស់បន្តិចម្តងៗយាងមកដល់។ យើងទាំងអស់គ្នាជាព្រះសហគមន៍ នៅក្នុងព្រះសហគមន៍យើងម្នាក់ៗមានតួនាទីដូចមានចែងក្នុងអត្ថបទទីមួយ ដែលព្រះសហគមន៍ដើមដំបូងបានរកឃើញមនុស្សខ្លះ អាចចេញទៅប្រកាសដំណឹងល្អបានរួចហើយគេបានតែងតាំង ដែលបន្ទាប់មកលោកបាណាបាស់ និងលោកប៉ូល បានចេញទៅប្រកាសដំណឹងល្អនៅតាមកន្លែងផ្សេងៗ។

ព្រះសហគមន៍មានតួនាទីប្រកាសដំណឹងល្អ គឺយើងម្នាក់ៗមានសមត្ថភាពមួយ មានកម្លាំងមួយប្លែកៗពីគ្នាដើម្បីប្រកាស។ អ្នកខ្លះប្រកាសដំណឹងល្អដោយប្រោសឲ្យអ្នកជំងឺបានជាសះស្បើយ អ្នកខ្លះប្រោសមនុស្សស្លាប់ឲ្យរស់ឡើងវិញ ខ្លះទៀតប្រោសមនុស្សឃ្លង់ឲ្យបានស្អាតបរិសុទ្ធ ខ្លះបណ្តេញខ្មោចចេញពីមនុស្ស...នេះគឺជាតួនាទីដែលយើងត្រូវទទួលសព្វថ្ងៃ។ តាមគម្រោងនៃការប្រកាសដំណឹងល្អរបស់យើង គឺក្រុមនីមួយៗត្រូវខិតខំណែនាំមនុស្សដែលបាត់បង់សេចក្តីសង្ឃឹមឲ្យមានសង្ឃឹមឡើងវិញដូចយើងបានស្តាប់ព្រះបន្ទូលរួចហើយថា **"យើងជាឧបករណ៍តូចមួយ ដើម្បីនាំឲ្យការសង្គ្រោះយាងមក"**។ យើងជាគ្រីស្តបរិស័ទនៅក្នុងភូមិភាគភ្នំពេញ គឺយើងទទួលតួនាទីជាគ្រីស្តទូតដើម្បីកសាងព្រះសហគមន៍ក្នុងភូមិភាគយើងឲ្យចម្រើនឡើងនៅក្នុងសេចក្តីស្រឡាញ់ នៅក្នុងយុត្តិធម៌ នៅក្នុងការគោរពសិទ្ធិមនុស្ស ដោយខិតខំជួយមនុស្សដែលអស់សង្ឃឹមនៅក្នុងជីវិត។ ក្នុងគម្រោងការដែលយើងបានរៀបចំ គ្មានក្រុមណាមួយសុំអ្វីសោះពីព្រះសហគមន៍ គឺយើងធ្វើតាមសមត្ថភាព ស្របតាមព្រះបន្ទូលថា "កុំរកមាសប្រាក់ ឬលុយដាក់ក្នុងថង់ឡើយ។ កុំយកថង់យាម កុំយកអាវពីរ កុំយកស្បែកជើង ឬដំបងទៅជាមួយ ដ្បិតអ្នកត្រូវតែទទួលម្ហូបអាហារ"។

ដូច្នេះ យើងបានផ្ញើជីវិតទាំងស្រុងលើឧបការគុណរបស់ព្រះជាម្ចាស់ ដែលស្រឡាញ់ និងជ្រើសរើសយើង ហើយព្រះអង្គក៏ផ្តល់កម្លាំងឲ្យយើងទៅមុខ ដើម្បីឲ្យទស្សនៈរបស់យើង

សេចក្ដីស្រឡាញ់របស់យើង គំនិតរបស់យើងកើតជារូបរាងតាមគំរូរបស់ព្រះយេស៊ូ។ យើងបានទទួលព្រះអំណោយទានគ្រប់បែបយ៉ាង ពីព្រះជាម្ចាស់ដោយឥតគិតថ្លៃ ដូច្នេះយើងត្រូវចែកទៅបងប្អូនឯទៀតៗដោយឥតគិតថ្លៃដែរ។ យើងត្រូវបង្កើតសមត្ថភាពរបស់ព្រះសហគមន៍យើងនីមួយៗឧទាហរណ៍យើងចង់ជួយក្មេងអនាថា យើងមិនសុំជំនួយពីបរទេសទេតែឲ្យយើងធ្វើនៅក្នុងសមត្ថភាពរបស់យើង។ ដូច្នេះក្រុមនីមួយៗ ព្រះសហគមន៍នីមួយៗ ត្រូវគិតពីសមត្ថ-ភាពរបស់ខ្លួនក្នុងការប្រកាសដំណឹងល្អនេះ។ រយៈពេលពីរឆ្នាំកន្លងមកនេះ យើងបានទទួលការសិក្សាយើងបានទទួលអំណរសប្បាយរួមគ្នា យើងបានទទួលបទពិសោធន៍យ៉ាងច្រើន និងយើងក៏បានធ្វើទស្សកិច្ចសិក្សានៅព្រះសហគមន៍ប្រទេសឡាវ វៀតណាម ថៃ អ៊ីស្រាអែល និងហ្វីលីពីន ដែរ។ យើងសូមអរព្រះគុណព្រះជាម្ចាស់។

ព្រះជាម្ចាស់បានជ្រើសរើសយើងទៅជាគ្រីស្តទូតតូចមួយ ឲ្យចេញទៅប្រកាសដំណឹងល្អ។ ដូច្នេះយើងត្រូវបន្តធ្វើកិច្ចការនេះដើម្បីឲ្យព្រះសហគមន៍របស់យើង ទៅជាព្រះសហគមន៍ដែលមានជីវិតថែមទៀត។ យើងត្រូវចូលយ៉ាងជ្រៅក្នុងបញ្ហាសង្គមទៅនិយាយប្រាប់ដល់បងប្អូនឯទៀតៗអំពីសេចក្ដីសុខសាន្តអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់តែយើងមិនបង្ខំគេដូចព្រះយេស៊ូមានព្រះបន្ទូលថា **"បើគេទទួល យើងនៅ បើគេមិនទទួល យើងចេញ"។ តាមអេភេសូជំពូក៣ "មនុស្សទាំងអស់មានសិទ្ធិទទួលដំណឹងល្អ មនុស្សទាំងអស់មានសិទ្ធិចូលនៅក្នុងព្រះកាយព្រះគ្រីស្តមនុស្សទាំងអស់មានសិទ្ធិទទួលមរតកពីព្រះជាម្ចាស់"** ដូច្នេះដើម្បីឲ្យមនុស្សទាំងអស់អាចទទួលដំណឹងល្អ អាចចូលនៅក្នុងព្រះកាយគ្រីស្ត និងអាចទទួលមរតកបាននោះយើងត្រូវមានសមត្ថភាពត្រូវមានកម្លាំងដើម្បីទៅបំពេញសិទ្ធិឲ្យគេ។ គ្រប់ពេលយើងគឺជាសាក្សីនៃសន្តិភាពដែលនាំឲ្យមនុស្សទាំងអស់មានសេចក្តីសុខសាន្ត ដោយមានសេចក្តីស្រឡាញ់។

យើងខ្ញុំសូមអរព្រះគុណព្រះជាម្ចាស់ សូមឲ្យពាក្យសន្យារបស់យើងខ្ញុំ បានចូលយ៉ាងជ្រៅនៅក្នុងខ្លួនរបស់យើងខ្ញុំ។ សូមឲ្យយើងខ្ញុំដឹងខ្លួនថា **"ព្រះជាម្ចាស់បានជ្រើសរើសយើងខ្ញុំបានចាត់យើងខ្ញុំឲ្យទៅប្រកាសដំណឹងល្អ"** ដូចពីដើមដែលព្រះអង្គបានជ្រើសរើស ហើយបានចាត់

សន្តៈប៉ូលនិងសន្តៈបាណាបាស់ឲ្យទៅប្រកាសដំណឹងល្អដែរ។  សូមអរព្រះគុណព្រះជាម្ចាស់ សូមព្រះវិញ្ញាណដ៏វិសុទ្ធយាងមកគង់នៅជាមួយយើងខ្ញុំ  ដើម្បីឲ្យយើងខ្ញុំម្នាក់ៗមានចិត្តក្លាហាន ហ៊ានប្រកាសដូចសន្តៈប៉ូល  និងសន្តៈសិលាដែរថា **"ព្រះយេស៊ូបានចាប់កំណើតជាមនុស្ស ព្រះយេស៊ូបានសោយទិវង្គត ព្រះយេស៊ូបានមានព្រះជន្មរស់ឡើងវិញ និងព្រះយេស៊ូគង់នៅជាមួយយើងខ្ញុំសព្វថ្ងៃ"**។ សូមឲ្យយើងខ្ញុំទាំងអស់គ្នាទៅជាពន្លឺសម្រាប់ពិភពលោក ទៅជាគ្រីស្តទូតតូចមួយយ៉ាងអស្ចារ្យ សម្រាប់ភូមិភាគភ្នំពេញដែរ។

**"សូមទៅប្រកាសថាព្រះរាជ្យនៃស្ថានបរមសុខមកជិតបង្កើយហើយ"**

# មិនមែនខ្ញុំទេដែលរស់នៅគឺព្រះគ្រីស្តទេតើ ដែលរស់នៅក្នុងខ្ញុំ

It is no longer I who live but Christ lives in me

អត្ថបទទី១៖ សម ១២, ៧-១០.១៣
អត្ថបទទី២៖ កាឡ ២, ១៦.១៩-២១
ដំណឹងល្អ៖ លក ៧, ៣៦ ដល់ ៨, ៣

កាលពីថ្ងៃអាទិត្យមុន ព្រះសហគមន៍របស់យើងបានទទួលកូនៗ៥នាក់ ឲ្យទទួលអគ្គសញ្ញាព្រះកាយព្រះគ្រីស្ត ហើយនៅថ្ងៃនេះ យើងបានទទួលកូនៗ៣នាក់ទៀតឲ្យទទួលអគ្គសញ្ញាជ្រមុជទឹក។ ថ្ងៃនេះក្នុងអត្ថបទទី២ សន្តៈប៉ូលមានប្រសាសន៍ថា **"មិនមែនខ្ញុំទេដែលរស់នៅ គឺព្រះគ្រីស្តទេតើដែលរស់នៅក្នុងខ្ញុំ"** នោះជួយឲ្យយើងយល់អត្ថន័យយ៉ាងជ្រៅនៃ អគ្គសញ្ញាជ្រមុជទឹក គឺយើងបានទទួលជីវិតថ្មីពីព្រះយេស៊ូ។ ព្រះយេស៊ូគង់នៅក្នុងយើងហើយ យើងគឺតែមួយជាមួយព្រះយេស៊ូ។ នៅក្នុងអគ្គសញ្ញាជ្រមុជទឹក យើងបានប្រើទឹកជាសញ្ញាថាយើងរួមស្លាប់និងរួមរស់ជាមួយព្រះយេស៊ូ។ យើងបានប្រើប្រេងជាសញ្ញាថា យើងទទួលកម្លាំងពីព្រះយេស៊ូ។ យើងបានប្រើអាវសបង្ហាញថារូបកាយរបស់យើងបំពាក់ដោយព្រះយេស៊ូ។ យើងបានប្រើទៀនជាសញ្ញាថាព្រះយេស៊ូជាព្រះពន្លឺបំភ្លឺយើងឲ្យដឹងថាជីវិតរបស់យើងមិនដូចពីមុនទេ។

បងប្អូនមួយចំនួនដែលទទួលអគ្គសញ្ញាជ្រមុជទឹកនៅពេលពេញវ័យ នោះគេមានសមត្ថភាពគ្រប់គ្រាន់នឹកចងចាំអំពីជំនឿ ប៉ុន្តែសម្រាប់កូនៗដែលទទួលអគ្គសញ្ញាជ្រមុជទឹកនៅថ្ងៃនេះ គឺគេនៅតូច ដូច្នេះការចងចាំរបស់គេ សង្ឃឹមទាំងស្រុងលើឪពុកម្តាយធម៌រួម

ពិធីទិវាព្រះមហាករុណាទិគុណសម្រាប់អ្នកជំងឺ និង ជនពិការ
នៅព្រះសហគមន៍សន្តៈសិលា និងសន្តៈប៉ូល ភ្នំពេញថ្មី
ថ្ងៃទី ១២ មិថុនា ២០១៦

ជាមួយ នឹងឪពុកម្ដាយបង្កើតជួយអប់រំពួកគេក្នុងការធ្វើដំណើររួមជាមួយព្រះយេស៊ូ ដែលបន្តិចម្ដងៗឲ្យគេចេះសូត្រធម៌បពិត្រព្រះនាងម៉ារី ធម៌ឱព្រះបិតា បន្ទាប់មកជំរុញគេឲ្យទៅទទួលការអប់រំជំនឿពីព្រះសហគមន៍ រហូតដល់ធំពេញវ័យឲ្យគេអាចប្រកាសដោយផ្ទាល់ថា **"មិនមែនខ្ញុំទេដែលរស់នៅ គឺព្រះគ្រីស្តទេតើដែលរស់នៅក្នុងខ្ញុំ"**។

ថ្ងៃនេះជាទិវាព្រះមហាករុណាទិគុណសម្រាប់អ្នកជំងឺ ជាពេលវេលាដែលយើងស្តាប់ ព្រះបន្ទូលដំណឹងល្អដែលបង្ហាញអំពីរបៀបព្រះបិតាស្រឡាញ់យើង ទាំងឲ្យដឹងថានៅពេលយើងសម្លឹងមើលព្រះយេស៊ូនោះយើងនឹងមើលឃើញព្រះបិតា។ នៅពេលយើងសម្តែងមេត្តាករុណាគឺយើងនៅជាប់ជាមួយព្រះយេស៊ូ។ នៅពេលយើងស្តាប់ព្រះបន្ទូលគឺយើងទៅជាផ្លូងតែមួយជាមួយនឹងព្រះយេស៊ូ។ ក្នុងឆ្នាំព្រះមហាករុណាទិគុណនេះព្រះសហគមន៍សូមឲ្យយើងមានចិត្តមេត្តាករុណា ដូចព្រះបិតាដែលមានព្រះហឫទ័យមេត្តាករុណា។ តាមអត្ថបទគម្ពីរកាលពីសប្តាហ៍មុនព្រះយេស៊ូបានមានព្រះបន្ទូលទៅកាន់ស្ត្រីមេម៉ាយម្នាក់ថា **"កុំយំអី នាងអើយ!"**។ ក្នុងឆ្នាំព្រះមហាករុណាទិគុណនេះ ព្រះបន្ទូលដែលជាប់ជាមួយពាក្យថា **"កុំយំ កុំពិបាកចិត្ត កុំបាក់ទឹកចិត្ត..."** ពិតជាមានអត្ថន័យសម្រាប់យើងជាគ្រីស្តបរិស័ទ។

ថ្ងៃនេះព្រះបន្ទូលមានចែងពីស្ត្រីម្នាក់ដែលមានបាបពេញខ្លួន នាងស្ថិតនៅចំពោះព្រះភ័ក្ត្រព្រះយេស៊ូទាំងយំយ៉ាងខ្លាំង ដោយនាងនឹកឃើញពីបាបរបស់ខ្លួន និងនឹកឃើញពីព្រះ-ហឫទ័យប្រណីសន្តោសរបស់ព្រះយេស៊ូមានចំពោះនាង ដ្បិតមនុស្សក្នុងសង្គម គ្មានអ្នកណាម្នាក់ចង់រាប់អាននាងទេ។ នៅក្នុងផ្ទះរបស់លោកស៊ីម៉ូន នាងទៅអង្គុយទៀបនឹងព្រះបាទារបស់ព្រះយេស៊ូ ហើយយកទឹកក្រអូបចាក់លាងព្រះបាទាព្រះអង្គផង ទាំងជូតសម្អាតដោយសក់របស់នាងទៀត។ ព្រះយេស៊ូមានព្រះបន្ទូលទៅនាងថា **"ខ្ញុំលើកលែងទោសឲ្យនាងបានរួចពីបាប ជំនឿរបស់នាងបានសង្គ្រោះនាង សូមនាងអញ្ជើញទៅវិញប្រកបដោយសេចក្តីសុខសាន្ត"**។ យើងទាំងអស់គ្នាមានបំណងឲ្យព្រះយេស៊ូមានព្រះបន្ទូលដូចនេះ មកយើងទាំងអស់គ្នាខ្លាំងណាស់ ។

ក្នុងឆ្នាំព្រះមហាករុណាទិគុណនេះ សូមឲ្យយើងជាគ្រីស្តបរិស័ទប្រកាសដោយផ្ទាល់ខ្លួនថា "មិនមែនខ្ញុំទេដែលរស់នៅ គឺព្រះគ្រីស្តទេតើដែលរស់នៅក្នុងខ្ញុំ" ដោយឲ្យយើងធ្វើសញ្ញាសម្គាល់នៃធម៌មេត្តាករុណាដល់អ្នកដទៃ។ យប់មិញយើងបានប្រមូលប្រជាជនប្រមាណ ៤៥០នាក់ មកចូលរួមក្នុង **"ពិធីជប់លៀងកសាងសុខសន្តិភាព"** នៅភូមិសុខសាន្ត ដែលមានគ្រីស្តបរិស័ទ មានអ្នកជំងឺអេដស៍ មានជនពិការ មានកូនសិស្សសាលាមត្តេយ្យ មានអាណាព្យាបាលសិស្ស មានអ្នកភូមិ មានឪពុកម្តាយរបស់ជនពិការ និងរបស់អ្នកជំងឺ ដែលពួកគាត់បានរៀបចំខ្លួនយ៉ាងស្អាតបាត ទាំងបានបង្ហាញអារម្មណ៍ថា ព្រះសហគមន៍យើងបានផ្តល់តម្លៃ និងបានបង្ហាញធម៌មេត្តាករុណា និងសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ដល់ពួកគាត់...។ នេះជាអ្វីដែលយើងបានធ្វើស្របតាមព្រះបន្ទូលរបស់ព្រះយេស៊ូថា **"សូមនាងអញ្ជើញទៅវិញប្រកបដោយសេចក្តីសុខសាន្ត"**។

តើធ្វើដូចម្តេចដើម្បីយើងកសាងសេចក្តីសុខសាន្ត? តើធ្វើដូចម្តេចដើម្បីយើងលើកទឹកចិត្តនិងបង្ហាញធម៌មេត្តាករុណារបស់ព្រះជាម្ចាស់?។ សម្រាប់យើងជាព្រះសហគមន៍នៅក្នុងភូមិភាគភ្នំពេញ គឺនៅគ្រប់ទីកន្លែងដែលយើងរស់នៅ នោះយើងត្រូវតែបង្កើតភូមិសុខសាន្តយ៉ាងតូចមួយដែលមានន័យថា យើងត្រូវមានកម្មវិធីជាក់ស្តែងជាមួយមនុស្សដែលសង្គម មើលមិនឃើញ ជាមួយជនដែលគ្មានទីពឹង ជាមួយជនពិការធ្ងន់ដែលគ្មានអ្នកថែទាំជាមួយជនចាស់ជរា។ល។ ក្នុងឆ្នាំព្រះមហាករុណាទិគុណនេះ គឺជាពេលវេលាមួយដែលយើងជាព្រះសហគមន៍ ត្រូវយកចិត្តទុកដាក់លើវិស័យជាអាទិភាពទាំងប្រាំពីរដែលមាន៖ ការអប់រំ សុខភាព ជនពិការ ពលករ ការការពារធម្មជាតិ ការណែនាំឲ្យអ្នកក្រីក្រចូលក្នុងសង្គម និងកិច្ចសន្ទនាអន្តរសាសនា។ ដោយសារយើងបានកសាងជីវិតយ៉ាងពិតប្រាកដដែលអាចឲ្យយើងធ្វើដំណើរទៅមុខបាន ដោយសារយើងបាននាំបងប្អូនឲ្យចូលនៅក្នុងសង្គមដោយសារយើង បានចូលក្នុងក្រុមផ្សេងៗដើម្បីជួយសង្គម ដោយសារយើងបានបង្កើតទំនាក់ទំនងពិតៗនៅក្នុងសង្គមនោះពិតប្រាកដណាស់គ្រប់ទីកន្លែងដែលយើងរស់នៅនឹងមានសន្តិភាពមានសេចក្តី

ស្រឡាញ់គ្រប់លក្ខណៈមកពីព្រះជាម្ចាស់ ទៅជាភូមិសុខសាន្តយ៉ាងតូចមួយ ស្របតាមព្រះបន្ទូលរបស់ព្រះយេស៊ូថា **"សូមនាងអញ្ជើញទៅវិញ ប្រកបដោយសេចក្តីសុខសាន្ត"**។

ពេលមានជនពិការ អ្នកជំងឺ អ្នកគ្មានទីពឹង អ្នកភូមិ សិស្សសាលា ....។ មានឱកាសមកហូបបាយរួមជាមួយគ្នា ពិតមែនគឺយើងបានណែនាំឲ្យពួកគេចូលនៅក្នុងសង្គមយ៉ាងពិតប្រាកដឲ្យទៅជាក្រុមគ្រួសារតែមួយ។ ខ្ញុំសង្ឃឹមថាក្នុងភូមិភាគភ្នំពេញយើងក្នុងឆ្នាំព្រះមហាករុណាទិគុណនេះ នឹងទៅជាឆ្នាំដែលមានផលផ្លែយ៉ាងច្រើនដោយដឹងថាព្រះយេស៊ូយាងមកទាំងមានព្រះបន្ទូលថា **"សូមអញ្ជើញទៅវិញចុះដោយសារអ្នកបានទទួលជីវិតថ្មី និងបានទទួលសេចក្តីសុខសាន្តហើយ"**។

ថ្ងៃនេះយើងខ្ញុំសូមអរព្រះគុណព្រះជាម្ចាស់ សម្រាប់ព្រះសហគមន៍ដែលព្រះយេស៊ូបានប្រទានឲ្យយើងខ្ញុំ។ សូមអរព្រះគុណព្រះជាម្ចាស់សម្រាប់កម្លាំងដែលយើងខ្ញុំបានទទួលពីព្រះយេស៊ូ។ សូមព្រះជាម្ចាស់ប្រទានពរដល់យើងខ្ញុំទាំងអស់គ្នាឲ្យដឹងយ៉ាងច្បាស់ថា បងប្អូនជាជនពិការ អ្នកជំងឺ...គឺជាបងប្អូនរបស់យើងខ្ញុំពិតប្រាកដមែន គឺជាក្រុមគ្រួសារតែមួយដែលព្រះជាម្ចាស់ណែនាំឲ្យយើងទៅជាបងប្អូនគ្នាក្នុងអង្គព្រះគ្រីស្ត ដែលពោរពេញដោយសេចក្តីស្រឡាញ់ និងដោយអំណរសប្បាយ។

# នៅលើផ្ទាំងសិលានេះខ្ញុំនឹងសង់ព្រះសហគមន៍របស់ខ្ញុំ

And on this rock I will build my church

---

អត្ថបទទី១៖ របា ២៤, ១៧-២៥
ដំណឹងល្អ៖ មថ ៦, ២៤-៣៤

ថ្ងៃនេះ យើងចូលនៅក្នុងព្រះវិហារដោយមានអារម្មណ៍កក់ក្តៅណាស់ ដោយសារយើងកំពុងជួបជាមួយព្រះយេស៊ូដោយដឹងថា យើងជាមហាគ្រួសារតែមួយ ដែលបានសាងសង់នៅលើសន្តៈសិលាដែលមានព្រះយេស៊ូជាគ្រឹះ។ ក្នុងខែនេះយើងត្រូវអធិដ្ឋានសម្រាប់លោកបូជាចារ្យជាច្រើននាក់ ដែលបានទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យក្នុងខែមិថុនានេះ។ ក្នុងភូមិភាគភ្នំពេញយើងមានលោកបូជាចារ្យ១៧នាក់ ដែលបានទទួលអគ្គសញ្ញាតែងតាំងក្នុងខែនេះ។

ក្នុងគម្ពីរដំណឹងល្អថ្ងៃនេះ ព្រះយេស៊ូមានព្រះបន្ទូលទៅលោកសិលាថា **"ខ្ញុំសូមប្រាប់អ្នកថាអ្នកឈ្មោះសិលា ហើយនៅលើផ្ទាំងសិលានេះ ខ្ញុំនឹងសាងសង់ព្រះសហគមន៍របស់ខ្ញុំ"**។ ដោយសារព្រះបន្ទូលនេះហើយ ជាអ្វីដែលលោកបូជាចារ្យសិលា សួនហង្សលី សុខចិត្តទទួលមុខងារថ្មី។ ខ្ញុំសូមស្វាគមន៍នៅក្នុងអំណរសប្បាយ និងទទួលលោកក្នុងសេចក្តីស្រឡាញ់ដើម្បីលោកបំពេញមុខងារបម្រើនៅមណ្ឌលសកម្មភាពភ្នំពេញថ្មីនេះ។ នៅឆ្នាំ២០០២ លោកបូជាចារ្យសិលា សួនហង្សលី រស់នៅជាមួយខ្ញុំនៅកំពត ក្រោយមកលោកទៅទទួលព្រះសហគមន៍ជុំគីរី និងថ្ងៃនេះលោកទទួលប្រចាំការនៅភ្នំពេញថ្មី ទាំងសម្រុះសម្រួលសម្រាប់ព្រះសហគមន៍នៅពោធិ៍ចិនតុងដែលមានលោកឪពុកតូនី ជាមួយព្រះហគមន៍នៅកំពង់ស្ពឺដែល

---

អភិបូជាសម្ពោធព្រះវិហារសន្តៈសិលា សន្តៈប៉ូលនៅភ្នំពេញថ្មី
ថ្ងៃទី ១៨ មិថុនា ២០១៦

មានលោកឪពុកក្រុមដេស្វីត ជាមួយព្រះសហគន៍នៅដុនបូស្កូដែលមានលោកឪពុករ៉ូអែល និងជាមួយក្រុមបងស្រីកាម៉ែល ដែលមានលោកឪពុកផ្សេងៗទៅរាល់ថ្ងៃថ្វាយអភិបូជា។

មានសំណួរមួយដែលយើងត្រូវទូលឆ្លើយទៅព្រះយេស៊ូដែលសួរយើងថា **"ឥឡូវនេះ ខ្ញុំសុំឲ្យអ្នកសាងសង់ព្រះសហគមន៍របស់ខ្ញុំ"** ចំពោះយើង តើព្រះសហគមន៍យ៉ាងដូចម្ដេច ដែលយើងត្រូវសាងសង់នៅក្នុងភូមិភាគភ្នំពេញរបស់យើង?។ ពិតមែនព្រះសហគមន៍គឺជាប្រជារាស្ត្ររបស់ព្រះជាម្ចាស់ ដែលព្រះអង្គបានត្រាស់ហៅ ដែលព្រះអង្គបានណែនាំឲ្យមកជួបជុំគ្នាក្នុងអង្គព្រះយេស៊ូគ្រីស្ត។ ថ្ងៃនេះលោកសិលា សួនហង្សលី បានឃើញប្រជារាស្ត្ររបស់ ព្រះជាម្ចាស់មកពីគ្រប់កន្លែងជួបជុំគ្នា ជាប្រជារាស្ត្រដែលព្រះជាម្ចាស់បានប្រទានឲ្យលោក។ ប៉ុន្តែមានប្រជារាស្ត្ររបស់ព្រះជាម្ចាស់មួយចំនួនធំទៀត រស់នៅជុំវិញភ្នំពេញថ្មីនេះ ដែលលោកមិនទាន់ស្គាល់ដូច្នេះព្រះសហគមន៍ដែលលោកបូជាចារ្យសិលា សួនហង្សលី ត្រូវសាងសង់ គឺ៖

ទី១/ ជាព្រះសហគមន៍ដែលប្រជារាស្ត្ររបស់ព្រះជាម្ចាស់ ជួបជាមួយព្រះយេស៊ូដោយផ្ទាល់ក្នុងព្រះវិហារនេះជារៀងរាល់ថ្ងៃ។ នៅពេលបិទឆ្នាំព្រះមហាករុណាទិគុណ ខ្ញុំនឹងតែងតាំងព្រះវិហារនេះជាកន្លែងពិសេស ដើម្បីឲ្យបងប្អូនយើងមកគោរពព្រះយេស៊ូដែលមានព្រះហឫទ័យមេត្តាករុណា។ ដូច្នេះសូមលោកណែនាំឲ្យបងប្អូនមកជួបជាមួយព្រះយេស៊ូដែលមានព្រះហឫទ័យមេត្តាករុណាតាមរយៈការអធិដ្ឋាន តាមរយៈការចូលរួមថ្វាយអភិបូជាដែលមានជាប្រចាំនៅទីនេះ។ ឲ្យបងប្អូនយើងចេញចូលទីនេះដើម្បីភ្ជាប់ខ្លួនគេជាមួយព្រះយេស៊ូ។ ឲ្យបងប្អូនរួមគ្នាសាងសង់ព្រះសហគមន៍លើផ្ទាំងសិលាដ៏រឹងមាំបំផុត គឺជាព្រះយេស៊ូផ្ទាល់ ហើយយើងអាចសាងសង់ព្រះសហគមន៍ លើគ្រឹះដ៏រឹងមាំនេះបានលុះត្រាយើងមានសហការីមានគ្រីស្តបរិស័ទដែលចូលរួម ដែលមានសេចក្តីស្រឡាញ់ ដែលមានការយកចិត្តទុកដាក់ ដែលមានការលើកទឹកចិត្ត និងដែលមានចិត្តអត់ធ្មត់។

ពេលយើងដើរជុំវិញព្រះវិហារ នោះយើងមានអារម្មណ៍ថាចូលនៅក្នុងសួនច្បារអេដែនជាសួនច្បារដែលព្រះជាម្ចាស់បានបង្កើតអាដាំ និងអេវ៉ា។ យើងមានសួនច្បារស្អាតបែបនេះ

គឺដោយសារយើងថែរក្សា និងយើងស្រឡាញ់។ ដូច្នេះដើម្បីមានព្រះសហគមន៍ស្អាត នោះយើងក៏ត្រូវការការថែរក្សា និងទឹកចិត្តស្រឡាញ់ ថែមទាំងត្រូវការពេលវេលា និងការលះបង់ ពីយើងម្នាក់ៗដែរ ពេលណាគេមើលមកព្រះសហគមន៍យើងជាព្រះកាយព្រះគ្រីស្តនោះគេនឹងឃើញព្រះភ័ក្ត្ររបស់ព្រះបិតា ដែលមានព្រះហឫទ័យមេត្តាករុណាជានិច្ចដល់មនុស្សលោក។

លោកបូជាចារ្យសិលា សួនហង្សលី ទទួលតួនាទីមួយជាអ្នកសម្រុះសម្រួលព្រះសហគមន៍ពោធិ៍ចិនតុង កំពង់ស្ពឺ បងស្រីកាម៉ែល និងភ្នំពេញថ្មីនេះ។ ដូច្នេះលោកឪពុកត្រូវសម្រុះសម្រួលដើម្បីឲ្យព្រះសហគមន៍ទាំងអស់សហការគ្នា យកចិត្តទុកដាក់ជួយគ្នាទៅវិញទៅមក ដើម្បីឲ្យព្រះសហគមន៍របស់យើងស្អាតជាងសួនច្បារទៅទៀត ដែលពិតមែនយើងមានសុខដុមរមនានៅក្នុងព្រះសហគមន៍។ ទីពីរ ខ្ញុំក៏សូមឲ្យលោកឪពុកសហការយ៉ាងជិតស្និទ្ធជាមួយភូមិភាគភ្នំពេញព្រោះកន្លែងនេះជាកន្លែងពិសេសបំផុតដែលនឹងទទួលភ្ញៀវ ទទួលសិក្ខាសាលា ទទួលកម្មវិធីទទួលសកម្មភាពផ្សេងៗរបស់ភូមិភាគទាំងមូល។ កន្លែងនេះក៏មានទ្វារជីវិតសុទ្ធដែរ និងបន្តិចទៀតជាកន្លែងដែលយើងគោរពព្រះយេស៊ូព្រះហឫទ័យប្រណីសន្តោស។ ដូច្នេះកន្លែងនេះស្ថិតនៅចំណុចកណ្តាលនៃភូមិភាគភ្នំពេញ។ វត្តមានរបស់លោកឪពុកសំខាន់ណាស់ ព្រោះជាវត្តមានរបស់ព្រះយេស៊ូ ដែលណែនាំឲ្យបងប្អូនចេញចូលនៅទីនេះដោយអំណរ និងកក់ក្តៅ។

២/ "អ្វីៗដែលអ្នកស្រាយនៅលើផែនដីនេះ ព្រះជាម្ចាស់ក៏នឹងស្រាយនៅស្ថានបរមសុខដែរ" នេះជាបេសកកម្មមួយយ៉ាងពិសេស គឺយើងត្រូវណែនាំ ឲ្យបងប្អូនបានរួចផុតពីអ្វីៗទាំងអស់ ដែលជាប់គាំងនៅក្នុងចិត្តរបស់គេ ដើម្បីគេទទួលជីវិតថ្មី ដូចព្រះយេស៊ូបានណែនាំ ឲ្យលោកសិលាបានទទួលជីវិតថ្មីដូច្នោះដែរ។ ពេលលោកសិលាប្រកាសថា **"ព្រះយេស៊ូជាព្រះបុត្រារបស់ព្រះជាម្ចាស់"** នោះអ្វីៗទាំងអស់ដែលជាប់នៅក្នុងចិត្តរបស់លោក បានព្យាបាលអស់ហើយ។ ជាមួយស្ត្រីសាសន៍សាម៉ារី ជាមួយអ្នកពិការ ជាមួយអ្នកអ្នកពិការ ជាមួយស្ត្រីដែលមានបាបពេញខ្លួនដោយសារព្រះយេស៊ូមានព្រះបន្ទូលថា **"ចូរឈរឡើង ជំនឿរបស់អ្នកបានសង្គ្រោះអ្នកហើយ"** នោះការអាក្រក់ទាំងប៉ុន្មានដែលជាប់ក្នុងចិត្តរបស់គេ ត្រូវបានដោះស្រាយទាំងអស់ ហើយគេបាន

ទទួលជីវិតថ្មីថែមទៀត។

ខ្ញុំសូមឲ្យលោកឪពុក និងបងប្អូនទាំងអស់ដែលចេញចូលនៅកន្លែងនេះ មានបេះដូងនៃភ្លើងដូចសន្តៈ សិលានិងសន្តៈប៉ូលដែរ ដើម្បីប្រកាសដំណឹងល្អឲ្យមនុស្សជាច្រើនបានជាសះស្បើយ។ ខ្ញុំសង្ឃឹមថាភ្នំពេញថ្មីនេះនឹងទៅជាកោះនៃធម៌មេត្តាករុណាដែលមនុស្សគ្រប់ៗរូបចេញចូលក្នុងអំណរសប្បាយ និងការជាសះស្បើយ។ បងប្អូនឃើញហើយលោកឪពុកលីបានទទួលមេកូនសោរដើម្បីបើកទ្វារឲ្យបងប្អូនចេញចូលដោយសារកន្លែងនេះជាកន្លែងមួយដែលបងប្អូនអាចរកឃើញសេចក្តីសង្ឃឹម និងការជាសះស្បើយ។ នៅទីនេះកាលពីថ្ងៃយើងប្រារព្ធ **"ទិវានៃព្រះមហាករុណាទិគុណសម្រាប់ជំងឺនិងជនពិការ"** មានមីងម្នាក់គាត់យំ ហើយប្រាប់យើងថា **"នេះជាលើកទីមួយក្នុងជីវិតរបស់ខ្ញុំ ដែលទទួលបានភាពកក់ក្តៅដូចនេះ។ ជាលើកទីមួយដែលគ្មានអ្នកមើលងាយខ្ញុំ។ ជាលើកទីមួយដែលខ្ញុំមានអារម្មណ៍ថាខ្ញុំមានគ្រួសារមួយដែលស្រឡាញ់ខ្ញុំ"**។ នេះជាបេសកកម្មរបស់ក្រុមសង្គហៈដែលត្រូវខិតខំថែមទៀត។

លោកឪពុកសួន ហង្សលី មានសំណាង ដោយសារនៅលើទឹកដីនេះមានក្រុមបងស្រីបងប្រុសជាច្រើនដែលសម្តែងមេត្តាករុណា ដូចជាក្រុមបងស្រីព្រះមាលា បងស្រីមេត្តាករុណា បងស្រីសាឡេស៊ាន បងស្រីបម្រើព្រះយេស៊ូ បងស្រីកាម៉ែលហើយមានលោកឪពុកមកពីដុនបូស្កូ លោកឪពុកពីក្រុមជេស្វិត លោកឪពុកពីក្រុមសាសនទូតកូរ៉េ។ មានក្រុមពីមេក្រុមស្ម័គ្រចិត្តបារាំង។ ក្រុមទាំងអស់នេះកំពុងរស់នៅលើទឹកដីរបស់លោកឪពុក និងកំពុងធ្វើសកម្មភាពលើការសិក្សា លើសុខភាព ជួយអ្នកក្រីក្រ ជួយជនពិការ ជួយអ្នកជំងឺគ្មានទីពឹង ជួយកម្មករ... ដើម្បីបង្ហាញធម៌មេត្តាករុណា។ ជាពិសេសក្រុមបងស្រីកាម៉ែល មិនបានជួយខាង វិជ្ជាបច្ចេកទេសទេ ប៉ុន្តែជួយព្យាបាលខាងដួងចិត្ត ដើម្បីឲ្យយើងបានទទួលជីវិតថ្មី។ នា ពេលអនាគតយើងសង្ឃឹមថាកន្លែងនេះនឹងមានមន្ទីរពេទ្យ មានភូមិសុខសាន្តមួយដើម្បីទទួល ជនពិការអ្នកជំងឺ ជនចាស់ជរា ជនគ្មានទីពឹង និងក៏មានសាលាមត្តេយ្យ និងជាកន្លែងដែលធ្វើកម្មវិធីសង្គមផ្សេងៗ ដែលណែនាំឲ្យព្រះសហគមន៍យើងទៅជាសញ្ញាសម្គាល់នៃព្រះហឫទ័យ

ប្រណីសន្តោសរបស់ព្រះជាម្ចាស់ពិតមែន។ ទីនេះយើងមានសួនច្បារដ៏សុខសាន្ត ដែលជួយព្យាបាលខាងចិត្តគំនិត និងខាងរូបកាយ ទាំងថែទាំសុខភាពផង ដើម្បីបង្ហាញថា ពិតមែនព្រះជាម្ចាស់បានបង្កើតអ្វីៗទាំងអស់។

លោកប៉ូលមានប្រសាសន៍ថា **"មានតែព្រះអម្ចាស់ប៉ុណ្ណោះ ដែលគាំទ្រនិងប្រទានឲ្យខ្ញុំមានកម្លាំង ដើម្បីឲ្យខ្ញុំអាចប្រកាសព្រះបន្ទូលយ៉ាងក្បោះក្បាយ ឲ្យសាសន៍ដទៃទាំងអស់ស្តាប់"** ដូច្នេះ ពេលលោកឪពុកនឹកឃើញពីការអធិដ្ឋាន ពីធម៌មេត្តាករុណា នោះលោកឪពុកត្រូវតែចេញទៅប្រកាសដំណឹងល្អតាមរបៀបសន្តៈប៉ូល។ ត្រូវធ្វើខ្លួនជាព្យាការីម្នាក់ ប្រកាសដំណឹងល្អក្នុងរបៀបថ្មី ដោយចិត្តតស៊ូ និងចិត្តស្រឡាញ់ដោយសារយើងមានព្រះយេស៊ូជាកម្លាំងរបស់យើង។ កន្លងមកលោកឪពុកបានទៅកន្លែងថ្មីនៅកប់ស្រូវ ដែលមានកម្មការិនីចូលរួមទទួលការអប់រំ និងមានកូនក្មេងរាប់សិបនាក់ ចូលរួមក្នុងកម្មវិធីកាយឫទ្ធិដែរ ដូច្នេះត្រូវបន្តថែរក្សាពួកគាត់។ ក្នុងព្រះវិហារនេះ កាលពីថ្ងៃសៅរ៍មុន យើងបានចាត់ក្រុមគ្រីស្តទូត ១២ក្រុម ទៅប្រកាសដំណឹងល្អនៅគ្រប់ទីកន្លែងក្នុងភូមិភាគភ្នំពេញ គឺជានិស្សិតសាលាអប់រំជំនឿសន្តៈយ៉ូស្វីន។ ពួកគាត់បានសន្យានៅចំពោះព្រះភ័ក្ត្រព្រះយេស៊ូថា ពេញមួយឆ្នាំនេះនឹងខិតខំប្រកាសដំណឹងល្អតាមកន្លែងផ្សេងៗ។ មានមួយក្រុមដែលនឹងមានសកម្មភាពនៅតំបន់នេះ ជាមួយអ្នកក្រីក្រ អ្នកជំងឺ អ្នកពិការ និងក្មេងអានាថា ដើម្បីកសាងព្រះសហគមន៍យើងនៅទីនេះក្នុងការប្រកាសដំណឹងល្អ។

សេចក្តីស្រឡាញ់របស់ព្រះយេស៊ូជាភ្លើងដែលឆេះរហូត មិនអាចរលត់បានទ ភ្លើងនោះណែនាំឲ្យយើងមានកម្លាំងទៅប្រកាសដំណឹងល្អ។ ដោយសារព្រះបន្ទូលរបស់ព្រះយេស៊ូណែនាំឲ្យយើងភ្ញាក់ស្មារតីជានិច្ច ចេញទៅប្រកាសដំណឹងល្អ។ ដោយសារព្រះបន្ទូលរបស់ព្រះយេស៊ូ ណែនាំឲ្យយើងដឹងថា ពិតមែនព្រះគ្រីស្តគង់នៅជាមួយយើង ពិតមែនព្រះវិញ្ញាណបំភ្លឺជីវិតយើង ពិតមែនព្រះបិតាមានព្រះហឫទ័យមេត្តាករុណា។ ដោយសារព្រះបន្ទូលរបស់ព្រះយេស៊ូណែនាំឲ្យយើងចង់ទៅជាគ្រីស្តទូតតាមរបៀបសន្តៈសិលា និងសន្តៈប៉ូលដែរ។

យើងខ្ញុំសូមអរព្រះគុណព្រះជាម្ចាស់ សូមព្រះអង្គប្រទានពរដល់លោកឪពុក បងប្រុស បងស្រី បងប្អូនគ្រីស្ទបរិស័ទទាំងអស់ ឲ្យមានកម្លាំង ឲ្យមានសេចក្តីស្រឡាញ់ ឲ្យចេញទៅណែនាំមនុស្សយ៉ាងច្រើនមានសេចក្តីសុខសាន្ត និងមានសេចក្តីសង្ឃឹម។

**"មានតែព្រះអម្ចាស់ប៉ុណ្ណោះ ដែលគាំទ្រ និងប្រទានឲ្យខ្ញុំមានកម្លាំង ដើម្បីឲ្យខ្ញុំអាចប្រកាសព្រះបន្ទូលយ៉ាងក្បោះក្បាយ ឲ្យសាសន៍ដទៃទាំងអស់ស្តាប់"**

# ចុះអ្នករាល់គ្នាវិញថាខ្ញុំជានរណា?

And you, who do you say I am?

អត្ថបទទី១៖ សក ១២, ១០-១១ក និង ១៣, ១
អត្ថបទទី២៖ កាឡ ៣, ២៦.២៩
ដំណឹងល្អ៖ លក ៩, ១៨-២៤

ថ្ងៃនេះយើងអង្វរសូមព្រះជាម្ចាស់ ប្រទានព្រះវិញ្ញាណដ៏វិសុទ្ធដល់បងប្អូនយើង៩៩នាក់។ យើងបានស្តាប់អត្ថបទគម្ពីរ ដែលមានសំណួរមួយពិសេសណាស់។ ពេលព្រះយេស៊ូសួរទៅលោកសិលានិងក្រុមគ្រីស្តទូតទាំងអស់ថា **"ចុះអ្នករាល់គ្នាវិញ តើអ្នករាល់គ្នាថាខ្ញុំជានរណាដែរ?"** នោះលោកសិលាបានទូលឆ្លើយថា **"លោកជាព្រះគ្រីស្តដែលព្រះជាម្ចាស់ចាត់ឲ្យមក"**។ ខ្ញុំជឿថាថ្ងៃនេះព្រះយេស៊ូក៏មានសំណួរថា **"តើខ្ញុំជានរណា?"** មកបងប្អូនទាំង៩៩នាក់ដែរ។ នៅថ្ងៃដែលយើងទទួលអគ្គសញ្ញាជ្រមុជទឹក យើងបានស្តាប់សន្តៈប៉ូលមានប្រសាសន៍ថា **"បងប្អូនទាំងអស់គ្នា បានរួមគ្នាជាអង្គតែមួយក្នុងព្រះគ្រីស្តយេស៊ូ"** គឺយើងជាគ្រីស្តបរិស័ទទៅជាតែមួយជាមួយព្រះយេស៊ូ យើងជាបរិស័ទរបស់ព្រះគ្រីស្តយើងជាសាវ័ក ជាមិត្ត ជាគ្រីស្តទូតរបស់ព្រះយេស៊ូ ដូច្នេះព្រះយេស៊ូជាជីវិតយើង។ ទោះបីសព្វថ្ងៃ យើងមើលព្រះយេស៊ូមិនឃើញ ប៉ុន្តែនៅថ្ងៃដែលយើងទទួលអគ្គសញ្ញាជ្រមុជទឹកដោយនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធនោះយើងបានបំពាក់អាវសដែលមានន័យថា យើងជាធ្លុងតែមួយជាមួយព្រះយេស៊ូ។ ដូច្នេះអស់មួយជីវិតយើងត្រូវខិតខំស្គាល់ព្រះយេស៊ូឲ្យច្បាស់ទៅៗ។

ថ្ងៃនេះ កូនៗដែលទទួលអគ្គសញ្ញាលាថ្វាស គឺទទួលព្រះវិញ្ញាណដ៏វិសុទ្ធដែលនឹងយាងមកដើម្បីបំភ្លឺកូនម្នាក់ៗឲ្យស្គាល់ព្រះយេស៊ូច្បាស់ទៅៗ។ ព្រះយេស៊ូមានព្រះបន្ទូលថានៅពេលយើងឡើងស្ថានបរមសុខ យើងនឹងមើលឃើញព្រះភក្ត្ររបស់ព្រះជាម្ចាស់ និងរបស់ព្រះយេស៊ូ

អភិបូជាអគ្គសញ្ញាលាបថ្វាសនៅចំប៉ា
ថ្ងៃទី ១៩ មិថុនា ២០១៦

ដោយជាក់ស្តែង។ រាល់ថ្ងៃលោកបូជាចារ្យ ណែនាំឲ្យយើងជាគ្រីស្តបរិស័ទមើលឃើញព្រះយេស៊ូផ្ទាល់ក្នុងអភិបូជា នៅពេលលោកមានប្រសាសន៍ថា **"នេះជារូបកាយរបស់ខ្ញុំ នេះជាលោហិតរបស់ខ្ញុំដែលត្រូវបូជាសម្រាប់អ្នករាល់គ្នា"**។ តាមរយៈអគ្គសញ្ញាតែងតាំងលោកបូជាចារ្យជាអ្នកណែនាំឲ្យយើងជាគ្រីស្តបរិស័ទមើលឃើញព្រះយេស៊ូផ្ទាល់។ ហេតុនេះហើយគ្រប់ពេលដែលយើងចូលរួមថ្វាយអភិបូជា យើងតែងមានអំណរសប្បាយដោយដឹងថា នំប៉័ងនិងស្រាលែងជានំប៉័ង និងស្រាទៀតហើយ តែជាព្រះយេស៊ូផ្ទាល់។

មានវីដេអូមួយបង្ហាញយើងអំពីព្រះវិញ្ញាណ នៅពេលលោកអភិបាលម្នាក់កំពុងថ្វាយភិបូជាជាមួយក្រុមលោកអភិបាលឯទៀតៗ។ ពេលលោកអភិបាលនោះលើកដៃឡើងទូលអង្វរព្រះវិញ្ញាណដ៏វិសុទ្ធយាងមកប្រសិទ្ធពរលើនំនិងស្រាឲ្យទៅជាព្រះកាយ និងព្រះលោហិតព្រះគ្រីស្តនោះស្រាប់តែនំបានហោះឡើងជិតប្រាំនាទី ជាសញ្ញាថាព្រះយេស៊ូគង់នៅក្នុងនំ។ ដូច្នេះរាល់ពេលយើងទទួលព្រះកាយ គឺយើងទទួលព្រះយេស៊ូផ្ទាល់ដែលគង់នៅក្នុងព្រះកាយយាងចូលក្នុងរូបកាយយើង ហើយយើងទៅជាធ្លុងតែមួយជាមួយព្រះអង្គ។ ហេតុនេះយើងយល់ថាសព្វថ្ងៃយើងក៏អាចប្រកាសអំពីព្រះយេស៊ូដូចលោកសិលាបានដែរថា **"ពិតមែនលោកជាព្រះគ្រីស្តដែលព្រះជាម្ចាស់ចាត់ឲ្យមក"** មានន័យថា ព្រះអង្គជាអ្នកដែលបានទទួល ការអភិសេកទៅជាព្រះសង្គ្រោះ យាងមកដើម្បីឲ្យយើងទាំងអស់គ្នាទទួលជីវិតថ្មី។ យើងដូចសន្តះសិលាដូចក្រុមគ្រីស្តទូតពីដើម យើងមើលឃើញព្រះយេស៊ូដោយផ្ទាល់ភ្នែក នៅពេលយើងចូលរួមថ្វាយអភិបូជា។

ថ្ងៃនេះយើងនឹងទទួលព្រះវិញ្ញាណដ៏វិសុទ្ធ ដែលផ្តល់កម្លាំង ផ្តល់ជំនឿថែមទៀត ដើម្បីឲ្យយើងម្នាក់ៗយល់ថា ខ្ញុំជាគ្រីស្តបរិស័ទ ខ្ញុំជាសាវ័ករបស់ព្រះយេស៊ូគ្រីស្តពិតមែន។ ចាប់តាំងពីថ្ងៃដែលខ្ញុំបានទទួលអគ្គសញ្ញាជ្រមុជទឹក រហូតដល់ថ្ងៃចុងក្រោយរបស់ខ្ញុំលើផែនដីនេះ ខ្ញុំគឺជាតំណាងរបស់ព្រះគ្រីស្ត ដើម្បីណែនាំឲ្យបងប្អូនឯទៀតៗអាចមើលឃើញព្រះយេស៊ូ។ តួនាទីរបស់ខ្ញុំ គឺណែនាំឲ្យអ្នកដទៃស្គាល់ព្រះយេស៊ូគ្រីស្ត។ ថ្ងៃនេះព្រះវិញ្ញាណដ៏វិសុទ្ធយាង

មកណែនាំឲ្យខ្ញុំលែងភ័យខ្លាច ឲ្យខ្ញុំផ្តល់សក្ខីភាព ឲ្យខ្ញុំមានអំណរសប្បាយ ឲ្យខ្ញុំមានសេចក្តីសុខសាន្ត ឲ្យខ្ញុំមានសេចក្តីសង្ឃឹម ដោយសារខ្ញុំមានព្រះយេស៊ូគ្រីស្តគង់នៅជាមួយ។

ក្នុងការរស់នៅយើងជួបបញ្ហាជាច្រើន ប៉ុន្តែយើងត្រូវតែមានសេចក្តីសង្ឃឹមជានិច្ចដោយសារយើងជាសាវ័ករបស់ព្រះយេស៊ូដែលណែនាំឲ្យយើងលែងភ័យខ្លាច។ ពេលយើងទទួលព្រះវិញ្ញាណដ៏វិសុទ្ធ យើងលែងភ័យខ្លាចហើយយើងចេញទៅប្រកាសដំណឹងល្អទាំងមានចិត្តភ្លឺស្វាង ព្រោះព្រះវិញ្ញាណដ៏វិសុទ្ធណែនាំឲ្យយើងទៅជាមនុស្សក្លាហាន។ ដូចព្រះយេស៊ូបានមានព្រះបន្ទូល **"បើអ្នកចង់មកតាមក្រោយខ្ញុំអ្នកត្រូវលះបង់ចោលខ្លួនឯង និងត្រូវលើឈើឆ្កាង"**។ សព្វថ្ងៃយើងអាចតស៊ូបានយើងអាចចែកអំណរសប្បាយដែលយើងបានទទួលពីព្រះយេស៊ូដល់អ្នកដទៃបានដោយសារយើងមានព្រះយេស៊ូដែលលីឈើឆ្កាងគង់នៅជាមួយយើងហើយណែនាំយើង។ ព្រះវិញ្ញាណដ៏វិសុទ្ធជាភ្លើងនៃសេចក្តីក្លាហានព្រះវិញ្ញាណដ៏វិសុទ្ធជាភ្លើងនៃសេចក្តីសុខសាន្តព្រះវិញ្ញាណដ៏វិសុទ្ធជាភ្លើងនៃធម៌មេត្តាករុណាព្រះវិញ្ញាណដ៏វិសុទ្ធជាភ្លើងនៃការលើកលែងទោសព្រះអង្គណែនាំឲ្យក្នុងឆ្នាំព្រះមហាករុណាទិគុណនេះឲ្យយើងអាចកសាងព្រះសហគមន៍របស់យើងបានដោយសារយើងជាកូនគ្រីស្តទូតដែលព្រះយេស៊ូបានជ្រើសរើស ដែលព្រះវិញ្ញាណដ៏វិសុទ្ធបានបំភ្លឺដែលព្រះបិតាបានគង់នៅជាមួយដើម្បីឲ្យយើងកសាងសង្គម និងពិភពលោករបស់យើងនៅក្នុងអំណរសប្បាយ និងសេចក្តីក្លាហាន។

ថ្ងៃនេះយើងខ្ញុំសូមអរព្រះគុណព្រះជាម្ចាស់ ដែលបង្រួបបង្រួមយើងខ្ញុំនៅក្នុងអង្គព្រះគ្រីស្តជាព្រះសហគមន៍។ បន្តិចទៀតបងប្អូនដែលទទួលអគ្គសញ្ញាលាបថ្ងាស នឹងទទួលព្រះវិញ្ញាណដ៏វិសុទ្ធ និងបន្ទាប់មកទៀត យើងនឹងទទួលព្រះកាយព្រះគ្រីស្តដោយអំណរសប្បាយដោយដឹងថាយើងបានទទួលព្រះយេស៊ូផ្ទាល់។ រាល់ពេលយើងទទួលព្រះកាយព្រះគ្រីស្ត យើងក៏អាចនិយាយបានដែរថាយើងបានទទួលជីវិតថ្មី។ យើងមានអំណរសប្បាយ យើងនឹងបន្តអធិដ្ឋានអង្វរព្រះវិញ្ញាណដ៏វិសុទ្ធឲ្យយាងមកបំភ្លឺចិត្តគំនិតរបស់យើង និងប្រោសឲ្យព្រះសហគមន៍របស់យើងទៅជាព្រះសហគមន៍ដ៏មានជីវិត និងចែករំលែកជីវិតនោះដល់បងប្អូនឯទៀតៗដែរ។

# យើងត្រូវតែប្រញាប់ប្រញាល់គ្រប់ពេលវេលាដើម្បីប្រកាសដំណឹងល្អ

Proclaiming the Gospel: a permanent emergency

អត្ថបទទី១៖ ពង្សា ១៩, ៩ខ-១១.១៤-២១.
៣១-៣៥ក.៣៦
ដំណឹងល្អ៖ មថ ៧, ៦.១២-១៤

ពេលនេះ ខ្ញុំសូមចែករំលែកចំណុចខ្លះៗនៅក្នុងព្រះគម្ពីរថ្ងៃនេះ សម្រាប់ជីវិតយើងជាបូជាចារ្យ។ នៅគ្រាដែលព្រះនាងម៉ារីប្រញាប់ប្រញាល់ធ្វើដំណើរទៅកាន់ភូមិមួយនៅតំបន់ភ្នំពេលនោះព្រះនាងមានអំណរសប្បាយពន់ពេកណាស់ ដ្បិតព្រះនាងចង់ទៅជួបយាយអេលីសាបែតដើម្បីចែកអំណរសប្បាយនោះ ប៉ុន្តែព្រះនាងត្រូវការធ្វើដំណើរច្រើនថ្ងៃ ទាំងមានផ្ទៃពោះផង។ នេះគឺជាឥរិយាបថដែលយើងជាបូជាចារ្យត្រូវតែមាន។ យើងជាបូជាចារ្យត្រូវតែប្រញាប់ប្រញាល់គ្រប់ពេលវេលាដើម្បីប្រកាសដំណឹងល្អ ប្រញាប់ប្រញាល់ដើម្បីជួបជាមួយបងប្អូន ប្រញាប់ប្រញាល់ដើម្បីអធិដ្ឋាន ប្រញាប់ប្រញាល់ដើម្បីថ្វាយអភិបូជា ប្រញាប់ប្រញាល់ដោយសារក្នុងចិត្តរបស់យើងពោរពេញដោយអំណរ ដែលព្រះជាម្ចាស់បានជ្រើសរើសយើង។ អំណរសប្បាយនេះជំរុញយើងឲ្យទៅមុខ ឲ្យរៀបចំអ្វីៗទាំងអស់តាមរបៀបព្រះនាងម៉ារី។ សម្រាប់យើងជាគ្រីស្តបរិស័ទសូមឲ្យយើងប្រញាប់ប្រញាល់ ទៅប្រកាសដំណឹងល្អដល់បងប្អូនដោយសារយើងមានអំណរសប្បាយ។

នៅពេលព្រះនាងម៉ារីជួបយាយអេលីសាបែតហើយ ព្រះនាងបានច្រៀងលើកតម្កើងព្រះជាម្ចាស់ **"ខ្ញុំមានចិត្តអំណរយ៉ាងខ្លាំង ព្រោះព្រះជាម្ចាស់ជាព្រះសង្គ្រោះរបស់ខ្ញុំ ព្រះអង្គទតមើលមកខ្ញុំដែលជាអ្នកបម្រើដ៏ទន់ទាបរបស់ព្រះអង្គ"**។ ព្រះនាងមានអំណរសប្បាយមកពីព្រះជាម្ចាស់បានជ្រើសរើស ហើយព្រះនាងបានឆ្លើយតបទៅព្រះជាម្ចាស់ថា **"ទូលបង្គំជាអ្នក**

---

អភិបូជាបួជនិយចរបូជាចារ្យ ភូមិភាគភ្នំពេញ
ថ្ងៃទី ២១ មិថុនា ២០១៦

**បម្រើរបស់ព្រះអង្គ សូមធ្វើតាមព្រះហឫទ័យរបស់ព្រះអង្គចុះ"**។ ជីវិតរបស់យើងក៏ដូចគ្នាដែរ ព្រះជាម្ចាស់បានជ្រើសរើសយើងទុកជាមនុស្សពិសេសនៅក្នុងព្រះហឫទ័យព្រះអង្គ ដោយសារព្រះអង្គសព្វព្រះហឫទ័យជ្រើសរើសប៉ុណ្ណោះ។ នេះជាអ្វីដែលយើងត្រូវការនឹកឃើញជានិច្ច។

សម័យព្រះយេស៊ូ មានមហាជនជាច្រើនបានដើរតាមព្រះអង្គ ប៉ុន្តែក្រុមគ្រីស្តទូត ១២នាក់ គឺជាមនុស្សពិសេសដែលព្រះយេស៊ូបានជ្រើសរើសឲ្យនៅជាមួយព្រះអង្គឲ្យធ្វើដំណើរជាមួយព្រះអង្គ។ ដូចគ្នាដែរយើងជាក្រុមដែលព្រះជាម្ចាស់បានជ្រើសរើសក្នុងចំណោមបងប្អូនយើងដើម្បីបម្រើព្រះអង្គ។ នេះជាអំណរសប្បាយរបស់យើង រាល់ពេលយើងអធិដ្ឋាន "បពិត្រព្រះនាងម៉ារី" ជាឱកាសមួយដើម្បីអរព្រះគុណព្រះជាម្ចាស់ ដែលបានជ្រើសរើសយើង។ នេះជាសេចក្តីស្រឡាញ់ដែលយើងបានទទួលពីព្រះជាម្ចាស់ និងជាសេចក្តីស្រឡាញ់ដែលដឹកនាំជីវិតរបស់យើង។

ខ្ញុំបានធ្វើជាសាក្សីក្នុងអគ្គសញ្ញាអាពាហ៍ពិពាហ៍ឲ្យគ្រួសារមួយ ប៉ុន្តែមួយខែក្រោយមកគេឈ្លោះគ្នា ចង់លែងលះគ្នា តែខ្ញុំបានប្រាប់ថា សូមនឹកឃើញសេចក្តីស្រឡាញ់ដើមដំបូងដែលគេទាំងពីរមាន ដែលគេទាំងពីរបានសម្រេចចិត្តជ្រើសរើសគ្នាជាប្តីប្រពន្ធដែលមិនមែនសម្រាប់មួយរយៈពេលខ្លី។ សម្រាប់ជីវិតយើងជាបូជាចារ្យក៏ដូចគ្នាយើងត្រូវការតស៊ូរហូតដល់ទីបំផុត។ រាល់ពេលយើងត្រូវនឹកឃើញដល់ព្រះជាម្ចាស់ដែលបានជ្រើសរើសយើងហើយ នេះជាអំណរសប្បាយរបស់យើង។ ពេលព្រះនាងម៉ារីធ្វើដំណើរទៅជួបយាយអេលីសាបែត ពេលនោះព្រះនាងអធិដ្ឋាន និងសូត្រទំនុកតម្កើងកោតសរសើរព្រះជាម្ចាស់ថា **"ទ្រង់មានព្រះហឫទ័យមេត្តាករុណា ដល់អស់អ្នកដែលកោតខ្លាចព្រះអង្គនៅគ្រប់ជំនាន់តរៀងទៅ"** ជាទំនុកតម្កើងដែលព្រះនាងស្រឡាញ់ និងដែលព្រះនាងជ្រើសរើសពីក្នុងចំណោមទំនុកតម្កើងទាំងអស់។ នេះមានន័យថាព្រះនាងម៉ារីទទួលស្គាល់ព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់។ នេះណែនាំឲ្យយើងនឹកឃើញពីជីវិតរបស់យើងជាបូជាចារ្យ គឺយើងជាឧបករណ៍តូចមួយរបស់ព្រះជាម្ចាស់ ដើម្បីនាំព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គឲ្យបានទៅដល់គ្រប់ទីកន្លែង ជា

ពិសេសដើម្បីជួយព្យាបាលមនុស្សដែលមានរបួសនៅក្នុងដួងចិត្តតាមរយៈអគ្គសញ្ញាលើកលែងទោស។ នៅក្នុងឆ្នាំព្រះមហាករុណាទិគុណនេះ យើងបានធ្វើអគ្គសញ្ញាលើកលែងទោសជាច្រើនដងហើយណែនាំឲ្យអ្នកដែលបានទទួល មានភាពធូរស្រាលក្នុងខ្លួនរបស់គេ។ កាលពីថ្ងៃសៅរ៍ ខ្ញុំបានប្រគល់មេកូនសោដល់លោកបូជាចារ្យសិលា សួនហង្សលី ដើម្បីបើកទ្វារនៃដួងចិត្ត ដើម្បីស្រាយអ្វីៗដែលធ្វើឲ្យយើងពិបាក ប្រែទៅជាធូរស្រាល និងទទួលបានជីវិតថ្មីវិញ។ នេះគឺជាតួនាទីរបស់យើងជាបូជាចារ្យត្រូវធ្វើមានអគ្គសញ្ញាព្រះកាយព្រះគ្រីស្ត អគ្គសញ្ញាលើកលែងទោស និងអគ្គសញ្ញាលាបថ្វាសជាដើម។

កាលពីថ្ងៃអាទិត្យមុន នៅព្រះសហគមន៍ចម្ប៉ា មាន៩៩នាក់បានទទួលអគ្គសញ្ញាលាបថ្វាស។ ពេលនោះខ្ញុំបានសួរគេថា តើធ្លាប់ឃើញព្រះយេស៊ូទេ? គេឆ្លើយថាគេឃើញព្រះយេស៊ូរាល់ថ្ងៃនៅពេលលោកបូជាចារ្យថ្វាយអភិបូជា ខណៈពេលលោកមានប្រសាសន៍ថា **"នេះជារូបកាយរបស់ខ្ញុំ..."**។ នេះជាជីវិតរបស់យើងជាបូជាចារ្យ គឺយើងណែនាំឲ្យបងប្អូនរបស់យើងបានទទួលជីវិត និងបានជាសះស្បើយខាងផ្លូវវិញ្ញាណពីព្រះយេស៊ូ។ **"ទ្រង់បានលើកតម្កើងមនុស្សទន់ទាប ទ្រង់បានប្រទានសម្បត្តិយ៉ាងបរិបូណ៌ដល់អស់អ្នកដែលស្រេកឃ្លាន"** ព្រះយេស៊ូព្យាបាលដួងចិត្តមនុស្ស ណែនាំឲ្យមនុស្សតូចតាចដែលអស់សង្ឃឹមឲ្យមានជីវិតថ្មី។

**"មនុស្សដែលមានអំណាចធ្លាក់ចុះ មនុស្សជាអ្នកមានទៅដោយដៃទទេ ប៉ុន្តែមនុស្សដែលគ្មានអ្វីសោះទទួលសុភមង្គល"** នេះជាការរស់នៅរបស់យើងដែលជាឧបករណ៍របស់ព្រះជាម្ចាស់ គឺយើងត្រូវយកចិត្តទុកដាក់នឹងសង្គម។ នៅប្រទេសកម្ពុជាយើងមានវាលស្រែដ៏ទូលំទូលាយដើម្បីប្រកាសដំណឹងល្អ មានបងប្អូនជាច្រើនដែលស្រេកឃ្លានយុត្តិធម៌ស្រេកឃ្លាន សេចក្តីសង្ឃឹមពិតៗ។ សូមឲ្យយើងទៅជាភ្លើងនៃសេចក្តីស្រឡាញ់សម្រាប់បងប្អូនទាំងអស់នៅក្នុងធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ ដើម្បីឲ្យមនុស្សជាច្រើនឈរឡើងមកទទួលជីវិតថ្មី។

ព្រះនាងម៉ារី បានស្នាក់នៅជាមួយយាយអេលីសាបែតអស់រយៈពេល៣ខែ។ ព្រះនាង

ម៉ារីប្រញ៉ាប់ប្រញ៉ាល់ដើម្បីទៅជួប តែមិនប្រញ៉ាប់ប្រញ៉ាល់ដើម្បីត្រឡប់មកវិញ។ ព្រះនាងប្រញ៉ាប់ប្រញ៉ាល់ដើម្បីបម្រើ ដើម្បីស្និទ្ធស្នាល ដើម្បីលើកទឹកចិត្តយាយអេលីសាបែត។ សូមឲ្យយើងជាបូជាចារ្យដូចព្រះនាងម៉ារីដែរ ដោយឲ្យយើងមានអំណរសប្បាយក្នុងការបង្កើតទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយបងប្អូន។ លោកឪពុកវីរៈជ័យបានប្រាប់ថា រាល់ថ្ងៃគាត់បានដើរតាមផ្ទះបងប្អូនគ្រីស្តបរិស័ទនៅភូមិចម្ប៉ា។ មានបងប្អូនខ្លះភ្លេចព្រះសហគមន៍យូរហើយ ប៉ុន្តែគេឃើញលោកទៅសួរសុខទុក្ខគេ ទៅអង្គុយលេងជាមួយគេ បង្កើតភាពស្និទ្ធស្នាល នាំឲ្យគេ គិតថាព្រះសហគមន៍មិនដែលលះបង់គេចោលទេ និងបន្ទាប់មកគេត្រឡប់មកព្រះសហគមន៍វិញដោយទទួលអគ្គសញ្ញាលើកលែងទោសដើម្បីមានជីវិតថ្មី។ ព្រះនាងម៉ារីបាននៅ៣ខែជា មួយយាយអេលីសាបែតនេះគឺជាជីវិតរបស់យើងដែលត្រូវតែជិតស្និទ្ធជាមួយបងប្អូន ដែលត្រូវតែបង្កើតទំនាក់ទំនងជាមួយគ្រីស្តបរិស័ទក្នុងនាមជាបូជាចារ្យ ជាឪពុក ជាម្តាយ ដែលថែរក្សាចៀមរបស់ខ្លួន និងក៏សូមឲ្យយើងបង្កើតទំនាក់ទំនងយ៉ាងជិតស្និទ្ធ នៅក្នុងចំណោមយើងជាបូជាចារ្យដែរ។ ប្រសិនបើយើងមានទឹកចិត្តជាឪពុកជាម្តាយពិតមែននោះ នឹងជួយឲ្យព្រះសហគមន៍យើងរីកចម្រើននៅក្នុងសេចក្តីស្រឡាញ់សម្រាប់បងប្អូនដែលជាគ្រីស្តបរិស័ទ និងក៏សម្រាប់បងប្អូនដែលមិនមែនជាគ្រីស្តបរិស័ទដែរ។

ថ្ងៃនេះយើងខ្ញុំសូមអរព្រះគុណព្រះជាម្ចាស់ ដែលប្រទានការអស្ចារ្យឲ្យយើងខ្ញុំធ្វើជាបូជាចារ្យ។ យើងខ្ញុំសូមអរព្រះគុណព្រះជាម្ចាស់សម្រាប់ជីវិតរបស់យើងខ្ញុំជាអ្នកបម្រើ។ សូមព្រះនាងម៉ារីជួយយើងខ្ញុំឲ្យរស់នៅតាមរបៀបព្រះយេស៊ូ និងតាមរបៀបព្រះនាងផ្ទាល់ផង គឺតាំងពីព្រះយេស៊ូចាប់ផ្ទៃ រហូតដល់ព្រះអង្គសោយទិវង្គតនៅលើឈើឆ្កាង ព្រះនាងនៅតែស្ថិតនៅជាមួយព្រះយេស៊ូជានិច្ច។ សូមឲ្យយើងខ្ញុំនៅជានិច្ចជាមួយព្រះយេស៊ូ រហូតដល់ដង្ហើមចុងក្រោយនៃជីវិតរបស់យើងខ្ញុំ ដូចលោកអភិបាលអេមីលដែលបានទទួលមរណភាពនៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៦ ក្រោយពេលលោកបានទទួលព្រះកាយព្រះគ្រីស្ត។ ពិតមែនលោកអភិបាលបានស្ថិតនៅក្បែរព្រះយេស៊ូ ដូចព្រះនាងម៉ារីស្ថិតនៅក្បែរព្រះយេស៊ូដែរ។

# ចូរប្រយ័ត្ននឹងពួកព្យាការីក្លែងក្លាយ

Beware of false prophets! Be Holy Apostles

---

អត្ថបទទី១៖ ពង្សរ ២២, ៨-១៣ និង ២៣. ១-៣
ដំណឹងល្អ៖ មថ ៧, ១៥-២០

ថ្ងៃនេះ យើងបិទឆ្នាំសិក្សានៅទេវវិទ្យាល័យ។ នៅពេលយើងស្តាប់ព្រះគម្ពីរ នោះបានជួយយើងច្រើនក្នុងការវាយតម្លៃនៃការសិក្សា។ យើងវាយតម្លៃការសិក្សាឆ្នាំ២០១៥-២០១៦នេះ ដោយចាប់អារម្មណ៍នឹងព្រះបន្ទូលរបស់ព្រះយេស៊ូថា **"ចូរប្រយ័ត្ននឹងពួកព្យាការីក្លែងក្លាយ"**។ ព្យាការីមានន័យថា អ្នកដែលថ្លែងព្រះបន្ទូលព្រះជាម្ចាស់។ ដូច្នេះ និស្សិតទេវវិទ្យាល័យអាចសួរសំណួរចំពោះខ្លួនឯងថា "តើខ្ញុំនឹងទៅជាព្យាការីរបៀបណា?" និងសួរទៀតថា **"តើជីវិតរបស់ខ្ញុំ និងអ្វីដែលខ្ញុំប្រកាសស្របគ្នាឬទេ?"**។

យើងជាបូជាចារ្យក៏ដូច្នោះដែរ យើងជាអ្នកដែលពូកែទេសនា ប៉ុន្តែយើងត្រូវទេសនាសម្រាប់ផ្ទាល់ខ្លួនជាមុនសិនហើយជាបន្ទាប់សម្រាប់បងប្អូនឲ្យគេប្រែចិត្ត។យើងត្រូវសួរសំណួរដល់ខ្លួនឯងថា **"តើជីវិតរបស់ខ្ញុំ និងអ្វីដែលខ្ញុំទេសនាស្របគ្នាឬទេ?"** នេះជាសំណួរទីមួយ និងសំណួរទីពីរ **"តើជីវិតខាងផ្លូវវិញ្ញាណរបស់ខ្ញុំយ៉ាងដូចម្តេច? តើខ្ញុំមានជំនឿលើព្រះយេស៊ូកម្រិតណា? តើព្រះបន្ទូលរបស់ព្រះយេស៊ូយាងចូលនៅក្នុងជីវិតរបស់ខ្ញុំកម្រិតណា?"**។

ឆ្នាំនេះជាឆ្នាំព្រះមហាករុណាទិគុណ ជាឱកាសមួយសម្រាប់យើងសួរខ្លួនឯងថា **"តើព្រះហប្ញទ័យប្រណីសន្តោសដែលខ្ញុំបានទទួលពីព្រះបិតា យាងចូលនៅក្នុងជីវិតរបស់ខ្ញុំកម្រិត**

---

អភិបូជាបិទឆ្នាំសិក្សានៅទេវវិទ្យាល័យ
ថ្ងៃទី ២២ មិថុនា ២០១៦

**ណា?"** សំនួរនេះមានតែយើងខ្លួនឯងដែលអាចឆ្លើយបាន ទាំងដឹងថាក្នុងឆ្នាំនេះខ្លួនមានចំណុចខ្លាំង និងចំណុចខ្សោយអ្វីខ្លះ ទាំងអាចពិនិត្យមើលអំពីផលផ្លែដែលយើងបានធ្វើពេញមួយឆ្នាំតាមសំណួរថា **"តើបងប្អូនឯទៀតៗគេអាចបេះផលនេះយកទៅញុំាបានឬទេ?"**។ ផលផ្លែដែលចេញពីដើមឈើដ៏រឹងមាំមួយ មិនប្រាកដថាអ្នកដទៃ អាចយកទៅហូបយ៉ាងឆ្ងាញ់បាននោះទេព្រោះវាអាស្រ័យសារជាតិចិញ្ចឹមរបស់ដើមឈើនោះ ផ្តល់ឲ្យទៅដើមនិងផ្លែ។ នៅក្នុងជីវិតរបស់យើងក៏ដូចគ្នាដែរតើធ្វើដូចម្តេចដើម្បីឲ្យផលផ្លែរបស់យើងមានរសជាតិឆ្ងាញ់ពិសាដល់អ្នកដទៃ? នោះគឺអាស្រ័យនឹងជីវិតខាងក្នុងដែលយើងមានទំនាក់ទំនងជាមួយព្រះជាម្ចាស់។

សម្រាប់ពិភពលោកទាំងមូល និងសម្រាប់ព្រះសហគមន៍ទាំងមូលដែរ គឺត្រូវការព្យាការីដែលរស់នៅស្របតាមព្រះបន្ទូលជាច្រើនរូប មកថ្លែងព្រះបន្ទូលដំណឹងល្អ ដើម្បីឲ្យមនុស្សជាតិភ្ញាក់ស្មារតី។ យើងមើលសន្តៈយ៉ូហានប៉ូលទី២ លោកជាព្យាការីមួយរូបយ៉ាងអស្ចារ្យ ដែលបានធ្វើឲ្យពិភពលោកទាំងមូលកោតសរសើរ។ តាមរយៈរបៀបដែលលោកបានធ្វើ របៀបដែលលោកបានអធិដ្ឋាន របៀបដែលលោកបានរិះគិត នោះបណ្តាលឲ្យពួកកុម្មុយនីស្តនៅ សហភាពសូវៀតមានការផ្លាស់ប្តូរ និងបានណែនាំមនុស្សដែលរស់នៅគ្មានសេរីភាពក្រោមអំណាចកុម្មុយនីស្តងើបឈរឡើង ដោយសារគេបានស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់តាមរយៈសន្តៈយ៉ូហានប៉ូលទី២ថ្លែង។ ពិភពលោកសព្វថ្ងៃត្រូវការព្យាការីបែបនេះ។ ប្រសិនបើគ្មានព្យាការីដាស់តឿនឲ្យពិភពលោកយើងភ្ញាក់ស្មារតីទេ នោះពិភពលោកយើង មិនអាចទៅមុខបានទេ។ យើងដឹងថាព្យាការីមានតួនាទីមួយដ៏លំបាក គឺត្រូវប្រកាសដំណឹងល្អ និងត្រូវរស់នៅជាគំរូគេតាមដំណឹងល្អដែលខ្លួនបានប្រកាស។ ដំណឹងល្អរបស់ព្រះយេស៊ូ មិនណែនាំឲ្យមនុស្សមានអំណរសប្បាយតាមរបៀបលោកិយទេ ប៉ុន្តែជួនកាលបណ្តាលឲ្យឈឺចិត្ត ឲ្យខឹង ឲ្យអន់ចិត្ត ដ្បិតថាដំណឹងល្អតម្រូវឲ្យស្រឡាញ់ខ្មាំងសត្រូវរបស់ខ្លួន ក្នុងពេលដែលក្នុងជម្រៅចិត្តមនុស្សចេះតែស្អប់គ្នា និងមានមនុស្សមួយចំនួនមិនចង់ឲ្យមាននរណាម្នាក់និយាយអំពីយុត្តិធម៌ អំពីសេរីភាពដោយសារគេចង់បន្តជិះជាន់ បន្តប្រើអំណាចរបស់ខ្លួនលើអ្នកដទៃ...។ ដូច្នេះព្យាការីណែនាំ

ឲ្យយើងភ្ញាក់ស្មារតីផង និងឲ្យយើងឈឺចិត្តដែរ ប៉ុន្តែដោយនាមព្រះយេស៊ូយើងអាចធ្វើបាន។

បើយើងពិនិត្យពីការរស់នៅរបស់ព្រះយេស៊ូ នោះអស់មួយជីវិត ព្រះអង្គតែងតែស្ដីបន្ទោសជានិច្ចដល់ការរស់នៅមិនសមរម្យរបស់គណៈផារីស៊ី របស់អ្នកមានទ្រព្យ របស់អ្នកវង្វេងផ្លូវរបស់អ្នកដែលមិនគោរពសិទ្ធិសេរីភាពអ្នកដទៃ...។ នៅវិសាលព្រះវិហារក្រុងយេរូសាឡឹម ព្រះអង្គបានបណ្តេញអ្នករកស៊ីលក់ដូរក្នុងព្រះវិហារ បណ្តាលឲ្យគេអន់ចិត្តរហូតដល់គេសម្លាប់ព្រះអង្គ។ ជាទូទៅយើងមើលឃើញថា ការរស់នៅរបស់ព្រះយេស៊ូគឺបរាជ័យ ប៉ុន្តែដោយសារឫទ្ធានុភាពរបស់ព្រះជាម្ចាស់ និងរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ការបរាជ័យនេះ បានណែនាំឲ្យមនុស្សតាំងពីប៉ុន្មានជំនាន់រហូតដល់ពេលនេះទទួលជីវិតពិតប្រាកដវិញ។ សម្រាប់និស្សិតទេវ វិទ្យាល័យត្រូវដឹងថាព្រះសហគមន៍ត្រូវការព្យាការី និងគ្រីស្តទូតដ៏វិសុទ្ធ គឺជាអ្នកបម្រើ ជាអ្នកមានចិត្តអត់ធ្មត់ជាអ្នកចេះបង្ហាញអំណរសប្បាយដែលខ្លួនបានទទួលពីព្រះជាម្ចាស់ និងពីព្រះនាងម៉ារី ជាអ្នកចេះស្រឡាញ់ ជាអ្នកមានចិត្តមេត្តាករុណា ជាអ្នកមានភ្លើងនៃព្រះវិញ្ញាណដ៏វិសុទ្ធដែលជាធ្លុងតែមួយជាមួយព្រះយេស៊ូ ជាអ្នកមានចិត្តស្រឡាញ់ព្រះនាងម៉ារី ជាអ្នកសម្លឹងមើលសន្តៈ សន្តីបុគ្គលទាំងអស់ជាអ្នកធ្វើសញ្ញាសម្គាល់ណែនាំឲ្យយើងទៅជាអង្គតែមួយនៅក្នុងព្រះសហគមន៍ទូទាំងពិភពលោក។

នៅក្នុងប្រទេសកម្ពុជាកើតមានបញ្ហាសង្គមជាច្រើន សូមឲ្យយើងជាគ្រីស្តបរិស័ទយល់ថា អ្វីដែលព្រះយេស៊ូណែនាំឲ្យយើងធ្វើ ឲ្យយើងប្រព្រឹត្ត គឺដើម្បីឲ្យសង្គមរបស់យើងរកឃើញសេចក្តីសុខសាន្ត។ សម្រាប់និស្សិតទេវវិទ្យាល័យ គឺជាមនុស្សដែលព្រះជាម្ចាស់បានជ្រើសរើសឲ្យទៅជាគ្រីស្តទូតដ៏វិសុទ្ធរបស់ព្រះអង្គ ដែលពោរពេញដោយភ្លើងនៃព្រះវិញ្ញាណដ៏វិសុទ្ធនិងចាត់ឲ្យទៅបង្កើតព្រះសហគមន៍មួយយ៉ាងស្អាត និងសង្គមមួយយ៉ាងអស្ចារ្យ។ ក្នុងខែកក្កដា និងខែសីហានេះ គឺជាឱកាសដែលនិស្សិតទេវវិទ្យាល័យទាំងអស់បន្តរៀបចំខ្លួន បន្តរិះគិត និងបន្តធ្វើជាព្យាការីតូចមួយ ដូចយ៉ូហានបាទីស្តដែរ។

យើងទាំងអស់គ្នាទទួលឋានៈបី គឺជាព្យាការី ជាបូជាចារ្យ ជាព្រះមហាក្សត្រ

នៅពេលយើងទទួលអគ្គសញ្ញាជ្រមុជទឹក។ ជាបូជាចារ្យមានន័យថាយើងថ្វាយជីវិតរបស់យើងទៅព្រះជាម្ចាស់រាល់ថ្ងៃ។ ជាព្យាការី គឺយើងថ្លែងព្រះបន្ទូលពិតប្រាកដដល់មនុស្សទាំងអស់រាល់ពេល។ ជាព្រះមហាក្សត្រ គឺយើងបម្រើបងប្អូនតាមរបៀបព្រះយេស៊ូគ្រប់កាលៈទេសៈ។ ក្នុងឱកាសវិស្សមកាលនេះនិស្សិតទេវវិទ្យាល័យគឺ វីសំណាង និងសុខឌឿន ទៅព្រះសហគមន៍តាកែវ នៅជាមួយលោកឪពុកហ្វៃណាន់ដូ។ និស្សិតខាន់ និងសុខសំណាងទៅព្រះសហគមន៍កំពង់សោម នៅជាមួយលោកឪពុកអ៊ុនសុន។ និស្សិតកែវសំណាងទៅព្រះសហគមន៍កំពត នៅជាមួយលោកឪពុកចនលូកា។ និស្សិតប៊ុនលី និងសុផាតទៅព្រះសហគមន៍កំពង់ចាម ម្នាក់នៅជាមួយលោកឪពុកហ្សេរ៉ាល់ និងម្នាក់ទៀតនៅជាមួយលោកឪពុកបូរី ដើម្បីបន្តការរិះគិត និងរៀបចំខ្លួនជាទៅអ្នកបម្រើ។

យើងខ្ញុំជាគ្រីស្តទូតដ៏វិសុទ្ធដែលជាប់ជាមួយព្រះយេស៊ូ ដែលស្រឡាញ់ព្រះនាងម៉ារី ដែលរៀបចំចិត្តគំនិតខាងក្នុងដើម្បីបម្រើព្រះសហគមន៍។ យើងខ្ញុំជាព្យាការីយ៉ាងពិសេសសម្រាប់ព្រះសហគមន៍។ សូមព្រះជាម្ចាស់ប្រទានពរឲ្យយើងខ្ញុំរស់នៅក្នុងសេចក្ដីសុខសាន្តជានិច្ច។

# ខ្ញុំជាយ៉ូហានបាទីស្ត

I am John the Baptist!

---

អត្ថបទទី១៖ អស៤៩, ១-៦
អត្ថបទទី១៖ កក ១៣, ២២-២៩
ដំណឹងល្អ៖ លក ១, ៥៧-៦៦.៨០

ថ្ងៃនេះ ជាថ្ងៃរំឭកដល់សន្តៈយ៉ូហានបាទីស្ត។ ក្នុងអត្ថបទគម្ពីរ ឪពុកបានដាក់ឈ្មោះឲ្យកូនថា **"យ៉ូហាន"** ដែលមានន័យថា **"កូនជាទីស្រឡាញ់របស់ព្រះជាម្ចាស់"**។ មូលហេតុដែលឪពុកមិនយកឈ្មោះតាមត្រកូលដាក់ឲ្យកូនរបស់ខ្លួនតាមប្រពៃណីអ្នកស្រុក ដោយសារនៅពេលលោកសាការីជាឪពុកទទួលដំណឹងថាភរិយារបស់លោកជាស្ត្រីអារមានផ្ទៃពោះ នោះលោកមិនជឿទេបន្ទាប់មកព្រះជាម្ចាស់ធ្វើឲ្យលោកទៅជាមនុស្សគអស់រយៈពេល៩ខែ។ ក្នុងរយៈនិយាយមិនបាននេះ លោកមានពេលច្រើនសម្រាប់គិតហើយលោកយល់ឃើញថាកូនដែលចាប់ផ្ទៃនោះគឺពិតជាការអស្ចារ្យដែលមកពីព្រះជាម្ចាស់។ លោកសម្រេចចិត្តដាក់ឈ្មោះឲ្យកូនរបស់លោកថា **"យ៉ូហាន"** ដែលមានន័យថា **"កូនជាទីស្រឡាញ់របស់ព្រះជាម្ចាស់"** ភ្លាមនោះ ស្រាប់តែលោកអាចនិយាយបានវិញ ដោយសារលោកបានយល់អំពីព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់។ ក្រោយមកព្រះសហគមន៍បានបន្ថែម **"បាទីស្ត"** ទៅជា **"យ៉ូហានបាទីស្ត"** ដោយសារលោកយ៉ូហានបានរស់នៅក្នុងវាលរហោស្ថាន ហើយលោកបានធ្វើពិធីជ្រមុជទឹកជូនអ្នកស្រុកដែលប្រែចិត្តគំនិតទៅរកព្រះជាម្ចាស់វិញ។ ដូច្នេះ **"យ៉ូហានបាទីស្ត"** មានន័យថា **"កូនជាទីស្រឡាញ់របស់ព្រះជាម្ចាស់ដែលធ្វើពិធីជ្រមុជទឹក"**។

---

អភិបូជាបុណ្យរំឭកសន្តៈ យ៉ូហានបាទីស្ត នៅផ្សារតូច
ថ្ងៃទី ២៤ មិថុនា ២០១៦

សំណួរទី១ "តើថ្ងៃក្រោយ កូននេះនឹងទៅជាយ៉ាងណា?" យើងជាឪពុកម្តាយដែលនៅទីនេះ តែងតែសួរសំណួរនេះអំពីកូនរបស់ខ្លួនថា **"តើនៅថ្ងៃអនាគត កូនរបស់ខ្ញុំនឹងទៅជាយ៉ាងណា?"**។ បងប្រុស ហ្វ្រេដេរិច រាល់ឆ្នាំបានទទួលក្មេងថ្មីៗមកស្នាក់នៅដើម្បីរៀនសូត្រ ក៏តែងមានសំណួរនេះដែរ **"តើនៅថ្ងៃអនាគត ពេលចេញពីមណ្ឌលយើងទៅពួកគេនឹងទៅជាយ៉ាងណា?"**។ យើងទាំងអស់គ្នាក៏ត្រូវតែសួរចំពោះខ្លួនឯងដែរថា "តើថ្ងៃអនាគត ខ្លួនខ្ញុំផ្ទាល់នឹងទៅជាមនុស្សយ៉ាងណា?"។

សំណួរទី២ "ដ្បិតព្រះបារមីរបស់ព្រះអម្ចាស់តាមជួយថែរក្សាកូននេះ"។ សម្រាប់យើងដែលជាអ្នកដើរតាមព្រះយេស៊ូ ដែលបានទទួលអគ្គសញ្ញាជ្រមុជទឹក យើងជឿថា ព្រះបារមីរបស់ព្រះអម្ចាស់តាមជួយថែរក្សាយើង។ សក្ខីភាពដែលយើងបានឃើញ គឺកុមារយ៉ូហានមានវ័យចម្រើនឡើងជាលំដាប់ ទាំងខាងរូបកាយ និងទាំងខាងវិញ្ញាណ នេះណែនាំឲ្យយើងទាំងអស់ជាឪពុកម្តាយមានចិត្តសង្ឃឹមជានិច្ចថា យើងនឹងអាចអប់រំណែនាំកុមារ យុវជន យុវនារីជាកូនៗរបស់យើងឲ្យគេចម្រើនឡើងទាំងខាងរូបកាយ និងទាំងខាងវិញ្ញាណបាន ដោយសារមានព្រះជាម្ចាស់គង់នៅជាមួយយើង និងជាពិសេសព្រះជាម្ចាស់ដែលថែរក្សាយើង ហើយយើងក៏អាចនិយាយដូចព្យាការីអេសាយក្នុងអត្ថបទទីមួយដែរថា "ហេតុនេះហើយ បានជាព្រះអម្ចាស់ចាត់ទុកខ្ញុំថាជាមនុស្សថ្លៃថ្នូរ ហើយព្រះនៃខ្ញុំពិតជាកម្លាំងរបស់ខ្ញុំមែន"។

នេះជាដំណឹងល្អមួយដ៏អស្ចារ្យ នៅពេលយើងដឹងថាព្រះជាម្ចាស់គង់នៅជាមួយយើង នោះណែនាំឲ្យយើងមានសេចក្តីថ្លៃថ្នូរ ដោយសារព្រះជាម្ចាស់បានបង្កើតយើង និងព្រះជាម្ចាស់បានស្រឡាញ់យើង។ ដំណឹងល្អដែលយើងត្រូវនឹកឃើញជារៀងរាល់ថ្ងៃគឺ **"ខ្ញុំជាមនុស្សថ្លៃថ្នូរ ដោយសារព្រះជាម្ចាស់ស្រឡាញ់ខ្ញុំ"** និង **"ខ្ញុំជាមនុស្សបាប ជាមនុស្សទន់ខ្សោយ ប៉ុន្តែព្រះជាម្ចាស់ស្រឡាញ់ខ្ញុំ"** នេះជាតម្លៃថ្លៃថ្នូរដែលខ្ញុំទទួលនៅក្នុងជីវិតថ្មីរបស់ខ្ញុំ។ **"ព្រះនៃខ្ញុំពិតជាកម្លាំងរបស់ខ្ញុំ"** ដោយសារព្រះជាអម្ចាស់គង់នៅជាមួយខ្ញុំ ព្រះអង្គថែរក្សាខ្ញុំ និងព្រះអង្គណែនាំឲ្យខ្ញុំមានកម្លាំង នោះខ្ញុំនឹងរីកចម្រើនឡើង ខ្ញុំនឹងមានឱកាសដើម្បីរៀបចំអនាគតដ៏អស្ចារ្យរបស់ខ្ញុំ។

ក្នុងអត្ថបទទី១ ព្រះជាម្ចាស់បានចាត់ព្រះបន្ទូលឲ្យយាងមកសង្គ្រោះយើងទាំងអស់គ្នា នេះហើយជាគម្រោងការដ៏អស្ចារ្យរបស់ព្រះអង្គសម្រាប់យើង។ តាមរយៈសំណួរដែលយើងបានដាក់ថា "តើថ្ងៃក្រោយកូននេះនឹងទៅជាយ៉ាងណា?"នោះសូមឲ្យយើងមានគម្រោងការ សូមឲ្យយើងមានយោបល់ សូមឲ្យយើងមានទស្សនវិស័យ ដើម្បីយើងទៅជាយ៉ូហានបាទីស្ត តូចមួយសម្រាប់ពិភពលោកនេះ ទៅជាពន្លឺតូចមួយសម្រាប់អ្នកដទៃ ទៅជាអ្នកនាំការសង្គ្រោះ នៅគ្រប់ទីកន្លែងក្នុងសង្គមរបស់យើងបច្ចុប្បន្ន។ សូមឲ្យយុវជន យុវនារី នៅវ័យក្មេងមានសុបិន្ត ច្រើនឡើងមានទស្សនវិស័យច្រើនឡើងសម្រាប់អនាគតផ្ទាល់ខ្លួនដោយគិតថា ខ្ញុំជាយ៉ូហាន បាទីស្ត សម្រាប់ពិភពលោកនេះ គឺខ្ញុំជាអ្នករៀបចំផ្លូវដើម្បីទទួលព្រះយេស៊ូ។ មានសុបិន្តថា ខ្ញុំជាយ៉ូហានបាទីស្ត មានន័យថាខ្ញុំកសាងពិភពលោកឲ្យមានយុត្តិធម៌ពិតៗ សេចក្តីសុខពិតៗ សេចក្តីស្រឡាញ់ពិតៗ ដោយដឹងថា ព្រះជាម្ចាស់បានជ្រើសរើសខ្ញុំ ដើម្បីឲ្យខ្ញុំរីកចម្រើនបន្តិចម្តងៗ រហូតទៅដល់កំពូលនៃជីវិតរបស់ខ្ញុំ គឺខ្ញុំជាយ៉ូហានបាទីស្តតូចមួយ ដើម្បីណែនាំឲ្យមនុស្សទាំងអស់ឃើញហើយស្គាល់ និងទទួលការសង្គ្រោះដែរ។

# តើខ្ញុំទៅជាមនុស្សយ៉ាងណា?

Who I will become?

---

អត្ថបទទី១៖ ហស ១០, ១-៣. ៧-៨. ១២
ដំណឹងល្អ៖ មថ ១០, ១-៧

ថ្ងៃនេះជាឱកាសមួយឲ្យយើងអរព្រះគុណព្រះជាម្ចាស់ដោយយើងស្មូត្រថា **"ចូរច្រៀងបទថ្វាយតម្កើងកុំណាយ រៀងរាល់វេលា រៀបរាប់អំពី សព្វអស់កិច្ចការ សុទ្ធតែអស្ចារ្យ ដែលទ្រង់ប្រព្រឹត្ត"**។ យើងរួមគ្នាអរគុណព្រះជាម្ចាស់ ក្នុងឱកាសយើងបិទឆ្នាំសិក្សាឆ្នាំ២០១៥-២០១៦។ យើងអរព្រះគុណព្រះជាម្ចាស់ដែលបានណែនាំឲ្យយើងទទួលជោគជ័យនៅក្នុងការសិក្សា។ យើងអរព្រះគុណព្រះជាម្ចាស់ ចំពោះលោកបូជាចារ្យដែលបានជួយណែនាំជាប្រចាំចំពោះ ប្រធាន និងជំនួយការមណ្ឌល ចំពោះមិត្តភក្រ្តយើងដែលរស់នៅក្នុងមណ្ឌល និងអរព្រះគុណព្រះជាម្ចាស់សម្រាប់បងប្អូនទាំងអស់ដែលបានជួយលើកទឹកចិត្តយើង។

ពេលនេះយើងនឹកឃើញដល់អ្វីៗទាំងអស់ ដែលយើងបានទទួលមួយឆ្នាំកន្លងទៅ ទាំងចំណេះដឹង និងទាំងទំនាក់ទំនង។ ជាពេលវេលាដែលយើងវាយតម្លៃអំពីខ្លួន ទោះបីនិស្សិតទាំងអស់មិនមែនជាគ្រីស្តបរិស័ទក៏ដោយ ប៉ុន្តែត្រូវទទួលយកទស្សនៈរបស់ព្រះសហគមន៍កាតូលិកទៅផ្ទៀងផ្ទាត់ការរស់នៅរបស់ខ្លួន។ តើមួយឆ្នាំកន្លងមកនេះ ចំណេះដឹងរបស់ខ្ញុំរីកចម្រើនកម្រឹតណា? តើទំនាក់ទំនងរបស់ខ្ញុំជាមួយអ្នកដទៃ ជាមួយព្រះជាម្ចាស់រីកចម្រើនកម្រឹតណា? តើកិច្ចការបម្រើអ្នកដទៃរបស់ខ្ញុំ រីកចម្រើនកម្រឹតណា? តើខ្ញុំបានបម្រើអ្នកដទៃដែរឬយ៉ាងណា? ទស្សនៈរបស់ព្រះសហគមន៍កាតូលិក គឺបង្ហាញធម៌មេត្តាករុណា ចិត្តស្រឡាញ់ និងចិត្តបម្រើ ។

---

អភិបូជាបិទឆ្នាំសិក្សានៅមណ្ឌលនិស្សិតកាតូលិកកម្ពុជា
ថ្ងៃទី០៦ កក្កដា ២០១៦

អត្ថបទដែលយើងស្តាប់ថ្ងៃនេះ គឺ **"ប្រជាជនអ៊ីស្រាអែលប្រៀបដូចជាចម្ការទំពាំងបាយជូរដែលដុះទ្រប់ទ្រុល និងដែលបង្កើតផលផ្លែយ៉ាងច្រើន។ ប៉ុន្តែផលផ្លែចម្រើនឡើងយ៉ាងណា ចំនួនអាសនៈសម្រាប់ព្រះក្លែងក្លាយក៏កើនឡើងច្រើនយ៉ាងនោះដែរ"**។ ពីដើមប្រជាជនអ៊ីស្រាអែលរីកចម្រើនប៉ុន្តែពេលគេរីកចម្រើនខាងសេដ្ឋកិច្ច និងខាងសង្គមនោះណែនាំឲ្យគេភ្លេចខ្លួនទៅគោរពព្រះក្លែងក្លាយ និងបណ្តោយខ្លួនឲ្យគេដើរឆ្ងាយពីព្រះជាម្ចាស់។ ដូច្នេះកន្លងមកនិស្សិតទាំងអស់ក៏មានការរីកចម្រើនយ៉ាងច្រើនដែរ គឺរីកចម្រើនខាងចំណេះដឹងខាងទំនាក់ទំនងជាដើម ដូច្នេះសូមឲ្យយើងសួរខ្លួនឯងថា **"តើកន្លងមក ខ្ញុំបានបង្កើតផលផ្លែអ្វីខ្លះ?" "តើក្នុងចិត្តរបស់ខ្ញុំមានការរីកចម្រើនដែរឬទេនៅក្នុងការស្រឡាញ់ នៅក្នុងការបម្រើ?" "តើក្នុងទំនាក់ទំនងដែលខ្ញុំបានបង្កើតជាមួយអ្នកដទៃ ជាទំនាក់ទំនងដើម្បីស្រឡាញ់គេ លើកទឹកចិត្តគេ ផ្តល់កម្លាំង និងសេចក្តីសង្ឃឹមដល់គេ ឬយ៉ាងណា?"**។

ក្នុងព្រះគម្ពីរដំណឹងល្អថ្ងៃនេះ ព្រះយេស៊ូមិនផ្ញើជូនតែក្រុមគ្រីស្តទូតពីដើមប៉ុណ្ណោះទេ ប៉ុន្តែសម្រាប់យើងសព្វថ្ងៃដែរ **"ពេលធ្វើដំណើរ ចូរប្រកាសថាព្រះរាជ្យនៃស្ថានបរមសុខមកជិតបង្កើយហើយ"**។ នេះជាឱកាសមួយ ឲ្យយើងគិតឡើងវិញពីបេសកកម្មដែលយើងបានទទួល តើបេសកកម្មនេះរីកចម្រើនដល់កម្រិតណាហើយ?។ ជាពិសេសក្នុងឆ្នាំព្រះមហាករុណាទិគុណនេះ គឺជាឱកាសមួយដើម្បីយើងប្រែចិត្តគំនិតផ្ទាល់ខ្លួន ប្រែចិត្តគំនិតរបស់មណ្ឌលទាំងមូល ប្រែចិត្តគំនិតរបស់ព្រះសហគមន៍ទាំងមូល មកធ្វើតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ ដើម្បីបង្កើតព្រះរាជ្យរបស់ព្រះអង្គ។ បង្កើតព្រះរាជ្យរបស់ព្រះជាម្ចាស់ គឺមានន័យថាយើងបណ្តេញខ្មោចឲ្យវាចេញទៅ និងណែនាំឲ្យអ្នកជំងឺបានជាសះស្បើយ និងឲ្យបងប្អូនបានរីកចម្រើនឡើង។ យើងមិនស្វែងរកការរីកចម្រើនសម្រាប់តែផ្ទាល់ខ្លួនទេ ប៉ុន្តែសម្រាប់បងប្អូនឯទៀតៗដែរឲ្យគេចម្រើនឡើងតាមផ្លូវកាយ ផ្លូវចិត្ត ផ្លូវវិញ្ញាណ ផ្លូវប្រាជ្ញា មានឱកាសទៅជាមនុស្សដ៏ពេញលក្ខណៈដែលជាព្រះអំណោយមកពីព្រះជាម្ចាស់។

ក្នុងអភិបូជានេះ យើងប្រមូលគ្រប់កិច្ចការទាំងអស់ដែលយើងបានធ្វើ មកអរព្រះគុណ

ព្រះជាម្ចាស់ និងក្នុងវិស្សមកាលខាងមុខនេះ មុននឹងចូលឆ្នាំសិក្សាថ្មី មុននឹងនិស្សិតខ្លះត្រូវចូលបម្រើការងារតាមកន្លែងផ្សេងៗ នោះសូមឲ្យយើងរិះគិតពីសំណួរខាងលើនេះ **"តើឥឡូវនេះខ្ញុំរីកចម្រើនដល់កម្រិតណា?"** និងចំណុចចុងក្រោយឲ្យប្អូនៗនិស្សិតទាំងអស់ ពិចារណាពីអនាគតរបស់ខ្លួនដោយគិតឲ្យបានវែងឆ្ងាយថា **"តើខ្ញុំទៅនឹងទៅជាមនុស្សយ៉ាងណា?"**។ សំណួរនេះក៏ជាសំណួររបស់បណ្ដាជនដែលបានសួរខ្លួនគេម្នាក់ៗ នៅពេលគេបានឃើញទារកយ៉ូហានបាទីស្ដកើតមកនោះដែរ។

យើងម្នាក់ៗត្រូវការមានកម្លាំងនៅក្នុងចិត្ត ដើម្បីរៀបចំអនាគត ដើម្បីរៀបចំជីវិតរបស់ខ្លួនឲ្យទៅជាគ្រីស្ដបរិស័ទនៅក្នុងសង្គម ដែលជួយឲ្យសង្គមរបស់យើងចម្រើនឡើង។ យើងត្រូវគិតឲ្យបានទូលំទូលាយ ពីរបៀបដែលយើងរៀបចំអនាគតពីរបៀបដែលយើងចេះគិតអំពីអ្នកដទៃជាពិសេសឲ្យយើងយល់ថាការងាររបស់យើងមានតម្លៃណាស់។ ហេតុដូច្នេះហើយយើងត្រូវតែយកចិត្តទុកចំពោះការងាររបស់យើង ដែលមានដូចជាការស្រាវជ្រាវឯកសារជូនសាស្ត្រាចារ្យការថែរក្សាការពារមណ្ឌល ការងារបម្រើព្រះសហគមន៍ ការងារបម្រើសង្គម... ដែលទាំងអស់ នេះគឺជាមោទនភាពរបស់យើង និងជាអំណរសប្បាយផ្ទាល់របស់យើង។ សូមចាប់ផ្ដើមគិតពីពេលនេះតទៅជ្បិតព្រះជាម្ចាស់ដ៏ពេញលក្ខណៈ ព្រះអង្គសព្វព្រះហឫទ័យឲ្យយើងទៅជាមនុស្សដ៏ពេញលក្ខណៈដូចព្រះអង្គដែរ។

ក្នុងការរស់នៅ សូមឲ្យយើងប្រឹងប្រែងធ្វើការងារឲ្យអស់ពីសមត្ថភាពដែលយើងមានដើម្បីឲ្យយើងរីកចម្រើនឡើង ដូចក្នុងអត្ថបទមានចែងអំពីអ្នកដែលបានទទួលប្រាក់ គឺមានម្នាក់បានទទួល២ ម្នាក់ទៀតបានទទួល៥ ក្រោយមកគេសងជា៤ និងម្នាក់ទៀតគេសងជា១០ ដោយសារគេបានធ្វើអស់ពីសមត្ថភាពរបស់គេ។ រីឯអ្នកដែលបានទទួល១សង១នោះ ត្រូវបានបណ្ដេញចេញជ្បិតអីគាត់ខ្ជិលមិនបានធ្វើអ្វីសោះ។ ព្រះជាម្ចាស់បង្កើតមនុស្សយើង ដើម្បីឲ្យមនុស្សយើងសម្ដែងភាពអស្ចារ្យរបស់ព្រះអង្គ។ ហេតុដូច្នេះហើយ ដោយសារព្រះជាម្ចាស់បង្កើតខ្ញុំ ដោយសារព្រះជាម្ចាស់ស្រឡាញ់ខ្ញុំ ដោយសារព្រះជាម្ចាស់ជ្រើសរើសខ្ញុំឲ្យធ្វើជានិស្សិតក្នុង

មណ្ឌលនិស្សិតកាតូលិក ដូច្នេះនៅថ្ងៃអនាគត ខ្ញុំត្រូវតែជាមនុស្សដ៏អស្ចារ្យដែលមកពីព្រះជាម្ចាស់ដើម្បីជួយសង្គម ឲ្យទៅជាសង្គមរីចម្រើន។ យើងអាចបង្កើតសង្គមថ្មីបានដោយយើងទទួលព្រះជាម្ចាស់ទុកជាទីពឹងរបស់យើង ព្រោះព្រះអង្គបានជ្រើសរើសយើងរួចទៅហើយ។

រួមជាមួយគ្នា យើងខ្ញុំសូមអរព្រះគុណព្រះជាម្ចាស់សម្រាប់ពេញមួយឆ្នាំនេះ ដោយច្រៀងថា **"ចូរច្រៀងបទថ្វាយ តម្កើងកុំណាយ រៀងរាល់វេលា រៀបរាប់អំពី សព្វអស់កិច្ចការ សុទ្ធតែអស្ចារ្យដែលទ្រង់ប្រព្រឹត្ត"**។

**"ប្រជាជនអ៊ីស្រាអែលប្រៀបដូចជាចម្ការទំពាំងបាយជូរដែលដុះទ្រប់ទ្រុល និងដែលបង្កើតផលផ្លែយ៉ាងច្រើន។ ប៉ុន្តែផលផ្លែចម្រើនឡើងយ៉ាងណាចំនួនអាសនៈសម្រាប់ព្រះក្លែងក្លាយក៏កើនឡើងច្រើនយ៉ាងនោះដែរ"**

# ព្រះសហគមន៍ត្រូវការអ្នកបម្រើចេញពីទឹកដីយើង

The Church needs servants here on earth

អត្ថបទទី១៖ ហស ១១, ១-៤.៨គ-៩
ដំណឹងល្អ៖ មថ ១០, ៧-១៥

ថ្ងៃនេះយើងរួមគ្នាអធិដ្ឋានពេញមួយយប់លើកទី៥១។ យើងអរព្រះគុណព្រះជាម្ចាស់ ដែលយើងបានស្ដាប់ព្រះបន្ទូលព្រះយេស៊ូ ចាត់ក្រុមសាវ័កទាំង១២នាក់ឲ្យទៅប្រកាសដំណឹងល្អ។ ពីដើម ព្រះយេស៊ូបានជ្រើសរើសសាវ័កឲ្យគេទៅប្រកាសដំណឹងល្អ ឲ្យគេព្យាបាលអ្នកជំងឺឲ្យជាសះស្បើយ ឲ្យគេប្រោសមនុស្សស្លាប់ឲ្យរស់ឡើងវិញ និងឲ្យគេបណ្ដេញខ្មោចចេញពីមនុស្សដែរ។ ព្រះយេស៊ូបានរៀបចំបេសកកម្មនេះ ដែលជាដំបូងព្រះអង្គបានចាត់គ្រីស្តទូត១២រូប បន្ទាប់មកព្រះយេស៊ូចាត់សាវ័ក៧២រូប។ មុនយាងឡើងស្ថានបរមសុខ ព្រះយេស៊ូបានផ្ដាំគ្រីស្តទូតទាំង១២រូបថា "ចូរចេញទៅប្រកាសដំណឹងល្អ នៅក្នុងពិភពលោកទាំងមូល រហូតដល់តំបន់ដាច់ស្រយាលនៃផែនដី ដោយព្យាបាលអ្នកជំងឺ ដោយប្រកាសអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់ដែលមកជិតដល់ហើយ"។

ក្រុមគ្រីស្តទូតដែលបានទទួលព្រះវិញ្ញាណដ៏វិសុទ្ធនៅថ្ងៃបុណ្យទី៥០ បានចាប់ផ្ដើមរៀបចំ ព្រះសហគមន៍ ដោយបានជ្រើសរើសឧបដ្ឋាកដើម្បីជួយបម្រើ ក្នុងនោះក្រុមគ្រីស្តទូតមានមុខងារអប់រំជំនឿ និងណែនាំការអធិដ្ឋាន និងមានក្រុមឧបដ្ឋាកដែលទទួលខុសត្រូវខាងកិច្ចការមេត្តាករុណាដោយយកចិត្តទុកដាក់នឹងអ្នកក្រីក្រ បង្ហាញពីរបៀបដែលព្រះជាម្ចាស់ស្រឡាញ់មនុស្សលោក។ ក្រោយមកគេជ្រើសរើសចាស់ទុំនៅក្នុងព្រះសហគមន៍ឲ្យបំពេញ

ក្នុងអភិបូជា អធិដ្ឋានពេញមួយយប់នៅចំប៉ា
ថ្ងៃទី០៧ កក្កដា ២០១៦

កិច្ចការតាមក្រុមនីមួយៗ ដោយទូលអង្វរព្រះវិញ្ញាណដ៏វិសុទ្ធបំភ្លឺ។ ព្រះសហគមន៍ដើមដំបូងបានចាត់ចែងឲ្យមាន លោកអភិបាលដើម្បីមើលថែព្រះសហគមន៍ក្នុងតំបន់មួយយ៉ាងធំ និងរៀបចំឲ្យមានបូជាចារ្យបម្រើតាមព្រះសហគមន៍នីមួយៗដោយអប់រំជំនឿ ណែនាំការអធិដ្ឋានអភិបូជា អគ្គសញ្ញានានា និងរៀបចំក្រុមឧបដ្ឋាកដើម្បីបម្រើតុអ្នកក្រីក្រ ស្ត្រីមេម៉ាយ កុមារកំព្រាឲ្យពួកគេមានភាពកក់ក្តៅ សេចក្តីសង្ឃឹម ក្នុងសេចក្តីស្រឡាញ់ ពីបងប្អូន។

សព្វថ្ងៃព្រះសហគមន៍រស់នៅបាន ដោយសារមានលោកអភិបាលជាអ្នកសម្រុះ-សម្រួលថែរក្សាការឯកភាពរវាងគ្នានិងគ្នា នឹងជាមួយសម្តេចប៉ាប។ យើងមានបូជាចារ្យតាមព្រះសហគមន៍នីមួយៗ ដើម្បីជួយបម្រើ ជួយលើកទឹកចិត្ត ជួយអធិដ្ឋានដោយនាមព្រះយេស៊ូគ្រីស្តផ្ទាល់។ យើងមានគ្រីស្តបរិស័ទបំពេញកិច្ចការក្នុងគណៈកម្មការផ្សេងៗដើម្បីបម្រើព្រះសហគមន៍។ យើងមានបងប្រុសបងស្រីដែលបម្រើព្រះសហគមន៍ក្នុងរបៀបពិសេស ដោយផ្ញើជីវិតទាំងស្រុងទៅព្រះជាម្ចាស់អស់កល្បជានិច្ច។ យើងអាចនិយាយថាប្រសិនបើឥតមានបូជាចារ្យ នោះព្រះសហគមន៍របស់យើងមិនអាចរស់បានទេ ឥតមានបូជាចារ្យ ឥតមានអគ្គ-សញ្ញា ដូចជាអគ្គសញ្ញាព្រះកាយព្រះគ្រីស្ត អគ្គសញ្ញាលើកលែងទោសជាដើម។ ហេតុនេះហើយ នៅតាមព្រះសហគមន៍នីមួយៗ យើងត្រូវតែយកចិត្តទុកដាក់ ដើម្បីឲ្យមានយុវជន យុវនារីខ្លះៗស្តាប់ឮព្រះបន្ទូលត្រាស់ហៅ ដើម្បីថ្វាយខ្លួនទៅជាអ្នកបម្រើក្នុងកិច្ចការដ៏ពិសេសនេះ។

ព្រះបន្ទូលក្នុងអត្ថបទទីមួយ យើងឃើញពីរបៀបដែលព្រះជាម្ចាស់ស្រឡាញ់យើងគឺ **"យើងណែនាំគេដោយចិត្តអាណិតអាសូរ និងដោយចិត្តស្រឡាញ់ យើងថ្នាក់ថ្នមគេដូចឪពុកលើកកូនមកបីថើបហើយ យើងយកចិត្តទុកដាក់បញ្ចុកចំណីគេ តែពួកគេមិនព្រមវិលមករកយើងវិញទេ"**។ដូច្នេះព្រះជាម្ចាស់ថែរក្សាយើងដោយសារព្រះអង្គស្រឡាញ់យើង ដោយព្រះអង្គគង់នៅជាមួយយើង ដូចក្នុងអត្ថបទដែលបានចែងថា **"យើងជាព្រះដ៏វិសុទ្ធដែលស្ថិតនៅជាមួយអ្នកយើងមិនមែនមកដើម្បីបំផ្លាញឡើយ"**។ យើងដឹងថាព្រះជាម្ចាស់ធ្វើដំណើរជាមួយយើងនិងជាពិសេសក្នុងព្រះសហគមន៍នីមួយៗ ព្រះជាម្ចាស់កំពុងទតមើលទៅយុវជនយុវនារីដែល

អាចបម្រើព្រះសហគមន៍អស់មួយជីវិត ដោយបំពេញមុខងារជាបូជាចារ្យ ជាបងស្រីបងប្រុស។ ពេលអធិដ្ឋានជាពេលវេលាមួយឲ្យយើងនឹកគិតពីការត្រាស់ហៅនេះ។

ប្រសិនបើយើងមិនយកចិត្តទុកដាក់ក្នុងការអធិដ្ឋានសម្រាប់ការត្រាស់ហៅទេ តើអ្នកណានឹងអាចទទួលការត្រាស់ហៅបាន? សព្វថ្ងៃមានយុវជនប៉ុន្មានអ្នកដែលកំពុងគិតអំពីជីវិតជាអ្នកបួស ជាបូជាចារ្យ ដែលទាំងអស់នោះកើតមកពីការអធិដ្ឋានរបស់យើង។ ព្រះសហគមន៍របស់យើងយកចិត្តទុកដាក់ថែរក្សាយុវជនយុវនារី ថែរក្សាកូនក្មេងរបស់យើងដើម្បី ឲ្យគេម្នាក់ៗមានឱកាសគិតពីអនាគតរបស់គេ ដើម្បីគេអាចនិយាយទៅកាន់ឪពុកម្ដាយ លោកតាលោកយាយអំពីការបូជាជីវិតដើម្បីបម្រើព្រះសហគមន៍អស់មួយជីវិតរបស់គេ។ ព្រះសហគមន៍របស់យើងរីកចម្រើនឡើងនៅពេលណាមានការត្រាស់ហៅ ដែលចេញពីព្រះសហគមន៍របស់ខ្លួនយើងផ្ទាល់។ យើងមិនអាចទីពឹងលើបូជាចារ្យ បងប្រុស បងស្រីមកពីបរទេសបានទេ។ ព្រះសហគមន៍របស់យើង ត្រូវការមានយុវជន យុវនារីបន្តវេន ទាំងយល់ដឹងថា **"ព្រះសហគមន៍នេះជារបស់យើងខ្ញុំជាព្រះសហគមន៍ដែលយើងខ្ញុំត្រូវតែបម្រើ"**។ មណ្ឌលសកម្មភាព ទាំង៩របស់ព្រះសហគមន៍ភូមិភាគភ្នំពេញយើង កំពុងរង់ចាំបូជាចារ្យ បងប្រុស បងស្រី ដែលចេញពីទឹកដីភូមិកំណើតរបស់យើងដោយផ្ទាល់។

ដូច្នេះឪពុកម្ដាយ លោកតាលោកយាយ ត្រូវការគិតពិចារណា ត្រូវការអធិដ្ឋានថែមទៀតដើម្បីសូមព្រះជាម្ចាស់អាណិតអាសូរយើងជានិច្ច ស្រឡាញ់យើងជានិច្ច ថែរក្សាយើងជានិច្ច ដោយសូមឲ្យមានយុវជន យុវនារីខ្លះស្ម័គ្របម្រើព្រះសហគមន៍តាមព្រះហឫទ័យព្រះយេស៊ូ ដែលចាត់គេទៅប្រកាសដំណឹងល្អ ឲ្យមនុស្សទាំងអស់ទទួលជីវិតថ្មី ដោយមានព្រះបន្ទូលថា **"ចូរប្រកាសពីព្រះរាជ្យនៃស្ថានបរមសុខមកជិតបង្កើយហើយ"**។ យើងទាំងអស់គ្នាជាគ្រីស្តបរិស័ទបានទទួលបេសកកម្មនេះ ប៉ុន្តែត្រូវមានមនុស្សមួយចំនួនទទួលបេសកកម្មក្នុងរបៀបពិសេស ដោយទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យ ដោយទទួលព្រះពររស់នៅជាក្រុមបងប្រុសបងស្រី ជាសញ្ញាយ៉ាងអស្ចារ្យរបស់ព្រះសហគមន៍ទាំងមូល និងដើម្បីបម្រើបងប្អូនដោយនាម

ព្រះជាម្ចាស់។ យើងអរព្រះគុណព្រះជាម្ចាស់ យើងដឹងថាព្រះអង្គស្រឡាញ់យើង ព្រះអង្គថែរក្សាយើង ព្រះអង្គយកចិត្តទុកដាក់ជាមួយយើង និងព្រះអង្គអាណិតអាសូរយើងជានិច្ច។

យប់នេះយើងអធិដ្ឋាន ដោយសម្លឹងមើលព្រះកាយព្រះគ្រីស្ត ដោយដឹងថា យើងត្រូវការទីពឹងលើព្រះយេស៊ូដែលស្រឡាញ់យើង ដែលថែរក្សាយើង ដែលអាណិតអាសូរយើង។ ប៉ុន្តែយើងក៏ត្រូវភ្ញាក់ស្មារតីថា ព្រះជាម្ចាស់មិនមែនត្រាស់ហៅគេទេ តែព្រះអង្គត្រាស់ហៅខ្ញុំដែលជាយុវជន យុវនារីឲ្យបំពេញមុខងារពិសេសដើម្បីបម្រើព្រះសហគមន៍។ ព្រះអង្គត្រាស់ហៅខ្ញុំជាឪពុកម្ដាយ ជាតាជាយាយឲ្យយើងម្នាក់ៗយកចិត្តទុកដាក់អធិដ្ឋានឲ្យកូនចៅ លើកទឹកចិត្តកូនចៅ និងថែរក្សាអប់រំពួកគេដែលមានបំណងចង់បម្រើព្រះសហគមន៍ ដោយធ្វើជាលោកបូជាចារ្យ បងប្រុសបងស្រី។ល។

ចូរប្រកាសថា **"ព្រះរាជ្យរបស់ព្រះជាម្ចាស់មកជិតបង្កើតហើយ"** នេះជាព្រះបញ្ជារបស់ព្រះយេស៊ូដែលចាត់ឲ្យយើងទៅ ឲ្យយើងទទួលខុសត្រូវ ដោយដឹងថាព្រះជាម្ចាស់មានព្រះហឫទ័យអាណិតអាសូរយើង ស្រឡាញ់ថ្នាក់ថ្នមយើងជានិច្ច។ នេះជាកម្លាំងរបស់យើង ដើម្បីក្លាយជាសាវ័កដ៏ជាទីស្រឡាញ់របស់ព្រះគ្រីស្ត។

# ព្រះយេស៊ូជ្រើសរើសយើងឲ្យធ្វើជាមិត្តសម្លាញ់របស់ព្រះអង្គ

Christ has chosen us to be his friends

អត្ថបទទី១៖ អស ៦, ១-៨
ដំណឹងល្អ៖ មថ ១០, ២៤-៣៣

អម្បាញ់មិញនៅពេលយើងស្តាប់ព្រះបន្ទូលរបស់ព្រះយេស៊ូ នោះយើងទាំងអស់គ្នាបានងើបឈរឡើងទាំងអំណរសប្បាយ។ ឥឡូវសូមឲ្យយើងអង្គុយចុះទាំងអស់គ្នាវិញដើម្បីយើងស្តាប់ធម្មទេសនា។ ថ្ងៃនេះយើងកំពុងធ្វើបូជនិយេស៍ចរយើងបានស្តាប់ឮព្រះបន្ទូលមួយយ៉ាងពិសេស គឺព្រះយេស៊ូបានជ្រើសរើសក្រុមគ្រីស្តទូតធ្វើជាមិត្តសម្លាញ់ដ៏ជិតស្និទ្ធបំផុតរបស់ព្រះអង្គ។ យើងឮមានឈ្មោះ លោកសិលា លោកយ៉ាកុប លោកយ៉ូហាន យើងក៏អាចគិតដែរថាមានឈ្មោះយើងម្នាក់ក្នុងចំណោមសាវ័កទាំងអស់របស់ព្រះអង្គ។

តាមពិតព្រះយេស៊ូ ក៏បានជ្រើសរើសយើងឲ្យទៅជាមិត្តសម្លាញ់របស់ព្រះអង្គដែរ។ ជាពិសេសនៅក្នុងចំណោមបងប្អូនដែលកំពុងអង្គុយនៅទីនេះ អត់មាននរណាម្នាក់ដែលមានឪពុកម្តាយជាគ្រីស្តបរិស័ទតាំងពីដើមមកទេ ប៉ុន្តែពេលនេះ ហេតុអ្វីបានជាបងប្អូនសុខចិត្តមកទីនេះ និងធ្វើអ្វីផ្សេងពីឪពុកម្តាយ ពីដូនពីតារបស់ខ្លួន គឺពិតប្រាកដណាស់ជាព្រះយេស៊ូដែលបានជ្រើសរើសបងប្អូន ដើម្បីធ្វើជាមិត្តសម្លាញ់របស់ព្រះអង្គ។ នៅវិទ្យាស្ថានសន្តៈប៉ូល នៅចម្ការទៀង នៅទីរួមខេត្តតាកែវ ព្រះយេស៊ូបានជ្រើសរើសបងប្អូនដើម្បីធ្វើមិត្តសម្លាញ់របស់ព្រះអង្គ។ ព្រះអង្គក៏បានជ្រើសរើសលោកបូជាចារ្យ និងនិស្សិតទេវវិទ្យាល័យ ដើម្បីធ្វើជាមិត្តសម្លាញ់របស់ព្រះអង្គដែរ។ ដូច្នេះយើងទាំងអស់គ្នាមិនមែនជាមនុស្សធម្មតាទេ ក្នុងចំណោម

ក្នុងអភិបូជាបូជនិយេសចរជាមួយមណ្ឌលសកម្មភាពតាកែវ
ថ្ងៃទី០៩ កក្កដា ២០១៦

ប្រជាជនយើង១៥លាននាក់ ព្រះយេស៊ូបានជ្រើសរើសយើងដើម្បីធ្វើមិត្តសម្លាញ់របស់ព្រះអង្គ។

ថ្ងៃនេះព្រះយេស៊ូមានព្រះបន្ទូលមកយើងថា **"សូមអញ្ជើញមកតាមខ្ញុំ"** នេះជាព្រះបន្ទូលដែលបងប្អូនធ្លាប់បានឮតាំងពីមុនរួចមកហើយ។ ក្នុងចំណោមបងប្អូននៅទីនេះ មានបងប្អូនខ្លះបានទៅជាគ្រីស្តបរិស័ទហើយ មានខ្លះទៀតបានចូលព្រះសហគមន៍ហើយ និងមានខ្លះទៀតកំពុងស្វែងយល់ព្រះបន្ទូល ដូច្នេះយើងម្នាក់ៗបានឆ្លើយរួចហើយ នឹងព្រះយេស៊ូដែលបានមានព្រះបន្ទូលមកយើងថា **"សូមអញ្ជើញមកតាមខ្ញុំ"**។ ពីដើម ពេលព្រះយេស៊ូមានព្រះបន្ទូលត្រាស់ហៅគេ ឲ្យទៅជាអ្នកនេសាទមនុស្ស ភ្លាមនោះអ្នកនេសាទពីរនាក់បងប្អូនបានទុកសំណាញ់ចោលភ្លាម ហើយដើរតាមព្រះយេស៊ូទៅ គឺទៅប្រកាសដំណឹងថា **"ព្រះរាជ្យរបស់ព្រះជាម្ចាស់យាងមកជិតបង្កើយហើយ ចូរប្រែចិត្តគំនិត ហើយជឿលើដំណឹងល្អចុះ"**។ សព្វថ្ងៃ យើងដើរតាមព្រះយេស៊ូ ក៏ដើម្បីប្រកាសសេចក្តីដូចគ្នានេះដែរ។

ព្រះយេស៊ូជ្រើសរើសយើង ទៅជាមិត្តសម្លាញ់របស់ព្រះអង្គ និងបំប្រែយើងឲ្យទៅជាមនុស្សថ្មី។ សាវ័ករបស់ព្រះយេស៊ូពីមុន គេជាអ្នកនេសាទត្រី បន្ទាប់មកគេទៅជាអ្នកនេសាទមនុស្សវិញ។ ចំពោះយើងក៏ដូច្នោះដែរ សូមឲ្យយើងគិតពីជីវិតរបស់យើង តើមុនពេលដែលខ្ញុំបានស្គាល់ព្រះយេស៊ូ មុនពេលដែលខ្ញុំបានស្គាល់ព្រះសហគមន៍ ខ្ញុំជាមនុស្សយ៉ាងដូចម្តេច? សព្វថ្ងៃ ខ្ញុំដែលបានស្គាល់ព្រះយេស៊ូហើយ តើមានអ្វីខ្លះដែលជួយឲ្យជីវិតរបស់ខ្ញុំមានការផ្លាស់ប្រែ? តើខ្ញុំមានការផ្លាស់ប្រែអ្វីខ្លះ? ថ្ងៃនេះ យើងបានមកដល់ទីនេះ យើងជួបជុំគ្នា យើងស្វាគមន៍គ្នាជាបងប្អូន យើងអធិដ្ឋានជាមួយគ្នា...។ ក្នុងចំណោមបងប្អូនទាំងអស់ពិតណាស់មានបងប្អូនខ្លះ ទើបតែមកជាលើកទីមួយនិងទើបតែមានបទពិសោធន៍អង្គុយនៅចំពោះមុខព្រះកាយព្រះគ្រីស្ត។

ថ្ងៃនេះយើងរិះគិតពីជីវិតរបស់យើង យើងដឹងថា យើងមានព្រះជាម្ចាស់ដែលស្រឡាញ់យើង។ យើងដឹងថា យើងមានម្តាយតែមួយគឺព្រះនាងម៉ារីដែលស្រឡាញ់យើង។ យើងដឹងថា

យើងជាព្រះសហគមន៍ដែលជាសហគមន៍មិត្តសម្លាញ់របស់ព្រះគ្រីស្ត ដែលជួបជុំគ្នាអធិដ្ឋាន ដែលជួបជុំគ្នាទទួលកម្លាំងពីព្រះយេស៊ូ។ ពីព្រឹកមិញខ្ញុំបានបង្ហាញថា ព្រះយេស៊ូបានប្រមូលយកទុក្ខលំបាករបស់យើងទាំងអស់ ហើយប្រែឲ្យទៅជាសេចក្តីសង្ឃឹម ទៅជាពន្លឺ ទៅជាកម្លាំង ដូចផ្កាឈូកផុសពី ភក់ទៅជាផ្កាស្រស់ស្អាត និងបែរទៅរកព្រះអាទិត្យនៅពេលព្រឹកព្រលឹម ដើម្បីទទួលភាពកក់ក្តៅ។ យើងក៏ដូចផ្កាឈូកដ៏ស្រស់ស្អាតដែរ ដ្បិតយើងក៏ជាអ្នកណែនាំឲ្យអ្នកដទៃសប្បាយចិត្តដែរ។ ដូច្នេះសូមឲ្យយើងទៅជាផ្កាឈូកដ៏ស្រស់ស្អាតជាងគេនៅក្នុងប្រទេសកម្ពុជា នៅក្នុងពិភពលោកទាំងមូលដោយសារព្រះជាម្ចាស់បានជ្រើសរើសយើងជាមិត្តសម្លាញ់របស់ព្រះអង្គ។

សូមកុំធ្វើអ្វីមួយឲ្យព្រះជាម្ចាស់ព្រួយព្រះហឫទ័យឡើយ។ ព្រះជាម្ចាស់គាប់ព្រះហឫទ័យនឹងយើងដែលចេះស្រឡាញ់គ្នា ដែលគោរពគ្នា ដែលជួយគ្នាទៅវិញទៅមក នឹងដែលខិតខំចែកធម៌មេត្តាករុណា ណែនាំឲ្យអ្នកដទៃមានអំណរសប្បាយពេញខ្លួន។ ព្រះជាម្ចាស់ក៏គាប់ព្រះហឫទ័យនឹងចិត្តបរិសុទ្ធរបស់យើងដែរ គឺឲ្យយើងញញឹមជានិច្ច ទោះបីយើងបែកញើស ទោះបីយើងហត់នឿយ ទោះបីយើងរងារទោះបីយើងឃ្លាន ទោះបីយើងត្រូវខ្យល់បក់បោកយ៉ាងខ្លាំងយ៉ាងណាក៏ដោយនោះសូមឲ្យយើងមានសេក្តីសុខខាងផ្លូវចិត្ត ដោយដឹងថាព្រះយេស៊ូបានជ្រើសរើសយើងធ្វើជាមិត្តសម្លាញ់របស់ព្រះអង្គដោយសារព្រះអង្គស្រឡាញ់យើង រហូតព្រះអង្គមានព្រះបន្ទូលមកយើងថា "សូមអញ្ជើញមកតាមខ្ញុំ" ដើម្បីទៅប្រកាសដំណឹងល្អពីព្រះជាម្ចាស់។

យើងបានស្តាប់នៅក្នុងអត្ថបទទី១ **"អ្នកមានចិត្តស្រឡាញ់តែងតែអត់ធ្មត់មិនចេះឈ្នានីសគេទេ អ្នកមានចិត្តស្រឡាញ់មិនវាយឫកខ្ពស់ មិនអួត។ អ្នកមានចិត្តស្រឡាញ់មិនប្រព្រឹត្តអំពើថោកទាប អ្នកមានចិត្តស្រឡាញ់អត់ឱនឲ្យគ្រប់កាលៈទេសៈ ជឿក្នុងគ្រប់កាលៈទេសៈ សង្ឃឹមក្នុងគ្រប់កាលៈទេសៈ ហើយគាំទ្រក្នុងគ្រប់កាលៈទេសៈ"** នេះជាអំណោយដែលយើងទទួលពីព្រះយេស៊ូ។ ដូច្នេះ នៅពេលនេះសូមឲ្យយើងនៅស្ងៀមស្ងាត់ដោយគិតក្នុងចិត្តថា ព្រះជាម្ចាស់បានជ្រើសរើសខ្ញុំឲ្យធ្វើជាមិត្តសម្លាញ់របស់ព្រះយេស៊ូជាព្រះបុត្រាព្រះអង្គ។ ខ្ញុំ

បានទទួលជីវិតថ្មីពីព្រះយេស៊ូ។ ខ្ញុំបានស្គាល់ព្រះយេស៊ូ ព្រះអង្គសព្វព្រះហឫទ័យឲ្យខ្ញុំបំពេញកិច្ចការដោយអំណរសប្បាយនៅក្នុងចិត្ត ដោយញញឹមនៅក្នុងចិត្ត។ ព្រះយេស៊ូចង់ឲ្យខ្ញុំធ្វើជាផ្កាឈូកមួយទងយ៉ាងស្អាត និងឲ្យខ្ញុំណែនាំបងប្អូនឯទៀតៗឲ្យមានអំណរសប្បាយដែរ។

នេះជាតួនាទី ជាបេសកកម្មដែលយើងជាគ្រីស្ដបរិស័ទបានទទួល ដើម្បីកសាងព្រះសហគមន៍របស់ព្រះជាម្ចាស់ ដូចយើងបានសូត្រទំនុកតម្កើងលេខ១៥ថា **"សេចក្ដីសុចរិតយុត្តិធម៌ប្រណិត នៅក្នុងព្រះអម្ចាស់ សុខសាន្តតាមជាន រៀបផ្លូវថ្វាយព្រះ ឥតមានក្រឡះសុខសាន្តរហូត"**។

**"អ្នកមានចិត្តស្រឡាញ់តែងតែអត់ធ្មត់មិនចេះឈ្នានីសគេទេ អ្នកមានចិត្តស្រឡាញ់មិនវាយឫកខ្ពស់មិនអួត។ អ្នកមានចិត្តស្រឡាញ់មិនប្រព្រឹត្តអំពើថោកទាប អ្នកមានចិត្តស្រឡាញ់អត់ឱនឲ្យគ្រប់កាលៈទេសៈ ជឿក្នុងគ្រប់កាលៈទេសៈ សង្ឃឹមក្នុងគ្រប់កាលៈទេសៈ ហើយតាំងទ្រក្នុងគ្រប់កាលៈទេសៈ"**

# មនុស្សទាំងអស់ជាមនុស្សដែលត្រូវការគ្រូពេទ្យ

We all need a doctor

| |
|---|
| អត្ថបទទី១៖ ទក ៣០, ១០-១៤ |
| អត្ថបទទី២៖ កាឡ ១, ១៥-២០ |
| ដំណឹងល្អ៖ លក ១០, ២៥-៣៧ |

ថ្ងៃនេះយើងបានស្ដាប់អត្ថបទដែលនិយាយអំពី អ្នកសប្បុរសសាម៉ារីជួយលាងរបួសជនរងគ្រោះនៅតាមផ្លូវ ជាអត្ថបទដែលយើងបានស្ដាប់ច្រើនដងមកហើយ ជាពិសេសក្នុងឆ្នាំនេះដែលជាឆ្នាំនៃព្រះមហាករុណាទិគុណ ដើម្បីសម្ដែងព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់។ កាលពីឆ្នាំ២០១៤ ភូមិភាគភ្នំពេញយើង បានធ្វើដំណើរជាមួយអត្ថបទនេះ ដូចយើងឃើញមានផ្ទាំងប៉ាណូមួយ ដែលបង្ហាញអំពីអ្នកសប្បុរសនោះជួយជនរងគ្រោះ បិទនៅមុខព្រះវិហារយើង។ សម្រាប់យើងឆ្នាំព្រះមហាករុណាទិគុណនេះ ជាឱកាសមួយឲ្យយើងនឹកឃើញម្ដងទៀតអំពីពាក្យប្រស្នានេះ ដែលជួយណែនាំយើងជាគ្រីស្ដបរិស័ទឲ្យមានចិត្តមេត្តាករុណាគ្រប់ពេលវេលា។ ដូច្នេះពេលស្ដាប់ពាក្យប្រស្នានេះ នោះយើងត្រូវមើលអ្វីដែលមាននៅក្នុងប្រស្នានោះ។

១) មានជនរងគ្រោះដេកស្ដូកនៅនៅតាមផ្លូវ។ ជនរងគ្រោះត្រូវគេវាយមានរបួសពេញខ្លួនគាត់អត់ដឹងខ្លួន បាត់ស្មារតី និងអត់មាននរណាដែលជួយមើលថែរ។ មនុស្សទី១ដែលដើរកាត់ទីនោះគឺជាបូជាចារ្យ។ គាត់អត់រវីរវល់នឹងអ្នករបួសនោះទេ ព្រោះគាត់ប្រញ៉ាប់ទៅជួបគេ តាមការណាត់ទុក គាត់អត់មានពេលមើលថែអ្នករបួសទេ ដូច្នេះគាត់សម្រេចចិត្តដើរហួសទៅ។ បន្ទាប់មកមានលេវីគាត់ដូចបូជាចារ្យដែរ ដោយឃើញមានឈាមច្រើនពេក គាត់ដើរហួសទៅ

---

អភិបូជា នៅទួលតាំង
ថ្ងៃទី ១០ កក្កដា ២០១៦

ដោយដឹងថាតាមវិន័យ គាត់គ្មានសិទ្ធប៉ះឈាមអ្នករបួសនោះទេ។ ក្រោយមកមានបុរសសាម៉ារីម្នាក់ គាត់ជាសាសន៍ដទៃ មិនជាប់ជាមួយវិន័យដូចលេវី និងប្រហែលមិនមានការរវល់ដូចបូជាចារ្យដែរ។ គាត់មានចិត្តមេត្តាករុណាពន់ពេកណាស់ ក្រោយពីបានឃើញអ្នករបួសនៅតាមផ្លូវតែម្នាក់ឯងដូច្នេះ។ គាត់ក៏យកពេលវេលារបស់ខ្លួនទៅយកចិត្តទុកដាក់នឹងជនរងគ្រោះនោះ ដោយលាងរបួស និងក្រោយមកលើកដាក់រទេះរបស់គាត់ ជូនទៅសម្រាកព្យាបាលនៅផ្ទះសម្នាក់មួយ ទាំងគាត់ចេញថ្លៃព្យាបាល និងថ្លៃផ្ទះសម្នាក់ទៀតផង។

ឥឡូវយើងពិនិត្យមើលទាំងគិតពីអត្ថន័យ តើអ្នកដែលត្រូវរបួសនៅតាមផ្លូវជាអ្នកណា? តាមពិតអ្នកដែលត្រូវរបួសនៅតាមផ្លូវ គឺជាយើងទាំងអស់គ្នា។ យើងម្នាក់ៗមានរបួសនៅក្នុងជីវិត គឺយើងមានទុក្ខលំបាក មានអំពើបាប មានសេចក្ដីអាក្រក់ មានជំងឺផ្លូវកាយ ផ្លូវចិត្ត ផ្លូវវិញ្ញាណ ជំងឺក្នុងរបៀបដែលយើងមើលងាយអ្នកដទៃ និយាយដើមគេ អត់ជួយឈឺឆ្អាលគេ យើងឈ្លោះគ្នា យើងអន់ចិត្តគ្នា យើងបង្កើតបក្សពួកនៅក្នុងព្រះសហគមន៍ យើងបង្កើតបញ្ហាជាច្រើន។ ដូច្នេះយើងជាអ្នកត្រូវរបួសដូចអ្នកមានរបួសនៅតាមផ្លូវដែរ។

ឯអ្នកសប្បុរសដែលជួយមើលថែជនរងគ្រោះ គឺជាព្រះយេស៊ូ។ ព្រះយេស៊ូមានព្រះបន្ទូលអំពីអ្នកសប្បុរសជាប្រស្នាអំពីព្រះអង្គផ្ទាល់ ដែលយាងមកដើម្បីព្យាបាលរបួស ដើម្បីថែរក្សាអ្នកជំងឺ ដើម្បីថែរក្សាអ្នកដែលមានបាបដើម្បីថែរក្សាអ្នកដែលវង្វេង ដើម្បីថែរក្សាអ្នកដែលមិនដឹងខ្លួនដើរនៅក្នុងភាពងងឹត ដើម្បីលាងរបួសក្នុងជីវិតរបស់យើង ដើម្បីលើកទឹកចិត្តយើងឲ្យមានកម្លាំង ដើម្បីយើងបន្តធ្វើដំណើរទៅមុខ។ អ្នកសប្បុរសនោះជូនដំណើរជនរងគ្រោះដល់ផ្ទះសម្នាក់ គឺជាព្រះសហគមន៍ដែលទទួលស្វាគមន៍មនុស្សទាំងអស់ ដែលមានរបួសនៅក្នុងចិត្តនៅក្នុងជីវិត។ សម្ដេចប៉ាប ហ្វ្រង់ស៊ីស្កូ មានប្រសាសន៍ថា **"ព្រះសហគមន៍ត្រូវតែជាមណ្ឌលសុខភាពមួយ ដើម្បីទទួលមនុស្សទាំងអស់ដែលកំពុងមានទុក្ខលំបាក ដែលកំពុងមានបញ្ហា ដែលកំពុងគ្មានទីពឹង ដែលកំពុងអស់សង្ឃឹម"**។ នេះជាតួនាទីរបស់យើង ជាតួនាទីរបស់ព្រះសហគមន៍ដែលត្រូវតែជាកន្លែងមួយដ៏ទូលំទូលាយ ដើម្បីទទួលស្វាគមន៍មនុស្សតូចតាច

មនុស្សដែលគ្មានទីពឹង និងអស់សង្ឃឹម។

ក្រោយមកគាត់ចំណាយលុយ២កាក់ ដែលកាក់ទី១ ជាសញ្ញាសម្គាល់នៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ ព្យាបាលខួរក្បាលដែលជាចិត្តគំនិតរបស់យើង និងណែនាំឲ្យយើងមានគោលដៅយ៉ាងច្បាស់នៅក្នុងការរស់នៅ គឺឲ្យយើងស្រឡាញ់អ្នកដទៃ លើកលែងទោសឲ្យអ្នកដទៃ និងធ្វើដំណើរជាមួយអ្នកតូចតាច។ ចំណែកកាក់១ទៀត ជាអគ្គសញ្ញានីមួយៗដែលយើងបានទទួលមានដូចជាអគ្គសញ្ញាអរព្រះគុណ (ព្រះកាយព្រះគ្រីស្ត) និងអគ្គសញ្ញាដ៏សំខាន់មួយទៀត គឺអគ្គសញ្ញាលើកលែងទោស ជាពិសេសគឺនៅក្នុងឆ្នាំព្រះមហាករុណាទិគុណនេះ ជាឱកាសមួយដើម្បីសូមព្រះជាម្ចាស់ជម្រះចិត្តគំនិតរបស់យើងតាមរយៈអគ្គសញ្ញាលើកលែងទោស។

សរុបសេចក្តីមក ផ្ទះសម្នាក់គឺជានិមិត្តរូបព្រះសហគមន៍ ដែលព្យាបាលយើងដោយសារព្រះបន្ទូល។ ព្រះបន្ទូលព្រះជាម្ចាស់ជាអ្នកថែរក្សា គឺជាព្រះយេស៊ូផ្ទាល់ហើយយើងជាអ្នកដែលមានរបួសដែលត្រូវការទទួលការព្យាបាលពីព្រះយេស៊ូ។ ព្រះយេស៊ូមានព្រះបន្ទូលថា **"សូមលោកអញ្ជើញទៅចុះ ហើយប្រព្រឹត្តឲ្យបានដូចអ្នកនោះទៅ"** មានន័យថា ព្រះយេស៊ូអញ្ជើញយើងឲ្យធ្វើដូចព្រះអង្គ គឺយើងជាអ្នកដែលបានទទួលការព្យាបាលពីព្រះអង្គហើយ នោះព្រះយេស៊ូសូមឲ្យយើងប្រព្រឹត្តដូចអ្នកសប្បុរសនោះដែរ គឺដូចព្រះអង្គដែលបានព្យាបាលបងប្អូនឯទៀតៗដោយចិត្តស្រឡាញ់។ ស្រឡាញ់មានន័យថា រាល់ពេលព្រឹកភ្ញាក់ពីដំណេក យើងត្រូវអរព្រះគុណព្រះជាម្ចាស់ដែលប្រទានជីវិតឲ្យយើង និងអរព្រះគុណព្រះជាម្ចាស់សម្រាប់បងប្អូនឯទៀតៗ មានទាំងអ្នកដែលយើងស្រឡាញ់ និងអស់អ្នកដែលយើងមិនស្រឡាញ់។ មានទាំងមិត្តសម្លាញ់ មានទាំងបងប្អូនយើងបង្កើត និងអស់អ្នកដែលជាសត្រូវរបស់យើង និងអស់អ្នកដែលមិនមែនជាសាច់ញាតិរបស់យើង ដោយដឹងថា មនុស្សទាំងអស់មានតម្លៃណាស់ ដោយសារព្រះជាម្ចាស់បានបង្កើតគេ ដូចព្រះអង្គបានបង្កើតយើងដែរ។

២) ស្រឡាញ់មានន័យថាគោរពបងប្អូនឯទៀតៗ។ យើងត្រូវការគោរពមនុស្សទាំងអស់ ដ្បិតមនុស្សទាំងអស់មានតម្លៃ មនុស្សទាំងអស់ជាបងប្អូនរបស់យើង។ ជាពិសេសនៅក្នុងព្រះ-

សហគមន៍ទូតាំងរបស់យើង តើយើងត្រូវគោរពគ្នាទៅវិញទៅមកយ៉ាងដូចម្តេចក្នុងគណៈកម្មការសង្គហៈ គណៈកម្មការពិធីបុណ្យ គណៈកម្មការអប់រំជំនឿ ក្រុមយុវជន ក្រុមកូនក្មេង ក្រុមចម្រៀង ដើម្បីឲ្យយើងបម្រើព្រះសហគមន៍ ដើម្បីឲ្យព្រះសហគមន៍របស់យើងមានជីវិតពិតមែន។ សូមឲ្យយើងចេះគោរពគ្នា ស្តាប់គ្នា យល់ចិត្តគ្នា អត់មានម្នាក់ដែលចង់មានអំណាចទេ យើងគឺជាអ្នកបម្រើគ្នាទៅវិញទៅមក ដើម្បីកសាងព្រះសហគមន៍របស់យើង ឲ្យទៅជាព្រះ-សហគមន៍របស់ព្រះយេស៊ូ។

៣) ដើម្បីស្រឡាញ់ យើងត្រូវតែកោតសរសើរ គោរព បម្រើគ្នាទៅវិញទៅមកនៅក្នុងព្រះសហគមន៍។ ប៉ុន្តែមិនទាន់ល្មមទេ គឺត្រូវបម្រើបងប្អូនដែលនៅជុំវិញយើងដែរ គឺអ្នកភូមិរបស់យើងអ្នកក្រីក្រដែលយើងបានជួបប្រទះ។ ដូច្នេះព្រះសហគមន៍របស់យើង មានគោលដៅបម្រើបងប្អូនទាំងអស់ស្វាគមន៍ទាំងអស់។ ព្រះសហគមន៍ជាមណ្ឌលសុខភាពមួយដែលអត់គិតលុយដែលយើងទទួលស្វាគមន៍ជានិច្ច ណែនាំឲ្យអ្នកតូចតាចអាចឈរឡើងបាន និងមានសេចក្តីសុខនៅក្នុងជីវិត។

ចំណុចចុងក្រោយ ដើម្បីស្រឡាញ់គេឲ្យយើងចេះលើកលែងទោស ប្រសិនបើយើងអត់មានចិត្តប្រណីសន្តោស អត់មានចិត្តលើកលែងទោស នោះយើងត្រូវឈ្លោះគ្នារហូត យើងមើលងាយគ្នា យើងមិនទាក់ទងគ្នាទេ។ ដូច្នេះមានតែការលើកលែងទោសទេដែលជួយឲ្យយើងបង្កើតព្រះសហគមន៍ជាព្រះសហគមន៍ដែលស្រឡាញ់គ្នាជាបងប្អូនពិតៗ និងជាព្រះ-សហគមន៍ដែលទទួលអ្នកដទៃទុកជាបងប្អូនរបស់យើង។ នៅក្នុងគ្រួសាររបស់យើងក៏ដូចគ្នាដែរ ប្រសិនបើអត់មានការលើកលែងទោសទេ ប្តីប្រពន្ធនឹងឈ្លោះគ្នា ម្តាយកូនឈ្លោះគ្នា ឪពុកកូនឈ្លោះគ្នា កូនៗឈ្លោះគ្នា ចាស់ក្មេងឈ្លោះគ្នា ដែលសុទ្ធតែជាបញ្ហា។ ប៉ុន្តែសម្រាប់យើងជាគ្រីស្តបរិស័ទ យើងមានការលើកលែងទោស។ ការលើកលែងទោសណែនាំឲ្យយើងមានការសម្រុះសម្រួលគ្នា ដើម្បីបន្តដំណើរតាមរបៀបដែលព្រះយេស៊ូណែនាំយើង។

សរុបមក ព្រះយេស៊ូអញ្ជើញយើងឲ្យក្លាយជាអ្នកសប្បុរសដូចព្រះអង្គ ដើម្បីព្យាបាល ដើម្បីថែទាំ ដើម្បីស្រឡាញ់។ ស្រឡាញ់មានន័យថា កោតសរសើរ គោរព បម្រើ លើកលែងទោសនេះជាជីវិតរបស់យើងជាគ្រីស្តបរិស័ទ។ ថ្ងៃនេះយើងស្តាប់ព្រះបន្ទូលរបស់ព្រះយេស៊ូជាព្រះបន្ទូលសម្រាប់យើងផ្ទាល់។ សូមអញ្ជើញទៅចុះហើយប្រព្រឹត្តឲ្យបានដូចអ្នកនោះទៅ មានន័យថា សូមប្រព្រឹត្តដូចព្រះយេស៊ូ។

**"សូម លោកអញ្ជើញទៅចុះ ហើយប្រព្រឹត្តឲ្យបានដូចអ្នកនោះទៅ"**

# ព្រះជាម្ចាស់មានព្រះហឫទ័យប្រណីសន្ដោស ចំពោះយើងខ្ញុំ

God forgives us

ដោយព្រះនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ!

បពិត្រព្រះអម្ចាស់ជាព្រះបិតា ថ្ងៃនេះកូនទាំងអស់គ្នាសូមអរព្រះគុណព្រះអង្គដែលបានត្រាស់ហៅយើងខ្ញុំ ឲ្យចូលរួមទិវាយុវជនពិភពលោកទាំងមូល រួមជាមួយសម្ដេចប៉ាប រួមជាមួយយុវជនយុវនារីទូទាំងពិភពលោករួមជាមួយគ្រីស្ដបរិស័ទ  ជាពិសេសគ្រីស្ដបរិស័ទនៅប្រទេសប៉ូឡូញដែលមានជំនឿរឹងមាំលើគ្រីស្ដសាសនា ដែលបានឆ្លងកាត់ប្រវត្តិសាស្ត្រជូរចត់នៃសង្គ្រាមលោកលើកទីពីរ នៃសម័យកុំម្មុយនីស្ដដែលបានខិតខំបំផ្លាញសាសនា ប៉ុន្ដែជំនឿរឹងមាំបានទៅមុខនឹងបានឈ្នះរហូត។

សូមព្រះអង្គជួយឲ្យយើងខ្ញុំមានជំនឿរឹងមាំ ឲ្យយើងខ្ញុំមានចិត្តក្លាហាននិងចិត្តមេត្តាករុណា។ សូមព្រះអង្គបំភ្លឺចិត្តគំនិតយើងខ្ញុំឲ្យរកឃើញសេរីភាពដ៏មានន័យ ដែលណែនាំឲ្យយើងខ្ញុំ ចេះស្រឡាញ់គ្នាទៅវិញទៅមក។ រកឃើញសេរីភាពដែលគ្មានព្រំដែនក្នុងទំនាក់ទំនងក្នុងការ ស្វាគមន៍ ក្នុងការលើកលែងទោសឲ្យគ្នាទៅវិញទៅមក។ សូមឲ្យទិវាយុវជនពិភពលោកនេះទៅជាឱកាសមួយ ឲ្យយើងខ្ញុំបានទទួលពិសោធន៍អំពីព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះជាម្ចាស់ចំពោះមនុស្សលោក និងចំពោះយើងខ្ញុំ។ សូមណែនាំឲ្យយើងខ្ញុំធ្វើជាសាក្សីនៃសុខសន្តិភាព ជាពិសេសនៅកន្លែងដែលមានភេរវកម្ម នៅកន្លែងដែលមានការស្អប់ខ្ពើមគ្នា នៅកន្លែង

---

អប់រំលើកទីមួយរបស់លោកអភិបាលអូលីវីយេ
ក្នុងទិវាយុវជនពិភពលោក នៅទីក្រុងក្រាកាវប្រទេសប៉ូឡូញ
ថ្ងៃទី២៧ កក្កដា ២០១៦

ដែលមានសង្គ្រាមនៅកន្លែងដែលមានការបៀតបៀនគ្នា។ សូមព្រះអង្គគង់នៅជាមួយយើងខ្ញុំ សូមឲ្យយើងខ្ញុំរៀងៗខ្លួន ធ្វើដំណើរនៅក្នុងអារាមសម្ងាត់នៃដួងចិត្តរបស់ខ្លួន ដើម្បីរកឃើញផ្លូវនៃសុភមង្គល។ យើងខ្ញុំសូមទូលអង្វរព្រះអង្គដោយរួមជាមួយព្រះយេស៊ូជាព្រះគ្រីស្ត និងជាព្រះអម្ចាស់របស់យើងខ្ញុំ។

ថ្ងៃនេះ ប្រធានបទរបស់យើងគឺ **"ព្រះជាម្ចាស់មានព្រះហឫទ័យប្រណីសន្តោសចំពោះយើងខ្ញុំ"** ជាអ្វីដែលយើងកំពុងធ្វើនៅក្នុងឆ្នាំព្រះមហាករុណាទិគុណ តាំងពីយូរខែមកហើយ។ ខ្ញុំសង្ឃឹមថាបងប្អូនមានពិសោធន៍អំពីរបៀបដែលព្រះជាម្ចាស់ស្រឡាញ់យើង អំពីរបៀបដែលព្រះជាម្ចាស់គង់នៅជាមួយយើង គឺយើងមិនដែលធុញទ្រាន់នឹងធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ទេ។ ពេលនេះយើងស្ថិតនៅក្នុងទីក្រុងក្រាការ ជាទីក្រុងពិសេសដោយសារជាទីក្រុងរបស់សម្ដេចប៉ាបយ៉ូហានប៉ូលទីពីរ។ ប៉ុន្មានរយម៉ែត្រពីទីនេះមានផ្ទះលោកអភិបាលមួយយ៉ាងធំ ជាកន្លែងដែលសន្តៈយ៉ូហានប៉ូលទីពីររស់នៅក្នុងពេលលោកទទួលមុខងារជាអភិបាលក្រុងក្រាការ មុនទទួលមុខងារជាសម្ដេចប៉ាប។ លោកកាឌីណាស់ដែលបានថ្វាយអភិបូជាបើកទិវាយុវជនពិភពលោកកាលពីម្សិលមិញ លោកធ្លាប់ជាលេខារបស់កាឌីណាល់ប៉ូទីឡាស់ ហើយលោកបានទៅទីក្រុងរ៉ូមកាលពីខែតុលា ឆ្នាំ១៩៧៨ ដើម្បីបោះឆ្នាតជ្រើសរើសសម្ដេចប៉ាបថ្មី។ លោកបានចូលក្នុងព្រះវិហារតូចស៊ីស្ទីន ដែលគេបិទទ្វារដើម្បីបោះឆ្នោតជ្រើសរើសសម្ដេចប៉ាប។ នៅចំពោះមុខរូបព្រះជាម្ចាស់វិនិច្ឆ័យពិភពលោកទាំងមូល គេបានរើសកាឌីណាល់ប៉ូទីឡាស់ទៅជាសម្ដេចប៉ាប ដែលហៅថាសម្ដេចប៉ាបយ៉ូហានប៉ូលទីពីរ។ កាឌីណាល់ដែលបានថ្វាយអភិបូជាបើកពីម្សិលមិញ បានទទួលមុខងារជាអគ្គលេខាផ្ទាល់របស់សម្ដេចប៉ាបយ៉ូហានប៉ូលទីពីររហូតដល់សម្ដេចប៉ាបសោយទិវង្គត។ លោកធ្លាប់រស់នៅជាមួយសន្តៈយ៉ូហានប៉ូលទីពីរ២៩ឆ្នាំ។

ទីក្រុងក្រាការនេះពិសេសណាស់ ដោយសារជាទីក្រុងរបស់សន្តបុគ្គលជាច្រើនរូប ហើយក៏ជាទីក្រុងរបស់សន្តីហ្វូស្ទីណាជាបងស្រីដែលមានពិសោធន៍យ៉ាងជ្រៅអំពីធម៌មេត្តាករុណារបស់ព្រះជាម្ចាស់។ នៅពេលគិតធ្វើជាដូនជីក្នុងអាយុ១៩ឆ្នាំ បងស្រីបានចាកចេញទៅកាន់ទីក្រុងវ៉ា-

ស្វរី។ បងស្រីធ្វើដំណើរតាមរថភ្លើង ពេលចេញពីរថភ្លើងឃើញមានមហាជនជាច្រើនដែលកំពុងធ្វើដំណើរទៅមកខ្វាត់ខ្វែងដើម្បីទៅធ្វើការ។ បងស្រីមិនដឹងទៅណាមកណាដោយសារគាត់មិនបានជ្រើសរើសជាមុនថានឹងចូលក្នុងក្រុមគ្រួសារណាមួយ។ បងស្រីបានអធិដ្ឋានដល់ព្រះនាងម៉ារីដែលបានឆ្លើយតបទៅបងស្រីថា **"កុំខ្លាចអ្វី សូមទៅមុខអ្នកនឹងឃើញកន្លែងដែលខ្ញុំបានរៀបចំសម្រាប់អ្នក"**។ បងស្រីបានធ្វើដំណើរទៅមុខរហូតដល់ផ្ទះក្រុមគ្រួសារបងស្រី **"ព្រះហឫទ័យមេត្តាករុណារបស់ព្រះជាម្ចាស់"**។ ទីនោះហើយដែលបងស្រីបានក្លាយទៅជាដូនជី។ បងស្រីជាប់ចិត្តជាមួយព្រះយេស៊ូ និងព្រះនាងម៉ារីជាខ្លាំង បងស្រីបានបម្រើការងារនៅច្រើនកន្លែង តែកន្លែងចុងក្រោយដែលបងស្រីបម្រើ គឺនៅទីក្រុងក្រាក្រាវនេះ។

ពេលស្ថិតនៅក្នុងទីក្រុងនេះ យើងត្រូវគិតថាយើងកំពុងស្ថិតនៅក្នុងទីក្រុងរបស់សន្តបុគ្គលដែលមានសម្តេចប៉ាបយ៉ូហានប៉ូលទីពីរ ជាគ្រីស្តទូតនៃព្រះហឫទ័យមេត្តាករុណារបស់ព្រះជា-ម្ចាស់ និងមានបងស្រីហ្វូស្ទីណា ជាលេខានៃព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់ដែលផ្តល់ពិសោធន៍អំពីធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ក្នុងជីវិតរបស់យើង និងអ្វីដែលសំខាន់គឺបងស្រីសូមឲ្យយើងថែរក្សាអារាមសម្ងាត់ក្នុងដួងចិត្តរបស់យើង។ យើងម្នាក់ៗដែលជាយុវជនកាតូលិកមានអារាមសម្ងាត់មួយយ៉ាងតូចនៅក្នុងដួងចិត្តរបស់យើងដែលយើងត្រូវថែរក្សា។ គ្រប់ពេលដែលយើងរងទុក្ខលំបាកគ្រប់ពេលវេលា ដែលយើងសប្បាយសូមឲ្យយើងចូលនៅក្នុងអារាមសម្ងាត់របស់យើង។ ត្រូវដឹងថានៅក្នុងអារាមសម្ងាត់នោះ យើងនឹងជួបព្រះយេស៊ូដែលគង់នៅក្នុងដួងចិត្តរបស់យើង។ នៅពេលយើងដើរ យើងអធិដ្ឋាន យើងសូត្រធម៌យើងនៅស្ងៀមស្ងាត់យើងតាំងព្រះកាយ នោះសូមឲ្យយើងចូលនៅក្នុងអារាមសម្ងាត់នៅក្នុងដួងចិត្តរបស់យើង។

ថ្ងៃនេះ ជាពេលវេលាសម្រាប់ការលើកលែងទោស ដែលជាអត្ថន័យនៃឆ្នាំព្រះមហាករុណាទិគុណ។ ពេលណាយើងអង្វរព្រះជាម្ចាស់ជាព្រះរបស់យើង នោះទ្រង់យាងមកជួយយើងសង្គ្រោះយើងឲ្យយើងរួចពីភាពទន់ខ្សោយ។ ព្រះអង្គជួយយើងឲ្យទទួលស្គាល់ថាព្រះអង្គគង់នៅជាមួយយើង គឺទ្រង់គង់នៅក្បែរយើង នេះស្រង់ចេញពីសារលិខិតរបស់សម្តេចប៉ាប។

ប្រសិនបើយើងចាប់អារម្មណ៍នឹង ព្រះហឫទ័យមេត្តាករុណារបស់ព្រះជាម្ចាស់ជារៀងរាល់ថ្ងៃ នោះយើងមុខជានឹងមានចិត្តមេត្តាករុណាចំពោះមនុស្សទាំងអស់គ្រប់ពេលវេលាដូចព្រះអង្គដែរ។ ថ្ងៃនេះយើងចូលនៅក្នុងការលើកលែងទោសរបស់ព្រះជាម្ចាស់ជាពេលវេលាមួយឲ្យយើងចាប់អារម្មណ៍នឹងព្រះហឫទ័យមេត្តាករុណា របស់ព្រះអង្គនៅក្នុងជីវិតរបស់យើង។ នេះជាពេលវេលាមួយពិសេសណាស់។

ថ្ងៃនេះយើងអានអត្ថបទគម្ពីរសន្តៈលូកាដែលចែងពីព្រះយេស៊ូឈ្នះការល្បួង ហើយព្រះ-អង្គចាប់ផ្ដើមប្រកាសដំណឹងល្អនៅស្រុកកាលីឡេ និងព្រះអង្គប្រកាសពីឆ្នាំព្រះមហាករុណាទិគុណ។ ព្រះយេស៊ូឈ្នះការល្បួងណែនាំឲ្យយើងនឹកស្ញើចសរសើរពីធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ ហើយក៏ ណែនាំឲ្យយើងគិតថា **"តើខ្ញុំជានរណា?"** ។ តាមពិតទៅជីវិតរបស់យើងក៏ដូចជីវិតព្រះយេស៊ូដែរ គឺយើងត្រូវទទួលការល្បួង។ នៅក្នុងវាលរហោស្ថានព្រះយេស៊ូទទួលការល្បួងចំនួនបី។ មារទូលព្រះអង្គថា **"ប្រសិនបើលោកពិតជាព្រះបុត្រារបស់ព្រះអម្ចាស់មែន សូមលោកធ្វើឲ្យដុំថ្មនេះទៅជានំប៉័ងមើល"**។ ព្រះយេស៊ូឆ្លើយទៅមារថា **"ក្នុងព្រះគម្ពីរមានចែងថាមនុស្សមិនរស់ដោយសារតែអាហារប៉ុណ្ណោះទេ"**។ ព្រះយេស៊ូឈ្នះការល្បួងគឺព្រះយេស៊ូឈ្នះចិត្តលោភលន់ ដែលគិតតែពីអាហារ ដែលផ្ទុយពីអារម្មណ៍ធម្មជាតិរបស់មនុស្ស។ សូមឲ្យយើងគិតគូរឲ្យបានទូលំទូលាយបន្តិច ព្រោះការល្បួងទីមួយនេះគឺជាការល្បួងរបស់មនុស្សទាំងអស់។ រឿងអាដាំនិងអេវ៉ា បានសរុបការល្បួងទាំងបីរបស់ព្រះយេស៊ូដូចតទៅ ៖

ទីមួយ សត្វពស់ល្បួងថា **"អ្នកនឹងបានជីវិតអស់កល្បជានិច្ច ឲ្យតែអ្នកទាំងពីរ (អាដាំ, អេវ៉ា) បរិភោគ ផ្លែឈើដែលព្រះជាម្ចាស់ហាមនោះ"**។ ក្នុងការរស់នៅរបស់យើងក៏ដូចគ្នាដែរ យើងសុខចិត្តលះបង់អ្វីមួយដើម្បីទទួលអ្វីមួយមកវិញ។ យើងចាប់ផ្ដើមពីតិចដើម្បីថ្ងៃអនាគតយើងនឹងទទួលបានច្រើន។ ដូចសន្តៈម៉ាស៊ីម៉ាំងកុលដែលបានលះបង់គ្រប់យ៉ាងក្រោយមកគាត់បានទទួលជីវិតអស់កល្បជានិច្ចរួមជាមួយព្រះជាម្ចាស់។ ដូចរឿងព្រះមហាក្សត្រមួយអង្គយាងតាមដងផ្លូវដែលមានអ្នកសូមទានម្នាក់នៅរង់ចាំព្រះអង្គ។ ពេលទៅដល់

ព្រះមហាក្សត្រសួរទៅអ្នកសូមទានថា **"តើអ្នកមានអង្ករប៉ុន្មានឲ្យខ្ញុំ?"** អ្នកសូមទាននោះបានរើសគ្រាប់អង្ករពីក្នុងថង់យាមរបស់ខ្លួនចំនួនប្រាំគ្រាប់ថ្វាយទៅព្រះមហាក្សត្រ។ ព្រះអង្គអរគុណហើយក៏យាងចេញទៅ។ អ្នកសូមទានយំ ព្រោះគាត់សង្ឃឹមថានឹងបានអំណោយពីព្រះមហាក្សត្រ តែបែរជាព្រះមហាក្សត្រជាអ្នកសុំពីគាត់វិញ។ ពេលយប់ទៅដល់ផ្ទះ អ្នកសូមទានបានបើកថង់យាមឡើងស្រាប់តែឃើញមានមាសប្រាំដុំ ណែនាំឲ្យគាត់ភ្ញាក់។

ទីពីរ មារល្បួងព្រះយេស៊ូថា **"ខ្ញុំនឹងប្រគល់អំណាច ព្រមទាំងភោគទ្រព្យរបស់នគរទាំងនោះឲ្យលោកដ្បិតអ្វីៗទាំងអស់ជារបស់ខ្ញុំខ្ញុំអាចប្រគល់ឲ្យអ្នកណាក៏បានស្រេចតែនឹងចិត្តខ្ញុំ"**។ ព្រះយេស៊ូឆ្លើយថា **"ក្នុងព្រះគម្ពីរមានចែងថា អ្នកត្រូវតែថ្វាយបង្គំព្រះអម្ចាស់ជាព្រះរបស់អ្នក និងគោរពបម្រើតែព្រះអង្គមួយប៉ុណ្ណោះ"**។ ការល្បួងទីពីរ គឺចិត្តចង់បានអំណាច ចង់ធ្វើជាអ្នកធំត្រួតត្រាអ្នកនៅក្រោមឱវាទរបស់ខ្លួន។ ការល្បួងនេះណែនាំឲ្យពិភពលោករបស់យើងវង្វេងកើតមានបញ្ហាជាច្រើន។ ព្រះបន្ទូលរបស់ព្រះយេស៊ូគឺផ្ទុយ **"អំណាចគឺបម្រើ"**។ ដូចរឿងរបស់លោកសេបេដេ ម្តាយរបស់គាត់បានសូមព្រះយេស៊ូថា **"នៅពេលព្រះអង្គគ្រងរាជ្យ សូមព្រះអង្គឲ្យកូនខ្ញុំម្នាក់នៅខាងស្តាំ និងម្នាក់ទៀតនៅខាងឆ្វេងព្រះអង្គ"**។ តាមរបៀបព្រះយេស៊ូអ្នកមានអំណាចគឺជាអ្នកបម្រើ ផ្ទុយនឹងអ្វីដែលមនុស្សលោកបានគិត។ ដូចអត្ថបទមួយដែលបានចែងថា **"យើងមិនមកពីលោកីយ៍ទេ តែយើងនៅក្នុងលោកីយ៍។ ទោះបីលោកីយ៍ណែនាំឲ្យយើងគិតផ្សេង តែយើងជាគ្រីស្តបរិស័ទត្រូវដឹងថា យើងត្រូវជួយឲ្យពិភពលោកនេះទៅជាពិភពលោកថ្មី"**។ ដូចជាកម្មវិធីទិវាយុវជនពិភពលោករបស់យើងនេះជាដើម ដែលទទួលជោគជ័យទៅបាន គឺដោយសារមានអ្នកស្ម័គ្រចិត្តបម្រើយើង។ ព្រះសហគមន៍យើងដែលមានអាយុជាង២០០០ឆ្នាំអាចទៅមុខបាន គឺដោយសារមានអ្នកបម្រើដែលមិនគិតប្រយោជន៍ផ្ទាល់ខ្លួន តាមគំរូរបស់ព្រះយេស៊ូ។ ព្រះសហគមន៍កាតូលិកយើងជាសាក្សីយ៉ាងពិសេសនៅប្រទេសកម្ពុជាយើង។ ដូចខ្ញុំបានទៅសួរសុខទុក្ខបងប្អូនកម្មករនៅមណ្ឌលយុវកម្មករពេលនោះមានកម្មករម្នាក់ដែលមិនមែនជាគ្រីស្តបរិស័ទសួរខ្ញុំថា **"តើធ្វើយ៉ាងណាដើម្បីជួយអ្នកដទៃដោយ**

**មិនគិតប្រយោជន៍ផ្ទាល់ខ្លួន?"**។ ខ្ញុំបានប្រាប់ថា **"ចូរឲ្យយើងចូលយ៉ាងជ្រៅនៅក្នុងអារាមសម្ងាត់នៃជីវិតរបស់យើងផ្ទាល់ខ្លួនសិន ក្រោយមកយើងនឹងអាចជួយអ្នកដទៃបាន"**។

ទីបី មារល្បួងព្រះយេស៊ូថា **"ប្រសិនបើលោកពិតជាព្រះបុត្រារបស់ព្រះជាម្ចាស់មែន សូមលោតទម្លាក់ខ្លួនចុះទៅក្រោមមើល៍"** ព្រះយេស៊ូឆ្លើយថា "ក្នុងព្រះគម្ពីរមានចែងថា កុំល្បួងលព្រះ-អម្ចាស់ជាព្រះរបស់អ្នកឡើយ"។ ការល្បួងទីបី គឺយើងចង់ស្មើនឹងព្រះជាម្ចាស់។ នៅក្នុងសម្ព័ន្ធមេត្រីចាស់មានអត្ថបទគម្ពីរមួយក្នុងកំណើតពិភពលោកចែងថា ប្រជាជនទាំងអស់ប្រមូលគ្នាសាងសង់ប៉មមួយឈ្មោះ **"បាបែល"** ដែលអាចឡើងខ្ពស់ ដើម្បីបង្ហាញថាយើងមានអំណាចលើសព្រះជាម្ចាស់។ នេះជាការល្បួងដ៏សំខាន់ចំពោះយើង គឺយើងចង់ស្មើឬលើសព្រះជាម្ចាស់។ ប៉ុន្តែព្រះជាម្ចាស់ទេដែលខ្ពង់ខ្ពស់លើសអ្វីទាំងអស់ ព្រះអង្គទេដែលបានត្រាស់ហៅយើងឲ្យធ្វើជាជនដ៏វិសុទ្ធដូចព្រះអង្គ។ ក្នុងគ្រប់អារ្យធម៌ គេតែងតែកែច្នៃអ្វីៗទាំងអស់ដើម្បីឲ្យមនុស្សលោកធំជាងព្រះជាម្ចាស់។ ដូច្នេះការល្បួងមានបីគឺ លោភលន់ អំណាច និងចង់ស្មើនឹងព្រះជាម្ចាស់ ដែលតែងតែល្បួងយើងទាំងអស់គ្នា ទាំងលោកអភិបាល ទាំងលោកបូជាចារ្យ ទាំងបងប្រុស បងស្រី ទាំងគ្រីស្តបរិស័ទ។

ចូរមានចិត្តមេត្តាករុណាដូចព្រះបិតា!។ ខ្ញុំសូមឲ្យយើងទាំងអស់គ្នាសួរខ្លួនឯងថា "តើខ្ញុំជានរណា? ខ្ញុំមានសមត្ថភាពអ្វី? ខ្ញុំមានអំណរសប្បាយអ្វី? ខ្ញុំមានសេចក្តីសង្ឃឹមអ្វីខ្លះ?" ដើម្បីកសាងជីវិតរបស់យើងផ្ទាល់។ ពេលយើងសួរក្មេងៗថា **"តើថ្ងៃអនាគតចង់ធ្វើអ្វី?"** គេនឹងឆ្លើយភ្លាមថា **"ខ្ញុំចង់ធ្វើគ្រូពេទ្យ ខ្ញុំធ្វើគ្រូបង្រៀន ខ្ញុំធ្វើប៉ូលីស ខ្ញុំធ្វើមេធាវី"** ដែលក្រោយមកគេត្រូវតែរៀបចំខ្លួនដើម្បីឲ្យអនាគតនោះបានសម្រេចឡើង។ សព្វថ្ងៃ ពេលនិយាយពីកសាងអនាគតនោះគឺត្រូវនិយាយពីការបង្កើតក្រុមគ្រួសារមួយដ៏សុខសាន្ត ការបង្កើតជីវិតដ៏អស្ចារ្យ បង្កើតសង្គមប្រកបដោយយុត្តិធម៌ ដូច្នេះយើងត្រូវសួរខ្លួនឯងថា តើខ្ញុំមានសមត្ថភាពអ្វីខ្លះ? ខ្ញុំជានរណា?។

សន្តៈយ៉ូហានបានសរសេរថា **"សូមគិតមើល៍ ព្រះបិតាមានព្រះហឫទ័យស្រឡាញ់**

**យើងខ្លាំងដល់កម្រិតណា គឺព្រះអង្គស្រឡាញ់យើងរហូតដល់ហៅយើងថា ជាបុត្រធីតារបស់ព្រះអង្គហើយយើងពិតជាបុត្រធីតារបស់ព្រះអង្គមែន"** នេះគឺជាការអស្ចារ្យសម្រាប់យើង។ ដូច្នេះសូមឲ្យយើងគិតថា ក្នុងឋានៈជាបុត្រធីតារបស់ព្រះជាម្ចាស់ តើខ្ញុំត្រូវធ្វើអ្វីខ្លះដើម្បីការរីកចម្រើនរបស់ខ្លួនខ្ញុំផ្ទាល់ និងដើម្បីជួយឲ្យអ្នកដទៃមានការរីកចម្រើនឡើងតាមរយៈខ្ញុំ? នេះជាមូលហេតុដែលយើងត្រូវការពារថែរក្សាបីចំណុចដូចខាងក្រោម៖

ទី១ **ដើម្បីដឹងថាខ្លួនខ្ញុំជាអ្នកណា** និងដើម្បីឲ្យអាចទៅមុខបានក្នុងការកសាងជីវិត នោះគឺយើងត្រូវបំបាត់អំពើបាប បំផ្លាញអំពើបាប និងសម្លាប់អំពើបាបដែលមាននៅក្នុងជីវិតរបស់យើង។ **"អ្នកណាស្ថិតនៅជាប់នឹងព្រះអង្គ អ្នកនោះមិនប្រព្រឹត្តអំពើបាបទេ រីឯអ្នកប្រព្រឹត្តអំពើបាប នោះមិនដែលបានឃើញព្រះអង្គ ព្រមទាំងមិនដែលស្គាល់ព្រះអង្គផង"**។ ហេតុដូច្នេះហើយ យើងត្រូវតែទទួលអត្តសញ្ញាលើកលែងទោស ដោយដឹងថាយើងមិនអាចបំផ្លាញបាបម្តងអស់បានទេ ប៉ុន្តែយើងចាប់ផ្តើមដំណើរការបន្តិចម្តងៗ ដើម្បីយើងអាចរកឃើញជីវិតដ៏សុខសាន្ត ដែលព្រះជាម្ចាស់ម្ចាស់បានបង្កើតយើង និងប្រោសយើងទៅជាបុត្រធីតាព្រះអង្គ។

ទី២ **"ស្រឡាញ់គ្នាជាបងប្អូន"** សេចក្តីស្រឡាញ់ជាវិន័យថ្មីមកពីព្រះយេស៊ូ។ យើងត្រូវរក្សាទុកវិន័យថ្មីនេះនៅក្នុងជីវិតរបស់យើងជានិច្ច ដើម្បីឲ្យយើងស្រឡាញ់គ្នាទៅវិញទៅមក។ "កូនចៅអើយ យើងមិនត្រូវស្រឡាញ់ត្រឹមតែបបូរមាត់ ឬពាក្យសម្តីប៉ុណ្ណោះទេ គឺត្រូវស្រឡាញ់តាមអំពើដែលយើងប្រព្រឹត្ត និងតាមសេចក្តីពិតវិញ"។ កុំឲ្យយើងនិយាយតែបបូរមាត់ ប៉ុន្តែឲ្យយើងធ្វើឲ្យយើងអនុវត្តនូវអ្វីដែលយើងបាននិយាយ បានអប់រំ បានទេសនា។

ទី៣ **"ត្រូវប្រយ័ត្ននឹងគ្រូក្លែងក្លាយ"** គឺឲ្យយើងចេះវិនិច្ឆ័យ ឲ្យយើងដើរតាមព្រះជាម្ចាស់ កុំឲ្យយើងដើរតាមគ្រូក្លែងក្លាយ។ ស្ថានភាពនៅប្រទេសកម្ពុជាសព្វថ្ងៃ មានរឿងរ៉ាវជាច្រើនដែលដូចទៅនឹងរឿងរបស់ព្រះយេស៊ូត្រូវគេសម្លាប់ គឺដោយសារព្រះអង្គមានព្រះបន្ទូលពីសេចក្តីពិត។ អ្នកដែលមានចិត្តលោភលន់តែងតែច្រណែននឹងអ្នកដែលនិយាយសេចក្តីពិតតាមរបៀបព្រះយេស៊ូគេស្អប់អ្នកដែលចេះពិចារណារកផ្លូវត្រឹមត្រូវដូចព្រះយេស៊ូ គេបៀតបៀនអ្នកដែល

បំភ្លឺឲ្យស្គាល់អ្វីល្អនិងអ្វីមិនល្អ។ នេះជាផ្លែនៃព្រះវិញ្ញាណដ៏វិសុទ្ធដែលយើងបានទទួលនៅពេលលាបថ្ងាស។

សូមកុំឲ្យយើងឈ្លក់វង្វេងនឹងគ្រូក្លែងក្លាយ មានដូចជាចិត្តលោភលន់ ឈ្លក់វង្វេងនឹងលុយជាដើម តែឲ្យយើងចេះប្រើទ្រព្យសម្បត្តិទាំងអស់ដែលយើងមាននៅក្នុងរបៀបល្អ។ **"អ្នកទាំងនោះកើតមកពីលោកីយ៍ ហេតុនេះហើយបានជាពាក្យសម្ដីរបស់គេចេញពីលោកីយ៍ ហើយមនុស្សលោកស្ដាប់គេ។ រីឯយើងវិញយើងកើតមកពីព្រះជាម្ចាស់ អ្នកណាស្គាល់ ព្រះជាម្ចាស់អ្នកនោះក៏ស្ដាប់យើងដែរ អ្នកណាមិនកើតមកពីព្រះជាម្ចាស់ទេអ្នកនោះមិនស្ដាប់យើងឡើយ"** សេចក្ដីនេះណែនាំឲ្យយើងដឹងថាព្រះវិញ្ញាណដ៏វិសុទ្ធសម្ដែងសេចក្ដីពិតខុសពីវិញ្ញាណក្លែងក្លាយដែលនាំឲ្យយើងវង្វេង។

យើងដែលបានទទួលការបៀតបៀន នោះសូមឲ្យយើងតស៊ូដើម្បីជាប្រយោជន៍សម្រាប់មនុស្សទាំងអស់វិញ។ សូមឲ្យយើងធ្វើដូចសន្តអន់ដ្រេ ជាគ្រីស្តទូតក្នុងការប្រកាសដំណឹងល្អ ដែលណែនាំឲ្យពិភពលោកទាំងមូលស្គាល់ព្រះយេស៊ូ។ សូមឲ្យយើងជាយុវជនកាតូលិកបន្តប្រកាសដំណឹងល្អ ដើម្បីឲ្យពិភពលោកស្គាល់សេចក្ដីពិត មេត្តាករុណា សេចក្ដីសុខសាន្ត និងសេចក្ដីសង្ឃឹម។ សូមឲ្យយើងស្គាល់សេរីភាពដ៏ពិតប្រាកដមកពីព្រះជាម្ចាស់ ដែលឲ្យយើងស្រឡាញ់បងប្អូនឯទៀតៗ និងឲ្យយើងបំផ្លាញអំពើបាបរបស់យើង ទាំងបដិសេធគ្រូក្លែងក្លាយដែលណែនាំឲ្យយើងវង្វេង។

ដោយព្រះនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ!

សូមអរព្រះគុណព្រះជាម្ចាស់ សូមព្រះអង្គប្រទានពរដល់យើងខ្ញុំ សូមឲ្យយើងខ្ញុំធ្វើដំណើរយ៉ាងជ្រៅនៅក្នុងអារាមសម្ងាត់នៃដួងចិត្តរបស់យើងខ្ញុំ ដើម្បីរកឃើញវត្តមានរបស់ព្រះគ្រីស្ត ដើម្បី រកឃើញសេចក្ដីស្រឡាញ់យ៉ាងពិសេសរបស់ព្រះជាម្ចាស់សម្រាប់មនុស្សលោកដើម្បីឲ្យជីវិតយើងទៅជាជីវិតថ្មី ជាជីវិតដ៏វិសុទ្ធ ជាជីវិតដែលមកពីព្រះជាម្ចាស់ និងទៅឯព្រះជាម្ចាស់វិញ។ យើងខ្ញុំសូមទូលអង្វរព្រះអង្គ ក្នុងនាមព្រះយេស៊ូជាព្រះគ្រីស្ត និងជាព្រះអម្ចាស់យើងខ្ញុំ។

# តើយើងត្រូវធ្វើយ៉ាងណាដើម្បីជាប់ជាមួយព្រះយេស៊ូថែមទៀត?

How to be more close to Christ?

អត្ថបទទី១៖ អផស ២, ៤-១០
ដំណឹងល្អ៖ យហ ៨, ១-១១

អត្ថបទដែលយើងស្ដាប់នៅពេលនេះ ជួយឲ្យយើងរិះគិតពីទិវាយុវជនភិភពលោកពីព្រឹកនេះទៅ។ អត្ថបទទីមួយចែងថា **"ពីកំណើតមក យើងជាមនុស្សដែលត្រូវទទួលទោស"** ក៏ប៉ុន្តែព្រះជាម្ចាស់ដែលមានព្រះហឫទ័យអាណិតមេត្តាដ៏លើសលប់ ព្រះអង្គស្រឡាញ់យើងខ្លាំងណាស់ គឺទោះបីយើងត្រូវស្លាប់ដោយសារអំពើបាបរបស់យើងក៏ដោយ ក៏ព្រះអង្គបានប្រោសប្រទានឲ្យយើងមានជីវិតរួមជាមួយព្រះគ្រីស្តវិញ។ យើងជាមនុស្សបាបមានភាពងងឹតនៅក្នុងខ្លួនតាំងពីដើមរៀងមក ប៉ុន្តែដំណឹងល្អដែលយើងបានទទួលពីក្នុងអត្ថបទនេះ គឺយើងជាអ្នកបាបដែលព្រះជាម្ចាស់លើកលែងទោសឲ្យ និងព្រះអង្គប្រទានជីវិតថ្មីឲ្យយើង។

យើងលែងជាប់ជាមួយបាបកម្ម យើងលែងជាប់ជាមួយអ្វីដែលរាំងផ្លូវជីវិតរបស់យើងទៀតហើយ នេះជាអំណរសប្បាយរបស់យើងជាគ្រីស្តបរិស័ទ ជាពិសេសជាអំណរសប្បាយរបស់បងប្អូនដែលចេញពីព្រះពុទ្ធសាសនាមកចូលសាសនាកាតូលិកយើង។ បងប្អូនបានប្រែចិត្តគំនិតដ៏កំពូលដើម្បីទទួលជីវិតថ្មី។ **"យើងជាអ្នកមានបាបដែលព្រះជាម្ចាស់លើកលែងទោសឲ្យ"** នេះជាសេចក្តីសង្ឃឹមរបស់មនុស្សយើង ដែលចាប់ផ្តើមមានតាំងពីពេលដែលព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ ពីគេឆ្កាងសម្លាប់នៅលើឈើឆ្កាង។ យើងជាគ្រីស្តបរិស័ទយើងទទួលជីវិតវិញពីព្រះគ្រីស្ត ទោះបីយើងស្លាប់ក៏ដោយ។ ជីវិតរបស់យើងមិនដែលអស់សង្ឃឹមទេ

---

អភិបូជាជាភាសាខ្មែរលើកទី១ ក្នុងទិវាយុវជនពិភពលោក
នៅទីក្រុងក្រាកាវ ប្រទេសប៉ូឡូញ
ថ្ងៃទី២៧ កក្កដា ២០១៦

ទោះបីយើងនៅទីងងឹត ទោះបីយើងវង្វេងផ្លូវ ដ្បិតយើងមានព្រះជាម្ចាស់ជាទីពឹង។ តើធ្វើយ៉ាងណាដើម្បីជីវិតយើងជាប់ជាមួយព្រះយេស៊ូ?

ពេលយើងស្ដាប់អត្ថបទព្រះគម្ពីរថ្ងៃនេះ ណែនាំឲ្យយើងយល់ថែមទៀតពីរបៀបដែលព្រះយេស៊ូលើកលែងទោសឲ្យយើង និងពីរបៀបដែលព្រះយេស៊ូឲ្យយើងទទួលជីវិតថ្មីពីព្រះ-ជាម្ចាស់។ ជាលើកទីមួយដែលយើងឃើញព្រះយេស៊ូកំពុងសរសេរលើដីខ្សាច់ គឺកំពុងសរសេររបាយការណ៍អំពីបាបរបស់ស្ត្រីមានបាបម្នាក់ ប៉ុន្តែក្រោយមកមានខ្យល់ផាត់មកធ្វើឲ្យរលុបរបាយការណ៍នោះអស់នេះមានន័យថាអំពើបាបរបស់នាងមិនសំខាន់ទេ។ ថ្ងៃនេះព្រះយេស៊ូចង់បង្ហាញថាអ្វីដែលយើងធ្វើខុសមិនសំខាន់ទេសម្រាប់ព្រះជាម្ចាស់ អ្វីដែលសំខាន់គឺឲ្យយើងប្រែចិត្តគំនិត ឲ្យយើងសុខចិត្តទទួលការលើកលែងទោសពីព្រះម្ចាស់ដោយចាប់ផ្ដើមជីវិតថ្មី។ ព្រះជាម្ចាស់មិនវិនិច្ឆ័យបាបរបស់ខ្ញុំ ប៉ុន្តែព្រះអង្គទន្ទឹងរង់ចាំខ្ញុំចូលទៅទទួលជីវិតថ្មីពីព្រះអង្គដោយឲ្យខ្ញុំសម្រេចចិត្តនៅថ្ងៃនេះថាខ្ញុំប្រែចិត្តគំនិតហើយ។ ព្រះយេស៊ូមានព្រះបន្ទូលថា "ខ្ញុំក៏មិនដាក់ទោសនាងដែរ សូមអញ្ជើញទៅចុះ តែពីពេលនេះតទៅ កុំប្រព្រឹត្តអំពើបាបទៀតឡើយ"។

សន្តីតេរេសានៃព្រះកុមារយេស៊ូ បានយល់អំពីហេតុការណ៍នេះច្បាស់ណាស់ដោយនិយាយច្រើនដងថា **"ទោះបីខ្ញុំធ្លាប់ធ្វើអំពើបាបធំជាងគេក្នុងពិភពលោកទាំងមូល តែខ្ញុំដឹងថាព្រះជា-ម្ចាស់លើកលែងទោសឲ្យខ្ញុំ"**។ សូមយើងវិលមកគិតពិចារណាអំពីជីវិតរបស់យើងវិញ ជាទូទៅយើងចូលចិត្តវិនិច្ឆ័យបាបរបស់គេ យើងមិនចូលចិត្តទុកឱកាសឲ្យគេប្រែចិត្តគំនិតដូចព្រះយេស៊ូទេ។ ក្នុងសង្គម ពេលយើងធ្វើខុសច្បាប់ នោះយើងត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ ប៉ុន្តែព្រះជាម្ចាស់ខុសប្លែកវិញ។ ព្រះយេស៊ូបានអត់ទោសបាបឲ្យចោរដែលគេឆ្កាងនៅក្បែរព្រះអង្គ ប៉ុន្តែសង្គមមិនអាចលើកលែងទោសឲ្យចោរនោះបានទេ។ យុត្តិធម៌របស់ព្រះជាម្ចាស់ផ្សេងពីយុត្តិធម៌របស់មនុស្ស គឺព្រះអង្គណែនាំឲ្យមនុស្សដែលចង់ទទួលជីវិតថ្មីអាចទទួលបាន។ មនុស្សដែលចង់ប្រែចិត្តគំនិតពិតមែន អាចទទួលជីវិតថ្មីបាន។ សម្រាប់យើងជាគ្រីស្តបរិស័ទ ពេលស្ដាប់អត្ថបទនេះយើងត្រូវការគិតច្រើនថែមទៀត ថាតើខ្ញុំជានរណាដែលវិនិច្ឆ័យគេ? តើខ្ញុំជានរណា

ដែលកាត់ក្ដីគេនិងដាក់ទោសគេ សូម្បីតែព្រះយេស៊ូក៏មិនបានដាក់ទោសគេផងនោះ។

ព្រះយេស៊ូ បានណែនាំឲ្យយើងយកចិត្តទុកដាក់ពិនិត្យមើលខ្លួនឯងជាមុនសិន ដោយព្រះអង្គមានព្រះបន្ទូលថា **"ក្នុងចំណោមអ្នករាល់គ្នា សុំឲ្យអ្នកដែលគ្មានបាបសោះយកដុំថ្មគប់នាងមុនគេទៅ"**។ ក្រោយមកគ្មាននៅសល់ម្នាក់ ដោយសារគេបានចូលនៅក្នុងជីវិតផ្ទាល់ខ្លួន ហើយឃើញមានបាបជាច្រើន។ ក្រោយមកព្រះយេស៊ូសួរនាងថា "នាងអើយពួកគេទៅណាអស់ហើយ គ្មានអ្នកណាដាក់ទោសនាងទេឬ? ដូច្នេះខ្ញុំក៏មិនដាក់ទោសនាងដែរ ដោយសារខ្ញុំដឹងថានាងចង់ទទួលជីវិតថ្មី"។នេះជាព្រះបន្ទូលរបស់ព្រះយេស៊ូដែលរំដោះយើងពីចំណងបាប ពីចំណងនៃអំពើអាក្រក់នានាដែលណែនាំឲ្យយើងទទួលសេរីភាពពិតប្រាកដ គឺទទួលជីវិតថ្មី។

ក្នុងពេលទទួលអគ្គសញ្ញាលើកលែងទោស លោកបូជាចារ្យមានប្រសាសន៍ថា **"រីឯខ្ញុំវិញ ដោយនាមព្រះសហគមន៍ ខ្ញុំលើកលែងទោសឲ្យកូនដោយនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ"** ជាពាក្យដែលចេញពីព្រះបន្ទូលរបស់ព្រះយេស៊ូចំពោះស្ត្រីមានបាបនោះ។ បន្ទាប់មកលោកបូជាចារ្យមានប្រសាសន៍ទៀតថា **"សូមអញ្ជើញដោយសុខសាន្តចុះ"** គឺដូចព្រះ-យេស៊ូដែលមានព្រះបន្ទូលទៅស្ត្រីមានបាបនោះថា **"សូមនាងទៅចុះ តែពីពេលនេះតទៅកុំប្រព្រឹត្តអំពើបាបទៀតឡើយ"**។

យើងខ្ញុំសូមអរព្រះគុណព្រះជាម្ចាស់ដែលបានយាងមកដើម្បីឲ្យយើងខ្ញុំយល់ ឲ្យយើងខ្ញុំឃើញ ឲ្យយើងខ្ញុំស្គាល់ព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គ និងព្រះអង្គយាងមកនៅក្នុងដួងចិត្តរបស់យើងខ្ញុំ នៅក្នុងអារាមសម្ងាត់របស់យើងខ្ញុំ ដើម្បីឲ្យយើងខ្ញុំប្រែចិត្តគំនិតទទួលជីវិតថ្មី ដើម្បីកុំយើងខ្ញុំ ភ្លេចថា យើងខ្ញុំរស់នៅលើផែនដីនេះមិនមែនដើម្បីដាក់ទោសគេ ប៉ុន្តែដើម្បីជួយគេឲ្យគេទទួលជីវិតថ្មី និងឲ្យគេបានស្ដាប់ព្រះបន្ទូលរបស់ព្រះយេស៊ូថា **"សូមអញ្ជើញទៅចុះដោយសុខសាន្ត"**។

# ធ្វើឲ្យព្រះហឫទ័យប្រណីសន្តោសរបស់ព្រះគ្រីស្តប៉ះបេះដូងខ្ញុំ

The mercy of Christ touches my heart

---

ពីម្សិលមិញយើងបានចូលក្នុងពេលវេលានៃការលើកលែងទោស ថ្ងៃស្អែកនេះ យើងនឹងទៅកន្លែងសន្តៈយ៉ូហានប៉ូលទីពីរនិងសន្តីហ្វូស្ទីណា។ នេះជាឱកាសមួយពិសេសដើម្បីទទួលអំណោយទានពីសន្តៈយ៉ូហានប៉ូលទីពីរ ដែលជាគ្រីស្តទូតនៃព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់ និងសន្តីហ្វូស្ទីណាជាលេខានៃព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់ ដោយសារបងស្រីបានកត់ត្រាចូលក្នុងសៀវភៅមួយក្បាល នូវពាក្យពេចន៍ទាំងអស់ ដែលព្រះយេស៊ូនិងព្រះនាងម៉ារីបានបំភ្លឺទៅគាត់ និងបានបង្ហាញខ្លួនឲ្យគាត់ឃើញជារៀងរាល់ថ្ងៃ ។

ថ្ងៃនេះយើងរិះគិតប្រធានបទទីពីរគឺ **"ធ្វើឲ្យព្រះហឫទ័យប្រណីសន្តោសរបស់ព្រះគ្រីស្តប៉ះបេះដូងខ្ញុំ"** មានន័យថាឲ្យសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ចូលនៅក្នុងខ្លួនរបស់ខ្ញុំទៅជាពិសោធរបស់ខ្ញុំផ្ទាល់វិញ។ សម្តេចប៉ាបណែនាំយើងក្នុងទិវាយុវជនពិភពលោកឆ្នាំ២០១៦នេះថា **"យុវជនយុវនារីទាំងអស់ តើប្អូនៗ ក្មួយៗដែលមានពិសោធន៍ថាព្រះបិតាអាណិតមេត្តាស្រឡាញ់អ្នកហើយសេចក្តីស្រឡាញ់របស់ព្រះអង្គគ្មានព្រំដែនដែរឬទេ?។ ព្រះបិតាមិនគិតពីបរាជ័យរបស់យើង មិនគិតពីភាពទន់ខ្សោយរបស់ប្អូនៗ ក្មួយៗ ហើយក៏មិនគិតពីបាបរបស់អ្នកតទៅទៀតដែរ។ ប៉ុន្តែព្រះអង្គយកព្រះហឫទ័យទុកដាក់នឹងអ្នក និងណែនាំ អ្នកឲ្យអាចគិតគូរពីជីវិតទាំងមានសេចក្តីសង្ឃឹម។ តើអ្នកដឹងទេ?"**។ នេះជាសំណួរសម្រាប់យើងនៅថ្ងៃ

---

អប់រំលើកទីពីររបស់លោកអភិបាលអូលីវីយេ
ក្នុងទិវាយុវជនពិភពលោក នៅទីក្រុងក្រាកាវប្រទេសប៉ូឡូញ
ថ្ងៃទី២៨ កក្កដា ២០១៦

នេះតើក្នុងការរស់នៅខ្ញុំធ្លាប់មានពិសោធន៍អំពីព្រះបិតា អាណិតស្រឡាញ់ខ្ញុំដោយគ្មានព្រំដែន ដែរឬទេ? តើប៉ុន្មានដងដែលខ្ញុំបានរំភើបចិត្តដោយដឹងថាព្រះជាម្ចាស់ស្រឡាញ់ខ្ញុំមែន?។ ព្រះជាម្ចាស់ជាសេចក្តីស្រឡាញ់ដែលគ្មានព្រំដែន។

ឆ្នាំ២០០២ ខ្ញុំរស់នៅឯក្រុងកំពតជាមួយលោកបូជាចារ្យសួនហង្សលី។ ពេលធ្វើដំណើរទៅកែប មានកន្លែងមួយជាផ្លូវកោងដែលយើងមើលឃើញតែសមុទ្រគ្មានជាប់អ្វីសោះ ពេលនោះយើងមានអារម្មណ៍ថាឥតមានព្រំដែន ដែលដូចទៅនឹងសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ដែលគ្មានព្រំដែន ដែលធំធេង ដែលណែនាំឲ្យយើងយល់ឃើញថា ឥតមានភាពសៅហ្មងណារាំងសេចក្តីស្រឡាញ់របស់ព្រះអង្គចំពោះយើងបានឡើយ។ នៅពេលយើងមើលឃើញសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់បែបនេះ ណែនាំឲ្យយើងមានពិសោធន៍ថ្មី។ មូលហេតុនេះហើយបានជាស្ត្រីមានបាបម្នាក់បានជូតព្រះបាទាព្រះយេស៊ូផងនិងយំផង ដោយសារនាងដឹងខ្លួនថានាងជាអ្នកមានបាបច្រើន ប៉ុន្តែព្រះយេស៊ូមិនបណ្តេញនាងដូចអ្នកដទៃទេ។ នាងរំភើបចិត្តហើយនាងយំ។

ក្នុងធម្មទេសនាទីមួយរបស់ព្រះយេស៊ូអំពីសុភមង្គល ព្រះអង្គមានព្រះបន្ទូលថា **"អ្នកណាយំសោក អ្នកនោះមានសុភមង្គលហើយ"** គឺអស់អ្នកដែលយំដោយសារមើលឃើញពីសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ចំពោះខ្លួន។ ពេលទទួលអគ្គសញ្ញាលើកលែងទោស ក៏ជាឱកាសមួយនាំឲ្យយើងយំដែរ គឺយើងយំនៅពេលស្តាប់ឮថា **"ខ្ញុំលើកលែងទោសឲ្យកូនតាមរយៈព្រះសហគមន៍ ដោយព្រះនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ។ សូមទៅដោយសុខសាន្តចុះ"** ដែលណែនាំឲ្យយើងមានពិសោធន៍អំពីសេចក្តីស្រឡាញ់គ្មានព្រំដែនរបស់ព្រះជាម្ចាស់ចំពោះយើង។ ព្រះយេស៊ូមិនបណ្តេញខ្ញុំទេ តែព្រះអង្គស្វាគមន៍ខ្ញុំ ស្រឡាញ់ខ្ញុំ និងលើកលែងទោសឲ្យខ្ញុំ។ អ្វីដែលណែនាំឲ្យខ្ញុំរំភើបចិត្ត ឲ្យខ្ញុំទៅជាមនុស្សថ្មី គឺ **"ព្រះហឫទ័យប្រណីសន្តោសរបស់ព្រះគ្រីស្តប៉ះបេះដូងខ្ញុំ"**។

ថ្ងៃនេះយើងមានអត្ថបទពីរ ទី១ជាប្រស្នាអំពីចៀមដែលបាត់ហើយរកឃើញវិញ និងទី២

ជាប្រស្នាអំពីលុយដែលបាត់ហើយរកឃើញវិញ។ ប្រស្នាទី១ **"ក្នុងចំណោមអ្នករាល់គ្នា ឧបមាថាមានម្នាក់មានចៀមមួយរយក្បាល បើគាត់បាត់ចៀមមួយក្បាល គាត់មុខជាទុកចៀមកៅសិបប្រាំបួនចោលនៅទីវាល ហើយទៅតាមរកចៀមដែលបាត់នោះ រហូតទាល់តែបានឃើញវិញ។ កាលរកឃើញហើយ គាត់ត្រេកអរណាស់ គាត់ក៏លើកចៀមដាក់លើ ស្មា"** និងប្រស្នាទី២ **"ឧបមាថាស្ត្រីម្នាក់មានប្រាក់ដប់ដួងហើយបាត់មួយដួង គាត់មុខជាអុជចង្កៀងបោសផ្ទះរក ប្រាក់នោះគ្រប់កៀនកោះ រហូតទាល់តែបានឃើញវិញ ពេលគាត់រកឃើញវិញ គាត់បានអញ្ជើញបងប្អូនដើម្បីបង្ហាញអំណរសប្បាយរបស់គាត់"** ណែនាំឲ្យយើងយល់អំពីធម៌មេត្តាករុណារបស់ព្រះបិតាចំពោះយើង។ ព្រះយេស៊ូខិតខំបង្ហាញដល់សាវ័កនិងបណ្ដាជនជាច្រើនដង ឲ្យដឹងថាព្រះបិតាស្រឡាញ់គេដោយបង្ហាញតាមរបៀបដែលព្រះអង្គស្វាគមន៍គេ តាមរបៀបដែលព្រះអង្គមិនដែលមើលងាយឬបដិសេធនរណាម្នាក់...ប៉ុន្តែ គេនៅតែមិនយល់ដដែល។ ម្ដងនេះទៀត ព្រះយេស៊ូខិតខំបង្ហាញគេអំពីរបៀបដែលព្រះបិតាស្រឡាញ់គេ ដែលមានបួនចំណុចដូចតទៅ៖

ទី១ **"ព្រះបិតាដើររកខ្ញុំ"** (បើយើងមានពេលសូមអានកំណើតពិភពលោកពីជំពូក១ដល់១១)។ ដើមដំបូងព្រះជាម្ចាស់បង្កើតមនុស្សលោក ព្រះអង្គសព្វព្រះហឫទ័យឲ្យមនុស្សលោកថែរក្សាគ្នា ដើម្បីបន្តពូជ។ ក្រោយមកអាដាំនិងអេវ៉ា បានហូបផ្លែឈើដែលព្រះជាម្ចាស់ហាមបណ្ដាលឲ្យពួកគាត់ដឹងថានៅខ្លួនទទេ ហើយពួកគាត់លាក់ខ្លួន។ ពេលនោះព្រះជាម្ចាស់មានសំណួរទៅពួកគាត់ទាំងពីរថា **"នៅឯណា?"**។ សំណួរនេះក៏ជាសំណួរចំពោះយើងសព្វថ្ងៃដែរ។ យើងឃើញថាមិនមែនអាដាំនិងអេវ៉ាឬយើងសព្វថ្ងៃទេដែលតាមរកព្រះជាម្ចាស់ តែជាព្រះជាម្ចាស់ដែលតាមរកអាដាំនិងអេវ៉ា និងយើងសព្វថ្ងៃនេះ។ ដូចក្នុងអត្ថបទកូនពៅដែរ គឺឪពុកដែល រត់ទៅស្វាគមន៍កូនពេលកូនត្រឡប់មកផ្ទះវិញ នេះជារបៀបបង្ហាញថាព្រះជាម្ចាស់ស្រឡាញ់មនុស្សយើង។ អាដាំនិងអេវ៉ាបានទទួលឥទ្ធិពលមិនល្អចូលនៅក្នុងចិត្ត ក្នុងខ្លួនរបស់គេដោយគេមានចិត្តលោភលន់ ចិត្តប្រណែនមិនទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន ហើយឆ្លើយដាក់គ្នា។ អាដាំថាមិនមែនខ្ញុំទេតែជាអេវ៉ា ហើយអេវ៉ាថា មិនមែនខ្ញុំទេតែជាសត្វពស់។ ព្រះជាម្ចាស់តាម

រកអាដាំនិងអេវ៉ា ដូចព្រះអង្គតាមរកខ្ញុំ ព្រះអង្គសួររកខ្ញុំដែលខិតខំលាក់ខ្លួនមិនឲ្យព្រះអង្គឃើញ ថា **"នៅឯណា"**។ យើងមិនត្រូវភ័យខ្លាចព្រះជាម្ចាស់រកឃើញយើងទេ ដ្បិតថានៅពេលព្រះអង្គ រកឃើញយើងនោះព្រះអង្គមិនបានកាត់ក្តីយើង តែព្រះអង្គថែរក្សាយើង។

ទី២ **"ព្រះបិតាថែរក្សាខ្ញុំ"** ដូចគង្វាលដែលបានរកឃើញកូនចៀម គាត់អរសប្បាយហើយ លើកដាក់លើស្មាដោយមិនបានវាយធ្វើបាបចៀមនោះទេ។ ដូចស្ត្រីដែលខិតខំបោសសម្អាតផ្ទះ ដើម្បីស្វែងរកប្រាក់ដែលបាត់ ក្រោយពេលរកឃើញប្រាក់ដែលបាត់នោះគាត់អរសប្បាយ។ ព្រះ-ជាម្ចាស់ប្រៀបដូចជាគង្វាល ប្រៀបដូចជាស្ត្រីដែលខិតខំរកប្រាក់ដែលបាត់ព្រះអង្គតាមរកខ្ញុំ ព្រះអង្គថែរក្សាខ្ញុំ ព្រះអង្គសួរខ្ញុំថា តើខ្ញុំមានឧបសគ្គអ្វីក្នុងការរស់នៅដើម្បីព្រះអង្គជួយកែខ្ញុំ ឲ្យខ្ញុំទៅជាមនុស្សថ្មី។

ទី៣ **"ព្រះបិតាមិនកាត់ក្តីខ្ញុំ មិនវិនិច្ឆ័យខ្ញុំ"**។ ម្សិលមិញយើងស្តាប់អត្ថបទអំពីព្រះយេស៊ូ កំពុងសរសេរលើដីខ្សាច់ ព្រះអង្គសរសេរពាក្យបណ្តឹងរបស់ប្រជាជនចំពោះស្ត្រីមានបាបម្នាក់។ យើងធ្លាប់សរសេរលើដីខ្សាច់ ពេលមានខ្យល់ផាត់មកវាក៏រលុបអស់។ តែអ្វីដែលព្រះជាម្ចាស់ បានសរសេរនៅក្នុងបេះដូងរបស់យើងមិនរលុបទេ ដោយសារព្រះអង្គវាយត្រានៃសេចក្តី ស្រឡាញ់។ យើងបានទទួលសេចក្តីស្រឡាញ់ពីព្រះជាម្ចាស់ តាំងពីយើងទទួលអគ្គសញ្ញា ជ្រមុជទឹក។ នៅប្រទេសអាឡឺម៉ង់ ពេលប្រជាជនចូលជាសាសនិករបស់និកាយកាតូលិក រដ្ឋាភិបាល បានកាត់ពន្ធរាល់ខែពីប្រាក់ខែ សមាជិកផ្ញើទៅព្រះសហគមន៍កាតូលិក។ ប៉ុន្តែរាល់ឆ្នាំមាន មនុស្សជាង១០ម៉ឺននាក់ដែលសុំលុបឈ្មោះ ដោយសារគេអន់ចិត្តនឹងព្រះសហគមន៍ផង និង ដោយសារគេមិនចង់បង់លុយផង។ គេអាចលុបឈ្មោះពីបញ្ជីបង់ពន្ធបាន ប៉ុន្តែឈ្មោះជាគ្រីស្ត បរិស័ទកាតូលិកលុបមិនបានទេ។ ដូចគ្នាដែរពេលយើងទទួលអគ្គសញ្ញាជ្រមុជទឹក គឺយើងទទួល អស់មួយជីវិត។ គ្មានសេចក្តីអាក្រក់ណាលុបសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ចំពោះយើង បានទេ ព្រះជាម្ចាស់នៅតែបន្តធ្វើដំណើរជាមួយយើង ដោយមិនកាត់ក្តីយើង មិនវិនិច្ឆ័យយើង ផ្ទុយទៅវិញ ព្រះអង្គសួរដដែលៗថា **"អ្នកនៅឯណា? អ្នកកំពុងធ្វើអ្វី?"**។ នៅស្រុកកាលីឡេ

ព្រះបន្ទូលទីមួយរបស់ព្រះយេស៊ូគឺ **"ចូរប្រែចិត្តគំនិត និងជឿលើដំណឹងល្អចុះ"** ដែលមានន័យថា សូមស្រឡាញ់ព្រះជាម្ចាស់ និងសូមស្រឡាញ់ព្រះបន្ទូលដែលខ្ញុំប្រកាស។ នេះជាសេចក្ដីសង្ឃឹមមួយយ៉ាងពិសេសសម្រាប់យើង។

ទី៤ **"ព្រះបិតាលើកលែងទោសឲ្យខ្ញុំ ដោយព្រះហឫទ័យអំណរ"**។ អត្ថបទដែលយើងប្រើនៅក្នុងទិវាយុវជនពិភពលោកនេះសុទ្ធតែជាអំណាររបស់ព្រះបិតា។ សូមឲ្យយើងយកចិត្តទុកដាក់ណែនាំបងប្អូនដែលវង្វេង ដែលចេញពីព្រះសហគមន៍ ឲ្យត្រឡប់មកវិញ។ សូមឲ្យយើងដើរតាមរកគេ ប្រមូលគេ លើកទឹកចិត្តគេ ឲ្យគេនឹកឃើញដល់ព្រះបន្ទូលនេះ ដោយប្រាប់គេថាព្រះបិតារង់ចាំទទួលគេដោយអំណរ។ យើងមានឧទាហរណ៍ថា ប្រសិនបើយើងចូលយ៉ាងជ្រៅនៅក្នុងសមុទ្រ ពេលមានខ្យល់ព្យុះបក់មកយ៉ាងខ្លាំងនៅផ្ទៃខាងលើ នោះក៏យើងមិនដឹងថាមានអ្វីកើតឡើងដែរ ដោយសារខ្យល់មិនអាចទៅដល់ក្នុងជម្រៅនៃសមុទ្របានទេ នេះប្រៀបទៅនឹងអំណាររបស់ព្រះជាម្ចាស់ដែលយើងបានទទួល គឺទោះបីមានបញ្ហាណាមួយកើតក្នុងជីវិតរបស់យើង តែបញ្ហានោះមិនប៉ះដល់អំណារក្នុងដួងចិត្តរបស់យើងនោះទេ។ អំណារនេះមិនប្រែប្រួលទេ ដ្បិតជាអំណារដ៏ពេញលក្ខណៈដូចព្រះយេស៊ូមានព្រះបន្ទូលថា **"ខ្ញុំប្រទានអំណារដ៏ពេញលក្ខណៈ"**។

**ចូរមានចិត្តមេត្តា ដូចព្រះបិតា ចូរមានចិត្តមេត្តា ដូចព្រះបិតា**

១. សូមអរព្រះគុណព្រះបិតា ដ្បិតទ្រង់ល្អ
ធម៌មេត្តាករុណារបស់ព្រះអង្គ អស់កល្បជានិច្ច។
២. ព្រះអង្គបានបង្កើតពិភពលោកដោយព្រះប្រាជ្ញាញាណ
ធម៌មេត្តាករុណារបស់ព្រះអង្គ អស់កល្បជានិច្ច។
៣. ព្រះអង្គដឹកនាំប្រជារាស្ត្ររបស់ព្រះអង្គ ទូទាំងប្រវត្តិសាស្ត្រ
ធម៌មេត្តាករុណារបស់ព្រះអង្គ អស់កល្បជានិច្ច។
៤. ព្រះអង្គលើកលែងទោស និងទទួលកូនទាំងអស់

ធម៌មេត្តាករុណារបស់ព្រះអង្គ អស់កល្បជានិច្ច។

**ចូរមានចិត្តមេត្តា ដូចព្រះបិតា ចូរមានចិត្តមេត្តា ដូចព្រះបិតា**

៥. សូមអរព្រះគុណព្រះបុត្រា ជាព្រះពន្លឺនៃប្រជាជាតិទាំងឡាយ

ធម៌មេត្តាករុណារបស់ព្រះអង្គ អស់កល្បជានិច្ច។

៦. ព្រះអង្គស្រឡាញ់យើងដោយព្រះហឫទ័យមេត្តា

ធម៌មេត្តាករុណារបស់ព្រះអង្គ អស់កល្បជានិច្ច។

៧. យើងខ្ញុំបានទទួលអ្វីគ្រប់យ៉ាងពីព្រះជាម្ចាស់

យើងខ្ញុំសូមថ្វាយអ្វីគ្រប់យ៉ាងទៅព្រះជាម្ចាស់វិញ

ធម៌មេត្តាករុណារបស់ព្រះអង្គ អស់កល្បជានិច្ច។

៨. យើងខ្ញុំសូមបើកចិត្តដល់អស់អ្នកដែលឃ្លាន និងស្រេក

ធម៌មេត្តាករុណារបស់ព្រះអង្គ អស់កល្បជានិច្ច។

ពេលព្រះយេស៊ូប្រសូត ជាពេលដែលព្រះជាម្ចាស់បង្ហាញសេចក្តីស្រឡាញ់ដល់មនុស្សយើង ដូចមានចែងក្នុងយ៉ូហានជំពូក៣ ខ ១៦ថា **"ព្រះជាម្ចាស់បានស្រឡាញ់មនុស្សលោកយ៉ាងខ្លាំងណាស់ ហេតុនេះហើយ ព្រះអង្គបានចាត់ឲ្យព្រះបុត្រាយាងមកដើម្បីសង្គ្រោះមនុស្សលោក"**។ ប្រសិនបើយើងបានអានអត្ថបទព្រះគម្ពីរពីកំណើតពិភពលោករហូតដល់ព្រះយេស៊ូប្រសូត នោះយើងនឹងឃើញពីប្រវត្តិនៃការសង្គ្រោះ ដែលព្រះជាម្ចាស់ខិតខំបង្កើតសម្ព័ន្ធមេត្រីរវាងយើងនឹងព្រះអង្គ។ មនុស្សយើងចេះតែបាក់បែករវាងគ្នាឯង និងបែកចេញពីព្រះជាម្ចាស់ ប៉ុន្តែព្រះជាម្ចាស់ខិតខំផ្សះផ្សា រហូតដល់ព្រះអង្គផ្ញើព្រះបុត្រាមកក្នុងលោកនេះ បង្ហាញថាព្រះ-អង្គស្រឡាញ់យើង។ ប៉ុន្តែមនុស្សយើងបានចាប់ព្រះបុត្រាព្រះអង្គយកទៅធ្វើគត តែព្រះជាម្ចាស់បានប្រោសឲ្យព្រះបុត្រាមានព្រះជន្មរស់ឡើងវិញ អស់កល្បជានិច្ច។

២.០០០ឆ្នាំកន្លងមកហើយដែលព្រះយេស៊ូសូមឲ្យយើងចេះស្រឡាញ់គ្នា ឲ្យយើងបង្កើតពិភពលោកដែលមានយុត្តិធម៌ ដែលមានសេចក្តីស្រឡាញ់ ដែលមានការលើកលែងទោស។

ប៉ុន្តែសង្គ្រាមនៅតែមាន ធ្វើឲ្យព្រះជាម្ចាស់ឈឺចាប់ជាទីបំផុត។ ដើម្បីឲ្យយើងយល់ពីរបៀបដែលព្រះជាម្ចាស់ស្រឡាញ់យើង នោះសូមឲ្យយើងសម្លឹងមើលក្រោលសត្វជាកន្លែងដែលព្រះយេស៊ូប្រសូត។ តាមរបៀបដែលព្រះយេស៊ូប្រសូត យើងអាចយល់ពីសេចក្តីស្រឡាញ់របស់ព្រះជា-ម្ចាស់ចំពោះមនុស្សយើង និងយល់ពីគម្រោងការរបស់ព្រះជាម្ចាស់ចំពោះយើងជាព្រះសហ-គមន៍។ ព្រះជាម្ចាស់ចង់ឲ្យយើងកសាងព្រះសហគមន៍ ដែលចេះសម្តែងធម៌មេត្តាករុណា។ ហេតុដូច្នេះហើយ សូមឲ្យយើងធ្វើដំណើរនៅក្នុងអារាមសម្ងាត់របស់យើង ដើម្បីឃើញព្រះយេស៊ូប្រសូតឃើញព្រះយេស៊ូសោយទិវង្គត និងឃើញព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ។

កន្លែងដែលសន្តៈម៉ាស៊ីមាំងកុលស្លាប់ ក៏ជាកន្លែងដែលស្ត្រីជាតិយូដាម្នាក់ឈ្មោះអេដីស្តាមស្លាប់ដែរ។ គាត់រស់នៅបែលហ្សិក គាត់ចូលនៅក្នុងអារាមសម្ងាត់របស់សន្តីតេរេសាហើយក្លាយជាបេណេឌីកដឹឡាហ្វូ។ អេដីស្តាមជាសន្តីដ៏ពិសេស ដ្បិតគាត់ជាទស្សនវិទូដ៏ឧត្តមក្នុងសាសនាយូដា ដែលបានប្រែចិត្តគំនិត។ ថ្ងៃមួយគាត់បានដើរទៅផ្សារតាមផ្លូវមួយដែលមានព្រះវិហារកាតូលិក។ គាត់ឃើញមានស្ត្រីម្នាក់មកពីផ្សារចូលក្នុងព្រះវិហារនោះរួចចេញមកវិញណែនាំឲ្យអេដីស្តាមឆ្ងល់ថា ហេតុអ្វីគេចូលក្នុងព្រះវិហារនេះ?។ គាត់ចាប់ផ្តើមរិះគិតហើយយល់ថាគេចូលក្នុងព្រះវិហារនេះដើម្បីជួបមនុស្សម្នាក់ឈ្មោះយេស៊ូ។ ក្រោយមកអេដីស្តាមបានប្រែចិត្តគំនិត ក្លាយជាអ្នកដែលស្រឡាញ់ព្រះយេស៊ូយ៉ាងខ្លាំង រហូតដល់គាត់សម្រេចចិត្តចូលបួសក្នុងអារាមសម្ងាត់កាម៉ែលដែល ក្រោយមកទាហានអាឡឺម៉ង់ចាប់គាត់យកទៅសម្លាប់។ គាត់បានសរសេរសៀវភៅច្រើនក្បាល ក្នុងនោះមានសៀវភៅមួយក្បាលមានចំណងជើងថា **"ពីក្រោលគោរហូតដល់ឈើឆ្កាង"**។ ក្នុងសៀវភៅនោះគាត់បង្ហាញថា ជីវិតគ្រីស្តបរិស័ទគឺជាជីវិតដែលសរុបចូលគ្នានូវព្រឹត្តិការណ៍ពីរ គឺព្រះយេស៊ូប្រសូតនិងព្រះយេស៊ូសោយទិវង្គត។ ជាដំបូងព្រះជាម្ចាស់បានបង្ហាញសេចក្តីស្រឡាញ់របស់ព្រះអង្គនៅថ្ងៃដែលព្រះយេស៊ូប្រសូត។ ដូច្នេះពេលបងប្អូនចូលក្នុងអារាមសម្ងាត់របស់ខ្លួន សូមនឹកដល់ក្រោលគោនិងឈើឆ្កាង ដែលជាពន្លឺមកពីព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ។ របៀបព្រះយេស៊ូប្រសូត ណែនាំឲ្យយើងយល់ពីអ្វី

ដែលព្រះអង្គចង់ណែនាំយើង គឺ៖

**១ ព្រះយេស៊ូប្រសូតនៅក្រោលគោជាកន្លែងសាមញ្ញបំផុត** មានន័យថាព្រះជាម្ចាស់យាងមកមិនមែនដើម្បីឲ្យមនុស្សអស្ចារ្យស្វាគមន៍ព្រះអង្គទេ។ ហេតុនេះហើយ យើងត្រូវកសាងជីវិតរបស់យើង កសាងព្រះសហគមន៍របស់យើង តាមរបៀបដែលបងប្អូនទាំងអស់អាចមកស្វាគមន៍ព្រះយេស៊ូ និងស្រឡាញ់ព្រះយេស៊ូបាន។

**២ អ្នកដែលទៅថ្វាយបង្គំព្រះយេស៊ូមុនគេបង្អស់គឺជាពួកគង្វាល** នេះមានន័យថាព្រះ-ជាម្ចាស់ស្រឡាញ់មនុស្សទាំងអស់ ជាពិសេសមនុស្សតូចតាច។ ប្រសិនបើព្រះយេស៊ូប្រសូតនៅកន្លែងមួយអស្ចារ្យ នោះពួកគង្វាលមិនអាចចូលទៅជិតព្រះអង្គបានទេ។ ដោយហេតុនេះហើយបានជាយើងត្រូវរៀបចំទីកន្លែងព្រះយេស៊ូប្រសូតឲ្យបានសមរម្យ សម្រាប់ឲ្យអ្នកតូចតាចអាចមកថ្វាយបង្គំព្រះយេស៊ូ និងអាចមកទទួលការស្វាគមន៍ពីយើងជាព្រះសហគមន៍បាន។

**៣ "ព្រះនាងម៉ារីកំពុងសម្លឹងមើលបុត្ររបស់ព្រះនាងដែលបានប្រសូតមក** ក្នុងរបៀបអធិដ្ឋាន" នេះជារបៀបដែលព្រះជាម្ចាស់អញ្ជើញយើង ឲ្យសម្លឹងមើលព្រះយេស៊ូទុកនៅក្នុងដួងចិត្តរបស់យើងជានិច្ច ដើម្បីឲ្យចិត្តរបស់យើងជាប់នឹងការអធិដ្ឋាន។

**៤ លោកយ៉ូសែបបានថែរក្សាព្រះនាងម៉ារី** ដែលលោកប្រៀបដូចជាអ្នកបម្រើម្យ៉ាង ដូច្នេះព្រះសហគមន៍របស់យើងក៏ត្រូវតែជាព្រះសហគមន៍ដែលចេះបម្រើ ដែលចេះអធិដ្ឋាន និងដែលចេះស្វាគមន៍មនុស្សទាំងអស់ នៅក្នុងរបៀបដ៏សាមញ្ញធម្មតា។

**៥ "មានទេវទូតជាច្រើនចុះពីស្ថានបរមសុខ មកច្រៀងកោតសរសើរសេរីរុងរឿងរបស់ព្រះជាម្ចាស់"**។ នេះជាសញ្ញាសម្គាល់នៃអំណរសប្បាយ ដើម្បីអបអរសាទរព្រះសង្គ្រោះដែលប្រសូតមក ជាមនុស្ស ណែនាំឲ្យមនុស្សទាំងអស់នៅលើផែនដី ទទួលសេចក្តីសុខសាន្ត។ ទេវទូតចែកអំណរសប្បាយដែលមកពីព្រះជាម្ចាស់ ដល់មនុស្សលោក។

៦ **"មានពន្លឺធ្លាក់ពីលើមេឃ មានផ្កាយបំភ្លឺក្រុមគ្រួសារដ៏វិសុទ្ធ មានព្រះឱរសយេស៊ូ មានសន្តៈយ៉ូសែប មានព្រះនាងម៉ារី"** នេះមានន័យថា ពិតមែនសេចក្តីស្រឡាញ់យាងមកនៅក្នុងអំណរ។

៧ **"មានហោរាចារ្យមកពីគ្រប់ទីកន្លែង"** មានន័យថា ព្រះយេស៊ូយាងមកសម្រាប់មនុស្សទាំងអស់ ហើយមនុស្សទាំងអស់អាចទទួលជីវិតថ្មីពីព្រះយេស៊ូ។ ព្រឹត្តិការណ៍នៅថ្ងៃដែលព្រះយេស៊ូប្រសូត ណែនាំឲ្យយើងឃើញពីលក្ខណៈរបស់ព្រះសហគមន៍ដែលគាប់ព្រះហឫទ័យព្រះជាម្ចាស់ គឺជាព្រះសហគមន៍ដែលអធិដ្ឋាន ដែលបម្រើ ដែលចេះជួយអ្នកដទៃ ដែលស្រឡាញ់ ដែលស្វាគមន៍ ដែលសាមញ្ញ ដែលផ្តល់ភាពកក់ក្តៅដល់មនុស្សទាំងអស់ ដែលប្រកាសដំណឹងល្អក្នុងពិភពលោកទាំងមូល និងដែលមានអំណរ សេចក្តីសុខសាន្តមកពីព្រះជាម្ចាស់។ មនុស្សយើងមិនអាចរស់នៅដោយគ្មានព្រះជាម្ចាស់បានទេ ដ្បិតព្រះជាម្ចាស់ជាពន្លឺដែលណែនាំឲ្យយើងបង្កើតទំនាក់ទំនងរវាងគ្នានឹងគ្នា និងឲ្យយើងទទួលជីវិតថ្មីដ៏ពេញលក្ខណៈពីព្រះអង្គ គឺជាជីវិតដែលយើងចូលរួមជាមួយព្រះជាម្ចាស់។ យើងមានពិសោធន៍អំពីព្រះជាម្ចាស់ស្រឡាញ់យើង ដូចព្រះនាងម៉ារីក្រោយពីបានជួបទេវទូតហើយ ព្រះនាងប្រញាប់ប្រញាល់ចេញទៅចែករំលែកអំណរសប្បាយជាមួយយាយអេលីបែត។

ថ្ងៃនេះ ព្រះយេស៊ូយាងមកដើម្បីនិយាយជាមួយខ្ញុំ និងដើម្បីប៉ះបេះដូងខ្ញុំ ឲ្យខ្ញុំមានពិសោធន៍អំពីសេចក្តីស្រឡាញ់មួយយ៉ាងពិសេស តាមរយៈការលើកលែងទោស។ សូមឲ្យយើងយកចិត្តទុកដាក់ទទួលអគ្គសញ្ញាលើកលែងទោស ដើម្បីឲ្យជីវិតរបស់យើងចូលយ៉ាងជ្រៅនៅក្នុងពិសោធន៍នៃសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ចំពោះយើង ឲ្យយើងយល់អំពីរបៀបដែលព្រះជាម្ចាស់ថែរក្សាយើង និងអំពីរបៀបដែលព្រះជាម្ចាស់មិនវិនិច្ឆ័យយើង។

ដោយព្រះនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ

បពិត្រព្រះជាម្ចាស់ជាព្រះបិតា យើងខ្ញុំសូមអរព្រះគុណព្រះអង្គ ដែលបានណែនាំឲ្យយើងខ្ញុំមកជួបជុំគ្នាជាមួយយុវជនពិភពលោកទាំងមូល ឲ្យយើងខ្ញុំជួបជាមួយព្រះជាម្ចាស់ជាព្រះបិតា

ជាពិសេសឲ្យយើងខ្ញុំមានឱកាសសម្លឹងមើលព្រះគ្រីស្ត ដែលបានបង្ហាញពីរបៀបព្រះបិតាស្រឡាញ់យើងខ្ញុំ។ យើងខ្ញុំសូមអរព្រះគុណព្រះជាម្ចាស់ជាព្រះបិតាសូមព្រះអង្គគង់នៅជាមួយយើងខ្ញុំ ដើម្បីឲ្យយើងខ្ញុំមានអំណរសប្បាយដ៏ស្ថិតស្ថេរ ដោយសារព្រះបិតាស្រឡាញ់យើងខ្ញុំ ដោយសារព្រះបិតាដើរតាមរកយើងខ្ញុំ ដោយសារព្រះបិតាថែរក្សាយើងខ្ញុំ និងដោយសារព្រះបិតាលើកលែងទោសឲ្យយើងខ្ញុំជានិច្ច។

**"ខ្ញុំលើកលែងទោសឲ្យកូនតាម រយៈព្រះសហគមន៍ ដោយព្រះនាមព្រះបិតា ព្រះបុត្រា និងព្រះវិសញ្ញាណដ៏វិសុទ្ធ។ សូមទៅ ដោយសុខសាន្តចុះ"**

# ទ្រព្យសម្បត្តិដែលយើងបានទទួលពីព្រះជាម្ចាស់គឺសេចក្ដីស្រឡាញ់១00%

## The treasure we have received from God is  love 100%

អត្ថបទទី១៖ ករថ ៥, ១៧-២១
ដំណឹងល្អ៖ លក ១៥, ១-៣. ១១-៣២

ថ្ងៃនេះជាពេលវេលាមួយ ដើម្បីយើងអធិដ្ឋានសម្រុះសម្រួលនៅក្នុងព្រះសហគមន៍ និងនៅក្នុងពិភពលោកទាំងមូល។ នៅក្នុងអត្ថបទទីមួយ **"ប្រសិនបើអ្នកណាម្នាក់នៅរួមជាមួយព្រះគ្រីស្ត អ្នកនោះបានកើតជាថ្មី"** នេះជាដំណឹងល្អមួយសម្រាប់យើង។ យើងទៅជាមនុស្សថ្មី ដូច្នេះយើងត្រូវការគិតពីឥទ្ធិពលដែលមាននៅក្នុងជីវិតរបស់យើង ជាពិសេសបងប្អូននៅទីនេះបានទទួលអគ្គសញ្ញាជ្រមុជទឹកថ្មីៗ មិនមែនពីក្មេងមកទេ ដូច្នេះពេលយើងស្ដាប់ឮថា **"បើអ្នកណាម្នាក់រួមជាមួយព្រះគ្រីស្ត អ្នកនោះបានកើតជាថ្មី"** នោះនាំឲ្យបងប្អូននឹកឃើញពីអគ្គសញ្ញាជ្រមុជទឹករបស់ខ្លួន។ យើងបន្តកើតជាថ្មីជារៀងរាល់ថ្ងៃ ដូចលោកនីកូដេមបានទូលសួរទៅព្រះយេស៊ូថា **"តើខ្ញុំត្រូវធ្វើយ៉ាងដូចម្ដេចដើម្បីបានកើតជាមនុស្សថ្មី?"**។

ព្រះយេស៊ូណែនាំឲ្យយើងធ្វើជាមនុស្សថ្មី ដោយសារយើងសុខចិត្តប្រែចិត្តគំនិត និងជឿលើព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដែលណែនាំឲ្យជីវិតរបស់យើងបន្តិចម្ដងៗទៅជាជីវិតថ្មី។ ជីវិតរបស់យើង ប្រៀបដូចជាផ្លូវមិនល្អដែលមានគ្រលុក មានទឹកដក់ ពិបាកធ្វើដំណើរ។ ប៉ុន្តែយើងត្រូវតែធ្វើឲ្យជីវិតរបស់យើងបន្តិចម្ដងៗទៅជាជីវិតមួយយ៉ាងស្អាតដោយសារយើងទទួល

អភិបូជាជាភាសាខ្មែរទី១ ក្នុងទិវាយុវជនពិភពលោក
នៅទីក្រុងក្រាកាវប្រទេសប៉ូឡូញ
ថ្ងៃទី២៨ កក្កដា ២០១៦

សេចក្ដីស្រឡាញ់ និងអំណរសប្បាយមកពីព្រះជាម្ចាស់។ តាមអត្ថបទទីមួយដែលយើងបានស្ដាប់ គឺយើងទទួលមុខងារពីរយ៉ាងដើម្បីទៅជាមនុស្សថ្មី គឺ ៖

ទីមួយ **"សម្រុះសម្រួលមនុស្សម្នាឲ្យជានានឹងព្រះជាម្ចាស់វិញ"** ដោយឲ្យយើងខិតខំណែនាំមនុស្ស គ្រប់គ្នាឲ្យគេស្រុះស្រួលជាមួយព្រះជាម្ចាស់។ នៅក្នុងពិភពលោកសព្វថ្ងៃមានភាពកម្សត់ទុគ៌តបីយ៉ាង គឺ៖ ទី១ អ្នកដែលខ្វះសម្ភារៈ ខ្វះម្ហូបអាហារ ទី២ អ្នកដែលខ្វះសីលធម៌ ខ្វះផ្លូវដើរ ទី៣ អ្នកដែលខ្វះទំនាក់ទំនងជាមួយព្រះជាម្ចាស់។ មានមនុស្សជាច្រើនដែលបែកចេញពីព្រះជាម្ចាស់។ ដូច្នេះតួនាទីរបស់យើង គឺសម្រុះសម្រួលមនុស្សទាំងអស់នោះឲ្យមកជានានឹងព្រះជាម្ចាស់វិញ។

ទីពីរ **"យើងជាទូតរបស់ព្រះជាម្ចាស់ ជាទូតរបស់ព្រះគ្រីស្ដ"**។ ព្រះជាម្ចាស់មានព្រះបន្ទូលជាស់តឿនបងប្អូនឯទៀតៗតាមរយៈយើង។ សាសនាទូតក្ដី ទេវទូតក្ដី គ្រីស្ដទូតក្ដី គឺជាព្រះជាម្ចាស់ផ្ទាល់ ដែលបានជ្រើសរើសដើម្បីឲ្យបំពេញកិច្ចការថ្វាយព្រះអង្គ។ ព្រះជាម្ចាស់ក៏ជ្រើសរើសយើងដែរ ដើម្បីឲ្យយើងទៅជាទូតរបស់ព្រះគ្រីស្ដបង្ហាញព្រះគ្រីស្ដដល់បងប្អូនឯទៀតៗតាមរបៀបយើងរស់នៅ។

កាលពីឆ្នាំ១៩៩៧ យើងមានទិវាយុវជនពិភពលោកនៅទីក្រុងប៉ារីសប្រទេសបារាំង។ ប្រទេសនេះមានគ្រីស្ដបរិស័ទជាច្រើនភ្លេចសាសនារបស់ខ្លួន។ មុនចាប់ផ្ដើមទិវាយុវជន មានប្រជាជនបារាំងជាច្រើននិយាយថាកម្មវិធីនេះគ្មានន័យ និងគ្មានមនុស្សចូលរួមទេ។ ប៉ុន្តែពេលគេឃើញមានយុវជនជាច្រើនមកពីទូទាំងពិភពលោកទាំងមូល ជួបជុំគ្នានៅក្បែរទូអេសហ្វែលដើម្បីស្វាគមន៍សម្ដេចប៉ាបយ៉ូហានប៉ូលទីពីរ និងពេញមួយអាទិត្យនៅទីក្រុងប៉ារីសគេឃើញមានការជួបជុំគ្នាដ៏ធំច្រៀងកោតសរសើរព្រះជាម្ចាស់ នោះបានធ្វើឲ្យជនជាតិបារាំងភ្ញាក់ស្មារតី។ នេះជារបៀបដែលយើងធ្វើជាទូតដើម្បីផ្ដល់សក្ខីភាព ដើម្បីនាំឲ្យយុវជនជាច្រើនប្រែចិត្តគំនិត។ រហូតដល់ទិវាយុវជនពិភពលោកនៅទីក្រុងក្រាកាវនេះ យុវជនដែលមកចូលរួមច្រើនជាងគេគឺជាយុវជនបារាំង។

របៀបដែលយើងប្រកាសដំណឹងល្អមានឥទ្ធិពលណាស់។ សម្រាប់យើងជាយុវជនមកពីប្រទេសកម្ពុជា សូមឲ្យយើងគិតពីរបៀបយើងផ្ដល់សក្ខីភាពប្រចាំថ្ងៃ។ យើងទៅជាទូតរបស់ព្រះគ្រីស្ទពិតមែននៅពេលណាយើងចេះបង្ហាញអំណរសប្បាយ និងសេចក្ដីស្រឡាញ់ដូចឪពុកនៅក្នុងព្រះគម្ពីរដែលយើងបានស្ដាប់នៅថ្ងៃនេះ។ យើងដូចឪពុកដែលចែកទ្រព្យសម្បត្តិឲ្យកូនភ្លាមនៅពេលកូនសុំ។ ចំពោះយើង ទ្រព្យសម្បត្តិដែលយើងបានទទួលពីព្រះជាម្ចាស់គឺជីវិតដ៏ពេញលក្ខណៈ និងសេចក្ដីស្រឡាញ់ដ៏ពេញបរិបូរណ៍របស់ព្រះអង្គ។ ព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យយើងមានជីវិតដ៏ពេញលក្ខណៈនេះ ឲ្យយើងមានសេចក្ដីស្រឡាញ់ដ៏ពេញបរិបូណ៌នេះ ដ្បិតអីបញ្ហាដ៏ធំនៅក្នុងពិភពលោករបស់យើងសព្វថ្ងៃ គឺការខ្វះសេចក្ដីស្រឡាញ់ និងការសម្លាប់ទារកនៅក្នុងផ្ទៃ ជាជីវិតដំបូង ជាជីវិតដែលដែលមកពីព្រះជាម្ចាស់។ យើងទាំងអស់គ្នាបានទទួលជីវិត ដូច្នេះយើងត្រូវតែថែរក្សាជីវិតនិងស្រឡាញ់ជីវិត។ ទោះបីកូនខ្សោយកូនដួលក៏ឪពុកនៅតែស្វាគមន៍កូនជានិច្ច ព្រោះឪពុកបានយល់ពីបញ្ហារបស់កូន។ កាលឪពុកបានឃើញកូនពីចម្ងាយ គាត់មានចិត្តអាណិតអាសូរកូនក្រៃលែងក៏រត់ទៅទទួលកូន និងឱបថើបកូនទៀតផង។ ក្រោយមកគាត់រៀបចំពិធីជប់លៀងដើម្បីឲ្យកូនសប្បាយចិត្ត ដើម្បីឲ្យកូនដឹងថាជីវិតគេមានតម្លៃពិតមែន។ នេះជារបៀបដែលព្រះបិតាស្រឡាញ់យើង។

ថ្ងៃនេះយើងខ្ញុំសប្បាយចិត្ត យើងខ្ញុំសូមអរព្រះគុណព្រះជាម្ចាស់ ដោយសារព្រះអង្គបានជ្រើសរើសឲ្យយើងខ្ញុំធ្វើជាទូតរបស់ព្រះគ្រីស្ត ដើម្បីសម្រុះសម្រួលមនុស្សលោកនិងព្រះជាម្ចាស់ និងដើម្បីឲ្យយើងខ្ញុំទទួលជីវិតថ្មីជានិច្ច ដោយសារយើងខ្ញុំជាប់ជាមួយព្រះគ្រីស្ត។ សូមអរព្រះគុណព្រះជាម្ចាស់សូមព្រះអង្គជួយឲ្យយើងខ្ញុំ បន្តធ្វើដំណើរនៅក្នុងអារាមសម្ងាត់នៃដួងចិត្តរបស់យើងខ្ញុំ ដើម្បីជួបព្រះយេស៊ូដែលគង់នៅក្នុងដួងចិត្តរបស់យើងខ្ញុំតាំងពីយូរមកហើយ។

# សូមព្រះអង្គប្រោសប្រណីឲ្យខ្ញុំមានចិត្តមេត្តាករុណាដូចព្រះអង្គ

Be merciful, just as your Father is merciful

បពិត្រព្រះអម្ចាស់ជាព្រះបិតា! យើងខ្ញុំសូមអរព្រះគុណព្រះអង្គ ដែលបានណែនាំឲ្យយើងខ្ញុំធ្វើដំណើរដ៏វិសុទ្ធនៅថ្ងៃនេះ រួមជាមួយសម្ដេចប៉ាបយ៉ូហានប៉ូលទីពីរនិងសន្ដីហ្វូស្ទីណា ដែលណែនាំឲ្យយើងខ្ញុំស្គាល់ធម៌មេត្តាករុណារបស់ព្រះអង្គថែមទៀត សម្រាប់ជីវិតរបស់យើងខ្ញុំផ្ទាល់។

បពិត្រព្រះបិតា!សូមព្រះអង្គប្រទានពរឲ្យយើងខ្ញុំទាំងអស់គ្នាជាតំណាងព្រះសហគមន៍កាតូលិកនៅប្រទេសកម្ពុជា ប្រទានពរឲ្យយុវជនទាំងអស់ដែលមកពីទូទាំងពិភពលោកទាំងមូល ដែលជួបជុំគ្នាដើម្បីបង្ហាញជំនឿ បង្ហាញសេចក្ដីស្រឡាញ់។

បពិត្រព្រះអម្ចាស់ជាព្រះបិតា!ថ្ងៃនេះព្រះអង្គណែនាំឲ្យយើងខ្ញុំទាំងអស់គ្នា ទៅជាឧបករណ៍នៃធម៌មេត្តាករុណារបស់ព្រះអង្គសម្រាប់ពិភពលោកទាំងមូល។ សូមព្រះអង្គជួយឲ្យយើងខ្ញុំភ្ញាក់ស្មារតីឲ្យយើងខ្ញុំឈរឡើងដើម្បីទៅប្រកាសដំណឹងល្អដល់ពិភពលោកទាំងមូល ជាពិសេសដល់បងប្អូនប្រជាជនកម្ពុជាយើងខ្ញុំ។ យើងខ្ញុំសូមទូលអង្វរព្រះអង្គ ក្នុងនាមព្រះយេស៊ូជាព្រះគ្រីស្ដ និងជាព្រះអម្ចាស់យើងខ្ញុំ។ ដោយព្រះនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ។

---

អបអរំលើកទីបីរបស់លោកអភិបាលអូលីវីយេ
ក្នុងទិវាយុវជនពិភពលោក នៅទីក្រុងក្រាកាវប្រទេសប៉ូឡូញ
ថ្ងៃទី២៩ កក្កដា ២០១៦

ម្សិលមិញយើងបានជួបជាមួយសម្តេចប៉ាប ប៉ុន្តែអ្នកខ្លះមានសំណាងជាង ដោយសារបានឃើញសម្តេចប៉ាបពីទីជិតនៅតាមផ្លូវដែលគេទៅយកម្ហូប។ វាមិនមែនជាការចៃដន្យទេសម្រាប់យើងជាគ្រីស្តបរិស័ទ អ្វីៗទាំងអស់ដែលបានកើតឡើង គឺជាសញ្ញាសម្គាល់ពីវត្តមានរបស់ព្រះជាម្ចាស់សម្រាប់ជីវិតរបស់យើង។ សម្តេចប៉ាបចង់ឃើញ និងចង់ជួបយើងជាព្រះសហគមន៍មកពីប្រទេសកម្ពុជា។ ថ្ងៃនេះ យើងមកទាន់ពេលវេលាក្នុងដំណើរបូជនិយស៍របស់យើង គឺយើងបានចូលទៅដល់កន្លែងសន្តៈយ៉ូហានប៉ូលទី២ ទៅដល់កន្លែងបងស្រីហ្វូស្ទីណាដែលមានបងស្រីម្នាក់កំពុងពន្យល់ជាភាសាបារាំងហើយខ្ញុំជាអ្នកបកប្រែ។ យើងបានចូលទៅយ៉ាងស្រួលដែល២០នាទីក្រោយមក មានមនុស្សជាច្រើនបានចូលទៅដល់ដែរ ប៉ុន្តែពិបាកនឹងចូលមកដល់ខាងក្នុងនេះណាស់។ កុំគិតថាជាការចៃដន្យ គឺជាព្រះជាម្ចាស់ដែលបានរៀបចំសម្រាប់យើង។

ថ្ងៃនេះ សូមឲ្យយើងម្នាក់ៗទទួលស្គាល់ថាមានវត្តមានរបស់ព្រះជាម្ចាស់ពិតមែននៅក្នុងជីវិតរបស់យើង ហើយប្រសិនបើពីមួយថ្ងៃទៅមួយថ្ងៃ យើងរកឃើញសញ្ញាសម្គាល់របៀបនេះនៅក្នុងជីវិតរបស់យើងនោះយើងមុខជានឹងមានសេចក្តីសុខមានសេរីភាពមានកម្លាំងពេញខ្លួនពីព្រះជាម្ចាស់ដែលគង់នៅក្នុងជីវិតប្រចាំថ្ងៃរបស់យើង។ ដូច្នេះរាល់យប់មុនចូលដំណេកសូមឲ្យយើងនឹកឃើញសេចក្តីនេះ និងរាល់ពេលភ្ញាក់ពីដំណេក សូមឲ្យនឹកឃើញពីព្រះយេស៊ូប្រសូតព្រះយេស៊ូសោយទិវង្គត និងព្រះយេស៊ូមានជន្មរស់ឡើងវិញ ដើម្បីយើងចូលនៅក្នុងប្រវត្តិសាស្ត្រនៃការសង្គ្រោះ ដែលមានក្រោលគោ ឈើឆ្កាង និងពន្លឺ។

នៅពេលចូលដំណេកយើងត្រូវនឹកថា **"តើថ្ងៃនេះ មានសញ្ញាអ្វីពិសេសមកពីព្រះជាម្ចាស់សម្រាប់ខ្ញុំ?"** ត្រូវជឿជាក់ថា អ្វីទាំងអស់ដែលបានកើតឡើងចំពោះយើង មិនមែនជាការចៃដន្យដូចយើងគិតនោះទេគឺជាព្រះជាម្ចាស់ដែលបានរៀបចំទុកជាមុន ដើម្បីឲ្យយើងយល់ថា ព្រះអង្គមានវត្តមានគង់នៅក្នុងខ្លួនយើង។ កុំភ្លេចពីរបៀបដែលលោកអភិបាលអេមីលបានទទួលមរណភាព ខ្ញុំសូមរំឭកបងប្អូនថា តាមពិតលោកអភិបាលអេមីលត្រូវទទួលមរណភាពមួយខែមុន មុនពេលលោកទទួលមរណភាពទៅទៀត ដ្បិតសុខភាពរបស់លោកធ្ងន់ធ្ងរណាស់ ប៉ុន្តែ

លោកទទួលមរណភាពនៅម៉ោង១១ពេលថ្ងៃជិតត្រង់ នៅពេលយើងកំពុងសូត្រផ្គាំត្រង់វគ្គព្រះយេស៊ូជិតផុតដង្ហើម គឺ១៥នាទីក្រោយពេលយើងថ្វាយអភិបូជាជាមួយលោករួចហើយ។ នេះមិនមែនចៃដន្យទេ គឺជាព្រះជាម្ចាស់ដែលបានរៀបចំពេលវេលាសម្រាប់ឲ្យលោកទទួលមរណភាព ដែលអស់មួយជីវិត លោកបានផ្ញើជីវិតទាំងស្រុងលើព្រះជាម្ចាស់។

រាល់ថ្ងៃ សូមឲ្យយើងសម្លឹងរកមើលសញ្ញាផ្សេងៗ ដែលព្រះជាម្ចាស់បានរៀបចំសម្រាប់យើងម្នាក់ៗ ដើម្បីអរព្រះគុណព្រះអង្គ និងដើម្បីបន្តិចម្តងៗយើងមានទំនាក់ទំនងកាន់តែជិតស្និទ្ធឡើងជាមួយព្រះអង្គ។ ថ្ងៃនេះពេលខ្ញុំចូលក្នុងព្រះវិហារ ស្រាប់តែមានមនុស្សមួយក្រុមមកសុំថតរូបជាមួយខ្ញុំ ក្រោយមកខ្ញុំសួរថាគេមកពីប្រទេសណា គេប្រាប់ខ្ញុំថាមកពីប្រទេសចិន ដែលនៅជាប់នឹងខ្លួនខ្ញុំ មានជាតុរបស់សន្តបុគ្គលមកពីប្រទេសចិន។ នេះជាការរៀបចំរបស់ព្រះជាម្ចាស់។

ប្រធានបទនៅថ្ងៃទីមួយជួយឲ្យយើងយល់ថា **"ដល់ពេលដែលយើងទទួលអគ្គសញ្ញាលើកលែងទោស"**។ ប្រធានបទនៅថ្ងៃទីពីរ ជួយឲ្យយើងយល់ថា **"ព្រះហឫទ័យប្រណីសន្តោសរបស់ព្រះគ្រីស្តប៉ះបេះដូងខ្ញុំ"** និងប្រធានបទថ្ងៃទីបីនេះ គឺ **"ឱព្រះអម្ចាស់អើយ! សូមព្រះអង្គប្រោសប្រណីឲ្យខ្ញុំមានចិត្តមេត្តាករុណាដូចព្រះអង្គ"**។ក្នុងពាក្យអធិដ្ឋានរបស់បងស្រីហ្វូស្ទីណាបានណែនាំឲ្យយើងចាប់អារម្មណ៍ប្រើសរីរាង្គរបស់យើង ដើម្បីសម្តែងធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ គឺ៖

**១. ភ្នែក ឲ្យភ្នែករបស់យើងមើលឃើញទុក្ខលំបាករបស់បងប្អូនឯទៀតៗ**
**២. ត្រចៀក ឲ្យត្រចៀករបស់យើង ស្តាប់ឮពីទុក្ខលំបាករបស់បងប្អូនឯទៀតៗ**
**៣. មាត់ ឲ្យមាត់របស់យើង បញ្ចេញសម្លេងលើកទឹកចិត្ត និងលើកលែងទោសឲ្យបងប្អូនឯទៀតៗ**
**៤. ដៃ ឲ្យដៃរបស់យើង ធ្វើកិច្ចការមេត្តាករុណា។**
**៥. បេះដូង ឲ្យបេះដូងរបស់យើង ស្រឡាញ់មនុស្សទាំងអស់។**

### ៦. ជើង ឲ្យជើងរបស់យើង ដើរទៅជួយអ្នកដទៃ។

រូបព្រះយេស៊ូដែលបងស្រីហ្វូស្ទីណាបានគូរ គឺព្រះយេស៊ូមានភ្នែកស្រទន់ បង្ហាញថាព្រះ-អង្គមានព្រះហឫទ័យសប្បុរស មានដៃដែលបង្ហាញថាព្រះអង្គលើកលែងទោស មានរស្មីចេញពីបេះដូងដែលបង្ហាញថាព្រះអង្គមានព្រះហឫទ័យប្រណីសន្ដោស មានជើងដែលមានស្នាមរបួស ជាជើងដែលស្ត្រីមានបាបបានថើប ជាជើងដែលបានធ្វើដំណើរទៅប្រកាសដំណឹងល្អ និងអាវពណ៌សដែលបង្ហាញអំពីសេចក្ដីស្រឡាញ់ដ៏ពេញលក្ខណៈរបស់ព្រះអង្គចំពោះមនុស្សលោក។ សរុបមក រូបដែលបងស្រីហ្វូស្ទីណាគូរ ណែនាំឲ្យយើងចេះប្រើសរីរាង្គទាំងអស់ ទាំងភ្នែក ទាំងដៃ ទាំងមាត់ ទាំងបេះដូង ទាំងជើងដើម្បីបង្ហាញធម៌មេត្តាករុណា។ ដូច្នេះសូមឲ្យយើងរៀងៗខ្លួនស្រឡាញ់រូបកាយរបស់យើងទុកសម្រាប់បម្រើអ្នកដទៃ ដូចមានចែងក្នុងព្រះគម្ពីរអំពីបុរសអ្នកមានម្នាក់ អង្វរសុំព្រះយេស៊ូប្រទានជីវិតអស់កល្បជានិច្ច។ ពេលនោះ ព្រះយេស៊ូទតសម្លឹងទៅគាត់ដោយព្រះហឫទ័យស្រឡាញ់ ណែនាំឲ្យបុរសនោះមានភាពកក់ក្ដៅក្នុងដួងចិត្ត។ នេះជារបៀបដែលព្រះយេស៊ូ ណែនាំឲ្យយើងចេះប្រើភ្នែករបស់យើង។ ចំពោះដៃ ជើង មាត់ និងបេះដូងក៏ដូចគ្នាដែរ មានសារៈសំខាន់ណាស់ គឺឲ្យយើងទុកសម្រាប់បម្រើអ្នកដទៃ។ តាមរយៈរូបកាយរបស់យើង ព្រះយេស៊ូបានប្រើយើង ដើម្បីទៅជាសញ្ញាសម្គាល់នៃធម៌មេត្តាករុណា។

ម្សិលមិញសម្ដេចប៉ាបបានសួរដល់យុវជនទាំងអស់ថា **"តើក្មួយៗ មានសុបិន្តសម្រាប់អនាគតដែរឬទេ?"** ក្រោយមកសម្ដេចប៉ាបបានស្ដីបន្ទោសយុវជនដែលខ្ជិលដោយសំដៅទៅលើយុវជនខ្លះដែលមានអាយុទើបតែ២៥ឆ្នាំគេសូមចូលនិវត្ត។ យើងជាយុវជនត្រូវតែទៅជាក្បាលម៉ាស៊ីន សម្រាប់យុវជនឯទៀតៗ និងសម្រាប់យុវជនជំនាន់ក្រោយ ដើម្បីណែនាំឲ្យមនុស្សដែលកំពុងពិបាកដែលកំពុងអស់កម្លាំងទៅជាមានកម្លាំង និងមានស្មារតីវិញ។ ថ្ងៃនេះខ្ញុំសូមណែនាំឲ្យយើងទាំងអស់គ្នាសម្លឹងមើលព្រះយេស៊ូដែលយាងមករំដោះពិភពលោកយើងទាំងមូល ដែលសម្ដេចប៉ាបសូមឲ្យយើងស្រែកខ្លាំងៗដើម្បីឮដល់គ្រប់ទីកន្លែងនៃផែនដីរបស់យើង។ ពេល

នេះខ្ញុំក៏សូមឲ្យយើងម្នាក់ៗគិតអំពីរបៀបដែលយើងត្រូវធ្វើដែរ ដោយសូមឲ្យយើងពិនិត្យមើលតាមរយៈធម៌របស់សន្តៈហ្វ្រង់ស្វ័រ នៃទីក្រុងអាស៊ីស៊ី។

ធម៌របស់សន្តហ្វ្រង់ស្វ័រ

បន្ទរ៖ ឱ!ព្រះអម្ចាស់អើយ សូមព្រះអង្គប្រោសប្រណីឲ្យខ្ញុំចេះ កសាងសន្តិភាព ដែលមកពីព្រះអង្គ។

1- នៅពេលមនុស្សស្អប់គ្នា សូមព្រះអង្គប្រទានឲ្យខ្ញុំបង្ហាញសេចក្តីស្រឡាញ់
ពេលមនុស្សប្រមាថគ្នា សូមព្រះអង្គប្រទាន ឲ្យខ្ញុំចេះនាំគេ អត់ទោសគ្នា។

2- នៅពេលមនុស្សស្អប់គ្នា សូមព្រះអង្គប្រទានឲ្យខ្ញុំចេះសម្រុះសម្រួលគេ
ពេលមនុស្សមានសង្ស័យ មិនទុកចិត្តគ្នា សូមព្រះអង្គប្រទានឲ្យខ្ញុំនាំគេឲ្យទុកចិត្តគ្នាវិញ។

3- ពេលមនុស្សចាកក្តីពិត សូមព្រះអង្គប្រទានឲ្យខ្ញុំនាំគេរកសេចក្តីពិត
ពេលមនុស្សអស់សង្ឃឹម សូមព្រះអង្គប្រទានឲ្យខ្ញុំ ចេះនាំគេឲ្យមានក្តីសង្ឃឹម ឡើងវិញ។

4- ពេលមនុស្សកើតទុក្ខព្រួយ សូមព្រះអង្គប្រទានឲ្យខ្ញុំជួយសម្រាលទុក្ខគេ
ពេលមនុស្សខ្វាក់ងងឹត សូមព្រះអង្គប្រទានឲ្យខ្ញុំនាំពន្លឺឲ្យភ្លឺ ស្វាងរុងរឿង។

ប្រសិនបើយើងអនុវត្តតាមសេចក្តីទាំងអស់នេះ នោះសង្គមរបស់យើងនឹងទៅជាសង្គមថ្មី។ សម្តេចប៉ាបយ៉ូហានប៉ូលទីពីរ សង្ឃឹមថាយុវជននឹងអនុវត្តសេចក្តីទាំងនេះ នៅក្នុងជីវិតផ្ទាល់ខ្លួនរបស់គេ។ ការលើកលែងទោសមិនគ្រាន់តែជាពាក្យសម្តីទេ ប៉ុន្តែជាកិច្ចការដែលយើងត្រូវធ្វើដើម្បីឲ្យគេបានទទួលនូវសេចក្តីសុខសាន្ត និងជោគជ័យពីយើងដែរ។

ឱ!ព្រះអម្ចាស់អើយ
សូមឲ្យខ្ញុំ យកចិត្តទុកដាក់រំលែកទុក្ខអ្នកឯទៀត ជាជាងឲ្យគេរំលែកទុក្ខខ្ញុំ
សូមឲ្យខ្ញុំ ចេះយល់ចិត្តអ្នកដទៃជាជាងឲ្យគេយល់ចិត្តខ្ញុំ
សូមឲ្យខ្ញុំចេះ ស្រឡាញ់អ្នកដទៃ ជាជាងឲ្យគេស្រឡាញ់ខ្ញុំ។

សន្តៈហ្វ្រង់ស្វ័របានសុបិន្តឃើញថាមានព្រះវិហារមួយកំពុងបាក់រលំ ហើយគាត់បានកល និងទប់ព្រះវិហារនោះកុំឲ្យបាក់រលំ។ ព្រះវិហារនោះគឺជាវិសាលវិហាររបស់សម្តេចប៉ាប។ ក្រោយមកគាត់បានទៅជួបសម្តេចប៉ាបនិងបានរៀបរាប់អំពីសុបិន្តនោះ ដែលណែនាំឲ្យសម្តេចប៉ាបភ្ញាក់ស្មារតី។ ក្រោយមក សម្តេចប៉ាបបានគាំទ្រសន្តៈហ្វ្រង់ស្វ័រឲ្យចេញទៅប្រកាសដំណឹងល្អ ដោយឲ្យយកចិត្តទុកដាក់ជាមួយអ្នកតូចតាច និងរស់នៅជាមួយអ្នកក្រីក្រ។ ដូច្នេះបទនេះសន្តៈហ្វ្រង់ស្វ័រចង់បង្ហាញពីរបៀបដែលយើងត្រូវស្រឡាញ់។ កុំឲ្យយើងគិតថាគេត្រូវស្រឡាញ់យើង គេត្រូវតែចែកឲ្យយើង គេត្រូវតែជួយយើង គេត្រូវតែលើកទឹកចិត្តយើង ប៉ុន្តែគឺយើងវិញទេដែលត្រូវការជួយគេ លើកទឹកចិត្តគេ ស្រឡាញ់គេ ចែករំលែកឲ្យគេ និងទទួលគេជាអ្នកកណ្តាលដែលយើងត្រូវស្រឡាញ់។ សេចក្តីនេះជាការបង្រៀនរបស់របស់ព្រះយេស៊ូ។

ដ្បិតពេលណាយើងស្ម័គ្របូជាជីវិត ពេលនោះយើងទទួលជីវិតវិញ។

នេះណែនាំឲ្យយើងនឹកឃើញដល់សន្តៈម៉ាកស៊ីមាំងកុលបេ ដែលសុខចិត្តបូជាជីវិត។ តើយើងត្រូវបូជាអ្វីខ្លះក្នុងការរស់នៅ? គឺយើងត្រូវសុខចិត្តឈឺចាប់ខ្លះៗដើម្បីទទួលជីវិត និងដើម្បីចែកជីវិតដល់អ្នកដទៃដែរ។ នេះជាអត្ថន័យនៃបូជនិយចរនៅថ្ងៃស្អែក ដែលយើងត្រូវការរិះគិតឲ្យបានច្រើននៅពេលយើងដើរ។ រាល់ខែ យើងមានកម្មវិធីជួបជុំគ្នាពេញមួយយប់ដើម្បីអធិដ្ឋាន គឺជាឱកាសដែលយើងត្រូវខិតខំចូលឲ្យបានទៅដល់ជីវិតនៃការលះបង់។ ក្នុងការរស់នៅមានរបៀបជាច្រើនដើម្បីលះបង់ និងដើម្បីទទួលជីវិត៖

ដ្បិតពេលណាយើងលះបង់ប្រយោជន៍ផ្ទាល់ ពេលនោះយើងទទួលប្រយោជន៍វិញ។

អ្នកម្តាយតេរេសាធ្លាប់មានប្រសាសន៍ថា **"សេចក្តីស្រឡាញ់របស់ខ្ញុំ ជាតំណក់ទឹកមួយនៅក្នុងមហាសមុទ្រ ប៉ុន្តែពេលខ្ញុំប្រមូលតំណក់ទឹកនេះមក នោះខ្ញុំមានតំណក់ជាច្រើន"**។ ប្រសិនបើយើងយល់ថា យើងម្នាក់ៗជាតំណក់ទឹកនៃសេចក្តីស្រឡាញ់ នោះយើងមានតំណក់ទឹកច្រើនណាស់។ នៅប្រទេសឥណ្ឌា ថ្ងៃមួយនោះនៅតាមដងផ្លូវ អ្នកម្តាយតេរេសាបានឃើញអ្នកជំងឺម្នាក់ជិតស្លាប់។ ពេលដើរហួសទៅ គាត់នឹកឃើញថាអ្នកជំងឺជិតស្លាប់នេះគឺជាព្រះ-

យេស៊ូ គាត់ក៏ត្រឡប់មកវិញភ្លាមទាំងយកអ្នកជំងឺនោះទៅថែទាំ។ តាំងពីពេលនោះមកគាត់បានចាប់ផ្ដើមប្រមូលយុវនារីខ្លះៗ មកជួយថែអ្នកជំងឺដែលហៀបនឹងស្លាប់នៅតាមផ្លូវ។ គាត់លែងគិតពីប្រយោជន៍ផ្ទាល់ខ្លួន តែគាត់គិតពីប្រយោជន៍រួមថ្វាយទៅព្រះជាម្ចាស់។ សន្ដៈវ៉ាំងសង់ដឺប៉ូល ជាសន្ដបុគ្គលមួយដ៏ពិសេសដែលបានលះបង់ប្រយោជន៍ផ្ទាល់ខ្លួនដើម្បីបម្រើអ្នកក្រីក្រ។ មុនពេលទទួលមរណភាព មានគេសួរទៅលោកថា **"តើលោកនៅមានខ្វះអ្វីទេ?"** គាត់ឆ្លើយថា **"ខ្ញុំនៅខ្វះសេចក្ដីមួយ គឺខ្ញុំមិនទាន់បានស្រឡាញ់បងប្អូនល្មមនៅឡើយ"**។ ឯសន្ដៈដាមីញៀងវិញ លោកសុខចិត្តលះបង់ចោលអ្វីៗទាំងអស់ទៅរស់នៅលើកោះមួយជាមួយអ្នកជំងឺឃ្លង់។ លោកបម្រើគេនៅទីនោះដែលក្រោយមកលោកទទួលមរណភាពដោយសារឆ្លងជំងឺឃ្លង់នេះ។ នេះជាសញ្ញាសម្គាល់អំពីការលះបង់ប្រយោជន៍ផ្ទាល់ខ្លួន ដើម្បីទទួលជីវិតថ្មី។

ដ្បិតពេលណាយើងអត់ទោសឲ្យអ្នកដទៃ ពេលនោះព្រះអម្ចាស់លើកលែងទោសឲ្យយើង។

ថ្ងៃនេះយើងត្រូវតែនឹកឃើញដល់សន្ដៈយ៉ូហានប៉ូលទីពីរ ដែលយើងបានឃើញរួចហើយអាវរបស់លោកប្រឡាក់ដោយឈាម។ ឃាតកលបបាញ់សម្លាប់ លោកនៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ១៩៨១។ ប៉ុន្មានឆ្នាំក្រោយមក សន្ដៈយ៉ូហានប៉ូលទីពីរបានទៅដល់មន្ទីរឃុំឃាំងដើម្បីលើកលែងទោសឲ្យឃាតកនោះ។ ពេលយើងស្ដាប់សេចក្ដីនេះ យើងប្រដូចលោកជាព្រះ-យេស៊ូដែលបានលើកលែងទោស ឲ្យអ្នកដែលបានឆ្កាងព្រះអង្គនៅលើឈើឆ្កាង។

ដ្បិតពេលណាយើងលាចាកលោកនេះទៅ ពេលនោះយើងនឹងមានជីវិតអស់កល្បជានិច្ច។

កុំឲ្យយើងព្រួយចិត្តនឹងសេចក្ដីស្លាប់ ប៉ុន្តែឲ្យយើងសម្លាប់ភាពងងឹតនៅក្នុងជីវិតរបស់យើង ដើម្បីយើងទទួលជីវិតថ្មី។ ប្រសិនបើយើងមិនសុខចិត្តស្លាប់ នោះក៏ឥតមានផ្លែដែរ។ ឧបមាដូចជាគ្រាប់ពូជដែលគេយកទៅសាបព្រោះ ក្រោយមកគេដកយកទៅស្ទូងហើយចុងក្រោយបានបង្កើតផល នេះក៏ដោយសារតែគ្រាប់ពូជមួយគ្រាប់បានងាប់។ ឬដូចដង្កូវនាងដំបូងវាមិនស្អាតទេ ប៉ុន្តែដោយសារវាបានរុំខ្លួនយ៉ាងយូរៗ និងក្រោយមកវាបានក្លាយជាមេអំបៅមួយយ៉ាងស្អាត ដែលនេះប្រដូចទៅនឹងយុវជនដែលនៅមានឱកាសច្រើន ដើម្បីនឹង

ប្រែចិត្តគំនិត។ ក្នុងអត្ថបទទីមួយបានចែងថា **"ព្រះជាម្ចាស់បានជ្រើសរើសយើងឲ្យយើងធ្វើជាអ្នកដ៏វិសុទ្ធ"** ដូច្នេះដើម្បីធ្វើអ្នកដ៏វិសុទ្ធនោះយើងត្រូវសម្លាប់ជីវិតចាស់ ដោយយើងទទួលអត្តសញ្ញាលើកលែងទោស និងដោយយើងលះបង់ចោលអ្វីដែលចាស់ ដើម្បី ទទួលយកជីវិតថ្មីដែលមានផ្លែច្រើន ដោយយើងខិតខំបង្កើតផ្លែបង្កើតសេចក្ដីសុខសម្រាប់អ្នកដទៃ និងដោយយើងចេះស្រឡាញ់ និងចេះលើកលែងទោសឲ្យអ្នកដទៃ។

សូមព្រះជាម្ចាស់ប្រទានពរឲ្យយើងខ្ញុំ ដើម្បីយើងខ្ញុំទាំងអស់គ្នាមានកម្លាំងពេញខ្លួនទៅជាយុវជនដែលភ្ញាក់ស្មារតី ដើម្បីធ្វើជាសាក្សីនៃព្រះហប្ញទ័យស្រឡាញ់របស់ព្រះជាម្ចាស់ដោយសុខចិត្តលះបង់ ដោយសុខចិត្តបូជា ដោយសុខចិត្តលើកលែងទោស ដោយសុខចិត្តស្រឡាញ់។

**"សេចក្ដីស្រឡាញ់របស់ខ្ញុំ ជាតំណក់ទឹកមួយ នៅក្នុងមហាសមុទ្រ ប៉ុន្តែពេលខ្ញុំប្រមូលតំណក់ទឹកនេះមក នោះខ្ញុំមានតំណក់ជាច្រើន"**

# យើងជាទូតដ៏វិសុទ្ធរបស់ព្រះគ្រីស្ត

Let us be saints!

អត្ថបទទី១៖ កឡ ៣, ១២-១៧
ដំណឹងល្អ៖ លក ១, ៣៩-៤៥

ថ្ងៃនេះយើងបន្តស្តាប់សម្តេចប៉ាប ជាភាសាអ៊ីតាលី សូមលោកឪពុកជួយបកប្រែ។ អ្វីជាចំណុចសំខាន់ ដែលខ្ញុំចង់និយាយនៅពេលនេះ ក្នុងនាមខ្ញុំជាលោកអភិបាលភូមិភាគភ្នំពេញ ក្នុងនាមលោកគីគេ និងលោកអន់តូនីដែរ ខ្ញុំសូមប្រាប់ថា យើងទាំងអស់គ្នា គឺជាតំណាងព្រះសហគមន៍ពីប្រទេសកម្ពុជា យើងមកចូលរួមទិវាយុវជនពិភពលោកនេះ មិនមែនជាភ្ញៀវ ទេសចរណ៍ទេហើយយើងមិនមែនជាអ្នកដែលមានសំណាង ដែលត្រូវបានលោកជ្រើសរើសដែរ។ ប៉ុន្តែយើងគឺជាតំណាងពេញសិទ្ធិនៃព្រះសហគមន៍កាតូលិកកម្ពុជា ដែលត្រូវចូលរួមដើម្បីជួបជាមួយបងប្អូនទាំងអស់មកពីជាង១៨០ប្រទេស។ តំណាងមានន័យថា ពេលត្រឡប់ទៅវិញ យើងត្រូវនាំយកបទពិសោធន៍ សេចក្តីស្រឡាញ់ កម្លាំងដែលយើងបានទទួលពីក្នុងពីរអាទិត្យកន្លងមក ទៅជូនដល់បងប្អូនយើងឯទៀតៗ នៅតាមព្រះសហគមន៍ នៅតាមភូមិភាគ នៅតាមកន្លែងដែលយើងធ្វើការ និងនៅក្នុងសង្គមរបស់យើង ដ្បិតយើងមកទីនេះមិនមែនដើម្បីទទួលបទពិសោធន៍សម្រាប់ផ្ទាល់ខ្លួនទេ។

យើងម្នាក់ៗ មានបទពិសោធន៍របស់ខ្លួនផ្ទាល់ ដើម្បីយើងចែករំលែកជាមួយយុវជនពិភព លោក។ម្សិលមិញមានមនុស្សតែ៦០ម៉ឺននាក់។ ល្ងាចថ្ងៃសៅរ៍ និងព្រឹកថ្ងៃអាទិត្យយើងនៅ

---

អភិបូជាជាភាសាខ្មែរលើកទី៣ ក្នុងទិវាយុវជនពិភពលោក
នៅទីក្រុងក្រាកាវ ប្រទេសប៉ូឡូញ
ថ្ងៃទី ២៩ កក្កដា ២០១៦

ជាមួយមនុស្សជាង២លាននាក់ ហើយនៅពេលនោះ យើងដូចជាស្រវាំងភ្នែកដោយសារមានមនុស្សច្រើនពេកប៉ុន្តែយើងស្រវាំងភ្នែកក្នុងអំណរសប្បាយ។ ដូចព្រះនាងម៉ារីដែរ ពេលទៅវិញយើងត្រូវប្រញាប់ប្រញាល់ចែករំលែកបទពិសោធន៍ពិសេសនេះ យើងមិនត្រូវទុកបទពិសោធន៍នោះចោលទេហើយយើងនឹងធ្វើជាសៀវភៅមាសមួយ ដែលម្នាក់ៗនឹងសរសេរបទពិសោធន៍ផ្ទាល់ខ្លួននៅក្នុងនោះ។ រឿងនេះពិសេសណាស់ ហើយខ្ញុំនឹងជំរុញក្នុងការបោះពុម្ពដើម្បីចែកផ្សាយ។ ពេលយើងទៅតាមព្រះសហគមន៍វិញ តើយើងបង្កើតស្នាដៃយ៉ាងពិតប្រាកដអ្វីខ្លះ ?

ប៉ុន្មានអាទិត្យមុន នៅក្នុងភូមិភាគភ្នំពេញ ខ្ញុំបានចាត់ក្រុមគ្រីស្តទូត១២ក្រុម ដែលចេញពីសាលាសន្តៈយ៉ូស្វីនឲ្យទៅប្រកាសធម៌មេត្តាករុណា ដែលជាឱកាសមួយដើម្បីឲ្យយុវជនយើងទៅមុខ។ ប៉ុន្តែខ្ញុំជឿជាក់ថា តំណាងទាំងអស់ដែលអង្គុយនៅទីនេះ ក៏គិតថាពេលទៅវិញ តើយើងត្រូវធ្វើអ្វីដើម្បីឲ្យព្រះសហគមន៍របស់យើងរីកចម្រើន ដើម្បីសង្គមរបស់យើងរីកចម្រើន។ ម្សិលមិញយើងបានស្តាប់ឮថាយើង **"ជាទូតរបស់ព្រះគ្រីស្ត"** ថ្ងៃនេះយើងស្តាប់ឮថែមថា **"ព្រះជាម្ចាស់បានជ្រើសរើសបងប្អូនធ្វើជាជនដ៏វិសុទ្ធ"**។ ដូច្នេះយើងមិនមែនជា **"ទូត"** តែប៉ុណ្ណោះ ប៉ុន្តែយើងជាទូតរបស់ព្រះគ្រីស្ត យើងជា **"ជនដ៏វិសុទ្ធ"**។ នេះជាការអស្ចារ្យដែល យើងបានទទួលការជ្រើសរើសពីព្រះជាម្ចាស់ ហើយនេះមិនមែនជាការសម្រេចចិត្តរបស់យើង មិនមែនជាកម្លាំងមកពីយើងទេ។ ដូចព្រះនាងម៉ារីបានទទួលដំណឹងថាព្រះនាងនឹងធ្វើជាមាតារបស់ព្រះជាម្ចាស់ថ្ងៃនេះយើងទទួលដំណឹងថា យើងជាទូតរបស់ព្រះគ្រីស្ត និងជាទូតដ៏វិសុទ្ធថែមទៀតផង។

ចូរយើងឆ្លៀតឱកាសអានអត្ថបទទី១សាជាថ្មី និងអានអំពីរបៀបដែលយើងទៅជាជនដ៏វិសុទ្ធ។ ឧបមាពេលយើងទិញកូនម៉ាញេមួយនោះយើងតែងទទួលបានក្រដាស់មួយសន្លឹកដែលនឹងពន្យល់អំពីរបៀបបើកបិទអំពីរបៀបដាក់ថ្មយ៉ាងដូចម្តេច?។ ថ្ងៃនេះពេលយើងអានអត្ថបទទី១យើងនឹងទទួលបានសេចក្តីពន្យល់ពីព្រះយេស៊ូ ថាត្រូវធ្វើយ៉ាងដូចម្តេចដើម្បីយើង

ក្លាយទៅជាទូតដ៏វិសុទ្ធ ដែលមាន ៣ចំណុចសំខាន់ដូចតទៅ៖

១) **"ទូតដ៏វិសុទ្ធ"** គឺយើងត្រូវការរៀបចំចិត្ត ឲ្យមានចិត្តអាណិតមេត្តា ចិត្តល្អ ចិត្តសប្បុរស ចិត្តបន្ទាបខ្លួន ចិត្តស្លូតបូត ចិត្តអត់ធ្មត់ ដែលជាឥរិយាបទត្រូវហៀរចេញពីចិត្តរបស់យើងជាគ្រីស្តបរិស័ទ ហើយឥរិយាបថនេះ ដែលណែនាំឲ្យសម្តេចប៉ាប យ៉ូហាន ប៉ូលទី២ ក្លាយជាសន្តបុគ្គល។ សម្តចប៉ាប លោកមានរបៀបរស់នៅជាធម្មតា លោកធ្លាប់ជាអភិបាលព្រះសហគមន៍នៅទីក្រុងក្រាកាវនេះ លោកធ្លាប់ជាអ្នកទទួលខុសត្រូវនិស្សិតនៅក្នុងសាកលវិទ្យាល័យ លោកចូលចិត្តធ្វើកីឡា ចូលចិត្តដើរជាមួយនិស្សិត...។ ពេលត្រូវបានជ្រើសរើសជាសម្តេចប៉ាបលោកបានយកពេលវេលាជាច្រើនដើម្បីអធិដ្ឋាន ដើម្បីឲ្យជីវិតរបស់លោកជាប់ជាមួយព្រះយេស៊ូ និងជាពិសេសដើម្បីឲ្យចិត្តគំនិតរបស់លោក ទៅជាតែមួយជាមួយព្រះយេស៊ូ។ ចំពោះយើងក៏ដូច្នោះដែរ គឺមុនគិតអំពីកិច្ចការ អំពីស្នាដៃដ៏អស្ចារ្យដើម្បីទៅជាជនដ៏វិសុទ្ធនោះ យើងត្រូវគិតអំពីផ្ទៃក្នុងនៃចិត្តរបស់យើងជាមុនសិន។

២) ចូរមានសកម្មភាពជាមួយបងប្អូន ចូរប្រៀនប្រដៅ និងដាស់តឿនគ្នាទៅវិញទៅមក និងលើកលែងទោសឲ្យគ្នា ដូចព្រះជាម្ចាស់លើកលែងទោសឲ្យយើងដែរ។ ប្រៀនប្រដៅ ដាស់តឿនគ្នាទៅវិញទៅមក នៅពេលយើងមើលឃើញដោយប្រាជ្ញាថាមានបញ្ហា ពេលនោះកុំឲ្យយើងនៅស្ងៀមប៉ុន្តែឲ្យយើងជួយប្រៀនប្រដៅគ្នាដើម្បីដាស់តឿនគ្នា។

៣) សូមឲ្យយើងមានទំនាក់ទំនងជាមួយព្រះជាម្ចាស់ ដោយយកពេលវេលាដើម្បីអធិដ្ឋានដើម្បីអរព្រះគុណព្រះអង្គ ដ្បិតព្រះជាម្ចាស់ជាជីវិតរបស់យើង។

ដូច្នេះដើម្បីទៅជាគ្រីស្តទូតដ៏វិសុទ្ធ ទី១ យើងត្រូវរៀបចំចិត្តគំនិត ទី២ យើងត្រូវមានសកម្មភាពជាមួយបងប្អូនឯទៀតៗ ត្រូវប្រៀនប្រដៅ ត្រូវបង្ហាញមេត្តាករុណា ដោយលើកលែងទោសឲ្យគ្នា និងទី៣ យើងត្រូវមានចិត្តអរព្រះគុណព្រះជាម្ចាស់ជានិច្ច ដោយសារព្រះជាម្ចាស់ជាជីវិតរបស់យើង។

ដើម្បីឲ្យយើងទៅមុខបាន យើងត្រូវតែសម្លឹងមើលព្រះនាងម៉ារី គឺសម្លឹងមើលពីរបៀប

របស់ព្រះនាង។ ព្រះនាងម៉ារីបានច្រៀងលើកតម្កើងព្រះជាម្ចាស់ថា **"ព្រលឹងខ្ញុំសូមលើកតម្កើងព្រះអម្ចាស់ ខ្ញុំមានចិត្តអំណរយ៉ាងខ្លាំង ព្រោះព្រះជាម្ចាស់ជាព្រះសង្គ្រោះរបស់ខ្ញុំ។ ព្រះអង្គទតមើលមកខ្ញុំដែលជាអ្នកបម្រើដ៏ទន់ទាបរបស់ព្រះអង្គ"**។ សេចក្តីទាំងនេះក៏ជាជីវិតរបស់យើងដែរ យើងមិនមែនជាមនុស្សអស្ចារ្យ យើងមិនមែនជាមនុស្សដែលមានកម្លាំងពិសេស ប៉ុន្តែយើងមានកម្លាំងពិសេសដោយសារព្រះជាម្ចាស់ យើងជាមនុស្សអស្ចារ្យដោយសារព្រះជាម្ចាស់ មិនមែនដោយសារកម្លាំងរបស់យើងទេ។ នៅពេលសម្តេចប៉ាបសួរយើងអំពីសុបិន្តអំពីអនាគតដែលយើងចង់បង្កើត នោះមិនមែនជាសុបិន ឬអនាគតតូចតាចទេ ប៉ុន្តែជាសុបិន ជាអនាគតដ៏ធំទូលំទូលាយ ដែលយើងយល់ថា សមត្ថភាព សកម្មភាព កម្លាំង និងលទ្ធភាពទាំងអស់ដែលអាចសម្រេចបាន គឺមកពីព្រះជាម្ចាស់។ ដូច្នេះ ប្រសិនបើយើងមិនរៀបចំចិត្តគំនិតជាមុនទេ នោះយើងមិនអាចសម្រេចអ្វីបានទេ។

ខ្ញុំសូមអញ្ជើញបងប្អូនទាំងអស់ពិចារណាយ៉ាងជ្រៅនៅក្នុងដួងចិត្ត ដោយចូលទៅក្នុងទីអារាមដ៏សម្ងាត់នៃដួងចិត្តរបស់យើង នៅពេលយើងកំពុងធ្វើដំណើរនៅថ្ងៃស្អែក និងខានស្អែក...។ យប់នេះយើងកំពុងដើរផ្លូវឈើឆ្កាង គឺយើងចូលនៅក្នុងទុក្ខលំបាករបស់មនុស្សលោក។ គ្រប់១៤ដំណាក់កាលនៃផ្លូវឈើឆ្កាង ណែនាំឲ្យយើងចូលនៅក្នុងទុក្ខលំបាករបស់បងប្អូនយើង របស់យុវជនយើងក្នុងពិភពលោកទាំងមូលក្នុងពេលសព្វថ្ងៃនេះ។ ថ្ងៃអាទិត្យយើងគោរពព្រះយេស៊ូ ដែលមានព្រះជន្មរស់ឡើងវិញរួមជាមួយគ្នាហើយយើងត្រឡប់ទៅវិញនៅថ្ងៃច័ន្ទ នឹងទៅដល់ប្រទេសរបស់យើងនៅថ្ងៃអង្គារ។ ថ្ងៃពុធយើងត្រូវចាប់ផ្តើមចែករំលែកជាមួយបងប្អូន ជាមួយក្រុមគ្រួសារជាមួយបងប្អូននៅកន្លែងធ្វើការ។ យើងមិនមែនចែករំលែកតាមរបៀបបានឃើញនេះ ឃើញនោះទេ ប៉ុន្តែចែករំលែកនៅក្នុងរបៀបដែលយើងជាមនុស្សថ្មីដោយសារ២អាទិត្យកន្លងមកនេះ យើងបានកើតជាថ្មី។ យើងជាមនុស្សថ្មី ហើយមនុស្សថ្មីនេះត្រូវការមានស្នាដៃដល់បងប្អូនឯទៀតៗ។ ដូច្នេះ យើងត្រូវចាប់ផ្តើមនៅថ្ងៃពុធ កុំឲ្យយើងចាំថ្ងៃស្អែកនោះនឹងហួសពេលហើយ។ សូមឲ្យយើងទៅមុខរួមជាមួយព្រះយេស៊ូនៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ។

នៅពេលនេះ យើងខ្ញុំសូមអរព្រះគុណព្រះជាម្ចាស់ និងសូមព្រះអង្គជួយយើងខ្ញុំបន្តទៀត ដើម្បីឲ្យយើងខ្ញុំទៅជាទូតដ៏វិសុទ្ធ ឲ្យយើងខ្ញុំទៅជាអនុលេខានៃព្រះហឫទ័យមេត្តាករុណារបស់ព្រះជាម្ចាស់សម្រាប់ប្រទេសកម្ពុជាទាំងមូល។

**ព្រះជាម្ចាស់បានប្រទានពរដល់នាងលើសស្ត្រីនានា ហើយព្រះអង្គក៏ប្រទានពរដល់បុត្រនាងដែរ។ តើរូបខ្ញុំនេះមានឋានៈអ្វី បានជាព្រះមាតាព្រះអម្ចាស់របស់ខ្ញុំមកសួរសុខទុក្ខខ្ញុំដូច្នេះ? កាលខ្ញុំបានឮពាក្យ ជម្រាបសួររបស់នាង ស្រាប់តែកូននៅក្នុងផ្ទៃរបស់ខ្ញុំបំរះឡើងដោយអំណរសប្បាយ នាងពិតជាមានសុភមង្គលមែន ព្រោះនាងបានជឿព្រះបន្ទូលដែលព្រះអម្ចាស់ប្រាប់នាង មុខជាបានសំរេចមិនខាន។**

# អ្នកម្ដាយតេរេសាជាគំរូនៃមេត្តាករុណា

Mother Teresa, model of Charity

---

អត្ថបទទី១៖ សស ១១, ៩ ដល់ ១២, ៨
ដំណឹងល្អ៖ លក ៩, ៤៣ខ-៤៥

ថ្ងៃនេះ ជាពេលវេលាមួយដែលព្រះសហគមន៍កាតូលិករបស់យើងមានអំណរសប្បាយនៅក្នុងឆ្នាំព្រះមហាករុណាទិគុណ។ ចំពោះឆ្នាំមេត្តាករុណារបស់យើងដែលមានរយៈពេលបីឆ្នាំ បានកន្លងទៅជិតផុតហើយ ដោយរួមជាមួយនឹងឆ្នាំនេះជាឆ្នាំព្រះមហាករុណាទិគុណ នោះជាឱកាសមួយឲ្យយើងអរព្រះគុណព្រះជាម្ចាស់ចំពោះគម្រូមួយនៃករុណាទិគុណរបស់ព្រះអង្គ គឺសន្តីតេរេសានៃទីក្រុងកាល់ហ្គូតា ដែលជាគម្រោងការមួយរបស់ព្រះជាម្ចាស់ ឲ្យពិភពលោករបស់យើងបានទទួលផ្លែនៅក្នុងសតវត្សទី២០នេះ។

សន្តៈយ៉ូហានប៉ូលទីពីរនិងសន្តីតេរេសានៃទីក្រុងកាល់ហ្គូតាដែលយើងបានស្គាល់ មិនមែនជាសន្តបុគ្គលដែលចូលក្នុងប្រវត្តិសាស្ត្រមនុស្សយើងពីយូរមកហើយនោះទេ ប៉ុន្តែជាសន្តបុគ្គលដែលចូលនៅក្នុងជីវិតរបស់យើង និងពិភពលោករបស់យើងនៅពេលកន្លងទៅថ្មីៗនេះ ដែលយើងធ្លាប់បានឃើញតាមទូរទស្សន៍ បានស្ដាប់ឮសម្លេងតាមវិទ្យុ គឺលោកទាំងពីរជាសន្តៈសន្តី ដែលអស់មួយជីវិតរបស់លោកទាំងពីរ បានខិតខំបង្កើតពិភពលោកយើងទៅជាពិភពលោកថ្មី។ លោកទាំងពីរជាស្ថាបនិកព្រះរាជ្យរបស់ព្រះជាម្ចាស់ ជាស្ថាបនិករសង្គមថ្មីក្នុងពេលបច្ចុប្បន្ននេះ។

ដូច្នេះសម្រាប់យើងទាំងអស់គ្នា តើយើងមានសុបិនអ្វីសម្រាប់ពិភពលោកយើងសព្វថ្ងៃ? តើយើងមានសុបិនអ្វីសម្រាប់ប្រទេសកម្ពុជាយើងសព្វថ្ងៃ?។ យើងគ្រប់គ្នាចង់បានពិភពលោក

---

អភិបូជាគោរពអ្នកម្ដាយតេរេសាទៅជាសន្តីបុគ្គលនៅភ្នំពេញថ្មី
ថ្ងៃទី២៤ កញ្ញា ២០១៦

មួយប្រកបដោយសេចក្តីសុខសាន្ត យើងចង់បានសង្គមកម្ពុជាមួយដែលផ្តល់សុខសន្តិភាព នេះហើយជាសេចក្តីត្រូវការរបស់យើង ដែលកន្លងមកអ្នកម្តាយតេរេសាបានខិតខំបង្ហាញតាមរយៈនៃសេចក្តីស្រឡាញ់ ដែលកន្លងមកសម្តេចប៉ាបយ៉ូហានប៉ូលទីពីរខិតខំបង្ហាញតាមរយៈការធ្វើដំណើររបស់លោកទៅគ្រប់ទីកន្លែងសំខាន់ៗក្នុងពិភពលោកទាំងមូល ដើម្បីណែនាំឲ្យព្រះរាជ្យរបស់ព្រះជាម្ចាស់ គឺសេចក្តីសុខសាន្តមានជារូបរាងជាក់ស្តែងឡើងក្នុងសង្គមរបស់យើង និងក្នុងពិភពលោករបស់យើង។

ពាក្យអធិដ្ឋានដែលអ្នកម្តាយតេរេសាចូលចិត្តអធិដ្ឋានច្រើនដងនោះគឺ **"ផលផ្លែនៃភាពស្ងៀមស្ងាត់គឺអធិដ្ឋាន ផលផ្លែនៃការអធិដ្ឋានគឺជំនឿ ផលផ្លែនៃជំនឿគឺសេចក្តីស្រឡាញ់ ផលផ្លែនៃសេចក្តីស្រឡាញ់គឺបម្រើ ផលផ្លែនៃការបម្រើគឺសន្តិភាព"**។ អត្ថបទទីពីរដែលយើងស្តាប់ឮនៅថ្ងៃនេះគឺ **"ដ្បិតព្រះជាម្ចាស់ជាសេចក្តីស្រឡាញ់"** ដែលសេចក្តីនេះស្របនឹងការរស់នៅរបស់អ្នកម្តាយ ដែលអស់មួយជីវិត អ្នកម្តាយបានយកចិត្តទុកដាក់យកសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់មកបង្កើតពិភពលោកថ្មី។ អ្នកម្តាយធ្លាប់មានប្រសាសន៍ថា **"នៅពេលដែលខ្ញុំបំពាក់ព្រះគ្រីស្តពេលនោះណែនាំឲ្យខ្ញុំមានសមត្ថភាពនាំសេចក្តីស្រឡាញ់របស់ព្រះអង្គទៅជូនដល់បងប្អូនឯទៀតៗ។ ខ្ញុំមានសមត្ថភាពកសាងពិភពលោកថ្មីដោយចិត្តមេត្តាករុណា គឺដោយសារសេចក្តីស្រឡាញ់ដែលមកពីព្រះគ្រីស្តផ្ទាល់ ដ្បិតព្រះជាម្ចាស់ជាសេចក្តីស្រឡាញ់"**។

អ្នកម្តាយតេរេសាបានរកឃើញពីក្នុងការអធិដ្ឋានរបស់គាត់ នូវកម្លាំងនៃសេចក្តីស្រឡាញ់ដើម្បីយកទៅបម្រើអ្នកក្រីក្រ បម្រើអ្នកដែលកំពុងស្លាប់។ ភាពស្ងៀមស្ងាត់ណែនាំឲ្យអ្នកម្តាយតេរេសាអធិដ្ឋាន។ ជារៀងរាល់ថ្ងៃអ្នកម្តាយបានអធិដ្ឋាននៅមុខព្រះកាយព្រះគ្រីស្តពីរឬបីម៉ោងដើម្បីទទួលកម្លាំងទៅជួយដល់អ្នកដែលកំពុងស្លាប់ ជួយដល់អ្នកក្រីក្រទុរគត។ សម្រាប់ជីវិតរបស់យើងក៏ដូចគ្នាដែរយើងអាចមានសមត្ថភាពដើម្បីស្រឡាញ់អ្នកដទៃបាន លុះត្រាណាយើងរកឃើញសេចក្តីស្រឡាញ់មកពីព្រះជាម្ចាស់ពីក្នុងការអធិដ្ឋានរបស់យើង។ សេចក្តីស្រឡាញ់មកពីព្រះជាម្ចាស់មានអំណាចលើអ្វីៗទាំងអស់ក្នុងការបង្កើតសង្គមថ្មី។ថ្ងៃនេះព្រះយេស៊ូដែល

កំពុងសម្លឹងមើលមកយើងនៅទីនេះ ដែលកំពុងប្រទានពរដល់យើង ដែលណែនាំឲ្យយើងទទួលជីវិតថ្មីមានព្រះបន្ទូលមកយើងថា **"អ្វីៗទាំងអស់ដែលអ្នករាល់គ្នាបានធ្វើចំពោះអ្នកតូចតាចជាងគេបំផុតម្នាក់ក្នុងចំណោមបងប្អូនរបស់យើង នោះដូចអ្នករាល់គ្នាបានធ្វើចំពោះខ្ញុំដែរ"**។ ដូច្នេះមានន័យថា នៅពេលយើងសម្លឹងមើលព្រះភក្ត្ររបស់ព្រះយេស៊ូ គឺយើងកំពុងសម្លឹងមើលមុខជនដែលកំពុងរងទុក្ខវេទនា។

សន្តៈវ៉ាំងសង់ដឺប៉ូលជាសន្តបុគ្គលម្នាក់ដែលមានចិត្តស្រឡាញ់ច្រើន។ ថ្ងៃមួយមានបងស្រីម្នាក់សួរគាត់ថា **"លោកឪពុក ពេលខ្ញុំកំពុងអធិដ្ឋាននៅមុខព្រះកាយ ហើយប្រសិនបើមានអ្នកក្រីក្រមកសុំទាន តើខ្ញុំងើបចោលព្រះកាយដើម្បីទៅជួយគាត់ឬខ្ញុំអធិដ្ឋានបន្ត?"**។ គាត់បានឆ្លើយថា **"មិនមែនចោលព្រះកាយទេនៅពេលបងស្រីទៅជួយអ្នកសុំទាន ដ្បិតអ្នកសូមទាននោះហើយជាព្រះកាយ"**។ នៅពេលយើងអធិដ្ឋាន គឺពិតប្រាកដយើងនៅជាមួយព្រះយេស៊ូដូចគ្នាដែរនៅពេលយើងទៅជួយអ្នកតូចតាចម្នាក់ដែលកំពុងមានសេចក្តីត្រូវការ គឺយើងពិតប្រាកដនៅជាមួយព្រះយេស៊ូដដែល។ ដូច្នេះព្រះយេស៊ូមិន នៅឆ្ងាយពីយើង ដែលកំពុងបំពេញតួនាទីជាគ្រីស្តបរិស័ទជាមួយអ្នកក្រីក្រទេ ...។

អ្នកម្តាយតេរេសាបានទទួលការត្រាស់ហៅដើម្បីបម្រើមនុស្សតូចតាច នៅពេលអ្នកម្តាយសម្លឹងមើលព្រះគ្រីស្តនៅលើព្រះឈើឆ្កាងទាំងបានឮព្រះអង្គមានព្រះបន្ទូលថា "ខ្ញុំស្រេកទឹក"។ ហេតុនេះហើយបានជានៅក្នុងព្រះវិហាររបស់ក្រុមបងស្រី បងប្រុសមេត្តាករុណានៅទូទាំងពិភពលោកទាំងមូល មានទូព្រះកាយដែលមានលក្ខណៈដូចគ្នាទាំងអស់ គឺមានឈើឆ្កាងរបស់ព្រះគ្រីស្តនិងមានព្រះបន្ទូលថាខ្ញុំស្រេកទឹក។ ថ្ងៃនេះសូមបងប្អូនទាំងអស់គ្នាសម្លឹងមើលព្រះ-យេស៊ូ ដែលមានព្រះបន្ទូលម្តងទៀតដល់យើងថា **"ខ្ញុំស្រេកទឹក"** គឺព្រះអង្គស្រេកប្រទានសេចក្តីសុខសាន្តនិងសន្តិភាពឲ្យយើង ព្រះអង្គស្រេកចង់ឲ្យយើងលើកលែងទោសឲ្យគ្នាទៅវិញទៅមក ព្រះអង្គស្រេកផ្តល់ជីវិត ផ្តល់សេចក្តីសង្ឃឹមឲ្យយើង ព្រះអង្គស្រេកឲ្យយើងនៅតែប្រយុទ្ធប្រឆាំងនឹងឥទ្ធិពលនៃសេចក្តីអាក្រក់ នៃភាពងងឹតអន្ទិកាដែលសម្ងំនៅក្នុងចិត្តរបស់យើង ដែលច្រើន

ដងបានផ្ទុះឡើងនូវការស្អប់ខ្ពើម កំហឹង ការសងសឹកដោយស្មានថាអ្នកដទៃដែលប្លែកពីយើង សុទ្ធតែជាខ្មាំងដែលយើងត្រូវតែវាយសម្លាប់។ តាមប្រវត្តិសាស្ត្រនៃពិភពលោក យើងនឹកឃើញដល់ហ៊ីត្លែ ប៉ុលពត អាយស៊ីសដែលគេបានប្រព្រឹត្តបែបនេះ ហើយក៏គេនៅតែប្រព្រឹត្តបែបនេះដដែលនៅបច្ចុប្បន្នកាលនេះ។

ព្រះយេស៊ូស្រែកថែមទៀត គឺព្រះអង្គស្រែកកុំឲ្យយើងថ្កោលទោសបងប្អូនដូចគេបានថ្កោលទោសព្រះអង្គ កុំឲ្យយើងឆ្កាងគេដូចគេឆ្កាងព្រះអង្គនៅឯភ្នំលលាដ៏ក្បាលដែរ។ សព្វថ្ងៃមានមនោគមវិជ្ជាផ្សេងៗមានរបបនយោបាយនានា មានរចនាសម្ព័ន្ធសេដ្ឋកិច្ចនានាដែលមិនរាប់មនុស្សទុកជាសំខាន់ជាងអ្វីទាំងអស់នោះទេ។ លទ្ធិអ្នកជាតិនិយមហួសហេតុ អត្តទត្ថបុគ្គលនិយមនៅតែឆ្កាងខ្ញុំតទៅទៀត។ សូមកុំចូលរួមក្នុងចំណោមគំនិតរបស់គេ។ អ្នកដែលជាសាវ័ករបស់ខ្ញុំអើយ!ចូរសម្លឹងមើលមកម្ដាយរបស់ខ្ញុំគឺព្រះនាងម៉ារីចូរសម្លឹងមើលមកខ្ញុំចូរស្ដាប់ដំណឹងល្អដំបូងបង្អស់របស់ខ្ញុំដែលបានប្រកាសថា **"ចូរប្រែចិត្តគំនិតនិងជឿលើដំណឹងល្អចុះ ដ្បិតព្រះ-ជាម្ចាស់ហៀបនឹងយាងមកគ្រងរាជ្យហើយ"**។ នេះជាសេចក្ដីសង្ឃឹមរបស់យើងនៅថ្ងៃនេះ ដែលព្រះយេស៊ូណែនាំឲ្យយើងភ្ញាក់ស្មារតីឈរឡើង ដើម្បីបំបាត់អ្វីៗទាំងអស់ដែលអសកម្មនៅក្នុងសង្គមរបស់យើង ដែលជិះជាន់លើសិទ្ធិមនុស្ស ដែលជិះជាន់តម្លៃថ្លៃថ្នូរនៃជីវិតដោយគេបណ្ដេញមនុស្សទន់ខ្សោយចេញពីសង្គម ដោយមិនអើពើនឹងអ្នកគ្មានសមត្ថភាពឲ្យអាចរស់នៅដូចគេឯងបាន ដែលនេះជាថ្មីម្ដងទៀតព្រះយេស៊ូស្រែកទឹក គឺព្រះអង្គស្រែកឲ្យយើងភ្ញាក់ស្មារតីបង្កើតពិភពលោកថ្មី បង្កើតសង្គមថ្មីរបស់យើង ឲ្យយើងទៅជាពន្លឺសម្រាប់ពិភពលោកទាំងមូល។

ក្នុងអត្ថបទទីមួយចែងថា **"ប្រសិនបើអ្នកសុខចិត្តបេះអាហារពីមាត់ខ្លួនយកទៅឲ្យអ្នកដែលស្រេកឃ្លាន ប្រសិនបើអ្នកយកម្ហូបអាហារទៅចម្អែតមនុស្សទុរគត នោះពន្លឺរបស់អ្នកនឹងចែងចាំងក្នុងទីងងឹត ហើយភាពងងឹតរបស់អ្នកនឹងប្រែទៅជាភ្លឺដូចពន្លឺថ្ងៃដែរ"** នេះជាជីវិតរបស់អ្នកម្ដាយតេរេសាហើយនេះក៏ត្រូវតែជាជីវិតរបស់យើងដែរ គឺឲ្យយើងបង្កើតពិភពលោកថ្មី ឲ្យយើងទៅជាពន្លឺសម្រាប់ពិភពលោកទាំងមូល ។ មានអ្នកកាសែតម្នាក់សួរអ្នកម្ដាយតេរេសាអំពី

ទស្សនៈក្នុងការកសាងពិភពលោកថ្មីថា **"សូមអ្នកម្ដាយជួយប្រាប់ផង តើយើងត្រូវការធ្វើអ្វីខ្លះដើម្បីកសាងពិភពលោកថ្មី?"**។ អ្នកម្ដាយបានឆ្លើយថា **"លោកនិងខ្ញុំត្រូវប្រែចិត្តគំនិតសិនដោយយល់ថា ការកសាងពិភពលោកថ្មីមិនត្រូវការទស្សនៈដ៏អស្ចារ្យទេ ដោយត្រូវចាប់ផ្ដើមពីការលើកលែងទោសប្រសិនបើគ្មានការលើកលែងទោសទេ យើងមិនអាចធ្វើអ្វីបានឡើយ"**។ អ្នកម្ដាយតេរេសាធ្លាប់មានប្រសាសន៍ថា **"យើងដែលជាអ្នកបាប ជួនកាលយើងគ្មានទុកកន្លែងណាមួយក្នុងចិត្តរបស់យើងថ្វាយព្រះជាម្ចាស់ទេ គឺក្នុងដួងចិត្តរបស់យើងពេញដោយភាពងងឹតពេញដោយអំពើអាក្រក់"**។ ហេតុនេះហើយ យើងត្រូវតែស្រាយបាបរបស់យើង ត្រូវដកភាពងងឹតពីក្នុងចិត្ត ត្រូវដកចេញនូវអ្វីៗទាំងអស់ដែលរាំងផ្លូវយើងឆ្ពោះទៅរកព្រះជាម្ចាស់ដោយយើងមកសម្រុះសម្រួល ទទួលការលើកលែងទោសពីព្រះជាម្ចាស់ ដើម្បីឲ្យព្រះជាម្ចាស់មានកន្លែងមួយគង់នៅក្នុងដួងចិត្តរបស់យើង ដើម្បីឲ្យសេចក្ដីស្រឡាញ់របស់ព្រះគ្រីស្ដចូលពេញក្នុងខ្លួនរបស់យើង ដែលពេលនោះខ្លួនរបស់យើងប្រៀបដូចជាអាងទឹកមួយដែលពោរពេញដោយសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ ដែលសេចក្ដីស្រឡាញ់នោះនឹងហៀរចេញពីអាងនៃដួងចិត្តរបស់យើងទៅលើអ្នកដទៃ។ យើងអាចធ្វើកិច្ចការគ្រប់យ៉ាងក្នុងសេចក្ដីស្រឡាញ់បានលុះត្រាយើងទទួលការលើកលែងទោស ដោយសារមានតែការលើកលែងទោសទេដែលនាំឲ្យដួងចិត្តរបស់យើងមានកន្លែងមួយថ្វាយព្រះយេស៊ូដែលពុងស្រេក។

យើងត្រូវផ្ដល់សក្ខីភាពអំពីសេចក្ដីស្រឡាញ់។ អ្នកម្ដាយតេរេសាធ្លាប់មានប្រសាសន៍ថា ប្រសិនបើអ្នកគ្មានសមត្ថភាពដើម្បីចិញ្ចឹមមនុស្ស១០០នាក់ នោះសូមចិញ្ចឹមតែម្នាក់ក៏បាន។ ពេលចេញពីពិធីបុណ្យនេះទៅ ដោយសារយើងបានទទួលកម្លាំងពីអ្នកម្ដាយតេរេសា និងព្រះយេស៊ូដែលកំពុងសម្លឹងមើលយើង នោះសូមឲ្យយើងសម្រេចចិត្តនៅថ្ងៃនេះថា **"តទៅទោះបីខ្ញុំជួយមនុស្ស១០០នាក់មិនបាន តែខ្ញុំត្រូវតែជួយឲ្យបានម្នាក់"**។ ធម៌មេត្តាករុណាតម្រូវឲ្យយើងភ្ញាក់ស្មារតីគ្រប់ពេលវេលាដើម្បីផ្ដល់សក្ខីភាព អ្នកម្ដាយតេរេសាមានប្រសាសន៍ថា យើងរស់នៅក្នុងមហាសមុទ្រនៃភាពក្រីក្រកម្សត់ទុរគត ប៉ុន្តែយើងអាចបង្រួមមហាសមុទ្រនោះឲ្យតូចជាងប្រសិនបើយើងខិតខំរស់នៅក្នុងសេចក្ដីស្រឡាញ់ ខិតខំកសាងពិភពលោកថ្មី។ ពេលយើងធ្វើ

ជាអ្នកបម្រើកិច្ចការរបស់យើងគឺកសាងសុខសន្តិភាពតាមពាក្យអធិដ្ឋានរបស់អ្នកម្ដាយតេរេសាថា **"ផលផ្លែនៃការបម្រើគឺសន្តិភាព"**។

ថ្ងៃនេះ ខ្ញុំសូមអញ្ជើញបងប្អូនទាំងអស់ធ្វើជាទូតនៃសុខសន្តិភាពសម្រាប់សង្គមរបស់យើង។ ខ្ញុំមានយោបល់មួយដោយសូមឲ្យការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិកកម្ពុជាបង្កើតទំព័រហ្វេសបុកមួយដែលមានឈ្មោះថា **"ព្រះសហគមន៍កាតូលិកកម្ពុជា ដើម្បីកសាងសុខសន្តិភាព"** សម្រាប់បងប្អូនទាំងអស់ ជាពិសេសសម្រាប់យុវជនយុវនារីយើង និងសម្រាប់បងប្អូនយើងដែលកំពុងប្រើប្រាស់ទូរស័ព្ទដៃ។ ខ្ញុំចង់ឲ្យទំព័រហ្វេសបុកនេះ ទៅជាកន្លែងមួយដើម្បីឲ្យយើងទាំងអស់គ្នាផុសគ្រប់ព័ត៌មានដែលទាក់ទងនឹងសុខសន្តិភាព។ ពេលយើងមានរូបថតមួយយ៉ាងស្អាតដែលបង្ហោះទៅណែនាំឲ្យមានសន្តិភាព នោះចូរផុសទៅ។ ពេលយើងមានគំនិតមួយដែលណែនាំឲ្យមានសន្តិភាពចូរផុសទៅ។ ពេលយើងមានពិសោធន៍ជាក់ស្ដែងមួយ ឧទាហរណ៍ថាថ្ងៃនេះខ្ញុំបានជួយសម្រុះសម្រួលមិត្តភក្តិពីរនាក់ ឲ្យគេស្រុះស្រួលគ្នា នោះចូរផុសទៅ ដើម្បីឲ្យព្រះសហគមន៍របស់យើង ឲ្យប្រទេសកម្ពុជារបស់យើងកើតមានតែសម្លេងអំពីសុខសន្តិភាព។ ពេលទំព័រហ្វេសបុកនេះរៀបចំហើយ គឺយើងទាំងអស់គ្នាជាអ្នកចូលរួមចិញ្ចឹមឲ្យមានដំណើរការរាល់ថ្ងៃ ដោយយើងចែករំលែកនូវពត៌មាន មតិយោបល់ រូបភាព ឬជាអ្វីក៏បានដែលនាំ មកនូវសុខសន្តិភាពសម្រាប់ក្រុមគ្រួសារ សម្រាប់សាលាសម្រាប់ព្រះសហគមន៍ និងសម្រាប់សង្គមរបស់យើង។ យើងហាមជាដាច់ខាតនូវការផុសទាំងឡាយណាដែលផ្ទុយនឹងសុខសន្តិភាព។ សូមឲ្យព្រះសហគមន៍កាតូលិករបស់យើងមានសម្លេងតាមរបៀបដែលនាំឲ្យមានសុខសន្តិភាព។

យើងខ្ញុំសូមអរព្រះគុណព្រះជាម្ចាស់ សូមព្រះអង្គគង់នៅជាមួយយើងខ្ញុំ ដើម្បីឲ្យយើងខ្ញុំបន្តរួមគ្នាបំពេញតួនាទីរបស់យើងខ្ញុំ ដោយនឹកគិតដល់ប្រសាសន៍អ្នកម្ដាយតេរេសាថា **"ផលផ្លែនៃភាពស្ងៀមស្ងាត់គឺអធិដ្ឋាន ផលផ្លែនៃការអធិដ្ឋានគឺជំនឿ ផលផ្លែនៃជំនឿគឺសេចក្ដីស្រឡាញ់ ផលផ្លែនៃសេចក្ដីស្រឡាញ់គឺបម្រើ ផលផ្លែនៃការបម្រើគឺសន្តិភាព"** ដ្បិតព្រះជាម្ចាស់ជាសេចក្ដីស្រឡាញ់។

# សូមព្រះជាម្ចាស់ប្រទានពរឲ្យយើងជាអ្នកកសាងសន្តិភាព

Blessed are the peacemakers

អត្ថបទទី១៖ ហាគ ១, ២-៣ និង ២, ២-៤
អត្ថបទទី២៖ ធម ១, ៦-៨. ១៣-១៤
ដំណឹងល្អ៖ លក ១៧, ៥-១០

ប៉ុន្មានថ្ងៃកន្លងមក គេល្បីរឿងទេសចរណ៍ទៅស្ថាននរក ប៉ុន្តែសម្រាប់យើងជាគ្រីស្តបរិស័ទ គឺយើងទេសចរណ៍ទៅស្ថានបរមសុខវិញ។ ព្រះបន្ទូលថ្ងៃនេះណែនាំឲ្យយើងយល់ខ្លះៗអំពីអ្វីដែលកើតឡើងនៅស្ថានបរមសុខ និងពីអ្វីដែលព្រះជាម្ចាស់រៀបចំសម្រាប់យើងនៅថ្ងៃអនាគត។ អត្ថបទទីពីរស្តីពីអនាគតផងនិងពេលបច្ចុប្បន្ននេះផងថែងថា "**បងប្អូនជាទីស្រឡាញ់! សូមគិតមើល ព្រះបិតាមានព្រះហឫទ័យស្រឡាញ់យើងដល់កម្រិតណាគឺព្រះអង្គស្រឡាញ់រហូតដល់ហៅយើងថាជាបុត្រធីតារបស់ព្រះអង្គ**"។ គ្រប់ពេលដែលយើងស្តាប់អត្ថបទនេះ យើងត្រូវតែរំភើបចិត្តយើងត្រូវតែមានមោទនភាពនិងកិត្តិយសរបស់យើង ដោយសារព្រះជាម្ចាស់ស្រឡាញ់យើងយ៉ាងខ្លាំងណាស់ រហូតដល់ព្រះអង្គហៅយើងថាជាបុត្រធីតារបស់ព្រះអង្គមានន័យថាជាកូនប្រុសស្រីរបស់ព្រះជាម្ចាស់។ យើងទាំងអស់គ្នាដែលនៅទីនេះដឹងថា យើងគឺជាបុត្រាបុត្រីរបស់ព្រះជាម្ចាស់។ សន្តៈយ៉ូហានបន្តថា "**ប៉ុន្តែនៅពេលព្រះគ្រីស្តយាងមកដល់យើងនឹងបានដូចព្រះអង្គដែរ**"។ អនាគតរបស់យើងគឺយើងដូចព្រះយេស៊ូ យើងចូលនៅក្នុងមហាកិត្តិយសមហាមោទនភាព ដោយសារនៅថ្ងៃអនាគតព្រះជាម្ចាស់រៀបចំឲ្យយើងបានដូចព្រះអង្គផ្ទាល់។ ដូច្នេះនៅលើផែនដីនេះ យើងត្រូវតែខិតខំរៀបចំខ្លួនដើម្បីទៅស្ថានបរមសុខដូចព្រះយេស៊ូ របៀបដែលយើងមើលឃើញព្រះយេស៊ូ គឺជារបៀបរបស់យើងនៅថ្ងៃអនាគត។ យើងពិបាកនឹងទទួល

---

ក្នុងអភិបូជាបុណ្យភ្ជុំនៅផ្សារតូច
ថ្ងៃទី០២ តុលា ២០១៦

ដំណឹងនេះណាស់ដោយនឹកឃើញពីជីវិតរបស់យើងដែលមានតែទុក្ខលំបាក ដែលមានបាប តើយើងនឹងដូចព្រះយេស៊ូយ៉ាងដូចម្ដេចបាន?

ក្នុងអត្ថបទទីមួយមានចែងថា មានមហាជនដែលមានអាវស មានគេសួរថាតើអស់អ្នកដែលពាក់អាវសវែងនោះជានរណា? ហើយគេមកពីណា?។ ចម្លើយគឺពួកគេសុទ្ធតែជាអ្នកដែលបានឆ្លងកាត់ទុក្ខវេទនាខ្លាំង គេបានបោកអាវរបស់គេបានស្អាតក្នុងព្រះលោហិតកូនចៀមរបស់ព្រះជាម្ចាស់។ មហាជនដែលពាក់អាវសនៅស្ថានបរមសុខ ជាមហាជនដែលបានឆ្លងកាត់ទុក្ខវេទនាពេលយើងស្ដាប់សេចក្ដីនេះ នាំឲ្យយើងនឹកឃើញដល់ទុក្ខលំបាកទាំងប៉ុន្មាន ដែលយើងមាននឹកឃើញដល់បាបទាំងប៉ុន្មាន ដែលយើងបានប្រព្រឹត្តណែនាំឲ្យយើងនៅឆ្ងាយពីសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ ក៏ប៉ុន្តែយើងបានលាងយើងបានបោកអាវផ្ទាល់របស់យើងបានសវិញនៅក្នុងលោហិតរបស់ព្រះគ្រីស្ត។ នៅថ្ងៃយើងទទួលអគ្គសញ្ញាជ្រមុជទឹក យើងបានបំពាក់អាវសដែលជាសញ្ញាសម្គាល់នៃជីវិតថ្មីដែលយើងបានទទួលពីព្រះគ្រីស្ត ជាសញ្ញាសម្គាល់ដែលព្រះគ្រីស្តភ្ជាប់ជាមួយយើងជានិច្ច។ អាវសដែលជាដំណើរនៃជីវិតរបស់យើង ដែលជាច្រើនដងបានប្រឡាក់ គឺប្រឡាក់នៅពេលយើងស្អប់គេ ប្រឡាក់នៅពេលយើងមើលងាយគេនៅពេលយើងប្រព្រឹត្តិអំពើបាបនានា ប៉ុន្តែយើងមានឱកាសអស់មួយជីវិតដើម្បីឲ្យយើងសទៅៗ ដោយសារយើងប្រែចិត្តគំនិត។ ដើម្បីចូលខ្លួននៅស្ថានបរមសុខ នោះយើងត្រូវចូលខ្លួននៅក្នុងចំណោមមហាជនដែលមានអាវសយ៉ាងស្អាតនេះ ដូច្នេះ យើងត្រូវតែប្រែចិត្តគំនិត។

ព្រះគម្ពីរដំណឹងល្អថ្ងៃនេះមានចែងថា **"អ្នកណាកសាងសន្តិភាព អ្នកនោះមានសុភមង្គល ហើយដ្បិតពួកគេនឹងមានឈ្មោះជាបុត្រធីតារបស់ព្រះជាម្ចាស់"**។ ដូច្នេះនៅលើផែនដីនេះ យើងដែលជាបុត្រធីតារបស់ព្រះជាម្ចាស់ មានតួនាទីមួយយ៉ាងពិសេសគឺយើងត្រូវកសាងសន្តិភាពដែលជាសេចក្ដីត្រូវការយ៉ាងចំបាច់របស់ពិភពលោកយើង និងយើងត្រូវប្រែចិត្តគំនិតដោយចាប់ផ្ដើមពីខ្លួនយើងម្នាក់ៗ ដើម្បីឲ្យអាវរបស់យើងដែលប្រឡាក់ទៅជាអាវដែលសទៅៗ។ ប៉ុន្មានថ្ងៃមុនអតីតនាយករដ្ឋមន្ត្រីប្រទេសអ៊ីស្រាអែលបានទទួលមរណភាព អស់មួយជីវិត គាត់បានខិត

ខំកសាងសន្តិភាពនៅលើទឹកដីកំណើតរបស់ព្រះយេស៊ូ ដែលសព្វថ្ងៃនៅតែបន្តមានសង្គ្រាមឥតឈប់សោះ។ គេបានធ្វើពិធីគោរពសពរបស់លោកនៅទីក្រុងយេរូសាឡឹម ដែលមានវត្តមានមេដឹកនាំនៃប្រទេសនានាក្នុងពិភពលោកមកចូលរួម។ ក្នុងឱកាសនោះមេដឹកនាំដែលជាខ្មាំងសត្រូវគ្នា បានអង្គុយនៅក្បែរគ្នាដើម្បីគោរពវិញ្ញាណក្ខន្ធរបស់គាត់ ដែលជាអ្នកបានខិតខំកសាងសន្តិភាពនៅប្រទេសរបស់ព្រះយេស៊ូ។ ប្រទេសអ៊ីស្រាអែលនិងប៉ាឡេស្ទីនចេះតែស្អប់គ្នាឈ្លោះគ្នាមិនដែលត្រូវគ្នាសោះ។

ប៉ុន្តែសម្រាប់ជីវិតរបស់យើងគឺចាប់ពីពេលនេះតទៅ យើងត្រូវតែចាប់ធ្វើសកម្មភាពតូចណាមួយដើម្បីកសាងសុខសន្តិភាព។ កាលពីអាទិត្យមុន ស្ថាបនិកនៃអង្គការភាពញញឹមនៃកុមារបានទទួលមរណភាព ដែលមានមនុស្សជាច្រើនបានចូលរួមគោរពសពរបស់គាត់។ នៅក្នុងហ្វេសបុក CSC ផុសព័ត៌មានពីមរណភាពនេះ មានមនុស្សជាងមួយលាននាក់ដែលបានចូលមើល។ ជីវិតរបស់ PAPY អស្ចារ្យមែនទែន ដ្បិតកាលពី២៥ឆ្នាំមុន ពេលចូលនិវត្តន៍ក្នុងអាយុ៦០ឆ្នាំ គាត់ពីរនាក់ប្ដីប្រពន្ធបានមកលេងប្រទេសកម្ពុជា ពេលនោះគាត់បានឃើញកូនក្មេងរើសសម្រាមនៅស្ទឹងមានជ័យ គាត់អាណិតក្មេងៗទាំងនោះណាស់ គាត់គិតថាមិនអាចទុកឲ្យក្មេងៗរស់នៅលើភ្នំសម្រាមដែលគ្មានអនាម័យ គ្មានការសិក្សា គ្មានម្ហូបអាហារគ្រប់គ្រាន់ គ្មានអនាគតដូចនេះបានទេ។ ដូច្នេះគាត់ពីរនាក់ប្ដីប្រពន្ធបានជួយឲ្យកូនក្មេងបីបួននាក់ទៅរៀន ក្រោយមកមានសប្បុរសជនចូលរួមជួយជាមួយគាត់ ដែលរហូតដល់សព្វថ្ងៃមានកុមាររាប់ម៉ឺននាក់បានទទួលការសិក្សាពីអង្គការនេះ។

អង្គការកុមារមេត្តាក៏ដូចគ្នាដែរ នៅឆ្នាំ១៩៦០ អ្នកដែលបង្កើតអង្គការនេះបានទៅលេងប្រទេសឡាវ និងប្រទេសវៀតណាម។ ពេលនោះគាត់ឃើញមានកូនក្មេងអនាថាគ្មានលទ្ធភាពនឹងចូលរៀន គាត់អាណិតគេហើយក៏ទៅរកឪពុកម្ដាយធម៌នៅប្រទេសបារាំងឲ្យជួយលុយបន្តិចបន្តួច ដើម្បីឲ្យកុមារទាំងនោះអាចទៅសាលាបាន។ គាត់ចាប់ផ្ដើមពីកុមារប៉ុន្មាននាក់ប៉ុណ្ណោះ ដែលសព្វថ្ងៃអង្គការនេះបានជួយកុមាររាប់ម៉ឺននាក់ឲ្យបានទៅសាលារៀន។ អ្នក

ម្តាយតេរេសាក៏ដូចគ្នា បានចាប់ផ្តើមដោយជួយឲ្យបុរសអនាថាម្នាក់ដែលឈឺនៅតាមដងផ្លូវបាន ទទួលការថែទាំ ក្រោយមកមានអ្នកជំងឺអនាថាជាច្រើនមកសូមឲ្យគាត់ជួយ ដែលសព្វថ្ងៃនេះ មានក្រុមបងស្រីមេត្តាករុណានាំសេចក្តីសុខសាន្តទៅកន្លែងជាច្រើនក្នុងពិភពលោកទាំងមូល។ សន្តៈហ្វ្រង់ស្វ័រនៃទីក្រុងអាស៊ីស៊ីក៏ដូចគ្នាដែរ ក្រោយពីបានជួបមនុស្សឃ្លង់ម្នាក់ដែលគាត់បាន ថើបនៅតាមដងផ្លូវ គាត់បានចាប់ផ្តើមសកម្មភាពជាមួយអ្នកក្រីក្របំផុត។ សព្វថ្ងៃមានមនុស្ស រាប់លាននាក់បានទទួលសេចក្តីស្រឡាញ់តាមរយៈក្រុម ហ្វ្រង់ស៊ីស្កូ ដែលសន្តហ្វ្រង់ស្វ័របាន បង្កើត។

សម្រាប់យើងជាគ្រីស្តបរិស័ទនៅទីនេះក៏ដូចគ្នាដែរ សប្តាហ៍មុនយើងបានប្រារព្ធសន្និបាត នៃព្រះមហាករុណាទិគុណរបស់ភូមិភាគភ្នំពេញ។ នៅពេលថ្វាយអភិបូជាបិទ តាមមណ្ឌល សកម្មភាពនីមួយៗបានឡើងប្រកាសថា ឆ្នាំក្រោយយើងខិតខំអនុវត្តគម្រោងការមេត្តាករុណា របស់យើងតាមចំណុចទាំងប៉ុន្មានដែលយើងបានមូលមតិគ្នា។យើងខិតខំណែនាំឲ្យមានសន្តិភាព នៅគ្រប់ទីកន្លែងដែលយើងរស់នៅ។ យើងយកចិត្តទុកដាក់កសាងសន្តិភាព តាមរយៈព្រះ-សហគមន៍ និងតាមរយៈសកម្មភាពរបស់យើងម្នាក់ដែរ ដោយយើងដឹងថា **"អ្នកណាកសាង សន្តិភាពអ្នកនោះមានសុភមង្គលហើយ ត្បិតពួកគេមានឈ្មោះជាបុត្រធីតារបស់ព្រះជាម្ចាស់"** ដែល បន្តិចម្តងៗជួយឲ្យសង្គមរបស់យើងមានសេចក្តីសុខសាន្ត ជួយឲ្យជីវិតរបស់យើងរកឃើញ សេចក្តីសង្ឃឹម និងជួយឲ្យអាវសដែលយើងបានទទួលនៅពេលទទួលអគ្គសញ្ញាជ្រមុជទឹក ដែលឥឡូវបានប្រឡាក់ ក្លាយជាសទៅៗដើម្បីយើងអាចមើលឃើញព្រះយេស៊ូនៅថ្ងៃអនាគត ដូចព្រះអង្គមានព្រះបន្ទូលថា "អ្នកណាមានសេចក្តីសង្ឃឹមលើព្រះអង្គបែបនេះ អ្នកនោះបាន ជម្រះខ្លួនឲ្យបរិសុទ្ធដូចព្រះអង្គទ្រង់បរិសុទ្ធដែរ"។

ថ្ងៃនេះយើងគោរពសន្តៈសន្តិបុគ្គលនិងបុព្វការីជនរបស់យើងទាំងអស់ ដែលបាន ទទួលមរណភាពទៅ។ យើងគោរពដោយជំនឿ និងដោយយកចិត្តទុកដាក់កសាងសុខសន្តិភាព ថ្មីៗថែមទៀតសម្រាប់សង្គម និងព្រះសហគមន៍របស់យើង។ សប្តាហ៍មុនខ្ញុំបានសុំឲ្យបង្កើត

ហ្វេសបុកមួយដែលមានចំណងជើងថា ព្រះសហគមន៍កាតូលិកកម្ពុជាកសាងសន្តិភាព ដែលយើងអាចផុសគ្រប់សកម្មភាព គ្រប់ព័ត៌មាន គ្រប់អត្ថបទ គ្រប់រូបភាពដែលយើងបានធ្វើទាក់ទងនឹងការកសាងសុខសន្តិភាព ដើម្បីឲ្យព្រះសហគមន៍របស់យើងមានឈ្មោះក្នុងការកសាងសុខសន្តិភាពនៅប្រទេសកម្ពុជា។ ដូច្នេះនៅថ្ងៃនេះ យើងគោរពសន្តៈសន្តីបុគ្គលដោយដឹងថាយើងក៏នឹងមានឈ្មោះជាសន្តៈសន្តីទៅថ្ងៃអនាគតដែរ ដោយសារព្រះជាម្ចាស់បានជ្រើសរើសយើងដើម្បីឲ្យយើងធ្វើដំណើររួមជាមួយព្រះអង្គ។

យើងខ្ញុំសូមអរព្រះគុណព្រះជាម្ចាស់ សូមព្រះអង្គគង់នៅជាមួយយើងខ្ញុំ ដើម្បីឲ្យព្រះ-អាទិត្យថ្មីរះលើផែនដីចាស់។

**"អ្នកណាកសាង សន្តិភាពអ្នកនោះមានសុភមង្គលហើយ ត្បិតពួកគេមានឈ្មោះជាបុត្រធីតារបស់ព្រះជាម្ចាស់"**

# ត្រូវប្រែចិត្តគំនិត, លើកលែងទោស, និងធ្វើជាសាក្សី

ខ្ញុំកំពុងតែជិះរថភ្លើងដែលបរយ៉ាងលឿនបំផុតត្រឡប់ទៅអាកាសយានដ្ឋានយ៉ូហានប៉ូល ទី២ នៅក្រុងក្រាកូវី (Crakovie) ប្រទេសប៉ូឡូញ។ ខ្ញុំនៅតែស្ងើចសរសើរ ពេលមើលឃើញទេសភាពស្រុកស្រែដ៏ល្អ ដែលខៀវស្រងាត់ ដែលមានផ្កាភ្ញីចម្រុះពណ៌ និងមានមេអំបៅមកក្រេបក្លិនក្រអូប និងជញ្ជក់ទឹកដមពីផ្កាទាំងរីករាយ។ ខ្ញុំក៏នឹកគិតដល់អ្វីៗដែលខ្ញុំបានឃើញប៉ុន្មានថ្ងៃកន្លងមក គឺដល់មហាជនរបស់យុវជនយុវនារី ដែលមានអំណរសប្បាយនៅពេលច្រៀងលើកតម្កើងស្នាព្រះហស្តដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ ខ្ញុំនឹកដល់សម្ដេចប៉ាប ហ្វ្រង់ស៊ីស្កូ ដែលបានអញ្ជើញយើងឲ្យកែប្រែពិភពលោកយើងនេះ ខ្ញុំនឹកដល់អស់លោកអភិបាល ដែលកាន់ឆ័ត្រការពារកម្ដៅថ្ងៃ ខ្ញុំនឹកដល់ដងផ្លូវនៅទីក្រុងក្រាកូវីដែលមានយុវជនសើចលេងអ៊ូអរ ដោយកាន់ទង់ជាតិប្រទេសរៀងៗខ្លួនមកពីពិភពលោកទាំងមូល។ ខ្ញុំនឹកដល់ក្រុមយុវជនយុវនារី ដែលមកពីប្រទេសកម្ពុជាយើង គេអស់កម្លាំងតែគេសប្បាយរីករាយ។

ជាពិសេស ខ្ញុំនៅតែនឹកគិតនិងនឹកគិតទៀតមិនអាចបំភ្លេចបាន គឺស្ថានីយ៍រថភ្លើងដែលគ្មានមនុស្សដើរមានតែខ្សែរថភ្លើងឆ្ងាត់ឆ្ងៃង មានខ្ទមសាងសង់ពីបន្ទះក្ដារច្រើនឥតគណនា... មានបំពង់ផ្សែង... គឺនៅភូមិអោហ្វីត្សបៀរកេណៅ (Auschwitz Birkenau)... មានសក់រាប់តោនទុកសម្រាប់ត្បាញធ្វើជាអាវបំពង់... មានវ៉ាលីដែលនៅតែមានសរសេរឈ្មោះម្ចាស់របស់វាដែលម្ចាស់របស់វានោះបានរត់ប្រសេចប្រសាចទាំងភ័យខ្លាចចោលវា... ខ្ញុំនឹកដល់បន្ទប់មុជទឹក

---

សារលិខិតលោកអភិបាល អូលីវីយេ
បុណ្យព្រះនាងម៉ារីចូលទុក្ខលំបាក
ថ្ងៃទី១៥ កញ្ញា ២០១៦

ដែលនៅលើពិដានមានបង្អួចតូចមួយ ដើម្បីទំលាក់ឧស្ម័នបំពុលសម្លាប់មនុស្ស... ខ្ញុំនឹកដល់ឡដែលបានដុតមនុស្ស ១,១០០,០០០នាក់ ក្នុងចំណោមនោះមានកុមារ ២៥៣,០០០នាក់ ... ពាក្យសម្តីគ្មានអត្ថន័យ...ត្រូវតែនៅស្ងៀម...ទុកឲ្យទឹកភ្នែកហូរចេញ...។

មនុស្សក្លាយទៅជាអមនុស្សធម៌ ដោយបានយក មនុស្សដែលគ្មានទោសច្រើនឥតគណនាមកឆ្កាងដោយអយុត្តិធម៌ដូច្នេះ...

ខ្ញុំនឹកដល់ក្រុមយុវជនយុវនារីខ្មែរយើង ដែលកំពុងសូត្រផ្ដាំនៅខាងមុខផ្នូររបស់សន្តីហ្វូស្ទីណា (Faustina) សូមព្រះជាម្ចាស់ប្រទានសេចក្តីសុខសាន្តឲ្យប្រទេសកម្ពុជាយើងឲ្យពិភពលោកទាំងមូលបានប្រកបដោយសុខសន្តិភាព... គេលុតជង្គង់នៅមុខជបតូចដែលមានដាក់ឈាមរបស់សន្តយ៉ូហានប៉ូលទី២។ គេឈរនៅខាងមុខអាវវែងដែលប្រឡាក់ឈាមរបស់លោក និងដែលរូបលោកគ្មានទោសសោះ... គេនៅស្ងៀមស្ងាត់...។

ខ្ញុំនៅខាងមុខរបងថ្ម ជាកន្លែងគេបាញ់សម្លាប់មនុស្សដែលឥតមានទោសជាច្រើននាក់ចោល... អគារទី១១ ជាកន្លែងទុកមនុស្សចោលឲ្យស្លាប់នៅទីនោះ... ខ្ញុំដើរនៅក្នុងរបៀងងងឹតនិងសើមៗ ទៅដល់គុកក្រោមដីបន្ទប់លេខ១៨។ បន្ទប់តូចមួយនោះជាកន្លែងលោកម៉ាក់-ស៊ីមីលីយាំង កូលបេ (Maximilien Kolbe) ទទួលមរណភាព គឺលោកទទួលមរណភាពដោយសេចក្តីស្រឡាញ់ ដូចព្រះអម្ចាស់របស់លោកដែរ។ ពន្លឺនៃសេចក្តីស្រឡាញ់ បានភ្លឺឡើងពីជម្រៅបំផុតនៃភាពងងឹតអន្ធិកានៃភាពអមនុស្សធម៌។ ឥឡូវអ្វីៗទាំងអស់ ស្ងាត់ស្ងៀមក្នុងស្ថាននរកអវិចីនេះ។ មានតែអណ្តាតភ្លើងទៀនមួយប៉ុណ្ណោះ កំពុងឆេះញ័រៗដែលរំឭកយើងថា សម្តេចប៉ាបហ្វ្រង់ស៊ីស្កូ មកទស្សនាទីនេះពីម្សិលមិញ។

នៅពេលនោះ ខ្ញុំនឹកដល់ទៀនតូចៗពីរលានដើម កំពុងតែឆេះបំភ្លឺភាពងងឹតនៅទីលាននៃព្រះហឫទ័យមេត្តាករុណា និងព្រះយេស៊ូដែលបានបូជាព្រះជន្មព្រះអង្គគង់នៅទីនេះ ខាងមុខយើង។ ម្នាក់ៗនៅស្ងៀមស្ងាត់ នឹកសញ្ជឹងគិតដល់ព្រះកាយព្រះគ្រីស្ត ដែលបានបូជាព្រះជន្ម

ដើម្បីសង្គ្រោះយើងទាំងអស់គ្នា។ ម្នាក់ៗនឹកគិតអំពី ការរស់នៅរបស់ផ្ទាល់ខ្លួនថា តើខ្ញុំរួមជាមួយព្រះនាងម៉ារី និងលោកយ៉ូហាននៅក្បែរឈើឆ្កាងរបស់ព្រះយេស៊ូឬ? តើខ្ញុំលាក់ខ្លួនដូចលោកសាខេឬ? តើខ្ញុំលាក់ខ្លួនដូចក្រុមសាវ័កឬ? តើខ្ញុំដូចលោកបារទីមេ និងអ្នកឯទៀតៗទាំងប៉ុន្មានឬ?... តើខ្ញុំយំសោកហូរទឹកភ្នែកដូចលោកសិលាឬ? ឬម្យ៉ាងខ្ញុំអស់សង្ឃឹមដូចយូដា?

**"ខ្ញុំស្រេកទឹក"** ខ្ញុំឮព្រះសូរសៀងរបស់ព្រះយេស៊ូដែលគង់នៅខាងមុខយើង។ ព្រះអង្គស្រែកម្តងទៀតថា **"ខ្ញុំស្រេកទឹក"**។ មនុស្សពី១៨៧ប្រទេស កំពុងតែស្រែកដូចព្រះយេស៊ូដែរ គឺមនុស្សនៅប្រទេសស៊ីរី នៅប្រទេសអ៊ីរ៉ាក់ នៅប្រទេសកម្ពុជា នៅប្រទេសវៀតណាម។ល។... មនុស្សទាំងអស់ក្នុងទ្វីបទាំងប្រាំ ក៏រួមគ្នាស្រែកជាមួយព្រះគ្រីស្តថា **"ខ្ញុំស្រេកទឹក"**។

**"ស្រេក"** ចង់បានទឹកនៃសុខសន្តិភាព **"ស្រេក"** ចង់ឲ្យគេអត់ទោសគ្នាទៅវិញទៅមក **"ស្រេក"** ចង់បានជីវិត **"ស្រេក"** ចង់មានសេចក្តីសង្ឃឹម។

ពេលយើងដើរតាមផ្លូវឈើឆ្កាង កាលពីថ្ងៃសុក្រយើងក៏បានឮថា យើងនៅតែប្រយុទ្ធប្រឆាំងនឹងឥទ្ធិពលរបស់សេចក្តីអាក្រក់នៃភាពងងឹតអន្ធិកា សេចក្តីអាក្រក់ដែលសំងំនៅក្នុងចិត្តយើង... ដែលហៀបតែនឹងផ្ទុះឡើងជានិច្ច ដើម្បីស្តោះចេញនូវសេចក្តីសម្អប់ នូវកំហឹង នូវការសងសឹក ដោយស្មានថាអ្នកដទៃសុទ្ធតែជាខ្មាំងដែលយើងត្រូវវាយសម្លាប់ ព្រោះគេប្លែកពីយើង។ ហ៊ីត្លែ (Hitler) ប៉ុលពត អាយស៊ីស បានប្រព្រឹត្តដូច្នេះ ហើយក៏មានគេនៅតែប្រព្រឹត្តដូច្នេះតទៅទៀតដែរនាបច្ចុប្បន្នកាលនេះ។

ព្រះយេស៊ូស្រែកតទៅទៀតថា **"ខ្ញុំស្រេកទឹក"**។ *"កុំថ្កោលទោសបងប្អូន... កុំឆ្កាងគេដូចគេឆ្កាងខ្ញុំនៅលើភ្នំលលាដ៏ក្បាល... សព្វថ្ងៃមានមនោគមវិជ្ជាផ្សេងៗ មានរបបនយោបាយនានារចនាសម្ពន្ធសេដ្ឋកិច្ច ដែលមិនរាប់មនុស្សទុកជាសំខាន់ជាងគេ លទ្ធិអ្នកជាតិនិយមហួសហេតុអត្តទត្តបុគ្គលនិយមដែលគិតតែពីជាតិសាសន៍របស់ខ្លួន។ល។ នៅតែឆ្កាងខ្ញុំតទៅទៀត។ ចូរកុំចូលរួមក្នុងចំណោមគំនិតរបស់គេឡើយ។ អ្នកជាសាវ័ករបស់ខ្ញុំ ចូរសម្លឹងមើលមកម្តាយខ្ញុំ ចូរ*

*សម្លឹងមើលមកខ្ញុំ។ ចូរស្តាប់បន្ទូលដំបូងបង្អស់របស់ខ្ញុំ "ចូរប្រែចិត្តគំនិតនិងជឿដំណឹងល្អចុះ" ព្រះជាម្ចាស់ហៀបនឹងយាងមកគ្រងរាជ្យហើយ"។*

ខ្ញុំបើកភ្នែក ទៀនតូចៗទាំងប៉ុន្មានរលត់អស់ទៅហើយ... មហាជនដេកលក់បណ្តើរៗ នៅក្បែរព្រះយេស៊ូដែលទតសម្លឹងមកយើង។ យើងបានមកដល់ ក្បែតូឈូវ៉ា (Czestochowa)... នៅទីនោះមានរូបគំនូរព្រះនាងម៉ារីពណ៌ខ្មៅ ដែលមានស្នាមរបួសនៅលើព្រះភ័ក្ត្ររបស់ព្រះនាង ដោយសារភាពអាក្រក់ព្រៃផ្សៃចេញពីខាងក្នុងបេះដូងរបស់មនុស្ស... ព្រះនាងទតមកយើង។ ក្នុងវិហារនោះ មានគ្រីស្តបរិស័ទរាប់លាននាក់យកពាក្យអង្វរដ៏សុភាពរាបសា និងទុក្ខលំបាករបស់គេមកថ្វាយ។ ព្រះនាងម៉ារីអញ្ជើញគេឲ្យទៅជាសាវ័ក ព្រះនាងម៉ារីជាសាវ័កមុនគេបង្អស់ គឺតាំងពីព្រះនាងសុខចិត្តទទួលសាររបស់ទេវទូត រហូតដល់ព្រះនាងស្រក់ទឹកភ្នែកនៅលើភ្នំលលាដ៍ក្បាលជាមួយបុត្ររបស់ព្រះនាង។ ព្រះនាងម៉ារី ជាមាតាដែលសប្បាយ និងរងទុក្ខលំបាក ជាអ្នកបម្រើ និងជាអ្នកស្រឡាញ់។ ព្រះនាងបើកមាគ៌ាដែលនាំទៅកាន់ជីវិតដ៏រុងរឿង គឺដល់ការរួមរស់ក្នុងព្រះដន្មរបស់ព្រះបិតា។ ព្រះនាងម៉ារីប្រាប់យើងថា៖

***"គ្រីស្តបរិស័ទនៅប្រទេសកម្ពុជាអើយ ចូរក្រោកឡើង! ចូរទៅជាសាវ័ករបស់ព្រះយេស៊ូទៅ! ចូរទៅជាសាវ័កដ៏វិសុទ្ធរបស់ព្រះអង្គទៅ! ចូរសុខចិត្តទទួលសាររបស់ព្រះអង្គ! ចូរប្រុងខ្លួនបម្រើព្រះអង្គ! ចូរបម្រុងខ្លួនដើរតាម ព្រះយេស៊ូរហូតដល់រងទុក្ខលំបាកនៅលើឈើឆ្កាងទៅ!"។***

ព្រះនាងម៉ារីកាន់ដៃយើង ដើម្បីជួយយើងឲ្យដើរតាមបុត្ររបស់ព្រះនាងទាំងធ្វើជីវិតលើព្រះអង្គទាំងមានចិត្តស្រឡាញ់ក្នុងសេចក្តីពិត។ កុំយល់ច្រឡំយើងមិនអាចទៅជាសាវ័កមិនសូវរួសរាយ ជាសាវ័កពាក់កណ្តាលបន្តិចបន្តួចប៉ុណ្ណោះទេ ឬជាសាវ័កដោយយើងគ្រាន់តែរួមថ្វាយអភិបូជានៅថ្ងៃអាទិត្យប៉ុណ្ណោះដែរ។ ព្រះនាងម៉ារីប្រាប់យើងនៅថ្ងៃនេះថា៖

***"អ្នកចង់ទៅជាសាវ័ក ត្រូវតែប្រែចិត្តគំនិតត្រូវតែលើកលែងទោស និងផ្តល់សន្តិភាពឲ្យអ្នកដទៃ"***

## ត្រូវប្រែចិត្តគំនិត

នៅព្រះវិហារនៃមេត្តាករុណា សន្តីហ្វូស្ទីណា បានអញ្ជើញយើងឲ្យនឹកសញ្ជឹងគិតដល់ព្រះយេស៊ូ ដែលទតមើលមនុស្សលោក។ ព្រះនេត្រព្រះអង្គទម្លុះចិត្តយើង ឈាមដែលបង្ហូរពីព្រះបេះដូងរបស់ព្រះអង្គ នាំព្រះជន្មរបស់ព្រះអង្គមកស្រោចស្រពលើការរស់នៅរបស់យើង។ ទឹកដែលចេញពីព្រះបេះដូងផុសឡើង និងជម្រះយើង។ បពិត្រព្រះយេស៊ូ ខ្ញុំទុកចិត្តលើព្រះអង្គ ព្រះអង្គសព្វព្រះហឫទ័យ ឲ្យខ្ញុំប្រែចិត្តគំនិត ដើម្បីឲ្យខ្ញុំស្រឡាញ់ព្រះអង្គ។ ព្រះអង្គសព្វព្រះហឫទ័យឲ្យខ្ញុំរស់នៅសម្រាប់ព្រះអង្គ និងរួមជាមួយព្រះអង្គ ។សន្តីហ្វូស្ទីណាមាន ប្រសាសន៍មកយើងថា៖

***"បងប្អូនគ្រីស្តបរិស័ទនៅប្រទេសកម្ពុជាអើយ! ចូរប្រែចិត្តគំនិត។ ព្រះជាម្ចាស់ត្រាស់ ហៅបងប្អូនឲ្យប្រែ ចិត្តគំនិតទាំងស្រុងដើម្បីឲ្យសេចក្ដីស្រឡាញ់ និងការប្រួបរួមគ្នាគ្រងរាជ្យលើបងប្អូន"។***

ព្រះយេស៊ូសព្វព្រះហឫទ័យបង្កាត់ភ្លើង នៃសេចក្ដីស្រឡាញ់ក្នុងចិត្តបងប្អូន។ ភ្លើងនោះនឹងទៅជាសញ្ញាសម្គាល់ប្រកែកប្រឆាំងនឹងរបៀបរស់នៅរបស់លោកីយ៍ និងគោលគំនិតរបស់មនុស្សលោកផង។ កុំស្អប់គ្នាកុំអត្តទត្ថបុគ្គល(កុំគិតតែពីខ្លួនឯង) កុំទាត់ចោលអ្នកដទៃចូរស្រឡាញ់គេចូរទទួលអ្នកដទៃ យ៉ាងរាក់ទាក់នេះជាបេសកកម្មរបស់យើង។ បពិត្រព្រះយេស៊ូជាអម្ចាស់ ព្រះអង្គជារៀមច្បងរបស់យើងខ្ញុំ យើងខ្ញុំទុកចិត្តលើព្រះអង្គជារៀមច្បងហើយ។

## ត្រូវលើកលែងទោស

នៅក្បែរសន្តីហ្វូស្ទីណា សន្តយ៉ូហានប៉ូលទី២ នៅចាំយាម។ សន្តយ៉ូហានប៉ូលទី២ ពិតជាមនុស្សដ៏ប្រសើរ អស្ចារ្យលោកបានធ្វើដំណើរក្នុងពិភពលោកទាំងមូល ដើម្បីនាំព្រះហឫទ័យមេត្តាករុណារបស់ព្រះបិតា ទៅដល់គ្រប់កៀនកោះនៃពិភពលោក។ លោកបានប្រកាសអំពីព្រះហឫទ័យមេត្តាករុណានោះ។ លោកបានរស់នៅតាមព្រះហឫទ័យមេត្តាករុណានោះជា

ពិសេស នៅពេលលោកអត់ទោសដល់អ្នកដែលចង់ធ្វើឃាតលើរូបលោក។ ព្រះជាម្ចាស់មានព្រះហឫទ័យមេត្តាករុណាយ៉ាងខ្លាំងបំផុត។

ម្នាក់ៗដឹងខ្លួនថា ព្រះហស្តរបស់ព្រះបិតានៅលើបេះដូងរបស់ខ្លួនម្នាក់ៗ។ ព្រះអង្គឱនមករកហើយមានព្រះបន្ទូលថា *"យើងលើកលែងទោសឲ្យកូន កូនទៅដោយសុខសាន្តចុះ"* ព្រះបន្ទូលដែលលើកលែងទោសនេះ បានកើតជារូបរាងក្នុងការរស់នៅរបស់ខ្ញុំ។ ចិត្តខ្ញុំរីកឡើង បេះដូងខ្ញុំចង់ផ្ទុះឡើងដោយអំណរ និងដោយសេចក្ដីសុខសាន្ត។ ខ្ញុំជាអ្នកបាប ដែលព្រះបិតាលើកលែងទោសឲ្យ ព្រះបិតាបានជ្រើសរើសខ្ញុំឲ្យ លើកលែងទោសឲ្យគេដែរ គឺមិនមែនលើកលែងទោសលេងៗទេ តែឲ្យលើកលែងទោសតាមរបៀបដែលនាំទុក្ខដល់យើង គឺនាំឲ្យយើងយំសោកតាមរបៀបដែលរំដោះយើង និងប្រោសឲ្យយើងក្រោកឈរឡើងវិញ។ សន្តយ៉ូហានប៉ូលទី២ មានប្រសាសន៍មកយើងថា៖

***"គ្រីស្តបរិស័ទនៅប្រទេសកម្ពុជាអើយ ព្រះបិតាបានអត់ទោសឲ្យបងប្អូនចូរអត់ទោសឲ្យគេផង។ ចូរដកបន្លា ដែលរារាំងចិត្តគំនិតបងប្អូនដើម្បីឲ្យបងប្អូនស្រឡាញ់សេចក្ដីពិត"។***

ឥឡូវនេះ លើសពីគ្រប់សម័យទាំងអស់ ព្រះបិតាអញ្ជើញយើងជាគ្រីស្តបរិស័ទឲ្យទៅជាសញ្ញាសម្គាល់ដែលមានជីវិតរស់រវើក ឲ្យទៅជាសញ្ញាម្គាល់អំពីការលើកលែងទោសក្នុងការរស់នៅប្រចាំថ្ងៃ ក្នុងព្រះសហគមន៍យើង និងក្នុងសង្គមយើង។ អ្នកណាដែលមិនដែលទទួលការលើកលែងទោសពីគេមិនអាចលើកលែងទោសឲ្យអ្នកដទៃបានទេ។ ហេតុនេះចូរបណ្ដោយឲ្យព្រះបិតាលើកលែងទោសឲ្យខ្លួន ដើម្បីឲ្យខ្លួនលើកលែងទោសឲ្យអ្នកដទៃយ៉ាងពិតប្រាកដ។

## ធ្វើជាសាក្សី

លោក ម៉ាក់ស៊ីមីលីយាំង កូលបេ ស្រឡាញ់ព្រះគ្រីស្ត និងព្រះនាងម៉ារីជាខ្លាំងលោកហៅយើងពីក្នុងគុកជ្រៅរបស់លោក។ កាលលោកអាយុ ១១ឆ្នាំ ព្រះនាងម៉ារី លេចមកឲ្យលោក

ឃើញនៅក្រុងក្សែតូឈ្យ៉ា និងផ្តល់ក្អួងជ័យពីរដល់លោក គឺក្អួងជ័យពណ៌ស និងក្អួងជ័យពណ៌ក្រហម លោកទទួលក្អួងជ័យទាំងពីរនោះ។ ក្អួងជ័យពណ៌ស ជាសញ្ញាសម្គាល់អំពីបំណងរបស់លោកដែលចង់ផ្តល់សក្ខីភាពនៅពេលប្រកាសដំណឹងល្អ។ លោកប្រកាសដំណឹងល្អយ៉ាងខ្លាំងបំផុត នៅបុរីព្រះនាងម៉ារីមិនដែលជំពាក់បាប ដាក់ន្លែងដែលលោករស់នៅក្នុងប្រទេសប៉ូឡូញ និងនៅក្រុងណាកាសាគីនៃប្រទេសជប៉ុន។ លោកសុខចិត្តបូជា កម្លាំងកាយកម្លាំងចិត្តដើម្បីប្រកាសអំពីព្រះអម្ចាស់ និងឲ្យគេទទួលស្គាល់ព្រះមាតារបស់ព្រះអង្គ។ ក្អួងជ័យពណ៌ក្រហម ជាសញ្ញាសម្គាល់អំពីសក្ខីភាព របស់លោករហូតដល់បូជាជីវិត។ នៅព្រឹកមួយនោះ ក្នុងខែសីហាឆ្នាំ១៩៤១ ពួកណាស៊ី បានជ្រើសរើសបុរស១០នាក់ នៅអោឈិស្សទៅបាញ់សម្លាប់ជាការសងសឹក ដ្បិតកាលពីយប់មុននោះមានអ្នកទោសរត់រួចចេញពីការឃុំឃាំង។ គេជ្រើសរើសបុរសម្នាក់ ដែលមានក្រុមគ្រួសារគាត់យំយ៉ាងខ្លាំងព្រោះនឹកអាណិតដល់ប្រពន្ធកូនរបស់គាត់។ លោកម៉ាក់ស៊ីមីលីយាំង កូលបេ បានប្រាប់ទៅអ្នកជ្រើសរើសថា ៖ "ខ្ញុំសុខចិត្តស្លាប់ជំនួសអ្នកនោះ"។ លោកម៉ាក់ស៊ីមីលីយាំង កូលបេ ប្រាប់យើងថា ៖

***"ចូរផ្តល់សក្ខីភាព! បងប្អូនគ្រីស្តបរិស័ទនៅប្រទេសកម្ពុជាអើយ! ចូរខ្ពស់មុខឡើង! ចូរមានមោទនភាពទៅជាសាវ័ករបស់ព្រះគ្រីស្តក្នុងសង្គមរបស់បងប្អូន! ចូរបន្តផ្តល់សក្ខីភាពពីលោកឆ្មារ សាឡាស និងសហការីដែលបានបូជាជីវិតក្នុងស្រែរបស់បងប្អូន"។***

ការផ្តល់សក្ខីភាពប្រកាសដំណឹងល្អនេះ មិនគ្រាន់តែជាបេសកកម្មរបស់យើងប៉ុណ្ណោះ តែជាជីវិតរបស់យើងទៅវិញ គឺឲ្យយើងទៅជាសញ្ញាសម្គាល់នៃសេចក្តីស្រឡាញ់ចំពោះមនុស្សទាំងអស់ និងទៅជាសញ្ញាសម្គាល់អំពីប្រជាជននានា រួបរួមគ្នាជាផ្លូងតែមួយឲ្យមានមេត្តាករុណាចំពោះអ្នកតូចតាចជាងគេ ដោយជួយគេឲ្យក្រោកឈរឡើង ទោះបីគេមកពីកន្លែងណាក៏ដោយក៏យើងត្រូវតែស្រឡាញ់គេម្នាក់ៗដែរ។ ពិភពលោកយើងនេះត្រូវការសេចក្តីស្រឡាញ់ខ្លាំងណាស់!។ ព្រះគ្រីស្តត្រាស់ហៅយើងឲ្យស្រឡាញ់ជាបន្ទាន់នៅថ្ងៃនេះ។

*"ឥឡូវនេះ យើងមិនត្រូវចាប់ផ្ដើមស្រែកប្រឆាំងនឹង មនុស្សណាម្នាក់ទេ យើងមិនត្រូវចាប់ផ្ដើមរករឿងគ្នាទេយើងមិនត្រូវបំផ្លាញគ្នាទេ ។ យើងមិនចង់ឈ្នះការស្អប់គ្នា ដោយរឹតតែស្អប់គេទៀតទេ យើងមិនចង់ឈ្នះហិង្សា ដោយរឹតតែប្រព្រឹត្តហិង្សា ។ យើងមិនចង់ឈ្នះការភ័យខ្លាចដោយប្រព្រឹត្តអំពើដែលបណ្ដាលឲ្យរឹតតែភ័យខ្លាចទៀតទេ យើងតបឆ្លើយនឹងពិភពលោកដែលកើតសង្គ្រាមដោយប្រកាសថា សូមស្រឡាញ់គ្នាដូចបងប្អូនបង្កើតយើងជាឆ្លុងតែមួយយើងរួបរួមគ្នាជាក្រុមគ្រួសារតែមួយ" ។*

*(សម្ដេចប៉ាប ហ្វ្រង់ស៊ីស្កូ សេចក្ដីអត្ថាធិប្បាយក្នុងអភិបូជាបញ្ចប់ ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៦)*

**បុណ្យព្រះនាងម៉ារីចូលទុក្ខលំបាក ថ្ងៃទី១៥ កញ្ញា ២០១៦**




អូលីវីយេ ឆ្មឹតអឺស្លែរ

អភិបាលព្រះសហគមន៍ភូមិភាគភ្នំពេញ

# CONVERSION, FORGIVENESS, WITNESS

The landscape before me unfolds at high speed as the train rushes back to the John Paul II Airport in Krakow. In contemplating this beautiful Polish countryside, lush images jostle in my head like butterflies flitting among colorful flowers.

The images of the young crowd happy to sing the wonders of the Lord, the Holy Father calling us to change the world, the mitred heads hidden under white umbrellas for protection from the sun, the streets of Krakow full of laughter, flags from around the world, our group from Cambodia tired but happy ...

And a subliminal image detours to the deserted train station that leads to nowhere...the huts, the crematories...Auschwitz.Birkenau. The tons of hair transformed into dresses...the bags marked with the names of their owners who feared losing them as they left in a hurry...the showers with their macabre skylights in the ceiling...the ovens that burned so many bodies...1,100,000. Silence. Tears.

The heart of humanity become inhuman and crucifying so many innocent hearts.

And then the image of our group praying the rosary for peace in Cambodia, for peace in the world, in front of the tomb of St. Faustina... kneeling in front of the bulb containing the blood of John Paul II, standing in front of the white cassock stained with the blood of this just man...

Silence.

The hall of the condemned. Building 11, block of death…footsteps in the dark and damp corridor. Cell 18. He died there, Maximilian Kolbe. Death because of love. Like His Lord. In the deep darkness of inhumanity, love shone. Everything seems so quiet now in the bowels of evil. Only a candle flickers, reminding us of the visit of the Holy Father the day before.

2 million small candles illuminate the night of the Field of Mercy now. Jesus in the Host is there in front of us. In silence, everyone looks at the body of Christ offered for our salvation. Each reviews his life: I am with Mary and John at the foot of the Cross, or hidden behind a wall with Zacchaeus, or with the apostles, Bartimaeus, and all the others...in tears with Peter, or desperate with Judas?

I'm thirsty. I hear the cry of Jesus. In front of us. He still cries: I am thirsty. This is humanity's cry across 187 countries. This is Syria, Iraq, Cambodia, Vietnam...the continents of the world crying with Jesus: I thirst.

A thirst for peace. For forgiveness. For life. For hope.

On Friday evening the way of Cross. The fight against the darkness and evil forces that lie dormant in us...always quick to wake up and be vomited out as our hatred, our anger, our vengeance on the other. Enemies to kill because they are different from me. Hitler…Pol Pot… Daech have done this and it continues.

Jesus still cries: I am thirsty. Do not condemn your brother...do not crucify as did those who crucified me on Golgotha...There are so many who continue to crucify me. Today. Ideologies, political and economic

systems that do not put people at the center, exaggerated nationalism, selfish individualism...dothis. You are my disciple. Look at my mother. Look at me!

Listen to me! Remember my words: “Convert and believe in the Gospel! The Kingdom is near!”

I open my eyes. Small candles gone out...the crowd gently asleep at the foot of Jesus looking at us.

Then we are transported to Jasna Gora Monastery inCzestochowa...the Black Madonna’s face,scarred with the horrors of the human heart, looking on us. In this sanctuary, where millions of pilgrims come to offer their humble prayer, their sufferings, at the foot of the Virgin, Mary invites us to discipleship.

Mary, the first disciple, from the yes of the Annunciation to the tears of Golgotha, is there with her son. Her Mother’s heart, happy and suffering, loving and serving, opens the road to resurrection and to eternal life. Mary says to us today:

**“Wake up! Christians of Cambodia, be disciples, holy disciples. Be ready to say yes, ready to serve, ready to follow Jesus to the cross.”**

Mary leads us out to follow her son in faith, charity, and truth. We have to face facts. We cannot be lukewarm disciples. Half disciples. Disciples at Sunday mass only.

To be a disciple today, Mary tells us, is to be converted, is to forgive, and is to be a witness.

## TO BE CONVERTED

At the Sanctuary of Mercy, Saint Faustina has invited us to contemplate Christ's gaze. This gaze pierces us. The blood flowing from his heart fills us with his life, the water that gushes forth cleanses us. "Jesus, I trust in you." This is my conversion you want.  I am with you. For you. With you.Saint Faustina says to us today:

**"Be converted. Christians of Cambodia, you are called to a deep conversion. To build the kingdom of love and communion."**

Jesus desires to light a fire in our hearts. A fire which will be a sign of contradiction of the fashions and ideas of the world. No hatred. No selfishness. No exclusion. Love. Welcome. Opening. This is our mission. Jesus I trust in you.

## TO FORGIVE

A few steps from Faustina's tomb is the John Paul II Sanctuary. John Paul II the Giant! He traveled around the world to bring God's mercy toall of humanity. He proclaimed mercy and he lived it in his flesh when he forgave his would-be assassin: God rich in mercy!

Everyone feels the Father's hand on his heart. The Father leans towards me: "I forgive you. Go in peace." Words of forgiveness become true for my life. My heart expands. I want to explode with joy and peace. A sinner forgiven, God chose me to be the one who forgives. Not just from the lips, but true forgiveness that hurts, that make me cry but which also liberates and frees me.Saint John Paul II says to us today :

**"You are forgiven. Christians of Cambodia, forgive others also! Undo the chains that hinder your heart from loving in truth."**

More than ever, we Christians are called to be in our life, in our church, in our society, a living sign of forgiveness. One who has never been forgiven cannot forgive. So let us accept forgiveness in order to really forgive .

## TO BEAR WITNESS

Maximilian Kolbe, lover of Christ and of the Virgin Mary, calls us from the depths of his cell. At 11 years of age, the Virgin Mary appeared to him at Czestochowa and gave him a white crown and a red crown. He accepted both. The white, was a sign of his eagerness to be a witness by evangelizing. He would do so passionately in his “City of the Immaculate” in Poland and in Nagasaki in Japan where he gives his body and soul to proclaim the Lord and to discover his Mother. The red crown is the sign of witness in martyrdom. He would do that when one morning in August, 1941, the Nazis selected ten men at Auschwitz to be killed in retaliation for an escape the night before. A father burst into tears when the Nazis chose him. Maximilian said: “I would like to die in the place of that man.” Kolbe says to us today :

**“Be a witness. Christians of Cambodia, follow Chhmar Salas and his companions who shed their blood in your rice fields. Be proud to be disciples and apostles of Christ.”**

More than our mission, that is our life itself: to be a sign of fraternal love and communion among peoples; to have compassion for the small ones by helping them stand up; to love everyone from wherever he comes.

Our world needs so much love. This is the urgent call of Christ to us today!

> *"This is no time for denouncing anyone or fighting. We do not want to tear down. We have no desire to conquer hatred with more hatred, violence with more violence, terror with more terror. We are here today because the Lord has called us together. Our response to a world at war has a name: its name is fraternity, its name is brotherhood, its name is communion, its name is family. We celebrate the fact that coming from different cultures, we have come together to pray. Let our best word, our best argument, be our unity in prayer. "*
> *(Pope Francis, WYD Prayer Vigil Homily, July 30, 2016)*

FEAST OF OUR LADY OF SORROWS, 15 September 2016




\+ Olivier Schmitthaeusler

Vicar Apostolic of Phnom Penh

Cambodia

## SE CONVERTIR, PARDONNER, TEMOIGNER...

Les paysages défilent à grande vitesse devant moi dans le train qui me ramène à l'aéroport Jean Paul II de Cracovie. En contemplant cette belle campagne polonaise verdoyante, colorée de fleurs que les papillons viennent butiner avec plaisir, les images se bousculent dans ma tête.

Cette foule de jeunes heureux de chanter les merveilles du Seigneur, le Saint Père qui nous appelle à changer le monde, les têtes mitrées cachées sous des parapluies blanc pour se protéger du soleil, les rues de Cracovie pleines de rires et de drapeaux du monde entier, notre groupe du Cambodge fatigué mais heureux…

Et comme une image subliminale, revient en boucle cette gare déserte qui ne mène nulle part… ces baraquements, ces cheminées… Auschwitz. Birkenau. Ces tonnes de cheveux transformés en robes… ces valises marquées du nom de leurs propriétaires partis en hâte de crainte de les perdre…ces douches avec leurs lucarnes macabres dans le plafond… ces fours qui ont brulé tant et tant de corps…1.100.000. Silence des mots. Larmes.

Le cœur de l'homme devenu inhumain a crucifié tant et tant de coeurs innocents.

Et revoilà notre groupe qui prie le chapelet pour la paix au Cambodge, la paix dans le monde devant la tombe de Sainte Faustine…à genoux devant l'ampoule qui contient le sang de Saint Jean Paul 2,

debout devant cette soutanetachée du sang du juste… Silence.

Le mur des condamnés. Le Bâtiment 11, bloc de la mort… des bruits de pas dans ce couloir obscur et humide. Cellule 18. Il est mort là. Maximilien Kolbe. Mort d'amour. Comme son Seigneur. Au plus profond des ténèbres de l'inhumanité, l'amour a brillé. Tout semble si calme maintenant dans les entrailles du Mal. Seule une bougie scintille, nous rappelant la visite du Saint Père la veille.

2 millions de petites bougies illuminent la nuit du Campus de la Miséricorde. Jésus Hostie est là devant nous. En silence, chacun contemple le Corps du Christ offert pour notre salut. Chacun revoit sa vie : suis-je avec Marie et Jean au pied de la Croix ou cachéderrière un mur avec Zachée, les apôtres, Bartimée et tout les autres… en larmes avec Pierre, désespéré avec Judas ?

J'ai soif. J'entends le cri de Jésus. Devant nous. Il crie encore une fois : j'ai soif. C'est le cri de l'humanitérassembléàtravers 187 pays. C'est la Syrie, l'Iraq, le Cambodge, le Vietnam, la France… les continents du monde joignent leurs crisà celui du Christ : J'ai soif.

Soif de paix. De pardon. De vie. D'espérance.

Le chemin de croix de vendredi soir nous l'a dit. Le combat est engagé contre les ténèbres et les forces du mal qui sommeillent en nous… toujours promptsà se réveiller pour vomir notre haine, notre colère, notre vengeance sur l'autre. Ennemisàabattre car différents, car autres que moi. Hitler. Pol Pot. Daech l'ont fait et continuent à le faire.

Jésus crie encore :j'ai soif. Ne condamne pas ton frère… ne le crucifie pas comme ceux qui m'ont crucifié sur le Golgotha… Il y en a tant  qui continuentà me crucifier. Aujourd'hui. Les idéologies, les sys-

tèmes politiques et économiques qui ne mettent pas l'homme au centre, les nationalismes exacerbés, les égoïsmes identitaires… ne soit de cela. Tu es mon disciple. Regarde ma mère. Regarde-moi !

Ecoute moi ! Rappelle-toi ma première parole : « convertissez-vous et croyez à l'Evangile ! Le Royaume est proche ! »

J'ouvre les yeux. Les petites bougies sont éteintes… la foule s'endort doucement au pied de Jésus qui nous regarde.

Nous voilà transporté à Czestochowa…JasnaGora : la Vierge Noire au visage balafré des horreurs du Coeur de l'homme, nous regarde. Dans ce sanctuaire où des millions de fidèles viennent offrir leur humble prière, leurs souffrances au pied de la Vierge, Marie nous invite à être disciple.

Marie première disciple, du oui de l'Annonciation aux larmes du Golgotha, Marie est là avec son fils. Coeur de mère heureuse et souffrante, servante et aimante, Marie nous ouvre le chemin qui mène à la résurrection, à la vie éternelle. Elle nous dit :

***« Debout. Chrétiens du Cambodge !Soyez disciples, saints disciples. Soyez prêts à dire oui, prêts à servir, prêts à suivre Jésus jusqu'à la croix. »***

Marie nous prend la main pour nous aider à suivre son fils avec foi, charité et vérité.Ne nous voilons pas la face. Nous ne pouvons pas être disciples tièdes. A moitié. Un peu le dimanche à la messe.

Être disciple, et Marie nous le dit aujourd'hui, c'est se convertir, c'est pardonner et c'est témoigner.

## SE CONVERTIR

Au sanctuaire de la Miséricorde, Sainte Faustinanous a invité à contempler leregard du Christ. Ce regard nous transperce, le sang qui s'écoule de son cœur nous irrigue de sa vie, l'eau qui en jailli nous purifie.  « Jésus, j'ai confiance en toi ». C'est ma conversion que tu veux. Pour que je sois à toi. Pour toi. Avec toi. Faustina nous dit :

***« Convertissez-vous. Chrétiens du Cambodge, vous êtes appelés à une conversion en profondeur. Pour que le royaume d'amour  et de communion advienne. »***

Jésus désire tant allumer un feu dans nos cœurs. Un feu qui sera signe de contradiction  avec la mode et les idées du monde. Pas de haine. Pas d'égoïsme. Pas d'exclusion. Amour. Accueil. Ouverture. C'est notre mission. Jésus j'ai confiance en toi.

## PARDONNER

A quelques pas de Faustine, c'est saint Jean Paul II qui veille. Jean-Paul II le Géant ! Il a parcouru le monde pour apporter la miséricorde de Dieu jusqu'au moindre recoin de l'humanité. Il l'a annoncée. Il l'a vécue dans sa chair lorsqu'il a pardonné à son assassin : Dieu riche en miséricorde !

Chacun sent la main du Père sur son cœur. Il se penche vers moi. : « Je te pardonne. Va en paix. » Parole de pardon qui devient réalité pour ma vie. Mon coeur se dilate.  Il veut exploser de joie et de paix. Pêcheur pardonné, Dieu me choisit pour être aussi celui qui pardonne. Pas du bout des lèvres, ni du cœur, mais un vrai pardon qui fait mal, qui fait pleurer mais qui libère et remet debout. Jean Paul II nous dit :

***« Vous êtes pardonnés, pardonnez à votre tour chrétiens du Cambodge. Libérez les chaines qui entravent votre cœur pour aimer en vérité.»***

Plus que jamais, nous chrétiens nous sommes appelés à être dans notre vie, dans notre Eglise, dans notre société des signes vivants du pardon. Celui qui n’a jamais été pardonné ne peut pas pardonner. Alors laissons nous pardonner pour pardonner vraiment.

## TEMOIGNER

C’est Maximilien Kolbe, amoureux du Christ et de la Vierge Marie qui nous appelle du fond de son cachot. A 11 ans, la Vierge Marie lui apparait àCzestochowa et lui donne une couronne blanche et une rouge. Il les accepte. La blanche, signe de son désir ardent de témoigner en évangélisant. Il le fera avec tant de passion dans sa « Cité de l’Immaculée » en Pologne et au Japon à Nagasaki où il se donne corps et âme pour annoncerle Seigneur et faire découvrir sa Mère. La rouge, signe du témoignage jusqu’aumartyrequ’il fera lorsque ce matin d’aout 1941, les nazis ont sélectionné 10 hommes àAuschwitz pour être tués en représaillesà une évasion la nuit d’avant. Le père de famille qui fond en larmes quand il est choisi lui doit sa vie : «je voudrais mourir à la place de cette homme». Maximilien Kolbe nous dit :

**« Témoignez, chrétiens du Cambodge. A la suite de Chmar Salas et de ses compagnons qui ont versé leur sang dans vos rizières, soyez fiers d’êtredisciples et apôtres du Christ dans votre société. »**

Plus que notre mission, c'est notre vie même : être signe d'amour fraternel et de communion entre les peuples ; avoir de la compassion pour les plus petits en les aidantà se mettre debout ; aimer, simplement chacun d'où qu'il vienne.

Notre Monde a tant besoin d'Amour. C'est l'appel urgent du Christ pour nous aujourd'hui !

> *« À présent, nous, nous ne mettrons pas à crier contre quelqu'un, nous ne mettrons pas à nous quereller, nous ne voulons pas détruire. Nous, nous ne voulons pas vaincre la haine par davantage de haine, vaincre la violence par davantage de violence, vaincre la terreur par davantage de terreur. Et notre réponse à ce monde en guerre a un nom : elle s'appelle fraternité, elle s'appelle lien fraternel, elle s'appelle communion, elle s'appelle famille. Nous célébrons le fait de venir de diverses cultures et nous nous unissons pour prier. Que notre meilleure parole, notre meilleur discours soit de nous unir en prière… » (Pape François, JMJ, Homélie messe de clôture, 31 juillet 2016)*

Fête de Notre Dame des Douleurs, 15 Septembre 2016

+OLIVIER SCHMITTHAEUSLER

Vicaire Apostolique de Phnom Penh

Cambodge



ចែកម្ហូបអាហារឲ្យអ្នកដែលស្រេកឃ្លាន ( ម៉ាថាយ ២៥, ៣៥ )

**Feed the Hungry** ( Matthew 25,35 )

# ចែកទឹកឲ្យអ្នកដែលស្រេកទឹក ( ម៉ាថាយ ២៥, ៣៥ )

## Give drink to the Thirsty ( Matthew 25,35 )





# ជូនសម្លៀកបំពាក់ឲ្យអ្នកដែលគ្មាន (ម៉ាថាយ ២៥; ៣៥)

# Clothe the Nake (Matthew 25; 35)





## ទទួលស្វាគមន៍ជនបរទេស (ម៉ាថាយ ២៥; ៣៥)

## Shelter the Homeless (Matthew 25; 35)



# សួរសុខទុក្ខអ្នកជម្ងឺ ( ម៉ាថាយ ២៥; ៣៦ )

# Visit the Sick ( Matthew 25; 36 )





# សួរសុខទុក្ខអស់អ្នកដែលជាប់ឃុំឃាំង (ម៉ាថាយ ២៥; ៣៦)

# Visit the Prisioned (Matthew 25; 36)







# ការបញ្ចុះសាកសព (ម៉ាថាយ ២៥; ៣៦)

# Bury the Dead (Matthew 25; 36)



# ចូរឲ្យដំបូន្មានដល់អស់អ្នកដែលឆ្ងល់អំពីនឿ ( លូកា ២៤,១៣-២៧ )

# Counsel the doubtful ( Luke 24, 13-27 )





# ចូរបង្រៀនដល់មនុស្សដែលមិនស្គាល់ និង មិនព្រមទទួលព្រះយេស៊ូ (ម៉ាថាយ ២៨,១៩-២០)

## Instruct the ignorant (Mathew 28, 19-20)







**ចូរដាស់តឿនអស់អ្នកដែលប្រព្រឹត្តអំពើខុសឆ្គង** (លូកា ២២.៥៤-៦១)

**Admonish the Sinner** ( Luke 22, 54-61 )



# ចូរលើកទឹកចិត្តអស់អ្នកដែលមានទុក្ខព្រួយ និងធ្លាក់ទឹកចិត្ត

( លូកា ៨, ៤០-៤២, ៤៩-៥៦ )

# Comfort the Sorrowful ( Luke 8, 40-42, 49-56 )



# ចូរលើកលែងទោសឲ្យអស់អ្នកដែលបង្ករបួសស្នាមដល់យើង

( កិច្ចការ ៧, ៥៥-៦០ )

# Forgive all injuries ( Acts 7, 55-60 )





# ចូរមានចិត្តអត់ធ្មត់ចំពោះអ្នកដែលធ្វើខុសមកលើយើង ( ម៉ាថាយ ២៦, ២០-២៥ )

# Bear Wrongs Patiently ( Matthew 26, 20-25 )





ចូរអធិដ្ឋានសម្រាប់មនុស្សនៅរស់ និង

វិញ្ញាណក្ខន្ធដែលស្លាប់ (ម៉ាកាបាយទី២ ១២, ៣៨-៤៦)

**Pray for the liring and the dead** ( 2 Maccabees 12, 38-46 )

ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ

Apostolic Vicariate of Phnom Penh

# ឆ្នាំមហាករុណាទិគុណ

# The Year of Jubilee

**2016**

**ខែវិច្ឆិកា**